A Commentary on the Revelation of St. John

សេចក្តីអធិប្បាយពន្យល់នៃកណ្ឌគម្ពីរវិវរណៈ របស់លោក យ៉ូហាន

1968 년

Rev. Yune Sun Park, TH. M., D.D.

Recommender: White Young Jeon

អ្នកបកប្រែ៖ Sreyleak Kohn

Cambodian Reformed Faith Institute

អារម្ភកថា

នៅក្នុងព្រះគម្ពីរសញ្ញាថ្មី កណ្ឌគម្ពីរវិវរណៈរបស់លោកយ៉ូហានជាកណ្ឌគម្ពីរដែលលំបាកមួយ។ ដូច្នេះ យើងនឹងជួបជាមួយនឹងការលំបាកមួយចំនួនដែលអ្នកបកប្រែពីបុរាណមិនបានបកប្រែដោយផ្ទាល់។ នៅក្នុងការបកស្រាយកណ្ឌគម្ពីរដែលលំបាកនេះ ខ្ញុំបានព្យាយាមយ៉ាងខ្លាំងដើម្បីដោះស្រាយវា។ អំពីពាក្យដែលមិនអាចដោះស្រាយបាន នោះខ្ញុំបានទុកវាសិនហើយផ្អាកដោយមានសេចក្តីញាប់ញ័រផង។

សេចក្តីអធិប្បាយពន្យល់នេះត្រូវបានបោះពុម្ពកាលពី13ឆ្នាំមុន ហើយត្រូវបានកែសម្រួលឡើងវិញកាលពីបីឆ្នាំមុន។ នៅរដូវក្តៅនេះ ម្តងទៀត ការបកប្រែនៃជំពូក12 ជំពូក20 និងជំពូក21ត្រូវបានបញ្ចូលបន្ថែមទៀត ជាពិសេសការបកប្រែនៃរាជ្យ1000ឆ្នាំ (មីលឡៃនៀម) នៅក្នុងជំពូក20ដែលត្រូវបានពិនិត្យយ៉ាងលម្អិត។

រចនាសម្ព័ន្ធនៃការអធិប្បាយពន្យល់នេះ រួមមានការបកស្រាយខ្លឹមសារសំខាន់ៗ និងការអធិប្បាយព្រះបន្ទូល។ នៅក្នុងការបកស្រាយរបស់ខ្ញុំ ខ្ញុំបានអនុវត្តយ៉ាងខ្ជាប់ខ្ជួននូវលទ្ធិ Calvinism ព្រោះវាដើរតាមបទគម្ពីរ។ កាលដែលខ្ញុំបានដកស្រង់ឃ្លាខ្លះពីអ្នកទ្រឹស្តីផ្សេងៗគ្នាដែលប្រកាន់ខ្ជាប់នូវទស្សនៈផ្សេងៗគ្នា វាមិនមានន័យថាបានជឿលើប្រព័ន្ធនៃគំនិតទ្រឹស្តីរបស់ពួកគេទេ មានតែទ្រឹស្តីនៃការគិតរបស់ពួកគេប៉ុណ្ណោះដែលមិនមែនបែបគ្រីស្ទានអូស្សូដក់។ ក្នុងការបកស្រាយបទគម្ពីរនេះ ខ្ញុំចង់បញ្ជាក់ពីការពិតដែលថា ការបកស្រាយរបស់ពួកគេគឺត្រឹមត្រូវសម្រាប់យើង។ នៅពេលដែលខ្ញុំបានដកស្រង់យោបល់របស់ពួកគេដោយសារតែខ្ញុំមិនបានពិភាក្សាដោយសង្ខេបអំពីការពិតដែលថាទស្សនៈទ្រឹស្តីរបស់ពួកគេមិនមែនជាបែបគ្រីស្ទានអូស្សូដក់ អ្នកអានគួរតែយល់ពីចំណុចនេះ។ ខ្ញុំមិនទាន់បានពន្យល់នូវចំណុចជាច្រើន តែបានបង្ហាញអត្ថន័យដោយផ្នែកតាមរយៈការអធិប្បាយព្រះបន្ទូលជាច្រើន។ អ្នកអានគួរតែអានផ្នែកនៃការ

អធិប្បាយដោយយកចិត្តទុកដាក់។ ខ្ញុំចង់អរគុណដល់ពួកបរិសុទ្ធសម្រាប់ការគាំទ្រដល់ផ្នែកនីមួយៗដោយព័ន្ធកិច្ចនៃការអធិស្ឋាន។

សរុបមក អ្វីដែលខ្ញុំផ្តល់យោបល់ដល់អ្នកអាន សូមយល់ប្រសិនបើអត្ថន័យណាផ្សេងទៀតត្រូវបានលើកមកដោយខុសអក្ខរាវិរុទ្ធនៅក្នុងការផ្តល់យោបល់នេះ និងប្រសិនបើការបកប្រែរបស់ខ្ញុំខុសក្តី នោះខ្ញុំសូមការអធ្យាស្រ័យ។ អ្វីដែលអ្នកនិពន្ធប្រាថ្នាយ៉ាងស្មោះត្រង់នោះគឺជា សេចក្តីពោរពេញនៃព្រះគុណខាងវិញ្ញាណដែលនឹងមកដល់មនុស្សម្នាក់ៗដែលអាននូវការអធិប្បាយនេះ។

កក្កដា 1968

អ្នកនិពន្ធ

ការផ្តល់យោបល់របស់អ្នកបកប្រែ

លោកគ្រូខាងវិញ្ញាណរបស់ខ្ញុំ លោកបណ្ឌិត យ៉ូន ស៊ុនជាក (1905-1988) ជាគំរូរបស់ខ្ញុំនៅក្នុងជីវិតថ្វាយបង្គំរបស់ខ្ញុំ និងព័ន្ធកិច្ចរបស់ខ្ញុំ និងជីវិតខាងព័ន្ធកិច្ចផង ពីព្រោះព្រះបាននាំឱ្យខ្ញុំទៅជួបគាត់កំឡុងពេលនៃការសិក្សានៅសាលាគម្ពីររបស់ខ្ញុំ ដែលជាមហាវិទ្យាល័យព្រះគម្ពីរចុងស៊ីន (BA) និងសាលាគម្ពីរហាប់ដុងនៅប្រទេសកូរ៉េខាងត្បូង (M.Div.) ហើយសាលាគម្ពីរវេសមីនស្ទើ (D. Min 1906)។ ពេលនេះ នៅក្នុងកំឡុងពេល 18 ឆ្នាំ ជាពេលធ្វើព័ន្ធកិច្ចនៅប្រទេសកម្ពុជា ខ្ញុំសូមអធិស្ឋានឱ្យជំនឿរបស់ ចុង អាំ និងភ្លើងនៃការផ្លាស់ប្រែរបស់គាត់នៅក្នុងព័ន្ធកិច្ចនឹងត្រូវបានដាំឡើងនៅក្នុងព័ន្ធកិច្ចប្រទេសកម្ពុជា ពីព្រោះខ្ញុំឃើញពីស្ថានភាពដែលច្របូកច្របល់នៃក្រុមជំនុំកម្ពុជា ហើយខ្ញុំអះអាងថា គេត្រូវការចិត្តដែលស្មោះត្រង់និងខ្នះខ្នែងរបស់គាត់ទៅកាន់ព្រះគម្ពីរ។

ដូច្នេះ តាមបំណងប្រាថ្នាខាងវិញ្ញាណនៃចិត្តរបស់ខ្ញុំ ដំបូងខ្ញុំចង់បកប្រែសៀវភៅនៃការបង្រៀនសាសនៈវិទ្យាសំខាន់ៗរបស់គាត់ សាសនៈតាមបទគម្ពីរ ទៅជាភាសាអង់គ្លេស ហើយខ្ញុំក៏បកប្រែនូវការអធិប្បាយចំនួន 68 ទៀតនៅក្នុងការបកស្រាយពន្យល់នៃកណ្ឌគម្ពីរវិវរណៈទៅជាភាសាអង់គ្លេស ដើម្បីនឹងត្រៀមសម្រាប់ការបកប្រែជាភាសាខ្មែរសម្រាប់ក្រុមជំនុំកម្ពុជាដោយក្រុមអ្នកបកប្រែ។

រួចមកខ្ញុំបានឃើញពីចិត្តដែលស្មោះត្រង់របស់គាត់ និងបំណងប្រាថ្នារបស់គាត់ក្នុងការប្រកាសពីព្រះគម្ពីរឱ្យអស់ពីចិត្ត។ ជាពិសេស ខ្ញុំដឹងថាគាត់មិនបានប្រកាសព្រះបន្ទូលដើម្បីនឹងសរសេរការបកស្រាយពន្យល់ទេ តែគាត់សរសេរការបកស្រាយពន្យល់ដើម្បីនឹងអធិប្បាយសេចក្តីពិតនៃព្រះគម្ពីរវិញ។ ដូច្នេះ នៅពេលយើងអានការបក

ស្រាយពន្យល់របស់គាត់ និងការអធិប្បាយរបស់គាត់ដោយយកចិត្តទុកដាក់ នោះយើងអាចដឹងពីសេចក្តីពិតដែលបើកបង្ហាញតាមរយៈការយល់ដឹងរបស់គាត់ពីបទគម្ពីរ។ ហើយខ្ញុំបានរកឃើញចម្លើយរបស់គាត់សម្រាប់សំណួរដ៏វែងអន្លាយរបស់ខ្ញុំថា គាត់បានដើរតាមទស្សនៈនៃការយាងមករបស់ព្រះគ្រីស្ទមុនរាជមួយពាន់ឆ្នាំ (premillennialism)។ ហេតុផលនោះពិតជាសាមញ្ញណាស់។ ដោយសារគាត់ស្រឡាញ់សេចក្តីពិតនៅក្នុងព្រះគម្ពីរដោយស្មោះត្រង់។ ខ្ញុំគិតថា គាត់អាចយកឈ្នះសេចក្តីល្បួងនៃពួកកាល់វីនជ្រុលនិយមនៅក្នុងជីវិតគ្រីស្ទានពិត។

ព័ន្ធកិច្ចខាងអក្សរសាស្ត្ររបស់ខ្ញុំនៅក្នុងបេសកកម្មប្រទេសកម្ពុជាបង្ហាញផលផ្លែនៃគម្រោងការដំបូងដោយការបោះពុម្ពនូវការបកស្រាយពន្យល់តាមរយៈការលះបង់ប៉ុន្មានឆ្នាំមក។ ខ្ញុំរីករាយដែលក្រុមជំនុំកម្ពុជាមានឱកាសនឹងជួបសេចក្តីស្រឡាញ់ស្មោះត្រង់របស់គាត់លើសេចក្តីពិត គឺជាព្រះគម្ពីរ។

ព័ន្ធកិច្ច CEMF ដែលខ្ញុំបានបម្រើអស់រយៈពេល 18 ឆ្នាំ មានគម្រោងនឹងចែកចាយការបង្រៀនរបស់គាត់នៅក្នុងក្រុមជំនុំប្រទេសកម្ពុជា។ ដូច្នេះ ខ្ញុំមានគម្រោងខ្លះនឹងចែករំលែកសេចក្តីពីដ៏មានតម្លៃនៃស្ថានសួគ៌របស់គាត់ជាមួយក្រុមជំនុំកម្ពុជាតាមរយៈសិក្ខសាលានៃជំនឿរបស់ ចុង អាំ វិទ្យាស្ថានសាលាគម្ពីរកាល់វីន និង សិក្ខាសាលាការលូតលាស់នៃធម្មយាត្រារបស់ពួកបរិសុទ្ធ ជាដើម។

សូមឱ្យព្រះគុណរបស់ព្រះបាននៅជាប់ជាមួយអ្នកអានទាំងអស់ឱ្យបានចូលទៅក្នុងការយល់ដឹងពីសេចក្តីពិត និងការថ្វាយបង្គំដ៏ខ្ពះខ្ពែងនៃពិភពរបស់លោកចុង អាំ តាមរយៈការបកស្រាយពន្យល់ និងការអធិប្បាយផង។

នៅក្នុងព្រះគ្រីស្ទ

លោកបណ្ឌិត វ៉ាយ យ៉ុងជុន ប្រធាន CRFI

លំដាប់នៃការបកស្រាយពន្យល់នៃកណ្ឌគម្ពីរវិវរណៈរបស់យ៉ូហាន

អារម្ភកថា

លំដាប់នៃការអធិប្បាយ

សេចក្តីផ្តើម

1. សិទ្ធិអំណាចនៃកណ្ឌគម្ពីរសញ្ញាថ្មី
2. ប្រវត្តិសាស្ត្រដែលបានបញ្ជូនមកនៃកណ្ឌគម្ពីរសញ្ញាថ្មី
3. អ្នកនិពន្ធនៃកណ្ឌគម្ពីរវិវរណៈរបស់លោកយ៉ូហាន
4. ទីកន្លែងនិងពេលវេលានៃកណ្ឌគម្ពីរវិវរណៈរបស់លោកយ៉ូហាន
5. វិធីសាស្ត្រនៃការបកស្រាយបទគម្ពីរ
6. វិធីសាស្ត្រនៃកណ្ឌគម្ពីរវិវរណៈរបស់លោកយ៉ូហាន
7. លេខនិងនិមិត្តសញ្ញានៃកណ្ឌគម្ពីរវិវរណៈរបស់លោកយ៉ូហាន
8. ភាពមិនអាចទៅរួចនៃការបកស្រាយក្នុងការរាប់ថ្ងៃនៃការយាងមកលើកទីពីរ
9. លក្ខណៈនៃ ការដែលអាចហៅបានថា អក្សរសាស្ត្រនៃកណ្ឌគម្ពីរវិវរណៈ
10. សេចក្តីសង្ខេបត្រួសៗនៃទ្រឹស្តីនៃគ្រាចុងក្រោយដែលដាក់នៅកន្លែងផ្សេងទៀតក្នុងបទគម្ពីរ
11. ការត្រួតពិនិត្យនៃខ្លឹមសារនៃកណ្ឌគម្ពីរវិវរណៈរបស់លោកយ៉ូហាន
    - ឯកសារយោង

ការបកស្រាយពន្យល់

ជំពូក 1

ជំពូក 2

ជំពូក 3

ជំពូក 4

ជំពូក 5

ជំពូក 6

ជំពូក 7

ជំពូក 8

ជំពូក 9

ជំពូក 10

ជំពូក 11

ជំពូក 12

ជំពូក 13

ជំពូក 14

ជំពូក 15

ជំពូក 16

ជំពូក 17

ជំពូក 18

ជំពូក 19

ជំពូក 20

ជំពូក 21

ជំពូក 22

លំដាប់នៃការអធិប្បាយ

ការអធិប្បាយទី 1 ពេលវេលាជិតមកដល់ហើយ (វិវរណៈ 1:1-3)
ការអធិប្បាយទី 2 អ្នកដែលចូលរួមក្នុងសេចក្តីទុកលំបាករបស់ព្រះយេស៊ូវនិងការស៊ូទ្រាំរបស់ទ្រង់ និងនគររបស់ទ្រង់ (វិវរណៈ 1:1-8)
ការអធិប្បាយទី 3 សភាពនៃការបើកសម្តែងរបស់សាវកយ៉ូហាន ជាអ្នកនិពន្ធនៃវិវរណៈដែលបានទទួលមក (វិវរណៈ 1:10)
ការអធិប្បាយទី 4 សេចក្តីស្រឡាញ់ដំបូង (វិវរណៈ 2:4, 9)
ការអធិប្បាយទី 5 ចំណុចខ្សោយនិងចំណុចល្អនៃក្រុមជំនុំអេភេសូរ (វិវរណៈ 2:1-7)
ការអធិប្បាយទី 6 ចូរស្មោះត្រង់រហូតដល់ស្លាប់ (វិវរណៈ 2:8-10) (1)
ការអធិប្បាយទី 7 ចូរស្មោះត្រង់រហូតដល់ស្លាប់ (2:8-10) (2)
ការអធិប្បាយទី 8 ចូរធ្វើឱ្យបានគ្រប់លក្ខណ៍នៅចំពោះព្រះ (វិវរណៈ 3:1-6)
ការអធិប្បាយទី 9 ក្រុមជំនុំភីឡាដិលភា (វិវរណៈ 3:1-11)
ការអធិប្បាយទី 10 ក្រុមជំនុំឡៅឌីសេ (វិវរណៈ 3:14-22)
ការអធិប្បាយទី 11 អំពីការប្រែចិត្ត (វិវរណៈ 3:19-22)
ការអធិប្បាយទី 12 ស្ថានសួគ៌ (វិវរណៈ 4:1-11)
ការអធិប្បាយទី 13 លំដាប់លំដោយនៃស្ថានសួគ៌ (វិវរណៈ 4:1-11)
ការអធិប្បាយទី 14 ចូរសរសើរភាពបរិសុទ្ធរបស់ព្រះ (វិវរណៈ 4:8)
ការអធិប្បាយទី 15 ការសរសើរនៃជីវិត4 (វិវរណៈ 4:8-11)
ការអធិប្បាយទី 16 អំពីការបង្កបង្កើត (1) (វិវរណៈ 4:11)
ការអធិប្បាយទី 17 អំពីការបង្កបង្កើត (2) (វិវរណៈ 4:11)
ការអធិប្បាយទី 18 ការសរសើរដំកើងពីរបៃប (វិវរណៈ 4:8-11)
ការអធិប្បាយទី 19 មានតែព្រះគ្រីស្ទទេដែលជាអង្គដែលផ្សះផ្សា (វិវរណៈ 5:1-14)

ការអធិប្បាយទី 20 កិច្ចការនៃឫសរបស់ដាវីឌ (វិវរណៈ 5:5,6) (យោងតាម អេសាយ 53:2)
ការអធិប្បាយទី 21 ការប្រកាសដំណឹងល្អនិងសេចក្តីវេទនា (វិវរណៈ 6:1-11)
ការអធិប្បាយទី 22 ព្រះបន្ទូលរបស់ព្រះជាម្ចាស់ និងស្ថានសួគ៌ (វិវរណៈ 6:9)
ការអធិប្បាយទី 23 សេចក្តីអង្វរករបស់ពួកបរិសុទ្ធត្រូវគេសម្លាប់ និងការកំសាន្តរបស់ពួកគេ (វិវរណៈ 6:9-11)
ការអធិប្បាយទី 24 ហេតុអ្វីបានជាពួកគេត្រូវគេធ្វើឃាត? (វិវរណៈ 6:9)
ការអធិប្បាយទី 25 ចលនានៃដំណឹងល្អ និងគ្រោះជាទូទៅ (វិវរណៈ 6:3-11)
ការអធិប្បាយទី 26 ជីវិតដែលរងចាំព្រះដែលទ្រង់មិនកាត់ទោសភ្លាមៗទេ (វិវរណៈ 6:9-11)
ការអធិប្បាយទី 27 អ្វីដែលយើងអាចស្តាប់ និងអ្វីដែលយើងអាចឃើញ (វិវរណៈ 7:1-12)
ការអធិប្បាយទី 28 អំពីសេចក្តីសង្គ្រោះ (វិវរណៈ 7:1-17)
ការអធិប្បាយទី 29 ចំនួនមនុស្សដែលត្រូវបានបោះត្រា (វិវរណៈ 7:4)
ការអធិប្បាយទី 30 ឈាមរបស់កូនចៀម (វិវរណៈ 7:14-17)
ការអធិប្បាយទី 31 ការអធិស្ឋានដែលត្រូវបានលើកឡើងទៅកាន់ព្រះ (ការអធិស្ឋានដែលព្រះទ្រង់ឆ្លើយតប) (វិវរណៈ 8:1-5)
ការអធិប្បាយទី 32 ការអធិស្ឋានដែលត្រូវបានលើកឡើងនៅចំពោះព្រះ (វិវរណៈ 8:3-5)
ការអធិប្បាយទី 33 ការរងទុក្ខនៃអ្នកដែលមិនបានធីសាំង
ការអធិប្បាយទី 34 ភាពផ្អែមល្ហែមនៃព្រះបន្ទូលរបស់ព្រះ (វិវរណៈ 10:9, 10)
ការអធិប្បាយទី 35 សាក្សីពីរនាក់
ការអធិប្បាយទី 36 អំពីការផ្សាយដំណឹងល្អដែលគួរឱ្យខ្លាច និងរន្ធត់

ការអធិប្បាយទី 37 ចូរចងចាំពីពេលវេលាដែលពិភពលោកជារបស់ព្រះជាម្ចាស់ (វិវរ
ណៈ 11:15)
ការអធិប្បាយទី 38 យកឈ្នះអារក្ស (វិវរណៈ 12:7-12)
ការអធិប្បាយទី 39 ឈាមនៃកូនចៀម (វិវរណៈ 12:11)
ការអធិប្បាយទី 40 ម្នាក់ដែលប្រកាសដំណឹងល្អត្រូវគេបៀតបៀននៅក្នុងលោកិយ (វិវរ
ណៈ 12:11)
ការអធិប្បាយទី 41 អ្នកដែលទាស់ប្រឆាំងនឹងព្រះគ្រីស្ទ (វិវរណៈ 13:1-3)
ការអធិប្បាយទី 42 ហោរាក្លែងក្លាយ (វិវរណៈ 13:11)
ការអធិប្បាយទី 43 អំពីម្នាក់ដែលថ្វាយបង្គំរូបព្រះក្លែងក្លាយ (13:14)
ការអធិប្បាយទី 44 ចូរគិតពីមួយអង្គដែលនៅស្ថានសួគ៌ (14:1-3)
ការអធិប្បាយទី 45 ព្រះគ្រីស្ទ និងពួក 144000 ែដលឈរនៅលើភ្នំស៊ីយ៉ូន (14:1-5)
ការអធិប្បាយទី 46 ដំណឹងល្អដ៏អស់កល្បជានិច្ច (14:6,7)
ការអធិប្បាយទី 47 ភាពចាំបាច់នៃការអត់ធ្មត់ (14:12)
ការអធិប្បាយទី 48 ព្រះពររបស់អ្នកដែលបានស្លាប់នៅក្នុងព្រះអម្ចាស់ (វិវរណៈ
14:13) (1)
ការអធិប្បាយទី 49 ព្រះពរនៃម្នាក់ដែលបានស្លាប់នៅក្នុងព្រះអម្ចាស់ (វិវរណៈ 14:13)
(2) ការ
អធិប្បាយទី 50 ព្រះដែលមានគ្រប់ចេស្តា (វិវរណៈ 15:3)
ការអធិប្បាយទី 51 ពីការដែលមិនប្រែចិត្ត (វិវរណៈ 16:1-21 ជាពិសេសយោងតាម
9:11, 21)
ការអធិប្បាយទី 52 សង្គ្រាមនៃអាម៉ាកេដុន (វិវរណៈ 16:12-16)
ការអធិប្បាយទី 53 បាប៊ីឡូន (17:1-5)
ការអធិប្បាយទី 54 ព្រះទ្រង់ចងចាំអំពើបាបនៃមនុស្សមានបាប (18:5-24)
ការអធិប្បាយទី 55 អំពើបាបរបស់បាប៊ីឡូន

ការអធិប្បាយទី 56 មង្គលការនៃកូនចៀម (វិវរណៈ 19:6-8)
ការអធិប្បាយទី 57 អំពីការរស់ឡើងវិញនៃរូបកាយ (វិវរណៈ 20:4-6)
ការអធិប្បាយទី 58 ភាពពិសេសនៃការរស់ឡើងវិណនៃរូបកាយ (វិវរណៈ 20:4-6)
ការអធិប្បាយទី 59 ការវិនិច្ឆ័យទោសចុងក្រោយ (វិវរណៈ 20:11-15)
ការអធិប្បាយទី 60 ម្នាក់ដែលគួរឱ្យកោតខ្លាច
ការអធិប្បាយទី 61 អំពើបាបដែលចូលរួមនៅក្នុងភ្លើងស្ពាន់ធ័រ (21:8)
ការអធិប្បាយទី 62 មេកុហក (21:8 (1)
ការអធិប្បាយទី 63 មេកុហក (21:8 (2)
ការអធិប្បាយទី 64 បឹងភ្លើងនិងស្ពាន់ធ័រ (21:8)
ការអធិប្បាយទី 65 ពិភាពលោកដែលអស់កល្បជានិច្ច
ការអធិប្បាយទី 66 ទន្លេជីវិតនៅក្នុងពិភពលោកដែលនឹងមកដល់ (22:1,17)
ការអធិប្បាយទី 67 សិទ្ធិអំណាចនៃព្រះគម្ពីរ (22:18, 19)
ការអធិប្បាយទី 68 ការអធិប្បាយនៃព្រះអម្ចាស់ (វិវរណៈ 22:18-21)

ការបកស្រាយពន្យល់នៃកណ្ឌគម្ពីរវិវរណៈរបស់យ៉ូហាន

សេចក្តីផ្តើម

ក្នុងការបកស្រាយបញ្ហានៃសិទ្ធិអំណាចនៃព្រះគម្ពីរសញ្ញាថ្មី និងប្រវត្តិសាស្ត្រដែលបានផ្សេរនេះ ខ្ញុំបាននិយាយហើយថា ឱ្យដកស្រង់ផ្នែកខ្លះចេញពីអត្ថបទរបស់លោក Stonehouse និង Skilton ពីសៀវភៅ “The Infallible Bible” (ព្រះគម្ពីរដែលគ្មានកំហុសសោះ)។

1. សិទ្ធិអំណាចនៃព្រះគម្ពីរសញ្ញាថ្មី

   វាមានន័យថា យើងមើលទៅសៀវភៅទាំង 27 កណ្ឌរបស់គម្ពីរសញ្ញាថ្មី ថាជាព្រះបន្ទូលរបស់ព្រះ ហើយវាត្រូវបានបញ្ចប់ជាកណ្ឌគម្ពីរចំនួន 27 ហើយយើងក៏ដឹងការពិតដែលបំពេញកណ្ឌគម្ពីរវិវរណៈ។
   អ្នកខ្លះយល់ច្រលំពីសិទ្ធិអំណាចនៃព្រះគម្ពីរសញ្ញាថ្មី (1) ពួកគេគិតថា កណ្ឌគម្ពីរពិតជាបរិសុទ្ធនៅផ្នែកធំ ហើយពួកគេទទួលយកគម្ពីរសញ្ញាថ្មីថាជាព្រះបន្ទូលរបស់ព្រះទាំងស្រុងនិងដោយផ្នែកផងដែរ។ (2) ព្រះគម្ពីរមិនមែនជាព្រះបន្ទូលរបស់ព្រះផ្ទាល់ទេ តែមានតែទំនាក់ទំនងក្នុងការបិតការបើកសម្តែងរបស់ព្រះ។

ប៉ុន្តែទស្សនៈដែលសមរម្យពីសិទ្ធិអំណាចនៃគម្ពីរសញ្ញាថ្មីគឺជា ការពិតដែលគម្ពីរសញ្ញាថ្មីជាព្រះបន្ទូលផ្ទាល់របស់ព្រះ និងជាការបើកសម្តែងទាំងស្រុងនិងជាផ្នែកផង។

2. ភស្តុតាងដែលគម្ពីរសញ្ញាថ្មីជាព្រះបន្ទូលរបស់ព្រះ

(1) ដ្បិតគម្ពីរសញ្ញាថ្មីជាការសម្រេចបំពេញនៃគម្ពីរសញ្ញាចាស់ ហើយវាជាព្រះបន្ទូលរបស់ព្រះ។ ប្រជារាស្ត្ររបស់ព្រះបានទទួលស្គាល់ថាគម្ពីរសញ្ញាថ្មីជាការសម្រេចបំពេញនៃគម្ពីរសញ្ញាចាស់។ ដ្បិតគម្ពីរសញ្ញាចាស់ជាព្រះបន្ទូលរបស់ព្រះ នោះគម្ពីរសញ្ញាថ្មីជាធម្មតាក៏ជាព្រះបន្ទូលរបស់ព្រះផងដែរ។

(2) ទីបន្ទាល់នៃគម្ពីរសញ្ញាថ្មីផ្ទាល់

[1] គម្ពីរសញ្ញាថ្មីនិយាយថា ព្រះយេស៊ូវជាព្រះ។ ដូច្នេះ ការដែលព្រះបន្ទូលរបស់ព្រះយេស៊ូវ និងកិច្ចការរបស់ទ្រង់សុទ្ធតែជាព្រះបន្ទូលរបស់ព្រះផ្ទាល់ នោះត្រូវបានប្រាប់ឱ្យដឹងហើយ។

[2] មិនតែប៉ុណ្ណោះទេ គម្ពីរសញ្ញាថ្មីនិយាយការពិតថា ពួកសាវកជាទូតពិសេសដែលប្រកាសព្រះបន្ទូលរបស់ព្រះ។ ដូច្នេះ ការកត់ត្រារបស់ពួកគេជាព្រះបន្ទូលរបស់ព្រះ។ ពួកសាវកមិនមានសិទ្ធិអំណាចដែលកសាងឡើងដោយខ្លួនពួកគេទេ តែមានជីវៈប្រវត្តិមកពីព្រះគ្រីស្ទវិញ។ ដូច្នេះ ការបង្រៀនរបស់ពួកគេមិនមែនជាអ្វីក្រៅពីជាការបង្រៀនរបស់ព្រះអម្ចាស់នោះទេ។ (កាឡាទី ជំពូក 1, 1កូរិនថូស 14:37, 7:10, 2ថែស្សាឡូនិច 3:14)

(3) ទីបន្ទាល់របស់ក្រុមជំនុំ

[1] សៀវភៅទីមួយរបស់ក្លេមិន។ វាជាសំបុត្រដែលលោកក្លេមិនពីក្រុងរ៉ូមផ្ញើទៅកាន់ក្រុមជំនុំកូរិនថូស (ប្រហែល គ.ស 95)។ គាត់បានដកស្រង់គម្ពីរសញ្ញាថ្មីប្រហែល 100 ដង ហើយគិតថាវាមានសិទ្ធិអំណាចស្មើគ្នានឹងគម្ពីរសញ្ញាចាស់។ គាត់ទទួលស្គាល់ថា គម្ពីរសញ្ញាចាស់ជាព្រះបន្ទូលរបស់ព្រះ

(ជំពូក 45) ហើយក៏ទទួលស្គាល់ថា សិទ្ធិអំណាចរបស់ព្រះគ្រីស្ទ និងការផ្សាយដំណឹងល្អរបស់ពួកសាវក គឺដូចគ្នានឹងសិទ្ធិអំណាចរបស់គម្ពីរសញ្ញាចាស់ (4:1, 2, 13:1), 42:1, 4, និង 46:7)។ គាត់និយាយថា “យើងបានទទួលដំណឹងល្អពីព្រះយេស៊ូវគ្រីស្ទ” (42:1) ហើយគាត់និយាយទៀតថា “ចូរបើកសំបុត្ររបស់ប៉ុល តើគាត់បាននិយាយអ្វីមកកាន់អ្នក? តាមការបើកសម្តែងដែលគាត់បានបង្រៀននោះ”។

[2] 20 ឆ្នាំក្រោយមក ចាប់តាំងពីសៀវភៅទីមួយរបស់ក្លេមិនចេញមក លោក អ៊ីកណាធាស ដែលជាប៊ីស្សពនៃអាន់ទីយ៉ូល បានសរសេរសំបុត្រចំនួន7 តាមផ្លូវទៅកាន់ក្រុងរ៉ូមដោយកាត់តាមអាស៊ីភាគតិច។ ក្នុងចំណោមសំបុត្រទាំងនោះ គាត់បានទទួលស្គាល់ការពិតដែលថា ព្រះបន្ទូលនៃគម្ពីរសញ្ញាថ្មីមានសិទ្ធិអំណាចដូចគ្នានឹងគម្ពីរសញ្ញាចាស់។ គាត់ទទួលស្គាល់ថាការបង្គាប់និងមេរៀនរបស់ពួកសាវកសុទ្ធតែជាព្រះបន្ទូលរបស់ព្រះជាម្ចាស់។ (សរសេរដោយលោក Ignatius, Bil សំបុត្រ 5:1, 2, Manecian សំបុត្រ 13:1, Trarian សំបុត្រ 12:2 Eph សំបុត្រ 11:2) គាត់និយាយថា “ខ្ញុំក៏បង្គាប់ដល់អ្នកដូចជាពេត្រុសនិងប៉ុលដែរ”។ (Rom សំបុត្រ 4:3) គាត់ចាត់ទុកកណ្ឌដំណឹងល្អជាកណ្ឌគម្ពីរដែលមានសិទ្ធិអំណាចជាងគម្ពីរសញ្ញាចាស់ផង។ (សំបុត្រអេភេសូរ ជំពូក12)។

[3] ជាភៀស ជាបុរសម្នាក់មកពីអាស៊ីភាគតិច គាត់បាននិយាយថា កណ្ឌគម្ពីរដំណឹងល្អជាការបើកសម្តែងរបស់ព្រះ។

[4] លោក ចាស្ទីន ម៉ាធើ បានសរសេរសៀវភៅរបស់គាត់នៅ គ.ស 160 ហើយនិយាយថា ព្រះគ្រីស្ទជាក្រិត្យវិន័យថ្មី និងជាការតាំងសញ្ញាថ្មី។

1. ប្រវត្តិសាស្ត្រដែលត្រូវបានផ្លាស់មកនៃគម្ពីរសញ្ញាថ្មី

ចំនួននៃក្រាំងគម្ពីរសញ្ញាថ្មីមានច្រើន ដែលពួកវាត្រូវបានចម្លងមិនយូរប៉ុន្មានបន្ទាប់ពីឯកសារដើម។ ក្រាំងរបស់ Chester Beatty Papyri ត្រូវបានកត់ត្រានៅស.វ ទី3 ជាក្រាំងដែលចាស់ជាងគេបំផុតនៃ Papirus ទៅ យ៉ូហាន 18:31-33, 37, 38 ត្រូវចម្លងនៅស.វ ទី 4។ ចំនួនក្រាំងប្រហែលចំនួន 4000។ ប៉ុន្តែបើយើងបន្ថែមការបកប្រែប្រហែលជាកើនដល់ 14000 ច្បាប់។

មានក្រាំង វ៉ុលហ្គេត ជាភាសាឡាតាំងគឺមាន 8000 ច្បាប់។ ក្រាំងនៃជាភាសាបុរាណផ្សេងទៀតយ៉ាងហោចណាស់ 1000 ច្បាប់។ រួចមក ខ្លឹមសារដែលក្រាំងជាច្រើនធ្វើបន្ទាល់ត្រូវបានដកស្រង់ពិត។ លោកបណ្ឌិត អេសរ៉ា អាបត បាននិយាយថា “នៅក្នុងចំណុចខុសគ្នាជាច្រើននៃក្រាំងនីមួយនៃគម្ពីរសញ្ញាថ្មី គឺ 19/20 ដែលមិនមានចំណុចខុសគ្នានឹងពីក្រាំងផ្សេងទៀត។ នៅក្នុងចំណោមការដែលនៅសល់ គឺត្រឹមតែ 19/20 ទល់នឹង 1/20 ដែលជាចំណុចខុស។ ពីព្រោះប្រសិនបើយើងទទួលយកពួកវាឬមិនទទួល អត្ថន័យនៃខ្លឹមសារមិនត្រូវបានផ្លាស់ប្តូរផ្សេងឡើយ។ “(Warfield, An Introduction to The Textual Criticism of the New Testament, p 12)។ លោក Warfield បាននិយាយម្តងទៀតដូចតទៅនេះថា “ខ្លឹមសារទាំងអស់នៃក្រាំងគម្ពីរសញ្ញាថ្មីមិនមានចំណុចខុសគ្នាទេ ហើយស្ទើតែគ្មានចំណុចខុសគ្នាសោះត្រូវបានផ្ទេរមកដល់យើង។ បើទោះជាខ្លះមានចំណុចនៃការចម្លងដ៏មិនល្អក៏ដោយ ដ្បិតដោយសារភាគច្រើនមានក្រាំងជាច្រើន អត្ថបទពិតនៃអ្នកសរសេរដ៏បរិសុទ្ធត្រូវបានបង្ហាញយ៉ាងច្បាស់ បែបគោលលិទ្ធិ និងបែបសីលធម៌ នឹងមិនមកដល់ការសរុបសេចក្តីដែលខុសឡើយ។ “(សៀវភៅដូចគ្នា ទំព័រ 14) ហើយ លោក Kenyon ដែល

ជាអ្នកប្រាជ្ញល្បីនៃឯកសារដែលនិយាយថា “អ្នកជឿសាសនាគ្រឹស្តយកបទគម្ពីរទាំងអស់ដាក់នៅដៃរបស់គេ ហើយអាចនិយាយថា នោះជាព្រះបន្ទូលពិតរបស់ព្រះ ដែលត្រូវបានផ្ទេរមកដោយមិនមានបាត់សេចក្តីពិតសោះ ដែលគេនិយាយដោយគ្មានការភ័យខ្លាចនិងគ្មានការស្ទាក់ស្ទើឡើយ។” (Our Scripture and ancient manuscripts” p 23)

2. គឺដូចជានៅក្នុងមូលដ្ឋានដែលមានភស្តុតាងដូចគ្នានៃឯកសារជាច្រើន នោះគម្ពីរក្រិកក៏ត្រូវបានបោះពុម្ពចែកចាយ ដែលយើងគិតពីការបោះពុម្ពរបស់វាជាទូទៅបីដង។

    1) ពេលទទួលបានអត្ថបទនោះ។ អត្ថបទដែលទទួលបានត្រូវបានបោះពុម្ពដោយStephanus នៅឆ្នាំ 1654។ អត្ថបទដែលទទួលបានសុំទោសពីចំណុចដែល គាត់មិនបានលើកពីឯកសារជាច្រើន តែយើងមិនអាចនិយាយថា ខ្លឹមសារទាំងនោះមានចំណុចខុសនោះទេ។ ដូចជាបាននិយាយខាងលើ អត្ថបទនៃសញ្ញាថ្មីត្រូវបានផ្ទេរមកយើងដោយគ្មានចំណុចខុសគ្នាសោះនៅក្នុងឯកសារនោះ។ អត្ថបទដែលទទួលបាននេះជាគ្រឹះនៃ ការបកប្រែនៃគម្ពីរ King James Version ដែលបានសម្រេចនៅឆ្នាំ 1611)។
    2) លើកទីពីរជាថ្ងៃដែលចាប់ផ្តើមនៃការរិះគន់លើឯកសារ
    3) លើកទីបីគឺជាថ្ងៃដែលការរិះគន់ឯកសារបានចាប់ផ្តើម ក្នុងពេលនេះ មានឯកសារជាច្រើនត្រូវបានរកឃើញ។ អ្នកវិទូល្បីនៃឯកសារមានពីរនាក់គឺ លោក Westcott និង Holt។ វិទ្យាសាស្ត្រនៃឯកសារត្រូវបានអភិវឌ្ឍតាមរយៈពួកគេ ហើយវាត្រូវបានជ្រើសរើសជាគោលការណ៍រហូតមកដល់សព្វថ្ងៃនេះ។ គម្ពីរ

ក្រិកដែលត្រូវដែលត្រូវបោះពុម្ពដោយមនុស្សពីរនាក់ គឺវាមានសេចក្តីពិតនៃអត្ថបទដើម។ “សព្វថ្ងៃនេះការបកប្រែភាសាអង់គ្លេសដែលត្រូវបានកែក៏ត្រូវបានបោះពុម្ពផ្សាយ។ ការបកប្រែនេះត្រូវផ្ទេរ នៅថ្ងៃនេះ ការបកប្រែជាអង់គ្លេសត្រូវបានបោះពុម្ពផ្សាយ។ ការបកប្រែនេះត្រូវបានគេលើកឡើងជាច្រើននៃកំណែកែសម្រួលរបស់អង់គ្លេសនៅក្នុងមូលដ្ឋាននៃបទគម្ពីរភាសាក្រិច។ ការបកប្រែជាភាសាកូរ៉េរបស់យើងត្រូវបានបកប្រែដោយអ្នកផ្សាយដំណឹងល្អនៅឆ្នាំ 1887 ។ សារព័ត៌មានដំបូងនៃគម្ពីរសញ្ញាថ្មីបានចេញនៅឆ្នាំ 1900 ការបោះពុម្ពឡើងវិញត្រូវបានបោះពុម្ពនៅឆ្នាំ 1904។ ការបោះពុម្ពលើកទីបីបានចេញមក ហើយនៅឆ្នាំ 1920 សូម្បីតែគម្ពីរសញ្ញាចាស់ក៏ត្រូវបានបកប្រែទាំងស្រុង។ ហើយគម្ពីរសញ្ញាចាស់នៃការបកប្រែដែល ត្រូវបានកែដំរូវនៅខែឧសភា ឆ្នាំ 1937 ហើយគម្ពីរសញ្ញាថ្មីត្រូវបានកែសម្រួលនៅខែមិថុនា ឆ្នាំ 1937។

I. អ្នកនិពន្ធនៃកណ្ឌគម្ពីរវិវរណៈរបស់យ៉ូហាន

អត្ថបទនិយាយបីបួនដងថាយ៉ូហានជាអ្នកនិពន្ធនៃកណ្ឌគម្ពីរនេះ។ (1:1, 4, និង 18; 22:8) ពួកគេសង្ស័យពីការដែលថាកណ្ឌគម្ពីរនេះជាសិទ្ធិអំណាចរបស់យ៉ូហានដូចតទៅនេះថា៖

1) លោក J. Wellhausen បានទាយថា យ៉ូហាន 1:1-3 និង 22:18, 19 មិនមែនដោយយសារយ៉ូហានទេ តែអ្នកផ្សេងទៀតបានសរសេរវា ហើយបានបង្ខូចវានៅក្នុងអត្ថបទ។ តែ លោក R. H. Charles ប្រឆាំងនឹងទ្រឹស្តីនេះដូចតទៅថា៖ គឺថា

1:1-3 មិនមែនជាជំពូក1នៃព្រះពរទាំងប្រាំពីរទេ (1:3, 14:13, 16:15, 19:9, 20:6, 22:7, 14) ហើយ វាក៏ត្រូវបានសរសេរដោយបុរសម្នាក់ដែលសរសេរជំពូកនៃព្រះពរទាំងប្រាំពីរយ៉ាងខ្លាំងក្លា។

1) ហេតុផលមួយដែលអ្នកខ្លះជំទាស់នឹងការអះអាងថា កណ្ឌគម្ពីរត្រូវបានសរសេរដោយសាវកយ៉ូហានគឺ ជាការពិតថា កណ្ឌគម្ពីរនេះមិនបាននិយាយថា គាត់ជាសាវក តែជាហោរាវិញ។ (10:11) តែវាត្រូវបានគិតថាគេមិនបានពិនិត្យនូវការពិតឱ្យបានត្រឹមត្រូវទេ។

   វិវរណៈជាកណ្ឌគម្ពីរនៃទំនាយ (1:3) វាសមហេតុផលដែលអ្នកនិពន្ធនៃកណ្ឌគម្ពីរនៃទំនាយមិនត្រូវបានហៅថាសាវក តែហៅថាជាហោរាវិញ។

2) ហេតុផលមួយទៀតដែលប្រឆាំងនឹងការពិតដែល កណ្ឌគម្ពីរត្រូវបានសរសេរដោយសាវកយ៉ូហាន នោះគឺជាបែបអក្សរសាស្ត្រនៃកណ្ឌគម្ពីរដែលវាខុសពីការសរសេរដំណឹងល្អ (ដំណឹងល្អយ៉ូហាន)។ ប៉ុន្តែនេះក៏មិនមែនជាហេតុផលដែរ។ យើងទាយថា ការបង្ហាញរបស់គាត់ថា គាត់ត្រូវបានបង្ហាញនៅក្នុងការទទួលការបើកសម្តែងពិសេសចេញពីទ្វារបើកនោះមានចំណុចខុសគ្នាជាងការមួយដែលត្រូវបានសរសេរដោយការបើកសម្តែង។ មិនត្រឹមតែសៀវភៅទាំងនោះ (ដំណឹងល្អយ៉ូហាន វិវរណៈរបស់យ៉ូហាន) មិនបញ្ចូលគ្រោងទូទៅនិងគំនិត។ ឧទាហរណ៍ ឡូហ្គូស(λόγος) (យ៉ូហាន 1:1 វិវរណៈ 10:13) “កូនចៀម” “មួយអង្គដែលយកជ័យជំនះ” (យ៉ូហាន 16:33 វិវរណៈ 2:7, 11) “មួយអង្គដែលរក្សាបទបញ្ញត្តិ” (1យ៉ូហាន 5:3 វិវរណៈ 12:17) “គំនិត

ដែលឃើញព្រះយេស៊ូវជាអង្គដែលនៅអស់កល្ប” (យ៉ូហាន 1:1, វិវរណៈ 22:13) “សេចក្តីសង្គ្រោះគឺត្រូវពឹងលើព្រះ និងព្រះលោហិតដ៏វិសេសរបស់ព្រះគ្រីស្ទ” (យ៉ូហាន 1:29, 3:3 5:24, 10:10, 11 វិវរណៈ 7:14 12:11 21:6, 22:17) “គំនិតដែលថាអ្នកណាដែលជឿដល់ទ្រង់នឹងបានសង្គ្រោះ” (យ៉ូហាន 3:16 វិវរណៈ 22:17) ជាដើម លើកលែងតែពួកគេ មានឃ្លាស្រដៀងៗគ្នា (នោះគឺ យ៉ូហាន7:7 និង វិវរណៈ 22:17, យ៉ូហាន 10:18 និង វិវរណៈ 22:7 យ៉ូហាន 20:12 និង វិវរណៈ 3:4, យ៉ូហាន 1:1 និង វិវរណៈ 19:13, យ៉ូហាន 1:29 និង វិវរណៈ 5:6 ជាដើម)។ ជាពិសេសគួរឱ្យភ្ញាក់ផ្អើលដែលថា កណ្ឌគម្ពីរទាំងពីរបានលើកឡើងនូវទម្រង់ស្រដៀងគ្នានៃសាការី 12:10 (យ៉ូហាន 19:37 វិវរណៈ 1:9)។

3) ដូចដែលយើងបានឃើញពីឃ្លារបស់ ជាកៀស ដែលជាសិស្សរបស់សាវកយ៉ូហាន (តាមរយៈការដកស្រង់របស់យូស៊ីបៀស)។ ព្រឹទ្ធាចារ្យយ៉ូហានបានរស់នៅក្រុងអេភេសូរនៅអាស៊ីភាគតិច។ យោងតាមសម្តីមួយចំនួន ត្រូវបានប្រាប់មកថា អ្នកនិពន្ធនៃកណ្ឌគម្ពីរវិវរណៈរបស់លោកយ៉ូហានជាបុរសម្នាក់នេះ។ តែវាពិបាកដែលថា “ព្រឹទ្ធាចារ្យយ៉ូហាន” ម្នាក់នេះពិតជាម្នាក់ផ្សេងទៀត ដែលមិនមែនជាយ៉ូហាននោះ។ ភស្តុតាងតាមប្រវត្តិសាស្ត្របានបង្ហាញប្រាកដថា អត្ថបទនេះត្រូវបានសរសេរឡើងដោយសាវកយ៉ូហាន។ ចាស្ទីន ម៉ាធើ (គ.ស 140) ចូរមើលទៅកណ្ឌគម្ពីរដូចជាសាវកយ៉ូហាន ដោយ អារីនាស (គ.ស 180) បានសង្កត់ធ្ងន់លើការពិតនេះប្រហែលបីបួនដងដែរ។ លោក ធើធូលៀន (គ.ស 200) លោក ខ្លេមិន នៃទីក្រុងអាឡិចសាន់ឌ្រា (គ

.ស 200) និង ហ៊ីផូលីធើស (គ.ស 240) ជាដើមបាននិយាយថា កណ្ឌគម្ពីរនេះមានសិទ្ធិនៃការចម្លងមកពីសាវកយ៉ូហាន។

II. ទីកន្លែងនិងពេលវេលានៃការសរសេរវិវរណៈរបស់យ៉ូហាន

កណ្ឌគម្ពីរត្រូវបានសរសេរឡើងនៅកោះប៉ាត់ម៉ុស (1-9)។ វាជាចំណតតែមួយគត់តាមផ្លូវទៅកាន់ក្រុងរ៉ូមចេញពីក្រុងអេភេសូរ។ មានអ្នកខ្លះអះអាងថា កណ្ឌគម្ពីរត្រូវបានសរសេរឡើងនៅ គ.ស 69។ យើងមិនអាចជឿការនេះបានទេ។ អ្នកគាំទ្រនៃទ្រឹស្តីនេះបានពឹងផ្អែកលើបញ្ហានៃការវាស់វែងនូវព្រះវិហារនៅក្នុងជំពូក 11។ គឺថា កាលដែលយ៉ូហានសរសេរកណ្ឌគម្ពីរនោះគឺពីព្រោះនៅមានព្រះវិហារនៅឡើយ នោះពួកគេអះអាងថា ពាក្យដូច្នោះដែលទាក់ទងនឹងការវាស់វែងគឺចេញមកពីវាមក។ ប៉ុន្តែការវាស់វែងព្រះវិហារនោះគ្រាន់តែជាសម្តីនិយាយបែបជានិមិត្តសញ្ញាប៉ុណ្ណោះ។ រ៉ាហារបែបសញ្ញាសម្គាល់ហើយ។ កាលដែលកណ្ឌគម្ពីរត្រូវបានសរសេរឡើង នោះក្រុមជំនុំអេភេសូរធ្លាប់មានចលនារបស់បក្សរបស់នីកូឡាស់ ជាជំនឿខុសឆ្គងដែលប៉ុលបានសរសេរទៅកាន់អេភេសូរដែលនាងមិនមាន។(2:6) វាបញ្ជាក់ការពិតថា វាត្រូវបានសរសេរជាយូរមកហើយ ពីកាលដែលប៉ុលបានធ្វើការនៅក្នុងក្រុមជំនុំអេភេសូរ។ ហើយវាជាការពិតដែលយ៉ូហានត្រូវបានជ្រើសរើសទៅកាន់កោះប៉ាត់ម៉ុស (1:9)។ ការដាក់ទោសដូច្នេះបានកើតឡើងក្នុងរាជរបស់អធិរាជរ៉ូមឈ្មោះ ដូមីស៊ានុស (គ.ស 81-96)។

III. វិធីសាស្ត្រនៃការបកស្រាយព្រះគម្ពីរ (ហឺម៉ាញូទិក ពីភាសាក្រិកថា ερμηνεύειν)

1. ប្រវត្តិសាស្ត្រនៃវិធីនៃការបកស្រាយ

ផ្នែកនេះត្រូវបានបកប្រែចេញពី "The principle of the interpretation of the Scripture (Schrift Beginselen ter verklaring)" ដែលត្រូវបានសរសេរឡើងដោយលោក ហ្គ្រេជដានុស។

ភាពចាំបាច់នៃការកាត់ស្រាយព្រះគម្ពីរ

ភាពចាំបាច់នៃការកាត់ស្រាយព្រះគម្ពីរមិនអាចត្រូវបានបដិសេធឡើយ ពីព្រោះ ព្រះយេស៊ូវបានបកស្រាយព្រះគម្ពីរដែរ។ (លូកា 24:32)។ មិនត្រឹមតែព្រះគម្ពីរបង្ហាញដល់យើងដោយមិនមានការបកស្រាយដោយផ្ទាល់ក៏ដោយ គឺវាពិបាកក្នុងការយល់ពីអត្ថន័យឱ្យបានបរិបូរណ៍និងច្បាស់ខ្លាំងណាស់ (ទំនុកដំកើង 119:18)។ ដូច្នេះ ក្រុមជំនុំកំណែទម្រង់បង្រៀនពីគោលការណ៍នៃភាពច្បាស់នៃបទគម្ពីរ (De erspicuitas van de Heilige Schrift) ហើយគិតពីអ្នកណាដែលមានសិទ្ធនឹងបកស្រាយព្រះគម្ពីរ។ ប៉ុន្តែក្រុមជំនុំរ៉ូម៉ាំងកាតូលិកមានគោលការណ៍នៃអាថ៌កំបាំងព្រះគម្ពីរ (De Duisterheid der Sc rift) ហើយអះអាងថា មានតែអ្នកដឹកនាំព័ន្ធកិច្ចនៃក្រុមជំនុំប៉ុណ្ណោះដែលអាចបកស្រាយព្រះគម្ពីរបាន ហើយសិទ្ធិអំណាចធំបំផុតនៃការបកស្រាយព្រះគម្ពីរគឺជាកម្មសិទ្ធិរបស់សម្តេចប៉ាប។

បញ្ហាលំបាកកាលដែលព្រះគម្ពីរត្រូវបានបកស្រាយ ដែលយើងបានជួប

បញ្ហានៃកម្មវត្ថុ– មនុស្សយល់ច្រឡំជាញឹកញាប់លើព្រះបន្ទូលរបស់ព្រះ។ លោក នីកូដេម បានយល់ច្រឡំពីព្រះបន្ទូលរបស់ព្រះយេស៊ូវថា “អ្នកត្រូវតែកើតម្តងទៀត”។ ពួកសាវកបានយល់ច្រឡំព្រះបន្ទូលរបស់ព្រះយេស៊ូវដែលថា “ឡាសាបានដេកលក់ហើយ”។ ការយល់ច្រឡំនេះបានកើតឡើងដោយការមានអារម្មណ៍យល់ពីព្រះបន្ទូលរបស់ព្រះពីខាងក្រៅតែម្យ៉ាងប៉ុណ្ណោះ។ ព្រះគម្ពីរយើង ក៏ដូច្នេះដែល គឺត្រូវគំនិតដោយសារសំលៀកបំពាក់នៃភាសា គឺភាសាដែលមានដើមកំណើតនិងបទពិសោធន៍ខុសគ្នាពីមួយទៅមួយ។ ដូច្នេះ នៅក្នុងការបកស្រាយព្រះគម្ពីរ យើងមិនអាចមើលងាយពីបញ្ហាលំបាកៗនៅក្នុងព្រះគម្ពីរទេ។ តែតាមរយៈការសិក្សាជាច្រើននោះវានឹងអាចដោះស្រាយបាន។

បញ្ហាពីខាងក្នុងបុគ្គល - នៅក្នុងការបកស្រាយព្រះគម្ពីរ នោះយើងដឹងថា “ខ្ញុំ” គឺជាមនុស្ស ជាភាវៈដែលត្រូវបានបង្កើតមក។ យើងមានកន្លែងដែលលំបាកជាច្រើនដែលត្រូវយល់ពីបំណងរបស់ព្រះអាទិករក្នុងនាមជារបស់ដែលត្រូវបានបង្កើតមក។ កាលដែលយើងបានស្គាល់ពីព្រះបន្ទូលរបស់ព្រះ នោះយើងយល់តែអ្វីដែលស្ថិតនៅក្នុងកម្រិតរបស់យើងប៉ុណ្ណោះ។ ប៉ុន្តែយើងមិនអាចមើលងាយថាយើងមានត្រឹមតែចំណេះដឹងប៉ុននេះក៏ដោយ យើងមិនអាចមិនអើពើនឹងការពិតថា វាជាចំណេះដឹងពិត និងជាចំណេះដឹងដែលមិនឯករាជឡើយ។ ដូច្នេះ អាកប្បកិរិយានៃការដែលត្រូវបានបង្កើតមកររបស់យើងមិនមែនជាបញ្ហាដែលពិបាកខ្លាំងនោះទេ។ លើសពីបញ្ហាទាំងអស់ ការដែលលំបាកបំផុតថែមទៀតនោះគឺ យើងត្រូវបានងងឹតដោយសារអំពើបាបរបស់យើង។ ព្រះគម្ពីរមានបន្ទូលថា សាច់ឈាមរបស់យើង (បំណងប្រាថ្នាពេញដោយបាប) គឺជាសត្រូវរបស់ព្រះ។ (រ៉ូម 8:7)។ ប៉ុន្តែវាត្រូវបានដោះស្រាយរួចហើយ។ ព្រះគ្រីស្ទបាន

ជំនួសកន្លែងនៃការស្លាប់របស់យើង ហើយបានផ្តល់ព្រះវិញ្ញាណបរិសុទ្ធមកយើងដើម្បី ឱ្យយើងអាចយល់ព្រះគម្ពីរតាមរយៈការបើកសម្តែងនៃព្រះវិញ្ញាណបរិសុទ្ធ។

ព្រះគម្ពីរគួរតែត្រូវបានបកស្រាយដោយព្រះគម្ពីរ

ដ្បិតកណ្ឌគម្ពីរទាំង 66 នៃព្រះគម្ពីរមានតែអ្នកនិពន្ធតែម្នាក់ប៉ុណ្ណោះ ដែលជាព្រះ បន្ទូលរបស់ព្រះវិញ្ញាណបរិសុទ្ធ គ្រប់ទាំងឃ្លានៅក្នុងកណ្ឌគម្ពីរមានទំនាក់ទំនងគ្នាទៅ វិញទៅមកនៅក្នុងលំនាំតែមួយ។ ដូច្នេះ ផ្នែកមួយអាចបើកសម្តែងពីផ្នែកផ្សេងទៀត។ មិនត្រឹមតែព្រះគម្ពីរបង្រៀនបែបអព្ភូតហេតុនោះទេ គោលការណ៍នៃការកត់ត្រាបែប អព្ភូតហេតុអស្ចារ្យនោះក៏ត្រូវបានបើកសម្តែងគោលការណ៍បែបអព្ភូតហេតុផងដែរ។ វិធីសាស្ត្រដែលថាព្រះគម្ពីរគួរតែត្រូវបានបកស្រាយដោយព្រះគម្ពីរ គឺជាវិធីសាស្ត្រ របស់ព្រះយេស៊ូវនិងសិស្សរបស់ទ្រង់។ (ម៉ាថាយ 1:22, 2:15, 17:23, 4:4, 7, 10, 26:54, លូកា 22:37, 24:27, 44, យ៉ូហាន 10:35 កិច្ចការ 3:18 13:27-41 17:2 3, 28:23 រ៉ូម 1:2, 4:23, 9:17 15:4 1កូរិនថូស 15:3,4 2ធីម៉ូថេ 3:15-17) នោះ យើងត្រូវការរៀនថ្នាក់ពាក្យនិងអក្សរជាពិសេស។ ពីព្រោះព្រះគម្ពីរជាព្រះបន្ទូលរបស់ ព្រះ ហើយត្រូវបានសរសេរដោយការគិតពីកិច្ចការផ្ទាល់របស់មនុស្ស (មិនមែនដោយ បែបអូតូម៉ាទិកទេ) វាបញ្ចូលនូវធាតុរបស់មនុស្សដែលត្រូវបានញែកជាបរិសុទ្ធដែរ។ និយាយមួយបែបទៀត យើងមិនមើលងាយដល់ការសិក្សាលើផ្នែកបែបនោះនៅក្នុង ការសិក្សាព្រះគម្ពីរនោះទេ។ ប៉ុន្តែ កាលដែលលទ្ធផលនៃការសិក្សានេះត្រូវបានបង្កើត រួចដោយទទួលបានការធានាដ៏ពិត។ ដូច្នេះ គោលការណ៍ដែលថា ព្រះគម្ពីរគួរតែត្រូវ បានកាត់ស្រាយដោយព្រះគម្ពីរគ្មានអ្វីក្រៅពីថាជាគោលការណ៍ដែលពិសេសខុសគេ នោះទេ។ តាមរយៈព្រះវិញ្ញាណបរិសុទ្ធ “ព្រះគម្ពីរបានមកដល់យើងដោយកិច្ចការ

របស់មនុស្ស តែវាលើសពីពាក្យរបស់មនុស្ស។ គឺជាព្រះបន្ទូលរបស់ព្រះ និងជាព្រះបន្ទូលរបស់ព្រះតែមួយគត។ ដូច្នេះ កាលដែលយើងពន្យល់ពីគំនិតរបស់ព្រះ និងគំនិតរបស់មនុស្ស នោះយើងគួរតែពន្យល់ដោយប្រើព្រះគម្ពីរ។ គំនិតរបស់ព្រះនោះខ្ពស់លើសពីគំនិតរបស់មនុស្ស។ គ្មានសៀវភៅណាដូចជាព្រះគម្ពីរទេនៅលើលោកិយនេះ។ ដូច្នេះ យើងមិនអាចពន្យល់ព្រះគម្ពីរដោយប្រើអ្វីផ្សេងឡើយ មានតែព្រះគម្ពីរត្រូវបានពន្យល់ដោយព្រះគម្ពីរតែមួយប៉ុណ្ណោះ។

ឥលូវនេះ ចូរយើងសង្កេតមើលពីដំណើរការនៃការអភិវឌ្ឍនៃវិធីសាស្ត្រនៃការបកស្រាយព្រះគម្ពីរ និងធ្វើការរិះគន់ពីវា។

(1) គ.ស 70 – គ.ស 170

ពួកសាវកបានបកស្រាយពីការពិតនៃគម្ពីរសញ្ញាថ្មីដោយប្រើគម្ពីរសញ្ញាចាស់។ នៅគ្រាចុងក្រោយនៃសតវត្សទី 1 លោក ក្លេមិន នៃក្រុងរ៉ូម បានទទួលវិធីសាស្ត្ររបស់ពួកសាវក និងបានទោរទៅរកវិធីសាស្ត្របែបនិម្មិតសញ្ញាដោយប្តូរបន្តិតបន្តួច។ ឧទាហរណ៍ សំបុត្របាណាបាសក៏បានទទួលនូវទំនោរនេះផងដែរ។

(2) គ.ស 170 – ស.វ ទៅ 5

មានក្រុមបីនៅក្នុងគ្រានេះ។

[1] ក្រុមមកពីទិសខាងលិច– វាមានលក្ខណៈដែលធ្វើតាមគោលការណ៍ប្រពៃណីនៃគ្រាចាស់។ ថ្វីត្បិតតែយើងមានចំណុចខ្លះចេញពីក្រុមនេះក៏ដោយ ក៏យើងមិនយល់ស្របសូម្បីតែចំណុចខុសឆ្គង ដែលធ្វើតាមប្រពៃណីខុសក៏ដោយ។ លោកអ៊ីរ៉ានាស ដែលជាសមាជិកនៃក្រុមបាននិយាយថា “យើងនឹងរៀនសេចក្តីពិតបែបប្រពៃណីពីក្រុមជំនុំ”។ នេះជាការគិតខុសដែលថាក្រុមជំនុំងាយនឹងធ្លាក់ចូលក្នុងទម្លាប់ដែលមិន

វិនាស ដែលចុះចូលនឹងប្រពៃណីក្រុងជំនុំដោយគ្មានលក្ខខណ្ឌ។ ប៉ុន្តែនៅសម័យបច្ចុប្បន្ន ក្នុងការការពារពីសាសនាខុសឆ្គង និងការរក្សាទំនៀមទំលាប់របស់ពួកជំនុំដែលដើម្បីសង្កត់ធ្ងន់លើប្រពៃណីគឺចាំបាច់។

គោលការណ៍រក្សាប្រពៃណីរបស់ក្រុមជំនុំមិនមានសិទ្ធិទាំងស្រុងនៅក្នុងការបកស្រាយព្រះគម្ពីរទេ តែវាមានឥទ្ធិពលនៅក្នុងការការពារការវិនិច្ឆ័យច្រើន និងការសន្និដ្ឋានរដិបរដុប។

[2] ក្រុមរបស់អាឡិចសាន់ឌ្រាបានយកគោលការណ៍នៃការប្រៀបធៀបជ្រុលនៅក្នុងការបកស្រាយបទគម្ពីរ។ អ្នកតំណាងនៃក្រុមនេះគឺ លោក អូរីជេន។ ឈ្មោះហៅក្រៅរបស់ក្រុមនេះគឺ បែបប្រៀបធៀបថាវាជាអ្វី? លោក Brouwel បាននិយាយថា “ការប្រៀបធៀបមិនសួរពីការពិតថា សម្ភារៈនៃការអធិប្បាយដែលបានប្រើជាប្រវត្តិសាស្ត្រពិតឬអត់នោះទេ”។ ការប្រៀបធៀបខុសរវាងអ្វីដែលវានិយាយ និងអត្ថន័យរបស់វា។ បទគម្ពីរមានការបង្រៀនបែបប្រៀបធៀប។ ប៉ុន្តែការបរាជ័យរបស់ក្រុមនៃការប្រៀបធៀបគឺជា ការអះអាងយ៉ាងជ្រុលហួសថា គ្រប់បទគម្ពីរសុទ្ធតែជាបែបប្រៀបធៀប។ លោក ក្លេមិន នៃទីក្រុងអាឡិចសាន់ឌ្រា អះអាងថា គ្រប់បទគម្ពីរគឺជាបែបប្រៀបធៀប។ គាត់បាននិយាយម្តងទៀតថា “ព្រះវិញ្ញាណបរិសុទ្ធបានធ្វើឱ្យយើងស្គាល់ពីអត្ថន័យពិតដើម្បីនឹងលាក់វាទុក...” អូរីជេន និយាយម្តងទៀតថា “បទគម្ពីរមិនមានចន្លោះដែលឥតប្រយោជន៍ទេ តែគ្រប់ទាំងសំបុត្រទាំងអស់សុទ្ធតែត្រូវបានបើកសម្តែង”។

[3] ក្រុមរបស់ពួកនៅអាន់ទីយ៉ូកមានការគោរពដល់គ្រប់ធាតុទាំងអស់របស់មនុស្ស ហើយបានសម្គាល់ពីប្រវត្តិសាស្ត្រ និងដាក់ទោសដល់ទ្រឹស្តី។ ក្រុមនេះល្អ គឺដែលអាចគេចផុតពីធាតុដែលរំខាន។ ជាញឹកញាប់តែងតែមិនអើពើនឹងអត្ថន័យខាងព្រលឹងវិញ្ញាណដែលជាការគួរសោកស្តាយ។

(3) សម័យកណ្តាល

នេះគឺជាគ្រាដែលពេញលេញទូលំទូលាយ ដែលមិនបានបកស្រាយប្រកបដោយភាពច្នៃប្រឌិតដោយបន្ទូរបន្ទាយរវាងសិទ្ធិអំណាចនៃបទគម្ពីរ និងក្រុមជំនុំមួយនោះទេ ពួកគេបានតែមើលបទគម្ពីរដោយប្រមូលទស្សនៈរបស់អ្នកដឹកនាំក្រុមជំនុំចាស់ៗ ប៉ុណ្ណោះ។ នៅគ្រានោះ ពួកកំណែទម្រង់ដូចជា លោក ចន វីខ្លីហ្វ (1348) គឺជាអ្នកបកប្រែនៃពួកកំណែទម្រង់។

(4) គោលការណ៍ខុសនៃមនុស្សសម័យនោះ

[1] សង្គមនិយម។ ការនេះនៅក្នុងការបកស្រាយព្រះគម្ពីរ គឺបានមើលទៅបទគម្ពីរដោយប្រើហេតុផលរបស់មនុស្ស ហើយយកហេតុផលរបស់មនុស្សជាស្តង់ដាដើម្បីនឹងវិនិច្ឆ័យលើសេចក្តីពិត។ ពិតណាស់ វាជាទ្រឹស្តីដែលធ្វើឱ្យយល់ច្រឡំបទគម្ពីរ។

[2] ពួកអាណាបាប់ទីស្ទ។ គេចាត់ទុកព្រះគម្ពីរជាឯកសារដែលពួកគេត្រូវទទួលយកបទពិសោធន៍ តែមិនស្គាល់ព្រះបន្ទូលរបស់ព្រះថានៅអស់កល្បទាំងស្រុងនោះទេ។ និកាយនេះគិតតែពីលើភស្តុតាងខាងក្នុងនៃបទគម្ពីរ ហើយចាត់ទុកបទគម្ពីរជាបណ្តុំនៃអក្សរដែលស្លាប់ដែលគ្មានជីវិត។ ពួកគេបានអះអាងថា អស់អ្នកណាដែលទទួលព្រះវិញ្ញាណបរិសុទ្ធមិនត្រូវការព្រះគម្ពីរទេ។ នេះជាទ្រឹស្តីដែលយល់ច្រឡំ ដែលមិនស្គាល់ពីតម្លៃនៃបទគម្ពីរ។

{3} demonstrants. ក្រុមនេះមិនមើលងាយធាតុរបស់ព្រះនៃបទគម្ពីរទេ តែពួកគេបង្ហាញយ៉ាងខ្លាំងក្លាថាមិនចុះចូលនឹងប្រពៃណីនិងគោលលិទ្ធិនោះទេ។ វិធីសាស្ត្រនៃក្រុមនេះគឺ បកស្រាយព្រះគម្ពីរបែបជាឥរិយាបថមិនស្ថិតស្ថេរដែលនៅកណ្តាល។ ពីព្រោះវាមានទំនោរទៅរកហេតុផលរបស់មនុស្សខ្ពស់ជាងច្បាប់របស់ព្រះ។ ពិតជា

គ្រោះថ្នាក់ណាស់ដែលទៅទោរទន់ទៅរកក្រុមនៃការបកប្រែដោយហេតុផលនេះ។ វាជាជំហ៊ានទីមួយទៅកាន់ការយល់ច្រឡំលើព្រះគម្ពីរហើយ។

[4] Rationalism. ក្រុមនេះមិនទទួលបទគម្ពីរថាជាព្រះបន្ទូលរបស់ព្រះទេ ហើយបក្សស្រាយព្រះគម្ពីរដូចជាចំណេះដឹងរបស់មនុស្សនិងដូចជាធម្មជាតិ។

[5] ក្រុមងាយស្រួល។ យើងអាចគិតពីការពីរដូចតទៅនេះនៅក្រោមចំណងជើងនេះ។ ទាំងពីរនោះគឺ 1) វិធីសាស្ត្រនៃការបកស្រាយបែបន័យត្រង់។ 2) វិធីសាស្ត្រនៃការបកស្រាយបែបព្រលឹងវិញ្ញាណជ្រុលហួស (J. S, Spener, Bengel)។ ពួកអ្នកដែលជាកម្មសិទ្ធិរបស់វិធីសាស្ត្រនៃអក្សរ ពួកគេបកស្រាយព្រះគម្ពីរដោយភ្ជាប់ជាមួយនឹងអត្ថន័យខាងវិញ្ញាណដោយឡែក។

[6] ក្រុមបកស្រាយតាមបែបចិត្តសាស្ត្រ។ ក្រុមនេះរាប់បញ្ចូលទាំងលោក ស្លាយម៉ាឃើ ជាអ្នកដែលព្យាយាមស្វែងរកលក្ខណៈពិសេសនៃដំណើរការបែបចិត្តសាស្ត្រ។ ប៉ុន្តែវាជាកំហុស ពីព្រោះគាត់មិនគិតពីកិច្ចការចូលរួមដ៏អស្ចារ្យរបស់ព្រះនោះទេ ប៉ុន្តែបកស្រាយសកម្មភាពបែបចិត្តសាស្ត្រដោយពឹងផ្អែកលើវិធីសាស្ត្របែបវិទ្យាសាស្ត្រទូទៅនៃអ្នកនិពន្ធវិញ។ មិនត្រឹមតែប៉ុណ្ណោះ ការបកស្រាយនេះមិនបាននាំមកនូវការសន្និដ្ឋានដែលសមស្របនឹងប្រព័ន្ធសាសនៈវិទ្យាមួយចំនួនទេ។ លោក F. H Germar ដែលនៅក្នុងក្រុមនេះបាននិយាយថា “អ្នកដែលបកស្រាយគ្រប់កណ្ឌព្រះគម្ពីរមិនគួរភ្ជាប់គំនិតនៃកណ្ឌគម្ពីរមួយទៅនឹងកណ្ឌគម្ពីរមួយទៀតឡើយ ហើយគួរតែយកគំនិតដែលឯករាជ្យវិញ។” វាជាទ្រឹស្តីខុស ពីព្រោះវាមានន័យថា ជាការមើលងាយសេចក្តីពិតដែលគ្រប់កណ្ឌគម្ពីរទាំងអស់ត្រូវបានសរសេរឡើងដោយអ្នកនិពន្ធតែម្នាក់គត់ គឺព្រះវិញ្ញាណបរិសុទ្ធ។ មិនត្រឹមតែប៉ុណ្ណោះ វាធ្វើឱ្យមានកំហុស ពីព្រោះវាបដិសេធការពិតដែលថា ព្រះយេស៊ូវនិងពួកសាវកត្រូវបានរួបរួម។

[7] Formgeschichtilich Schrift Verlkaring.

ទ្រឹស្តីនេះត្រូវបានចាប់ផ្តើមដោយ លោក H. Kungel។ គាត់បានសម្គាល់ការនេះនៅលើសៀវភៅមួយហៅថា “ការបង្កបង្កើតនិងការច្របូកច្របល់ (Schopfung und Chaos, 1898)” ចុះ តើអ្វីទៅជាវិធីសាស្ត្រនៃការបកស្រាយនៅក្នុងក្រុមវិទ្យាសាស្ត្រនេះ? ដំបូង ពួកគេមិនទទួលស្គាល់ការពិតដែលថាបទគម្ពីរមានលក្ខណៈដែលគួរឱ្យទុកចិត្តបានតាមប្រវត្តិសាស្ត្រទេ តែវាគ្រាន់តែជាកិច្ចការសាមញ្ញរបស់មនុស្សដែលមានកំហុសមួយចំនួនប៉ុណ្ណោះ។ ពួកគេនិយាយថា នៅក្នុងគ្រាមុន បទគម្ពីរ (ជាពិសេសដំណឹងល្អស្រដៀងគ្នាទាំងបី) បាននៅដូចជាការបង្រៀនដែលគ្មានលក្ខណៈស្ថិតស្ថេរ ដែលត្រូវបានផ្លាស់ប្តូរដោយពាក្យសម្តីរបស់បបូរមាត់បន្តិចបន្តួចនិងត្រូវបានផ្ទេរមក ក្រោយមក វាត្រូវបានបង្ហាញជាប្រភេទនៃដំណឹងល្អបច្ចុប្បន្ននេះ។ នេះគឺជាអ្នកស្រាវជ្រាវដែលគួរតែស្តារឡើងវិញនូវប្រព័ន្ធដើមនៃការបង្រៀន។

(5) វិធីសាស្ត្របកស្រាយបទគម្ពីររបស់ក្រុមកំណែទម្រង់

អ្នកកំណែទម្រង់បង្កើតគោលការណ៍នៃការបកស្រាយបទគម្ពីរដូចតទៅនេះ។

[1] គេជឿលើបទគម្ពីរថាជាព្រះបន្ទូលរបស់ព្រះ។ លោក កាល់វីន និយាយថា សិទ្ធិអំណាចនៃព្រះគម្ពីរប្រៀបដូចជាសម្លេងរបស់ព្រះដែលចេញមកពីស្ថានសួគ៌ដោយផ្ទាល់។

[2] ពីព្រោះព្រះគម្ពីរមានលក្ខណៈពេញដោយសិទ្ធអំណាចឯករាជ្យ (αὐτοπιστια) បើគ្មានការបញ្ជាក់ពីការផ្សេងទៀត និងគ្មានការទទួលស្គាល់ពីអ្នកផ្សេងទៀត គឺជាសេចក្តីពិតនៃការបង្កើតឡើងដោយខ្លួនឯងនិងភស្តុតាងដោយខ្លួនឯង (Calvin, Inst. 1:75)។

[3] កាលដែលយើងចង់ស្គាល់ព្រះគម្ពីរដោយស្មោះត្រង់ នោះភ្នែករបស់យើងនឹងត្រូវបានបើកដោយទីបន្ទាល់ខាងក្នុងនៃព្រះវិញ្ញាណបរិសុទ្ធ។

[4] សំបុត្រអាផូគ្រីផា មិនមែនជាបទគម្ពីរទេ។

[5] កាលដែលព្រះគម្ពីរត្រូវបានបកប្រែដោយភាសាដើមត្រូវបានបញ្ចប់។

[6] សកម្មភាពនៃការបកស្រាយដែលមកតាមពីប្រពៃណីនិងពឹងផ្អែកលើវាគួរតែត្រូវបានបដិសេធ។

[7] អ្នកដែលកាត់សេចក្តីធំបំផុតសម្រាប់ការបកស្រាយព្រះគម្ពីរគឺជាព្រះគម្ពីរផ្ទាល់។

[8] ពួកកំណែទម្រង់ជឿលើការបើកសម្តែងរបស់ព្រះគម្ពីរ ពីភាពល្អឥតខ្ចោះនៃបទគម្ពីរ ភាពគ្រប់គ្រាន់នៃបទគម្ពីរ និងភាពជាក់ស្តែងនៃបទគម្ពីរ។

[9] បទគម្ពីរមិនគួរត្រូវបានបកស្រាយដោយបង្ខំបែបន័យត្រង់ៗឡើយ។

[10] យើងទទួលស្គាល់ភាពចាំបាច់នៃការបកស្រាយតាមបែបវេយ្យាករណ៍។

[11] យើងទទួលស្គាល់ភាពចាំបាច់នៃការបកស្រាយតាមប្រវត្តិសាស្ត្រ។

[12] មេរៀនដែលសមហេតុផលដែលព្រះគម្ពីរទទួលយកគួរតែត្រូវបានទទួលស្គាល់ទុកជាបំណងរបស់ព្រះ។

[13] យើងសំដៅទៅលើគោលលិទ្ធិប្រវត្តិសាស្ត្រនៃការបកស្រាយព្រះគម្ពីរជាសំខាន់។

[14] ឃ្លាដែលមិនច្បាស់គួរតែត្រូវបានបញ្ជាក់ដោយអត្ថន័យនៃបទគម្ពីរដែលច្បាស់លាស់ជាងផ្សេងទៀត។

(6) វិធីសាស្ត្របកស្រាយបទគម្ពីរដោយព្រះយេស៊ូវ

កណ្ឌគម្ពីរដំណឹងល្អបង្ហាញគំរូជាច្រើនដែលព្រះយេស៊ូវបានកាត់ស្រាយព្រះគម្ពីរសញ្ញាចាស់។

[1] ទ្រង់ទទួលស្គាល់ភាពសាមញ្ញនៅក្នុងគំនិតនៃបទគម្ពីរ ដែលផ្តល់គម្រូស្តង់ដារនៃគោលការណ៍ដែលបទគម្ពីរគួរតែត្រូវបានបកស្រាយដោយបទគម្ពីរ។

[2] ទ្រង់បានបកស្រាយបទគម្ពីរដោយបែបប្រៀបធៀប។

[3] ទ្រង់អនុវត្តគោលការណ៍ដើម្បីនឹងបកស្រាយបទគម្ពីរជាបទគម្ពីរដោយស្មោះត្រង់។

[4] ព្រះយេស៊ូវបានជឿលើសិទ្ធិអំណាចយ៉ាងពេញលេញរបស់បទគម្ពីរ។

[5] ទ្រង់គោរពដល់ការបកស្រាយបែបប្រវត្តិសាស្ត្រនៅក្នុងការបកស្រាយបទគម្ពីរ។

[6] ព្រះគម្ពីរមិនឈប់ដោយសារឯកសារនៃបទពិសោធន៍ទេ (គឺថា វាមិនមែនសម្រាប់សិស្សផ្ទាល់ទេ) តែបានយកគោលការណ៍ដែលទាក់ទងនឹងមនុស្សគ្រប់គ្នាដោយផ្ទាល់ និងជាសកលវិញ ។

(ម៉ាថាយ 15:7,8, អេសាយ 29:13, ហេព្រើរ 1:1) ដូចដែលយើងឃើញវា ព្រះយេស៊ូវបានទទួលស្គាល់ថា ព្រះគម្ពីរជាព្រះបន្ទូលដែលមានសិទ្ធិអំណាច ដែលនិយាយទៅកាន់មនុស្សទាំងអស់ដោយផ្ទាល់ ហើយគ្រប់គ្រងលើពួកគេ ហើយនិងកាត់ទោសពួកគេ។ កាលដែលយើងពិនិត្យទៅលើគោលការណ៍ខាងលើ គឺវាច្បាស់ណាស់ថា ព្រះយេស៊ូវបានយកគោលការណ៍បកស្រាយព្រះគម្ពីរដោយប្រើព្រះគម្ពីរ។

2. ការបកស្រាយព្រះគម្ពីរនៃព្រះគម្ពីរ

ផ្នែកនេះត្រូវបានសង្ខេបនិងបកប្រែចេញពី Hermenutiek ដែលត្រូវបានសរសេរដោយលោក Grosheide ដែលជាវិធីសាស្ត្របកស្រាយព្រះគម្ពីរ។

ឈ្មោះនិងដំណើរការ

ពាក្យ Hermenutiek មានន័យថាបកប្រែជាទូទៅ។ នៅពេលក្រោយគេប្រើវាទៅក្នុងអត្ថន័យដើម្បីពន្យល់អំពីកំណាព្យ ពិបាក។ ទីបំផុតការទាំងនេះចង្អុលទៅកាន់ការសិក្សាពីច្បាប់នៃការបកស្រាយ និងរៀបចំជាប្រព័ន្ធ។ នេះមិនមែនជាសិល្បៈទេ តែជាវិទ្យាសាស្ត្រ ព្រោះវាផ្តោតលើមូលដ្ឋាន លើមូលហេតុ លើការវិភាគជាដើម ហើយស្រាវជ្រាវរកការទាំងអស់ផង។

Hermeneutic គឺជាការងារដែលមនុស្សប្រើជាទូទៅ។ ដោយសារវាទាក់ទងនឹងការបើកសម្តែងពិសេសរបស់ព្រះ នោះវាមានទិដ្ឋភាពពិសេស។ ដោយសារវាទាក់ទងនឹងគម្ពីរសញ្ញាថ្មី វាកាន់តែពិសេស។ នៅក្នុង Hermeneutic នេះ រឿងសំខាន់ពីរគឺមានការពិតដែលថា 1) មនុស្សមិនអាចយល់ពីបទគម្ពីរសម្រាប់អំពើបាបរបស់ខ្លួន 2) ប៉ុន្តែការពិតដែលមនុស្សបានកើតជាថ្មីអាចយល់វាបាន។

អ្នកបកប្រែគម្ពីរសញ្ញាថ្មីគួរតែយកចំណេះដឹងដែលបានរៀបចំដូចខាងក្រោម។

(1) បញ្ហានៃភាសា

មធ្យោបាយនៃការទំនាក់ទំនងដ៏ល្អបំផុតដែលមនុស្សជាតិបង្ហាញគំនិតរបស់ខ្លួននោះគឺជាភាសា។ ប៉ុន្តែទោះបីជាយើងអាចយល់ពីការគិតរបស់អ្នកដទៃក៏ដោយ ប៉ុន្តែមានការយល់ច្រលំជាច្រើននៅក្នុងនោះ ដែលយើងគួរតែប្រយ័ត្នចំពោះវា។ ក្នុងការបកស្រាយបទគម្ពីរ (នៅទីនេះត្រូវបានកំណត់ដោយគម្ពីរសញ្ញាថ្មី) មានបញ្ហាបែបនេះ។ មានមូលហេតុជាច្រើន។ នោះគឺ [1] ពាក្យដែលគម្ពីរសញ្ញាថ្មីបានប្រើដើម្បីប្រាប់ពីការគិតនោះគឺជាភាសាក្រិច [2] វាគ្មានរសជាតិច្បាស់លាស់យល់ដោឱ្យយល់បានដោយសារការស្តាប់វាដោយផ្ទាល់ទេ។ [3] វាពិបាកក្នុងការស្វែងរកទ្រឹស្តីរបស់អ្នកប្រាប់យ៉ាងឆាប់រហ័សណាស់។ [4] ពិបាកយល់ខ្លឹមសារដែលរួមបញ្ចូលក្នុងបរិបទ។

[5] វាគឺជាអាកប្បកិរិយាអវិជ្ជមានក្នុងការស្អប់កិច្ចព្រមព្រៀងជាមួយនឹងការពិតដែលត្រូវបានកត់ទុកមក នោះគឺដោយសារតែមនុស្សនោះគឺជាមនុស្សមានបាប គាត់មានទំនោរទៅរកទំនោរមិនយល់ព្រមជាមួយវា... យើងនឹងនិយាយចំណុចនេះជាមួយនឹងការសរសេរពិសេស ភាសាយើងអាចនិយាយឧទាហរណ៍ខ្លះថាជាខ្លឹមសារនៃភាសាដែលទីមួយថា ភាសាគឺជាការបញ្ចេញមតិលម្អិតដែលបានកើតឡើងនៅក្នុងជីវិតនៃសហគមន៍។ ទីពីរ សហគមន៍ទាំងនេះបង្ហាញពីការបញ្ចេញមតិខុសៗគ្នាសម្រាប់ពួកគេ ដែលមានភាពខុសប្លែកគ្នានៅក្នុងអារម្មណ៍ និងការគិតរបស់ពួកគេ (ឧទាហរណ៍ចំណុចខុសគ្នារវាងជាតិមួយ និងជាតិមួយទៀត) តាមពាក្យមានចំណុចខុសគ្នាដោយសារសហគមន៍ផ្សេងគ្នាប្រើ។ ទីបី ភាសាមិនបានបង្ហាញការពិតគ្រប់គ្រាន់ទេព្រោះមនុស្សជាមនុស្សមានកម្រិត។ ភាសាត្រូវបានធំឡើង ហើយត្រូវបានអភិវឌ្ឍ។ ដូច្នេះ អត្ថន័យក៏ត្រូវបានបង្កើតឡើងដោយការបំប្លែងបន្តិចបន្តួចក្នុងមួយថ្ងៃទៅមួយថ្ងៃ។ ទីបួន ភាសាត្រូវបានធ្វើឱ្យច្រឡំដោយអំពើបាបរបស់មនុស្សជាតិ ហើយក្លាយទៅជាងងឹត។

(2) លក្ខណៈពិសេសនៃគម្ពីរសញ្ញាថ្មី

[1] គោលការណ៍មូលដ្ឋាន។ គម្ពីរសញ្ញាថ្មីជាព្រះបន្ទូលរបស់ព្រះ។ (1)

វាបញ្ជាក់ការពិតថាព្រះបន្ទូលរបស់ព្រះគ្រីស្ទជាសេចក្តីពិត។ (យ៉ូហាន 8:14-) ការប្រកាសរបស់ពួកសាវកគ្មានបរាជ័យទេ (យ៉ូហាន 15:26) ក្រុមជំនុំក្រោយមកបានទទួលដូច្នោះ ហើយការប្រកាសផ្ទាល់នៃព្រះវិញ្ញាណបរិសុទ្ធប្រាប់មក។ ដូចជាការនិយាយខាងលើ ការពិតដែលគម្ពីរសញ្ញាថ្មីជាព្រះបន្ទូលរបស់ព្រះគួរតែត្រូវបានចងចាំដោយអ្នកបកស្រាយទុកជាច្បាប់មូលដ្ឋាន។ វាជាជំនឿសន្មត់នៃការបកស្រាយ តែវាមិនមែនជាគំនិតប្រឆាំងទេ។ គ្រប់វិទ្យាសាស្ត្រទាំងអស់សុទ្ធតែចាប់ផ្តើមដោយគោល

ការណ៍មូលដ្ឋាននិងជំនឿសន្មត់មួយ។ មានគោលការណ៍មូលដ្ឋានផ្សេងទៀតដែល អ្នកកាត់ស្រាយគួរតែចងចាំពីលក្ខណៈច្បាស់លាស់នៅក្នុងបទគម្ពីរដែលថា បទគម្ពីរ មិនមែនជាសៀវភៅដែលមិនអាចនឹងយល់បានទេ តែអាចដឹងបានដោយការ ស្រាវជ្រាវវិញ។ ប៉ុន្តែវាមិនមានន័យថា យើងមិនអាននូវការអធិប្បាយពន្យល់ទេ។ ហើយវាជាការពិតដែលគោលការណ៍មូលដ្ឋានផ្សេងទៀត ថាជំនឿគ្រប់គ្រងលើហេតុ ផលនៅក្នុងការកាត់ស្រាយបទគម្ពីរ។

[2] ដែលកំណត់នៃការយល់ដឹងសម្រាប់គម្ពីរសញ្ញាថ្មីដែលត្រូវបានសរសេរដោយ ពាក្យរបស់មនុស្ស។ វាមិនផ្តល់នូវការយល់ដឹងសរុបទេ តែគឺពិត (finite non capax infiniti)។

[3] គម្ពីរសញ្ញាថ្មីគឺស្ថិតស្ថេរ។ គ្រប់កណ្ឌគម្ពីរស្របទៅតាមការបើកសម្តែងខាងព្រលឹង វិញ្ញាណ (យ៉ូហាន 16:13, 14)។ គ្រប់សៀវភៅនិយាយទាំងអស់គ្នាអំពីលក្ខណៈ សម្បត្តិរបស់ព្រះគ្រីស្ទនិងកិច្ចការរបស់ទ្រង់។ គឺថា ពួកគេសុទ្ធតែជាដៃតែមួយនៃព្រះ បន្ទូលរបស់ព្រះ ក្នុងពេលតែមួយត្រូវបានបង្ហាញមកនូវធាតុនានារបស់មនុស្ស។ (បើ ទោះជាវាត្រូវបានបង្ហាញចេញតាមរយៈមនុស្ស តែវាមិនមានកំហុសអ្វីឡើយ)។

(3) អ្នកបកស្រាយគម្ពីរសញ្ញាថ្មី

គុណសម្បត្តិនៃការបកស្រាយត្រូវបានផ្តល់ដល់ក្រុមជំនុំដំបូងគេបង្អស់។ (រ៉ូម 3:2) ប៉ុន្តែក្រុមជំនុំមិនបានមើលងាយដល់សិទ្ធបុគ្គលទេ ពីព្រោះក្រុមជំនុំរ៉ូមបានមើលងាយ ដល់សិទ្ធិបុគ្គល ហើយវាជាការហុសឆ្គង។ បុគ្គលមិនគួរទទួលយកការបកស្រាយ របស់ក្រុមជំនុំដោយឥតលក្ខខណ្ឌឡើយ តែទទួលតែការបកស្រាយដែលសមស្របនូវ អត្ថន័យរបស់ព្រះគម្ពីរ។ អ្នកសាសនៈវិទូអាចបកស្រាយដោយទទួលបេសកកម្មនៃ ការបកស្រាយពិសេសដោយការតែងតាំងរបស់ក្រុមជំនុំ។ ប៉ុន្តែពួកគេគួរនិយាយអ្វី

ដែលពួកគេត្រូវបានទទួលស្គាល់នៅចំពោះព្រះតាមរយៈការយល់ដឹងនៃមនសិការ
របស់ពួកគេ។

ច្បាប់ដែលអ្នកបកស្រាយបទគម្ពីរគួរពឹងលើដូចតទៅនេះ។

[1] យើងគួរតែពឹងលើព្រះវិញ្ញាណបរិសុទ្ធទុកជាព្រះអម្ចាស់លើការបកស្រាយ ពីព្រោះបទគម្ពីរត្រូវបានបើកសម្តែងដោយព្រះវិញ្ញាណបរិសុទ្ធ។ ដូច្នេះ គម្ពីរសញ្ញាចាស់និងគម្ពីរសញ្ញាថ្មីចែករំលែកការបកស្រាយជាមួយគ្នាទៅវិញទៅមក។ បទគម្ពីរគួរតែត្រូវបានបកស្រាយដោយបទគម្ពីរ។

[2] ព្រះគ្រីស្ទជាចំណុចកណ្តាលនៃការបកស្រាយ។ អ្នកកាត់ស្រាយគួរតែស្វែងរកឃើញពីខ្លឹមសារដើម្បីនឹងភ្ជាប់ទៅនឹងព្រះគ្រីស្ទចេញពីគ្រប់កន្លែងនៃបទគម្ពីរ ជាពិសេសនៅក្នុងកន្លែងដែលសំខាន់។

[3] ការបកស្រាយនិងគោលលិទ្ធរបស់ក្រុមជំនុំមិនមែនជាសិទ្ធិអំណាចដ៏ធំបំផុតនោះទេ។ នៅក្នុងការបកស្រាយ បើទោះជាយើងសំដៅទៅលើការពឹងផ្អែកលើគោលលិទ្ធិក៏ដោយ ការសិទ្ធិអំណាចដ៏ធំបំផុតគឺជាព្រះគម្ពីរផ្ទាល់វិញ។ ដូចជាគាត់បានសុំអភ័យទោសនូវចំណុចខុសគ្នានៃបទគម្ពីរដូចជាក្រុមជំនុំរ៉ូម៉ាំង មិនគួរអះអាងថាជាការបកស្រាយតែមួយរបស់ក្រុមជំនុំថាជាសិទ្ធិអំណាចដ៏ធំបំផុតនោះទេ។ គេគួរបកស្រាយបែបជាការសន្មត់នៃសេចក្តីជំនឿ។ (រ៉ូម 12:6) ដែលមានន័យថា វាទាក់ទងនឹងជំនឿនិងស្របជាមួយនឹងជំនឿ។ (ស្របជាមួយជំនឿ នៅក្នុងទំនាក់ទំនងទៅនឹងជំនឿ)

(4) បញ្ហាដែលត្រូវបានពិចារណាជាពិសេសនៅក្នុងការបកស្រាយគម្ពីរសញ្ញាថ្មី

[1] ការបកស្រាយសំយោគ។ ការបកស្រាយសំយោគឈរលើមូលដ្ឋាននៃការបកស្រាយការរិភាគ។ នោះគឺបន្ទាប់ពីវាលាតត្រដាងការបកស្រាយតាមវេយ្យាករណ៍និងប្រវត្តិសាស្ត្រ។វាគួរតែត្រូវបានពិចារណា។ តាមរយៈការបកស្រាយសំយោគនៅទី

បំផុត យើងរកឃើញនូវអ្វីដែលព្រះវិញ្ញាណបរិសុទ្ធចង់បាន នោះគឺជាមេរៀនដែលត្រូវផ្តល់ឱ្យអ្នកជឿគ្រប់ជំនាន់ ពោលគឺស្វែងរកអត្ថន័យដែលផ្តោតលើព្រះគ្រីស្ទ។

សម្រាប់ការបកស្រាយសំយោគ យើងគួរតែចង់បានជំនួយពីព្រះវិញ្ញាណបរិសុទ្ធ។ វាមិនមានន័យថាការបកស្រាយសំយោគនៃអត្ថន័យអក្សរសាស្ត្រ និងអត្ថន័យប្រៀបធៀបដែលលោក អ្វីជេន បាននិយាយ និងអត្ថន័យអាថ៌កំបាំងនោះទេ ហើយវាមិនមែនជាការសំយោគនៃអត្ថន័យអក្សរសាស្ត្រ និងអត្ថន័យអាថ៌កំបាំងដែលក្រុមជំនុំរ៉ូម៉ាំងកាតូលិកបានបង្រៀននោះទេ។ វាមិនខុសគ្នានឹងការយល់នៃបុគ្គលផ្ទាល់បែបនេះទេ។

[2] អំពីការស្វែងរកឃ្លាដែលស្របគ្នា។ កាលដែលយើងបកស្រាយបទគម្ពីរ យើងបានជួបនឹងឃ្លាដែលស្រដៀងគ្នា។ ប៉ុន្តអ្នកកាត់ស្រាយគួរតែប្រយ័ត្ននៅទីនោះ។ បើទោះជាឃ្លាស្ថិតនៅផ្នែកខុសគ្នានៅក្នុងព្រះគម្ពីរក៏ដោយ ក៏ការទាំងពីរមិនអាចមានអត្ថន័យដូចគ្នាឡើយ ពីព្រោះឃ្លាពីរអាចនឹងត្រូវបានសរសេរឡើងដោយទស្សនៈខុសគ្នាពីរដែរ។ ឃ្លានៅសញ្ញាចាស់គួរត្រូវប្រុងប្រយ័ត្ននៅក្នុងការស្វែងរកអត្ថន័យនៅក្នុងសញ្ញាចាស់។ ជាពិសេសអ្នកកាត់ស្រាយបទគម្ពីរតែងជួបនឹងអក្សរសាស្ត្របែបសាច់ឈាមនោះគាត់គួរតែលើកពីវាមកដោយងាយស្រួល។ វាគួរតែត្រូវបានរិះគន់ដោយស្តង់ដានៃបរិបទរបស់ព្រះគម្ពីរ។ ជាពិសេស បើទោះជានៅក្នុងអក្សរសាស្ត្ររបស់អ្នកមិនជឿក៏មានការខ្លះដែលស្រដៀងទៅនឹងបទគម្ពីរ អត្ថន័យត្រូវបានប្រើប្រាស់ទៅកាន់ខ្លឹមសារខុសគ្នានៃបទគម្ពីរ។

[3] តម្លៃនៃការបកស្រាយ។ ដ្បិតមនុស្សត្រូវបានបង្កើតនៅក្នុងរូបឆ្លុះរបស់ព្រះ មនុស្សដែលត្រូវបានកើតជាថ្មីមានសិទ្ធិដូចគ្នានៅក្នុងការបកស្រាយបទគម្ពីរ។ បញ្ហាខ្លះនឹងត្រូវបានកើតឡើង។ គឺយោងតាមមនុស្សម្នាក់ៗ គឺម្នាក់ៗមានការបកស្រាយខុសគ្នា។

តែវាមិនមែនជាបញ្ហាដ៏ធំមួយនោះទេ។ ពីព្រោះ (1) ដ្បិតបទគម្ពីរពន្យល់ពីចំណុចសំខាន់ នោះក្រុមជំនុំទាំងអស់នឹងមានការបកស្រាយដូចគ្នានៅក្នុងចំណុចនោះ។ (2) សម្រាប់ចំណុចខុសគ្នាមួយចំនួននៅក្នុងការបកស្រាយខុសគ្នាទៅនឹងទំនាក់ទំនងទៅនឹងគំនិតនៃគ្រា នោះវាអាចដោះស្រាយនៅក្នុងដំណើរការនៃពេលវេលា។ (3) ចំណុចខុសគ្នាខ្លះនៅក្នុងការបកស្រាយមិនជារបស់ក្រុមជំនុំទេ តែជារបស់បុគ្គល នោះវានឹងត្រូវបាត់ទៅបន្តិចម្តងៗ។ (4) ព្រះវិញ្ញាណបរិសុទ្ធដឹកនាំចំណុចខុសៗគ្នានៃការបកស្រាយដើម្បីធ្វើឱ្យពួកគេរួបរួមជាមួយគ្នា។ (5) ចំណុចខុសគ្នានៃការបកស្រាយទៅកាន់ចំណុចតូចមិនមែនជាអ្វីសំខាន់នោះទេ។

[4] តើយើងអាចរិះគន់បទគម្ពីរទេ? ពួកខាងហេតផលនិយមធ្វើការរិះគន់ដោយគ្មានដែនកំណត់ ដ្បិតពួកគេដឹងថា បទគម្ពីរជាកិច្ចការរបស់មនុស្ស។ វាជាការរិះគន់ខុស ពីព្រោះពួកគេមិនអើពើលើលក្ខណៈពិសេសនៃបទគម្ពីរដែលថាជាធាតុដែលអព្ភូតហេតុអស្ចារ្យទេ។ ហើយពួកខាងធ្វើពិសោធន៍និយមវិញដឹងថា បទគម្ពីរជាឯកសារនៃការពិសោធន៍របស់បុគ្គល ពួកគេរិះគន់វានៅក្នុងស្តង់ដានៃជំនឿរបស់អ្នកជឿ។ (ឬ មនសិការរបស់អ្នកជឿ) ការនេះដឹកនាំទៅរកការយល់របស់បុគ្គលនិយមដែលខុសឆ្គងហើយ។

ប៉ុន្តែសាសនៈវិទ្យារបស់ពួកកំណែទម្រង់អះអាងថា បទគម្ពីរត្រូវបានបើកសម្តែងការរួបរួមរវាងធាតុរបស់ព្រះនិងធាតុរបស់មនុស្ស។ ភាសាដែលប្រើជាធាតុរបស់មនុស្ស។ វាទទួលការរិះគន់នៃវិទ្យាសាស្ត្រ ប៉ុន្តែបុគ្គលដែលរិះគន់ជឿថា វាត្រូវបានប្រើដោយការដឹកនាំរបស់ព្រះវិញ្ញាណបរិសុទ្ធពិត ហើយសិក្សាបែបជាគំនិតនៃការការពារវាផង ដូច្នេះសាសនៈវិទ្យារបស់ពួកកំណែទម្រង់គិតថា ព្រះបន្ទូលរបស់ព្រះផ្ទាល់មិនមែនជាកម្មវត្ថុនៃការរិះគន់នោះទេ។

(5) ចំណេះដឹងសំខាន់នៅក្នុងការបកស្រាយបទគម្ពីរ។ អ្នកកាត់ស្រាយបទគម្ពីរគួរតែមានចំណេះដឹងសំខាន់ៗដូចតទៅនេះ។ ពីបញ្ហាក្នុងការទទួលស្គាល់ក្រាំងនៃបទគម្ពីរប្រវត្តិសាស្ត្រក្រុមជំនុំយកលក្ខណៈនៃទំនាក់ទំនងយ៉ាងខ្លាំង។ គឺថា ការពិតដែលការយល់ដឹងសេចក្តីពិតត្រូវបានអភិវឌ្ឍបន្តិតម្តងៗ នោះយើងអាចដឹងតាមរយៈប្រវត្តិសាស្ត្ររបស់ក្រុមជំនុំ។ មិនត្រឹមតែប៉ុណ្ណោះ ការរុករកឃើញរបស់បុរេសិក្សារបស់គ្រីស្ទានបានផ្តល់ជំនួយជាច្រើននៅក្នុងការបកស្រាយគម្ពីរសញ្ញាថ្មីលើកលែងតែការមួយនេះ យើងធ្វើអ្ីបបានក្រៅពីត្រូវការចំណេះដឹងបែបសាសនៈវិទ្យា។ ប្រធានបទនៃសាសនៈវិទ្យាមិនត្រូវបានទុកចោលទេ តែមានទំនាក់ទំនងជាមួយគ្នានៅគ្រប់កន្លែង។ ហើយវាជាការពិតដែល ពួកគេត្រូវការចំណេះដឹងវិទ្យាសាស្ត្រទូទៅនោះ។ ឧទាហរណ៍ មានវិទ្យាសាស្ត្រអក្សរសាស្ត្រ ទស្សនៈវិទ្យា និងចិត្តសាស្ត្រ ជាដើម។ ការដែលសំខាន់ជាងធាតុខាងលើគឺជាចំណេះដឹងខាងព្រលឹងវិញ្ញាណ។ ការបកស្រាយតាមបទគម្ពីរមិនអាចធ្វើបានដោយគ្មានការដឹកនាំរបស់ព្រះវិញ្ញាណបរិសុទ្ធនោះទេ។ ជាមួយនឹងចំណេះដឹងខាងលើទាំងអស់ អ្នកបកស្រាយគួរដឹងថា ដើម្បីនឹងអាចរិះគន់លើអត្ថបទបានថាវាជាអ្វីនោះ?

នៅទីនេះ អ្វីដែលខ្ញុំពិភាក្សាមិនមែនចង់និយាយជាខ្លឹមសារនៃការរិះគន់អត្ថបទដោយលម្អិតទេ ប៉ុន្តែជាការស្រាវជ្រាវលក្ខណៈវិញ។ អត្ថបទព្រះគម្ពីរដែលយើងមានមិនមែនការសរសេរដំបូងនៃអត្ថបទដើមទេ តែជាអត្ថបទដែលត្រូវបានជ្រើសរើសចេញពីអត្ថបទដែលបានជ្រើសយកមកពីឯកសារនានា។ ដ្បិតនៅក្នុងចំណោមឯកសារនានា អត្ថបទខុសអាចនឹងមានដែរ នោះពួកគេត្រូវការការរិះគន់ទៅលើអត្ថបទ។

[1] សម្ភារៈនៃការរិះគន់លើអត្ថបទ។ សម្ភារៈសម្រាប់នឹងរិះគន់លើអត្ថបទភាគច្រើនគឺជាឯកសារនានា។ ប៉ុន្តែការបកប្រែភាសាឡាតាំងចាស់ និងភាសាស៊ីរីចាស់បានផ្តល់ផលប្រយោជន៍ និងជំនួយដល់យើង។ ការបកប្រែជាភាសាឡាតាំងចាស់មានតម្លៃតិចជាងការបកប្រែជាភាសាស៊ីរីចាស់។ ប៉ុន្តែជាទូទៅ តាមរយៈការបកប្រែទាំងនោះ យើងអាចដឹងថាពេលណាដែលខ្លឹមសារនៃអត្ថបទត្រូវបានប្រើប្រាស់នៅក្នុងគ្រានៃការបកប្រែ។

ខ្លឹមសារដែលត្រូវបានលើកយកមកប្រើរបស់បុព្វបុរសនៃក្រុមជំនុំត្រូវបានលើកមកសម្រាប់ការរិះគន់លើអត្ថបទ។ តែជាអកុសល អត្ថបទដើមនៃអត្ថបទដែលត្រូវបានលើកយកមកប្រើមិនមាននៅទេ។ ត្រឹមតែប្រាប់មកតាមរយៈសៀវភៅផ្សេងទៀតដូចជាប្រភេទដែលត្រូវបានប្រែប្រួលច្រើនជាង។

រួចមកតើអត្ថបទដើមសព្វថ្ងៃនេះនៃគម្ពីរសញ្ញាថ្មីមិនគ្រាប់គ្រាន់ដើម្បីនឹងក្លាយជាអត្ថបទដើមមែនទេ? វាមិនដូច្នោះទេ ពីព្រោះ (ក) នៅក្នុងឯកសារ ចំណុចខុសគ្នានៃឯកសារបង្ហាញការសំខាន់បន្តិចបន្តួចប៉ុណ្ណោះ។ (ខ) នៅក្នុងចំណុចខុសៗគ្នាទាំងអស់សម្រាប់ការកត់ត្រាខុសត្រូវបានលើកបង្ហាញយ៉ាងច្បាស់ ថាគ្មានបញ្ហាអ្វីឡើយ។ (គ) ចំណុចខុសគ្នាទាំងអស់មិនបាននាំមកនូវចំណុចខុសគ្នានៃគោលលិទ្ធិ ឬការបង្រៀនទេ... (ឃ) ចំណុចខុសគ្នាខ្លះត្រូវបានបង្ហាញការពិត ពីការចម្លងអោយខុសដោយចេតនាដោយសារឥទ្ធិពលរបស់ពួកឆ្កាំឆ្គង។ ដូច្នេះ អ្នកប្រាជ្ញលើឯកសារបានរកឃើញអត្ថបទដើមយ៉ាងងាយស្រួលដោយគ្មានបញ្ហាចេញពីចំណុចខុសគ្នាឡើយ។ (e) យើងបានចងចាំការផ្សេងៗ ទស្សនៈខាងព្រលឹងវិញ្ញាណទៅកាន់អត្ថបទព្រះគម្ពីរ។ គឺថា បន្ទាប់ពីព្រះបើកបង្ហាញពីព្រះបន្ទូលដល់យើង ទ្រង់បានរក្សាវាមិនឱ្យបាត់សោះនៅក្នុងអំណាចគ្រប់គ្រងរបស់ព្រះ។ គម្ពីរសញ្ញាថ្មីមានឯកសារជាច្រើនដែលខុសគ្នា

ទៅនឹងអក្សរសាស្ត្រខាងលោកិយ។ ពីព្រោះគម្ពីរសញ្ញាថ្មីត្រូវបានចម្លងដោយអ្នកជឿទូទៅ និងពួកគេបានអានជាច្រើន។ នៅក្នុងភស្តុតាងនៃឯកសារដ៏ច្រើន យើងអាចរកឃើញអត្ថបទដើមដោយងាយ។ បើទោះជាយើងមិនមានចំណុចដែលលំបាកក្នុងការសម្រេចវា ហើយរួចមកយើងគួរប្រាកដថា នៅក្នុងអត្ថបទដើមគឺវាដូចគ្នាមែន។ បែបដូច្នេះដែលវិទ្យាសាស្ត្រនៃឯកសារគម្ពីរសញ្ញាថ្មីគឺជាវិទ្យាសាស្ត្រខាងសាសនៈវិទ្យា ដ្បិតវាពិសេសជាងអក្សរសាស្ត្រខាងសាច់ឈាមផង។ អ្វីដែលយើងដឹងជាសេចក្តីពិតដែលថា នៅក្នុងការអានព្រះគម្ពីរ នោះយើងដឹងថាព្រះគម្ពីរពិតជាព្រះបន្ទូលរបស់ព្រះដោយព្រះវិញ្ញាណបរិសុទ្ធតែមួយអង្គគត់។ ត្រឹមចំណុចខុសគ្នានៅក្នុងឯកសារ ការពិតដែលថាមួយណាជាអត្ថបទដើមនឹងត្រូវបានដោះស្រាយដោយការសិក្សាបែបវិទ្យាសាស្ត្រ។

[2] វិធីសាស្ត្រលើវិធីសាស្ត្រនៃការរិះគន់

(ក) ការរិះគន់អត្ថបទនៅក្នុងគម្ពីរសញ្ញាថ្មីស្រដៀងទៅនឹងអក្សរសាស្ត្រខាងលោកិយនៅក្នុងចំណុចមួយចំនួន ដូចជាបាននិយាយខាងលើថា វាមានទស្សនៈខាងវិញ្ញាណដែលត្រូវបានហៅថា វិទ្យាសាស្ត្រខាងសាសនៈវិទ្យា។ (ខ) វាគួរតែប្រមូលរាល់ភស្តុតាងទៅនឹងអត្ថបទ (ឯកសារ អត្ថបទដែលត្រូវបានបកប្រែ អត្ថបទដែលត្រូវបានលើកយកមកប្រើប្រាស) ហើយគួរតែអានវា។ (គ) កាលដែលវាបានដាក់នូវតម្លៃនៃអត្ថបទចម្លងមួយចំនួន នោះវាមិនគួរពឹងផ្អែកលើតួលេខតិចឬច្រើនទេ ពីព្រោះភស្តុតាងខ្លះនៃឯកសារស្រដៀងគ្នាដោយពន្លឺដែលធ្ងន់និងស្រាល។ រួចមក អ្នកកាត់ស្រាយអាចជ្រើសរើសអ្វីដែលគាត់គិតថាមានតម្លៃខ្លាំង។ ពិតណាស់ គាត់គួរតែប្រយត្នពីវាផងដែរ។

(6) វិធីសាស្ត្រនៃការបកស្រាយ

[1] ការបកស្រាយបែបវេយ្យាករណ៍និងប្រវត្តិសាស្ត្រ និងការបកស្រាយបែបចិត្តសាស្ត្រ។

ការបកស្រាយបទគម្ពីរងាយនឹងបរាជ័យ នៅពេលដែលគេធ្វើវាជាប្រភេទមួយ ពីព្រោះបទគម្ពីរបើកបង្ហាញពីពិភពលោករបស់ព្រះជាច្រើនបែបបទ។ ដូច្នេះ យើងគួរពិចារណាវិធីសាស្ត្រមួយចំនួននៅក្នុងការបកស្រាយបទគម្ពីរ។ វិធីសាស្ត្រដែលសំខាន់បំផុតនៃការបកស្រាយគឺជាវេយ្យាករណ៍ វិធីសាស្ត្របែបប្រវត្តិសាស្ត្រ។ វាមានន័យថាជាការសិក្សាខាងអក្សរសាស្ត្រ និងកាសិក្សាពីប្រវត្តិសាស្ត្រ។ ក៏មានការបកស្រាយតាមបែបចិត្តសាស្ត្រផងដែរ ដែលប្រើសម្រាប់ផ្នែកបន្ទាប់បន្សំបន្ទាប់ពីវេយ្យាករណ៍ និងប្រវត្តិសាស្ត្រ។ ចុះតើវិធីសាស្ត្របែបវេយ្យាករណ៍និងប្រវត្តិសាស្ត្រដំណើរការយ៉ាងម៉េចឱ្យប្រាកដទៅ? (ក) ការបកស្រាយបែបវេយ្យាករណ៍ជាការសិក្សាពីប្រភេទកិរិយាស័ព្ទនៅក្នុងអត្ថបទ និងទីតាំងនៃពាក្យ និងដើម្បីការពារពីការទាយដោយបង្ខំរបស់អ្នកកាត់ស្រាយ។ មិនត្រឹមតែប៉ុណ្ណោះទេ ការបកស្រាយតាមបែបវេយ្យាករណ៍ព្យាយាមដឹងរឿងដូចជា ពាក្យរបស់អ្នកនិពន្ធ និងទម្លាប់របស់អ្នកសរសេរឱ្យបានត្រឹមត្រូវ។ អ្នកបកស្រាយតាមបែបវេយ្យាករណ៍ប្រើគ្រោងនៃល្បះនៅក្នុងអត្ថបទ និងប្រស្នា និងការប្រៀបធៀប ហើយនឹងបកប្រាយការទាំងនោះ។

(ខ) ការបកស្រាយបែបប្រវត្តិសាស្ត្រជាវិធីសាស្ត្រស្រាវជ្រាវរកធាតុនានានៃគ្រោ និងបរិស្ថានដែលទាក់ទងទៅនឹងអត្ថបទ។ ដូច្នេះ ការបកស្រាយនេះសំដៅរកការសិក្សាបុរេវិទ្យា។ ប៉ុន្តែការនេះមិនមើលទៅព្រះគម្ពីរទុកដូចជាប្រវត្តិសាស្ត្រមួយទេ តែសំដៅរកប្រវត្តិសាស្ត្រដើម្បីឱ្យបានយល់ពីចំណេះដឹងប្រវត្តិសាស្ត្រនៅក្នុងបទគម្ពីរ។ នៅត្រង់ចំណុចនេះ ពួកគេត្រូវតែប្រយ័ត្នពីកម្រិតទាប ដែលសម្ភារៈប្រវត្តិសាស្ត្រនៅក្នុងគម្ពីរ

សញ្ញាថ្មីដែលវាអាក្រក់ជាងប្រវត្តិសាស្ត្រខាងលោកិយផង។ អ្វីដែលត្រូវបានកត់ត្រានៅក្នុងព្រះគម្ពីរសុទ្ធតែពិត។ (គ) ការបកស្រាយបែបចិត្តសាស្ត្រ ជាវិធីសាស្ត្រស្រាវជ្រាវរកពាក្យនៅក្នុងអត្ថបទ និងពីកត្តាជំរុញនៃសកម្មភាពនោះ។ ប៉ុន្តែយើងមិនគួរបំភ្លេចថា ចលនានៃការបើកសម្តែងរបស់ព្រះគឺជាហេតុបង្ក។ ប្រសិនបើអ្នកបកស្រាយភ្លេចវា តែជ្រើសរើសយកការបកស្រាយបែបចិត្តសាស្ត្រ នោះគាត់នឹងអាចយល់ច្រឡំដោយចាត់ទុកព្រះគម្ពីរគ្រាន់តែជាកិច្ចការរបស់មនុស្សប៉ុណ្ណោះ។ ការបកស្រាយបែបចិត្តសាស្ត្រនេះត្រូវបានប្រើដើម្បីនឹងយល់ពីធាតុរបស់មនុស្សតែមួយ
ប៉ុណ្ណោះ។ ប៉ុន្តែ ហេតុផលដែលការនេះជាការដែលសំខាន់គឺជាការពិតដែលថា ព្រះទ្រង់បានប្រើមនុស្សនៅក្នុងចលនានៃការបើកសម្តែងពិសេស។ តាមរយៈធាតុរបស់មនុស្សទាំងនេះ ព្រះវិញ្ញាណបរិសុទ្ធបានធ្វើការនៃការបើកសម្តែង។ នៅពេលខ្លះ កាលព្រះបានប្រើមនុស្សទៅកាន់ទិសដៅដែលពួកគេមិនចូលចិត្តផង។ ប៉ុន្តែនៅពេលនោះ ព្រះទ្រង់មិនបានធ្វើឱ្យមនុស្សក្លាយដូចជាម៉ាស៊ីននោះទេ។ មកដល់ត្រង់នេះ អ្វីដែលយើងគួរចងចាំនោះ គឺការពិតដែលថា មនុស្សជាតួអង្គបន្ទាប់បន្សំសម្រាប់ព្រះដែលទ្រង់បានប្រើមនុស្សនោះ។ ដូច្នេះ នៅក្នុងការបកស្រាយបែបចិត្តសាស្ត្រ វាបានធ្វើការបន្ទាប់បន្សំ ប៉ុន្តែវាមិនធ្វើការនៅក្នុងគ្រប់ផ្នែកនោះទេ។

[2] វិធីសាស្ត្រស្វែងរកអត្ថន័យដ៏ជ្រាលជ្រៅ

បើទោះជាការបកស្រាយតាមបែបវេយ្យាករណ៍និងប្រវត្តិសាស្ត្រត្រូវបានបញ្ចប់ក៏ដោយ អ្នកកាត់ស្រាយមិនបានបញ្ចប់តួនាទីនៃការបកស្រាយរបស់គាត់ទេ ទាល់តែគាត់រកឃើញគំនិតសំខាន់នៅក្នុងអត្ថបទ គឺការស្វែងរកអត្ថន័យសំយោគ។ វាពិបាកនៅក្នុងការបង្កើតច្បាប់ពេញលេញក្នុងការស្វែងរកវិធីសាស្ត្រស្វែងរកគំនិតសំខាន់នោះ។

ពីព្រោះបទគម្ពីរត្រូវបានសរសេរដោយបែបបទមួយចំនួន។ ដើម្បីនឹងស្វែងរកអត្ថន័យសំខាន់ អ្នកកាត់ស្រាយគួរតែមានអំណោយទាននៅក្នុងការកាត់ស្រាយ និងរស់នៅដោយមានទំនាក់ទំនងជាមួយនឹងព្រះគម្ពីរ និងដោយមានការបើកសម្តែងរបស់ព្រះវិញ្ញាណបរិសុទ្ធ។ វិធីសាស្ត្រមួយចំនួននៃការកាត់ស្រាយដូចបានសម្គាល់ខាងលើ (តាមបែបវេយ្យាករណ៍ ប្រវត្តិសាស្ត្រ) ជួយឱ្យយើងកុំឱ្យទាសចេញទៅតាមផ្លូវខុស យើងគួរតែបកស្រាយវិធីសាស្ត្រមួយជាមួយនឹងការបកស្រាយសំយោគចូលជាមួយគ្នា។

ការអនុវត្តជាក់ស្តែងនៃការកាត់ស្រាយបទគម្ពីរ

(ក) យើងគួរដាក់អត្ថបទ និងសួរថា “តើផ្នែកនេះបើកសម្តែងអ្វីដល់ខ្ញុំនៅពេលនេះ?” នោះគឺ យើងគួរគិតពីអ្វីដែលផ្នែកនេះបង្ហាញដល់ខ្ញុំ និងក្រុមជំនុំ និងលោកិយសព្វថ្ងៃនេះ តែយើងគួរតែប្រយ័ត្នពីអារម្មណ៍បែបបុគ្គលនិយមនៅត្រង់ចំណុចនេះ។ ដូច្នេះយើងគួរប្រើច្បាប់ផ្សេងទៀត។ នោះគឺ (ខ) យើងគួរសួរសំណួរមួយទៀតដូចតទៅនេះថា “មកដល់ត្រង់នេះ តើអ្វីជាគំនិតសំខាន់? ឬ តើអ្វីជាធាតុសំខាន់ទីពីរ?” (គ) យើងមិនគួរគិតថា ព្រះបន្ទូលនៃបទគម្ពីរជាព្រះបន្ទូលដែលស្លាប់នោះទេ ហើយគួរដឹងថាព្រះគម្ពីរជាព្រះបន្ទូលនៃជីវិត។ មិនត្រឹមតែជាផ្នែកសំខាន់ទេ តែសម្ភារៈបន្ទាប់បន្សំក៏ជាព្រះបន្ទូលរបស់ព្រះដែរ។ (ឃ) កាលដែលយើងសិក្សាអត្ថបទ យើងគួរគិតពីវាដោយប៉ានស្មាន។ (ង) ដ្បិតព្រះបន្ទូលរបស់ព្រះនៅក្នុងចំណុចកណ្តាលដែលជាព្រះគ្រីស្ទ នោះអ្នកបកស្រាយគួរតែព្យាយាមរកទំនាក់ទំនងទៅជាមួយនឹងព្រះគ្រីស្ទ។ មកដល់ត្រង់នេះ យើងគួរគេចចេញពីការបំពាននៃការប្រៀបធៀប។ កាឡាទី ជំពូក 4 ត្រូវបានបកស្រាយដោយការប្រៀបធៀបជាមួយនឹងព្រឹត្តិការណ៍។ វាត្រូវតែបានយកមក

និយាយ ដ្បិតវាត្រូវបានបើកផ្លូវដល់ការបកស្រាយបែបប្រៀបធៀប។ អ្នកកាត់ស្រាយមិនគួរបកស្រាយប្រវត្តិសាស្ត្រនៅក្នុងព្រះគម្ពីរនៅក្នុងគោលការណ៍ជាពាក្យប្រៀបធៀបឡើយ។ អ្នកកាត់ស្រាយត្រូវយកវិធីសាស្ត្រនៃការបកស្រាយបែបប្រៀបធៀបដើម្បីនឹងស្វែងរកអត្ថន័យដ៏ជ្រៅនៅក្នុងនោះ។ តែវាចាការធ្វើមិនត្រឹមត្រូវទេ។ ប្រសិនបើអ្នកកាត់ស្រាយមានពាក្យដែលគាត់មិនអាចយល់បាននៅពេលនេះ វាសាកសមដែលត្រូវរងចាំដោយទុកផ្នែកនោះជាខ្លឹមសារដែលមិនដឹង។ គឺមិនមែនដើម្បីនឹងផ្តល់ដល់គាត់ដោយផ្ទាល់ទេ តែទៅកាន់ក្រុមជំនុំនៅគ្រប់ជំនាន់។ បើទោះជាគាត់មិនអាចស្វែងរកអត្ថន័យនៅពេលក្រោយមកក៏ដោយ តែក្រុមជំនុំអាចនឹងរកឃើញវា។ (ច) ព្រឹត្តិការណ៍ដែលបានកត់ត្រាក្នុងបទគម្ពីរជាញឹកញាប់រួមបញ្ចូលទាំងការបង្រៀនទូទៅ ។ (ឆ) ដើម្បីស្វែងយល់ពីអត្ថន័យដ៏ជ្រាលជ្រៅ អ្នកបកស្រាយគួរតែស្រាវជ្រាវរកបរិបទឱ្យបានល្អ។ បរិបទមានន័យថា លក្ខណៈនៃទំនាក់ទំនងរវាងពាក្យខាងលើ ទៅនិងពាក្យខាងក្រោម។ គាត់គួរតែផ្តោតលើការពិតដែលថា តើបរិបទគ្រាន់តែជាដំណើរការ ឬពាក្យផ្ទុយ។ (ជ) អ្នកបកស្រាយអាចទាយអ្វីមួយដើម្បីស្វែងរកអត្ថន័យនៃអត្ថបទ នោះមានន័យថាអត្ថបទដែលគាត់អានមិនបង្ហាញអត្ថន័យ។ គាត់អាចទាយពាក្យត្រឹមត្រូវសម្រាប់សួរពីអ្វីដែលអត្ថបទមិនប្រាប់ពីពាក្យដើម។ ប៉ុន្តែវាគួរតែប្រយ័ត្នផងដែរ។ (ឈ) ដោយសារពាក្យក្នុងសំបុត្ររួមមានការដាស់តឿន និងការពិភាក្សា ត្រង់នោះអាចរកឃើញអត្ថន័យដែលទាក់ទងនឹងអត្ថបទផ្ទាល់។ នៅទីនោះ វាមានភាពងាយស្រួលជាងដំណឹងល្អមួយ ដើម្បីស្វែងរកអត្ថន័យសំយោគ។ អ្នកបកស្រាយគួរសួរក្នុងផ្នែកនេះដោយខ្លួនឯងថា “តើវគ្គបំណងនៃសំបុត្រនេះធ្វើអ្វី? តើអ្នកនិពន្ធឆ្លើយយ៉ាងណា?” នៅពេលយើងគិតពីវា នោះយើងនឹងដឹងពីអត្ថន័យសំយោគយ៉ាងងាយស្រួល។ (ញ) កាលដែលអ្នកបកស្រាយកាត់ស្រាយសម្ភាររបស់ហោរា គាត់គួរពិចារណាតាមដានរឿងដូច

តទៅនេះ។ ទំនាយ នៅក្នុងប្រភេទ ដែលទាក់ទងទៅនឹងបច្ចុប្បន្ន។ ម្យ៉ាងទៀត ទំនាយមិនអាចជួយអ្វីបានក្រៅពីនិយាយអំពីអនាគតជាមួយនឹងសម្ភារៈនាសម័យបច្ចុប្បន្ននាពេលនោះទេ។ ដូច្នោះហើយវាត្រូវបានសរសេរដោយពាក្យប្រៀបធៀប។ មិនត្រឹមតែប៉ុណ្ណោះ ពេលខ្លះវាអាចត្រូវបានបង្ហាញដោយកំណាព្យ ឬនិមិត្តសញ្ញាផង។ ដូច្នេះ អ្នកបកប្រែមិនគួរមើលទៅទំនាយដែលសរសេរទុកដូចជាជាប្រវត្តិសាស្ត្រនៅសម័យបច្ចុប្បន្ននោះឡើយ។ បើគាត់មើលទំនាយដោយខុស វានឹងបំផ្លាញចរិតលក្ខណៈនៃទំនាយ។ មូលហេតុដែលទំនាយប្រើប្រវត្តិសាស្ត្រពិតគឺដើម្បីនិយាយពីអនាគត។ ដូច្នេះ ទំនាយនៃគម្ពីរសញ្ញាថ្មី ជួនកាលបានប្រើសម្ភារៈនៃគម្ពីរសញ្ញាចាស់។ ក្នុងទំនាយ ប្រសិនបើគាត់ស្វែងរកអត្ថន័យសំយោគ នោះវាសំខាន់ជាងការស្វែងរកខ្លឹមសារដែលសម្រេចបាន គឺគាត់ស្វែងរកអត្ថន័យនៃខ្លឹមសារដែលគាត់សិក្សាអំពីនិមិត្តសញ្ញា ឈ្មោះ ព្រឹត្តិការណ៍ ឈ្មោះប្រទេស និងឈ្មោះផ្ទាល់ខ្លួនជាដើម។ ហើយយើងគួរចងចាំថាអត្ថន័យសំយោគត្រូវបានលាក់នៅក្នុងនិមិត្តសញ្ញាដែលអាចមើលឃើញ ប៉ុន្តែវាមិនមែនជានិមិត្តសញ្ញាផ្ទាល់នោះទេ។ ជាឧទាហរណ៍ នៅពេលយើងពិនិត្យមើលទំនាយរបស់ម៉ាថាយ ជំពូកទី 24 នោះយើងងាយស្រួលគិតដល់ព្រឹត្តិការណ៍ដែលបែងចែករវាងការបំផ្លិចបំផ្លាញនៃក្រុងយេរូសាឡិម និងការបំផ្លិចបំផ្លាញនៅគ្រាចុងក្រោយ។ ដូចដែលយើងគិតពីវា គាត់បានបំបែកចេញនូវភាពសាមញ្ញនៃទំនាយ។ ទំនាយអំពីការបំផ្លិចបំផ្លាញនៃក្រុងយេរូសាឡិមគឺជានិមិត្តសញ្ញានៃការបំផ្លិចបំផ្លាញនៅគ្រាចុងក្រោយនៃពិភពលោកនេះ។ ទំនាយដូចដែលមិនបានផ្តល់មកយើងឱ្យបានគ្រប់គ្រាន ឱ្យយើងមានការឆ្ងល់ចង់ដឹង វាបង្ហាញពីការពិតនៃគ្រាចុងក្រោយ ហើយក្នុងពេលតែមួយ វាធ្វើឱ្យយើងមានឥរិយាបថត្រឹមត្រូវនៅក្នុងជីវិតពិតនាពេលបច្ចុប្បន្ននេះពីមនសិការនៃគ្រាចុងក្រោយ។

6. វិធីសាស្ត្រនៃការកាត់ស្រាយវិវរណៈរបស់យ៉ូហាន

នៅក្នុងការបកស្រាយកណ្ឌគម្ពីរ គំនិតរបស់អ្នកវិទូត្រូវបានបែងចែក។

1. ការបកស្រាយដើម្បីមើលទៅដូចជាការសង្ខេប
អ្នកដែលមានទស្សនៈបែបនេះបាននិយាយថា ក្នុងវិវរណៈរបស់យ៉ូហាន ផ្នែកទីមួយ និងផ្នែកចុងក្រោយមិននិយាយពីខ្លឹមសារខុសគ្នានោះទេ ប៉ុន្តែមានខ្លឹមសារដូចគ្នាវិញ។ ជាឧទាហរណ៍ គ្រោះនៃចាននានាបាននិយាយម្តងហើយម្តងទៀតដល់គ្រោះនៃត្រែ។ ប៉ុន្តែនៅពេលដែលយើងឃើញ គឺវិវរណៈមានភាពជឿជាក់អស់កល្បជានិច្ច។
2. ក្រុមនៃសម័យកាលប្រវត្តិសាស្ត្រដូចគ្នា។ នៅក្នុងក្រុមនេះ ព្រឹត្តិការណ៍នៃអនាគតរបស់គាត់ និងព្រឹត្តិការណ៍ដែលកើតឡើងនៅសម័យរបស់គាត់នៅក្នុងវិវរណៈត្រូវបានសរសេរចុះមកដោយអ្នកនិពន្ធ។ ក្រុមនេះបញ្ចូលអ្នកដែលជឿលើហេតុផលពីព្រោះកណ្ឌគម្ពីរនេះជាទំនាយ។ (1:3)
3. ក្រុមនៃប្រព័ន្ធប្រវត្តិសាស្ត្រក្រុមជំនុំ។ អ្នកប្រាជ្ញនៃក្រុមនេះបាននិយាយថា ខ្លឹមសារនៃវិវរណៈគឺជានិមិត្តសញ្ញានៃព្រឹត្តិការណ៍ប្រវត្តិសាស្ត្រនៅក្នុងគំនិតនៃក្រុមជំនុំ។ ជាឧទាហរណ៍ ខ្លឹមសារនៃវិវរណៈនៃត្រាប្រាំមួយដែលបានកត់ត្រានៅក្នុងជំពូកទី 6 ចង្អុលទៅនយោបាយកំណែទម្រង់ដែលអធិរាជដ៏អស្ចារ្យ ខនស្តែនធីន (ព្រះចៅអធិរាជរ៉ូម) ដែលបានតាំងសាសនាគ្រីស្តជាសាសនានៃអាណាចក្រ។ យើងគិតថាការបកស្រាយអំពីប្រវត្តិក្រុមជំនុំគឺសមហេតុផល។ ប៉ុន្តែវាពិបាកដែលខ្លឹមសារនៃវិវរណៈត្រូវបានសម្រេចដោយព្រឹត្តិការណ៍នៃប្រវត្តិសាស្ត្រក្រុមជំនុំទាំងស្រុង។
4. ប្រព័ន្ធខាងព្រលឹងវិញ្ញាណ

ក្រុមនេះមិនឃើញថាខ្លឹមសារនៃវិវរណៈគឺជាទំនាយនៃព្រឹត្តិការណ៍ប្រវត្តិសាស្ត្រនោះទេ ប៉ុន្តែជានិមិត្តសញ្ញានៃការបង្រៀនខាងវិញ្ញាណនៅក្នុងដំណឹងល្អនៃគ្រីស្ទសាសនាវិញ។ ប៉ុន្តែ វិវរណៈលាតត្រដាងពីព្រឹត្តិការណ៍ដែលនឹងត្រូវកើតឡើងរហូតដល់ការយាងមកជាលើកទីពីររបស់ព្រះគ្រីស្ទ ជាជាងមេរៀនខាងវិញ្ញាណ។

5. ប្រព័ន្ធរបស់អ្នកខាងអនាគត ក្រុមនេះនិយាយថា ខ្លឹមសាររបស់វិវរណៈចង្អុលទៅកាន់ព្រឹត្តិការណ៍ដែលកើតឡើងដោយផ្ទាល់ពីមុននិងបន្ទាប់ពីការយាងមកលើកទីពីររបស់ព្រះគ្រីស្ទជាចម្បង។ អ្នកប្រាជ្ញនៃក្រុមនេះមានទំនោរទៅរកការប្រៃបែបអក្សរសាស្ត្រ។ ពួកគេមើលឃើញថា ព្រះវិហារនៅក្នុងវិវរណៈជាព្រះវិហារដែលនឹងត្រូវបានកសាងឡើងវិញនៅក្រុងយេរូសាឡិម ហើយថាអ៊ីស្រាអែលជាជាតិសាសន៍យូដាពិតៗ។ ការបកស្រាយន័យត្រង់ជ្រុលបែបនេះជាការបរាជ័យរបស់ក្រុមនេះ។ តែវាជាទស្សនៈត្រឹមត្រូវនៃក្រុមនេះដែលថា វិវរណៈជាសញ្ញាសម្គាល់ពីព្រឹត្តិការណ៍ដែលនឹងត្រូវកើតឡើងដោយផ្ទាល់មុននិងក្រោយមក។

6. នៅក្នុងចំណោមវិធីសាស្ត្រនៃការបកស្រាយទាំងអស់ ជាពិសេស យើងពិចារណាពីទស្សនៈនៃប្រព័ន្ធអ្នកគិតខាងអនាគតជាសំខាន់ តែផ្នែកខ្លះនៃទស្សនៈក្រុមនេះពីប្រវត្តិសាស្ត្រក្រុមជំនុំ និងក្រុមនៃការបកស្រាយខាងព្រលឹងវិញ្ញាណគួរតែត្រូវបានលើកឡើងមក។
7. ចំនួន និងសញ្ញាសម្គាល់នៃវិវរណៈរបស់យ៉ូហាន

វិវរណៈចេញមកជាមួយនឹងសញ្ញាសម្គាល់ដោយលេខជាច្រើន

1. លេខ 3 ហាក់បីដូចជាភាពពេញលេញរបស់ព្រះ។ អេសាយ 6:3 បង្ហាញថា កាលដែលពួកគេសរសើរដំកើងព្រះ នោះពួកគេបង្ហាញថា “បានបរិសុទ្ធ” ចំនួនបីដ

ង។ វាមានន័យថា ពួកគេសរសើរដង្ហើងព្រះត្រៃឯកថាជាព្រះពិត មិនត្រឹមតែប៉ុណ្ណោះ គឺដែលថា ព្រះគ្រីស្ទមានហាន:បីផងដែរ (ជាសង្ឃ ជាស្តេច និងជាហោរា) បង្ហាញពីអត្តន័យ។

2. លេខ 4 ចង្អុលទៅកាន់លោកិយនៃគ្រប់របស់ដែលត្រូវបានបង្កើតមកទាំងអស់។ នៅផ្នែកផ្សេងទៀតនៃបទគម្ពីរ ពាក្យថា “ទិសទាំងបួន” ត្រូវបានប្រើ។ (អេសាយ 11:12, អេសេគាល 7:2)។ វិវរណៈក៏ប្រើលេខ 4 កាលដែលវានិយាយពីគ្រប់របស់ដែលត្រូវបានបង្កើតមកទាំងអស់និងផែនដីផង។ (វិវរណៈ 7:4)

3. លេខ 7 បញ្ជាក់ពីទំនាក់ទំនងយ៉ាងពេញលេញរវាងព្រះនិងមនុស្ស។ ដូច្នេះ ថ្ងៃទីប្រាំពីរជាសញ្ញានៃថ្ងៃសប្ប័ថ (លោកុប្បត្តិ 2:3)។ វិញ្ញាណទាំងប្រាំពីរជាឈ្មោះដែលមានន័យថា ជាកិច្ចការពេញលេញនៃព្រះវិញ្ញាណបរិសុទ្ធមកដល់មនុស្ស។

4. ពាក់កណ្តាលនៃប្រាំពីរឆ្នាំ ដែលហៅថា “ពាក់កណ្តាលនៃបីឆ្នាំ” (ឬ ពាក់កណ្តាលនៃបីថ្ងៃ) ជាសញ្ញានៃពេលការគ្មានសម្រាក ការរងទុក្ខ និងសេចក្តីលំបាកវេទនា (យោងតាម លូកា 4:25 យ៉ាកុប 5:17, 7:25, 12:7 វិវរណៈ 12:14)។ អំឡុងពេលនេះគឺបីឆ្នាំកន្លះត្រង់ៗ តែមានអ្នកវិទូខាងអរតូដកជាច្រើនចាត់ទុកលេខនេះជាអត្តន័យសម្រាប់សម្គាល់។

5. លេខ 6 និង លេខ 12 លេខ 6 ជាពាក់កណ្តាលនៃលេខ 12។ លេខ 12 មានន័យថាជាប្រព័ន្ធពេញលេញ និងការសាងសង់ដែលត្រូវបានសម្រេចដោយការរើសតាំងរបស់ព្រះ និងសិស្សទាំង 12 និង លេខ 144000 (ចំនួនដែលមានលេខ 12 ជាលេខមូលដ្ឋាន)។ ផ្ទុយពីវា លេខ 6 មិនមែនដោយការរើសតាំងរបស់ព្រះទេ តែដោយមនុស្សនិយមវិញ ដែលជានិម្មិតសញ្ញានៃការលះបង់ ការ

កសាង ប្រព័ន្ធ ។ល។ ផ្នែកទ្វេរជាបីនេះចង្អុលទៅកាន់សញ្ញានៃអ្នកប្រឆាំងនឹងព្រះគ្រីស្ទ (យោងតាម វិវរណៈ 13:18)។

8. ភាពមិនអាចទទួលយកបាននៃការបកស្រាយដែលព្យាយាមរាប់ថ្ងៃនៃការយាងមកលើកទីពីររបស់ព្រះគ្រីស្ទ។

យើងគួរតែមានការទប់ចិត្តខ្លួនឯងអំពីចំណេះដឹងនេះ។ (2ពេត្រុស 1:6)។ អ្នកនោះមិនមែនជាអ្នកដែលអាចធ្វើគ្រប់ការទាំងបាននោះឡើយ។ ជាពិសេសពីកាលបរិច្ឆេទនៃព្រឹត្តិការណ៍អនាគត គឺមានតែព្រះទេដែលដឹង តែមនុស្សមិនអាចដឹងបានឡើយ។ ដូច្នេះ ព្រះយេស៊ូវមានបន្ទូលថា “ឯត្រង់ថ្ងៃនឹងពេលកំណត់ នោះគ្មានអ្នកណាដឹងទេ ទោះទាំងពួកទេវតាដែលនៅស្ថានសួគ៌ ក៏មិនដឹងដែរ ជ្រាបតែព្រះវរបិតានៃខ្ញុំប៉ុណ្ណោះ” (ម៉ាថាយ 24:36)។ ហើយទ្រង់មានបន្ទូលថា “ដូច្នេះ ឱ្យចាំយាម ដ្បិតអ្នករាល់គ្នាមិនដឹងជាពេលណាដែលព្រះអម្ចាស់នៃអ្នករាល់គ្នានឹងយាងមកទេ។ ចូរដឹងសេចក្តីនេះចុះ បើម្ចាស់ផ្ទះបានដឹងជាចោរនឹងមកនៅយាមណា ណោះគេនឹងបានចាំយាម មិនឱ្យចោរទំលុះចូលផ្ទះបានទេ” (ម៉ាថាយ 24:42, 43)។ ដូចជាយើងបានឃើញសម្តីរបស់អ្នកជឿរហូតដល់ការយាងមកលើកទីពីររបស់ព្រះយេស៊ូវផងដែរ គឺពួកគេមិនដឹងពីកាលបរិច្ឆេទទេ។ ប្រៀបដូចជាគោលលិទ្ធស្រដៀងគ្នានិយាយពីវាបន្ទាប់ពីព្រះគ្រីស្ទទ្រង់បានមានព្រះជន្មរស់ឡើងវិញ។ កិច្ចការ 1:6-7 បាននិយាយថា “ដូច្នេះ កាលពួកសាវកបានប្រជុំគ្នា នោះក៏ទូលសួរថា ព្រះអម្ចាស់អើយ តើនៅគ្រានេះឬអី ដែលទ្រង់នឹងតាំងនគរឱ្យសាសន៍អ៊ីស្រាអែលឡើងវិញនោះ។ តែទ្រង់មានបន្ទូលឆ្លើយថា មិនត្រូវឱ្យអ្នករាល់គ្នាដឹងពេល ដឹងកំណត់ ដែលព្រះវរបិតាបានទុកនៅក្នុងអំណាចរបស់ទ្រង់នោះឡើយ”។ នៅត្រង់នេះថា “មិនត្រូវឱ្យអ្នករាល់គ្នាដឹងពេល ដឹងកំណត់” គឺថា

អ៊ូក វីម៉ូន អេស្ទីន ក្នុន (Οὐχ ὑμῶν ἐστιν γνῶναι) នៅក្នុងភាសាក្រិក ការនេះមានន័យថា ការដែលដឹងពីវា នោះមិនមែនជារបស់អ្នកឡើយ។

9. លក្ខណៈរបស់អក្សរសាស្ត្រនៃវិវរណៈ ដែលហៅថាអក្សរសាស្ត្រវិវរណៈ មិនមែនជាក្រាំងទេ

អក្សរសិល្ប៍វិវរណៈដែលមិនមែនជាក្រាំង គឺជាសៀវភៅនៅសម័យពាក់កណ្តាល (សម័យកណ្តាលរវាងគម្ពីរសញ្ញាថ្មី និងគម្ពីរសញ្ញាចាស់) មនុស្សមួយចំនួនបានបោះពុម្ពសៀវភៅដែលបានខ្ចីឈ្មោះដ៏អស្ចារ្យនៃសម័យបុរាណ ហើយភ្ជាប់ជាមួយពួកគេ។ សំខាន់គឺដូចខាងក្រោមនេះ។

1. កណ្ឌគម្ពីរអេណុក។ សៀវភៅនេះត្រូវបានរកឃើញថ្មីៗនេះនៅ អាប៊ីស្ស៊ៀ។ នៅឆ្នាំ 1822 សៀវភៅនេះត្រូវបានបោះពុម្ពជាលើកដំបូង។ សៀវភៅនេះអះអាងថាជាការបង្រៀនរបស់អេណុក ដែលជាខ្សែស្រឡាយទីប្រាំពីររបស់អ័ដាម។ មានការបង្រៀនដែលអេណុកបានឡើងទៅកាន់ស្ថានសួគ៌ ហើយបានជជែកជាមួយនឹងព្រះ និងរឿងមួយចំនួនទៀត។ ប៉ុន្តែសៀវភៅនេះមិនអាចទទួលស្គាល់ជាផ្លូវការឡើយ។ អ្នកវិទូសាស្ត្រយូដាបុរាណក៏មិនបានចាត់ទុកវាថាជានៅក្នុងខ្សែនៃជំនឿដែរ។
2. ការឡើងទៅរបស់អេសាយ

កណ្ឌគម្ពីរនេះត្រូវបានកត់ត្រាពីការបង្រៀនដូចជាបំណងដែលស្តេចហេសេគានៅពេលស្លាប់របស់ទ្រង់បានផ្តល់ដល់បុត្ររបស់ទ្រង់ ម៉ាណាសេ ហើយក្រោយមក ការបង្រៀនដែលអេសាយបានស្លាប់ដោយសារអំបោះចេញពីវា។ តែមួយនេះក៏មិនត្រូវបានទទួលស្គាល់ដែរ តាំងពីសម័យបុរាណមកម្ល៉េះ។

3. លើកលែងពីការទាំងនេះ មានអក្សរសាស្ត្រមួយចំនួនរបស់អាផូគ្រីផាដូចតទៅនេះ។

ដ្បិតឈ្មោះ– សៀវភៅនៃអាថ៌កំបាំងរបស់អេណុក សៀវភៅ Slavonic របស់អេណុក សៀវភៅជូប៊ីលី ការប៉ាន់ស្មានរបស់ម៉ូសេ កណ្ឌគម្ពីរនៃឰយុកោទាំង12 ទំនុកដំកើងរបស់សាឡូម៉ូន អេសទ្រុសទី2 គ្រោះចង្រៃរបស់បារុក ស៊ីរីគ្រោះចង្រៃរបស់បារុក គ្រោះចង្រៃរបស់អ័ប្រាហាំ។

កណ្ឌគម្ពីរទាំងនោះសុទ្ធតែឯកសារខុសឆ្គង និងមានអ្នកនិពន្ធដែលមិនត្រូវបានប្រាប់ឈ្មោះឡើយ (2) មិនត្រឹមតែប៉ុណ្ណោះ អ្នកវិទូសាសន៍យូដាបុរាណមិនបានទទួលស្គាល់សៀវភៅទាំងនេះទុកជាក្រាំងគម្ពីរទេ (3) កាលដែលយើងពិនិត្យមើលពួកវា គឺមានខ្លឹមសារដែលល្ងីល្ងើជាច្រើន។ (4) កណ្ឌគម្ពីរសញ្ញាថ្មីមិនបានដកស្រង់ខ្លឹមសាររបស់ឯកសារនោះឡើយ។ ដូច្នេះ ឯកសារទដូច្នេះមិនអាចប្រៀបធៀបនឹងវិវរណៈរបស់យ៉ូហានបានឡើយ។

10. ការសិក្សាទ្រឹស្តីនៃគ្រាចុងក្រោយដែលត្រូវបានមើលឃើញនៅក្នុងផ្នែកផ្សេងទៀតនៃបទគម្ពីរ

ផ្នែកនេះត្រូវបានលើកមកទៅកាន់ប្រព័ន្ធសាសនៈវិទ្យាដោយលោក ល្វីស បឺខហ្វ

1. សញ្ញានៃការយាងមកលើកទីពីរបស់ព្រះគ្រីស្ទ

1) ការប្រកាសដំណឹងល្អដល់សាសន៍ដទៃ (ម៉ាថាយ 24:14, ម៉ាកុស 13:10 រ៉ូម 11:25)

2) ទុក្ខវេទនានិងការក្បត់ (ម៉ាថាយ 24: លូកា 18:8 2ថែស្សាឡូនិច 2:3)

3) បើកបង្ហាញពីមនុស្សមានបាប (2ថែស្សាឡូនិច 2:3)

2. រូបភាពនៃការយាងមកលើកទីពីររបស់ព្រះគ្រីស្ទ និងគោលបំណងរបស់វា

1) គ្រានៃការយាងមកលើកទីពីរបស់ព្រះគ្រីស្ទមិនត្រូវបានបើកបង្ហាញដល់មនុស្សទេ។ (ម៉ាថាយ 24:36)

2) ការយាងមកដែលមាននូវសេចក្តីលម្អិត។ ទ្រង់បានយាងមកបែបជារូបកាយដែលត្រូវបានរស់ពីស្លាប់ឡើងវិញ មិនត្រឹមតែជារូបអង្គខាងវិញ្ញាណទេ មិនមែនបែបចិត្តសាស្ត្រឡើយ (ម៉ាថាយ 22:44 កិច្ចការ 1:11 1កូរិនថូស 15:23, ភីលីព 3:20, កូឡូស 3:4 1ថែស្សាឡូនិច 2:19, 4:15-17 2ធីម៉ូថេ 4:8 ហេព្រើរ 9:28)។

3) ការយាងចុះរបស់ទ្រង់អាចនឹងមើលឃើញដោយមនុស្សគ្រប់គ្នា។ (ម៉ាថាយ 24:30, 26:64, ម៉ាកុស 13:26, លូកា 21:27, កិច្ចការ 1:11 កូឡូស 3:4, ទីតុស 2:13 ហេព្រើរ 9:28, វិវរណៈ 1:7)។

4) ទ្រង់យាងមកនៅក្នុងសិរីល្អនិងព្រះចេស្តា។ (ម៉ាថាយ 24:30, 1ថែស្សាឡូនិច 3:13, 4:16 2ថែស្សាឡូនិច 1:7, 10 ហេព្រើរ 9:28, វិវរណៈ 19:11-16)។

5) ព្រះគ្រីស្ទដែលមានព្រះជន្មរស់ពីស្លាប់ឡើងវិញ ហើយទ្រង់នឹងកាត់ទោសពួកគេ (ម៉ាថាយ 13:49, 50, 25:14-16, លូកា 9:26, 19:11-27, យ៉ូហាន 5:25-29 កិច្ចការ 17:33, រ៉ូម 2:3-16, 1កូរិនថូស 4;5, 115:13 2កូរិនថូស 5:10, ភីលីព 3:20, 21, 1ថែស្សាឡូនិច 4:13-17 2ថែស្សាឡូនិច 1:7-10, 2:7,8 2ធីម៉ូថេ 4:1, 8 2ពេត្រុស 3:10-13 យូដាស 1:14,15 វិវរណៈ 20:11-15 22:12)។

3. ហេតុការណ៍ដែលត្រូវកើតឡើងបន្ទាប់ពីការយាងមកលើទីពីររបស់ព្រះគ្រីស្ទ។

1) ការរស់ឡើងវិញរបស់មនុស្សស្លាប់

[1] ភស្តុតាងរបស់ព្រះគម្ពីរពីការរស់ឡើងវិញមានរឿងជាច្រើន។ គម្ពីរសញ្ញាចាស់ - យ៉ូប 19:25-27, ទំនុកដំកើង 49:15 73:24, 25 សុភាសិត 23:14, អេសាយ 26:19, អេសេគាល 37:14 ដានីយ៉ែល 12:2 ។ល។ និងគម្ពីរសញ្ញាថ្មី យ៉ាកុប 5:29, 6:39, 40:54 11:24, 25 14:3 1កូរិនថូស 15: 2កូរិនថូស 5:1-10, 1ថែស្សាឡូនិច 4:13-17 20: វិវរណៈ4-6 ,13 ។ល។

[2] សភាពនៃសេចក្តីរស់ឡើងវិញ (ក) វាជាសេចក្តីរស់ឡើងវិញជារូបកាយ (រ៉ូម 8:23 1កូរិនថូស 6:14-20, 15:53) (ខ) អ្នកជឿនឹងត្រូវបានរស់ឡើងវិញ និងមនុស្សទុច្ចរិតនឹងត្រូវបានរស់ឡើងវិញ តែអ្នកជឿនឹងទទួលបានសេចក្តីរស់ឡើងនៃសិរីល្អ តែមនុស្សទុច្ចរិតនឹងត្រូវបានរស់ឡើងវិញនៅក្នុងការដាក់ទោសអស់កល្បជានិច្ច (យ៉ូហាន 5:26-29) (គ) ហើយគ្រានៃសេចក្តីរស់ឡើងវិញ ទ្រឹស្តីនៃគ្រាមុនរាជ1000ឆ្នាំនិយាយថា នៅពេលចាប់ផ្តើមនៃនគររបស់ព្រះ អ្នកជឿនឹងត្រូវបានរស់ឡើងវិញ (វិវរណៈ 20:1-6) រួចមកនគររបស់មនុស្សទុច្ចរិតនឹងត្រូវបានរស់ឡើងវិញដែរ (វិវរណៈ 20:12, 13)។

2) ការវិនិច្ឆ័យទោសចុងក្រោយ

[1] ទ្រឹស្តីក្នុងការយល់ពីការកាត់ទោស

(a) លោក ស្លេយម៉ាឃើ បានឃើញដូចជាពាក្យប្រៀបធៀបទៅកាន់ការកត់ត្រាព្រះគម្ពីរពីការកាត់ទោស ដែលវាជាសញ្ញានៃការដាច់ចេញពីពិភពនៃក្រុមជំនុំ។ តែទ្រឹស្តីនេះគឺជាការអះអាងខុសដែលយល់ច្រឡំពីកំណត់ត្រាយ៉ាងច្បាស់របស់បទគម្ពីរ ដែលមិនអើពើនឹងការកាត់ទោសដែលត្រូវបានផ្លាស់ប្តែងអស្ចារ្យដល់លោកិយនេះ។

(b) លោក ស្កីលឺ និយាយថា ការកត់ត្រាពីការកាត់ទោសនៅក្នុងព្រះគម្ពីរជាការអស្ចារ្យទូទៅនៃប្រវត្តិសាស្ត្ររបស់លោកិយ តែម្នាក់ដែលគ្មានគំនិតប្រឆាំងមិនអាចមើល

ឃើញការកត់ត្រានៃការកាត់ទោសទេ ដូច្នេះការកត់ត្រារបស់ព្រះគម្ពីរមិនចង្អុលទៅកាន់ការលូតលាស់ និងសេចក្តីវិនាសនៅក្នុងប្រវត្តិសាស្ត្រទេ តែដោយកាត់ចេញបន្ទាត់នៃប្រវត្តិសាស្ត្រ នោះលោកិយថ្មីនឹងមកដល់ដោយការពិតដែលអស្ចារ្យ។

[2] ចៅក្រៃ ជាព្រះគ្រីស្ទដែលពួកទេវតាបម្រើ និងពួកបរិសុទ្ធបានចូលរួមទៅក្នុងសកម្មភាពនៃការកាត់ទោសរបស់ព្រះគ្រីស្ទផង (ម៉ាថាយ 13:41, 42, 24:31 25:31, 32, យ៉ាកុប 5:27 កិច្ចការ 10:42, 17:3 ភីលីព 2:10, 2ធីម៉ូថេ 4:1 វិវរណៈ 20:4 ទំនុកដំកើង 149:5-9)។

3) ពិភពលោកចុងក្រោយ

[1] កន្លែងដែលពួកមនុស្សទុច្ចរិតទៅនោះគឺជាស្ថាននរក។ បទគម្ពីរហៅថា “គុកភ្លើង” (ម៉ាថាយ 10:42) និងបឹងភ្លើង (វិវរណៈ 20:14, 15)។

(a) វាជាកន្លែងដែលត្រូវបានកាត់ចេញពីព្រះគុណរបស់ព្រះ។

(b) វាជាកន្លែងទៅកាន់សេចក្តីទុក្ខព្រួយដែលនឹងមកជាលទ្ធផលនៃអំពើបាប។

(c) វាជាកន្លែងដែលទាំងព្រលឹងនិងរូបកាយត្រូវបានធ្វើទុក្ខជាមួយគ្នា។

(d) វាជាកន្លែងដែលមានទុក្ខព្រួយ ការបាក់ទឹកចិត្ត និងកាសង្កៀតធ្មេញ (យោងតាមម៉ាថាយ 11:22, 24, 18:9 ម៉ាកុស 9: 42-44, 47, 48 លូកា 13:28, 16:23, 28, 2 ថែស្សាឡូនិច 1:9, វិវរណៈ 14:11 21:8)។

(e) វាជាកន្លែងដែលមានទុក្ខវេទនានេះអស់កល្បជានិច្ច (ម៉ាថាយ 25:46 ម៉ាកុស 9:42-48)។

[2] កន្លែងដែលមនុស្សសុចរិតចូលគឺ “កន្លែងដែលថ្មី” (ម៉ាថាយ 19:28) “កន្លែងដែលមិនរង្គើរ” (ហេព្រើរ12:27) “កន្លែងថ្មីនៃស្ថានសួគ៌និងផែនដីថ្មី” (2ពេត្រុស 3:13 វិវរណៈ 21:1)។

(a) វាជាកន្លែងមួយ និងជាទីស្នាក់នៅផង (ម៉ាថាយ 22:11-13 25:10-12 យ៉ូហាន 14:3-4)។

(b) វាជាកន្លែងដែលរីករាយនឹងជីវិតអស់កល្បជានិច្ច (វិវរណៈ 21:3)។

11. ការសិក្សាពីខ្លឹមសារនៃវិវរណៈរបស់យ៉ូហាន

ផ្នែកទី 1 សេចក្តីផ្តើម (1:1-20)

ផ្នែកទី 2 ក្រុមជំនុំទាំងប្រាំពីរ (2:1-3:22)

ផ្នែកទី 3 ចៅក្រម និងអ្នកបើកបង្ហាញនូវការវិនិច្ឆ័យទោស (4:1-5:14)

ផ្នែកទី 4 ការបើកសៀវភៅដែលបិទដោយត្រាប្រាំពីរ (6:1-8:5)

ផ្នែកទី 5 គ្រោះចង្រៃនៃត្រែ (8:6-11:19)

ផ្នែកទី 6 ទុក្ខវេទនានៃក្រុមជំនុំ (12:1-13:18)

ផ្នែកទី 7 ការកំសាន្តចិត្តដល់ពួកបរិសុទ្ធ និងការព្រមានពីការកាត់ទោសនៃគ្រាចុងក្រោយ (14:1-20)

ផ្នែកទី 8 គ្រោះចុងក្រោយ (15:1—19:10)

ផ្នែកទី 9 ការយាងមកលើកទីពីររបស់ព្រះគ្រីស្ទនិងការកាត់ទោស (19:11-20:15)

ផ្នែកទី 12 ពិភពលោកនៃការកំសាន្តដែលគ្មានកំណត់ (21:1- 22:5)

ផ្នែកទី 11 សេចក្តីសរុប (22:6-21)

សៀវភៅយោង

1. Grejedanus, Commentaar op Het Neuwe Testament (Openbaring)
2. Ringnalda, Het Koningcharp Van Christus.
3. R. J. Van Der Meulen, De Openbaring in Het Laatste BijBelboek
4. E. Smilde, Leven In de Johanneische Geshriften
5. Mathias Rissi, Zeit und Gechichte in der Offenbarung des Johannes
6. Albertus Pieters, Studies in the revelation of St, John
7. W. Hendricksen, More than Conquerers
8. H. b Swete, The Apocalypse of st. John
9. R. H. Charles, A Critical nd Exegetical Commentary on The Revelation of St. John
10. Beckwith, The Apocalypse of John
11. Abraham Kuyper, The Revelation of St. John
12. James Moffatt, The Expositors Greek Testament (Revelation of St. John)
13. Lohmeyer, Hand Book Zum Neuen Testament (Die Offenbarung Des Johnnes)
14. Alford's Greek Testament
15. F. C. Cook, The Bible Commentary
16. Lange, Commentary on The Holy Scriptures

17. Dusterdiek, In the Series of Meyer's Commentary of the New Testament (Revelation)
18. Bengel, Gnomon
19. Matthew Henry, Commentary on the New Testament
20. Herman Bavinck, Gereformeerde Dogmatiek
21. K Schilder, Wat is de Hemel?
22. Calvin, The Institutes of Christian Religion

សេចក្តីអធិប្បាយពន្យល់នៃវិវរណៈរបស់យ៉ូហាន

ផ្នែកទី 1

ផ្តើមសេចក្តី 1:1-20

ជំពូក 1

1. វិវរណៈ និងអ្នកនិពន្ធ (1-3)
2. ការប្រសិទ្ធពរជ័យ ការសរសើរដំកើង (4-6)
3. ការប្រកាសនៃគំនិតសំខាន់នៃកណ្ឌគម្ពីរនេះ (7, 8)
4. ការបើកសម្តែងនៃអ្នកបើកសម្តែង (9-20)

ការបកស្រាយ

1 ការបើកសម្តែងរបស់ព្រះយេស៊ូវគ្រីស្ទ វាមានន័យថាជាព្រះបន្ទូលដែលព្រះយេស៊ូវទ្រង់បានបើកបង្ហាញ។ ពាក្យថា "ការបើកសម្តែង" គឺថា អាផូខាលូផសីស (ἀποκάλυψις) ក្នុងភាសាក្រិក ដែលមានន័យថា ដើម្បីបង្ហាញការដែលលាក់កំបាំងដោយត្រូវបានបើកចំហរ។ (Lohmeyer) តើអ្នកណាដឹងពីហេតុការណ៍ចុងក្រោយនៅទីបញ្ចប់នៃលោកិយនេះ? ប៉ុន្តែប្រសិនបើព្រះបង្ហាញការទាំងនោះដល់ពួកគេ គេអាចដឹងបានដោយអំណាចដែលធ្វើឱ្យគាត់បានដឹងដែលអំណាចនោះជារបស់ទ្រង់។ ដូច្នេះ ចាប់តាំងពីបុរាណមកទស្សនៈវិទ្យា និងវិទ្យាសាស្ត្រមិនបានដឹងការនេះទេ ពីព្រោះការអ្វីដែលព្រះកំណត់ទុក នោះគ្មានអ្នកណាអាចធ្វើរំលងបានទេ។

ចុះតើការបើកសម្តែងនេះបានផ្តល់ដល់អ្នកណា? វាត្រូវបានបើកសម្តែងដល់សាវកយ៉ូហាន។ ដ្បិតអ្នកដែលប្រាប់មកនោះជាសាវក ឥទ្ធិពលដែលមានប្រសិទ្ធិភាពរបស់វាជាផលប្រយោជន៍ដល់អ្នកជឿទូទៅទាំងអស់។ គឺថាវាមិនមែនជាការប្រើប្រាស់របស់ពួកសាវក និងហោរាទេ តែសម្រាប់ជាប្រយោជន៍រួមនៃក្រុមជំនុំទាំងអស់។ ដូច្នេះ អ្នកណាដែលអានវិវរណៈគួរដឹងការពិតថា វាទាក់ទងនឹងគេដោយផ្ទាល់ដូចជាពួកសាវកដែរ។ *ដែលនឹងត្រូវកើតឡើងឆាប់ៗ ។* ពាក្យថា "ត្រូវតែ" គឺ ដេយ (δεῖ) នៅក្នុងភាសាក្រិក ដែលទាក់ទងនឹងភាពចាំបាច់ដែលបានទាយទុករួចហើយ។ នោះគឺជាពាក្យរបស់ ឡូមៀ វាមានការប្រាកដទាំងស្រុងនៃកិច្ចការដែលនឹងធ្វើសម្រេចកិច្ចការដែលព្រះទ្រង់បានកំណត់ទុក។ ((δεῖ p. 8) ទំនាយត្រូវបានកត់ទុកនៅក្នុងសៀវភៅមានអំណាចដែលមិនអាចគេចរួច និងដែលអាចយល់ដល់ ដែលវាមិនអាចនឹងសម្រេចបំពេញដោយតែម្តងទេ អ្នកដែលជឿលើវា ជាមនុស្សដែលមានចំណេះដឹង។ "បន្តិចទៀត" គឺ អេន ថាខាយ (ἐν τάχει) នៅក្នុងភាសាក្រិកត្រូវបានសង្កេតដោយលោក ហ្គ្រេជដានុស ថា "យ៉ាងឆាប់" (វាមិនមានន័យថាជាល្បឿនឆាប់រហ័សនៃការសម្រេចបំពេញទេ តែមានន័យថាជាអំឡុងពេលដែលខ្លី)។ រួចមកខ្ញុំបានគិតថាសម្រាប់ព្រះដើម្បីនឹងសម្រេចសេចក្តីសង្គ្រោះរបស់យើង នោះទ្រង់បានធ្វើគ្រប់ការទាំងអស់ដោយល្បឿនរបស់ព្រះ។ ទ្រង់ធ្វើការដោយខិតខំយ៉ាងស្មោះត្រង់សម្រាប់យើង តែចិត្តដែលតូចចង្អៀតនិងល្ងីល្ងើរបស់យើងបានគិតថា វាយឺតយ៉ាវទៅវិញ។

ដែលព្រះទ្រង់ផ្តល់ដល់គាត់ឱ្យបង្ហាញ "បង្ហាញ" គឺ អេសេម៉ាំនែន (ἐσήμανεν)ក្នុងភាសាក្រិក មានន័យបញ្ជាក់ដោយសញ្ញាសម្គាល់ (ហ្គ្រេជដានុស)។ ដូច្នេះ ជាការត្រឹមត្រូវដែល វិវរណៈរបស់យ៉ូហានគួរតែត្រូវបានបកស្រាយមិនដោយន័យត្រង់ទេ តែដោយន័យបែបជានិមិត្តសញ្ញាវិញ។

តើអ្វីជាគោលបំណងក្នុងការប្រើនិមិត្តសញ្ញានៅក្នុងវិវរណៈរបស់យ៉ូហាន? (1) វាមានបំណង អ្នកណាដែលមានត្រចៀកអាចស្តាប់វាបាន (វិវរណៈ 2:7 ម៉ាថាយ 3:9)។ គឺថា វាមានន័យថា មានតែកូនរបស់ព្រះទេដែលបានទទួលព្រះវិញ្ញាណបរិសុទ្ធ និងមានត្រចៀកខាងវិញ្ញាណដែលអាចយល់បាន។ ពួកគេយល់ការពិតជាច្រើនយ៉ាងច្បាស់ប្រៀបដូចជាការពេលអនាគតត្រូវបានបង្ហាញដោយនិមិត្តសញ្ញា គឺថាពីព្រោះអ្នកដែលមិនចង់បានសេចក្តីពិត នោះវានឹងត្រូវបានលាក់កំបាំង (ម៉ាថាយ 13:1-15)។

2. ប្រាប់តាមព្រះបន្ទូល និងសេចក្តីបន្ទាល់នៃព្រះយេស៊ូវគ្រីស្ទ គឺពីគ្រប់ទាំងសេចក្តីដែលគាត់បានឃើញ។ នៅទីនេះ ឃ្លាបីជាការបញ្ជាក់ផ្សេងទៀតដែលចង្អុលទៅកាន់អត្ថន័យតែមួយ។ ព្រះបន្ទូលរបស់ព្រះបានបង្ហាញដោយការប្រកាសដោយព្រះយេស៊ូវគ្រីស្ទ វាបង្ហាញទៅកាន់សាវកយ៉ូហាន។ ខ្លឹមសារនៃវិវរណៈរបស់យ៉ូហានគឺ ដែលជាទីបន្ទាល់របស់ព្រះអម្ចាស់។

3. មានពរហើយអ្នកណាដែលមើល និងអស់អ្នកដែលស្តាប់ពាក្យទំនាយទាំងនេះ ហើយប្រព្រឹត្តតាមសេចក្តីទាំងប៉ុន្មានដែលកត់ទុកនេះដែរ។

តើអ្វីគឺជាគោលបំណងពាក្យឯកវចនៈថា “អ្នកណាដែលអាន” (ὁ ἀναγινώσκων)” ហើយពាក្យពហុវចនៈថា “អស់អ្នកដែលស្តាប់” (οἱ ἀκούοντες) និង “ហើយអ្នកដែលប្រព្រឹត្តតាម” (τηροῦντες) “សេចក្តីទាំងប៉ុន្មានដែលបានកត់ទុកនេះ” ត្រូវបានប្រើនោះ? វាចង្អុលទៅកាន់រូបភាពថា នៅក្នុងកន្លែងសាធារណៈនៅក្នុងក្រុមជំនុំ មនុស្សម្នាក់អានបទគម្ពីរ និងសមាជិកក្រុមជំនុំជាអ្នកស្តាប់។ លោក សេអូឌ័រ ស្បាញ់ ចង្អុលមកថា ក្រុមជំនុំនៅសតវត្សទី2 ទី3នៅក្នុងបទគម្ពីរអានផ្នែកខ្លះនៃបទគម្ពីរជាងផ្នែក

ផ្សេងទៀតនៃបទគម្ពីរ និងទទួលបានការកំសាន្តចិត្តនៅក្នុងការបៀតបៀន។ ដូចដែលយើងឃើញវា គឺវាជាគោលការណ៍ដើមនៅក្នុងការអានបទគម្ពីរជាសាធារណៈ និងការស្តាប់ការអធិប្បាយដោយការពន្យល់ពីការអធិប្បាយនិងការមួយ។

ដ្បិតដរាបណាលោ នោះជិតមកដល់ហើយ។ ដោយផ្អែកលើចំណុចនេះ លោក ប្រ្គេជដានុស បានចង្អុលទៅការខុសឆ្គងដែលអ្នកប្រាជ្ញមើលទៅកាន់លំនាំប្រវត្តិសាស្ត្របរិសុទ្ធនៃវិវរណៈរបស់យ៉ូហានថាខុស។ ហើយគាត់និយាយថា ហេតុការចាប់ផ្តើមបានកើតឡើងនៅក្នុងអនាគត កិច្ចការនៅគ្រាចុងក្រោយនៃលោកិយនិងទំនាយនានារាប់បញ្ចូលទាំងលោកិយដែលត្រូវមកដល់ផង។ (bestijds spoedig aanvangen zoude te gebeuren, en vervorgens in snel verloop plaate grijpen zoude den ganschen loop des tijds of der eeuwen…)។ ទស្សនៈនេះជាអត្ថន័យយ៉ាងសមស្របនិងទូទៅនៃល្អះនេះ។ ពីព្រោះម្នាក់ដែលសិក្សាពីទំនាយ និងធ្វើតាមគឺជាអ្នកដែលមានពរ។

ក្រុមជំនុំទាំងប្រាំពីរ។ ហេតុអ្វីបានជាទ្រង់ជ្រើសរើសលេខ “ប្រាំពីរ”? បើទោះនៅអាស៊ីមានក្រុមជំនុំផ្សេងៗទៀត (កូឡូស ហេរ៉ាប៉ូលីស ម៉ាក់នីសៀ ត្រូអា ជាដើម) ទ្រង់ជ្រើសយកតែក្រុមជំនុំប្រាំពីរប៉ុណ្ណោះ។

វាច្បាស់ណាស់ថាអ្នកនិពន្ធលោកយ៉ូហានបានគិតពីអត្ថន័យខាងព្រលឹងវិញ្ញាននៃលេខប្រាំពីរ។ អត្ថន័យខាងព្រលឹងវិញ្ញាណនៃលេខប្រាំពីរជានិមិ្មតសញ្ញា (Moffatt, Greijadanus)។ រួចមកក្រុមជំនុំទាំងប្រាំពីរជាតំណាងនៃគ្រប់ក្រុមជំនុំនៃលោកិយទាំងមូល។ លោក A. Kuyper ក៏បាននិយាយនៅក្នុងន័យដូចគ្នាថា “ព្រះគ្រីស្ទមានបន្ទូលពីក្រុមជំនុំប្រាំពីរនៅក្នុងក្រុមជំនុំប្រាំពីរ។ រដ្ឋទាំងប្រាំពីរនេះបើកបង្ហាញពីគ្រប់

គ្រាទាំងអស់ និងគ្រប់តំបន់ទាំងអស់។" (វិវរណៈរបស់អ្នកបរិសុទ្ធ យ៉ូហាន ទំព័រ 42) ។

ទ្រង់ដែលគង់នៅ ក៏គង់នៅតាំងពីដើម ហើយត្រូវយាងមកទៀត (ពី)ពាក្យនេះគឺនៅក្នុងភាសាក្រិកថា អាផូ ហូ អូន ខាយ ហូ ខាយ អូ អែខូមែនូស *(ἀπὸ ὁ ὢν καὶ ὁ ἦν καὶ ὁ ἐρχόμενος,)*។ ទីនេះជាឈ្មោះ អាផូ *(ἀπὸ=* តាមរយៈ*)* ត្រូវបានដាក់នៅលើនាមប្រធាន *(ὁ ὢν καὶ ὁ ἦν καὶ ὁ ἐρχόμενος,)* នៃព្រះនាមបរិសុទ្ធរបស់ព្រះ (ក្រៅពីអាផូ ត្រូវមានថ្នាក់ជានាមដែលដាក់នៅលើធ្នាក់) ជាថ្នាក់ដែលលើកលែង។ ថ្នាក់ដែលលើកលែងត្រូវបានបង្ហាញនៅក្នុងអារម្មណ៍ភ័យខ្លាចដែលនឹងត្រូវរំលងសព្វនាមនៃព្រះវរបិតា។ លោក *Grejidanus* បាននិយាយថា "ឃ្លាបែបនេះគឺមិនគួរប្រើឬ ឬកំហុសមួយនោះទេ...ការនេះចង្អុលទៅកាន់ភាពមិនប្រែប្រួលរបស់ព្រះ *(Openbaring,* ទំព័រ *14)*។ នាមដែលបរិសុទ្ធនេះមានន័យពី ព្រះយេហូវ៉ា *(*יהוה = អង្គដែលមានព្រះជន្មគង់នៅដោយខ្លួនឯង*)* នៅក្នុងសញ្ញាចាស់ (យោងតាម និក្ខមនំ *3:14)*។

ដូច្នេះ ការនេះមានន័យថា ព្រះសម្រេចសេចក្តីសង្គ្រោះទៅតាមការតាំងសញ្ញារបស់ទ្រង់ទៅកាន់រាស្ត្រដែលរើសតាំងរបស់ទ្រង់ដោយគ្មានបំបែកចេញឡើយ (ម៉ាឡាគី 3:6)។

វិញ្ញាណទាំងប្រាំពីរ នេះជាព្រះវិញ្ញាណបរិសុទ្ធ ហេតុផលនិយាយលេខ "ប្រាំពីរ" ហោរានៃកណ្ឌគម្ពីរសាការីបានប្រៀបធៀបរួចហើយទៅកាន់ព្រះវិញ្ញាណបរិសុទ្ធនៃភ្នែកទាំងប្រាំពីររបស់ព្រះយេហូវ៉ា (សាការី 3:9 វិវរណៈ 5:6)។ ប្រៀបដូចជាលេខប្រាំពីរជានិមិត្តសញ្ញានៃសេចក្តីពោរពេញនិងភាពបរិសុទ្ធ។ អង្គព្រះវិញ្ញាណបរិសុទ្ធជាការរួបរួមនៃបុគ្គលិកលក្ខណៈនិងចេស្តារបស់ទ្រង់ ដែលជាសេចក្តីពោរពេញ (លោក Van Der

Meulen) បាននិយាយថា “វិញ្ញាណប្រាំពីរ” ចង្អុលទៅកាន់វិញ្ញាណនៃព្រះគុណរបស់ព្រះ ដែលត្រូវបានបង្ហូរនូវអំណោយទាននៃលេខពេញលេញតាមរយៈព្រះគ្រីស្ទ (អេសាយ 11:2)។ វាជាការបកស្រាយតាមធម្មជាតិ។ (De Openbaring in Het Laatste Bijbel boek. pp 38-39)។ ការពិតដែលវិញ្ញាណនេះគង់នៅ “នៅមុខបល្ល័ង្ក” មានន័យថា ទ្រង់ជាអ្នកធ្វើការក្នុងការបើកបង្ហាញពីសិទ្ធិអំណាចនៃភាពជាស្តេចរបស់ព្រះវរបិតា និងចេស្តារបស់ទ្រង់ និងបុគ្គលិកលក្ខណៈទាំងអស់ផ្សេងទៀត។ ត្រង់ចំណុចនេះ លោក Graijdanus បានរំលឹកពីគ្រោងនៃរោងឧបោសថ។ នោះគឺ “បល្ល័ង្ក” ជាកន្លែងដែលបរិសុទ្ធបំផុត “វិញ្ញាណទាំងប្រាំពីរ” ចង្កៀងប្រាំពីរដែលដាក់នៅទីបរិសុទ្ធបំផុត (នៅខាងមុខកន្លែងបរិសុទ្ធបំផុត) និងខបន្ទាប់ ព្រះគ្រីស្ទជាម្នាក់នៅក្នុងចំណោមនៃការបង់ថ្លៃលោះដែលបានប្រើនៅនឹងអាសនា។ (យោងតាម និក្ខមនំ 40:1-6)។ (In het heilige der heiligen was da ark. Daar troonde God. និក្ខមនំ 25:22 Voor dit binnente heilindom was het heilige, waarin de kandelaar met zijne zeven lampen branded, និក្ខមនំ 40:24, 25, En voor dit heilige bevond zich het voorhof, waarin de diest der verzoening uitgericht werd. និក្ខមនំ 40:25-33 – Openbaring. P. 16)។

សាក្សីដែលស្មោះត្រង់។ ខនេះនិយាយពីហានៈទ្វេជាបីរបស់ព្រះយេស៊ូវគ្រីស្ទ ទាំងនោះមាន ហោរា (ជាសាក្សីស្មោះត្រង់) សង្ឃ (មួយអង្គដែលបានសុគត) ស្តេច (កូនច្បងដែលបានប្រសូត្រ ជាសិរសានៃស្តេចនៅលើផែនដី) នៅក្នុងចំណោមឃ្លានេះ (សាក្សីស្មោះត្រង់) ព្រះយេស៊ូវចង្អុលថា តាមរយៈជីវិតទាំងមូលរបស់ទ្រង់ ទ្រង់ត្រូវបានជំនួសនូវទុក្ខលំបាកទាំងអស់ ទាំងដែលទ្រង់បានសុគត និងបានប្រាប់ការពិតទៅកាន់

មនុស្សដែលមិនដឹងផង។ (ម៉ាថាយ 11:27, យ៉ូហាន 1:18, 14:6, 18:37 1ធីម៉ូថេ 6:13)។ កាលដែលយើងប្រាថ្នាចង់ស្គាល់ព្រះ ការស្គាល់ព្រះយេស៊ូវគ្រីស្ទគឺជាផ្លូវតែមួយគត់។ (យ៉ូហាន 14:6)។ ប្រសិនបើអ្នកណាជឿដល់ព្រះយេស៊ូវ នោះគេស្គាល់ថាព្រះទ្រង់ជានរណា និងសភាពរបស់នៅរបស់គេហើយ។ មនុស្សមិនអាចចូលដល់កន្លែងដែលស្គាល់ព្រះដោយភាពវិសុទ្ធរបស់គេឡើយ ពីព្រោះមនុស្សបានទៅជាងងឹតដោយសារអំពើបាបរបស់ខ្លួនរួចហើយ (1កូរិនថូស 1:21)។ ភាពវិសុទ្ធខាងវិញ្ញាណដែលព្រះផ្តល់សេចក្តីសង្គ្រោះដល់មនុស្សគឺ មានតែការជឿដល់ព្រះយេស៊ូវតែមួយគត។ ដ្បិតព្រះយេស៊ូវជាព្រះអង្គដែលផ្សះផ្សារវាងព្រះនិងមនុស្ស ដែលយើងអាចទំនាក់ទំនងជាមួយព្រះតាមរយៈទ្រង់បាន។

កូនច្បងនៃពួកដែលបានស្លាប់ នៅទីនេះឃ្លាថា (ὁ πρωτότοκος τῶν νεκρῶν) “កូនច្បងនៃអ្នកដែលបានស្លាប់” ជាការបកប្រែដែលសមស្រប។ រួចមក អត្ថន័យគឺជាអ្នកនាំមុខនៃសេចក្តីរស់ឡើងវិញនៅក្នុងចំណោមមនុស្សដែលបានស្លាប់។ វាចង្អុលទៅកាន់ថា កូនច្បងបានយកឈ្នះសេចក្តីស្លាប់សម្រាប់រាស្ត្ររបស់ទ្រង់ ទ្រង់បានលុបបំបាត់សេចក្តីស្លាប់។ រាស្ត្ររបស់ទ្រង់អាចចូលទៅក្នុងសិរីល្អនៃសេចក្តីរស់ឡើងវិញតាមរយៈកិច្ចការរបស់ទ្រង់។ លោក Grejidanus និយាយថា “មួយអង្គដែលបានប្រសូត្រដំបូងគេ” នៅក្នុងភាសាក្រិកថា ផ្រូថូ ថូខូស (πρωτότοκος) បង្ហាញពីកម្រិតនៃពេលវេលា និងក្នុងពេលតែមួយ ការបង្ហាញពីចេស្តានៃសេចក្តីរស់ឡើងវិញ (ដែលយកឈ្នះសេចក្តីស្លាប់សម្រាប់ទ្រង់និងអ្នកជឿគ្រប់រូប) (πρωτότοκος drukt de gedacht uit van eerste in tijd voor ganger en dan, daarmede samen hangende van machthebber – Openb. P. 16) (យោងតាម 1:18)។ មុនព្រះ

យេស៊ូវក៏មានមនុស្សដែលរស់ពីស្លាប់ឡើងវិញតែ តែដូចជាសេចក្តីរស់ឡើងវិញរបស់ព្រះយេស៊ូវដែលទ្រង់បានរស់ឡើងវិញដោយមិនស្លាប់ម្តងទៀត នោះគ្មានអ្នកណាឡើយលើកលែងតែព្រះយេស៊ូវ ការពិតដែលព្រះយេស៊ូវទ្រង់ជាអ្នកនាំមុខនៃសេចក្តីរស់ឡើងវិញចង្អុលថា ទ្រង់ជាសិរសាដែលយកឈ្នះសេចក្តីស្លាប់និងបានដឹកនាំរូបកាយរបស់ទ្រង់ដែលជាក្រុមជំនុំឱ្យបានចូលទៅក្នុងពិភពលោកនៃសេចក្តីរស់ឡើងវិញ។ ពីព្រោះព្រះគ្រីស្ទ ដែលជាសិរសាបានចូលទៅក្នុងសេចក្តីរស់ឡើងវិញ នោះក្រុមជំនុំដែលជារូបកាយរបស់ទ្រង់ដែលត្រូវបានរួបរួមជាមួយនឹងព្រះគ្រីស្ទ ក៏បានចូលទៅក្នុងសេចក្តីរស់ឡើងវិញដូចគ្នាដែរ។ ដ្បិតព្រះគ្រីស្ទមានព្រះជន្មរស់ នោះជីវិតរបស់នៅរបស់យើងជាគោលលិទ្ធិនៃព្រះគម្ពីរ។ (យោងតាម យ៉ូហាន 14:19, អេភេសូរ 2:5, 6) ។

អ្នកគ្រប់គ្រងលើស្តេចនៅផែនដី (καὶ ὁ ἄρχων τῶν βασιλέων τῆς γῆς)។ ការនេះមានន័យថា “អ្នកគ្រប់គ្រងលើស្តេចនានានៅផែនដី”។ សេចក្តីរស់ពីស្លាប់ឡើងវិញរបស់ព្រះគ្រីស្ទបានសម្រេចបំពេញឱ្យបានក្លាយជាស្តេចលើក្រុមជំនុំ និងស្តេចលើមនុស្សជាតិទាំងអស់ *(រ៉ូម 14:9)*។ សាតាំងបានល្បួងព្រះគ្រីស្ទ និងធ្វើឱ្យទ្រង់ធ្វើអំពើបាបដើម្បីឱ្យបានប្រជាជាតិទាំងអស់នៅលើលោកិយ *(ម៉ាថាយ 4:81)*។ ព្រះគ្រីស្ទទទួលបានវា *(នគរទាំងអស់នៃលោកិយ)* ដោយការសុគតរបស់ទ្រង់ *(វិវរណៈ 19:12, 16)*។ ដ្បិតទ្រង់ជាស្តេចលើអស់ទាំងស្តេច ទ្រង់បានសម្រេចសេចក្តីរស់ឡើងវិញ និងសេចក្តីសង្គ្រោះសម្រាប់អ្នកជឿទាំងអស់ *(យ៉ូហាន 3:35, 36, ភីលីព 3:21)*។ នៅទីនេះ ការដែលមើលទៅកាន់ព្រះគ្រីស្ទជាស្តេចលើសអស់ទាំងស្តេច គឺជាការមើលទៅកាន់សភាពនៃគ្រាចុងក្រោយរបស់ព្រះយេស៊ូវគ្រីស្ទ។ ការយាងចុះនៅគ្រាចុងក្រោយ

របស់ទ្រង់បង្ហាញពីរូបភាពនៃការគ្រប់គ្រងដ៏រឹងមាំ។ ប៉ុន្តែអ្វីដែលយើងគួរតែប្រយ័ត្នពីការនោះគឺ វាមិនមែនជារបស់លោកិយនេះទេទាំងនៅក្នុងវិធីសាស្ត្រនិងស្តាយ និងផ្នែកគ្រប់គ្រង ប៉ុន្តែជាព្រឹត្តិការណ៍អស្ចារ្យ។ *(យោងតាម 17:19)*

ដល់ទ្រង់ដែលស្រឡាញ់យើង

សេចក្តីស្រឡាញ់ជាមូលដ្ឋានគ្រឹះនៃការប្រោសលោះ។ គ្មានសេចក្តីស្រឡាញ់ ក៏គ្មានការលះបង់ដែរ។ ការសុគតរបស់ព្រះគ្រីស្ទ ទ្រង់ដែលបានសុគតដើម្បីនឹងជំនួសយើង គឺការសុគតនោះជាចំនុចខ្ពស់បំផុតនៃសេចក្តីស្រឡាញ់។ សេចក្តីស្រឡាញ់ជាសកម្មភាពបង់ថ្លៃលោះ ជាការបូជាមួយដែលបរិសុទ្ធ។

ដោយព្រះលោហិតទ្រង់

“លោហិត” ប្រៀបដូចជាជីវិត ជាតម្លៃនៃអំពើបាបដែលត្រូវបានតាំងមកដោយឈាមដែលនោះគឺដោយការបង់ថ្លៃជាជីវិត។ ម្យ៉ាងទៀត តម្លៃនៃអំពើបាបរបស់យើងអាចនឹងបង់ថ្លៃបានដោយសារឈាម (ការបង់ថ្លៃនៃជីវិត គឺជាការស្លាប់) (លោកុប្បត្តិ 9:4, ហេព្រើរ 9:22)។ ព្រះលោហិតរបស់ព្រះគ្រីស្ទអាចបង់ថ្លៃបាបនៃរាស្ត្ររើសតាំងរបស់ទ្រង់បាន ហើយជា “ព្រះលោហិត” ដ៏មានតម្លៃបំផុត។

ពាក្យថា “ឈាម” ចេញមកសរុប 700 ដងនៅក្នុងព្រះគម្ពីរ។ ព្រះទ្រង់បានសន្យាការពិតដែលថា យើងគ្មានផ្លូវនៃសេចក្តីសង្គ្រោះទេលើកលែងតែដោយសារលោហិតរបស់ព្រះគ្រីស្ទដែលមានអំណាចបំផុត។ យើងគ្រាន់តែជឿលើលោហិតរបស់ព្រះគ្រីស្ទដោយខ្លាំងក្លាចុះ។

ប៉ុលបាននិយាយថា នៅក្នុងអត្ថន័យនៃការជឿលើលោហិតរបស់ព្រះគ្រីស្ទដែលអាច បង់ថ្លៃលោះអ្នកជឿដោយយ៉ាងមានចេស្តា។ “ដ្បិតខ្ញុំប្តេជ្ញាចិត្តថា ខ្ញុំមិនព្រមស្គាល់រឿង អ្វីទៀត ក្រៅពីព្រះយេស៊ូវគ្រីស្ទទេ ហើយគឺដែលទ្រង់ត្រូវឆ្កាងផង” លោក លូធើ និយាយថា “ព្រះរាជបុត្រារបស់ព្រះបានស្រឡាញ់ខ្ញុំ ហើយទ្រង់បានប្រគល់អង្គទ្រង់ ដល់ខ្ញុំ វាជាចំណុចដែលផ្ទុយប្រៀបដូចជាផ្លេកបន្ទោរបំផ្ទុះទៅកាន់ក្រឹត្យវិន័យ និង សេចក្តីសុចរិតនៃកិច្ចការរបស់មនុស្សអីចឹង។ ប្រសិនបើអ្នកទទួលស្គាល់បុត្ររបស់ព្រះ ទុកជារតនៈសម្បត្តិដែលមិនអាចប្រៀបផ្ទឹមបាន នោះអ្នកនឹងបោះចោលគ្រប់ពិធី សាសនា សកម្មភាព និងការធ្វើបុណ្យទាំងអស់ចូលទៅក្នុងនរកហើយ ពីព្រោះអ្នកគិត តែពីការសុគតរបស់ព្រះរាជបុត្រារបស់ព្រះទេ ដែលអាចបញ្ឈប់សេចក្តីក្រោធរបស់ព្រះ និងធ្វើឱ្យមានសន្តិភាពជាមួយទ្រង់បាន។”

ហើយបានរំដោះយើងឱ្យមានសេរីភាព។ នេះគឺ លូសានធី *(λύσαντι)* នៅក្នុងភាសា ក្រិក ដែលជាការចម្លងនៃអក្សរ អាឡែហ្វ *(א)* និងឯកសារអាឡិចសាន់ឌ្រា ជាឯកសារ មួយ *(R, Q)* លូសានធី *(λύσαντι)* ដែលមានន័យថា “បានស្អាត”។ លោក *Grejidanus* និងអ្នកសរសេរការអធិប្បាយពន្យល់ផ្សេងទៀតបានជ្រើសរើសទីមួយ នោះ។ លោក *Moffatt* ក៏បានជ្រើសដូច្នោះដែរ។ អំពើបាបជាខ្សែដែលចងយើងទៅ កាន់ការជាប់ទោសអស់កល្បជានិច្ច តែព្រះគ្រីស្ទបានកាត់ចោលខ្សែដ៏គួរឱ្យរន្ធត់នោះ ចេញដោយការសុគតរបស់ទ្រង់ (លោហិត) ហើយធ្វើឱ្យយើងបានរត់គេចផុតពីការ ដាក់ទោសនៃសេចក្តីវិនាស។ អ្នកជឿបានគេចផុតការដាក់ទោសនេះដោយសារ លោហិតរបស់ព្រះយេស៊ូវគ្រីស្ទ តើមិនឱ្យគេសរសើរដំកើតម្តេចកើតទៅ!

6 ដល់ព្រះនិងជាព្រះវរបិតារបស់ទ្រង់

ទង្វើនៃសេចក្តីសង្គ្រោះជាសកម្មភាពរបស់ព្រះគ្រីស្ទ ពិតណាស់វាមានឥទ្ធិពលមកលើយើងជាចម្បង។ តែគោលបំណងចម្បងនោះគឺដើម្បីនឹងថ្វាយសិរីល្អដល់ព្រះ (វិវរណៈ 22:3 អេភេសូរ 1:6)។ ព្រះបានសង្គ្រោះយើង និងធ្វើឱ្យយើងស្គាល់ទ្រង់ និងបានបម្រើទ្រង់ទុកជាគោលបំណងតែមួយ (អេភេសូរ 1:5,6)។ ព្រះគ្រីស្ទបានសម្រេចការនេះទុកជាសកម្មភាពនៃសេចក្តីសង្គ្រោះ។

ហើយបានបង្កើតយើងជានគរមួយ និងជាសង្ឃ

ពាក្យថា “នគរ និងសង្ឃ” គឺ បាស៊ីលេអាន ហ៊ិរេរេស (βασιλείαν, ἱερεῖς) នៅក្នុងភាសាក្រិក វាមានន័យថា “សញ្ជាតិនៃពួកសង្ឃ”។ វាមិនមែនជាសង្ឃដែលប៉ាត់ប៉ាយនោះទេ តែជាហ្វូងនៃសង្ឃម្នាក់ៗ ហើយបានទទួលព្រះគ្រីស្ទទុកជាស្តេច និងជាសង្ឃនៃសហគមន៍ដែលមានរបៀបរៀបរយនិងសន្តិភាព។ ក្រុមជំនុំនៅផែនដីគួរតែមានលំដាប់លំដោយ និងសន្តិភាពដូចនេះនៅក្នុងជីវិត។ នេះគឺជាការសម្រេចបំពេញចម្បងនៃទំនាយរបស់ និក្ខមនំ 19:6 (5:10, 7:15, 20:6, 21:3) យោងតាម រ៉ូម 12:1 ហេព្រើរ 13:15 1ពេត្រុស 2:5។ អ្នកជឿទាំងអស់សុទ្ធតែជាសង្ឃហ្លួងដែលបម្រើព្រះជាមួយគ្នា ហើយគួរបង្កើតនូវលំដាប់លំដោយខាងវិញ្ញាណដោយធ្វើតាមព្រះបន្ទូល (ការប្រកាសរបស់ពួកសាវក និងហោរា គឺជាបទគម្ពីរ) នៃសេចក្តីរបស់ពួកគេ (ព្រះគ្រីស្ទ)។ យោងតាមលោក បែកវិច នៅទីនេះ ឃ្លាថា “នគរនិងសង្ឃ” និយាយថា អ្នកជឿនឹងបានក្លាយជាស្តេចនៅពេលពិភពលោកថ្មីមកដល់ និងពួកគេនឹងបានក្លាយជាសង្ឃផង។ (ភាពជាស្តេចរបស់រាស្ត្រនៅក្នុងនគររបស់ព្រះមេស៊ីជាទស្សនៈមួយទៀតនៃភាពជាសង្ឃរបស់ពួកគេ ជាគ្រោះចង្រៃនៃយ៉ូហាន ទំព័រ 430)។

7 ទ្រង់នឹងយាងមកនៅលើពពក

នៅមុនខ 4 និយាយថា ព្រះវរបិតាគឺ “មួយអង្គនឹងយាងមក” នៅទីនេះ គឺជាព្រះគ្រីស្ទ តែមួយអង្គ។ យ៉ូហានយករូបភាពនៃសកម្មភាពរបស់ព្រះគ្រីស្ទដូចគ្នានឹងព្រះវរបិតាដែរ។ ពិតណាស់ មិនមែនជាអង្គតែមួយទេ តែជាលក្ខណៈរបស់ព្រះ។ លោក Grejidanus បានចង្អុលទៅវា និងពន្យល់ដូចតទៅ។ (នៅក្នុងខ 4 heet de vander. Hier wordt van Heere Chistus gezegt, dat Hij komt voor Johannes is dus zoon volkomen gelijk aan den Vander, vgl. Ook vs 8. Wel niet wat person aangaat, vgl. Vss. 4 en 5, 5:1 6. Maar wat wezen betreft. De vander komt in den zoon)។ តើពពកជានិមិត្តរូបអ្វីដែរ? លោក Grejidanus បាននិយាយថាការដែលមើលឃើញបង្ហាញពីរូបរាងនៃសិរីល្អរបស់ព្រះ។ (deze wolken zijn de zichtbare openbaring van zijn Goddelike majesteit)។ យោងតាម និក្ខមនំ 13:21, 14:16, 14:19។ រួចមក “ពពក” នេះមិនមែនជាពពកទូទៅទេ តែជាពពកដែលគួរឱ្យឆ្ងល់។ កាលដែលម៉ូសេបានឃើញភ្លើងឆេះនៅក្នុងគុម្ពបន្លា វាមិនមែនជាភ្លើងធម្មតាទេ។ ភ្លើងឆេះគម្លោតបន្លា។ ដូចនោះដែរវាជាភ្លើងដែលគួរឱ្យឆ្ងល់ដោយសារគុម្ពបន្លាមិនបានឆេះទេ នៅទីនេះ តើពពកនេះមិនគួរឱ្យឆ្ងល់ទេឬ? យោងតាម កិច្ចការ 1:9-11។ ប៉ុន្តែបើទោះជាយើងឃើញវាជាពពកធម្មតា ក៏វាមិនខុសដែរ (Lange)។ កាលដែលទ្រង់កំពុងតែយាងឡើងទៅស្ថានសួគ៌ ពពកក៏បានគ្របបាំងទ្រង់ (កិច្ចការ 1:9)។ កាលដែលទ្រង់នឹងយាងមកលើផែនដីម្តងទៀត នោះទ្រង់នឹងយាងមកនៅក្នុងរូបរាងដូច្នោះដែរ (កិច្ចការ 1:10)។ ហើយភ្នែកទាំងឡាយនឹងមើលឃើញទ្រង់។ កាលដែលយើងមើលឃើញ ការចុះនៅគ្រាចុងក្រោយរបស់ព្រះជាម្ចាស់ ពីព្រោះទ្រង់មិនអាចលាក់បន្តិច តែទ្រង់នឹងយាងមកឱ្យមនុស្សគ្រប់គ្នាបានឃើ

ញ។ វាពិបាកនៅក្នុងការទាយពីអ្វីដែលនឹងត្រូវកើតឡើង។ ពីព្រោះវាស្ថិតលើការយល់ដឹងដ៏អស្ចារ្យ វាជារឿងធម្មតាទេដែលត្រូវទាយពីវាដោយចំណេះដឹងទូទៅរបស់យើង។ ទាំងអស់អ្នកដែលបានចាក់ទំលុះទ្រង់ផង យោងតាម សាការី 12:10, យ៉ូហាន 19:34, 20:25, 27។ តើអ្នកណាដែលបានចាក់ទ្រង់? តែនៅទីនេះ វាចង្អុលទៅកាន់ឆ្មោះសរុបដែលបានធ្វើការបៀតបៀនដល់ព្រះអម្ចាស់។ កាលដែលព្រះគ្រីស្ទយាងមកនៅលើផែនដីនេះជាលើកដំបូង គ្មានមនុស្សច្រើនដែលបានស្គាល់ព្រះអម្ចាស់ទេ។ តែពេលដែលទ្រង់បានមកកាន់លោកិយ សត្រូវដ៏អាក្រក់បំផុងបានស្គាល់ទ្រង់ថាទ្រង់ជាព្រះ ហើយវាខ្លាចទ្រង់ផង។ លោក Moffatt និយាយពាក្យថា “អ្នកដែលចាក់ទំលុះទ្រង់ នោះចង្អុលទៅកាន់ពួកយូដា តែវាមិនមែនជាការបកស្រាយដែលសមហេតុផលទេ។ រួចគ្រប់ទាំងពូជមនុស្សនៅផែនដីនឹងយំសោកដោយព្រោះទ្រង់។ ហេតុផលដែលពួកគេទួញសោកមានដូចតទៅនេះ (1) មុនគ្រាចុងក្រោយបង្ហោះមកដល់លើលោកិយនេះ ពួកគេមិនបានប្រែចិត្ត ពួកគេក៏សោកស្តាយ (មិនប្រែចិត្ត –ម៉ាថាយ 27:3) ហើយមានអារម្មណ៍សោកស្តាយដោយសារការនោះ។ (2) ពួកគេខ្លាចការកាត់ទោសដ៏គួរឱ្យភ័យខ្លាចរបស់ព្រះអម្ចាស់ (ម៉ាថាយ 8:12)។

អើ មែនហើយ អាម៉ែន។ នៅទីនេះ ពាក្យថា “មែនហើយ” គឺ នេយ (ναί) នៅក្នុងភាសាក្រិក មានន័យថា មែន (គឺពិតមែន)។ ចំណុចទាំងនេះ ខាងក្រោមវា គឺ អាម៉ែន (אָמֵן) ជាភាសាហេព្រើរ។ ត្រង់ចំណុចនេះ លោក Grejidanus បាននិយាយថា “នៅទីនេះ យ៉ូហានបញ្ជាក់ពីការធានាអះអាងទ្វេរពីការយាងចុះមកនៅគ្រាចុងក្រោយរបស់ព្រះគ្រីស្ទដោយពាក្យជាពីរភាសា។” ហេតុផលដែលគាត់បានបញ្ជាក់ជាការធានាអះអាងទ្វេរគឺ ដើម្បីនឹងសង្កត់ធ្ងន់ថាការយាងចុះមកនៅគ្រាចុងក្រោយរបស់ព្រះអ

ម្ចាស់នឹងមិនត្រូវបានផ្លាស់ប្រែឡើយ គឺតាមអ្វីដែលទ្រង់បានសន្យា។ (De Grieksche en de Hebreeuwsche woorden ter bevestiging woorden hier bijeengevoegd om te sterker de stellige zekerheid uit tespreken, dat de Heere alzoo komen zal, gelijk Hij beloofd heft ( )។

ខ 8 អត្ថបទជាការបញ្ជាក់ថា ការយាងចុះមកនៅគ្រាចុងក្រោយរបស់ព្រះអម្ចាស់ វាត្រូវបានបញ្ជាក់ដោយព្រះនាមរបស់ព្រះ។ នាមបរិសុទ្ធរបស់ព្រះផ្គាល់លាយឡំជាមួយនឹងការយាងមកលើកទីពីររបស់ព្រះជាម្ចាស់។ និយាយមួយបែបទៀត នាមបរិសុទ្ធនៃធាតុរបស់ព្រះជាសញ្ញានៃធាតុរបស់ទ្រង់ វារាប់បញ្ចូលការយាងចុះមកនៅគ្រាចុងក្រោយជាចាំបាច់រួចទៅហើយ។ លោក Grejidanus បាននិយាយថា “សកម្មភាពរបស់ទ្រង់ចេញមកពីធាតុរបស់ទ្រង់” (uit het zijn wezen Gods, volgt zijn werken)។

អាលផា និងអូមេកា ការនេះចង្អុលទៅកាន់អក្សរដំបូង (A) នៅក្នុងភាសាក្រិក និងអក្សរចុងក្រោយ *(Ω)*។ នេះជាអត្ថន័យដែល ព្រះទ្រង់ជាព្រះអង្គដែលចាប់ផ្តើមជាមួយនឹងការទាំងអស់ ហើយទ្រង់នឹងបញ្ចប់គ្រប់ការទាំងអស់។ និយាយម្យ៉ាងទៀត ទ្រង់ជាព្រះដែលបង្កើត ហើយក៏ជាចៅក្រម។ ទ្រង់ដែលគង់នៅ ក៏គង់នៅតាំងតែពីដើមហើយត្រូវយាងមកទៀត។ ព្រះនាមបរិសុទ្ធនេះបង្ហាញនៅក្នុងខ *4* វាត្រូវតែជាការពន្យល់សម្រាយនៃព្រះយេហូវ៉ា *(יהוה)* នៅក្នុងភាសាហេព្រើរ “អង្គដែលមានព្រះជន្មគង់នៅដោយអង្គឯងអស់កល្បជានិច្ច” នៅក្នុងនិក្ខមនំ *3:14. (ព្រៃជជានុស)* “អត្ថន័យនៃ អង្គដែលមានព្រះជន្មគង់នៅដោយអង្គឯងអស់កល្បជានិច្ច គឺថា មិនត្រូវបានគេបង្កើតមកទេ គឺបានគង់នៅដោយខ្លួនឯង ជាអង្គដែលមិនប្រែប្រួលដែលអស់កល្ប

ជានិច្ច និងគ្រប់គ្រងគ្រប់របស់ដែលត្រូវបានបង្កើតមកជាមួយនឹងព្រះទ័យសប្បុរស
របស់ទ្រង់ ហើយនៅពេលមកដល់ទ្រង់នឹងកាត់ទោសពួកគេ ហើយនឹងរៀបចំពួកគេ។
នៅក្នុងការបកស្រាយបែបបំបែក វាមិននិយាយថា “មួយអង្គដែលនឹងមានវត្តមាននៅ
ពេលអនាគត” នោះទេ ប៉ុន្តែត្រូវបាននិយាយសង្ខេបថា “មួយអង្គដែលនឹងមកនៅ
ពេលអនាគត”។ អត្ថន័យនៃការយោងមកលើកទីពីររបស់ព្រះយេហូវ៉ា (יהוה) ព្រះនាម
បរិសុទ្ធត្រូវបានចង្អុលប្រាប់យ៉ាងច្បាស់។

ព្រះអង្គដែលមានគ្រប់ចេស្តា។ នៅក្នុងភាសាក្រិកគឺ ជានថូក្រាថូរ *(παντοκράτωρ)* ដែលមានន័យថា បើកបង្ហាញពីបុគ្គលិកលក្ខណៈនៃការយោងមកលើកទីពីរដែលនឹងមកដល់។ ព្រះអម្ចាស់នឹងនឹងត្រឡប់មកនឹងត្រឡប់មកពិតប្រាកដមែន។

9 យ៉ូហានខ្ញុំ ដែលជាបងប្អូននៃអ្នករាល់គ្នា ហើយជាអ្នកមានចំណែកក្នុងសេចក្តី
ទុក្ខលំបាក និងក្នុងនគរ ហើយក្នុងសេចក្តីអត់ធ្មត់របស់ព្រះយេស៊ូវគ្រីស្ទ។

នៅទីនេះ ពាក្យថា “បងប្អូន” និងពាក្យ “អ្នកមានចំណែក” នៅក្នុងភាសាក្រិក
ស្ថិតនៅនឹងចំណងជើងមួយ (ὁ ἀδελφὸς ὑμῶν καὶ συγκοινωνὸς) ហើយ
មានទំនាក់ទំនងយ៉ាងជិតស្និតជាមួយគ្នា។ វាប្រាប់ពីទំនាក់ទំនងនៃហេតុនិងផល
ដោយការពិតសម្រាប់ “បងប្អូន” គាត់បានចូលរួមនៅក្នុង “ទុក្ខលំបាក ក្នុងនគរ
និងសេចក្តីអត់ធ្មត់”។ នៅទីនេះ ពីការពិតដែលយ៉ូហានមិនលើកឡើងពីឋានៈ
របស់គាត់ (សាវក ឬហោរា) ពិតណាស់ យើងមិនត្រូវការគិតបែបប្លែកអ្វីទេ។ ពិត
ណាស់ កាលដែលគាត់សរសេរអត្ថបទ គាត់បានប្រកាសព្រះបន្ទូលរបស់ព្រះជា
សិទ្ធិអំណាចជាសាវកទៅកាន់ក្រុមជំនុំ។ ប៉ុន្តែក្នុងពេលតែមួយ គាត់សង្កត់ធ្ងន់ថា

គាត់ផ្ទាល់ជាបងប្អូនដែលរួមចំណែកនៅក្នុងទុក្ខលំបាក និងសិរីល្អជាមួយនឹងពួកជំនុំ និងបានសរសេរអត្ថបទ។ យោងតាម ម៉ាថាយ 23:8។

និងក្នុងនគរ និងក្នុងសេចក្តីអត់ធ្មត់របស់ព្រះយេស៊ូវគ្រីស្ទ

នៅក្នុងឃ្លា ពាក្យថា “ព្រះយេស៊ូវ” ទាក់ទងនឹងពាក្យ “ទុក្ខលំបាក” “នគរ” និង “ការអត់ធ្មត់” ជាចំណុចរួមទូទៅ។ (ἐν τῇ θλίψει καὶ βασιλείᾳ καὶ ὑπομονῇ)។ ដូច្នេះវាមានន័យថា “ទុក្ខលំបាករបស់ព្រះយេស៊ូវ” “នគររបស់ព្រះយេស៊ូវ” និង “ការអត់ធ្មត់របស់ព្រះយេស៊ូវ”។ ពាក្យថា “របស់ព្រះយេស៊ូវ” គឺ អែន យ៉េស៊ូ (ἐν Ἰησοῦ) មានន័យថា “នៅក្នុងយេស៊ូវ”។ សេចក្តីទុក្ខលំបាក និងនគរនៅក្នុងព្រះយេស៊ូវមានន័យថា ទុក្ខលំបាកនិងនគរដែលបានចូលរួមដូចជាទំនាក់ទំនងដែលរួបរួមជាមួយនឹងព្រះយេស៊ូវ មានន័យថាការអត់ធ្មត់ដែលព្រះយេស៊ូវបង្ហាញជាឧទាហរណ៍ និងធ្វើឱ្យពួកគេអត់ធ្មត់ដោយផ្តល់អំណាចចេស្តាដល់ពួកគេ។ (Moffatt) ទុក្ខលំបាកជាផ្លូវទទួលបាននគរ។ ការអត់ធ្មត់ជាអំណាចដើរនៅលើផ្លូវ។

ដោយព្រោះព្រះបន្ទូល និងសេចក្តីបន្ទាល់ពីព្រះយេស៊ូវគ្រីស្ទ។ យោងតាមការបកស្រាយនៅខ 2។ យ៉ូហានត្រូវបានគេបៀតបៀនដោយសារដំណឹងល្អ និងត្រូវបានបណ្តេញទៅកោះប៉ាត់មុស។ ហើយមានអ្នកទោសជាច្រើនដែលត្រូវបានបញ្ជូនទៅទីនោះ។ *(Moffatt)*

ប៉ាត់មុស។ នេះជាកោះតូចមួយ ដែលទូកអាចទៅដល់ដោយជិះប្រហែល14ម៉ោងចេញពីក្រុងអេភេសូរ។

10 ថ្ងៃនៃព្រះអម្ចាស់ ចង្អុលទៅកាន់ថ្ងៃបរិសុទ្ធដែលយើងអាចរក្សាមករហូតដល់សព្វថ្ងៃនេះ ដែលត្រូវបានញែកចេញមកតាំងពីសម័យរបស់ពួកសាវក (1កូរិនថូស 16:2)។ មានទីបន្ទាល់ជាច្រើនដែលក្រុមជំនុំបានរក្សានៅថ្ងៃនោះ ដែលត្រូវបានបង្ហាញនៅសម័យបន្ទាប់ពីពួកសាវក។ (Didache 14, Ignatius ad Man. 9) ។

ខ្ញុំបានត្រឡប់ជានៅដោយវិញ្ញាណ។ វាគឺ អេហ្គេណូមែន អែន ផ្នូម៉ាធី *(ἐγενόμην ἐν πνεύματι)* នៅក្នុងភាសាក្រិក ដែលមានន័យថា "គាត់បាននៅក្នុងព្រះវិញ្ញាណបរិសុទ្ធ" លោក *Rohmeyer* បានបកប្រែវាដូចតទៅថា នោះមិនមែនជាសភាពធម្មតា ឬសភាពបែបផែទមន្តទូទៅទេ តែគាត់ត្រូវបានដកទៅកាន់ពិភពខាងវិញ្ញាណនៃសភាពពេញដោយសេចក្តីអំណរយ៉ាងខ្លាំង (វិវរណៈ *4:1,* 2កូរិនថូស *12:1) – Nicht einen dauernden habitus gleich dem πνεύματι (*រ៉ូម *8:9) such wohl nicht nurallgemein (S. zu 4:1 und vgl. Etwa* 2កូរិនថូស *12:1 ff)*។ ប៉ុន្តែពេលនេះយ៉ូហានមិនបានដេកលក់ទេ ហើយគាត់ក៏មិនបានស្ថិតនៅក្នុងសភាពដូចជាស្លាប់ដែរ។ ប៉ុន្តែផ្ទុយពីនេះវិញ គាត់នៅតែរក្សាគំនិតដែលច្បាស់លាស់ និងដឹងខ្លួនយ៉ាងច្បាស់។ *(Grejidanus)*
ដូចជាត្រែ វាប្រៀបដូចជាសម្លេងត្រែ ហើយមិនមែនជាសម្លេងត្រែ។ នៅក្នុងសម័យបុរាណ ត្រែត្រូវបានប្រើសម្រាប់នឹងដាស់មនុស្ស (ជនគណនា *10:2)*។ ដូច្នេះ ពាក្យថា "សម្លេង" នេះប្រាកដជាសម្លេងដើម្បីនឹងដាស់តឿនហើយ។
11 ព្រះក្រុមជំនុំទាំងប្រាំពីរនៅក្នុងខនេះគឺសំដៅទៅរកការបកស្រាយពីក្រុមជំនុំនីមួយៗនៅក្នុងជំពូក *2-3.*

12 ជើងចង្កៀងទាំងប្រាំពីរ

ការនេះត្រូវបានបកប្រែនៅក្នុង ខ 20 គឺជាក្រុមជំនុំទាំងប្រាំពីរ។ យោងតាម 25:31-40

13 នៅចំកណ្តាលនៃជើងចង្កៀងមានម្នាក់ដូចជាបុត្រមនុស្ស

នេះគឺ “បុត្រមនុស្ស” នៅក្នុង ដានីយ៉ែល 7:13 ដែលជាព្រះមេស៊ី (ព្រះគ្រីស្ទ)។ មួយអង្គនេះតែងតែគង់នៅក្នុងក្រុមជំនុំ គ្មានការប្រៀបប្រដូចជាច្រើនចេញមកពីខាងក្រោយ។ វាខុសហើយដែលថា Seiss បានឃើញពីការបង្ហាញមកមិនមែនជាបែបប្រៀបធៀប តែជាការពិតជាក់ស្តែងនោះ។ (A. Rieters. Studies, in The Revelation of St. John p 87)។ លោក Wm Hendricksen បាននិយាយថា ព្រះគ្រីស្ទត្រូវបានរៀបរាប់នៅទីនេះប្រៀបដូចជារូបភាពដែលថាទ្រង់តែងតែគង់នៅកណ្តាលក្រុមជំនុំ ដូច្នេះគាត់ចង់សង្កត់ន័យពីទំនាក់ទំនងរវាងពាក្យនេះនិងជំពូកបន្ទាប់ (ជំពូក 2 និង 3= ទ្រឹស្តីរបស់ក្រុមជំនុំ) យ៉ាងជិតស្និត។ (More than Conquerors, pp 33-34)។

បំពាក់ដោយព្រះពស្ត្រវែង នេះគឺជាសំលៀកបំពាក់របស់សម្តេចសង្ឃ *(និក្ខមនំ 28:4, 29:5)*។ ជាមួយនឹងខ្សែមាសសំរឹតត្រង់ព្រះឱរា គឺជាសំលៀកបំពាក់របស់ស្តេច *(Grejidanus)*។ រួចមកយ៉ូហាននៅទីនេះបានឃើញព្រះមេស៊ីដែលជាសង្ឃនិងជាស្តេច *(*ទំនុកដំកើង *110:* អេសាយ *6:1-5)*។

14 ព្រះសិរសានិងព្រះកេសាទ្រង់សដូចជាពាមចៀមដែលស នេះជានិមិ្តតសញ្ញានៃជីវិតអស់កល្បជានិច្ចរបស់ព្រះគ្រីស្ទ *(*ដានីយ៉ែល *7:9)* និងភាពបរិសុទ្ធ *(*អេសាយ *1:18)* ។

ព្រះនេត្រទ្រង់ដូចជាអណ្តាតភ្លើង នេះគឺជាអំណាចដែលអាចធ្វើគ្រប់យ៉ាងរបស់ទ្រង់ គឺថាទ្រង់មានភាពវៃឆ្លាតដែលអាចដឹងគ្រប់ការទាំងអស់បាន។ យោងតាម ដានីយ៉ែល *10:6*។

ព្រះបាទទ្រង់ដូចជាលង្ហិនរលីងដែលភ្លឺផ្លេកៗដូចជាដុតក្នុងគុកភ្លើង (1) ការនេះគឺមិនត្រូវបានបំបែកដោយងាយៗនោះទេ “ជើងដែលលាយដោយដីឥដ្ឋនិងដែល” វាចង្អុលទៅកាន់ នគរដែលមិនអាចប្រៀបធៀបបានដ៏រឹងមាំរបស់ព្រះ ឬជានិមិ្តតសញ្ញានៃការកាត់ទោស។ យោងតាម ដានីយ៉ែល *2:31-35*។ *(2)*

ការយោងមកលើកទីមួយរបស់ព្រះយេស៊ូវ ព្រះបាទទ្រង់ត្រូវបានធ្វើឱ្យមានរបួសដោយត្រូវបានឆ្កាងនៅលើឈើឆ្កាង តែកាលដែលទ្រង់នឹងយាងមកម្តងទៀតនៅលើផែនដី ព្រះបាទទ្រង់នឹងមិនត្រូវឈឺទៀតទេ បើទោះជាទ្រង់នឹងជាន់សត្រូវរបស់ទ្រង់ក៏ដោយ ពីព្រោះទ្រង់នឹងយាងមកនៅក្នុងសិរីល្អនិងព្រះចេស្តា។

ព្រះសូរសៀងទ្រង់ដូចជាសូរនៃទឹកច្រើន

ពាក្យនេះគឺចង់សម្គាល់ថាព្រះគ្រីស្ទទ្រង់ជាព្រះ។ អេសេគាល 43:2 បាននិយាយថា សូរសៀងរបស់ព្រះប្រៀបដូចជាសម្លេងនៃទឹកជាច្រើន។ ទំនុកដំកើង 29:3 ក៏មានធ្វើដូច្នោះ។ នេះជាសម្លេងដែលមានអំណាច ដូច្នេះនៅក្នុងពេលមួយ វាជម្រុញឱ្យមានការប្រែចិត្ត ធ្វើឱ្យមនុស្សមានបាបភ័យខ្លាច តែពាក្យជាពាក្យដែលគួរឱ្យភ័យខ្លាចដែលព្រមានពីការកាត់ទោសនៅគ្រាចុងក្រោយនៃលោកិយនេះ។

15 នៅព្រះហស្តស្តាំទ្រង់កាន់ផ្កាយប្រាំពីរ ដៃស្តាំជាដៃដែលមានអំណាចចេស្តា វាជាដៃដែលធ្វើការ *(Grejidanus)* ដើម្បីនឹងធ្វើតួនាទីនៃការការពារ។ ដូច្នេះ ការដែលកាន់

ផ្តាយប្រាំពីរជាមួយនឹងព្រះហស្តស្តាំមានន័យថា ទ្រង់ធ្វើការយ៉ាងអស្ចារ្យតាមរយៈព្រះហស្តទ្រង់ដែលជាអ្នកបម្រើនៅក្នុងក្រុមជំនុំ *(ខ 18)*។

ក៏មានដាវមុខ2ដ៏មុត ចេញពីព្រះឱស្ឋទ្រង់

ការនេះចង្អុលទៅកាន់ដាវរបស់ព្រះដែលទំលុះចិត្តនិងព្រលឹងរបស់មនុស្ស និងកាត់ទោសអំពើបាបយ៉ាងមុត។ ព្រះបន្ទូលរបស់ទ្រង់វះកាត់ព្រលឹងវិញ្ញាណរបស់អ្នកជំងឺ ហើយបានជួយសង្គ្រោះ (ហេព្រើរ 4:12) ហើយដាក់ទោសមនុស្សមានបាបដែលមិនព្រមប្រែចិត្តរហូតដល់ទីបញ្ចប់ ហើយក៏កាត់ទោសគេផង។ (វិវរណៈ 19:20, យ៉ូហាន 12:48)។

ហើយព្រះភក្ត្រទ្រង់ដូចជាថ្ងៃភ្លឺពេញអំណាច។ ភាពភ្លឺនៃមួយអង្គដែលមានសិរីរុងរឿងនៃនគររបស់ចៃងចាំងមកដូចនោះ។ កាលដែលទ្រង់បង្ហាញពីសិរីល្អរបស់ទ្រង់នៅលើភ្នំនៃការផ្លាស់ប្រែគឺទ្រង់បានធ្វើបែបនោះ។ *(ម៉ាកុស 9:3)*។ រូបភាពនៃមនុស្សសុចរិតដែលបានចូលរួមនៅក្នុងស្ថានសួគ៌នឹងបានចៃងចាំងដូចជាព្រះអាទិត្យ។ *(ម៉ាថាយ 13:43)*។

17 នោះខ្ញុំដួលនៅទៀបព្រះបាទទ្រង់ដូចជាស្លាប់។ យោងតាម អេសេគាល *1:28,* ដានីយ៉ែល *8:17*។ ហេតុផលដែលគាត់បានក្លាយទៅជាបែបនោះគឺជាការនេះ គឺដែលគាត់ត្រូវបានហ៊ុំព័ទ្ធដោយសេចក្តីភ័យខ្លាច។ ហេតុអ្វីបានជាសេចក្តីភ័យខ្លាចមកលើគាត់? គឺដោយសារគាត់ជាមនុស្ស គាត់ខ្សោយហើយមានបាប។ លោក *Grejidanus* និយាយថា “ហេតុផលដែលគាត់ធ្វើដូច្នោះ មិនមែនដោយសេចក្តីកំសោយរបស់គាត់ទេ តែជាអំពើបាបរបស់គាត់វិញទេ”។ *(យោងតាម អេសាយ 6:5)*

(De Verklarng dezer overweldinging ligt nier zoozeer in's menschen brroshield als wel in zijne zondigheld. Vgl. Jes. 6:6)។

"កុំខ្លាចឡើយ អញជាដើម ហើយជាចុង" ភាសាដើមក្រិកនៃឃ្លានេះ *(Μὴ φοβοῦ · ἐγώ εἰμι ὁ πρῶτος καὶ ὁ ἔσχατος)* ត្រូវបានបកប្រែដោយលោក សេអូឌ័រ ស្យាញ់ ដូចតទៅថា។ គឺថា កុំខ្លាចឡើយ នេះគឺជាអញ ដែលជាដើមហើយក៏ជាចុងផង។" ការបកប្រែនៃពាក្យថា ជាដើមនិងជាចុង ចេញមកពីខ *៨*។

18 ហើយជាព្រះដ៏រស់។ គឺ ហូ ស្សូន *(ὁ ζῶν)* នៅក្នុងភាសាក្រិក ដែលមានន័យថា ម្នាក់ដែលមានព្រះជន្មគង់នៅជានិច្ចជាមួយនឹងភាពអស់កល្បជានិច្ច។

អញក៏មានកូនសោរនៃសេចក្តីស្លាប់។ *"កូនសោរ"* មានន័យថាជាភាពជាអម្ចាស់ ដែលមានគ្រប់អំណាចចេស្តា *(ប្រៀបដានុស)* គឺទ្រង់មានភាពជាអម្ចាស់លើសេចក្តីស្លាប់ និងស្ថានឃុំព្រលឹង (ជាកន្លែងដែលសេចក្តីស្លាប់ និងមនុស្សស្លាប់នៅទីនោះ) មានន័យថា ទ្រង់អាចដោះលែងមនុស្សដែលស្ថិតនៅក្រោមការគ្រប់គ្រងដោយសេចក្តីស្លាប់បានដោយសិទ្ធិអំណាចរបស់ទ្រង់ចាប់ពីពេលនេះតទៅ ពីព្រោះទ្រង់ផ្ទាល់បានយកឈ្នះសេចក្តីស្លាប់ហើយទ្រង់ក៏បានរស់ឡើងវិញហើយ។ តើ "ស្ថានឃុំព្រលឹង" ជាអ្វី? វាគឺ អាយដេស *(εἵδεσ)* នៅក្នុងភាសាក្រិក នៅក្នុងគម្ពីរសញ្ញាចាស់គឺពាក្យថា ស្ហេអូល *(שְׁאוֹל)*។ គម្ពីរសញ្ញាថ្មីបង្ហាញថា វាជាកន្លែងដែលគួរឱ្យភ័យខ្លាច ដែលមនុស្សដែលមិនបានប្រែចិត្តនឹងចូលទៅទីនោះបន្ទាប់ពីស្លាប់ ប៉ុន្តែក៏ត្រូវបានប្រើថាជាកន្លែងដែលព្រលឹងដែលបានចាកចេញនឹងទៅទីនោះដែរ។ ជាពិសេស វាអាចនឹងចង្អុលទៅកាន់កន្លែងដែលទាំងមនុស្សល្អនិងមនុស្សអាក្រក់នឹងចូលទៅទីនោះ។ *(1*ពង្សាវតារក្សត្រ *2:2,9* យ៉ូប *3:13, 30:23* ទំនុកដំកើង *89:48,* អេសាយ *14:9* អេ

សេគាល *32:28)*។ មនុស្សដែលទៅកាន់ទីនោះអាចនិយាយជាមួយគ្នាបាន *(អេសាយ 14:9)*។ លោក ដេលីហ្សឆ៍ និយាយពីជំពូកនិងខនេះដូចតទៅថា “បើទោះជានៅទីនេះទស្សនៈនៃស្ថានឃុំព្រលឹងមានលក្ខណៈដូចជារឿងនិទាន តែវាបានផ្អែកលើសេចក្តីពិតពីរ។ គឺ *(1)* មនុស្សដែលបានរស់នៅពីមុន នោះផ្នូរនឹងមិនត្រូវបានទៅដោយដៃដែលនៅលើផ្នូរឡើយ *(2)* នៅក្នុងបរិស្ថានដែលព្រះទ្រង់ប្រទានដល់យើងប្រភេទដែលមិនមែនជាសម្ភារៈនៅក្នុងមនុស្សនឹងត្រូវបានបង្ហាញដូចជាខ្លឹមសារដោយបង្ហាញខ្លួនរបស់មនុស្សនៅក្នុងកញ្ចក់ដែរ។”

លោក ហឺម៉ាន់ បាវីង និយាយថា កាលដែលគម្ពីរសញ្ញាចាស់និយាយថា “ស្ថានឃុំព្រលឹង”។ វាជាកន្លែងដែលមនុស្សស្លាប់នៅទីនោះនិងរស់នៅទីនោះ។ មនុស្សស្លាប់ប្រៀបដូចនៅក្នុងផែនដីដែរ ធ្វើចលនានៅក្នុងសភាពអារម្មណ៍ដោយស្គាល់គ្នាទៅវិញទៅមកនិងបានជួបគ្នា។”

យើងអាចសន្និដ្ឋានពីស្ថានឃុំព្រលឹងដូចតទៅនេះ (1) ស្ថានឃុំព្រលឹងមិនមែនជាផ្នូរហូតទេ។ (2) ស្ថានឃុំព្រលឹងគឺជាកន្លែងដែលមនុស្សទុច្ចរិតចូលទៅ ក្នុងពេលតែមួយ វាមានន័យថាជាកន្លែងដែលមនុស្សសុចរិតដែលចូលទៅដែរ។ (លោកុប្បត្តិ 37:35)។ អីចឹងវាមាននៅកន្លែងណាមួយ។ តើមនុស្សល្អនិងមនុស្សអាក្រក់ទៅកន្លែងតែមួយបន្ទាប់ពីស្លាប់ទៅបានយ៉ាងម៉េច? វាមិនសមស្របទេទាំងនៅក្នុងសញ្ញាចាស់និងនៅសញ្ញាថ្មី។ (16:11, 17:15, ម៉ាថាយ 8:11,12)។ តើយើងដោះស្រាយបញ្ហានេះបានយ៉ាងម៉េច? នៅក្នុងសញ្ញាចាស់ ពាក្យថា “ស្ថានឃុំព្រលឹង” ចង្អុលទៅកាន់ផ្នូរខាងរូបកាយក្នុងពេលមួយ។ ហើយវាក៏ចង្អុលទៅកាន់ផ្នូរបន្ទាប់ពីស្លាប់ទៅផងដែរ។ តែវាមានន័យថា វាជាលក្ខណៈរបស់លោកិយ ដូចជាអត្ថន័យកណ្តាលដែលមិនទាន់

រាប់ពីភាពចំរុងចម្រើន សេចក្តីវិនាស បណ្តាសារ ព្រះពរនៅឡើយ និយាយទៅគ្រាន់តែបន្ទាប់ពីស្លាប់ (លោកុប្បត្តិ 37:35)។ លោក រ៉ូរ៉ែន ប៉ូតនើ ក៏និយាយន័យដូចគ្នាថា "ពីព្រោះសញ្ញាចាស់និយាយថា មនុស្សសុចរិតនិងមនុស្សទុច្ចរិតទាំងអស់នឹងទៅកាន់ស្ថានឃុំព្រលឹង ពាក្យថា ស្ថានឃុំព្រលឹងមានទស្សនៈពីរង្វាន់និងការដាក់ទោសយ៉ាងជាក់"។ ប៉ុន្តែនៅក្នុងសញ្ញាថ្មី ពាក្យថាឋានឃុំព្រលឹងត្រូវបានបកប្រែថា ស្ថានឃុំព្រលឹង (ᾅδης) (កិច្ចការ 2:27) មានន័យថាកន្លែងដែលគួរឱ្យភ័យខ្លាចបន្ទាប់ពីស្លាប់ទៅ (លូកា 16:23)។ មនុស្សទុច្ចរិតចូលទៅទីនោះ និងត្រូវរងទុក្ខពិតប្រាកដ។

19 ទាំងសេចក្តីដែលឯងបានឃើញ ព្រមទាំងសេចក្តីដែលមានសព្វថ្ងៃនេះ និងសេចក្តីទាំងប៉ុន្មានដែលត្រូវកើតមកតាមក្រោយទៀតផង។ នៅទីនេះ "ទាំងសេចក្តីដែលឯងបានឃើញ" ត្រូវបានពន្យល់ដោយឃ្លាបន្ទាប់ថា "ព្រមទាំងសេចក្តីដែលមានសព្វថ្ងៃនេះ" ហាក់បីដូចជា "សភាពរបស់ក្រុមជំនុំដែលត្រូវបានកត់ទុកនៅក្នុងជំពូក *2-3* "និងសេចក្តីទាំងប៉ុន្មានដែលត្រូវកើតមកតាមក្រោយទៀតផង" ហាក់បីដូចជាខ្លឹមសារនៃការបើកសម្តែងដែលត្រូវបានកត់ត្រាទុកនេះ។

ចំណុចសំខាន់

1. ដ្បិតព្រះបន្ទូលរបស់ព្រះជាសេចក្តីពិត វានឹងសម្រេចបំពេញតាមព្រះបន្ទូលពិតប្រាកដ អ្នកដែលនឹងសម្រេចធ្វើតាមព្រះបន្ទូលរបស់ព្រះដោយស្មោះត្រង់គឺជាអ្នកដែលមានពរ។ ការធ្វើតាមព្រះបន្ទូលប្រសើរជាងការការពារជីវិតផង។ ព្រះបន្ទូលរបស់ព្រះជាប្រភពនៃជីវិត ហើយជាផ្លូវដើម្បីចូលទៅកាន់សិរីរុងរឿងនៃលោកិយដែលនឹងមកដល់ និងភាពបរិបូរណ៍របស់វា ហើយវាបង្ហាញពីឥទ្ធិពលយ៉ាងពិតប្រាកដ។

2. អំពីកំណើតនៃកណ្ឌគម្ពីរវិវរណៈ (1-3) កណ្ឌគម្ពីរនេះព្រះបានប្រទានដល់ព្រះយេស៊ូវ ហើយឱ្យទ្រង់បើកសម្តែងដល់ក្រុមជំនុំ។ វាបញ្ជាក់ដោយពាក្យថា "នេះជាសេចក្តីដែលព្រះយេស៊ូវគ្រីស្ទបានបើកឱ្យឃើញ ជាសេចក្តីដែលព្រះបានប្រទានមកទ្រង់"។ ព្រះបានតាំងព្រះយេស៊ូវគ្រីស្ទជាអង្គផ្សះផ្សា និងបានផ្តល់នូវសិទ្ធិនៃការបើកសម្តែងដ៏អាថ៌កំបាំង។ (1កូរិនថូស 15:24-28, ភីលីព 2:9)។ ព្រះទ្រង់ទុកចិត្តនឹងព្រះយេស៊ូវគ្រីស្ទទាំងស្រុង ហើយបានប្រគល់នូវសេចក្តីអាថ៌កំបាំងទាំងអស់ដល់ទ្រង់។ ចុះបើមនុស្សមិនទុកចិត្តលើព្រះយេស៊ូវវិញ ចុះប្រសិនបើពួកគេមិនព្រមជឿនោះ? មនុស្សគួរតែជឿលើព្រះរាជបុត្រាតែមួយដែលព្រះទ្រង់បានទុកចិត្តទាំងស្រុងដែរ។ អ្នកណាដែលរក្សាអាថ៌កំបាំងដែលព្រះយេស៊ូវគ្រីស្ទបានទទួលពីព្រះហើយដែលបានប្រកាសដែលជាពាក្យរបស់ហោរានោះជាអ្នកដែលមានពរហើយ។
3. ព្រះពរដែលចេញមកពីព្រះត្រៃឯក។ (4-6)។ សេចក្តីសង្គ្រោះរបស់សាសនាគ្រីស្ទជាអំណោយទានរបស់ព្រះត្រៃឯក។ ដែលជា ព្រះវរបិតាទ្រង់បានរៀបគម្រោង ព្រះយេស៊ូវគ្រីស្ទទ្រង់បានធ្វើឱ្យបានសម្រេច និងព្រះវិញ្ញាណបរិសុទ្ធទ្រង់អនុវត្តសេចក្តីសង្គ្រោះ។ "ព្រះអង្គដែលគង់នៅ ហើយជាអង្គដែលបានយាងមក ហើយនឹងត្រឡប់មកវិញផង"។ ជានាមបរិសុទ្ធដែលចង្អុលទៅកាន់ ព្រះវរបិតាដែលទ្រង់គង់នៅ ទ្រង់ជាអង្គដែលមានព្រះជន្មគង់នៅដោយខ្លួនឯងនៅអស់កល្បជានិច្ច ហើយទ្រង់ជាប្រភពនៃការដែលពេញដោយព្រះពរទាំងអស់ និងគ្រប់ទាំងហេតុការណ៍ផង។ ព្រះពរគួរតែចេញមកពីប្រភពយ៉ាងជ្រៅ។

“វិញ្ញាណទាំងប្រាំពីរដែលនៅខាងមុខបល្ល័ង្ក” ជានាមបរិសុទ្ធរបស់ព្រះវិញ្ញាណបរិសុទ្ធ ដែលធ្វើឱ្យយើងបានដឹងពីចេស្តាយ៉ាងពេញលេញ។ ចេស្តារបស់ទ្រង់មិនមានកំណត់ទេ ហើយទ្រង់អាចបង្កើតកូនចៅរបស់អ៊ីស្រាអែលចេញពីថ្មក៏បាន។ ទ្រង់អាចសម្រេចនូវអ្វីដែលព្រះទ្រង់ចង់បាន។ ពាក្យថា “ហើយអំពីព្រះយេស៊ូវគ្រីស្ទជាស្មរបន្ទាល់ស្មោះត្រង់ ដែលកើតពីពួកស្លាប់មកមុនគេបង្អស់ ជាអធិបតីលើអស់ទាំងស្តេចនៅផែនដី”។ ចង្អុលទៅកាន់ព្រះរាជបុត្រា គឺព្រះយេស៊ូវគ្រីស្ទ ហើយបង្ហាញពីហាន:ទ្វេជាបីរបស់ទ្រង់ផង។ ហាន:នោះមាន បន្ទាល់ស្មោះត្រង់គឺជាដំណែងរបស់ហោរា ការពិតនៃការសុគតរបស់ទ្រង់បានអនុវត្តនូវហាន:ជាហោរារបស់ទ្រង់ ហើយការពិតដែលទ្រង់មានព្រះជន្មរស់ឡើងវិញ និងបានក្លាយជាសិរសានៃស្តេចនៅផែនដី មានន័យថាទ្រង់ជាស្តេចលើអស់ទាំងស្តេច។ ព្រះគ្រីស្ទបានធ្វើសម្រេចការសង្គ្រោះរបស់យើងដោយបំពេញតាមហាន:ទ្វេរជាបីរបស់ទ្រង់។ នៅក្នុងហាន:ជាហោរារបស់ទ្រង់ ទ្រង់បានធ្វើឱ្យយើងបានស្គាល់ព្រះវរបិតា នៅក្នុងតំណែងជាសង្ឃ ទ្រង់បានជំនួសកន្លែងយើង ហើយបានបង់ថ្លៃលោះយើង ហើយទ្រង់ជាជីវិត (ជាស្តេចដែលផ្តល់ជីវិតដល់យើង) ទ្រង់ធ្វើឱ្យយើងរស់នៅអស់កល្បជានិច្ច។ អ្វីដែលទ្រង់បានបង់ថ្លៃលោះយើងត្រូវបានសម្រេចមិនមែនដោយសារឈាមសត្វទេ តែដោយសារលោហិតរបស់ទ្រង់។ មិនតែប៉ុណ្ណោះទ្រង់ធ្វើឱ្យយើងអាចបម្រើព្រះ និងធ្វើឱ្យយើងបានក្លាយជាសង្ឃ និងធ្វើឱ្យយើងស្តេចដូចជាអង្គទ្រង់ផ្ទាល់។ សិទ្ធិនៃសង្ឃមិនស្រួលទេ។ ស្តេច អ៊ូសៀ នៅក្នុងសម័យបុរាណ បានព្យាយាមអះអាងពីតំណែងជាសង្ឃដោយបង្ខំ នោះទ្រង់ក៏ត្រូវបានដាក់ទោស (2របាក្សត្រ 26:16-21)។ មិនត្រឹមតែប៉ុណ្ណោះ

តើការដែលក្លាយជាស្តេចតើនឹងលំបាកប៉ុណ្ណាទៅ! ប៉ុន្តែព្រះគ្រីស្ទបានធ្វើឱ្យយើងបានក្លាយជាសង្ឃនិងជាស្តេច។ នេះជាហានៈដ៏ខ្ពស់បំផុតដែលមនុស្សអាចទទួលបាន។

4. ព្រះគ្រីស្ទដែលយាងមកដើម្បីនឹងកាត់ទោស (7, 8)។ ចំពោះមនុស្សដែលមិនបានសង្កេតការខាងលោកិយនេះឱ្យបានល្អ គាត់មើលឃើញថាកិច្ចការនៅក្នុងលោកិយនេះគ្មានប្រយោជន៍ទេ។ តើហេតុអ្វីបានជាមានមនុស្សទុច្ចរិតហើយហេតុអ្វីបានជាគេរស់បានសុខសាន្តយូរម្ល៉េះ? ទោះជាយ៉ាងណាក៏ដោយ អ្នកស្រាយជ្រាវដែលមានការពិចារណាបានដឹងពីកម្មពារនៅក្នុងលោកិយ។ គាត់ឃើញថាមនុស្សអាក្រក់ត្រូវទទួលបានថ្លៃឈ្នួលតាមការដែលគេធ្វើ។ វាកម្រណាស់ដែលមនុស្សទុច្ចរិតត្រូវបានដាក់ទោសដោយព្រះក្នុងកំឡុងពេលដែលគាត់កំពុងធ្វើបាបនោះ។ វាបានធ្វើឱ្យយើងយល់ពីសេចក្តីសប្បុរសរបស់ព្រះ។ ព្រះទ្រង់មិនចង្អៀតចង្អល់ទេ ហើយទ្រង់ក៏មិនមានការខឹងច្រឡោតដែរ។ នេះជាបុគ្គលិកលក្ខណៈគួរឱ្យចាប់អារម្មណ៍របស់ព្រះនៅក្នុងការគ្រប់គ្រងលើលោកិយទាំងមូល ដែលទ្រង់រង់ចាំពួកទុច្ចរិតអស់ពេលជាយូរ ហើយជាចុងក្រោយទើបទ្រង់ដាក់ទោសពួកគេ។ យើងមិនដឹងថ្ងៃនៃការយាងមកលើកទីពីររបស់ព្រះយេស៊ូវទេ តែវានឹងមកលើលោកិយនេះយ៉ាងប្រាកដមែន។ បើទោះជាមនុស្សដេកនៅក្នុងអំពើបាប ហើយមិនបានរៀបចំទទួលការកាត់ទោសក៏ដោយ ក៏ការកាត់ទោសមិនត្រូវបានពន្យាពេលឡើយ។

ព្រះគ្រីស្ទយាងមកផែនដីដើម្បីកាត់ទោសលោកិយ។ ពេលនោះ អ្នកដែលចាក់ទម្លុះទ្រង់នឹងឃើញទ្រង់ ព្រោះទ្រង់នឹងមកផែនដីដោយសិរីល្អ និងឫទ្ធានុភាពរបស់ទ្រង់។ ពេលទ្រង់ប្រសូត្រនៅក្រោលសេះ ហើយយាងកាត់ក្នុងស្រុកយូដា មានមនុស្សជាច្រើនមិនស្គាល់ថាទ្រង់ជាមេស្ស៊ីទេ។ ប៉ុន្តែនៅពេលទ្រង់យាងមកជាលើកទី2 វាមិនដូចគ្នាទេ។ អ្នកដែលចាក់ទំលុះទ្រង់នឹងអាចស្គាល់ទ្រង់បាន។ តើអ្នកណាទៅដែលបានទំលុះទ្រង់នោះ? ពួកគេជាអ្នកដែលបានឆ្កាងទ្រង់។ បន្ទាប់ពីព្រះយេស៊ូវបានសុគតនៅលើឈើឆ្កាង មានកិច្ចការដ៏អស្ចារ្យជាច្រើនបានកើតឡើងនៅក្នុងសម័យនៃគម្ពីរសញ្ញាថ្មី។ ការពិតដែលថាព្រះយេស៊ូវទ្រង់ត្រូវ ហើយអ្នកដែលសម្លាប់ទ្រង់គឺខុស គឺត្រូវបានបង្ហាញឱ្យឃើញដោយភស្តុតាងជាច្រើនរួចមកហើយ។ រួចមក សកម្មភាពដែលមិនព្រមជឿព្រះយេស៊ូវ ជាការធំជាងអំពើបាបដែលសម្លាប់ព្រះយេស៊ូវជាលើកទីពីរផង។ វាច្បាស់ណាស់ថា នៅក្នុងគ្រានោះ មនុស្សដែលបានស្លាប់ព្រះយេស៊ូវនៅលើឈើឆ្កាងតិចជាមនុស្សបន្ទាប់ពីការដែលព្រះយេស៊ូវទ្រង់មានព្រះជន្មរស់ឡើងវិញ។ ដូច្នេះមនុស្សក្រោយមកដោយការពិតដែលមិនព្រមជឿព្រះយេស៊ូវ ហើយមិនស្តាប់បង្គាប់ទ្រង់ នោះជាអំពើបាបធ្ងន់ជាង។ ដូច្នេះ សាវកប៉ុលបាននិយាយថា “ឬតើយើងចង់បណ្តាលឱ្យព្រះអម្ចាស់ប្រចណ្ឌឬអី តើយើងខ្លាំងពូកែជាងទ្រង់ឬ?” (1កូរិនថូស 10:22)។

5. “ប៉ាត់មុស” ជាកន្លែងដែលមនុស្សមានបាបត្រូវបានបញ្ជូនទៅនៅក្រោមការគ្រប់គ្រងរបស់ពួករ៉ូម។ យោងតាមសាច់រឿងនិទាន កាលដែល ព្រះចៅអធិរាជ ដូមីធាន (គ.ស 81-96) បានគ្រប់គ្រងនាសម័យនោះ សាវកយ៉ូ

ហានត្រូវបានបញ្ជូនទៅកោះនោះ នៅ គ.ស 96។ គាត់ត្រូវបានដោះលែង និងបានត្រឡប់មកក្រុងអេភេសូរវិញ។ សាច់រឿងនេះត្រូវបានប្រាប់មកដោយ លោក អ៊ីរ៉ានាស យ៉ូស៊ីបៀស និង ជើរ៉ូម ជាដើម។ នៅក្នុងបល្ល័ង្កនៃសេចក្តី ទុក្ខលំបាក សាវកយ៉ូហានបានទទួលការបើកសម្តែងយ៉ាងមានតម្លៃបំផុត។ នៅក្នុងពេលតែមួយ ផ្លូវនៅលើផែនដីត្រូវបាបបិទ តែផ្លូវទៅស្ថានសួគ៌បាន បើកឡើង។ យើងក៏ដូចគ្នាជាអ្នកដែលត្រូវបានធ្លាក់ចុះនៅក្នុងសេចក្តីវេទនា ត្រូវតែបើកផ្លូវនោះ។ (ខ 9)។

6. ថ្ងៃរបស់ព្រះអម្ចាស់ជាពាក្យថា ថេ ឃូរៀខេ ហេមេរ៉ា (τῇ κυριακῇ ἡμέρᾳ) ជាភាសាក្រិក។ មានតែទីនេះ (ខ 10) ចេញមក។ សម័យក្រោយពួកសាវក ព្រះបន្ទូលត្រូវបានប្រើច្រើន សៀវភៅរបស់ អ៊ីណាធាស និយាយថា “កុំរក្សា ថ្ងៃសប្ប័ថអី តែត្រូវរក្សាថ្ងៃព្រះអម្ចាស់វិញ”។ (ad Mag. 9:1)។ ហើយដំណឹង ល្អពេត្រុសនិយាយថា “ថ្ងៃរបស់ព្រះអម្ចាស់ភ្លឺចែងចាំងណាស់”។ ហើយ សំបុត្ររបស់បាណាបាសនិយាយថា “យើងរក្សាជានិច្ចនូវថ្ងៃនៃការរស់ឡើង វិញរបស់ព្រះអម្ចាស់ ដែលជាថ្ងៃទីប្រាំបី ដោយអំណរ។ សម័យពួកសាវកក៏ មានភស្តុតាង នៅក្នុងចំណោមប្រាំពីរថ្ងៃ គឺថ្ងៃទីមួយបានថ្វាយដល់ព្រះ (1កូរិនថូស 16:2) ហើយបានធ្វើពិធីលៀងព្រះអម្ចាស់ផង (កិច្ចការ 20:7) ។ល។ ថ្ងៃដែលសាវកយ៉ូហានបានថ្វាយបង្គំព្រះអម្ចាស់ នោះជាថ្ងៃដែលគាត់បាន ទទួលការបើកសម្តែងគឺនៅថ្ងៃព្រះអម្ចាស់ ហើយគាត់បានទទួលព្រះគុណនៅ ពេលដែលសមស្រប។

7. ជើងចង្កៀងមាសទាំងប្រាំពីរ (ខ 12) ចេញមកពីសាការី 4:2 ហើយចង្កៀល ទៅកាន់ក្រុមជំនុំ ដែលចែងចាំងពន្លឺឡើង។ ព្រះយេស៊ូវមានបន្ទូលថា “អ្នក

រាល់គ្នាជាពន្លឺលោកិយ” (ម៉ាថាយ 3:14-16)។ ការពិតដែលវាត្រូវបានធ្វើពីមាស មានន័យថា (1) ក្រុមជំនុំជារតនៈសម្បត្តិដ៏ខ្ពស់បំផុត។ (2) ក្រុមជំនុំនឹងមិនត្រូវវិនាសអស់កល្បជានិច្ច។ មាសពិតត្រូវបាននិយាយថាជារបស់ដែលមានតម្លៃខ្ពស់បំផុតនៅក្នុងលោកិយនេះ។ (សុភាសិត 3:14, 8:9, 10 16:16-22, 25:12) ហើយជារបស់ដែលនឹងមិនត្រូវរលាយបាត់ឡើយ។ (យ៉ូប 23:10)។ ក្រុមជំនុំមានតម្លៃដូចជាត្បូងនៅទីរហោស្ថាន នាងទទួលនូវការបៀតបៀនជាច្រើន តែនឹងស៊ូទ្រាំដល់ទីបញ្ចប់។

8. ព្រះយេស៊ូវគ្រីស្ទជាសម្តេចសង្ឃដ៏ខ្ពស់នៃក្រុមជំនុំ និងជាស្តេច។ ទ្រង់បានជំនួសអ្នកជឿ ហើយសម្រុះសម្រួលពួកគេផង។ មិនត្រឹមតែប៉ុណ្ណោះ ទ្រង់បានលុបចោលអំពើបាប និងការកាត់ទោសរបស់បាបចេញសម្រាប់ក្រុមជំនុំផង។

ការអធិប្បាយ

ការអធិប្បាយទី 1. ពេលវេលាជិតមកដល់ហើយ (វិវរណៈ 1:1-3)

យើងឃើញពីពង្សាវតារនៃ “ពេលវេលាដែលជិតមកដល់” នៅក្នុងគំនិតនៃពួកសាវ័កពីបុរាណ។ ពួក Formgeschichte បានចង្អុលថា វាជាការច្របូកច្របល់របស់ពួកសាវ័កនិងក្រុមជំនុំដើម។ តែដូចដែលបងគម្ពីរបាននិយាយ ការយាងមកជាលើកទីពីររបស់ព្រះអម្ចាស់គឺនៅជិតបង្កើយ ហើយវាជាពាក្យដែលពួកគេបានបង្រៀនថាជាសេចក្តីពិត។

1. បទគម្ពីរមិននិយាយតាមស្តង់ដាររបស់មនុស្សទេ តែនិយាយតាមស្តង់ដាររបស់ព្រះ។

វាមានន័យថា កាលដែលព្រះអម្ចាស់មានបន្ទូលថា អ្នកជឿត្រូវតែបរិសុទ្ធ នោះពួកគេត្រូវតែបរិសុទ្ធតាមស្តង់ដាររបស់ទ្រង់។ កាលដែលទ្រង់បានហៅអ័ប្រាហាំនៅស្រុកកាល់ដេហើយបានទាញគាត់ចេញមក ព្រះបានធ្វើឱ្យការនោះបានសម្រេចបន្ទាប់ពី400ឆ្នាំក្រោយមក ហើយទ្រង់ក៏បានធ្វើវាឱ្យសម្រេចមែន (លោកុប្បត្តិ 15:13, 14) ព្រះទ្រង់ឃើញ1000ឆ្នាំដូចជា1ថ្ងៃ (2 ពេត្រុស 3:8)។ ពេលយើងឃើញពាក្យដែលបទគម្ពីរចង្អុលថា ពេលនៃការយាងមកលើកទីពីរជិតមកដល់ យើងមិនគួរគិតថាវាជាពេលដែលខ្លីទេ។ រង្វាស់ដែលព្រះរាប់ពេលវាធំជាងរង្វាស់របស់ពួកយើង។ យើងគួរតែរស់នៅដូចជារង្វាស់របស់ទ្រង់។ វាជាសេចក្តីជំនឿ។ ទាល់តែស្តាប់បង្គាប់ដល់គំនិតដែលធំរបស់ព្រះ ទើបយើងមិនជំពប់ដួល។ ហោរាអេសាយនិយាយថា “ពីព្រោះព្រះយេហូវ៉ាទ្រង់មានបន្ទូលថា គំនិតអញ មិនមែនដូចជាគំនិតរបស់ឯងរាល់គ្នាទេ ឯផ្លូវរបស់ឯងរាល់គ្នាក៏មិនមែនជាផ្លូវរបស់អញដែរ។ ដ្បិតផ្ទៃមេឃខ្ពស់ជាងផែនដីយ៉ាងណា នោះអស់ទាំងផ្លូវរបស់អញ ក៏ខ្ពស់ជាងគំនិតរបស់ឯងរាល់គ្នាយ៉ាងនោះដែរ” (អេសាយ 55:8, 9)។

2. ពីព្រោះថ្ងៃនៃសញ្ញាថ្មីបានជាឆាកមួយនៃការមកដល់នៃអាណាចក្ររបស់ព្រះរួចហើយ ដែលយើងឃើញពីលក្ខណៈនៃថ្ងៃនោះ ដែលជាថ្ងៃបែបជាពេលចុងបញ្ចប់នៃពេលវេលា (ហេព្រើរ 1:1)

ព្រះយេស៊ូវមានបន្ទូលថា “ប្រាកដមែន ខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា អ្នកណាដែលស្តាប់ពាក្យខ្ញុំ ហើយជឿដល់ព្រះអង្គ ដែលចាត់ឱ្យខ្ញុំមក អ្នកនោះមានជីវិតដ៏នៅអស់កល្បជានិច្ច ហើយមិនដែលត្រូវជំនុំជំរះឡើយ គឺកន្លងហួសពីសេចក្តីស្លាប់ ទៅដល់

ជីវិតវិញ។” (យ៉ូហាន 5:25)។ ការបង្រៀនរបស់សញ្ញាថ្មីបង្ហាញថា ថ្ងៃនៃសញ្ញាថ្មីគ្រាន់តែជាថ្ងៃចុងក្រោយ ហើយការយាងមកលើកទីពីររបស់ព្រះអម្ចាស់ជាការដែលបន្ទាន់ ពីព្រោះវានឹងបានសម្រេចនៅក្នុងថ្ងៃនេះ (ភីលីព 4:5)។ ដូច្នេះ លោក Riddelbos ជាអ្នកសាសនវិទូបែបលិទ្ធិកាល់វីននៅក្នុងពេលនោះ ការយាងមកលើកទីពីររបស់ទ្រង់មិនត្រូវបានបំបែកពីការយាងមកលើកទីមួយរបស់ទ្រង់ឡើយ តែធ្វើឱ្យព្រឹត្តិការណ៍ពីរបានចូលគ្នាតែមួយនៅក្នុងទស្សនៈនៃគ្រាចុងក្រោយរបស់គាត់។ និយាយទៅគឺ ការយាងមកលើកទីមួយរបស់ព្រះអម្ចាស់ជាការចាប់ផ្តើមនៃការយាងមកលើកទីពីររបស់ទ្រង់។ គាត់និយាយថា យើងគួរតែពិចារណាថាការទាំងពីរគួរតែត្រូវបានគិតថាជាការតែមួយវិញ។ ត្រង់ចំណុចនេះ លោក Reddelbos បានសង្កេតលើការបើកសម្តែងនៃសញ្ញាថ្មីយ៉ាងត្រឹមត្រូវ។ (យោងតាម Riddelbos, De Komst van Het Koninkrijk) ពីព្រោះយើងរស់នៅក្នុងគ្រានៃសញ្ញាថ្មី នោះយើងគួរតែមានអារម្មណ៍បែបបន្ទាន់នៃគ្រាចុងក្រោយនៃលោកិយ។ អារម្មណ៍ដែលជាគំនិតស្របតាមសេចក្តីពិត។ សាវ័កពីដើមដើម្បីនឹងស្គាល់សេចក្តីពិតត្រូវតែដឹងការមួយនោះ។ ដូច្នេះដោយសារពួកគេមានអារម្មណ៍ពី “ការយាងមកលើកទីពីររបស់ព្រះអម្ចាស់ជិតមកដល់ហើយ” ហើយអះអាងថា វាគ្រាន់តែជាការបង្ហាញពីសេចក្តីពិតប៉ុណ្ណោះ។

យើងគួរតែរស់នៅដោយអារម្មណ៍ដែលបន្ទាន់នៃការយាងមកលើកទីពីររបស់ព្រះអម្ចាស់។ វាជាជីវិតនៃសេចក្តីពិត។ មានតែព្រះប៉ុណ្ណោះដែលដឹងថា ព្រះអម្ចាស់នឹងយាងមកម្តងទៀតមិនថាវាជាអនាគតដែលនៅជិតនេះ ឬក្រោយមកនោះទេ។ ទោះជាយ៉ាងណា យើងគ្រាន់តែគិតពីវានៅក្នុងលំនាំនៃលក្ខណៈនៃគ្រានោះ។ លក្ខណៈនៃគ្រានោះបង្ហាញពីពណ៌នៃគ្រាចុងក្រោយនៃលោកិយនេះ។

3. ពីព្រោះវាជាពេលដែលព្រះបានកំណត់ទុក នោះយើងមិនមានអារម្មណ៍ថាធុញទ្រាន់ទេ ប៉ុន្តែយើងទទួលវាទុកដូចជាពេលនៃរឿងដ៏ឧត្តុងឧត្តមបំផុត។

“ដែលទ្រង់នឹងបង្ហាញនៅពេលដែលសមស្រប” ក្នុង 1ធីម៉ូថេ 6:15 ជាពាក្យដែលបានប្រើនៅក្នុងការយាងមកជាលើកទីពីរ។ អ្នកជឿមិនមានអារម្មណ៍ធុញទៅកាន់ពេលនោះទេ ហើយក៏មិនគិតពីវាថាជាពេលដៅនៅឆ្ងាយដែរ។ គាត់បានទួញសោកនឹងសភាពដែលមិនពេញលេញរបស់គាត់ ដោយសារគាត់ចង់បានទទួលស្គាល់ដោយព្រះអម្ចាស់នៅក្នុងគ្រានៃការយាងមកជាលើកទីពីរ ហើយបានលះបង់ខ្លួនរបស់គាត់ដើម្បីនឹងទទួលឧសត្រូវទៅកាន់ព្រះអម្ចាស់។ ទំនួលខុសត្រូវរបស់គាត់មានរាប់ពាន់ រាប់ម៉ឺនប្រភេទ។ គាត់រវល់ណាស់។ ដូច្នេះហើយ គាត់គ្មានពេលទំនេរមុនគ្រានៃការយាងមកលើកទីពីររបស់ព្រះអម្ចាស់។ សម្រាប់អ្នកដែលមានទំនួលខុសត្រូវខ្ពស់ពេលវេលាហាក់ដូចជាលឿនណាស់។ គាត់ក្រោកឈរនៅចន្លោះការយាងមកលើកទីពីរនិងពេលបច្ចុប្បន្ន ដែលគាត់មានពេញដោយកម្មវិធីដែលគួរកោតសរសើរជាច្រើននៅក្នុងចិត្ត។ គាត់សប្បាយនឹងធ្វើទំនួលខុសត្រូវ។ ដូចដែលលោកអ័ប្រាហាំមិនបានទទួលសេចក្តីសន្យាក្នុងកាលដែលគាត់បានមកដល់ទឹកដីកាណាន តែ4000ឆ្នាំក្រោយមកគាត់បានទទួលវា គាត់មិនមានអារម្មណ៍ធុញទ្រាន់ តែរស់នៅក្នុងជីវិតនៅក្នុងត្រសាលយ៉ាងស្មោះត្រង់។

ម្នាក់ដែលមានអារម្មណ៍បន្ទាន់នៃការយាងមកលើកទីពីរ (1) គាត់អធិស្ឋាន (1 ពេត្រុស 4:7), 2) គាត់ស្រឡាញ់ (1 ពេត្រុស 4:6) 3) គាត់អរសប្បាយ (ភីលីព 4:4) 4) គាត់អត់ទោស (ភីលីព 4:5) 5) គាត់បោះអំពើបាបចោល (រ៉ូម 13:11-14) 6) គាត់

ចេះគ្រប់គ្រងខ្លួនឯងដោយចាត់ចែងរបស់ខាងលោកិយដោយត្រឹមត្រូវ (1កូរិនថូស 7:29-31) 7) គាត់អត់ធន់ស៊ូទ្រាំ (យ៉ាកុប 5:7)

ការអធិប្បាយទី 2 អ្នកដែលចូលរួមក្នុងទុកលំបាករបស់ព្រះយេស៊ូវនិងការរងទ្រាំរបស់ទ្រង់និងនគររបស់ទ្រង់ (វិវរណៈ 1:1-8)

“ការរងទុក្ខរបស់ព្រះយេស៊ូវ” ជាពាក្យដែលបានកើតឡើង ពីព្រោះអ្នកដើរតាមព្រះយេស៊ូវជួបនូវសេចក្តីរងទុក្ខពិតមែន។ មិនមែនគ្រាន់តែជាពាក្យថា “សេចក្តីរងទុក្ខរបស់ព្រះយេស៊ូវ” ដែលបានភ្ជាប់នោះទេ ពីព្រោះអ្នកដែលរងទុក្ខលំបាកបានជឿលើព្រះយេស៊ូវដោយមានទំនុកចិត្ត។ បរិស្ថានដែលល្អសម្រាប់ការបង្កើតផលផ្លែជា កន្លែងនៃទុក្ខលំបាក។

1. មនុស្សត្រូវបានបង្ហាត់យ៉ាងត្រឹមត្រូវដោយសារទុក្ខលំបាក

ទំនុកដំកើង 119:67 “កាលមុនដែលទូលបង្គំកើតទុក្ខព្រួយ នោះទូលបង្គំបានវង្វេងទៅ តែឥឡូវនេះ ទូលបង្គំកាន់តាមព្រះបន្ទូលទ្រង់វិញ”។ ហើយនៅទំនុកដំកើង 119: 69-72 ក៏មានបន្ទូលថា “ពួកមនុស្សឆ្មើងឆ្មៃបានបង្កើតសេចក្តីភូតភរទាស់នឹងទូលបង្គំ តែទូលបង្គំនឹងរក្សាទុកនូវបញ្ញត្តទ្រង់យ៉ាងអស់ពីចិត្ត ចិត្តគេស្ពឹកដូចជាមនុស្សមានខ្លាញ់ខន់

តែទូលបង្គំមានចិត្តអំណរចំពោះក្រឹត្យវិន័យទ្រង់វិញ។ ការដែលទូលបង្គំកើតមានទុក្ខព្រួយ នោះគឺជាប្រយោជន៍ដល់ទូលបង្គំហើយ ដើម្បីឱ្យទូលបង្គំបានរៀនយកបញ្ញត្ត

របស់ទ្រង់។ ក្រឹត្យវិន័យដែលចេញពីព្រះឱស្ឋទ្រង់មកនោះវិសេសដល់ទូលបង្គំ ជាជាងមាសប្រាក់ទាំងពាន់ផង។” លោក ស្ពឺចិន បានបកស្រាយបទគម្ពីរនេះយ៉ាងត្រឹមត្រូវថា “ភាពចម្រុងចម្រើនជាការសាកល្បងមួយដែលខ្លាំងនិងលំបាកដល់អាកប្បកិរិយាជាង។ មួយម៉ោងនៃរដូវក្តៅបង្កើតសេចក្តីពុករលួយច្រើនជាងថ្ងៃដ៏វែងមួយនៃរដូវត្រជាក់។ ដូច្នេះលោក St. Bernard បានអធិស្ឋានថា “ព្រះអម្ចាស់អើយ សូមក្រោធនឹងទូលបង្គំទៅ (Iracaris mihi Domine) ដែលជាមនុស្សល្ងីល្ងើដូចជាសត្វចៀម។ ចៀមដែលរវែងផ្លូវរបស់ខ្លួនកាលដែលពួកគេជួបនឹងអាកាសធាតុល្អ នោះពួកគេទាសចេញទៅគ្រប់ទិស។ តែនៅពេលមានភ្លៀងធ្លាក់មក និងមានខ្យល់បក់មក នោះពួកគេក៏ស្វែងរកហ្វូងរបស់ពួកគេហើយត្រឡប់មកវិញ។ ប្រៀបដូចជាអ្នកជឿត្រឡប់មកកាន់ជំនឿនៅពេលដែលពួកគេរងទុក្ខដែរ។ នៅពេលមនុស្សជួបបញ្ហា នោះគេត្រូវបានបង្វឹកនិងត្រូវបានសម្រេចវា ហើយបង្រៀនពីអំណាចរបស់គេមក។ វាប្រៀបដូចជាសេចក្តីពិតដែលផ្កាស្អាតៗជាច្រើននៅលើកំពូលភ្នំដែលមានខ្យល់ខ្លាំងក៏លូតលាស់ឡើង។”

2. វាជាការកំណត់ទូទៅរបស់ព្រះអម្ចាស់ដែលបន្ទាប់ពីការរងទុក្ខនោះសេចក្តីសុខសាន្តក៏មកដល់

គ្រប់ការទាំងអស់នៅក្រោមមេឃ យើងមិនឃើញថាសេចក្តីសុខសាន្តមកដោយគ្មានការរងទុក្ខឡើយ។ លោក Ruskin បាននិយាយថា សេចក្តីសុខសាន្តមិនមែនជាផលផ្លែនៃព្រំលិខិតឡើយ។ វាមិនរង់ចាំយើងទេ។ យើងទទួលបានវា កាលដែលយើងអាចយកឈ្នះអំពើបាបនិងសេចក្តីអាម៉ាស់របស់វា។ ហើយយើងទទួលបានវា កាលណាដែលយើងយកឈ្នះនូវអ្នកដែលគៀបសង្កត់និងសេចក្តីពុករលួយ។ វាជាពាក្យដែលបកស្រាយបទគម្ពីរយ៉ាងត្រឹមត្រូវ។

3. ពីព្រោះព្រះជួយយើងនៅក្នុងការរងទុក្ខ នោះយើងមិនគួរខ្វល់ខ្វាយឡើយ

លោក ស្ពឺចិន បានបកស្រាយបទគម្ពីរយ៉ាងត្រឹមត្រូវថា “វាមិនមែនសម្រាប់ស្រមៃទេ ថា ទ្រង់ដែលជួយយើងនៅក្នុងបញ្ហាទាំងប្រាំមួយនឹងចាកចោលយើងនៅក្នុងបញ្ហាទីប្រាំពីរ។”

ដូចជាលោក លូធើបានចូលរួមនៅក្នុងការប្រជុំនៅក្នុង សន្និបាត the Diet of Worms លោកមន្ត្រី ស្តាឡាទីន ជាអ្នកដែលការពាររលោកដោយកងកម្លាំង បានបញ្ជូនមនុស្សម្នាក់មកគាត់ដើម្បីជម្រុញគាត់កុំឱ្យចូលទៅក្នុងអង្គប្រជុំ។ បន្ទាប់មក លោក លូធើ បានឆ្លើយថា “ទៅកាន់អ្នកបម្រើរបស់គាត់ឱ្យផ្តល់ដំណឹង” បើទោះជាមានអារក្សជាច្រើនដូចជាដុំតដ្ឋជាច្រើននៅផ្ទះជាច្រើននៅក្នុងទីក្រុង វើម នេះក៏ដោយ។ កាលដែលគាត់ជិតស្លាប់ គាត់បានទុកពាក្យមួយថា “ខ្ញុំមិនខ្លាចអ្វីទាំងអស់។”

ការអធិប្បាយទី3 សភាពនៃការដែលសាវ័កយ៉ូហាន ជាអ្នកនិពន្ធនៃវិវរណៈបានទទួល (1:10)

“ហើយនៅថ្ងៃនៃព្រះអម្ចាស់ ខ្ញុំបានត្រឡប់ជានៅដោយវិញ្ញាណ នោះក៏ឮសំឡេងបន្លឺឡើង ដូចជាសូរត្រែ”។ នៅត្រង់នេះថា “បានត្រឡប់ជានៅដោយវិញ្ញាណ” គឺថា “ἐγενόμην ἐν Πνεύματι” ជាភាសាក្រិក។ ការបកប្រែត្រង់ៗនៃពាក្យនេះគឺ “ខ្ញុំស្នាក់នៅក្នុងព្រះវិញ្ញាណបរិសុទ្ធ”។ វាមានន័យថា ការទាំងមូលរបស់គាត់គឺនៅក្នុងការគ្រប់គ្រងនៃព្រះវិញ្ញាណបរិសុទ្ធ។ នៅក្នុងលោកនេះមានគ្រប់គ្រងដែលខុសឆ្គងជាច្រើន ដែលអ្នកដែលបានគ្រប់គ្រងបានបាត់ស្មារតីរបស់គេប្រៀបដូចជាការឆ្លីនភ្នែកដែរ។ ការបើកសម្តែងរបស់បទគម្ពីរជាចេស្តាយ៉ាងចម្បងដែលត្រូវបានគ្រប់គ្រងដោយចេ

ស្តារបស់ព្រះវិញ្ញាណបរិសុទ្ធ តែវាមិនចាំបាច់បញ្ឈប់ដល់ស្មារតីរបស់ខ្លួនដោយមានលក្ខខណ្ឌនោះទេ។ ដូចជាលោក សាំយ៊ូអែលបានស្តាប់ទៅកាន់ការត្រាស់ហៅរបស់ព្រះ ដែលគាត់ហាក់ដូចជាមានអារម្មណ៍ថាជាការហៅរបស់លោកអេលី ហើយក៏ទៅកាន់លោកអេលី នោះវាបញ្ជាក់ថា គាត់មានការដំណើរការបែបធម្មតានៃស្មារតីទៅកាន់ពិភពខាងក្រៅ។ ហេតុការណ៍ដែលប៉ុលបានទៅកាន់ស្ថានសួគ៌ទីបីហាក់ដូចជាបង្ហាញថា គាត់បានបាត់បង់ស្មារតីខ្លួន ហើយត្រូវបានធ្លាក់ចុះទៅក្នុងសភាពនៃការចូលទៅក្នុងភាពដូចជាព្រះ។ តែវាបង្ហាញថា គាត់មានកម្លាំងខ្សោយក្នុងការបែងចែក កាលដែលគាត់បានឃើញការបើកសម្តែងតែគាត់មិនព្យាយាមបែងចែកវា ដោយសារគាត់គ្មានស្មារតីរបស់ខ្លួនឡើយ។ តាមបទពិសោធន៍របស់គាត់ បទគម្ពីរថា “ខ្ញុំស្គាល់មនុស្សម្នាក់នៅក្នុងព្រះគ្រីស្ទ ដែលបានលើកឡើងទៅស្ថានសួគ៌ នៅជាន់ទី3 នោះប្រហែល14ឆ្នាំមកហើយ ទោះបើក្នុងរូបកាយ ឬក្រៅពីរូបកាយ នោះខ្ញុំមិនដឹងទេ មានតែព្រះដែលទ្រង់ជ្រាប” (កូរិនថូសទី2 12:2)។ វាមិនមានន័យថា គាត់ត្រូវបានបានចូលដូចជាសភាពនៃសុបិនទេ។ កាលដែលគាត់បានចូលទៅកាន់ស្ថានសួគ៌ទីបី “គាត់បានឮពីការដែលមិនអាចថ្លែងប្រាប់បាន”។ វាបញ្ជាក់ថា គាត់មិនបានធ្វើការចំណាំដោយឯកឯងនោះទេ តែគាត់មានស្មារតីដែលសកម្មទៅនឹងការកាត់សេចក្តីរបស់គាត់។ ផ្ទុយពីការនោះ ការអះអាងយ៉ាងចម្លែកកាលដែលគាត់ទទួលបានបទពិសោធន៍យ៉ាងអាថ៌កំបាំង ជាវិរិយាបថពីស្មារតីរបស់គាត់ត្រូវបានបាត់ទៅដែលជាញឹកញាប់ដោយសភាពដែលត្រូវបានបានគ្រប់គ្រង ហើយគាត់បានចូលទៅកាន់សភាពដែលអាថ៌កំបាំងនៃការរួបរួមរវាងព្រះនិងមនុស្ស ហើយត្រូវបានធ្លាក់ចុះទៅក្នុងនោះដូចជាភាពសភាពដែលស្រឹងស្រោ។

សេនថ៍ ម៉ារី ថេរេសា ជួនកាលបានចូលទៅក្នុងសភាពដូចជាស្លាប់ប្រហែល 5-6 ម៉ោង ហើយនៅក្នុងសៀវភៅ មិត្តរបស់ព្រះ មានមនុស្សម្នាក់ឈ្មោះ អេលីនុស បានចូលទៅក្នុងបទពិសោធន៍យ៉ាងអាថ៌កំបាំង ហើយនៅដូចជាមនុស្សលង់អស់រយៈពេល 7 ឆ្នាំ ហើយបានភ្ញាក់វិញពីសភាពដែលភាពភ្លឹកអស់រយៈពេល 7 ថ្ងៃ។ នៅពេលដែល Sundasing ថ្ងៃមួយបានចូលទៅក្នុងភាពដូចជាទេវតា ហើយបានភ្ញាក់វិញនៅក្រោមដើមឈើមួយ នោះរូបកាយរបស់គាត់បានហើមដោយសារសត្វឃ្មុំទិច។ តែគាត់មិនបានដឹងឡើយដោយសារសភាពនោះ។ ហើយកាលដែលគាត់ដឹកនាំការជួបជុំអធិស្ឋាន គាត់កំណត់ម៉ោងប្រាំបីព្រឹកជាម៉ោងចាប់ផ្តើម។ នៅពេលព្រឹកព្រលឹមថ្ងៃនោះនៅម៉ោងប្រាំព្រឹក ហើយបានចូលទៅក្នុងសភាពដូចជាទេវតា ការជួបជុំក៏ត្រូវកន្លងផុតទៅ ហើយក្រុមជំនុំនៅរង់ចាំគាត់ហើយក៏បែកគ្នាទៅ។

ទាំងនេះជាបទពិសោធន៍របស់លោក ស៊ុនដេស៊ីង និងការអាថ៌កំបាំងផ្សេងទៀត តែពួកគេមិនស្របគ្នានឹងគោលការណ៍នៃបទគម្ពីរនោះទេ។ គោលការណ៍របស់បទគម្ពីរជាការដែល មនុស្សម្នាក់ទទួលបានការបើកសម្តែងត្រូវបានគ្រប់គ្រងដោយព្រះវិញ្ញាណបរិសុទ្ធ ហើយមិនបានបាត់ស្មារតីខ្លួនឡើយ ហើយក៏ប្រកាសពីការបើកសម្តែងដល់អ្នកផ្សេងទៀត។ លោក បារីង និយាយដូចតទៅថា “សភាពដែលបាត់ស្មារតីពីខ្លួនជាបទពិសោធន៍របស់ការអាថ៌កំបាំងរបស់ក្រិកនៅក្នុងបទពីសោធន៍អាថ៌កំបាំងរបស់ពួកគេ”។ ហេតុការណ៍ដែលហោរាបានទទួលការបើកសម្តែងពីព្រះមិនបានកើតឡើងនៅក្នុងពេលពួកគេដេកលក់ទេ តែនៅពេលពួកគេភ្ញាក់នៅឡើយ ហើយវាមិនបានកើតឡើងតែពេលដែលនៅតែម្នាក់ឯងនោះឡើយ តែក៏ទទួលបាននៅពេលជួបប្រជុំជាមួយនឹងក្រុមជំនុំផងដែរ (អេសេគាល 8:1 និក្ខមនំ 4:-6: 32:7, អេសាយ

6:)។ ការចូលទៅក្នុងពិភពលោកនៃការអាថ៌កំបាំងខាងព្រះ ជាបទពិសោធន៍ដោយការស្រែកឃ្លានរបស់ពួកគេចង់បានបទពិសោធន៍នៅក្នុងដៃរបស់មនុស្ស។ វិធីដូច្នោះមិនត្រូវបានបង្រៀនដោយបទគម្ពីរឡើយ។ វាត្រូវបានផ្តាំមកថា ការចូលទៅក្នុងភាពរបស់ព្រះ ការគេចចេញពីព្រលឹងរបស់ពួកគេពីរូបកាយត្រូវបានកើតឡើងចេញពីសាសនាក្លែងក្លាយជាច្រើន ហើយការទាំងនោះបានកើតឡើងដោយការ តមអត់ ការវាយដំ ការរាំរែក ការសណ្តំជាដើម។ លោក Schwester Katrei ជាសាវ័ករបស់លោក Erchart គាត់ស្ទើរតែត្រូវស្លាប់ដោយការដកព្រលឹងរបស់ខ្លួនពីរូបកាយ។ មនុស្សបានរៀបចំបុណ្យសពរបស់គាត់។ ពីព្រោះបទពិសោធន៍ខុសឆ្គងនៃបទពិសោធន៍អាថ៌កំបាំងដូចជាការចូលទៅក្នុងភាពបែបជាព្រះ និងការដកព្រលឹងចេញពីខ្លួនជាបែបបទដែលត្រូវជាការរួបរួមរវាងព្រះនឹងមនុស្ស វាមិនមែនជាកំហុសនោះទេ។ ព្រះទ្រង់ជាព្រះអាទិករ ហើយមនុស្សជារបស់ដែលព្រះបានបង្កើតមក នោះយើងមិនអាចបំផ្លាញនូវបន្ទាក់ខណ្ឌដែលដាក់មកបានឡើយ។ ការពិតដែលយើងចងចាំវា ហើយស្គាល់ព្រះថាទ្រង់ជាព្រះអាទិករ ហើយមានការកោតខ្លាចដល់ព្រះអម្ចាស់ជា រូបភាពមួយនៃការថ្វាយបង្គំទ្រង់។ ពីព្រោះ សាសនាបំបែកនូវបន្ទាត់ខ័ណ្ឌរវាងព្រះនិងមនុស្ស ហើយអះអាងនូវការស្របសំខាន់របស់ព្រះនិងមនុស្ស វាខុសហើយ។ ការអាថ៌កំបាំងនៅក្នុងសម័យកណ្តាលបានអះអាងថា មនុស្សមានចំណុចដែលខ្ពស់បំផុតនៃចិត្ត (អណ្តាតភ្លើងចិត្ត) ដែលស្គាល់ព្រះ។ ពួកគេបានអះអាងថា កាលដែលមនុស្សផ្តោតលើព្រះដោយមុខងារនៃខួរក្បាលនោះគេអាចនឹងទៅដល់ព្រះ។

បទពិសោធន៍នៃសភាពដូចជាព្រះនៅក្នុងអាថ៌កំបាំង ឬបទពិសោធន៍នៃការដកព្រលឹងចេញពីខ្លួនជាផលនៃការដោយលះបង់របស់ពួកគេចុះចូល តែយើងមិនអាច

និយាយថាវាដូចជាការបើកសម្តែងដែលអស្ចារ្យឡើយ។ បន្ទាប់មក វាជាអត្ថន័យនៃបទពិសោធន៍ពីការអាថ៌កំបាំងមែនទេ? វាជាការដែលគ្មានតម្លៃមែនទេ? វាមិនមែនទេ។ យើងអាចដឹងការពិតថា លោកិយនៃសំភារៈនិងពិភពលោកនៃវិញ្ញាណចាកចេញហើយវិញ្ញាណមិនមែនជាផលនៃសំភារៈទេ វាចេញនៅក្នុងសភាពនៃការខ្ពស់ដាច់ចេញពីសំភារៈ ហើយអាចធ្វើដូច្នោះបាន។ នៅក្នុងវិទ្យាសាស្ត្របានបញ្ជាក់ថា វិញ្ញាណមាននៅដោយមិនពឹងលើសំភារៈឡើយ។ តាមការធ្វើពិសោធន៍របស់សកលវិទ្យាល័យដ្យូក ថាបើទោះជាមនុស្សនៅឆ្ងាយពីគ្នា កាលដែលគេផ្តោតលើគំនិតណាមួយដែលចង់ប្រាប់ដល់អ្នកផ្សេងទៀត វាអាចទៅរួច។ (The Reader's Digest February 1948 p 131)។

យើងដឹងថាវិញ្ញាណអាចចាកចេញពីសំភារៈបាន ហើយអាចធ្វើដំណើរបាន។ យ៉ាងណាក៏ដោយ យើងមិនអាចទុកចិត្តថា បទពិសោធន៍នៃការអាថ៌កំបាំងជាកម្រិតវាស់នៃសេចក្តីពិតឡើយ។ យើងមិនអាចទទួលយកការយល់ឃើញរបស់ពួកគេនៅក្នុងការខាងព្រះនិងការលើកឡើងរបស់ពួកគេទេ ពីព្រោះពួកគេខុសពីបទគម្ពីរ។ (1) លោកស៊ុនដេស៊ីង បាននិយាយថា ពួកបរិសុទ្ធនៅក្នុងស្ថានសួគ៌ធ្វើការដើម្បីនឹងសង្គ្រោះព្រលឹងដែលនៅក្នុងស្ថាននរក។ វាមិនមែនជាការបង្រៀនខុសឆ្គងទេ ដែលបទគម្ពីរមិននិយាយ។ (2) ហើយគាត់ក៏និយាយថា មនុស្សភាគច្រើននៅក្នុស្ថាននរកនឹងត្រូវបានសង្គ្រោះហើយចូលទៅក្នុងស្ថានសួគ៌បន្ទាប់ពីប៉ុន្មានជំនាន់ក្រោយមក។ វាផ្ទុយនឹងការបង្រៀនរបស់បទគម្ពីរ។ (3) គាត់បានឃើញព្រះយេស៊ូវនៅក្នុងសភាពដែលនៅខាងវិញ្ញាណរបស់គាត់ ទាំងនោះមាន សក់របស់ទ្រង់ដូចជាមានពណ៌មាស ពុកមាត់

របស់ទ្រង់នៅលើព្រះភ័ក្ត្រទ្រង់ ហើយព្រះភ័ក្ត្រទ្រង់ចែងចាំងមកលើគាត់ ហើយព្រះភ័ក្ត្រទ្រង់មើលទៅចិត្តល្អ ញញឹមជានិច្ច ហើយខ្ញុំមិនអាចភ័យខ្លាចទ្រង់ឡើយ។

ពាក្យនេះដែលលោក ស៊ុនដេស៊ីង បានសារភាពបង្ហាញពីធាតុថ្មីៗនៃការដែលមិនមែនចេញពីបទគម្ពីរ។ តែព្រះយេស៊ូវដែលលោកយ៉ូហានបានឃើញត្រូវបានបង្ហាញមកដូចជាការតំណាង ដែលជាការបើកសម្តែងបែបនិមិត្តរូបនៃសញ្ញាចាស់អំពីលក្ខណៈរបស់ព្រះមេស៊ីបែបនោះ។ អ្នកនិពន្ធនៃសញ្ញាថ្មីបានរៀបរាប់ជាធម្មតាពីស្ថានសួគ៌ និងព្រះ និងព្រះយេស៊ូវគ្រីស្ទដែលបានយាងមកដោយជៀសចេញពីពាក្យពីអារម្មណ៍ តែដោយប្រើធាតុនៃសញ្ញាចាស់តាមដែលអាចទៅរួច។

ការរៀបរាប់ពីព្រះគ្រីស្ទនៅក្នុងវិវរណៈ 1:12-20 មិនមានការរៀបរាប់អ្វីថ្មីទេ តែបានប្រើរបស់មកពីសញ្ញាចាស់ដដែលដូចជា សម្លេងត្រែ (និក្ខមនំ 19:19, ជនគណនា 10:1-10) 2) សម្លេងយ៉ាងខ្លាំង (អេសេគាល 3:12) 3) ទៀនមាសទាំងប្រាំពីរ (និក្ខមនំ 25:32 សាការី 4:2) 4) កូនមនុស្ស (ដានីយ៉ែល 7:13) 5) ទ្រង់បំពាក់ដោយសំលៀកបំពាក់វែងជាមួយនឹងខ្សែមាសព័ទ្ធទ្រូងរបស់ទ្រង់ (និក្ខមនំ 25:7, 28:4) 6) សក់របស់ទ្រង់មានពណ៌ស ដូចជារោមចៀម ដូចជាព្រិល (ដានីយ៉ែល 7:9) 7) ព្រះនេត្ររបស់ទ្រង់ដូចជាអណ្តាតភ្លើង (ដានីយ៉ែល 10:6) 8) ប្រអប់ជើងទ្រង់ដូចជាអណ្តាតភ្លើង (អេសេគាល 1:7) 9) ជើងរបស់ទ្រង់ដូចជាស្ពាន់ដែលឆេះសន្ធៅ ដែលបន្សុទ្ធនៅក្នុងឡ។ (អេសេគាល 49:2 ទំនុកដំកើង 29:3) 10) សម្លេងរបស់ទ្រង់ដូចជាសម្លេងទឹកជាច្រើន (អេសាយ 62:3, ដានីយ៉ែល 12:3) 11) នៅព្រះហស្តស្តាំទ្រង់មានកាន់ផ្កាយចំនួយប្រាំពីរ (អេសាយ 11:4 ហេព្រើរ 4:12)។ 12) ចេញពីព្រះឱស្ឋទ្រង់មានដាវមុខពីរយ៉ាងមុត (ម៉ាថាយ 17:2)។ 13) ព្រះភ័ក្ត្រទ្រង់ដូចជាព្រះអាទិត្យចែងចាំង

យ៉ាងខ្លាំង (និក្ខមនំ 33: 20, ជនគណនា 8:27) សំដៅលើការទាំងនោះ។ នៅទីនេះ រូបភាពដែលគាត់ស្ទើរតែស្លាប់នោះ វាហាក់ដូចជាភាពជាព្រះនិងការលេចមករបស់ទ្រង់។ តែការទាំងនេះ (ការពិតដែលយ៉ូហានស្ទើរតែស្លាប់) មិនមែនជាប្រភេទនៃសភាពខាងវិញ្ញាណ ឬការលេចមករបស់ព្រះទេ។ វាមានហេតុផល។ នោះជាការដែល មុនលោកយ៉ូហានបានឃើញព្រះយេស៊ូវ វាមិនមានន័យថា គាត់ស្ទើរតែស្លាប់នោះទេ។ និយាយមួយបែបទៀតថា វាមិនមែនជាការរៀបចំមុនពេលគាត់បានឃើញព្រះយេស៊ូវ (ដូចជាសភាពខាងវិញ្ញាណ) ប្រសិនបើគាត់ហាក់ដូចជាចស្លាប់នៅក្នុងលើកដំបូង នោះគាត់មិនអាចឃើញការបើកសម្តែងទេ។ បន្ទាប់ពីគាត់បានឃើញសិរីល្អនិងចេស្តារបស់ព្រះយេស៊ូវ នោះគាត់ហាក់ដូចជាស្លាប់។ នៅក្នុងសញ្ញាចាស់ កាលដែលលោកដានីយ៉ែលបានឃើញការបើកសម្តែង នោះគាត់ហាក់ដូចជាស្ទើរតែស្លាប់ (ដានីយ៉ែល 9:27)។ វាក៏មានន័យថា គាត់ហាក់ដូចជាស្លាប់ ពីព្រោះដោយសារការភ្ញាក់ផ្អើលរបស់គាត់ដោយបានឃើញការបើកសម្តែង។ តែវាមិនមានន័យថាគាត់បានឃើញការបើកសម្តែងដោយសារចិត្តនិងរូបកាយរបស់គាត់មិននៅតាមរបៀបរៀបរយនោះទេ។

ផ្នែកទី 2

ក្រុមជំនុំទាំងប្រាំពីរ 2:1-3:22

អត្ថន័យនៃក្រុមជំនុំទាំងប្រាំពីរ

ដោយសារលេខប្រាំពីរមានន័យថាជាលេខពេញលេញ បានហៅក្រុមជំនុំពីសម័យមុន និងសម័យថ្មី។ លោក ស្តូវហ្វីល បន្តែមថា “ក្រុមជំនុំទាំងប្រាំពីរជាទស្សនៈនៃសម័យទាំងប្រាំពីររហូតដល់ការយាងមកលើកទីពីររបស់ព្រះយេស៊ូវនៅក្នុងប្រវត្តិសាស្ត្រក្រុមជំនុំ”។ ទស្សនៈនេះ ក្រុមជំនុំពីបុរាណមិនមែនទេ ប្រហែល គ.ស 1200 លោក ជោគីម នៅ ហ្គ្លឺស បាននិយាយថា រីតរីងហ្គា នៅដាច់ឆ៊ ពន្យល់រាងខុសគ្នាបន្តិច។ យោងតាមទ្រឹស្តីនេះ (1) ចាប់តាំងពីសម័យសាវកយ៉ូហានរហូតដល់ការបៀតបៀនពីព្រះចៅអធិរាជ ឌីសើស (គ.ស 100-250) ត្រូវបានតំណាងដោយក្រុមជំនុំនៅក្រុងអេភេសូរ។ (2) ចាប់ពីសម័យនៃការបៀតបៀនរបស់ព្រះចៅអធិរាជឌីសើស រហូតដល់ អធិរាជ ដេអូឃ្លេសិន (250-311 A) ជាតំណាងដោយក្រុមជំនុំនៅស្មៀណា។ (3) ពីការបៀតបៀនរបស់អធិរាជដេអូឃ្លេសិនដល់ គ.ស 800 តំណាងដោយក្រុមជំនុំនៅទីក្រុងពើកាម៉ុស។ (4) សម័យចាប់ពី គ.ស 800 ដល់ គ.ស 12000 ជាបានតំណាងដោយក្រុមជំនុំនៅទីក្រុងធាទេរ៉ា។ (5) សម័យចាប់ពី គ.ស 1200 ដល់ គ.ស 1500 ជាតំណាងក្រុមជំនុំនៅក្រុងសើដេស។ (6) សម័យមុនការកំណែទម្រង់តំណាងឱ្យក្រុមជំនុំនៅក្រុងភីឡាដិលភា (7) សម័យនៃមនុស្សនិយម និងសម័យបន្ទាប់ជាត្រូវបានតំណាងដោយក្រុមជំនុំឡៅឌីសេ។

រួចមកយោងតាមទ្រឹស្តីនេះ ការបំបែកនៃសម័យមិនដូចគ្នាទេ តែខុសពីការបែងចែក
របស់ វិតធីងហ្គា។

(1) ក្រុមជំនុំនៅសម័យរបស់ពួកសាវកបានរក្សាព្រះគម្ពីរ និងគោលលិទ្ធិសេចក្តី
ជំនឿ តែមនុស្សដែលអនុវត្តវាបានពុករលួយ យើងអាចដឹងបានដោយអានសំបុត្រ
របស់យ៉ាកុប។ ដូច្នេះ វាត្រូវបានតំណាងដោយក្រុមជំនុំនៅក្រុងអេភេសូរ (2:1-7)។ (2)
ក្រុមជំនុំមុនសម័យនៃការប្រជុំក្រុមព្រឹក្សានីសៀ (គ.ស 100-313) មានរូបភាពនៃការ
សម្លាប់ ដូច្នេះវាត្រូវបានតំណាងដោយក្រុមជំនុំ ស្មឺណា (2:8-11) នៅក្នុងវិវរណៈរបស់
យ៉ូហាន។ (3) ក្រុមជំនុំនៃសម័យជាប្រជាជាតិបានពឹងផ្អែកលើអំណាចរបស់
លោកិយ ហើយបានចូលថ្វាយបង្គំដោយរូបភាពផ្សេងៗ ដោយការថ្វាយបង្គំពួក
បរិសុទ្ធជាដើម ហើយត្រូវបានតំណាងដោយក្រុមជំនុំនៅក្រុងពើកាម៉ុស (2:12-17)
ដែលមានទីតាំងនៅអាសនារបស់សាតាំង (អំណាចរបស់លោកិយ) (វិវរណៈ 2:13)
ដោយបរិភោគដង្វាយរបស់រូបព្រះក្លែងក្លាយ និងថ្វាយបង្គំរូបព្រះក្លែងក្លាយ។ (4)

ជំពូកទី 2

1. ពីព្រោះក្រុមជំនុំអេភេសូរបានរក្សាគោលលិទ្ធិសេចក្តីជំនឿ តែបានបាត់បង់សេចក្តីស្រឡាញ់ នោះនាងបានទទួលការជំរុញឱ្យរក្សាសភាពដែលពេញលេញ។ (1-7)

2. ពីព្រោះក្រុមជំនុំស្មឺណាបានទទួលការរងទុក្ខដោយសារព្រះជាម្ចាស់ នោះនាងបានទទួលការសរសើរ និងការលើកទឹកចិត្ត (8-11)។

3. ពីព្រោះក្រុមជំនុំពើកាម៉ុសបានទទួលពួកគ្រូក្លែងក្លាយ នោះនាងត្រូវបានព្រមាន (12-17)។

4. ពីព្រោះក្រុមជំនុំធាទេរាបានផ្តល់សិទ្ធិអំណាចដល់គ្រូក្លែងក្លាយ នោះនាងបានទទួលការស្តីបន្ទោសពីព្រះជាម្ចាស់។ (18-29)

ការបកស្រាយ

1-7 សំបុត្រដែលផ្ញើទៅក្រុមជំនុំអេភេសូរ។

ខ 1 ក្រុមជំនុំអេភេសូរ។ “អេភេសូរ” ជាទីក្រុងដ៏សំខាន់មួយនៅអាស៊ីមីនើ និងជាកំពង់ផែផងដែរ។ នៅគ្រានោះ វាជាផ្លូវឆ្លងកាត់ដើម្បីនឹងទាក់ទងរវាងតំបន់ខាងកើត និងតំបន់ខាងត្បូង (ប្រៀជដានុស) ពីព្រោះអេភេសូរជាក្រុមជំនុំដែលសំខាន់បំផុតនៅអាស៊ីមីនើ អាចនឹងត្រូវបានកត់ត្រានៅទីនេះ។

“ព្រះអង្គដែលកាន់ផ្កាយទាំង7នៅព្រះហស្តស្តាំ ហើយយាងនៅកណ្តាលជើងចង្កៀងមាសទាំង7នោះ ទ្រង់មានព្រះបន្ទូលសេចក្តីទាំងនេះថា”។ សំបុត្រប្រាំពីរចាប់ផ្តើមដោយប្រាប់ពីឈ្មោះនៃកិច្ចការរបស់ព្រះជាម្ចាស់នៅផ្នែកដំបូង ឈ្មោះនីមួយៗសុទ្ធតែសាកសមនឹងសំបុត្រនីមួយៗ។ “ដ្បិតទ្រង់កាន់ផ្កាយទាំង7" ហើយយាងនៅក្នុង

ចំណោមពួកគេ ហើយទ្រង់ដឹងពីគ្រប់ការល្អនិងការអាក្រក់របស់ក្រុមជំនុំ វាជាការពិតដែលទ្រង់ដឹងពីស្ថានភាពរបស់ក្រុមជំនុំអេភេសូរ។

2 អស់ទាំងការដែលឯងធ្វើ និងសេចក្តីនឿយហត់ ហើយសេចក្តីអត់ធ្មត់របស់ឯងហើយ។ "កិច្ចការ" មិនមែនជាសីលធម៌ដែលពិសេសទេ តែជាពាក្យដែលសង្ខេបកិច្ចការដែលនៅខាងក្រោម។ "ការនឿយហត់" គឺ ខូផូស (κοπος) ជាភាសាក្រិក ជាពិសេសវាចង្អុលទៅកាន់ការលះបង់នៃកំណើត។ ពីព្រោះក្រុមជំនុំអេភេសូរអាចនឹងមានសកម្មភាពច្រើនចេញពីហោរាក្លែងក្លាយ ការដែលត្រូវបណ្តេញពួកទាំងនោះចេញគឺអាចនឹងពិបាក។ វាមិនមែនជាការតយុទ្ធដោយឈាមនិងអំណាចទេ តែតយុទ្ធជាមួយនឹងការបង្កើតសីលធម៌។ មុននឹងសង្គ្រាមខាងវិញ្ញាណដូច្នោះត្រូវបានកើតឡើង វាពិបាកណាស់សម្រាប់ឱ្យគេយល់ពីការនឿយហត់។ "សេចក្តីអត់ធ្មត់" គឺ អ៊ីផូម៉ូនេ (υπομονη) ជាភាសាក្រិក ជាប្រភពនៃពាក្យដែលមានន័យថា "ស្ថិតនៅក្រោម" ។ ការអត់ធ្មត់មិនមែនស្អប់គ្រប់ទុក្ខលំបាកទាំងអស់នោះទេ ប៉ុន្តែគឺស្ថិតនៅក្រោមការលំបាកទាំងនោះយ៉ាងរឹងមាំ។ នេះជាអក្សរដែលចង្អុលទៅកាន់ការស៊ូទ្រាំដោយអវិជ្ជមាន និងដើម្បីយកឈ្នះ និងដើម្បីទៅមុខដោយវិជ្ជមាន។ ពីព្រោះពាក្យភាសាក្រិកនៃពាក្យថា "អស់អ្នកដែលអាក្រក់" ជានាមពហុវចនៈដែលគ្មាន article គឺវាសមណាស់ដែលត្រូវបកប្រែថា "ពួកមនុស្សដែលអាក្រក់"។ (ប្រៀបដានុស)។ ដ្បិតពាក្យថា ខាខូស Kakos (κακος) នៅក្នុងភាសាក្រិកនៃពាក្យនេះមានន័យថាជា ធាតុលក្ខណៈអាក្រក់ ព្រះដែលពេញដោយសេចក្តីមេត្តានិងក្រុមជំនុំក៏មិនអាចទទួលបានដែរ។ ការអាក្រក់ដូចនោះអាចជាមេរៀននៃគ្រូក្លែងក្លាយដែលជាពួកគ្រូក្លែងក្លាយនោះ។

ពួកអ្នក ដែលហៅខ្លួនជាសាវ័ក។ សាវកប៉ុលបានព្រមានដល់ក្រុមជំនុំអេភេសូរឱ្យប្រុងប្រយត្នឹងការជួបប្រជុំរបស់ពួកគេ (កិច្ចការ 20:28-30)។ ក្រុមជំនុំហាក់ដូចជាព្យាយាមប្រុងប្រយ័ត្ននឹងវាបានល្អណាស់។ យោងតាម ម៉ាថាយ 7:26, 2កូរិនថូស 11:13, កាឡាទី 1:8, 9។

3 ឯងបានអត់ធន់ ហើយទ្រាំទ្រ ទាំងធ្វើការដោយនឿយហត់ ឥតណាយចិត្តឡើយ ដោយព្រោះឈ្មោះអញ។ ឃ្លានេះហាក់ដូចជាផ្តោតលើផ្នែកទីមួយនៃខខាងលើដដែលៗ។ "ឈ្មោះអញ" ជាដំណឹងល្អដែលព្រះយេស៊ូវបានបង្ហាញ។

4 តែអញប្រកាន់សេចក្តីនេះនឹងឯង។ ព្រះគ្រីស្ទបានស្វែងរកអ្វីដែលទ្រង់បានសរសើរដល់ក្រុមជំនុំមុនគេ ហើយទ្រង់បានស្តីបន្ទោសដល់ចំណុចខ្សោយបន្ទាប់ទៀត ពីព្រោះ (1) វាគឺជាសេចក្តីស្រឡាញ់របស់ទ្រង់ក្នុងសេចក្តីមេត្តាដល់មនុស្ស (2) ក្រោយមកទ្រង់បានបន្ទោសចំនុចអាក្រក់របស់គេ វាគឺជាសេចក្តីសុចរិតរបស់ទ្រង់។ ប៉ុន្តែការស្តីបន្ទោសនេះក៏មិនមែនជារឿងឈាមក្តៅទេ តែដោយហេតុផលនៃការស្រឡាញ់ដើម្បីនឹងកែកំហុសវិញ។ "សេចក្តីស្រឡាញ់ដំបូង" (ចំពោះព្រះ និងមនុស្ស) គឺជាសេចក្តីស្រឡាញ់ដែលពួកជំនុំអេភេសូរមាននៅពេលដំបូង កាលដែលនាងជឿលើព្រះយេស៊ូវ។ គេយកសេចក្តីស្រឡាញ់ដើម្បីរក្សាគោលលទ្ធិនៃសេចក្តីជំនឿ ប៉ុន្តែហេតុអ្វីបានជាគេបោះចោលសេចក្តីស្រឡាញ់? ដូចដែលបទពិសោធន៍ និងប្រវត្តិសាស្ត្របានបង្ហាញឱ្យឃើញ ថាវាងាយស្រួលធ្វើ ព្រោះវាពិបាកណាស់ដែលមនុស្សទស្សនៈទាំងពីរនៃជីវិតរបស់ខ្លួន។ ប៉ុន្តែប្រសិនបើពួកគេរក្សាសេចក្តីស្រឡាញ់ដោយលះបង់ នោះពួកគេអាចនឹងស្ថិតនៅក្នុងព្រះគុណ។ ពេលគេត្រូវការជជែកដេញដោល គេមិនគួរធ្វើដោយឈាមក្តៅ ឬហឹង្សាទេ តែដោយប្រាជ្ញា ការអត់ធ្មត់ ការលះបង់ គុណធម៌។ ដូច្នេះ វាជា

ការលំបាកដែលបុគ្គលអ្នកជឿអាចធ្វើបាន ប៉ុន្តែអ្នកជឿគ្រប់រូបគួរតែរួបរួមគ្នា ។ ក្រុមជំនុំអេភេសូរមានការអត់ធ្មត់ និងការលះបង់ ប៉ុន្តែគុណធម៌ និងប្រាជ្ញារបស់នាងគឺខ្លី។ បើគេមានប្រាជ្ញា និងគុណធម៌ នាងក៏អាចនឹងមានសេចក្តីស្រឡាញ់ផងដែរ។

5 ចូរនឹកចាំ ដែលឯងបានធ្លាក់ចេញពីសណ្ឋានណានោះ ហើយប្រែចិត្តចុះ រួចប្រព្រឹត្តតាមការដើមដំបូងនោះវិញ

ការនេះសង្កត់ធ្ងន់ពីសេចក្តីត្រូវការអំពើដើម្បីស៊ើបអង្កេតមូលហេតុនៃអំពើបាប។ មាគ៌ានៃការប្រែចិត្ត និងការអត់ទោសបាប មានតែនៅក្នុងគ្រីស្ទសាសនាតែមួយប៉ុណ្ណោះ។ ទោះជាអំពើបាបធំដូចភ្នំក៏ដោយ ប្រសិនបើគេប្រែចិត្តពិតប្រាកដ ព្រះនឹងអត់ទោសឱ្យគេ។ ទោះជាមានអ្នកដែលបានប្រែចិត្តរួច ប៉ុន្តែបានប្រព្រឹត្តអំពើបាបម្តងទៀតខ្លាំងក៏ដោយ ប្រសិនបើគាត់ប្រែចិត្តពីអំពើបាបរបស់គាត់ពិតប្រាកដ តើព្រះអត់ទោសឱ្យគាត់ទេ? ទ្រង់នឹងអត់ទោសបាបឱ្យគាត់។ វាគឺជាការអត់ទោសបាបដ៏ពិតប្រាកដ។ វាជាការអត់ទោសបាបដែលព្រះទ្រង់គិត។(ម៉ាថាយ 18:21, 22)។ បែបដូចនោះ គឺការប្រែចិត្តមានតម្លៃណាស់ ប៉ុន្តែបន្ទាប់ពីមនុស្សបានប្រព្រឹត្តអំពើបាបដោយអាកប្បកិរិយាក្រអឺតក្រទម គឺមានករណីជាច្រើនដែលគាត់មិនចូលចិត្តនឹងប្រែចិត្ត។ ដូច្នេះ ព្រះដាក់ទោសគាត់ ដើម្បីធ្វើឱ្យគាត់ប្រែចិត្តពីអំពើបាបរបស់គាត់។ ឯការដាក់ទោសនេះមានគោលបំណងដើម្បីឱ្យប្រែចិត្ត មិនមែនជាការដាក់ទោសដែលជាកម្រិតទទួលនូវការរងទុក្ខខាងផ្លូវកាយនោះទេ ប៉ុន្តែវាក៏ជាការដាក់ទណ្ឌកម្មដ៏អាក្រក់ផងដែរ។

ដូច្នេះ ពេលយើងប្រព្រឹត្តអំពើបាប យើងត្រូវប្រែចិត្តពីអំពើបាបភ្លាម។ កាលដែលយើងប្រែចិត្តពីអំពើបាបរបស់យើង យើងគួរតែដឹងពីចំណុចចាប់ផ្តើមនៃអំពើបាប។

ព្រោះបាបមានលក្ខណៈសាយភាយ កាលណាចំណុចចាប់ផ្តើមត្រូវបានព្យាបាល នោះវាក៏ជាសះស្បើយដែរ។

ពុំនោះសោត អញនឹងមកឯង ហើយនិងហូតយកជើងចង្កៀងឯងពីកន្លែងចេញ លើកតែឯងប្រែចិត្តឡើងវិញ

វាជាទំនាយដែលក្រុមជំនុំអេភេសូរនឹងត្រូវដកចេញ ពិតណាស់សព្វថ្ងៃនេះ បានប្រាប់មកថា គ្រប់ទីក្រុងទាំងអស់ត្រូវបានបោះបង់ចោល។ (ហ្គ្រេចដានុស ឆាល)។ ពីព្រោះក្រុមជំនុំមិនបានស្តាប់ទៅកាន់ការជំរុញរបស់ព្រះយេស៊ូវ វាក៏ដូច្នោះមែន។ (នូវែល)។ រ៉ាំសេ និយាយថា ក្រុមជំនុំនឹងត្រូវបានដកចេញទៅកន្លែងផ្សេងទៀត តែវាមិនត្រូវទេ។

ពួកនីកូឡាស

លោកអ៊ីរ៉ានុសបាននិយាយថា មានចាស់ទុំម្នាក់នៅក្នុងចំណោមប្រាំពីរនាក់នៅក្នុងក្រុមជំនុំនៃសម័យដើមត្រូវបានដកចេញ ហើយគឺដោយសារការបង្រៀនខុសឆ្គងដែលគាត់បានបង្រៀន។ (Adv. Haer I, 26, 3)។ ប៉ុន្តែតើចាស់ទុំអាចបានពេញដោយព្រះវិញ្ញាណបរិសុទ្ធបានដូចម្តេច? (កិច្ចការ 6:5) ត្រូវបានពុករលួយនោះ? អ្នកខ្លះនិយាយដូចតទៅនេះថា “ភាសាដើមថា នីកូឡាស មានន័យថា ដើម្បីនឹងយកឈ្នះមនុស្ស មិនមែនជាឈ្មោះបុគ្គលដែលទាក់ទងនឹងលោកបាឡាមទេ (בִּלְעָם = ដើម្បីយកឈ្នះមនុស្ស) នៅក្នុងសញ្ញាចាស់ (ជនគណនា 22:12) ប៉ុន្តែជាក្រុមនៃគ្រូក្លែងក្លាយទេដែលត្រូវយកឈ្នះ ហើយដើម្បីនឹងកំទេចពួកគេទៅជាមួយនឹងសេចក្តីបង្រៀនខុសឆ្គងរបស់ពួកគេផង។ ការបង្រៀនរបស់ពួកនីកូឡាសត្រូវបានបើបង្ហាញ

នៅក្នុង 2:14, 20 ពិតណាស់ វាមិនមែនជាការស្តាប់បង្គាប់ព្រះវិញ្ញាណបរិសុទ្ធនៅក្នុង កិច្ចការ 15:28, 29។ (ឆាលស៍)។

អស់អ្នកណាដែលឈ្នះ

វាមិនមែនជាទម្រង់អតីតកាលទេ តែជាទម្រង់បច្ចុប្បន្នកាលកំពុងបន្ត (νικῶντι), (ព្រ្ហេចដានុស) (យោងតាម ម៉ាថាយ 23:13)។ ជ័យជំនះនៃសេចក្តីជំនឿមិនមែន ពេលដើម្បីនឹងបំពេញលោកិយសព្វថ្ងៃនេះទេ។ វាចង្អុលទៅកាន់ពេលកំពុងដំកើងការ រហូតដល់ពេលនៃការចាកចេញរបស់យើង។ នៅទីនេះ “ការយកឈ្នះ” ក៏ជាការសរ សេររបស់សាវកយ៉ូហានដែរ។ សំបុត្រទីមួយរបស់យ៉ូហានក៏បើកសម្តែងពាក្យនេះដែ រ។ យោងតាម 1យ៉ូហាន 5:4, 5។

ស្ថានសួគ៌របស់ព្រះ។ នេះជាកន្លែងដែលព្រលឹងចូលទៅបន្ទាប់ពីបានចាកចេញ។ (លូកា 23:34)។ ប៉ុលបានទៅទីនោះ វាប្រៀបដូចជាស្ថានសួគ៌ជាន់ទីបី (2កូរិនថូស 12:2)។ លើកលែងតែវា បើទោះជាព្រះយេស៊ូវមានបន្ទូលពីស្ថានសួគ៌ដោយផ្ទាល់ក៏ដោយ តែទ្រង់មានបន្ទូលដោយប្រយោលនៅក្នុងការប្រៀបធៀប “នៅដើមទ្រូងរបស់អ័ ប្រាហាំ”។ អ្នកនិពន្ធរបស់អាប៉ូគ្រីផា បាននិយាយច្រើនពីស្ថានបរមសុខបែបខាងអារ ម្មណ៍។ ប៉ុន្តែតាមដែលវាប្រៀបធៀបនឹងស្ថានបរមសុខដែលព្រះយេស៊ូវនិងសាវក របស់ទ្រង់និយាយ គឺវាខុស ពីព្រោះវាមានពណ៌ខុសគ្នា ដែលចេញមកពីការស្រមើស្រ ម៉ៃរបស់មនុស្ស។ ពៃរ៉ូនី បាននិយាយថា “ការពិតដែលស្ថានបរមសុខមិនអាចរក្សា ភាពស្ងៀមស្ងាត់ អក្សរសិល្ប៍ដែលអាថ៌កំបាំងរៀបរាប់វាយ៉ាងស្រស់ស្អាត។” តែយើង

ទទួលស្គាល់ថា ការកត់ត្រាសាមញ្ញរបស់បទគម្ពីរគឺពិតជាង វាល្អនិងស្រស់ស្អាតផង។

តាមប្រពៃណីមួយថា “ស្ថានបរមសុខ” ត្រូវបានចាត់ទុកថាជាផ្នែកនៃស្ថានឃុំព្រលឹង។ គឺជាព្រលឹងរបស់មនុស្សអាក្រក់ដែលចូលទៅផ្នែកមួយនៃស្ថានឃុំព្រលឹង និងព្រលឹងមនុស្សសុចរិតចូលទៅក្នុងផ្នែកមួយនៃស្ថានឃុំព្រលឹងនោះ។ តែវាមិនមែនជាទ្រឹស្តីត្រឹមត្រូវទេ។ នៅក្នុងគម្ពីរសញ្ញាចាស់ពាក្យថា “ស្ថានឃុំព្រលឹង” ត្រូវបានប្រើជាស្ថានភាពរបស់មនុស្សដែលស្លាប់ (ផ្នូរ) (យ៉ូប 10 :21, 26:5, ទំនុកដំកើង 88:10-12, 94:17,22 115:12 សុភាសិត 2:18, 15:11, 21:16, អេសាយ 14:9, 26:14) ។ គ្រប់ខគម្ពីរទាំងនេះសុទ្ធតែមានន័យថាជាផ្នូរ។ តែព្រះគម្ពីរនិយាយថាជាឋានឃុំព្រលឹងដែលព្រលឹងរបស់មនុស្សទុច្ចរិតទៅនៅ។ (យោងតាម ទំនុកដំកើង 44:23, អេសេគាល 26:20, អេសាយ 9:9, 10, ម៉ាថាយ 11:23)។ ហើយស្ថានបរមសុខស្ថិតនៅក្នុងពិភពនៃស្ថានសួគ៌ (2កូរិនថូស 12:4)។

ដើមឈើជីវិតចេញមកដំបូងនៅក្នុងលោកុប្បត្តិនៅក្នុងគម្ពីរសញ្ញាចាស់ (លោកុប្បត្តិ 2:9, 3:22) ដែលត្រូវបានបកប្រែក្នុងន័យប្រៀបធៀប និងបែបប្រវត្តិសាស្ត្រ។

ការបកប្រែតាមន័យប្រៀបធៀបអះអាងថា ដើម្បីឈើនេះមិនមាននោះទេ តែវាជាការប្រៀបប្រដូចនៃទស្សនៈនៃ “ជីវិតអស់កល្បជានិច្ច”។ តែការនេះក៏វាដោយឡែកដែរ។ យើងឃើញថាដើមឈើជាដើមឈើពិត ហើយវាក៏ជាការប្រៀបធៀបទៅនឹងព្រះគ្រីស្ទជាព្រះអម្ចាស់ជីវិតដែរ។ (លោកបណ្ឌិត ហ្គេហាត វ៉ែស)។ រូបកាយជាជីវិតអស់កល្បជា

និច្ច ហើយការបរិភោគអាហារជារូបភាពនៃពិភពលោកដែលនឹងមកដល់ (យោងតាម វិវរណៈ 22:2)។

អ័ដាមមិនបានយកឈ្នះទេ ហើយបានបាត់បង់នូវអាហារខាងជីវិតអស់កល្បជានិច្ច នោះ។ អ្នកដែលឈ្នះនៅក្នុងព្រះគ្រីស្ទបានទទួលវាម្តងទៀត។ ផ្លែឈើផ្ងាល់មិនមាន អំណាចវេទមន្តធ្វើឱ្យមនុស្សមានជីវិតអស់កល្បជានិច្ចទេ។ អំណាចដែលធ្វើឱ្យមនុស្ស មានជីវិតអស់កល្បជានិច្ចមានតែនៅក្នុងព្រះគ្រីស្ទតែមួយអង្គគត់។ ផលផ្លែនៃដើមឈើ នឹងជាចំណែករបស់ពួកបរិសុទ្ធនៅក្នុងផែនដីដែលនឹងមកដល់។

អាផូគ្រីជា និយាយថា ផលផ្លែត្រូវបានប្រាប់ថាជាការដូចតទៅនេះ “ពួកបរិសុទ្ធនឹងប្រើ ទឹកជីវិតនេះជាទឹកអប់”។ (2 Esd 2:12) “ទឹកអប់នៃដើមជីវិតវាល្អឥតខ្ចោះជាងទឹក អប់ទាំងអស់ ហើយស្លឹកឈើនិងដើមនឹងមិនត្រូវស្រែកឡើយ ហើយផលផ្លែនោះ ប្រៀបដូចជាផ្លែនៃដើមត្នោត”។ (Ethiopic Enoch 24:4)។ រឿងនេះនៅក្នុងអាផូគ្រីជា ជាលទ្ធផលនៃការស្រមើស្រម៉ៃរបស់មនុស្ស តែមិនមែនជាសេចក្តីពិតទេ។

អ្នកណាដែលមានត្រចៀក ឱអ្នកនោះស្តាប់ ដល់អ្នកដែលមានត្រចៀកខាងវិញ្ញាណ ដែលអាចនឹងស្តាប់ទៅកាន់ព្រះបន្ទូលរបស់ព្រះ។ ដោយសារហេតុផលនេះ វាបាន និយាយដូចខាងក្រោមថា “ឱអ្នកនោះស្តាប់សេចក្តី ដែលព្រះវិញ្ញាណមានព្រះបន្ទូល ដល់ពួកជំនុំទាំងប៉ុន្មានចុះ”។ ព្រះបន្ទូលនេះបង្រៀនយ៉ាងច្បាស់ដល់ក្រុមជំនុំ និងអ្នក ជឿដោយផ្ងាល់។

ដល់ពួកជំនុំទាំងប៉ុន្មាន (ταῖς ἐκκλησίαις) ពាក្យថាផ្ញើទៅកាន់ក្រុមជំនុំអេភេសូរ ផ្ងាល់ត្រូវបានបង្ហាញថា “ក្រុមជំនុំ” វាមានន័យពីការពិតដែលថា សំបុត្រត្រូវបានសរ សេរទៅកាន់ក្រុមជំនុំ។

8-11 សំបុត្រផ្ញើទៅកាន់ក្រុមជំនុំស្មឺណា

ខ 8 ស្មឺណា។ នេះជាទីក្រុងបច្ចុប្បន្នដែលមានទីតាំងនៅភាគខាងជើងនៃអេភេសូរ ហើយមានទន្លេ មីដេស។ នៅក្នុងគ្រានោះ ប៉ូលីខាប ជាប៊ីស្សពនៅក្នុងទីក្រុងនោះ។ កាលបរិច្ឆេទដែលគាត់ត្រូវបានគេសម្លាប់គឺនៅ គ.ស 168។

ព្រះដ៏ជាដើម ហើយជាចុង ដែលបានសុគតរួចមានព្រះជន្មរស់ឡើងវិញ ទ្រង់មានបន្ទូលសេចក្តីទាំងនេះថា។ នេះជាព្រះនាមរបស់ព្រះអម្ចាស់ ដែលជាការសម្រាលនិងជាសង្ឃឹមដល់ក្រុមជំនុំស្មឺណាដែលរងទុក្ខ។ ព្រះនាមរបស់ព្រះអម្ចាស់ដែលចេញមកពីសំបុត្រទាំងប្រាំពីរ ត្រូវបានធ្វើឡើងដោយការបង្ហាញទំនាក់ទំនងដែលសមស្របទៅកាន់ក្រុមជំនុំទាំងប្រាំពីរ។ “ជាដើម” និង “ចុង” មានន័យថាមានអ្វីដែលនៅអស់កល្ប ហើយវាក៏មានន័យថាជាមួយអង្គដែលបង្កើតសកលលោក ទ្រង់រក្សាវា ហើយនឹងត្រឡប់ទៅរកទ្រង់វិញ។ នាមថា “បានសុគតហើយបានរស់ឡើងវិញ” មានន័យថាជា មួយអង្គដែលបានសុគតដើម្បីនឹងប្រោសលោះមនុស្សមានបាប ហើយទ្រង់បានយកឈ្នះសេចក្តីស្លាប់ដើម្បីរំដោះមនុស្សជាច្រើន ហើយទ្រង់បានរស់ឡើងវិញ ហើយទ្រង់ក៏ផ្តល់សេចក្តីរស់ឡើងវិញដូចគ្នានោះដល់អ្នកជឿយ៉ាងពេញលេញ។

9 សេចក្តីទុក្ខលំបាក និងសេចក្តីកំសត់របស់ឯង។ សេចកក្តីទុក្ខលំបាក (θλῖψιν) ជាការបៀតបៀនពីខាងក្រៅដោយសារសេចក្តីជំនឿលើព្រះគ្រីស្ទ។ “πτωχείαvis” ជាសេចក្តីក្រីក្រនៃជីវិតរបស់ពួកគេដែលចេញមកពីលទ្ធផលនៃការបៀតបៀន។ អ្នកជឿត្រូវបានរងទុក្ខការបៀតបៀនដូច្នោះតាមរយៈពួកយូដាដែលមិនជឿ និងអ្នកបៀតបៀនពីសាសនាផ្សេងទៀត។ (ហេព្រើរ 10:34)។

*ប៉ុន្តែឯងជាអ្នកមានវិញ។*វាបង្ហាញថា ពួកគេក្រខាងសភាពរូបសាច់ នៅក្នុងវិញ្ញាណ ពួកគេជាអ្នកមាន។ យោងតាម លូកា 12:21, 1ធីម៉ូថេ 6:17, 18 2កូរិនថូស 6:10, វិវរណៈ 3:17, 2កូរិនថូស 6:10 យ៉ាកុប 2:5។

ខ្លាំងនៅតំបន់ស្មឺណា ហើយគ្រីស្ទានត្រូវបានគេបៀតបៀន។ (ដានីយ៉ែល 16, 11, និង3)។ វាត្រូវបានប្រាប់ថា មនុស្សក្នុងសាសនាយូដាមិនជឿព្រះយេស៊ូវទុកជាព្រះជាម្ចាស់របស់ពួកគេទេ តែបានយល់ច្រឡំថា ពួកគេជាកូនចៅរបស់អ័ប្រាហាំ និងការដែលបានក្លាយជាសាសន៍យូដាគឺជាការចូលសញ្ជាតិនៃស្ថានសួគ៌។ ដូចជាលោក ប៉ូលីខាប ត្រូវបានគេសម្លាប់ គឺពួកគេបានចូលរួមជាមួយនឹងអ្នកបៀតបៀនដែលគោរពសាសនាដទៃ ហើយសពរបស់ពួកគេក៏មិនមែនជាអ្នកជឿគ្រីស្ទានដែរ ហើយដែលធ្វើចរិតរឹកពារជាសាសន៍យូដា។

ទីប្រជុំរបស់សាតាំង។ ពាក្យនេះមិនបង្ហាញនៅក្នុងសញ្ញាចាស់ទេ តែត្រូវបានហៅដោយពាក្យថា ទីប្រជុំរបស់មនុស្សទុច្ចរិត។ (ជនគណនា 14:27, 35 ទំនុកដំកើង 21:16)។ វាស្រដៀងទៅនឹង “ទីប្រជុំរបស់សាតាំង” នៅក្នុងវិវរណៈ។ ហ្វូងមនុស្សជាសាសន៍យូដាដូច្នោះមិនបានកោតខ្លាចព្រះយេហូវ៉ាទេ តែបានបៀតបៀនអ្នកជឿគ្រីស្ទានដោយគ្មានរអា។ នៅក្នុងការសរសេររបស់លោក ប៉ូលីខាប ដែលជាប៊ីស្សពនៅក្រុមជំនុំស្មឺណា (Polyc. Mart. 15-) បានរៀបរាប់ថាសាសន៍យូដាបានធ្វើការបៀតបៀនដល់ដំណឹងល្អ។ ហើយបំណែកឯកសារដែលបង្ហាញសញ្ញានៃអ្នកដែលរស់នៅបង្ហាញពាក្យថាបោះបង់ចោលសាសនាយូដា។ (CIG. 3148)។

*10 នោះឯងរាល់គ្នានឹងត្រូវរងវេទនាអស់10ថ្ងៃ។*នេះជាពាក្យដ៏លំបាកមួយ។ (1) មានអ្នកបកស្រាយខ្លះគិតថា លេខនៃថ្ងៃនៅទីនេះចង្អុលពីសញ្ញានៃលេខនៃឆ្នាំ ដែល

ចង្អុលការបៀតបៀនយ៉ាងខ្លាំងនៃអធិរាជរ៉ូម គឺអធិរាជ ដេអូខ្លេសិន អស់រយៈពេលដប់ឆ្នាំ។ (2) ហើយអ្នកផ្សេងទៀតអះអាងថា វាចង្អុលទៅកាន់អំឡុងពេលទាំងដប់នៃអ្នកបៀតបៀនរ៉ូម៉ាំងទាំងដប់ ទាំងនោះមាន នេរ៉ូ (54-68) ដូមីធាន (81-96) ត្រាចាន់ (98-117) ហាឌ្រាន (117-138) ម៉ាកុស អារីលៀស (161-180), សែបធីមីន សើវៀស (193-211), ម៉ាស៊ីមីនុស (135-138) ឌីសៀស (249-251) វ៉ាលើរៀន(253-260), ដេអូក្លេសិន (254-305) ។ល។ តែមិនប្រាកដទេ។ (3) ព្រ្ហេជដានុស បានិយាយថា ការនោះត្រូវបានប្រៀបធៀបទៅនឹងអំឡុងពេលដែលបានកំណត់ដែលមិនមានពេលយូរ។ (De tien dagen spreken van een bepaalden tijd die eindigt, aan welken vaste grenzen gesteld zijn (យោងតាម 11:3, 12:6, 11:9-11)។ (4) នៅទីនេះ ខ្ញុំហាក់ដូចជាគិតថា ដប់ថ្ងៃគឺចេញមកពីដានីយ៉ែល 1:12, 14។ ដែលនោះជាការរងទុក្ខដែលគ្រីស្ទានទទួល ដើម្បីធ្វើឱ្យមានប្រយោជន៍ដល់ព្រលឹងរបស់ពួកគេ។ ដានីយ៉ែលបានរងទុក្ខដោយបរិភោគតែបន្លែនិងផឹកតែទឹកអស់រយៈពេលដប់ថ្ងៃតែចុងក្រោយ មុខរបស់គាត់បានផ្លាស់ប្រែទៅជារូបរាងដែលភ្លឺថ្លា។

យើងឃើញថាវាពិតជាមានតម្លៃដែល យើងគិតពីការបកស្រាយពីមួយនិងការបកស្រាយទីពីរចូលគ្នា។ ការរងទុក្ខដែលគ្រីស្ទានទទួលជាពេលមួយរំពេចដូចជាដប់ថ្ងៃ (1ពេត្រុស 1:6, រ៉ូម 8:18)។ មិនត្រឹមតែទុក្ខលំបាកដែលពួកគេបានជួបបាននាំមកនូវប្រយោជន៍ដល់ព្រលឹងរបស់ពួកគេនោះទេ។

មកុដនៃជីវិត។ ការនេះចង្អុលទៅកាន់ជីវិតនៃលោកិយដែលនឹងមកដល់និងសិរីល្អផង។ វាពិបាកដែល យើងមិនអាចនិយាយនៅក្នុងពាក្យសម្តីបែបស្ថានភាពបច្ចុប្បន្នកាលបាន។ នោះអ្នកដែលបានចូលរួមនៅក្នុងការត្រូវគេសម្លាប់នៅក្នុង

លោកិយ នោះមិនបានធ្លាក់ចុះក្នុងសេចក្តីស្លាប់ទាំងស្រុងនោះទេ តែគេត្រូវមានជីវិតរស់នៅវិញ ហើយគេក៏នឹងត្រូវបានរស់ឡើងវិញ ហើយនឹងទៅដល់ជីវិតពេលដោយសិរីរុងរឿងដល់ចំណុចខ្ពស់បំផុតនៃជីវិតរបស់គាត់ផង។

នៅក្នុងន័យរបស់លោក ព្រ្តេចដានុស បានសរសេរនូវការសម្គាល់ដែលទាក់ទង។ ( ) យោងតាមការអធិប្បាយរបស់ខ្ញុំ (ចូរប្រុងប្រយ័ត្នរហូតដល់ទីបញ្ចប់នៃការស្លាប់) ដែលមាននៅទីបញ្ចប់នៃជំពូក 2។

នោះសេចក្តីស្លាប់ទីពីរនឹងធ្វើទុក្ខដល់អ្នកនោះមិនបានឡើយ។ នេះគឺជាបំណែកចុងក្រោយនៃអ្នកដែលនឹងត្រូវវិនាស គឺថានឹងត្រូវមានវត្តមាននៅក្នុងបឹងភ្លើង វិវរណ 19:20, 20:10, និង 21:8។ យោងតាមទ្រឹស្តីមួយ អ្នកសរសេរបានយកចេញពីសមុទ្រស្លាប់ (ជាតំបន់នៃក្រុងសូដុម និងកូម៉ូរ៉ា ជាសមុទ្រមួយដែលអាក្រក់បំផុត ហើយហាក់ដូចជាបង្ហាញពីស្ថានមនុស្សស្លាប់ ជាកន្លែងដែលអាក្រក់ដែលយើងមិនអាចនឹងថ្លែងជាពាក្យសម្តីបាន។ សៀវភៅរបស់អេណុកប្រាប់យើងថា សមុទ្រស្លាប់ជាកន្លែងដែលវិញ្ញាណអារក្សត្រូវរងការដាក់ទោស។ ប៉ុន្តែយើងត្រឹមតែជឿលើការពិតដែលថាស្ថានឃុំព្រលឹងនៅក្នុងវិវរណរបស់យ៉ូហានថាជាកន្លែងដែលមនុស្សអាក្រក់នឹងត្រូវដាក់ទោសប៉ុណ្ណោះ។

12-17 សំបុត្រផ្ញើទៅកាន់ពើកាម៉ុស

ក្រុមជំនុំនៅទីក្រុងពើកាម៉ុស។ នេះជាទឹកដីដែលស្ថិតនៅក្បែរទន្លេសៃខាស ហើយទីនេះជាព្រះវិហារដែលត្រូវថ្វាយបង្គំដល់អធិរាជរបស់រ៉ូម ដែលព្រះវិហារមានឆ្លាក់រូបរបស់ អេស្កាផៀស ជាព្រះនៃពស់ ណាងព្រះវិហាររបស់ព្រះនៃ សេអ៊ូស ដែលត្រូវបាន

ហៅថាជា មជ្ឈមណ្ឌលនៃការថ្វាយបង្គំព្រះក្លែងក្លាយ។ ដូច្នេះ អត្ថបទនិយាយថា ទីកន្លែងនេះជាបល្ល័ង្ករបស់សាតាំង។

*ព្រះដែលមានជាវមុខ2ដ៏មុត។*ឈ្មោះនេះមានទំនាក់ទំនងខ្លាំងទៅកាន់ព្រះអម្ចាស់ ដែលបានយាងមកលើក្រុមជំនុំពើកាម៉ុស។ (យោងតាម 2:16) “ដាវមុខ2ដ៏មុត” ជាសញ្ញានៃព្រះបន្ទូលរបស់ព្រះ ដែលត្រូវបានប្រើដើម្បីនឹងទាញត្រឡប់មនុស្សមានបាប និងកាត់ទោសពួកគេ។ (យោងតាម ការបកស្រាយនៃ 1:16)។

13 ជាកន្លែងដែលមានបល្ល័ង្ករបស់អារក្សសាតាំង។ នេះគឺជាពាក្យដែលគេសន្មត់ថា ពើកាម៉ុម គឺជាមជ្ឈមណ្ឌលនៃរូបព្រះក្លែងក្លាយ។ ពើកាម៉ុម មានព្រះវិហារធំៗចំនួនបួន គឺ វិហាររបស់ហ្សេអ៊ូស វិហាររបស់ដីអូនីសើស វិហាររបស់អាដេណា វិហាររបស់អេស្កាភៀស ហើយក៏មានប្រាសាទចំនួនពីរដែលត្រូវបានបញ្ចុះដើម្បីគោរពបូជាព្រះចៅអធិរាជរ៉ូម៉ាំងផងដែរ។ ជាពិសេស នៅប្រាសាទផ្នូរ អេស្កូឡាភៀស ជនពិការត្រូវបានប្រមូលផ្តុំពីគ្រប់តំបន់ ហើយស្វែងរកវិធីព្យាបាលក្នុងសុបិនដែលព្រះ អេស្កូឡាភៀសបានផ្តល់ ដូចជា ពើកាម៉ុម គឺជាទីស្នាក់ការកណ្តាលនៃការថ្វាយបង្គំរូបព្រះនៅអាស៊ី នៅសម័យលោក យ៉ូហាន។ ទីតាំងប្រវត្តិសាស្ត្ររបស់ Zeus ត្រូវបានរកឃើញដោយជនជាតិអាឡឺម៉ង់ លោក ហ៊ូម៉ាន់ និងត្រូវបាននៅជាសារមន្ទីរ បែកលីុម។ (E, J Banks)

*អាន់ធីផាស។*បុរសម្នាក់នេះហាក់ដូចជាបុរសដែលត្រូវបានគេសម្លាប់នៅទីក្រុងពើកាម៉ុម ដែលមានឈ្មោះរបស់គាត់ឆ្លាក់នៅលើរូបចម្លាក់របស់ពើកាម៉ុមនៅសតវត្សទីបី។ (Deism, 187) លោកធើធូលៀន បានទទួលស្គាល់ថា បុរសនេះជាអ្នកដែលត្រូវគេសម្លាប់ពិតនៅក្រុងពើកាម៉ុម។ (Adv. Goat. Scrp 120)។ ប៉ុន្តែមិនមានប្រវត្តិសា

ស្តែលម្អិតអំពីបុរសនេះទេ។ យោងតាមព័ត៌មានប្រពៃណីរបស់ ស៊ីម៉ូន មេតាផ្រេត (វាគ្រាន់តែជាពាក្យប្រពៃណីប៉ុន្តែវាមិនមែនជាបទគម្ពីរទេ) អាន់ទីផាសគឺជាប៊ីស្សពដែលបង្រៀននៅព្រះវិហារ ពើកាម៉ុម បន្ទាប់មកសម្រាប់ឈ្មោះរបស់គាត់គឺខ្ពស់ គាត់ត្រូវបានចាប់ខ្លួនដោយនិកាយសាសនានៃអណាចក្រ៉ូម៉ាំង ហើយត្រូវបានដាក់ចូលទៅក្នុងគោធ្វើពីលង្ហិន ហើយត្រូវបានគេសម្លាប់។ (Moffatt) វាត្រូវបានគេជូនដំណឹងអំពីការពិតដែលថា យូស៊ីបៀស ខាភើស ជាជាយរីស អាហ្គាថូនិក និងអ្នកផ្សេងទៀតត្រូវបានគេសម្លាប់នៅក្នុងសំបុត្ររបស់យ៉ូហានចេញពីក្រុងពើកាម៉ុម។ (Eusebius H. E. 4:15, 48)។ វាត្រូវបានគេជូនដំណឹងថា ទោះបីជាអ្នកបៀតបៀនបានផ្តល់ការប្រហារជីវិតដ៏ឈឺចាប់ដែលមិនអាចរកពាក្យពន្យល់បានទៅកាន់អ្នកបុគ្គលដែលត្រូវបានគេសម្លាប់ដើម្បីឱ្យពួកគេនិយាយពាក្យប្រមាថដល់ព្រះគ្រីស្ទក៏ដោយ ក៏ពួកគេមិនចុះចាញ់នឹងពួកគេដែរ។

14, 15 ប៉ុន្តែអញប្រកាន់សេចក្តីខ្លះនេះនឹងឯង។ នៅទីនេះ “សេចក្តីខ្លះ” ចង្អុលទៅកាន់ពាក្យថា អូលីហ្គា (ὀλίγα) ជាភាសាក្រិក ដែលមានន័យថាបរិមាណតិចទួច និងជាលេខដែលអាចបង្ហាញនូវពហុវចនៈខាងលើជាជាការពីរ ឬលេខមួយ (Grejidanus)។

ជាថ្មដែលនាំឱ្យជំពប់ដល់កូនចៅអ៊ីស្រាអែល យោងតាម ជនគណនា 31:16, 25:1-5។ បាឡាម មិនបានដាក់បណ្តាសាទាស់នឹងអ៊ីស្រាអែលតាមការទាមទាររបស់បាឡាក់ទេ តែគាត់បានបង្រៀនពីវិធីល្បួងអ៊ីស្រាអែល និងការប្រព្រឹត្តសេចក្តីកំផិតរបស់ស្ត្រីសាសន៍ម៉ូអាប់ដល់បាឡាក់។ (ជនគណនា 24:25, 26:1, 31:16)។ មួយវិញទៀត ក្រុមជំនុំនៅពើកាម៉ុម ត្រូវបានជនទុច្ចរិតចូលទៅដោយសម្ងាត់ ហើយនាំពួកអ្នក

ជឿ ហើយនាំពួកគេចូលទៅក្នុងកន្លែងថ្វាយបង្គំព្រះក្លែងក្លាយ ហើយឱ្យពួកគេបរិភោគ
សំណែនទាំងនោះ ដែលពិតជាអាក្រក់ណាស់។ សកម្មភាពបែបនេះបានបំបែកច្បាប់
ដែលហាមឃាត់ដែលពួកសាវកបានបង្កើតឡើងនៅក្នុងព្រះវិញ្ញាណបរិសុទ្ធ ហើយ
បានបញ្ជូនវាទៅក្រុមជំនុំសាសន៍ដទៃ។ (កិច្ចការ15:20, 29)

16 ខនេះជាពាក្យរំលឹកពីការពិតដែលបាឡាមធ្វើជំទាស់នឹងព្រះហឫទ័យរបស់ព្រះ
ហើយទៅធ្វើតាមការសំណូមពររបស់បាឡាក់ ជាស្តេចម៉ូអាប់ ហើយគាត់ក៏បានជួប
នឹងទេវតារបស់ព្រះយេហូវ៉ាដែលមានដាវផង។ (យោងតាម ជនគណនា 22:31, 32
អេសេគាល Ezek 3:17-20, 33:6, 13)។ នោះអញនឹងយកដាវ ដែលនៅមាត់អញ
ច្បាំងនឹងគេ។ ព្រះអម្ចាស់មិនព្រមើយកន្តើយនឹងអ្នកដែលធ្វើបាបរាស្ត្ររបស់ព្រះអង្គ
ទេ ប៉ុន្តែទ្រង់ប្រាកដជាធ្វើប្រឆាំងនឹងពួកគេ។ ភាពផ្ទុយគ្នាបែបនេះត្រូវបានបង្ហាញដល់
បាឡាមផងដែរ (ជនគណនា 22:31, 32) វាពិតជាគ្រោះថ្នាក់ណាស់! វាជាទង្វើដ៏
លួងដែលធ្វើបាបរាស្ត្ររបស់ព្រះ!

17 នំម៉ាណាដ៏លាក់កំបាំង។ យោងទៅតាមទំនៀមទម្លាប់របស់រ៉ាប៊ី យេរេមា និងអេ
សាយបានលាក់ហិប ដែលមាននំម៉ាណានៅកន្លែងណាមួយ នៅពេលវេលានៃព្រះមេ
ស្ស៊ី បាននិយាយថានំម៉ាណានឹងត្រូវបានបង្ហាញជាសាធារណៈម្តងទៀត។ (2 Macc.
2:4-6 Mechilta Ex 16:25)។ តើពាក្យនេះនៅក្នុងខគម្ពីរបានគិតពីប្រពៃណីទេ? តើ
យើងមិនគិតដូច្នេះទេ? មេយើ បាននិយាយថាពាក្យ "លាក់កំបាំង" មានន័យថាវាមិន
មាននៅក្នុងពិភពលោកទេ ប៉ុន្តែនៅស្ថានសួគ៌។ នំម៉ាណា គឺជាអាហារនៅស្ថានសួគ៌វា
ហាក់ដូចជាការបកស្រាយមួយដ៏ត្រឹមត្រូវ។ ហ្គ្រេជដានុស ក៏បានយកការបកស្រាយ

ស្រដៀងគ្នានេះដែរ ដោយបានមានប្រសាសន៍ថា “នំម៉ាណាដែលលាក់កំបាំងគឺជាអាហារពិតដ៏អស្ចារ្យខាងវិញ្ញាណ។

គ្រួសសមួយ។ គ្រួស គឺជានិមិត្តសញ្ញានៃអ្នកជឿ (1ពេត្រុស 2:5-6) ហើយជាសញ្ញាសម្គាល់នៃមនុស្សដែលត្រូវបានជ្រើសរើស។ (និក្ខមនំ 28-15-21)។ ពន្លឺពណ៌ "ស" មានន័យថាបរិសុទ្ធ។ លោក ម៉ូហ្វាត គិតថា "ថ្មស" ត្រូវបានគិតថាចេញពីអបិយជំនឿរបស់ពួកអ្នកខុសឆ្គង ហើយបានណែនាំអបិយជំនឿមួយចំនួនដូចខាងក្រោម។ 91) បុរាណគិតថាថ្មពណ៌សមានន័យថាជាសញ្ញានៃសំណាង។ ប្រសិនបើឈ្មោះរបស់ព្រះត្រូវបានសរសេរនៅលើវា នោះវាអាចដេញអារក្សចេញបាន ហើយគេអាចចូលទៅកាន់កន្លែងថ្វាយបង្គំព្រះរបស់វាបាន។ (Dieterich. Mithrea Liturgie 31) យោងទៅតាមអបិយជំនឿនេះ ការសរសេរព្រះនាមរបស់ព្រះគ្រីស្ទនៅលើថ្មពណ៌សមានន័យថា អ្នកដែលជាម្ចាស់ថ្មនឹងត្រូវបានការពារពីគ្រោះថ្នាក់ទាំងអស់ ហើយអាចចូលទៅជិតព្រះយ៉ាងជិតស្និទ្ធ។ ប៉ុន្តែការបកស្រាយនេះចេញមកពីការយល់ខុសលើអ្នកនិពន្ធបទគម្ពីរទេ។ អ្នកនិពន្ធបទគម្ពីរស្អប់ទំនៀមទម្លាប់នៃអបិយជំនឿ ហើយបានទុកវាចោលមកវិញ។

(2) ម៉ូហ្វាត ម្តងទៀតបានឃើញចំណុចដែលសង្ឃទាក់ទងនឹងការថ្វាយបង្គំអធិរាជរ៉ូម៉ាំងបាននិយាយថា "សរសេរឈ្មោះខ្ញុំនៅលើថ្មបន្ទាប់មកអ្នកនឹងត្រូវបានទ្រទ្រង់ជានិច្ច" សម្រាប់ឈ្មោះអចិន្ត្រៃយ៍របស់គាត់គឺទាក់ទងនឹងខ្លឹមសារនេះ។ ប៉ុន្តែវាក៏ជាទ្រឹស្តីដ៏អាក្រក់ផងដែរ។ (3) គាត់ប្រហែលជាគិតថា នេះកើតចេញពីទំនៀមទម្លាប់ដែលថាក្នុងនាមជាគ្រូបង្ហាត់នៃពិធីជប់លៀងសាសនាអាថ៌កំបាំងដែលបានចូលជាសមាជិកធម្មតា គាត់គួរតែសរសេរឈ្មោះរបស់គាត់នៅលើថ្មស។ ប៉ុន្តែ នេះក៏ត្រូវបានគេ

និយាយផងដែរ ដោយមិនអើពើពីចិត្តរបស់អ្នកនិពន្ធបទគម្ពីរ។ អ្នកនិពន្ធក្នុងបទគម្ពីរ ស្អប់ទំនៀមទម្លាប់របស់អ្នកមិនជឿ ហើយក៏មិនដែលខ្វីវាដែរ។

នៅគ្រួសរនោះមានឆ្លាក់ជាឈ្មោះថ្មី ដែលគ្មានអ្នកណាស្គាល់ឡើយ ស្គាល់បានតែអ្នក ដែលទទួលប៉ុណ្ណោះ។ លោក ហ្គ្រេចដានុស បាននិយាយដូចតទៅថា “ឈ្មោះថ្មីដែលសរសេរនៅលើថ្មនោះជា សញ្ញានៃវត្តមាននៃធាតុរបស់គាត់ បុគ្គលិកលក្ខណៈរបស់គាត់ សិរីល្អរបស់គាត់ និងឋានៈរបស់គាត់ដែលត្រូវបានផ្តល់ដល់អ្នកមានមានជ័យជំនះ។ នៅក្នុងលោកិយ អ្នកជឿដែលបដិសេធនឹងការចូលរួមទៅក្នុងការប្រារព្ធពិធីបែបនោះ នោះពួកគេនឹងត្រូវលោកិយបៀតបៀន។ តែពួកគេកំណត់ផ្លូវនៃជីវិតរបស់ពួកគេ។ តែមនុស្សនៃលោកិយនឹងទទួលបានអត្តចរិតដែលមានកិត្តិយស និងឋានៈរបស់វានៃស្ថានសួគ៌។” (Grejidanus, Openbaring p 77) ខ្ញុំគិតថាការបកស្រាយនេះជាគំនិតត្រឹមត្រូវ។ លោក បឺត ឡូមេយើ បាននិយាយទីនេះថា “ឈ្មោះថ្មី” មានន័យថាជាទ្រព្យសម្បត្តិរបស់ព្រះគ្រីស្ទ។ គាត់និយាយថា “វាគឺថ្មី។ ពីព្រោះវាមិនបានបង្ហាញទេ តែគ្រាន់តែទទួលបាន តែដែលអាចដឹងវាបាន គឺចុងក្រោយដែលនៅស្ថានសួគ៌ប៉ុណ្ណោះ។” (Der name ist naturlich der Christi; er ist “neu”, Wenn er in der Form bisher unbokannter, nur dem Empfager verstandicher Zeichen und Zahlen auf dem Stein eingeschrieben ist – Den Openbarong Des Johannes, p 27). កាលដែលយើងនិយាយពី វិវរណៈ 19:12 ការបកប្រែនេះនឹងអាចត្រូវពិចារណាបាន។ ព្រះគ្រីស្ទបានសរសេរព្រះនាមរបស់ទ្រង់ចុះនៅលើគ្រួសស ហើយប្រគល់ដល់អ្នកដែលមានជ័យជំនះដែលមិនបានមានពីមុនមក។ តែវាពិបាកដែលយើងមិនអាចទុកចិត្តលើការបកប្រែបាន។

18-29 សំបុត្រផ្ញើទៅកាន់ក្រុមជំនុំធាទេរ៉ា

18, ធាទេរ៉ា។ នេះគឺជា អាគីសា ជាឈ្មោះបច្ចុប្បន្ន ដែលជាកន្លែងស្នាក់នៅនៃមូសៀ ដែល លីឌា ជាអ្នកលក់សំលៀកបំពាក់ពណ៌ស្វាយរស់នៅទីនោះ (កិច្ចការ 16:14)។ ដោយសារនាងនោះក្រុមជំនុំអាចនឹងត្រូវបានសាងសង់នៅទីនេះ។ “ធាទេរ៉ា” មានទម្លាប់អាក្រក់ក្នុងការថ្វាយបង្គំព្រះទាំងប្រុសទាំងស្រី ជាពិសេសព្រះវិហារមួយមានហោរាស្រីដែលជឿថាបានទទួលការបើកសម្តែងពីព្រះផង។ អ្នកខ្លះនិយាយថា ស្ត្រីម្នាក់នេះជានាងយេសិបិលនៅក្នុង វិវរណៈ 2:20 តែវាមិនប្រាកដ (2) មានការណែនាំជាសាធារណៈជាច្រើន៖ factory guild and dye guild etc។

លីឌា បានចេញមកពីតំបន់នេះ ហើយជាអ្នកលក់នូវផលិតផលដែលជ្រលក់ពណ៌។ (កិច្ចការ 16:14)។ គឺបែបដូច្នោះ ពីព្រោះកន្លែងនោះមានអំណាចខ្លាំងនៃការណែនាំដែលមានការគ្រប់គ្រងនៃជីវិត វាអាចនឹងមានការទាស់ទែងជាច្រើនទៅនឹងដំណឹងល្អ។ ដូច្នេះក្រុមជំនុំខ្សោយងាយនឹងជ្រើសយកផ្លូវដើម្បីនឹងគេចចេញពីការឈ្លោះប្រកែក។ អ្នកជឿនៅក្រុងធាទេរ៉ាហាក់ដូចជាបានធ្វើពិធីដែលទាក់ទងនឹងព្រះក្លែងក្លាយ ដោយនៅក្រោមការដឹកនាំនៃសាសនា ហើយរួចមកពួកគេអាចនឹងបរិភោគដង្វាយរបស់ព្រះទាំងនោះ ហើយក៏អាចនឹងនាំទៅរកភាពអសីលធម៌ខាងផ្លូវភេទជាមួយនឹងមនុស្សកំផិតទាំងនោះ។ ពីព្រោះដោយសារការយល់ច្រឡំពីគោលលិទ្ធិដ៏អស្ចារ្យ ដែលដំណឹងល្អបានផ្សាយមកដល់ពួកអ្នកជឿពេញពីក្រឹត្យវិន័យ គំនិតអាក្រក់ដែលបានធ្លាក់ចុះទៅក្នុងការប្រឆាំងនឹងច្បាប់គឺជាអ្វីដែលកំពុងកើតឡើងនៅក្នុងក្រុមជំនុំបុរាណនេះ។ ហ្វូងមនុស្សដែលត្រូវបានប៉ះពាល់ដោយគំនិតអាក្រក់ហាក់ដូចជា

ខូចនៅក្នុងការបរិភោគរបស់ដែលថ្វាយដល់ព្រះក្លែងក្លាយ ហើយមានសេចក្តីកំផិត ខាងផ្លូវភេទដោយគ្មានការស្តាក់ស្តើងផង។

ដែលមានព្រះនេត្រដូចអណ្តាតភ្លើង ហើយព្រះបាទដូចជាលង្ហិនរលីង។ សំដៅទៅលើការបកប្រែនៃ 1:45, 15។ នៅក្នុងសំបុត្រដើម្បីនឹងព្រមានដោយមានសកម្មភាពជំនុំជំរះផង (22, 23) ឈ្មោះនេះគឺសមស្រប។

19 ការដែលឯងធ្វើហើយ ព្រមទាំងសេចក្តីស្រឡាញ់ សេចក្តីជំនឿ និងសេចក្តីអត់ធ្មត់របស់ឯងដែរ។ "ការដែលធ្វើ" នៅទីនេះជាពាក្យសរុបនៃពាក្យដែលនៅខាងក្រោម។ ដូចដែលយើងឃើញថាសេចក្តីស្រឡាញ់បានដាក់ជាការចាបផ្តើម នោះក្រុមជំនុំនេះហាក់ដូចជាមានសេចក្តីស្រឡាញ់ដែលបរិបូរណ៍។ ប៉ុន្តែនៅទីនេះ យោងតាមលំដាប់លំដោយនៃពាក្យ បន្ទាប់ពីសេចក្តីស្រឡាញ់គឺ "សេចក្តីជំនឿ" បានចេញមក ដែលរាប់បញ្ចូលអត្ថន័យដែលហាក់ដូចជាបានលូតលាស់ចេញមកតាមធម្មតា (សំដៅទៅ 1 ថែស្សាឡូនិក 1:3, 2:6, 5:8)។ ដូចដែលសេចក្តីស្រឡាញ់ចេញពីសេចក្តីជំនឿ វាគឺជាសេចក្តីស្រឡាញ់នៃភាពជាព្រះ។ ដំបូង សេចក្តីស្រឡាញ់គួរតែចេញពីការជឿលើព្រះបន្ទូលដែលបើកសម្តែងមក ប្រៀបដូចជាផលផ្លែដែលចេញមកដែរ។ ប៉ុន្តែ បើទោះជាក្រុមជំនុំធាទេ៉ាអះអាងពីសេចក្តីពីមុនក៏ដោយ នាងហាក់ដូចជាពិចារណាពីសេចក្តីជំនឿ (សេចក្តីជំនឿដែលជឿតាមព្រះបន្ទូលរបស់ព្រះ) ជាធាតុបន្ទាប់បន្សំ។ វាជាកំហុសសម្រាប់ការផ្លាស់ប្តូរការដែលមកមុនជាមួយនិងការដែលមកបន្ទាប់។

ប៉ុន្តែជាការធម្មតាទេដែលការនោះមិនតាមលំដាប់លំដោយនៃពាក្យ គឺដើម្បីនឹងទាញនូវអត្ថន័យចេញមក។ ការបកស្រាយរបស់ព្រ្តេចដានុសគឺដូចតទៅនេះថា "នៅទីនេះ សេចក្តីស្រឡាញ់ជាធាតុនៃគ្រប់សកម្មភាពទាំងអស់ដែលនៅខាងក្រោមវា។

ចេញពីសេចក្តីស្រឡាញ់គឺ សេចក្តីជំនឿ (កម្មភាពដែលស្មោះត្រង់) ការបម្រើ និងការអត់ធ្មត់។”

ជាពិសេស “ការបម្រើ និងការអត់ធ្មត់” ជាការបង្ហាញមកខាងក្រៅនៃ “សេចក្តីស្រឡាញ់”។ ស្ថានភាពនៃក្រុមជំនុំធាទេរ៉ាបានផ្តោតលើគោលលិទ្ធិនៃជំនឿ តែនាងបានធ្លាក់ចុះខាងសេចក្តីស្រឡាញ់សកម្មភាពដែលទុច្ចរិត ដែលក្រុមជំនុំធាទេរ៉ាព្យាយាមស្រឡាញ់ ប៉ុន្តែដោយនាងមិនបានស្តាប់តាមសេចក្តីពិត នោះនាងបានទាសចេញឆ្ងាយ។

20-ស្ត្រីឈ្មោះយេសិបិល។ លោក ហ្សាញ់ បានសង្កេតឃើញពីឯកសារមួយ (A, Q) បង្ហាញពីពាក្យ “របស់អ្នក” ដូច្នេះគាត់បានបកប្រែថា “ស្ត្រីរបស់អ្នកយេសិបិល”។ និង “ស្ត្រីរបស់អ្នក” មានន័យថាជា ប្រពន្ធរបស់គ្រូគង្វាលនៅក្នុងក្រុមជំនុំ។ លោក ម៉ូហ្វាត បាននិយាយថា បើទោះជាព្រះបន្ទូលត្រូវបានបើកសម្តែងនៅក្នុងឯកសារខ្លះទៀតក៏ដោយ វាពិបាកនឹងទុកចិត្តបានណាស់។ ហើយអ្នកផ្សេងទៀតបានចង្អុលទៅកាន់ស្ត្រីម្នាក់ដែលទាក់ទងទៅនឹងព្រះរបស់បាប៊ីឡូន គឺ ស៊ីប៊ីល (វាស្រដៀងនឹងឈ្មោះរបស់យេសិបិល)។ យោងតាមភស្តុតាងរបស់ ស្តើរើ (Theol. Abhandlungen, p 39) ។ មានព្រះវិហាររបស់បាប៊ីឡូននៅទីក្រុងធាទេរ៉ា ដែលយើងមិនទាន់ដោះស្រាយឱ្យប្រាកដដល់ចំណុចនេះនោះទេ។ ដោយខ្លីៗទៅ យេសិបិលជាស្ត្រីដែលអាក្រក់ ដែលនាងជាប្រពន្ធរបស់ស្តេចអ័ហាប ហើយនាងបាននាំមកនូវការថ្វាយបង្គំរូបព្រះរបស់សាសន៍ដទៃ និងធ្វើឱ្យសាសនារបស់អ៊ីស្រាអែលច្របូកច្របល់ (1ពង្សាវតារក្សត្រ 16:31 2ពង្សាវតារក្សត្រ 9:22)។ អេលីយ៉ា បានថ្លែងទំនាយពីស្ត្រីនោះ។ (1) ឆ្កែលិតរូបកាយរបស់នាង (1ពង្សាវតារក្សត្រ 21:23) ហើយវាពិតជាបានកើតឡើងពិតមែន។

នាងត្រូវបានយេហ៊ូបណ្តេញចេញដោយទម្លាក់តាមបង្អួច និងបានធ្លាក់ចុះ និងក៏បានស្លាប់ទៅ (2ពង្សាវតារក្សត្រ 9:33)។ (2) គាត់បានថ្លែងទំនាយទៅកាន់កូនចៅរបស់គាត់ ថាព្រះទ្រង់បំផ្លាញពួកគេទាំងអស់ (1ពង្សាវតារក្សត្រ 21:21) វាបានកើតឡើងប្រាកដមែន (2ពង្សាវតារក្សត្រ 9:6-37)។ (3) ហោរាទាំង 450 នាក់ដែលបរិភោគនៅតុរបស់អ័ហាបបានស្លាប់ (1ពង្សាវតារក្សត្រ 19:40)។ ព្រឹត្តិការណ៍ដ៏ធំខាងលើទាក់ទងទៅនឹងការគម្រាមនៅវិវរណៈ 2:22, 23។ ការគម្រាមដ៏ធំរបស់យេសិបិលត្រូវបានបង្ហាញនៅក្នុងវិវរណៈរបស់យ៉ូហាន [1] ស្ត្រីនោះផ្ទាល់ត្រូវបានធ្លាក់នៅក្នុងគ្រែដេកឈឺ និងបានស្លាប់ទៅ។ (ខ 22)។ [2] មនុស្សកំផិតដែលធ្វើការជាមួយនាង ជាម្នាក់ដែលធ្វើការជាមួយនាងដោយយោគយល់ជាមួយនាង នោះគេនឹងត្រូវបោះចូលទៅក្នុងសេចក្តីរងទុក្ខវេទនា។ [3] កូនចៅរបស់គេ គឺជាមនុស្សដែលត្រឡប់មកពីកនាងនឹងត្រូវស្លាប់ទាំងអស់។ ដូច្នេះ យេសិបិលនៅក្នុងក្រុមជំនុំធាទេរ៉ា គឺជាអ្នកដែលគោរពព្រះផ្សេងទៀត ហើយពួកគេបានផ្លាស់ប្រែដំណឹងល្អជាមួយនឹងគំនិតរបស់នាង។ បើទោះជាយើងមិនអាចដឹងពីមនុស្សនោះថាជា ស្រី ឬប្រុស តែវាច្បាស់ថាគាត់បានត្រឡប់មកក្រុមជំនុំ ហើយបានបំពេញនូវតួនាទីរបស់គាត់ផង។ មេរៀននៃបុគ្គលនោះមិនមែនជាក្រុមក្រឹត្យវិន័យរបស់ ណូស្ទិកនិយម (វាអះអាងថាសម្ភារៈសុទ្ធតែអាក្រក់ និងជាទុក្ខលំបាកនៃជីវិតនេះ) នៅក្នុងបក្សពួកនៃក្រិត្យវិន័យ គាត់ជឿនៅក្នុងការគ្មានទំនាក់ទំនងរវាងព្រលឹងនិងរបស់ខាងរូបកាយ ហើយគាត់អាចធ្វើបាបបាននៅក្នុងរូបកាយ។ វាច្បាស់ដែលថា ការបង្រៀនក្លែងក្លាយបានជ្រៀតចូលទៅក្នុងក្រុមជំនុំធាទេរ៉ា និងបានគ្រប់គ្រងអំណាចរបស់ក្រុមជំនុំផង។

ទៅប្រព្រឹត្តសេចក្តីកំផិត នៅគ្រានោះភាពអសីលធម៌ខាងផ្លូវភេទជាអំពើបាបដែលដើរជាមួយនឹងការថ្វាយបង្គំរូបព្រះក្លែងក្លាយ (ជនគណនា 25:1-5)។ ពីព្រោះការថ្វាយបង្គំព្រះក្លែងក្លាយជាអំពើបាបដែលអាចផ្លាស់ប្តូរបាននៅចំពោះព្រះខាងវិញ្ញាណ ការកំផិតខាងវិញ្ញាណមានគ្រោះថ្នាក់ក្នុងការប្រព្រឹត្តការកំផិត និងដោយងាយផង។ ដូច្នេះ បទគម្ពីរបង្ហាញច្រើនដងថា ព្រះទ្រង់បានបង្គាប់ច្បាស់ថា មនុស្សគួរតែចាកចេញពីការថ្វាយបង្គំព្រះក្លែងក្លាយ និងពីការថ្វាយដង្វាយទាំងនោះ (កិច្ចការ 15:20, 28, 29)។

22, 23 មើល អញនឹងបោះវាទៅលើព្រែគឈី នេះមានន័យថាព្រះទ្រង់ដាក់ទោសយេសិបិល ហើយធ្វើឱ្យនាងមានជំងឺ (I Macc. 1:5)។ នៅក្នុងឯកសារមួយចំនួនដែលត្រូវបានរកឃើញនៅប្រទេសអេស៊ីព មានចំណុចជាច្រើនដែលត្រូវបានដាក់ទោសដល់ការកំផិត និងបានស្លាប់ (Moffatt)។

ហើយបោះពួកអ្នកដែលប្រព្រឹត្តសេចក្តីកំផិតជាមួយនឹងនាង។ ពួកគេចង្អុលទៅកាន់មនុស្សដែលបានចូលរួមក្នុងការគោរពព្រះក្លែងក្លាយរបស់ស្ត្រីនោះ។ ហើយ “កូនចៅវា” ចង្អុលទៅកាន់មនុស្សដែលបានត្រឡប់ទៅកាន់ការបង្រៀនរបស់នាង។ ការពិតដែលបណ្តាសា និងការដាក់ទោសចេញមកពីពួកគេស្រដៀងទៅនឹងការពិតដែលកូនចៅរបស់យេសិបិលនៅអ៊ីស្រាអែលត្រូវបានសម្លាប់ (1ពង្សាវតារក្សត្រ 21:29 2 ពង្សាវតារក្សត្រ 10:7, 8)។

លើកតែគេប្រែចិត្តលះបង់ការដែលគេប្រព្រឹត្តនោះចេញ។ នៅក្នុងលោកិយយើងអាចដឹងថា ព្រះទ្រង់ជាព្រះពិត និងជាព្រះដែលលពេញដោយព្រះគុណជានិច្ច។ បើទោះជាគាត់បានធ្វើបានយ៉ាងធ្ងន់ ប្រសិនបើគាត់ប្រែចិត្តពីអំពើបាប ទ្រង់នឹងអត់ទោសដល់គា

ត់។ នោះគ្រប់ទាំងក្រុមជំនុំនឹងដឹងថា គឺអញនេះហើយដែលស្ទង់មើលចិត្តនិងថ្លើម យោងតាម ទំនុកដំកើង 71:10, យេរេមា 11:20។ “ចិត្ត” នៅត្រង់នេះគឺ នេហ្រ្វូស (νεφροὺς) ដែលជាសេចក្តីប៉ងប្រាថ្នាយ៉ាងជ្រាលជ្រៅ និងជាប្រភពនៃញាណនៅក្នុងមនុស្ស។

អ្វីដែលមនុស្សត្រូវបានលាក់នៅក្នុងកន្លែងដ៏ជ្រៅបំផុតរបស់គាត់យ៉ាងណា ក៏នៅចំពោះព្រះគាត់មិនអាចត្រូវបានលាក់កំបាំងបានឡើយ។ (Bavinck)

ទេសចក្តីជម្រៅរបស់អារក្សាសាតាំង នេះគឺណូស្ទីកនិយម ដែលបានជ្រៀតចូលមកជុំវិញក្រុមជំនុំធាទេរ៉ា។ ពួកគេនិយាយថា សម្រាប់ជាភាពចាំបាច់នៃការពញ្ញាក់នូវទីជម្រៅបំផុតនៃទ្រឹស្តី ហើយពួកគេអះអាងថា ដើម្បីទទួលបានចំណឹងដែលដឹងខ្លួន នោះពួកគេគួរតែនិយាយទៅកាន់រូបកាយរបស់ពួកគេ រួចមកពួកគេបានចូលទៅក្នុងអំពើបាបដើម្បីទទួលបានអត្ថន័យនៃអំពើបាបអាក្រក់ (ហ្សាញ់ ដូលីខើ)។ ពួកគេបានគិតថា បើទោះជាពួកគេបានចូលទៅក្នុងអំពើបាបដ៏អាក្រក់ក៏ដោយ ការអត្តសញ្ញាណនៃចិត្តដែលថ្លៃថ្នូរបស់ពួកគេនឹងមិនត្រូវប្រឡាក់ឡើយ។ ដូច្នេះ ពួកគេព្យាយាមថ្វាយបង្គំអារក្ស អ្នកជឿខ្លះត្រូវបានល្បួងដោយគំនិតបែបនេះ ដែលពួកគេបានលើកលែងនូវការថ្វាយបង្គំរូបព្រះ និងការកំផិត។ ដូច្នេះ ព្រះគ្រីស្ទបានហាមវានៅទីនេះយ៉ាងខ្លាំង។ ការបកប្រែបែបនេះក៏ត្រូវបានបង្កើតមកដោយលោក ម៉ូហ្វាត ដែរ។ (The Expositors’greek Testament, revelation of St. John by James Moffatt, p 362)។ បើទោះជាម៉ូហ្វាតមិនមែនជាអ្នកប្រាជ្ញបែបអាភិរក្សនិយមក៏ដោយ សម្ភារៈមួយចំនួននៃអក្សរសាស្ត្របែបប្រវត្តិសាស្ត្រនៅក្នុងការពន្យល់បកស្រាយរបស់គាត់ ដែលយើងអាចលើកយកមកធ្វើជាឯកសារយោងបានផងដែរ។

តែអញ្ចឹងមិនផ្ទុកបន្ទុកអ្វីទៀតលើឯងរាល់គ្នាទេ យោងតាម កិច្ចការ 15:28, 29។

អំណាចលើពួកសាសន៍ដទៃ នៅក្នុងទំនុកដំកើង 2:8 ព្រះគ្រីស្ទបានទទួលអំណាចចេស្តា។ អ្នកជឿជាគ្រីស្ទានត្រូវបានរួបរួមជាមួយនឹងព្រះគ្រីស្ទ។ ពួកគេបានចូលរួមនៅក្នុងសិរីល្អនេះ (យោងតាម 2ធីម៉ូថេ 2:11, 12)។

ផ្កាយព្រឹក។ នេះជាសញ្ញានៃព្រះគ្រីស្ទផ្ទាល់។ (វិវរណៈ 22:16)។ ហេតុអ្វីបានជាព្រះគ្រីស្ទប្រៀបធៀបនឹងផ្កាយព្រឹកនោះ? វាហាក់ដូចជាធ្វើបែបនោះដោយគិតពីសិរីល្អបែបជាស្តេចរបស់ព្រះគ្រីស្ទ។ (ជនគណនា 24:17)

29 អ្នកណាដែលមានត្រចៀក។ យោងតាមការបកប្រែនៃពាក្យដូចគ្នានៅក្នុងខ 7។

ចំណុចសំខាន់

1. អ្នកណាដែលលន់តួបាបនឹងត្រូវបានអត់ទោស នេះជាសេចក្តីពិតនៅក្នុងគ្រីស្ទសាសនា (5, 16, 21, 22)។ បើមិនមានសេចក្តីពិតនេះ មនុស្សនឹងក្លាយជាវាលរហោស្ថានអស់កល្បជានិច្ច ហើយគេនឹងត្រូវបានបោះបង់ចោល។ ប៉ុន្តែដោយសារសេចក្តីពិតនេះ គឺមនុស្សមានការធានាអះអាងដោយសង្ឃឹមនៃសេចក្តីសង្គ្រោះ និងជីវិតអស់កល្បជានិច្ច។

2. ព្រះយេស៊ូវគ្រីស្ទទ្រង់ជ្រាបពីចំណុចល្អ និងចំណុចខ្សោយរបស់យើង។ (2, 3) ដោយដឹងការទាំងពីរនេះ ទ្រង់ខ្ពស់ជាងយើង។ ដូច្នេះ យើងគួរតែកាត់ទោសខ្លួនយើងដោយមិនអត់អោនឡើយគឺនៅក្នុងពន្លឺនៃព្រះបន្ទូល ហើយគួរតែប្រែចិត្ត និងផ្លាស់ប្រែយើង ហើយយើងមិនគួរធ្លាក់ចុះទៅក្នុងអាកប្បកិរិយាដែលស្មោគគ្រោកដែលនាំខ្លួនយើងទៅតាមទិសដៅនៃចិត្តដ៏ងងឹតរបស់យើងឡើយ។

3. ព្រះទ្រង់មិនដាក់ទោសមនុស្សមានបាបដោយមិនបានផ្តល់នូវឱកាសលន់តួបាបឡើយ (2:21)។ ពីព្រោះ ទ្រង់ជាព្រះដែលមានមេត្តាដ៏ពិត ទ្រង់មានសេចក្តីអំណរដោយសារមនុស្សមានបាបម្នាក់ដែលលន់តួបាប ជាជាងមនុស្សសុចរិត 99 នាក់ផង (លូកា 15:7)។

4. ព្រះទ្រង់រងចាំការលន់តួបាបរបស់មនុស្សមានបាប ប្រសិនបើមនុស្សមានបាបមិនប្រែចិត្តទេ តែបានបំពេញអំពើយ៉ាងជ្រុលហួស នោះទ្រង់នឹងដាក់ទោសពួកគេ (22, 23)។ រយៈពេលនៃការរងចាំដែលពេញទៅដោយអំពើបាបអាចនឹងយូរអង្វែង។ ឧទាហរណ៍ វាជាហេតុការណ៍ដើម្បីនឹងបំផ្លាញផែនដីដោយទឹកជំនន់។ វាត្រូវបានសម្រេច120ឆ្នាំក្រោយមកបន្ទាប់ពីការព្រមាន។ មិនតែប៉ុណ្ណោះ ថេរវេលាដែលកុលសម្ព័ន្ធទាំងប្រាំពីររបស់កាណានបានពោរពេញដោយអំពើបាប គឺរយៈបួនជំនាន់ (លោកុប្បត្តិ 15:16) គឺរយៈពេល 400 ឆ្នាំ។ ដូច្នេះ វាគ្រោះថ្នាក់នៅពេលដែលវាក្លាយជាពេលដែលពេញដោយអំពើបាបដោយធ្វើបាបបន្តិចម្តងៗ។ បើទោះជាវាជាអំពើបាបតូចក៏ដោយ នោះមិនត្រូវចាត់ទុកថាមិនបាច់គិតនោះទេ។ ប៉ុន្តែបើទោះជាអំពើបាបតូចដែលអាក្រក់ជ្រុលមួយក៏នឹងត្រូវដាក់ទោសនៅក្នុងពេលមួយផងដែរ វាបានកើតឡើងដែលព្រះទ្រង់ដាក់ទោសគេភ្លាមដោយគ្មានមិនរំលងទង្វើពេញដោយបាបឡើយ។ ឧទាហរណ៍ (1) មនុស្សដែលចង់បានជារបស់ព្រះបាល បេអ័រ 24000 នាក់បានស្លាប់ដោយសារគ្រោះចង្រៃ (ជនគណនា 25:1-9)។ ពួកគេបានឃើញការអស្ចារ្យជាច្រើនរបស់ព្រះយេហូវ៉ា តែពួកគេបះបោរទាស់នឹងទ្រង់មួយរំពេចទៅធ្វើ “បាបដោយចេតនា” នោះពួកគេមិនត្រូវបានព្រះអត់ទោសឱ្យទេ។ (2) ដ្បិតរាស្ត្រអ៊ីស្រាអែលបានទាស់នឹងម៉ូសេ និងព្រះផង នោះពួកគេបានស្លាប់ដោយសារសត្វពស់ភ្លើង (ជនគណនា 21:4-6)។ បើទោះជាពួកគេបានមើលឃើញការអស្ចារ្យរបស់ព្រះយ៉ាងជាក់ច្បាស់ក៏ដោយ

ពួកគេនៅតែទាស់នឹងព្រះ និងម៉ូសេផង នោះពួកគេត្រូវបានដាក់ទោសភ្លាមៗ។ (3) អ្នកស៊ើបអង្កេតដប់នាក់ត្រូវបានបញ្ជូនទៅទឹកដីកាណានបានស្លាប់ដោយជំងឺគ្រុនក្តៅ ដោយសារពួកគេបានធ្វើឱ្យមនុស្សធ្លាក់ទឹកចិត្ត (ជនគណនា 14:37)។ (4) ពីព្រោះ ណាដាប់ និងអាប៊ីហ៊ូបានស្លាប់ដោយឆេះស្លាប់ ដោយសារពួកគេបានដុតកំញ៉ាណ នៅលើអាសនាជាមួយនឹងភ្លើងផ្សេងទៀត នោះពួកគេត្រូវបានដុតឆេះដោយសារភ្លើង (លេវីវិន័យ 10:1, 2)។ ហើយពួកគេក៏បានស្លាប់ដោយអំពើបាបនៃការប្រមាថដល់ទីបរិសុទ្ធ។ (5) ស្តេចអ៊ូសៀ ដែលមិនមែនជាសង្ឃបានកើតជំងឺឃ្លង់ ដោយសារបានថ្វាយគ្រឿងក្រអូបទៅព្រះយេហូវ៉ានៅក្នុងព្រះវិហារ ទ្រង់ត្រូវបានដាក់ទោស (2របាក្សត្រ 26:16-21)។ (6) ការស្លាប់ភ្លាមៗរបស់ប្តីប្រពន្ធរបស់អាណានាស និងសាហ្វីរ៉ា (កិច្ចការ 8 :)។ វាជាអំពើបាបនៃការធ្វើបំពានសេចក្តីបរិសុទ្ធដោយការកុហកដល់ព្រះវិញ្ញាណបរិសុទ្ធ។ (7) ហេរ៉ូឌបានស្លាប់ដោយសារដង្កូវ (កិច្ចការ 12:21-33), ពីព្រោះទ្រង់បានប្រព្រឹត្តអំពើបាបបំពានដល់ទីបរិសុទ្ធរបស់ព្រះ នោះទ្រង់ត្រូវបានដាក់ទោស។

ការអធិប្បាយទី 4 សេចក្តីស្រឡាញ់ដំបូង (វិវរណៈ 2:4, 9)

1. តើសេចក្តីស្រឡាញ់ជាអ្វី?

នៅក្នុងភាសាក្រិក មានពាក្យស្រឡាញ់បួន ស្តូលហ្គេ (στοργή), អេរ៉ុស (ἔρως), ហ្វីឡេអា (φιλία) និង អាកាផេ (ἀγάπη)។ ស្តូលហ្គេ មានន័យថា សេចក្តីស្រឡាញ់ដែលលាក់កំបាំងនៃអ្នកដែលមកឈាមដូចគ្នា អេរ៉ុសជាសេចក្តីស្រឡាញ់បែបខាងផ្លូវភេទ ហ្វីលេអាជាសេចក្តីស្រឡាញ់នៃអំណរដែលកើតចេញពីមិត្តភាព ចំណែកអាកា

ផេ ជាសកម្មភាពនៃការវាតម្លៃ។ សេចក្តីស្រឡាញ់នេះជាទីមួយ ជាសេចក្តីស្រឡាញ់ទៅកាន់ព្រះ ទីពីរជាសេចក្តីស្រឡាញ់ទៅកាន់មនុស្ស។

1. វិធីសាស្ត្រអនុវត្តសេចក្តីស្រឡាញ់

សម្រាប់អាកាផេយើងគិតដូចតទៅនេះ

(1) យើងគួរតែស្រឡាញ់ព្រះជាទីមួយ

សេចក្តីជំនឿជាការជឿលើសេចក្តីពិត ក្នុងពេលតែមួយគឺស្រឡាញ់ព្រះផងដែលសេចក្តីពិតបានចង្អុលបង្ហាញនោះ។ តើការស្រឡាញ់ព្រះជាអ្វី? វាជាការរក្សាបញ្ញត្តិរបស់ទ្រង់ (យ៉ូហាន 14:21)។ អ្នកដែលរក្សាបញ្ញត្តិរបស់ទ្រង់ គួរតែរក្សាវាសម្រាប់ព្រះ តែមិនគួរទទួលការកោតសរសើរនៅចំពោះមនុស្សទេ។ អ្នកដែលរក្សាបញ្ញត្តិដើម្បីទទួលបានការកោតសរសើរពីមនុស្ស គេមិនមែនជាមនុស្សដែលបម្រើព្រះទេ តែគេបម្រើមនុស្សវិញ។ ការដែលសំខាន់ជាងនេះទៀតនៅក្នុងការស្រឡាញ់ព្រះ ជាការថ្វាយបង្គំចេញពីចិត្ត។ ដោយសារបទគម្ពីរមានបន្ទូលថា យើងគួរបម្រើព្រះឱ្យអស់ពីចិត្ត យើងគួរស្វែងរកព្រះឱ្យអស់ពីចិត្ត (ចោទិយកថា 4:29) ចូរបម្រើព្រះឱ្យអស់ពីចិត្ត (ចោទិយកថា 10:12) ចូរស្រឡាញ់ទ្រង់ឱ្យអស់ពីចិត្ត (ចោទិយកថា 13:3) មិនគ្រាន់តែស្តាប់បង្គាប់តែប៉ុណ្ណោះ (ចោទិយកថា 13:2) ចូរបែរមករកព្រះអម្ចាស់ (ចោទិយកថា

30:10) ធ្វើការនៅចំពោះព្រះអម្ចាស់ (ពង្សាវតារក្សត្រទី1 2:4) ការដើរតាមព្រះអម្ចាស់ (ពង្សាវតារក្សត្រទី1 14:8) ការសរសើរដំកើងព្រះអម្ចាស់ (ទំនុកដំកើង 86:12) ហើយជឿលើព្រះអម្ចាស់ យើងគួរធ្វើឱ្យអស់ពីចិត្ត។ នោះទង្វើដែលធ្វើអស់ពីចិត្តនៅខាងលើមានន័យថា កាលដែលពួកគេរក្សាបញ្ញាត្តិដោយអស់ពីចិត្ត នោះជាអ្នកជឿដែលស្រឡាញ់ព្រះ។ ការរក្សាបញ្ញាត្តិជាបញ្ហាដែលទាក់ទងនឹងការប្រព្រឹត្ត។ អ្នកដែលស្រឡាញ់ព្រះប្រព្រឹត្តដោយស្មោះត្រង់សម្រាប់ព្រះ។ លោកគ្រូ Moody បាននិយាយថា "សេចក្តីជំនឿមានអំណាចពិសេសដែលមាន ការបន្ទាបខ្លួនជាកំលាំងយ៉ាងខ្លាំងនៃការរក្សានិងស្រឡាញ់ប្រព្រឹត្តបានច្រើនបំផុត" សេចក្តីស្រឡាញ់ជាលក្ខណៈសំខាន់នៅក្នុងការស្រឡាញ់ព្រះ ហើយក៏ស្រឡាញ់ដល់មនុស្សផងជាផលផ្លែរបស់វា។ ហេតុផលដែលស្រឡាញ់ព្រះនោះជាការពិតនោះគឺដោយសារមនុស្សជារូបឆ្លុះរបស់ព្រះ។ មិនត្រឹមតែបង្គាប់ឱ្យស្រឡាញ់តែមនុស្សនោះទេ" (ម៉ាថាយ 22:39)។ ដូច្នេះ ការស្រឡាញ់មនុស្សក៏ស្ថិតនៅក្នុងគោលជំនឿដល់ព្រះផងដែរ។

(2) ការចាប់ផ្តើមនៃសេចក្តីស្រឡាញ់

តើសេចក្តីស្រឡាញ់ពិតចាប់ផ្តើមនៅពេលណា? តើសេចក្តីស្រឡាញ់របស់មនុស្សពីធម្មជាតិអាចចាប់ផ្តើមជាមួយនឹងសេចក្តីស្រឡាញ់ដូច្នេះទេ? វាមិនអាចទៅរួចឡើយ។ អ្នកដែលស្គាល់សេចក្តីស្រឡាញ់ពិតគឺបន្ទាប់ពីស្គាល់សេចក្តីស្រឡាញ់នៃសេចក្តីប្រោសលោះ ហើយក៏ចាប់ផ្តើមស្រឡាញ់វាដែរ។ មុនដែលមនុស្សនោះបង្ហាញមកជាសេចក្តីស្រឡាញ់ដែលប្រោសលោះ នោះគេមិនអាចស្គាល់សេចក្តីស្រឡាញ់ពិតឡើ

យ។ យ៉ូហានទី1 4:10-12 មានបន្ទូលថា “នេះហើយជាសេចក្តីស្រឡាញ់ មិនមែនជាយើងបានស្រឡាញ់ព្រះនោះទេ គឺទ្រង់បានស្រឡាញ់យើងវិញទេតើ ហើយបានចាត់ព្រះរាជបុត្រាទ្រង់មក ទុកជាដង្វាយឱ្យធួននឹងបាបយើងរាល់គ្នាផង។ ពួកសួនភ្ងាអើយ បើព្រះបានស្រឡាញ់យើងរាល់គ្នាជាខ្លាំងទាំងម្ល៉េះ នោះត្រូវឱ្យយើងស្រឡាញ់គ្នាទៅវិញទៅមកដែរ គ្មានអ្នកណាដែលឃើញព្រះឡើយ តែបើយើងស្រឡាញ់គ្នាទៅវិញទៅមក នោះព្រះទ្រង់គង់នៅក្នុងយើង ហើយសេចក្តីស្រឡាញ់របស់ទ្រង់ បានពេញខ្នាតក្នុងយើងដែរ” ដំណាក់កាលដែលសមហេតុផលនៃពាក្យនេះគឺដូចខាងក្រោម។ ទាំងនោះគឺ កាលដែលមនុស្សឃើញសេចក្តីស្រឡាញ់ដែលប្រោសលោះ នោះអ្នកជឿនៅទីបំផុតអាចស្រឡាញ់គ្នាទៅវិញទៅមក។ តាមរយៈការស្រឡាញ់គ្នាទៅវិញទៅមក ពួកគេស្គាល់ព្រះកាន់តែច្បាស់។ នៅពេលយើងឃើញថា តាមរយៈការអនុវត្តសេចក្តីស្រឡាញ់ស្របតាមការបើកសម្តែងពិត នោះយើងអាចឈានដល់ចំណេះដឹងឱ្យបានស្គាល់ព្រះ និងសេចក្តីស្រឡាញ់ដើម្បីស្រឡាញ់ព្រះ។ វិធីសាស្ត្រដើម្បីស្គាល់ព្រះច្បាស់ជាងនេះគឺការអនុវត្តសេចក្តីស្រឡាញ់ដែលបានបើកសម្តែង ប៉ុន្តែមិនមែនជាប្រតិបត្តិតាមគំនិតសាមញ្ញនោះទេ។ ទោះជាយ៉ាងណាក៏ដោយ យើងមិនចាត់ទុកសកម្មភាពនៃចំណេះដឹងដែលជាការទទួលយកការបើកសម្តែងដែលអ្នកទេវវិទូថ្មីគិតដូចបញ្ហាទីពីរនោះទេ។ វាជាបញ្ហាចម្បង។ ដើម្បីឈានដល់ចំណេះដឹងអំពីព្រះ យើងគួរដឹងថាអ្វីដែលសេចក្តីស្រឡាញ់នៃវិវរណៈគឺជាអ្វី ហើយជំហានបន្ទាប់យើងគួរធ្វើការប្រព្រឹត្តនូវសេចក្តីស្រឡាញ់។ អត្ថន័យដែលថាមុននឹងយើងស្រឡាញ់ យើងមិនអាចដឹងថាសេចក្តីស្រឡាញ់នោះមាននៅក្នុង យ៉ូហានទី 1 4:10-12។ ដោយសារលោកយ៉ូហានបាននិយាយរហូតដល់ពាក្យថាព្រះជាម្ចាស់ជាសេចក្តីស្រឡាញ់ ការស្រឡាញ់មនុស្សគឺជាវិធីសាស្ត្រដើម្បីស្រឡាញ់ព្រះជាម្ចាស់។ សេចក្តីស្រឡាញ់ធ្វើឱ្យយើង

ស្គាល់ដោយសេចក្តីស្រឡាញ់។ សេចក្តីស្រឡាញ់គឺជាលក្ខណៈរបស់ព្រះ ប៉ុន្តែដោយសារតែអ្វីដែលសំខាន់ជាងនេះទៅទៀតគឺថា វាគឺជាលក្ខណៈសំខាន់របស់ព្រះ ហើយវាគឺជាមនុស្សនៅក្នុងសកម្មភាពនៃការបើកសម្តែងរបស់ទ្រង់ វាគឺជាការបើកសម្តែងដ៏អស្ចារ្យបំផុតដើម្បីធ្វើឱ្យពួកគេស្គាល់ព្រះ។ ចំពោះសេចក្តីស្រឡាញ់នេះគ្រាន់តែជារឿងដែលបទគម្ពីរបើកសម្តែងប៉ុណ្ណោះ អ្នកណាដែលជឿលើវា ហើយទទួលយកវា ហើយស្រឡាញ់អ្នកម្នាងទៀតតាមគោលការណ៍នៃសេចក្តីស្រឡាញ់នេះ នោះស្រឡាញ់ព្រះច្បាស់មែន។

(3) អំពីសេចក្តីស្រឡាញ់ជាបន្តទៀត

មនុស្សមិនអាចគេចផុតពីស្រលាញ់ទេ ទោះបីជាវាជាសេចក្តីស្រឡាញ់ក្លែងក្លាយក៏ដោយ។ ប៉ុន្តែវាមិនងាយស្រួលទេក្នុងការបន្តការងារល្អជាប្រចាំ។ អ្នកដែលរក្សាស្នេហ៍ដំបូងមិនច្រើនទេ។ ប៉ុន្តែអ្នកណាដែលបន្តនៅជាប់នោះមានពរហើយ ហើយនឹងទទួលរង្វាន់ពីព្រះ។ សកម្មភាពរបស់មនុស្សក្នុងព្រះគម្ពីរ។ 1) ដាវីឌស្រឡាញ់សូលជាដំបូង ហើយគោរពគាត់ដោយមិនប្តូរចិត្ត ហើយស្រឡាញ់គាត់ផង។ ទោះបីសូលព្យាយាមសម្លាប់ដាវីឌជាច្រើនដងក៏ដោយ ក៏ដាវីឌមិនបានសងសឹកគាត់ទេ។ ហើយគាត់បានសម្លាប់បុរសម្នាក់ដែលបានសម្លាប់សូលផង (2 សាំយូអែល 1:15) ហើយសម្លាប់បុរសដែលសម្លាប់អ៊ីស-បូសែត (2 សាំយូអែល 4:5-12) ហើយចិញ្ចឹមមភីបូសែតដែលជាមនុស្សខ្វិន ដែលជាចៅរបស់សូលឱ្យបរិភោគអាហារនៅតុជាមួយគ្នាផង (2 សាំយ៊ូអែល 9:1-13)។ 2) យ៉ូណាថានស្រឡាញ់ដាវីឌដែលជាមនុស្សឱពូកខ្លួនបានស្អប់រហូតដល់ទីបញ្ចប់ ខណៈដែលឪពុករបស់គាត់ព្យាយាមសម្លាប់ដាវីឌ នោះគាត់ខំការពារដាវីឌ ហើយលាក់គាត់ (1 សាំយ៊ូអែល 19:1-7, 20:17, 35-42)។

នេះជាទង្វើដែលយ៉ូណាថានបានទទួលស្គាល់ថាសេចក្តីសុចរិតសំខាន់ជាងការជាប់ឈាមគ្នាទៅទៀត។ ទោះបីជាគាត់ស្រឡាញ់ឪពុករបស់គាត់ក៏ដោយ គាត់មិនបានចូលរួមក្នុងអំពើអាក្រក់របស់ឪពុកគាត់ទេ វាគឺជាជីវិតនៃបុគ្គលិកលក្ខណៈដែលរឹងមាំដែលគាត់មានសេចក្តីស្រឡាញ់និងវិន័យព្រមគ្នាផង 3) ប៉ុលមិនបានទទួលស្គាល់ម៉ាកុសមួយរយៈជាមិត្តរួមការងាររបស់គាត់ (កិច្ចការ 15:37-39) បន្ទាប់ពីនោះគាត់បានចាត់ទុកគាត់ថាមានតម្លៃ ហើយស្រឡាញ់គាត់ផង។ (កូឡុស 4:10, 2ធីម៉ូថេ 4:11, យ៉ូណាស 1:24)។ វាមានន័យសម្រាប់ជាភស្តុតាងក្នុងទំនាក់ទំនងជាមួយអ្នកឯទៀត។ គាត់បានបង្កើតគោលការណ៍ ហើយក៏មិនបានកាត់ផ្តាច់សេចក្តីស្រឡាញ់របស់គាត់ឡើយ។ 4) ពេត្រុសត្រូវបានប៉ូលស្តីបន្ទោស (កាឡាទី 2:11-21) បន្ទាប់ពីនោះពួកគេបានសហការគ្នាជាគុណធម៌ប្រសើរ។ (ពេត្រុសទី2 3:15, 16)។ វាបង្ហាញពីចរិតលក្ខណៈរបស់ពេត្រុសផង។

ការអធិប្បាយទី 5 ចំណុចខ្សោយនិងចំណុចល្អនៃក្រុមជំនុំអេភេសូ (វិវរណៈ 2:1-7)

1. ចំណុចខ្សោយ

ការពិតដែលថាពួកជំនុំអេភេសូរមិនទទួលយកគ្រូក្លែងក្លាយគឺល្អណាស់។ ដោយសារក្រុមជំនុំមិនអាចទទួលយកមនុស្សអាក្រក់ប្រភេទណាមួយទេ គ្រូក្លែងក្លាយមិនគួរត្រូវបានទទួលយកទេ ពីព្រោះគ្រូក្លែងក្លាយមិនបានកែតម្រូវអំពើបាបរបស់គេទេ ប៉ុន្តែបានព្យាយាមធ្វើឱ្យក្រុមជំនុំប្រព្រឹត្តអំពើបាបដដែលរបស់ពួកគេ។ ដូចជាមន្ទីរពេទ្យអាចទទួលយកអ្នកជំងឺទូទៅទាំងអស់ ប៉ុន្តែអ្នកជំងឺរាតត្បាតមិនគួរទទួលយកទេ។ តើគ្រូក្លែងក្លាយជាអ្វី? 1) ខាងលើការបង្រៀនរបស់គាត់គឺមិនត្រឹមត្រូវទៅនឹងបទគម្ពីរទេ។ បទគម្ពីរសង្កត់ធ្ងន់លើការបង្រៀនថាគួរតែត្រឹមត្រូវ។ កាឡាទី 1:8 មានប្រសាសន៍ថា៖ ប៉ុន្តែ បើយើងខ្ញុំ ឬទេវតាពីស្ថានសួគ៌ នឹងប្រាប់ដំណឹងណាមកអ្នករាល់គ្នា ខុសពីដំណឹងល្អ ដែលយើងខ្ញុំបានប្រាប់ហើយ នោះឱ្យគេត្រូវបណ្តាសាចុះ”។ កាលដែលការបង្រៀនមិនពិតបានចូលមកក្នុងក្រុមជំនុំ នោះក្រុមជំនុំត្រូវបានបំផ្លាញហើយ។ ដូច្នេះ 2ធីម៉ូថេ 2:17 និយាយថា “ហើយសំដីគេនឹងស៊ីរូងដូចជាដំបៅក្លាយ ក្នុងពួកនេះមានឈ្មោះហ៊ីមេនាស និងភីលេត”។ វាពិបាកណាស់ក្នុងការធ្វើឱ្យគ្រូខុសឆ្គងត្រលប់ទៅមនុស្សថ្មី។ 2) គ្រូក្លែងក្លាយគឺជាអ្នកគង្វាលដែលចិញ្ចឹមតែរូបកាយរបស់គាត់ ដូច្នេះគាត់មិនមានឥទ្ធិពលផ្តល់ព្រះគុណលើអ្នកដ៏ទៃដូចជាពពកដែលគ្មានទឹកនោះវិញ (យូដាស 1:12)។ ដូច្នេះ ការប្រគល់ក្រុមជំនុំឱ្យគ្រូក្លែងក្លាយជាការប្រព្រឹត្តដោយគ្មានមេត្តា។ ផ្ទុយទៅវិញ រឿងដែលមិនទទួលយកគ្រូក្លែងក្លាយ គឺជាអាកប្ប

កិរិយាដ៏សុចរិតជាង ហើយជាកិច្ចការដ៏មានមេត្តាចំពោះក្រុមជំនុំ។ វាមិនត្រឹមត្រូវទេ ដែលព្រលឹងជាច្រើនត្រូវបានគេបោះបង់ចោល ប្រសើរជាងការដែលមនុស្សម្នាក់ទទួលបានអត្ថប្រយោជន៍ខ្លះខាងសាច់ឈាមរបស់គាត់។

2. ចំណុចខ្សោយ

ក្រុមជំនុំអេភេសូរបានបាត់បង់សេចក្តីស្រឡាញ់ដំបូង។ មនុស្សគ្រប់គ្នាហាក់ដូចជាមានជំនឿងប់ងល់ជាលើកដំបូងនៅក្នុងការធ្វើល្អ។ ប៉ុន្តែវាជាចំណុចខ្សោយដែលអ្នករាល់គ្នាមិនរក្សាចំណង់ចំណូលចិត្តជាប់ជានិច្ច។ ដោយសារតែតម្លៃខាងលោកិយក៏ត្រូវធ្លាក់ចុះដោយសារការផ្លាស់ប្តូរច្រើន ដូច្នេះសេចក្តីស្រឡាញ់របស់អ្នកជឿត្រូវធ្លាក់ចុះកាន់តែច្រើន ឬច្រើនជាងនេះទៅទៀត។ ប៉ុន្តែតម្លៃនៃព្រះមិនត្រូវបានផ្លាស់ប្តូរដ៏រិតដែលទាក់ទងទៅនឹងនោះទេ កាន់តែឃ្លេមកសេចក្តីស្រឡាញ់ចំពោះទ្រង់នឹងកាន់តែជ្រៅឬកាន់តែជ្រៅថែមទៀត។ ទោះយ៉ាងណាក៏ដោយ អត្ថបទនោះបាននិយាយថា ក្រុមជំនុំអេភេសូរបានបោះបង់ចោលសេចក្តីស្រឡាញ់ដំបូងរបស់គេ។ (1) ដូចដែលយើងឃើញថាសេចក្តីស្រឡាញ់ដំបូងរបស់នាងត្រូវបានធ្លាក់ចុះ វាជាការគួរសង្ស័យថានាងមានភាពស្មោះត្រង់ (ដែលជាលក្ខណៈរឹងមាំ)។ ទោះជាក្រុមជំនុំមិនអាចធ្វើការអស្ចារ្យក៏ដោយ ប្រសិនបើនាងមានភាពស្មោះត្រង់ ការប្រកាសដំណឹងល្អត្រូវបានកើតឡើងហើយ។ 1ធីម៉ូថេ 3:15 ក្រុមជំនុំបាននិយាយថា ក្រុមជំនុំគឺជា “សសរស្តម្ភ ហើយជាគ្រឹះនៃសេចក្តីពិត” ក្នុងការប្រកាសសេចក្តីពិត ការពង្រឹងដូចជាសសរ និងភាពរឹងមាំដូចជាគ្រឹះជាជីវិតនៃពួកជំនុំ។ បន្ទាប់ពីព្រះបានពិនិត្យមើលភាពស្មោះត្រង់របស់យើង នោះទ្រង់បានប្រគល់ទ្រព្យសម្បត្តិនៃស្ថានសួគ៌មក។ ហេតុដូច្នេះហើយ ព្រះកំពុងរង់ចាំជាយូរមកហើយ ដោយសាកល្បងភាពស្មោះត្រង់របស់យើងក្នុងការរងទុក្ខរបស់យើង

ដើម្បីផ្តល់ព្រះគុណកាន់តែច្រើនដល់យើង។ (2) ការពិតដែលថាពួកជំនុំអេភេសូរបានបាត់បង់សេចក្តីស្រឡាញ់ដំបូងរបស់គាត់មានន័យថា នាងមិនអាចបំពេញបេសកកម្មរបស់ពួកជំនុំបានទៀតទេ។ មនុស្សខាងលោកិយត្រឡប់ទៅរកជំណឹងល្អវិញដោយឃើញសេចក្តីស្រឡាញ់របស់អ្នកជឿលើគ្នាទៅវិញទៅមក។ យ៉ូហាន 17:22 ចែងថា៖ “ឯសិរីល្អដែលទ្រង់បានប្រទានមកទូលបង្គំ នោះទូលបង្គំបានឱ្យដល់គេហើយ ដើម្បីឱ្យគេបានរួមគ្នាតែមួយ ដូចជាយើងក៏រួមតែមួយដែរ”។ ដូច្នេះ ក្រុមជំនុំមិនគួរបាត់បង់ក្តីស្រឡាញ់ក្នុងស្ថានភាពណាមួយឡើយ។ ដោយសារសេចក្តីស្រឡាញ់ជាជីវិតរបស់ក្រុមជំនុំ។ ទោះបីជាគុជខ្យងស្ថិតនៅក្នុងសមុទ្រក៏ដោយ ពន្លឺគឺស្រស់ស្អាតដូចជាពន្លឺនៃស្ថានសួគ៌ ព្រះវិហារគួរតែបង្ហាញពីសេចក្តីស្រឡាញ់របស់ព្រះនៅក្នុងពិភពលោកនេះ។

ប្រសិនបើក្រុមជំនុំបោះបង់ចោលសេចក្តីស្រឡាញ់ដំបូង នាងគួរតែលន់តួប្រែចិត្ត។ អំពីវិវរណៈពីការប្រែចិត្ត 2:5 បង្ហាញពីលក្ខណៈពិសេសមួយដែលយើងមិនអាចមើលឃើញនៅឯណានោះគឺ “ដូច្នេះ ចូរនឹកចាំ ដែលឯងបានធ្លាក់ចេញពីសណ្ឋានណានោះ ហើយប្រែចិត្តចុះ រួចប្រព្រឹត្តតាមការដើមដំបូងនោះវិញ ពុំនោះសោត អញនឹងមកឯងឯង ហើយនិងហូតយកជើងចង្កៀងឯងពីកន្លែងចេញ លើកតែឯងប្រែចិត្តឡើងវិញ”។ ការដែលមនុស្សមានបាបប្រែចិត្ត គឺដើម្បីព្យាបាលជំងឺនៃព្រលឹងខ្លួន ដូចជាជំងឺនៃរូបកាយរបស់គេដែរ វាគួរតែត្រូវបានធ្វើរោគវិនិច្ឆ័យឱ្យបានច្បាស់។ នោះគឺយើងគួរដឹងមូលហេតុនៃជំងឺខាងវិញ្ញាណ ហើយគួរព្យាបាលចំណុចដែលឈឺនោះ។

3. រង្វាន់របស់អ្នកដែលយកឈ្នះ។ នៅក្នុងអត្ថបទរបស់យើង អ្នកឈ្នះមានន័យថាអ្នកដែលប្រែចិត្តពីអំពើបាបរបស់គាត់។ ខទី 7 ចែងថា “អ្នកណាដែលមានត្រចៀក ឱ្យ

អ្នកនោះស្តាប់សេចក្តី ដែលព្រះវិញ្ញាណមានព្រះបន្ទូល ដល់ពួកជំនុំទាំងប៉ុន្មានចុះ ឯអស់អ្នកណាដែលឈ្នះ នោះអញនឹងឱ្យបរិភោគផ្លែរបស់ដើមជីវិត ដែលនៅស្ថានបរមសុខរបស់ព្រះ” វាគឺជាការបង្ហាញនៃពាក្យប្រៀបធៀប ព្រលឹងនៃអ្នកជឿរីករាយនឹងជីវិតដ៏បរិបូរណ៍ដែលជារបស់នៃស្ថានសួគ៌។ សោក ស្មីតដល (St. Smilde) និយាយយ៉ាងត្រឹមត្រូវថា “ការសន្យាថាទ្រង់នឹងផ្តល់ផ្លែឈើនៅក្នុងដើមឈើនៃជីវិត ហើយធ្វើឱ្យគេមានវា វាមានន័យថាអ្នកដែលបានស្លាប់នៅក្នុងព្រះគ្រីស្ទនឹងរីករាយនឹងជីវិតដ៏បរិបូរនៃស្ថានសួគ៌។” (De beloften aanannde het eten van den boom des Levens ziet op de volle levensgenieting in den hemel voor hen, die in Christus sterven – Leven in De Johanneische geschriften, p 184).

ការអធិប្បាយទី 6 ចូរស្មោះត្រង់រហូតដល់ស្លាប់ (វិវរណៈ 2:8-10) (1)

មនុស្សទាំងអស់ស្អប់ការស្លាប់ព្រោះការស្លាប់គឺវាអាក្រក់។ ទោះគេស្អប់ក៏ដោយក៏គ្មានអ្នកណាមិនស្លាប់ដែរ។ ហើយកូនក្មេងក៏នឹងត្រូវស្លាប់ដែរ។ វាជារឿងឆ្គួតដែលយើងខំតែគេចចេញពីសេចក្តីស្លាប់។ សុភាសិត 14:32 ចែងថា៖ “មនុស្សអាក្រក់ត្រូវធ្លាក់ចុះដោយអំពើខូចអាក្រក់របស់ខ្លួន តែមនុស្សសុចរិតមានទីពំនាក់ក្នុងកាលដែលស្លាប់វិញ។” មនុស្សព្យាយាមទទួលបានការលួងលោមខ្លះតាមរយៈការស្លាប់ដ៏ស្រស់ស្អាត។ ពួកគេព្យាយាមរក្សាសាកសពជាអចិន្ត្រៃយ៍ ដោយប្រើថ្នាំដែលធ្វើមិនឱ្យរលួយលើវា ហើយវាមិនត្រូវផ្លាស់ប្តូរឡើយ។ ទោះបីជាយ៉ាងណាវាមិនអាចជួយអ្វីបានក្រៅពីការធ្វើឱ្យសាកសពមានភាពស្រស់ស្អាតនោះទេ។ ព្រោះវាជារបស់ដែលយើងចង់ឱ្យរូបមនុស្សមានបាបដែលយើងស្អប់ត្រូវបានរក្សាទុកជាអចិន្ត្រៃយ៍ ផ្ទុយទៅវិញការនៅជាប់នៃសាកសពគឺអាក្រក់ជាងដែលសូម្បីតែមើលមិនឃើញនូវអ្វីដែលខ្ញុំមើលមិនឃើញនៅចំពោះមុខខ្ញុំនោះផង។ អ្វីដែលមនុស្សរស់នៅត្រឹមត្រូវ (រស់ដោយសុចរិត) ជាអាថ៌កំបាំងដើម្បីរក្សាជីវិតឱ្យស្ថិតស្ថេរ។ ដូច្នេះជីវិតគឺសំខាន់ ហើយការស្លាប់ក៏សំខាន់ដែរ។ ដោយសារការស្លាប់គឺដូចជាជីវិតសម្រាប់ដើម្បីធ្វើឱ្យជីវិតមានតម្លៃ ដូច្នេះយើងមិនគួរគេចពីវាទេ ប៉ុន្តែគួរតែព្យាយាមស្លាប់ឱ្យត្រឹមត្រូវ។ ការពិតគឺជាក់ស្តែង ប៉ុន្តែមនុស្សនោះក្លាយជាមនុស្សល្ងង់ ដែលមិនចាត់ទុកវាជាកំណប់ ការអនុវត្តធ្វើសេចក្តីពិតគឺជាការចម្បង។ ឥឡូវនេះអត្ថបទដោះស្រាយបញ្ហាពីការអនុវត្តនេះ។

1. ស្គាល់ថាព្រះគ្រីស្ទជានរណា

“អញជាអាល់ហ្វានិងជាអូមេហ្គា” ព្រះអម្ចាស់មានបន្ទូល “ដែលមានវត្តមាន ហើយនៅពីដើម ហើយនឹងមកដល់ជាព្រះដែលមានគ្រប់អំណាចចេស្តា” (ខ 8)។ ដោយពាក្យមួយទៀត ព្រះអង្គដែលធ្វើការបង្កបង្កើតហើយទ្រង់ជាចៅក្រម (ជាដើមនិងជាចុង) ដែលត្រូវមានព្រះជន្មរស់ឡើងវិញបន្ទាប់ពីបានសុគត។ មានពាក្យជាច្រើននៅក្នុងបទគម្ពីរបង្រៀនពីការពិតមួយនេះ។ ដូច្នេះ ដែលយើងដឹងថាគម្ពីរទាំង66កណ្ឌជាសេចក្តីពិត នោះការរស់ឡើងវិញជាសេចក្តីពិតជាក់ស្តែងមែន។ ដែលយើងដឹងថាការរស់ឡើងវិញជាសេចក្តីពិត នោះយើងក៏អាចស្លាប់ផងដែរ។

2. ព្រះគ្រីស្ទស្គាល់ទុក្ខលំបាកនិងភាពក្រីក្រ

យើងអាចស្លាប់បានយ៉ាងល្អដូចដែលយើងដឹងថាព្រះអម្ចាស់ជ្រាបពីទុក្ខលំបាក និងភាពក្រីក្ររបស់យើង។ ខ9 ចែងថា “យ៉ូហានខ្ញុំ ដែលជាបងប្អូននៃអ្នករាល់គ្នា ហើយជាអ្នកមានចំណែកក្នុងសេចក្តីទុក្ខលំបាក និងក្នុងនគរ ហើយក្នុងសេចក្តីអត់ធ្មត់របស់ព្រះយេស៊ូវគ្រីស្ទ ជាមួយនឹងអ្នករាល់គ្នាដែរ ខ្ញុំបាននៅឯកោះឈ្មោះប៉ាត់ម៉ុស ដោយព្រោះព្រះបន្ទូល និងសេចក្តីបន្ទាល់ពីព្រះយេស៊ូវគ្រីស្ទ”។ គោលបំណងដែលទ្រង់បានសុគត ប៉ុន្តែត្រូវបានប្រោសឱ្យរស់ឡើងវិញ គឺដើម្បីឱ្យដឹងថាទ្រង់ដឹងពីទុក្ខលំបាក និងភាពក្រីក្ររបស់យើង (សេចក្តីស្លាប់)។ ព្រះអម្ចាស់ដែលប្រោសឱ្យរស់ឡើងវិញ បើកសម្តែងថា នៅពេលយើងស្លាប់ ហើយយើងបានជួបនឹងពេលវេលាដ៏លំបាក ដូច្នេះយើងជួបប្រទះនឹងអំណាចនៃព្រះអម្ចាស់ដែលបានរស់ឡើងវិញកាន់តែច្បាស់ នៅពេលដែលយើងជួបនឹងពេលវេលានៃការស្លាប់របស់យើង ជាជាងពេលវេលាដ៏សុខសាន្ត

របស់យើង។ មុនពេលយើងស្លាប់ វាមិនច្បាស់ទេថាយើងបានជួបព្រះអម្ចាស់ដ៏មានព្រះជន្មរស់នោះ។ សាវកប៉ុលមានប្រសាសន៍ថា “ដើម្បីឱ្យខ្ញុំបានស្គាល់ទ្រង់ និងព្រះចេស្តានៃដំណើរដែលទ្រង់រស់ឡើងវិញ ហើយនិងសេចក្តីប្រកបក្នុងការរងទុក្ខរបស់ទ្រង់ ព្រមទាំងត្រឡប់ទៅដូចជាទ្រង់ក្នុងសេចក្តីស្លាប់ផង។ នោះគឺបើសិនជាមានផ្លូវណា ឱ្យខ្ញុំបានមកដល់សេចក្តីរស់ពីស្លាប់ឡើងវិញ” (ភីលីព 3: 10, 11)។ ហើយគាត់ក៏បាននិយាយថា៖ “យើងមានទ្រព្យសម្បត្តិនេះនៅក្នុងភាជនៈដី ដើម្បីឱ្យឥទ្ធិឫទ្ធិលើសលប់បានមកពីព្រះ មិនមែនពីយើងខ្ញុំទេ។ ដែលយើងខ្ញុំត្រូវគេសង្កត់សង្កិនគ្រប់ជំពូក តែមិនទ័លផ្លូវឡើយ មានសេចក្តីវិលវល់ តែមិនទ័លគំនិតទេ។ មានគេធ្វើទុក្ខ តែមិនមែនត្រូវចោលនៅម្នាក់ឯងទេ ត្រូវគេវាយដួលស្លុក តែមិនស្លាប់ទេ។ យើងខ្ញុំផ្ទុកសេចក្តីសុគតនៃព្រះអម្ចាស់យេស៊ូវ នៅក្នុងរូបកាយយើងខ្ញុំជានិច្ច ដើម្បីឱ្យព្រះជន្មនៃទ្រង់បានសំដែងមក ក្នុងរូបកាយយើងខ្ញុំដែរ។ ដ្បិតយើងរាល់គ្នាដែលរស់នៅ នោះយើងត្រូវប្រគល់ដល់សេចក្តីស្លាប់ជាដរាប ដោយព្រោះព្រះយេស៊ូវ ដើម្បីឱ្យព្រះជន្មនៃទ្រង់បានសំដែងមក ក្នុងរូបសាច់យើង ដែលតែងតែស្លាប់នេះ” (2កូរិនថូស 4:7-11)។ ពេលយើងចូលទៅក្នុងស្ថានភាពនៃសេចក្តីស្លាប់របស់យើង (ឬកាលយើងបានស្លាប់) បានជួបប្រទះនឹងអំណាចនៃការរស់ឡើងវិញរបស់ព្រះយេស៊ូវគ្រីស្ទកាន់តែច្បាស់។ ដូច្នេះ យើងមិនគួរបាត់បង់ជំនឿរបស់យើងនៅពេលដែលយើងជួបនឹងទុក្ខលំបាកនិងភាពក្រីក្រ (ទុក្ខលំបាកត្រូវធ្លាក់ទៅក្នុងស្ថានភាពស្លាប់) ប៉ុន្តែគួររក្សាជំនឿរបស់យើង។

3. យើងគួរដឹងដើម្បីទទួលបានការកំសាន្តពីព្រះបន្ទូលរបស់ព្រះ

នៅក្នុងពាក្យថា "ខ្ញុំដឹងពីទុក្ខព្រួយរបស់អ្នក និងភាពក្រីក្ររបស់អ្នក (តែអ្នកជាអ្នកមាន) និងការបង្កាច់បង្ខូចអ្នកដែលថាពួកគេជាសាសន៍យូដា ហើយមិនមែនទេ ប៉ុន្តែជាក្រុមជំនុំរបស់សាតាំង" ។ យើងអាចស្លាប់បានយ៉ាងល្អ នៅពេលយើងទទួលបានការសម្រាលទុក្ខដែលពួកបរិសុទ្ធគួរទទួល។ (1) ព្រះអម្ចាស់ទទួលស្គាល់ថា ពួកបរិសុទ្ធត្រូវបានចំអក (បៀតបៀន) ដោយមនុស្សអាក្រក់។ យ៉ូហាន 15:18 ចែងថា៖ “បើសិនជាលោកីយ៍ស្អប់អ្នករាល់គ្នា នោះអ្នករាល់គ្នាដឹងហើយ ថាគេបានស្អប់ខ្ញុំជាមុន”។ ដូច្នេះ កាលដែលអ្នកជឿបានទទួលការបៀតបៀនដោយសារព្រះអម្ចាស់ គេត្រូវនឹកចាំពីការពិតដែលថាខ្លួនគេតែម្នាក់ឯងមិនបានទទួលការបៀតបៀននោះទេ ប៉ុន្តែព្រះអម្ចាស់ផ្ទាល់បានទទួលវាជាមួយគ្នានោះ ពេលដែលគាត់នឹកឃើញការពិតថាគាត់អាចទទួលបានការលួងលោម ព្រមទាំងអាចទទួលបានអំណាចព្រះអម្ចាស់ប្រទានដល់គាត់ផង។ (2) មិនត្រឹមតែប៉ុណ្ណោះទេ វាបាននិយាយថា មនុស្សដែលបានបៀតបៀនពួកបរិសុទ្ធ ត្រូវបានហៅឱ្យ "ក្រុមជំនុំរបស់សាតាំង" ខណៈដែលគាត់ចងចាំពីការពិត គាត់ក៏អាចទទួលបានអំណាចផងដែរ។ ពួកបរិសុទ្ធមិនគួរស្វែងរកជំនួយពីសាតាំង ជាជាងចាត់ទុកការប្រមាថរបស់វាថាជាសេចក្តីអំណរវិញ។ មារសាតាំងគឺជាអរិយវៈនៃអំពើអាក្រក់ កាលដែលមនុស្សទន់ខ្សោយ វាងាយនឹងទំនោរទៅរកការល្បួងដើម្បីសម្របសម្រួលជាមួយនឹងអំពើបាបតិចតួច។ ប៉ុន្តែ មនុស្សអាក្រក់បែបនេះខ្លាចអំពើបាបដ៏ខ្លាំងក្លា ដែលខ្លួនមិនព្រមចុះសម្រុងនឹងអំពើបាបនោះទេ។ ទោះបីជាបុរសនោះឃ្លានយ៉ាងណាក៏ដោយ ក៏គាត់មិនបានស៊ីចំណីដែរ។ ដូចអ្នកជឿ វាជារឿងធម្មតាទេដែលគាត់មិនទទួលបានការសរសើរ និងជំនួយពីមនុស្សដែលចំអកព្រះនាមព្រះយេស៊ូវ។

4. យើងគួរដឹងថាទ្រង់នឹងប្រទានរង្វាន់ដល់យើង

យើងអាចស្លាប់បានយ៉ាងល្អ ដោយយើងដឹងថាព្រះអម្ចាស់ប្រទានមកុដនៃជីវិតដល់អ្នកដែលស្មោះត្រង់នឹងព្រះអម្ចាស់រហូតដល់ស្លាប់។ តើមកុដនៃជីវិតគឺជាអ្វី? ដូចអ្នកឈ្នះទទួលអំណោយជីវិតជារង្វាន់របស់ខ្លួននោះគឺការទទួលបានភាពបរិបូរណ៍ដ៏រុងរឿង។ នេះមិនមែនជាព្រឹត្តិការណ៍ដែលនឹងកើតឡើងនៅការយាងមកជាលើកទីពីររបស់ព្រះយេស៊ូវទេ វាបានកើតឡើងនៅក្នុងព្រឹត្តិការណ៍នៃការចាកចេញរបស់ពួកបរិសុទ្ធ។ ហេតុផលដែលខ្ញុំបកស្រាយយ៉ាងដូច្នេះ លុះនិយាយដល់ការស្លាប់នៃរូបកាយ ពាក្យនេះ (មកុដនៃជីវិត) ក៏ចេញមក។ លោក E. Smilde បាននិយាយថានេះគឺជាព្រឹត្តិការណ៍ដែលបន្ទាប់ពីការចាកចេញរបស់ពួកបរិសុទ្ធដែលរងទុក្ខនឹងកើតឡើងក្នុងពេលឆាប់ៗពិតមែន។ (Hertgeen gezegd wordt in dit vers over den fysieken dood, als het einde van het lijden der gemeente, wijst echter in een andere richting. Deze belofte gaat in vervalling terstond na het sterven der geloovigen . – Leven In De Johanneische Gesch iriften, p 186)

ការអធិប្បាយទី 7 ចូរស្មោះត្រង់រហូតដល់ទីបញ្ចប់នៃសេចក្តីស្លាប់ (2:8-10) (2)

ព្រះបន្ទូលថា “ចូរស្មោះត្រង់” មានផ្នែកការបីជាចម្បង។ ទីមួយ វាជាការស្គាល់សេចក្តីពិតនិងរក្សាវាជានិច្ចដោយផ្ទាល់។ ទីពីរ វាជាការបូជាខ្លួននឹងរក្សាវាទៅ។ ទីបី វាជាការរក្សាភាពស្មោះត្រង់របស់គេ។

1. ការស្គាល់សេចក្តីពិតឱ្យជាក់និងរក្សាសេចក្តីពិតនោះ។ “ភាពស្មោះត្រង់” ជា ភីស្តុស (πιστὸς) នៅក្នុងភាសាក្រិក មានន័យថាភាពស្មោះត្រង់។ (Bavinck) តើមានបទគម្ពីរអ្វីអំពីភីស្តុសនោះ? វាមានន័យទីមួយថា វាជា លក្ខណៈរបស់ព្រះ ហើយក៏ចង្អុលទៅកាន់លក្ខណៈនៃសេចក្តីពិតពីព្រះ (លក្ខណៈនៃសេចក្តីពិតផ្ទុយពីព្រះក្លែងក្លាយ) និងភាពមិនចេះប្រែប្រួលនៃការ តាំងសញ្ញារបស់ទ្រង់។ លោក Bavinck បានបកស្រាយលក្ខណៈនៃភីស្តុស ដូចតទៅនេះថា “ព្រះជាព្រះពិតនៅក្នុងធាតុនិងជាសេចក្តីស្មោះត្រង់យ៉ាង ពេញលេញដែលសាងព្រះបន្ទូលរបស់ទ្រង់ឡើង” (Dogmatic vol II p 174).

(1) តើភាពស្មោះត្រង់របស់អ្នកជឿជាអ្វី? វាចេញមកពីសេចក្តីស្មោះត្រង់របស់ ព្រះ។ ទីមួយជាការស្គាល់ព្រះឱ្យបានត្រឹមត្រូវ រក្សាវាតទៅនិងប្រកាសវា ដោយចំៗ (1កូរិនថូស 4:1)។ ដូច្នេះ ភាពស្មោះត្រង់ពីបុរាណមិនមែន ជាចំណុចកណ្តាលនៃសេចក្តីពិតទេ តែវាហាក់ដូចជាទេរទៅរកភាពអភិ រក្សនិយមយ៉ាងខុសឆ្គង។ ភាពស្មោះត្រង់របស់បទគម្ពីរមិនមែនអភិរក្ស និយមដោយគ្មានគោលបំណងឡើយ តែផ្តោតលើសេចក្តីពិតវិញ។ ដូច្នេះវាចាប់ផ្តើមចេញសកម្មភាពដែលពេញដោយឆ្លាតវៃនៅក្រោមការ ដឹកនាំរបស់ព្រះវិញ្ញាណបរិសុទ្ធ។ "មួយណាជាសេចក្តីពិត?" “តើជាដំ ហ៊ានដំបូងនៃភាពស្មោះត្រង់មែនទេ?” ដូច្នេះ ដំបូងបង្អោះយើងគួរតែធ្វើ ឱ្យបានល្អបំផុតដើម្បីឱ្យបានស្គាល់ព្រះគម្ពីរបានត្រឹមត្រូវ។ ពីព្រោះ ប្រសិនបើ គ្រូគង្វាលមិនស្គាល់បទគម្ពីរទេ គាត់អាចនឹងកុហកច្រើនមិន

ខាន។ សុភាសិតនិយាយថា "ប្រៀបដូចជាពពកនិងខ្យល់តែគ្មានភ្លៀង ជាអ្នកដែលអួតអាងពីអំណោយតែមិនព្រមឱ្យសោះ" (សុភាសិត 25:14) “សាក្សីភូតភរនឹងមិនរួចចាកទោសឡើយ ហើយអ្នកណាដែលពោលពាក្យកុហកក៏នឹងគេចមិនរួចដែរ” (សុភាសិត 19:5) ហើយ “សេចក្ដីដែលនាំឱ្យគេរកពឹងដល់មនុស្សណា នោះគឺជាសេចក្ដីសប្បុរសរបស់អ្នកនោះឯង ហើយមនុស្សទាល់ក្រមែងវិសេសជាងមនុស្សភូតភរ” (សុភាសិត 19:22)។

(2) បន្ទាប់ពីយើងស្គាល់សេចក្តីពិត យើងគួរតែរស់នៅដូចជាសេចក្តីពិតនៅក្នុងជីវិតរបស់យើង ហើយប្រកាសវាទៅកាន់អ្នកផ្សេងទៀត។ ប្រសិនបើយើងមិនរស់នៅដូចជាសេចក្តីពិតនិងប្រកាសវាទេ ទ្រង់មានបន្ទូលថាវាជាការឥតប្រយោជន៍ទេដែលប្រៀបដូចជាការកុហកវិញ។ ព្រះទ្រង់ស្រឡាញ់ការថ្វាយបង្គំពិតជាងការថ្វាយបង្គំក្លែងក្លាយ។ លោក Spurgeon បានមានប្រសាសន៍ថា “រស់នៅក្នុងសត្វតោប្រសើរជាងរស់នៅក្នុងមនុស្សអួតអាង។ បើទោះជាគេអាច តែគេមិនព្រមដេញតាមសេចក្តីពិតដោយស្មោះត្រង់ តែបែរជាធ្វើទុក្ខដល់ក្រុមជំនុំវិញ។”

2. ការថ្វាយខ្លួនយើងក្នុងការរក្សាតំណែងរបស់យើង

ព្រះទ្រង់ទតមើលគុណសម្បត្តិនៃការគោរពបូជារបស់យើងជាជាងលទ្ធផលជោគជ័យរបស់យើង។ គ្រូគង្វាលគួរប្រកាសដំណឹងល្អទាំងក្នុងទុក្ខលំបាក ឬក្នុងសេចក្តីរីករាយ។ យើងគួរតែបំពេញបេសកកម្មរបស់យើងនៅគ្រប់រដូវកាលឱ្យទទួលបានឱកាស

ឬអត់ (1ធីម៉ូថេ 4:2)។ សម្រាប់អ្នកដែលប្រកាសដំណឹងល្អក្នុងគ្រានៃទុក្ខលំបាកគឺជាឱកាសទទួលបានផលផ្លែជាច្រើននៃដំណឹងល្អ។ ដូចដែល ចន ប៊ុនយាន ប្រកាសដំណឹងល្អក្នុងជីវិតអ្នកជាប់ឃុំក្នុងការចាំងពន្លឺជាអចិន្ត្រៃយ៍ (សៀវភៅរបស់គាត់ Pilgrim's Progress) Ambrose (គ.ស. 340) គឺជាការដែលខ្លាំងប្រឆាំងនឹងការសម្របសម្រួលជាមួយនឹងភាពអយុត្តិធម៌។ គាត់បានហាមឃាត់ថានៅពេលដែល Theodosius 329-395) បានចូលទៅក្នុងទីសក្ការៈនៃព្រះវិហារ ហើយដកចោលនូវកៅអីអ្នកដឹកនាំចេញ មិនមែនដកកៅអីរបស់មនុស្សធម្មតានោះទេ។ បន្ទាប់ពីនោះពេលដែលព្រះចៅអធិរាជចូលទៅក្នុងទីសក្ការៈ បន្ទាប់ពីគាត់បានបង្ហូរឈាមមនុស្សស្លូតត្រង់ជាច្រើននាក់ ។

គាត់ប្រដៅស្តេច។ អធិរាជត្រូវបានស្តីបន្ទោសពីគាត់ ហើយបាននៅក្នុងព្រះរាជវាំងអស់រយៈពេល8ខែហើយយំផង។ លោក Theodosius បាននិយាយទៅកាន់ប៊ីស្សបអាំប្រូស ថា “ខ្ញុំបានឃើញមនុស្សម្នាក់ដែលនិយាយសេចក្តីពិតជាលើកទីមួយ។ គាត់មានគុណសម្បត្តិនៃប៊ីស្សបដែលគាត់នៅមីឡាន។” “”អធិរាជត្រូវបានអោបក្រសោបដោយដើមទ្រូងរបស់អាំប្រូស ហើយបានស្លាប់នៅឆ្នាំ 395 គ.ស។” នៅពេលដែលគ្រូគង្វាលលោក Ki Chul Joo ដែលត្រូវជាម្នាក់ដែលគេបានសម្លាប់ ត្រូវបានគេឃុំក្នុងគុកនៅ Ei Sung កាលដែលមន្ត្រីចង់វាយគាត់ គាត់បានគិតពីព្រលឹងរបស់មន្ត្រីនោះ ហើយនិយាយថា “បន្ទាប់ពីអ្នកវាយខ្ញុំកាលដែលអ្នកនឹងត្រូវដាក់ទោសពីព្រះ តើអ្នកអាចឆ្លើយពីហេតុផលដែលអ្នកវាយខ្ញុំបានទេ? នៅក្នុងពេលជំនុំជំរះ តើអ្នកនឹងឆ្លើយយ៉ាងណាទៅកាន់ព្រះ? បន្ទាប់ពីមន្ត្រីនោះគិតមួយរំពេច គាត់ក៏ទៅកាន់អ្នកផ្សេងទៀត។”

3. ការរក្សាភាពស្មោះត្រង់របស់យើង

មនុស្សដែលគ្មានភាពស្មោះត្រង់ប្រៀបដូចជាមនុស្សដែលគ្មានឆ្អឹងដែរ។ នៅក្នុងលោកិយនេះ មានមនុស្សដែលរស់សម្រាប់ប្រទេសខ្លួន ឬអ្នកដែលរស់នៅសម្រាប់ប្រយោជន៍ផ្ទាល់ខ្លួន។ កាលដែលយើងមានមិត្តស្និតស្នាល យើងត្រូវការភាពស្មោះត្រង់។ មិនដូច្នោះទេ វាដូចជា Kanjoong បានលក់របស់ជាមួយនឹង Posuk នោះ Kanjoong បានយករបស់ច្រើនជានលោក Posuk។ បន្ទាប់មកប្រសិនបើលោក Posuk យល់ពីលោក Kan Joong ថាគាត់បានធ្វើនោះដោយសារតែភាពក្រីក្ររបស់គាត់ នោះកាត់បានរក្សាមិត្តភាពរបស់ពួកគេរហូតដល់ទីបំផុត។ តើអ្នកជឿជាមួយនឹងព្រះវិញ្ញាណបរិសុទ្ធអាចរក្សាភាពស្មោះត្រង់ទៅកាន់ព្រះរហូតដល់ទីបំផុតយ៉ាងម៉េចបាន?

4. ទំនាក់ទំនងរវាងពាក្យថា រហូតដល់ទីបញ្ចប់សេចក្តីស្លាប់និងភាពស្មោះត្រង់

(1) ភាពស្មោះត្រង់ គឺការថ្វាយជីវិតរបស់យើងចំពោះព្រះចំពោះសេចក្តីពិតទុកជាតង្វាយ។ យើងគួរតែស្មោះត្រង់ មិនមែនរស់ទេ តែស្លាប់វិញ។ ការស្មោះត្រង់ក្នុងការរស់នៅ គឺជាសកម្មភាពបះបោរ ដែលខ្ញុំបម្រើជីវិតរបស់ខ្ញុំនៅចំពោះព្រះ។ ដោយសារគ្រិស្ទានជាអ្នកបម្រើព្រះ គាត់គួរដកយូបព្រះ

ចេញ។ គាត់គួរតែលះបង់ជីវិតរបស់គាត់ចំពោះព្រះ គាត់គួរតែលើឈើឆ្កាងនៅលើស្មារបស់ពួកគេជារៀងរាល់ថ្ងៃ។

(2) ប៉ុន្តែយើងមិនគួរធ្លាក់ក្នុងសភាពស្លាប់យ៉ាងធ្ងន់ធ្ងរឡើយ។ យើងគួរតែរស់នៅជាព្រះគុណនៃព្រះអម្ចាស់ ហើយគួរតែស្លាប់ក្នុងព្រះគុណនៃព្រះអម្ចាស់។ កាលដែលយើងស្លាប់ដោយព្រះគុណនៃព្រះអម្ចាស់ វាមិនមែនជាសេចក្តីស្លាប់ដ៏វេទនានោះទេ។ ដូច្នេះ “ភាពស្មោះត្រង់” មិនមែនជាសេចក្តីស្លាប់ដ៏វេទនានោះទេ។ តើការស្លាប់ដោយព្រះគុណមានន័យដូចម្តេច? គឺមានដូចខាងក្រោមនេះ។ ព្រោះការស្លាប់អាស្រ័យលើការរៀបចំទុករបស់ព្រះ មនុស្សមិនចាំបាច់គិតហើយព្រួយបារម្ភឡើយ។ ដូច្នេះ អ្នកជឿគួរតែស្មោះត្រង់ក្រោមការគំរាមកំហែងនៃសេចក្តីស្លាប់។ ភស្តុតាងដែលថាបញ្ហានៃការស្លាប់ត្រូវបានគ្រប់គ្រងដោយព្រះតែមួយគត់ដែលបង្ហាញនៅក្នុងបទពិសោធន៍របស់មនុស្សជាតិយ៉ាងជាក់ស្តែង។

ជំពូកទី3

អញនឹងមិនលុបឈ្មោះគេចេញពីបញ្ជីជីវិតឡើយ។ យោងតាម 20:12។

6 អ្នកណាដែលមានត្រចៀក ឱអ្នកនោះស្តាប់សេចក្តីដែលព្រះវិញ្ញាណមានបន្ទូលដល់ពួកជំនុំទាំងប៉ុន្មានចុះ។ យោងតាមការបកស្រាយនៃពាក្យដូចគ្នានៅ 2:7។

7-13 សំបុត្រទៅកាន់ក្រុមជំនុំនៅក្រុងភីឡាដិលភា

7 ក្រុងភីឡាដិលភា កន្លែងនេះត្រូវបានហៅពេលនេះថា អាឡាស្ការ សព្វថ្ងៃនេះ តាមដែលគ្រីស្ទានជាច្រើនបានដឹង។

ពាក្យថា “ព្រះអង្គដ៏បរិសុទ្ធ ហើយពិតប្រាកដ ដែលទ្រង់កាន់កូនសោររបស់ហ្លួងដាវីឌ” តាមការបកស្រាយរបស់លោក ប្រេដដានុស ថា “ចូរឱ្យបានបរិសុទ្ធ” មានន័យថាជាសភាពដែលកាត់ផ្តាច់ពីអំពើបាបដោយអវិជ្ជមាន ដោយវិជ្ជមានវាចង្អុលទៅកាន់អំណាចចេស្តារបស់ទ្រង់ ជាលក្ខណៈរបស់ព្រះ និងលក្ខណៈបរិសុទ្ធដែលទ្រង់សង្គ្រោះរាស្ត្ររបស់ទ្រង់។ ពាក្យថា “ពិត” គឺ អាលេសីនូស (ἀληθινός) នៅក្នុងភាសាក្រិក ដែលមិនមានន័យថា សភាពផ្ទុយនៃការកុហកទេ តែជាសេចក្តីពិត និងជាធាតុដែលផ្ទុយនឹងភាពមិនពេញលេញ។ នោះពាក្យនេះចង្អុលទៅកាន់ចំណុចដ៏ពេញលេញខ្ពស់បំផុតនៃការបើកសម្តែងរបស់ព្រះគ្រីស្ទ។ ព្រះទ្រង់បើកបង្ហាញព្រះគ្រីស្ទថាទ្រង់ពិតជាគ្មានស្នាមសោះ ហើយការសន្យារបស់ទ្រង់ត្រូវបានសម្រេចនៅក្នុងព្រះគ្រីស្ទពិត (2កូរិនថូស 1:20)។ “កូនសោររបស់ហ្លួងដាវីឌ” ចង្អុលទៅកាន់ភាពជាព្រះអម្ចាស់ដែលមានគ្រប់អំណាចចេស្តានៃនគររបស់ព្រះ។ “ដាវីឌ” ជាឈ្មោះព្រះមេស៊ី

ដែលនៅក្នុងទំនាយ ឈ្មោះនេះត្រូវបានប្រើទៅកាន់ព្រះគ្រីស្ទនៅក្នុងគម្ពីរសញ្ញាចាស់ (អេសេគាល 34:23)។

៨ មើល អញបានបើកទ្វារចំហនៅមុខឯង ការប្រៀបប្រដូចនេះគឺពីឱកាសដែលអាចចូលទៅក្នុងនគររបស់ព្រះ។ បើទោះជាពួកយូដាដែលជាអ្នកបៀតបៀនបានបិតវាក៏ដោយ (ខ 9) ពួកគេមិនអាចធ្វើបានទេ។

ពីព្រោះទោះបើឯងមានអំណាចតែបន្តិចក៏ដោយ គង់តែបានកាន់តាមពាក្យអញដែរ ហើយមិនបានលះបង់ឈ្មោះអញទេ។ ហេតុផលដែលព្រះគ្រីស្ទសរសើរដល់ក្រុមជំនុំភីឡាដិលភា គឺជាការពិតដែលថា បើទោះជានាងមានប្រភពខាងវិញ្ញាណតូចក៏ដោយ តែនាងបានរក្សាសេចក្តីជំនឿជានិច្ចអស់ពីចិត្ត។ វាហាក់ដូចជាការពិតដែលព្រះអម្ចាស់ទតមើលការទុក្ខលំបាកនៃស្ត្រីមេម៉ាយក្រីក្រ និងទ្រង់បានលើកសរសើរផង (ម៉ាកុស 12:41-44)។ ព្រះអម្ចាស់មិនចូលចិត្តម្នាក់ដែល បើទោះជាគេមានច្រើនក៏ដោយ តែបណ្តោយខ្លួនឱ្យខូចទេ តែបើទោះជាគេមានតិចក៏ដោយ ទទួលស្គាល់អ្នកដែលចង់ធ្វើការដែលល្អប្រសើរមួយ។

៩ ដែលពួកគេអួតខ្លួនថាជាសាសន៍យូដា តែមិនមែនទេ គឺគេកុហកវិញ—យោងតាមការបកស្រាយនៃ 2:9។ ការពិតដែលពួកយូដាបានបៀតបៀនអ្នកជឿនៅក្រុងភីឡាដិលភាបានបញ្ជាក់អះអាងដោយ អ៊ីកណាធាស (Philad 6)។

មើល អញនឹងឱ្យគេមកក្រាបសំពះ នៅទៀបជើងឯង ព្រមទាំងឱ្យគេដឹងថា អញបានស្រឡាញ់ដល់ឯងផង។ យោងតាម អេសាយ 60:14, 45:14, 49:23។ នេះជាទំនាយដែលអ្នកខ្លះក្នុងចំណោមសាសន៍យូដាបានប្រែចិត្ត និងបានត្រឡប់មករកព្រះអម្ចាស់។ ប៉ុន្តែយោងតាមទ្រឹស្តីមួយចំនួន ការនេះចង្អុលថា អ្នកមិនជឿនៅក្នុង

ចំណោមពួកយូដានឹងត្រូវចុះចូលនៅចំពោះមុខពួកបរិសុទ្ធ ហើយនឹងត្រូវទទួលការ
កាត់ទោសដោយពួកបរិសុទ្ធ ប៉ុន្តែការបកស្រាយទីមួយគឺត្រឹមត្រូវ (ប្រហែចជានុស)។

*10 ពីព្រោះឯងបានកាន់តាម*នេះជាពាក្យមួយដែលគួរឱ្យចាប់អារម្មណ៍ដែលត្រូវបាន
សង្កត់ធ្ងន់ដោយវិធីផ្ទុយគ្នា។

*ពីសេចក្តីអត់ធ្មត់របស់អញ។*ការនេះមានន័យថា (1) ដំណឹងល្អត្រូវបានស្គាល់បាន
ដោយការអត់ធ្មត់ និងដើរទៅមុខ។ ហើយ (2) ដំណឹងល្អត្រូវបានសម្រេចដោយការរង
ទុក្ខរបស់ព្រះគ្រីស្ទ ដែលទ្រង់បានទ្រាំទ្ររហូតដល់ការត្រូវឆ្កាង (ប្រហែជជានុស)។ (3)
លោក ឡូមេយើ បានបកស្រាយពាក្យថា “ការអត់ធ្មត់របស់អញ” ថា “ការរងទុក្ខដ៏
ឈឺចាប់របស់អញ” (Harren auf mich)។

*ពីពេលនៃទុក្ខលំបាក។*ការនេះចង្អុលទៅកាន់ពេលនៃការរងទុក្ខវេទនា ដែលយើងមិន
អាចដឹងពីពេលវេលាលម្អិតឡើយ។

នោះអញនឹងរក្សាឯង ពួកគេបានយកឈ្នះការបៀតបៀនរបស់សាសន៍យូដា (ខ 9)
ការបៀតបៀនដែលខ្លាំងជាងនេះនៅចំពោះពួកគេនឹងត្រូវបានកាត់បន្ថយដោយសារ
ជំនួយពិសេសរបស់ព្រះជាម្ចាស់។ ការនេះពឹងលើគោលការណ៍នៃភាពស្មោះត្រង់នៅ
ក្នុងការតូច និងការទទួលព្រះគុណដ៏អស្ចារ្យ។

*ដើម្បីកុំឱ្យអ្នកណាយកមកុដរបស់ឯងបានឡើយ។*នេះជារឿងដែលបានកើតឡើងនៅ
ក្នុងឆាក ដែលជាការប្រៀបធៀបនៃគោលការណ៍ខាងវិញ្ញាណ។ វាមានន័យថា
ព្យាយាមដល់ទីបញ្ចប់ដើម្បីកុំឱ្យបាត់រង្វាន់ទៅ។ យោងតាម ហេព្រើរ 12:1-4.

ជាសសរទ្រូង។ នេះក៏ជារង្វាន់នៃគោលការណ៍ដែល កាលណាគេស្មោះត្រង់នឹងការតូច នោះគេនឹងបានទទួលរង្វាន់យ៉ាងធំ (ម៉ាថាយ 25:23)។ យោងតាម គោលការណ៍ដូចគ្នានៃខ 10 ខាងលើ។ “សសរ” ត្រូវបានប្រើជាកម្លាំងធ្ងន់បំផុតនៅក្នុងការកសាងលក្ខណៈខ្លាំង។ ក្រុមជំនុំភីឡាដិលភាបានទទួលតំណែងយ៉ាងសំខាន់ដូចជាសសរយ៉ាងរឹងមាំនៅក្នុងពិភពលោកដែលនឹងមកដល់ ពីព្រោះនាងបានស្មោះត្រង់ជាមួយនឹងអំណាចតិចតួចនៅក្នុងលោកិយនេះ តែសម្រាប់កិច្ចការដែលមិនស្មោះត្រង់នោះគេនឹងក្លាយជាមនុស្សដែលខ្សោយ វាគួរឱ្យសោកស្តាយណាស់។ ប៉ុន្តែនៅក្នុងលោកិយ បើទោះជាគេមានអំណាចតូចតាច តែស្មោះត្រង់ នោះគេនឹងក្លាយជាអ្នកមាននៃសិរីល្អ វាជាសេចក្តីអំណរយ៉ាងអស្ចារ្យ។

រួចអ្នកនោះនឹងមិនចេញពីទីនោះទៀតឡើយ។ ការនេះចង្អុលទៅកាន់ការពិតដែល គេនឹងមិនត្រូវរង្គើឡើយនៅលើបល្ល័ង្កដ៏មានពរអស់កល្បជានិច្ច។ យោងតាមសម្តីមួយ ភីឡាដិលភា ជាទីក្រុងដែលមានរញ្ជួយដីជាច្រើន ពីព្រោះប្រជាជនជួសជុលផ្ទះបែកបាក់ជាញឹកញាប់ ពួកគេត្រូវបានកាត់នូវការបង់ពន្ធពីរដ្ឋាភិបាល។ ចំពោះអ្នកដែលរស់នៅក្នុងដីដែលមានការផ្លាស់ប្តូរច្រើន ហើយដោយមិនត្រូវរង្គើនៃព្រះពរនៃពិភពលោកខាងមុខដូចជាសសរស្តម្ភ ដោយមិនរើជាអចិន្ត្រៃយ៍ នោះនឹងបានជាពរជ័យដូចជាទឹកសម្រាប់អ្នកស្រែក។

ព្រះនាមនៃព្រះនៃខ្ញុំ និងឈ្មោះនៃទីក្រុងនៃព្រះនៃខ្ញុំ គឺយេរូសាឡិមថ្មី ដែលបានចុះមកពីព្រះនៃខ្ញុំពីស្ថានសួគ៌ ហើយនឹងឈ្មោះថ្មីរបស់ខ្ញុំផ្ទាល់។ នេះជាពាក្យដើម្បីធានាសិទ្ធិអំណាចបីយ៉ាង ដែលអ្នកឈ្នះត្រូវបានទទួលថាជាកំណប់ស្ថានសួគ៌ ហើយព្រះក៏ផ្តល់សិទ្ធិកាន់កាប់របស់ទ្រង់ដល់គាត់។ ទ្រង់បានព្យាយាមសរសេរឈ្មោះបរិសុទ្ធបីនៅក្នុង

នាង ដើម្បីធានាជាអចិន្ត្រៃយ៍ ដូចជាកម្មសិទ្ធិកាន់កាប់របស់ព្រះជាម្ចាស់ ការកាន់កាប់ក្រុងយេរូសាឡឹមថ្មី និងកម្មសិទ្ធិរបស់ព្រះគ្រីស្ទ។ នៅពេលគាត់សរសេរឈ្មោះរបស់ព្រះគ្រីស្ទ ការពិតដែលគាត់សរសេរឈ្មោះថ្មី គឺដើម្បីធ្វើឱ្យយើងផ្តោតអារម្មណ៍។ ដ្បិតមានតែគាត់ប៉ុណ្ណោះដែលស្គាល់ឈ្មោះថ្មីរបស់គាត់ (19:12)។ វាគឺជាឈ្មោះដែលបង្ហាញពីខ្លឹមសារដ៏ជ្រាលជ្រៅបំផុត ដូចជាសាច់ឈាម ឆ្អឹង។ វាមិនមែនជាការពិតដែលទ្រង់មិនបង្ហាញវានៅក្នុងព្រះបន្ទូលនោះទេ។ ការដែលទ្រង់ធានានូវកម្មសិទ្ធិរបស់គាត់ដោយឈ្មោះបរិសុទ្ធនៃអត្ថន័យបែបនេះមានន័យថា ទ្រង់ស្គាល់ពីកម្មសិទ្ធិយ៉ាងខ្លាំងនិងដ៏វិសេស។ ការពិតដែលក្រុមជំនុំភីឡាដិលភាកាន់ដំណឹងល្អដោយអំណាចតូចរបស់នាង (3:8)។ ត្រូវបានទទួលស្គាល់ដោយព្រះអម្ចាស់។ នៅពេលដែលពួកគេព្យាយាមលះបង់ខ្លួនក្នុងកិច្ចការតូចតាច ពួកគេអាចនឹងស្ទើរតែធ្លាក់ចុះ ឬហាក់ដូចជាត្រូវបានទម្លាក់ចុះហើយ។ ប៉ុន្តែ ព្រះអម្ចាស់មិនបានស្តីបន្ទោសគេទេ គឺទ្រង់ទទួលយកថាមានតម្លៃវិញ។ ហេតុដូច្នេះហើយ ផ្ទុយពីស្ថានភាពនៃការប្រយុទ្ធដែលពួកគេបានធ្វើឱ្យមានភាពរអាក់រអួល និងមានបញ្ហា ឥឡូវនេះព្រះបានធានានូវរបស់កម្មសិទ្ធស្ថានសួគ៌របស់ព្រះគ្រីស្ទថា ពួកគេមិនចេញទៅក្រៅដូចជាសសរដែលបានពង្រឹងដោយសរសេរហត្ថលេខាបីដង។ នេះគឺជាភាពផ្ទុយគ្នានៃព្រះគុណ ហើយគោលការណ៍នៃដំណឹងល្អដែលអ្នកស្មោះត្រង់នឹងការងារតូចមួយ នឹងទទួលបានរង្វាន់ដ៏អស្ចារ្យ។ (ម៉ាថាយ 25:21)។ ពេលយើងឃើញពាក្យនេះ មនុស្សទន់ខ្សោយដូចជាយើងបានទទួលការកំសាន្តចិត្ត និងសេចក្តីសង្ឃឹមផង។

13 អ្នកណាដែលមានត្រចៀក ឱអ្នកនោះស្តាប់សេចក្តីដែលព្រះវិញ្ញាណមានបន្ទូលដល់ពួកជំនុំទាំងប៉ុន្មានចុះ។

យោងតាមពាក្យនេះ ជាព្រះបន្ទូលនៃវិវរណៈត្រូវបានដាក់ដែនកំណត់ត្រឹមមនុស្សដែលត្រូវបានជ្រើសរើសប៉ុណ្ណោះ។ “អ្នកណាដែលមានត្រចៀក” គឺជាអ្នកដែលមានការស្តាប់ខាងវិញ្ញាណ នោះហើយជាមនុស្សដែលបានរើស។ អ្នកណាដែលយល់ពីការបង្រៀនខាងវិញ្ញាណ នោះអាចមានការធានាថា ខ្លួនឯងជាមនុស្សដែលត្រូវបានជ្រើសរើស។ “អ្វីដែលព្រះវិញ្ញាណមានបន្ទូលទៅកាន់ក្រុមជំនុំ។” បង្ហាញថាសំបុត្រផ្ញើទៅក្រុមជំនុំក្នុងតំបន់ពិតជាមានបំណងផ្ញើទៅគ្រប់ក្រុមជំនុំមែន។

14-22 សំបុត្រផ្ញើទៅក្រុមជំនុំឡៅឌីសេ។

14 “ឡៅឌីសេ” ក្រុមជំនុំនេះមានទីតាំងនៅក្បែរតំបន់ភាគខាងត្បូងនៃទន្លេ រូខា គឺជាទីក្រុងពាណិជ្ជកម្ម និងឧស្សាហកម្មដ៏សម្បូរបែប ហើយនៅតំបន់ខាងកើត និងខាងត្បូងនៃទីក្រុង ភីឡាដិលភា ដែលឈ្មោះបច្ចុប្បន្នរបស់វាគឺ អេស្តី ហីសា ដែលមិនមែនជាទីក្រុងសំខាន់នោះទេ។

ព្រះដ៏ជាអាម៉ែន។ យោងតាម វិវរណៈ 1:6 អេសាយ 65:16។ ព្រះយេស៊ូវបានសម្រេចព្រះបន្ទូលរបស់ព្រះ និងសេចក្តីសន្យារបស់ទ្រង់ទាំងអស់។ ទ្រង់បានបង្កើតសេចក្តីស្មោះត្រង់របស់ព្រះយ៉ាងពេញលេញ។ នៅក្នុងអត្ថន័យដូចនេះ ទ្រង់ជាព្រះដ៏ជាអាម៉ែន (ἀμήν= ដែលពិតប្រាកដ) យោងតាម 2កូរិនថូស 1:20។

ជាស្មរបន្ទាល់ស្មោះត្រង់ ហើយពិតប្រាកដ។ នេះជាពាក្យនៅក្នុងការរក្សានៅក្នុងគំនិតពីការពិតដែលថា ព្រះយេស៊ូវបានបង្ហាញពីព្រះ និងបានប្រកាសពីសេចក្តីស្មោះត្រង់របស់ព្រះ ហើយគ្រប់ទាំងការសម្រេចបំពេញដែលទ្រង់បានសម្រេចតាមគ្រប់ទំនាយទាំងអស់នៅក្នុងគម្ពីរសញ្ញាចាស់។ យោងតាម ការបកស្រាយនៃ 1:5។

ជាដើមការដែលព្រះទ្រង់បានបង្កើតមក។ នេះជាពាក្យដែលថាព្រះយេស៊ូវជាព្រះអទិក
រ។ ដូចជាព្រះនាមរបស់ព្រះអម្ចាស់មានលក្ខណៈត្រឹមត្រូវ ដែលដាស់ក្រុមជំនុំឡៅឌី
សេ។ ភាពស្មោះត្រង់របស់ព្រះអម្ចាស់គឺផ្ទុយពីភាពមិនស្មោះត្រង់នៃក្រុមជំនុំរបស់ទ្រង់
ហើយភាពសម្បូរបែបនៃការបង្កើតរបស់ព្រះអម្ចាស់អាចព្យាបាលភាពខ្វះខាតខាង
វិញ្ញាណរបស់ពួកគេបាន។

15 ឯងមិនត្រជាក់ ក៏មិនក្តៅផង។ ថាអ្នកត្រជាក់ឬក្តៅ! នៅទីនេះ ភាពត្រជាក់គឺជាស
ភាពដែលមិនជឿ ដែលមិនដែលទាក់ទងជាមួយដំណឹងល្អទេ ភាពក្តៅមានន័យថា
ស្ថានភាពនៃសេចក្តីស្រឡាញ់ និងចំណង់ចំណូលចិត្តជាអ្នកជឿក្នុងការទទួលយក
ដំណឹងល្អ។ (ព្រៃជដានុស)។

16 ដោយព្រោះឯងគ្រាន់តែស្ទើរៗប៉ុណ្ណោះ។ នេះគឺជាសកម្មភាព និងអាកប្បកិរិយាគួរ
ឱ្យស្អប់ខ្ពើម ដែលដឹងថាក្លាយជារបស់អ្វីមួយ ទោះបីជាគាត់មិនបានក្លាយជាអ្វីមួយក៏
ដោយ។ (ខ 17)។

គឺមិនមែនត្រជាក់ ក៏មិនក្តៅផង នោះអញនឹងខ្ជាក់ឯងចេញពីមាត់អញទៅ។ មូល
ហេតុដែលទ្រង់ខ្ជាក់គេចេញ គឺជាការខ្ពើមក្នុងចិត្ត។ អាកប្បកិរិយាដែលដឹងថានឹង
ក្លាយទៅជាអ្វីមួយ ទោះបីជាគេមិនក្លាយជាអ្វីមួយក៏ដោយ គឺជាស្ថានភាពដែលលាយ
បញ្ចូលគ្នានូវអំពើបាបពីរដែលព្រះអម្ចាស់ស្អប់ នោះគឺ ពុតត្បុត និងភាពក្រអឺតក្រទ
ម។ អំពើបាបដែលព្រះយេហូវ៉ាបានស្តីបន្ទោសខ្លាំងបំផុតគឺ ការលាក់ពុតរបស់ពួកផារិ
ស៊ី។ ព្រះសព្វព្រះទ័យនឹងប្រទានព្រះគុណរបស់ទ្រង់ ប៉ុន្តែទ្រង់បណ្តេញតែមនុស្ស
ក្រអឺតក្រទមចេញ។ (យ៉ាកុប 4:6)។

17 អត្ថបទជាពាក្យដែលចង្អុលទៅលើអំពើបាបដែលគេគិតថាមិនបានក្លាយទៅជា ប៉ុន្តែគេដឹងថាខ្លួនបានក្លាយជាបែបនោះរួចហើយ។ បានកាន់តែស្គុកស្គមឡើងហើយ នោះមានន័យថាគេថាមានទ្រព្យខាងវិញ្ញាណ។ វេទនា គួរឱ្យអាណិត ការទាំងពីរនេះ ជាពាក្យសំដែងនូវសេចក្តីទុក្ខវេទនាដោយភាពក្រីក្រខាងវិញ្ញាណ។ ហេតុផលបីយ៉ាង នៃស្ថានភាពដែលវេទនាគឺ ក្រីក្រ ខ្វាក់ និងអាក្រាត។ ខគម្ពីរខាងក្រោមនិយាយម្តង ទៀតអំពីរឿងបីនេះ។

18 មាសដែលសំរង្គក្នុងភ្លើង។ ការនេះចង្អុលទៅកាន់សេចក្តីជំនឿសុទ្ធ (1ពេត្រុស 1:7) សំលៀកបំពាក់ស ជាការរាប់ជាសុចរិតដែលព្រះគ្រីស្ទបានសុគតនៅលើឈើ ឆ្កាង និងបានផ្តល់ឱ្យអ្នកជឿ។ ថ្នាំលាបភ្នែកជាការប្រៀបធៀបពីព្រះគុណ ដែលព្រះ វិញ្ញាណបរិសុទ្ធបើកបង្ហាញយ៉ាងភ្លឺចែងចាំង។ ទិញ នេះជាការដោះស្រាយខាង វិញ្ញាណដោយមិនបង់ថ្លៃជាតម្លៃ។

19 អស់អ្នកណាដែលអញស្រឡាញ់។ ស្រឡាញ់ គឺថា ហ្វីលេអូ (φιλεῶ) នៅក្នុង ភាសាក្រិក ដែលលោក បែងហ្គល ចាត់ទុកជាទង្វើនៃការស្រឡាញ់ដែលថែរក្សាដោយ អរគុណ។ យោងតាម សុភាសិត 3:12, ហេព្រើរ 12:6-13។ នៅខាងលើ ក្រុមជំនុំភី ឡាដិលភាបានទទួលសេចក្តីស្រឡាញ់គឺ អាហ្គាផេ (ἀγάπη = ជាសេចក្តីស្រឡាញ់ ដ៏មានតម្លៃ កាលដែលទ្រង់សម្លឹងមើលទៅកាន់ចំណុចល្អនៃក្រុមជំនុំភីឡាដិលភា នោះទ្រង់ទទួលនាងជាពិសេស) (ខ 9) “ក្រុមជំនុំឡៅឌីសេទទួលនូវសេចក្តីស្រឡាញ់ ដែលលាក់កំបាំង។ យោងតាម 1សាំយ៉ូអែល 7:3 2កូរិនថូស 7:14, ទំនុកដំកើង 34:18, 51:17, 147:3។

20 មើល អញឈរនៅមាត់ទ្វារទាំងគោះ។ ពាក្យនេះបង្ហាញថា (1) សេចក្តីប៉ងប្រាថ្នាចង់រៀបចំគ្រប់ការទាំងអស់ (2) ការជំរុញឱ្យប្រែចិត្តដល់អ្នកជឿដែលធ្វើអំពើបាប។

ហើយនឹងបរិភោគជាមួយនឹងអ្នកនោះ។ យោងតាម បទចំរៀនសាឡូម៉ូន 5:1, 2, នេះជាការប្រៀបធៀបដែលចង្អុលទៅកាន់ការប្រកបគ្នានៃសេចក្តីស្រឡាញ់ខាងវិញ្ញាណ។ (វិវរណៈ 19:9, 17 លូកា 14:12, 17:8)។

21 អ្នកណាដែលឈ្នះ ការនេះចង្អុលទៅកាន់អ្នកដែលយកឈ្នះបានដោយការលន់តួបាប។

ឱ្យអង្គុយនៅលើបល្ល័ង្កជាមួយនឹងអញ។ ការនេះចង្អុលទៅកាន់អ្នកជឿដែលបានយកឈ្នះដែលនឹងត្រូវចូលទៅក្នុងលោកិយដែលនឹងមកដល់ និងបានសោយរាជ្យជាមួយនឹងព្រះជាម្ចាស់។

22 អ្នកណាដែលមានត្រចៀក ឱ្យអ្នកនោះស្តាប់សេចក្តីដែលព្រះវិញ្ញាណមានបន្ទូលដល់ពួកជំនុំទាំងប៉ុន្មាន។ សំដៅទៅលើការបកស្រាយនៃពាក្យដូចគ្នានៅ 2:7 និង 3:13។

ចំណុចសំខាន់

ការអធិប្បាយទី 9 ក្រុមជំនុំភីឡាដែលភា (វិវរណៈ 3:1-11)

ភីឡាដែលភាជាកន្លែងដែលមានរញ្ជួយដីច្រើនកើតឡើង។ ទីក្រុងនេះត្រូវបានកសាងឡើងដោយស្តេច អាតាលឹស ហើយវាមានឈ្មោះហៅក្រៅថាជា សួនអេដែនតូច ដោយសាររូបព្រះក្លែងក្លាយជាច្រើន។

1. ព្រះគុណដែលក្រុមភីឡាដែលភាបានទទួល

ខទី 8 “ទ្វារចំហ” អាចជាពាក្យប្រៀបប្រដូចដើម្បីចង្អុលទៅព្រះយេស៊ូវផ្ទាល់។ ទីមួយ ទ្រង់ជាទ្វារដែលនាំទៅដល់សេចក្តីសង្គ្រោះ។ ដោយសារអ្នកជឿគឺជាអ្នកដែលរត់ចេញពីពិភពលោក (ហេព្រើរ 6:18) “ដើម្បីឱ្យយើងរាល់គ្នា ដែលបានរត់មកចាប់កាន់សេចក្តីសង្ឃឹម ដែលដាក់នៅមុខយើង ទុកជាទីជ្រកកោន បានសេចក្តីកំឡាចិត្តឡើងជាខ្លាំង”។ ពួកគេត្រូវការទ្វារចូលទៅពិភពលោកខាងក្រៅយ៉ាងពិតប្រាកដ។ ពេលមនុស្សចេញទៅក្រៅទីក្រុងដែលត្រូវបានបំផ្លាញ គាត់នឹងអាចរស់បាន។ ទីពីរ ព្រះគ្រីស្ទជាទ្វារដែលយើងអាចធ្វើឱ្យយើងប្រាស្រ័យទាក់ទងជាមួយព្រះបាន។ យ៉ូហាន 10:9 មានប្រសាសន៍ថា “ខ្ញុំជាទ្វារ បើអ្នកណាចូលតាមខ្ញុំ នេះនឹងបានសង្គ្រោះ រួចនឹងចេញចូល ហើយនឹងរកបានវាលស្មៅដ៏ស្រួល”។ ផ្នែកចុងក្រោយនៃវគ្គនេះបង្ហាញថា អ្នកជឿទទួលបានអាហារខាងវិញ្ញាណតាមរយៈការទំនាក់ទំនងជាមួយព្រះ។ អ្នកជឿទទួលបានខ្លឹមសារដោយការប្រាស្រ័យទាក់ទងនឹងព្រះ ដូចចៀមទទួលបានដអាហារដែរ។ ខទី 8 ចែងថា៖ “អញស្គាល់ការដែលឯងធ្វើហើយ មើល អញបានបើកទ្វារចំហនៅមុខឯង គ្មានអ្នកណានឹងបិទបានទេ ពីព្រោះទោះបើឯងមានអំណាចដែលបន្តិចក៏ដោយ គង់តែបានកាន់តាមពាក្យអញដែរ ហើយមិនបានលះបង់ឈ្មោះអញទេ”។ វាជាពាក្យសរសើរដែលពេលនោះព្រះអម្ចាស់បានប្រទានដល់ក្រុមជំនុំភីឡាដែលភា។ (1) ទោះបីជាយើងបានទទួលអំណាចដ៏តូចក៏ដោយ នៅពេលដែលយើងអរព្រះគុណព្រះជាម្ចាស់ ហើយបានប្រើវាសម្រាប់ព្រះអម្ចាស់ដោយថ្វាយបង្គំ នោះទ្រង់អាចទទួលបានរបស់ដ៏អស្ចារ្យ។ ព្រះអម្ចាស់មានព្រះទ័យរីករាយ ពេលយើងលះបង់អ្វីដែលយើងមានដោយចិត្តស្មោះនៅចំពោះព្រះអម្ចាស់។ ព្រះមិនសព្វព្រះហឫទ័យសម្រាប់ចំនួនដែលយើងបានផ្តល់ជូនជាជាងចិត្តភក្តីដ៏ល្អនៃការថ្វាយដល់ទ្រង់នោះទេ។ (2) ផ្ទុយទៅវិញ វាងាយស្រួលជាងដែលអ្នកដែលមានអំណាចតូចកាន់

កាប់កៅអីនៃភាពរាបទាប។ ហេតុផលដែលពួកគេទទួលបានភាពជោគជ័យគឺការពិត ដែលថាព្រះប្រទានព្រះគុណរបស់ទ្រង់ដល់មនុស្សរាបទាប។ សាការី 13: “ដូច្នេះ ចូរប្រាប់ពួកគេថា ព្រះអម្ចាស់នៃពិភពទាំងមូលមានព្រះបន្ទូលថា ចូរត្រឡប់មកឯអញវិញ នោះព្រះយេហូវ៉ានៃពិភពទាំងមូលមានព្រះបន្ទូលថា អញនឹងត្រឡប់មកឯងវិញ” ។ (3) ព្រះចង់ក្រោកឈរឡើងលើអ្នកដែលមានអំណាចតូច ដោយសារទ្រង់ចង់បានរបស់តូចវិញ ដែលធ្វើឱ្យអ្នកមានច្រើនទៅជាអាម៉ាស់ (1កូរិនថូស 1:27, 28)។ តើអ្នកជឿនៅក្រុមជំនុំក្រុងហ្វីឡាដែលហៀបានធ្វើអ្វីខ្លះជាមួយនឹងអំណាចដ៏តូចរបស់ពួកគេ? គឺការរក្សាព្រះបន្ទូលរបស់ព្រះដោយផ្ទាល់ជាមួយនឹងអំណាចតូចនោះ។ ពេលយើងរក្សាព្រះបន្ទូលរបស់ព្រះ មានផ្នែកងាយស្រួល និងផ្នែកដែលពិបាក។ (1) ទស្សនៈងាយស្រួល។ (ក) អ្នកជឿពេញចិត្តនឹងព្រះបន្ទូលនៃព្រះសម្រាប់ការរស់ឡើងវិញរបស់ពួកគេ។ ទំនុកតម្កើង 119:14 ចែងថា៖ “ទូលបង្គំបានត្រេកអរក្នុងផ្លូវប្រព្រឹត្តតាមសេចក្តីបន្ទាល់របស់ទ្រង់ឱ្យស្មើនឹងសេចក្តីអំណរចំពោះទ្រព្យសម្បត្តិគ្រប់យ៉ាង”។ ហើយខ 56 និយាយថា "ឯចំណែកនៃទូលបង្គំ ឱព្រះយេហូវ៉ាអើយទូលបង្គំបានពោលថា ត្រូវឱ្យទូលបង្គំរក្សាអស់ទាំងព្រះបន្ទូលនៃទ្រង់”។ ហើយខ 72 និយាយថា "ក្រឹត្យវិន័យដែលចេញពីព្រះឱស្ឋទ្រង់មកនោះវិសេសដល់ទូលបង្គំ ជាជាងមាសប្រាក់ទាំងពាន់ផង"។ ហើយ ខ 136 ចែងថា “ទឹកភ្នែកទូលបង្គំហូររហាមពីព្រោះគេមិនកាន់តាមក្រឹត្យវិន័យរបស់ទ្រង់”។ (ខ) ការដែលយើងរក្សាព្រះបន្ទូលរបស់ព្រះ យើងនឹងមានព្រះពរដែលនាំទៅកាន់ជីវិតនិងអ្វីផ្សេងទៀត។ យើងមានទម្លាប់ល្អដែលធ្វើតាមព្រះបន្ទូល ការគោរពប្រតិបត្តិគឺជាអ្នកត្រួសត្រាយផ្លូវនៃពិភពលោកនៃជីវិត។ អ្នកដែលមានជំនឿដើម្បីសរសើរតម្កើងព្រះយេហូវ៉ា គឺជាមនុស្សដែលស្តាប់បង្គាប់។ (2) ទស្សនៈដែលពិបាក។ (ក) ក្នុងការកាន់តាមព្រះបន្ទូលរបស់ព្រះចំនុចមួយពិបាកធ្វើឱ្យមាន

ការបាំងនឹងការរក្សាវាដោយសារអំពើបាបដែលមានមន្តស្នេហ៍។ តើអំពើបាបដែលមានមន្តស្នេហ៍គឺជាអ្វី? ឧទាហរណ៍វាគឺជាភាពលោភលន់ ឬចំណង់ផ្លូវភេទ។ សម្ភារៈល្អរួងមនុស្សនោះ។ ចំណង់ផ្លូវភេទក៏ដូចគ្នាដែរ។ ប៉ុន្តែអ្នកជឿមើលឃើញពេលវេលានាពេលអនាគត។ កាលដែលយើងនឹងបានបរាជ័យក្នុងកន្លែងនោះមួយដង ដែលវាច្បាស់វាជាត្រូវបានជាសេចក្តីអាម៉ាស់ដ៏អស់កល្បជានិច្ច។ (ខ) ទស្សនៈដ៏ពិបាកមួយទៀតក្នុងការរក្សាព្រះបន្ទូលរបស់ព្រះ នៅពេលអ្នកជឿដែលមានក្នុងពិភពលោកនឹងបន្តរក្សាព្រះបន្ទូលរបស់ព្រះ គេនឹងជួបការរងទុក្ខខ្លះដោយធម្មជាតិ។ ប៉ុន្តែក្នុងករណីនេះរាស្ត្រដ៏វិសុទ្ធមិនស្វាក់ស្ទើរក្នុងការរក្សាព្រះបន្ទូលរបស់ព្រះដោយក្លាហានឡើយ។ នៅចំពោះមុខសត្រូវ នៅពេលដែលយើងរក្សាព្រះបន្ទូលរបស់ព្រះយើងមានអារម្មណ៍ថាជាការងារនៃជីវិតខាងវិញ្ញាណដែលព្រះបានផ្តត់ផ្តង់នោះ។ ហើយនៅចំពោះពួកគេដែលត្រូវគេបៀតបៀនក៏ឃើញសិរីរុងរឿងរបស់ពិភពលោកដែលនឹងមកជិតមកដល់ហើយនោះ។ “ខ្ញុំរាប់អស់ទាំងសេចក្តីទុក្ខលំបាកនៅជាន់នេះ ថាជាសេចក្តីមិនគួរប្រៀបផ្ទឹមនឹងសិរីល្អ ដែលនឹងបើកសំដែងមកឱ្យយើងរាល់គ្នាឃើញនោះទេ” (រ៉ូម 8:18)។ ការរងទុក្ខសម្រាប់ព្រះបន្ទូលរបស់ព្រះសន្យាថានឹងទទួលព្រះពរនាពេលអនាគត (រ៉ូម 5: 3, 4)។ ដូចមនុស្សម្នាក់បាននិយាយថាឃ្លាំងរបស់ព្រះមានកន្លែងនោះឱ្យដាក់ពរជ័យដែលបានពន្យារពេលរង្វាន់នេះ។ ព្រះពរមួយចំនួនមិនបានមកយ៉ាងឆាប់រហ័សដូចដែលយើងបានរំពឹងទុកនោះទេ ប៉ុន្តែវាអាចត្រូវបានពន្យារពេល។ រ៉ូម 8:15 ចែងថា: “អ្នករាល់គ្នាមិនបានទទួលនិស្ស័យជាបាវបំរើ ឱ្យត្រូវភ័យខ្លាចទៀតឡើយ គឺបានទទួលនិស្ស័យជាកូនចិញ្ចឹមវិញ ដោយហេតុនោះបានជាយើងស្រែកឡើងថា ឱអ័ប្បាព្រះវរបិតាអើយ”។ និង លូកា 21:19 ចែងថា “អ្នករាល់គ្នានឹងបានជីវិតគង់នៅវិញដោយមានចិត្តខ្ជាប់ខ្ជួន”។ (គ) នៅពេលដែលយើងរក្សាព្រះបន្ទូលរបស់ព្រះអម្ចាស់

នោះមានទស្សនៈដ៏ពិបាកមួយទៀត។ វាគឺជាការពិតដែលថាចំពោះអ្វីដែលពាក្យនេះទាមទារឱ្យយើងគួរតែយកឥរិយាបថនៃការគោរពប្រតិបត្តិដែលគួរតែជ្រៅហើយគួរតែខ្ពស់។ តើមនុស្សប្រៀបអំណាចអ្វីចំពោះបទដ្ឋាននេះ? វាមិនអាចទៅរួចទេ។ ប៉ុន្តែនៅពេលនេះយើងគួរតែជំនួសអាកប្បកិរិយា "ខ្ញុំជាមនុស្សមានបាប" ដោយមានបន្ទាបខ្លួនយ៉ាងខ្លាំង។ ទោះជាមនុស្សសុចរិតមិនមានចិត្តរាបទាបទ្រង់បានផ្តាច់អស់ឱ្យបានសុចរិតទាំងស្រុងផង។

ការអធិប្បាយទី 10 ក្រុមជំនុំឡៅឌីសេ (វិវរណៈ 3:14-22)

1. ក្រុមជំនុំឡៅឌីសេមានភាពក្តៅអ៊ុនៗ

   (1) សភាពក្តៅអ៊ុនៗនាំមកនូវភាពពុករលួយ។ របស់ដែលត្រជាក់ការពាររបស់ផ្សេងៗ ហើយរបស់ដែលក្តៅក៏រក្សាដូចគ្នា។ តែភាពក្តៅអ៊ុនៗនាំឱ្យមានការរលួយ។ ពីព្រោះសភាពក្តៅអ៊ុនៗនៅក្នុងជីវិតអ្នកជឿធ្វើឱ្យគេគេចមិនផុតពីការពុករលួយឡើយតែធ្វើឱ្យគេអោបវាជាប់វិញ វាជម្រុញដល់សេចក្តីពុករលួយ ហើយធ្វើឱ្យយើងចេញមកជាស្មោកគ្រោកដោយសារសេចក្តីពុករលួយ។

   (2) ភាពក្តៅអ៊ុនៗមិនមានការតាំងចិត្តទេ។ ប្រសិនបើអ្នកណាមិនក្លាយជាបែបហ្នឹង និងនៅកន្លែងតែមួយទេ នោះវានឹងចេញពីការមិនតាំងចិត្ត។

ដោយសារសេចក្តីជំនឿជាការផ្សងព្រេងនៃការផ្សងព្រេងទាំងអស់ ដែលគ្មានការតាំងចិត្តគ្មានការទទួលបានផល។ យើងគួរតែធ្វើដូចជាការមើលទៅកាន់របស់ស្ថានសួគ៌ដែលមើលមិនឃើញ ដូច្នេះវាគ្មានអ្វីក្រៅពីការផ្សងព្រេងឡើយ។ នៅពេលយើងរស់នៅដោយសេចក្តីជំនឿ យើងគួរតែឆ្លងទៅរកគោលបំណងដោយដកចេញនូវឧបសគ្គដែលជំពប់ដួលដោយមិនបានស្គាល់។ អ្នកដែលមិនមានការតាំងចិត្តយ៉ាងនេះ គាត់មិនអាចឆ្ពោះទៅរកគោលដៅបានទេ ដោយសារគាត់បានជួបនឹងបាំងជិត និងអន្ទាក់នៃសម្ភារៈដែលមើលឃើញទាំងអស់នៅតាមផ្លូវរបស់គាត់។ អ័ប្រាហាំបានតាំងចិត្តបន្ទាប់ពីបានស្តាប់តាមបង្គាប់របស់ព្រះថា៖ “ចូរចាកចេញពីក្រុងអ៊ើរក្នុងស្រុកខាល់ឌាទៅ”។ តើគាត់មិនបានស្តាប់តាមការបង្គាប់របស់ព្រះ ហើយតាំងចិត្តទេឬ? តើគាត់បានដេញតាមភាពសុខសុវត្ថិភាពនៃបច្ចុប្បន្ននេះតាមការមើលឃើញរបស់គាត់ឬ? គាត់បានតាំងចិត្តដែលត្រូវផ្តោតតែទៅនឹងព្រះបន្ទូលរបស់ព្រះជាម្ចាស់ ទោះបីជាគាត់មើលឃើញអ្វីដែលផ្ទុយទៅនឹងស្ថានភាពជាក់ស្តែងក៏ដោយ។ ប្រសិនបើវាជាព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដូចមនុស្សស្រេកទឹកហើយដងក់រកទឹកដែរ។ ដោយសារគាត់បានដឹងថា ព្រះបន្ទូលរបស់ព្រះមិនដែលបរាជ័យឡើយ។ នៅលើនៃការប្រែចិត្តទាំងអស់ គឺវាត្រូវការការតាំងចិត្ត។ បើជាវាជារឿងហាមឃាត់ យើងគួរកាត់វាចោល ទោះបីយើងខាតច្រើនក៏ដោយ។ មិនត្រឹមតែប៉ុណ្ណោះ នៅក្នុងការអនុវត្តរបស់យើង យើងត្រូវការការប្តេជ្ញាចិត្តដូចគ្នា។ តើយើងនឹងស្លាប់ដោយមិនមានការតាំងចិត្តទាល់តែសោះឬ បើយើងមានកិច្ចការដែលយើងគួរធ្វើនោះ? លោក

Chapman Amstrong បានទទួលយកភាពមិនអាចទៅរួចដែលគាត់មិនអាចធ្វើដូចគោលបំណងរបស់គាត់។ បាវចនានៃជីវិតរបស់គាត់គឺ "សម្រេចបាននូវអ្វីដែលមិនអាចទៅរួច"។ តើយើងមិនគួរប្រតិបត្តិអ្វីដែលយើងគួរធ្វើតាមធម្មជាតិទេឬ? តើយើងគួរត្រូវបំផ្លាញឬ? ស្ថានភាពនៃភាពភ័យខ្លាច គឺជាអាកប្បកិរិយាដើម្បីស្វាក់ស្ងើរ។ អាកប្បកិរិយាបែបនេះមិនមែនជាជំនឿទេ។ អេលីយ៉ានិយាយថា៖ “អេលីយ៉ាបានចូលទៅជិតមនុស្សទាំងអស់ហើយនិយាយថា៖ “តើអ្នករាល់គ្នានឹងមានគំនិតពីរផ្សេងគ្នាដល់ពេលណា? ប្រសិនបើព្រះអម្ចាស់ជាព្រះ ចូរធ្វើតាមព្រះអង្គទៅ។ ប៉ុន្តែប្រសិនបើព្រះបាល ចូរតាមគេទៅ”។ ហើយប្រជាជនមិនបានឆ្លើយតបនឹងគាត់មួយម៉ាត់ឡើយ” (1 ពង្សាវតារក្សត្រ 18:21)។

(3) សភាពក្តៅអ៊ុនៗមិនមានជីវិតចាស់ទុំទេ។ យើងមិនគួរបែងចែកពេលវេលាពិតប្រាកដឡើយ ហើយក៏យើងមិនគួរសម្របសម្រួលទៅនឹងពេលបច្ចុប្បន្នដែរ។ យើងគួរតែមានការយល់ដឹងដើម្បីយកឈ្នះលើពេលវេលា និងគុណធម៌ក្នុងជីវិតរបស់យើង។ វាចេញមកពីបទគម្ពីរ។ ព្រះបន្ទូលនៃបទគម្ពីរមិនមែនជាពាក្យដែលទទួលភ្លាមៗដូចដែលយើងកាន់បាន ប្រសិនបើយើងអាចត្រូវបានទៅជាថ្មីនៅពេលណាក៏បាននោះទេ។ ដោយសារយើងមិនរស់នៅតាមបទគម្ពីរ ដូច្នេះអ្នកជឿមិនអាចយកឈ្នះពិភពលោកបានទេ។ អ្នកជឿដែលមិនរស់នៅដូចបទគម្ពីរនឹងក្លាយទៅជាដូចជាព្រះបន្ទូលរបស់ព្រះថា នោះហើយជាមនុស្សលោកនឹងត្រូវអាម៉ាស់។ ព្រះយេស៊ូវមានប្រសាសន៍ថា៖ “អ្នករាល់គ្នាជាអំបិលនៃផែនដី តែ

បើអំបិលបាត់រសជាតិប្រៃ តើធ្វើដូចម្តេចឱ្យប្រៃឡើងវិញបាន? វាមិនល្អ
សម្រាប់អ្វីទៀតទេ លើកលែងតែត្រូវបោះចោល ហើយជាន់នៅនឹងជើង
មនុស្ស។"

2. វិធីសាស្ត្រក្នុងការរំដោះក្រុមជំនុំឡៅឌីសេ

ក្រុមជំនុំឡៅឌីសេមានការត្រឹមត្រូវមួយនៅក្នុងនាង។ ក្រុមជំនុំផ្សេងទៀតបានទទួល
ការស្តីបន្ទោសពីព្រះអម្ចាស់ ម្ខាងទៀត ពួកគេបានទទួលការសរសើរមួយចំនួន។ តែ
ក្រុមជំនុំឡៅឌីសេបានទទួលតែការស្តីបន្ទោសដោយគ្មានការណែនាំអ្វីឡើយ។ ព្រះ
អម្ចាស់បានបង្គាប់ឱ្យទិញមាស សំលៀកបំពាក់សរ និងថ្នាំភ្នែក។ នៅទីនេះ ការប្រៀប
ប្រដូចចង្អុលទៅកាន់មាសនៃសេចក្តីជំនឿ សំលៀកបំពាក់សជាសេចក្តីសុចរិត និងថ្នាំ
ភ្នែកជាព្រះវិញ្ញាណបរិសុទ្ធដែលធ្វើឱ្យពួកគេមើលឃើញ។ នៅទីនេះ តើការទិញមាន
ន័យយ៉ាងណា? វាមានន័យថាការចង់បានការទាំងឡាយខាងលើ ហើយដឹងពីវាយ៉ាង
ខ្លាំង ហើយទទួលវាដោយពិត។ អេសាយ 55:1 បានមានបន្ទូលថា "ហឺយ អស់អ្នក
ដែលស្រេកអើយ ចូរមកឯទីទឹកចុះ ឯអ្នកដែលគ្មានប្រាក់អើយ ចូរមកទិញ ហើយ
បរិភោគទៅ អើ ចូរមកទិញស្រាទំពាំងបាយជូរ និងទឹកដោះគោឥតបង់លុយ ឥតថ្លៃ
ទេ"។

ការអធិប្បាយទី 11 អំពីការលន់តួបាប (វិវរណៈ 3:19-22)

1. តើការប្រែចិត្តជាអ្វី?

ពាក្យប្រែចិត្តគឺ ណាខាម (בָּנַם) នៅក្នុងភាសាហេព្រើរ ឬ ស្យូប (בּוּשׁ) ណាខាមមាន
ន័យថាសោកសៅ ស្យូបជាការបែរត្រឡប់។ ពាក្យទាំងពីរជាពាក្យដែលជាទស្សនៈនៃ
ការលន់តួបាប។ ការលន់តួបាបមានន័យថាជាការទទួលស្គាល់នូវកំហុសនៃការធ្វើ
ទុក្ខរបស់បាប ហើយការមានភាពសោកសៅ ហើយនឹងបែរត្រឡប់ចេញពីផ្លូវនៃបាប។
ប្រសិនបើគាត់មានអារម្មណ៍សោកសៅតែមួយទៅកាន់អំពើបាបរបស់ខ្លួនដោយគ្មាន
ការបែរត្រឡប់ចេញពីវា វាមិនអាចហៅថាជាការប្រែចិត្តពិតទេ។ វាជាបែបនៃការធ្លាក់
ទឹកចិត្ត។ សាសនាគ្រិះមិនទទួលពាក្យថាការធ្លាក់ទឹកចិត្តទេ ពីព្រោះព្រះផ្តល់សេចក្តីស
ង្រ្គោះ ប្រសិនបើគេត្រឡប់មករកព្រះយេស៊ូវគ្រីស្ទចេញពីសភាពនោះ បើទោះជា
មនុស្សបានធ្លាក់ចុះទៅក្នុងការធ្លាក់ទឹកចិត្ត។ ប្រសិនបើគេប្រែចិត្ត បរាជ័យពីអតីត
កាលត្រូវបានដកចេញជាជាង ហើយធ្វើឱ្យគេធ្លាក់ចុះទៅក្នុងសភាពនោះម្តងទៀត។
ដូច្នេះ នៅក្នុងសុភាសិតអង់គ្លេសនិយាយថា “បរាជ័យជាថ្មជ្រុងទៅកាន់ភាព
ជោគជ័យ”។

ការលន់តួបាបមិនចង្អុលទៅការកែប្រែគោលការណ៍បែបសាមញ្ញទេ ឬការផ្លាស់ប្តូរនៅ
ក្នុងជីវិត តែអ្នកមានបាបត្រឡប់ទៅរកព្រះ។ ការកែទម្រង់នៃការកែទម្រង់សាមញ្ញនៃ
គោលការណ៍ដែលនៅក្រៅពីសាសនាគ្រីស្ត វាមិនមែនជាការលន់តួបាបពិតទេ។ ក្រិក
ផ្លេម៉ូ ជាកូនប្រុសនៃអ្នកមានហើយក៏ពុករលួយ បន្ទាប់មកគាត់មានការកោតសរសើរ
ដោយលក្ខណៈសម្បត្តិដែលថ្លៃថ្នូរនៃប្រជាធិបតេយ្យ និងការថ្លែងយ៉ាងគួរកោតសរសើរ
យ៉ាងជ្រាលជ្រៅ គាត់រស់នៅដោយមានគោលការណ៍ជីវិតយ៉ាងខ្លាំង។ បុរសទំពែក
ដែលជាអ្នកដឹកនាំបក្សចេណា ដែលជាបក្សមួយនៃព្រះពុទ្ធសាសនាដែលរស់នៅក្នុង
ជីវិតដែលមានសីលធម៌នៅពេលគាត់នៅក្មេង ហើយបានផ្លាស់ប្រែជំនឿពេលគាត់

អាយុ30ឆ្នាំ ហើយសញ្ជឹងគិតអស់រយៈពេល12ឆ្នាំ ហើយបន្ទាប់មកគាត់ត្រូវបាន កសាងឡើងដាច់ដោយឡែក។ លោក Thomas Carlyle បានយកកំឡុងពេលនៃ ការកែទម្រង់នៃជីវិតរបស់គាត់ដែលមកដល់កន្លែងអង្គុយដែលមិនត្រូវខ្លាចសេចក្តី ស្លាប់និងអារក្ស។ ហើយលោក John Stuart Mill បានអានពីកំណាព្យនៃតម្លៃពាក្យ និងបានយល់ ហើយបានចាប់ផ្តើមជីវិតថ្មីរបស់គាត់។ ការផ្លាស់ប្រែជាបណ្តោះអាសន្ន នៅខាងលើមិនមែនជាការប្រែចិត្តពិតទេ។ ការប្រែចិត្តជាការផ្លាស់ប្រែនៃជីវិតពិសេស ដែល មនុស្សមានបាបត្រឡប់ទៅកាន់ព្រះបន្ទូលរបស់ព្រះនិងព្រះ។

លោក Bavinck បែងចែកការប្រែចិត្ត និងការមិនប្រែចិត្តដូចតទៅ។ ការប្រែចិត្តជាការ ព្រួយបារម្ភស្របតាមបំណងរបស់ព្រះ ដែលសម្រេចនូវសេចក្តីសង្គ្រោះ។ ដូច្នេះវាជា ការព្រួយបារម្ភដែលគ្មានការសោកស្តាយ។ តែការមិនប្រែចិត្តមិនមែនជាការព្រួយ បារម្ភតាមបំណងព្រះហឫទ័យរបស់ព្រះ តែការដើរតាមលោកិយហើយមកដល់សេចក្តី ស្លាប់។ ពាក្យនេះបាននិយាយនៅ 2កូរិនថូស 7:10 បាននិយាយចំៗ។ រួចមកការប្រែ ចិត្តពិតនេះមិនមែនដោយចិត្តឯកឯងរបស់មនុស្សនោះទេ តែបច្ចុប្បន្នដែលព្រះប្រទាន ឱ្យ។ លោក Bavinck បានចង្អុលសេចក្តីពិតនេះយ៉ាងច្បាស់។ ការដែលត្រូវលន់តួ បាបពិតចេញមកពីព្រះគុណនៃព្រះវិញ្ញាណបរិសុទ្ធ។ ដូច្នេះជាពេលមួយដែលមនុស្ស ជាច្រើនអាចកែប្រែចិត្ត ហើយឱ្យប្រែចិត្តជាបន្តទៀត។

ដូចជាលោក Whitefield និយាយពីគាត់អធិប្បាយទៅកាន់កម្មករមីននៅ Kingswood ពួកគេបានលន់តួបាបហើយយំ ហើយបន្ទាត់សបានលេចមកនៅលើផ្ទៃ មុនរបស់ពួកគេអស់មួយរយៈ មនុស្ស 20000នាក់មានការភ្ញាក់ផ្អើលដោយការ

អធិប្បាយរបស់គាត់ប្រហែល1ម៉ោងកន្លះ ហើយមនុស្សក៏យំសោកយ៉ាងខ្លាំងទួញយំជាទូទៅ។ កិច្ចការនេះមិនអាចជាអំណាចរបស់មនុស្សទេ។

2. ការប្រែចិត្តគួរតែចេញពីចិត្ត

ការប្រែចិត្តត្រូវបានបង្កើតឡើងដោយការឈឺចាប់ចេញពីចិត្តនិងសេចក្តីកោតខ្លាចភាពពុតត្បុតបានរារាំង។ នេះជាព្រឹត្តិការណ៍ដែលធ្វើឱ្យចិត្តរឹងដូចជាថ្ម ដែលបានប្តូរទៅជាសាច់ឈាមដែលទន់។ ដូច្នេះ អារក្សធ្វើឱ្យយើងមានការលន់តួបាបដែលមានពុតត្បុតច្រើនដែលរារាំង។ យ៉ូអែល 2:13 មានបន្ទូលថា “មិនត្រូវឱ្យហែកអាវខ្លួនទេ គឺត្រូវហែកចិត្តវិញ”។ ការហែកចិត្តជាគោលបំណងនៃការកែប្រែចិត្ត។ ហេតុផលដែលព្រះវិញ្ញាណបរិសុទ្ធធ្វើឱ្យចិត្តយើងទន់ ជាការផ្តល់នូវព្រះគុណដ៏អស្ចារ្យដល់យើងនៅពេលអនាគត។ ប្រសិនបើចិត្តរបស់យើងរឹងរូសនិងមានហិង្សា ព្រះគុណរបស់ព្រះវិញ្ញាណបរិសុទ្ធមិនអាចមកដោយបរិបូរទេ។ តើការប្រើប្រាស់អ្វីដែលវាមាន ដែលជាគ្រាប់ពូជដែលរាយនៅលើព្រិល? កាលដែលវាត្រូវព្រោះទៅនៅរដូវផ្កាឫស្សី វានឹងលូតលាស់ឡើង ចិត្តដែលមុតស្រួចដោយគ្មានការលន់តួបាបមិនអាចបង្កើតផលផ្លែនៃព្រះវិញ្ញាណបរិសុទ្ធឡើយ។ ពីព្រោះការប្រែចិត្តធ្វើឱ្យចិត្តទន់ ប្រសិនបើយើងដើរតាមការធ្វើពុតដោយគ្មានន័យទេមានតែចិត្តរបស់យើងត្រូវបានរឹងឡើង។

3. អ្វីដែលបិទបាំងការលន់តួបាប

(1) ភាពមានពុត។ តើអ្វីជាសេចក្តីកំពុត?

1) វាជាការជំនុំជំរះតាមការដែលមើលឃើញ។ ព្រះយេស៊ូវមានបន្ទូលថា "ហេតុអ្វីបានជាអ្នកមើលឃើញកំទេច ដែលនៅក្នុងភ្នែករបស់បងប្អូនអ្នក តែមិនឃើញធ្នឹម ដែលនៅក្នុងភ្នែករបស់ខ្លួនសោះដូច្នេះ។ ឬធ្វើដូចម្តេចឱ្យអ្នកនិយាយនឹងបងប្អូនថា ចូរឱ្យអញយកកំទេចពីភ្នែកឯងចេញ តែមើល មានធ្នឹមនៅក្នុងភ្នែកខ្លួនអ្នកវិញ។ អ្នកមានពុតអើយ ចូរយកធ្នឹមពីភ្នែករបស់ខ្លួនចេញជាមុនសិន នោះទើបនឹងបានឃើញច្បាស់ អាចនឹងយកកំទេចចេញពីភ្នែករបស់បងប្អូនអ្នកបានដែរ។" (ម៉ាថាយ 7:3-5)។ ពីព្រោះអ្នកដែលមានពុតដូចមនុស្សនេះអាចមើលឃើញតែការដែលមើលឃើញ គេមិនប្រែចិត្តទេ តែនិយាយតែពីកំហុសរបស់អ្នកផ្សេង។ ដូចដែលយើងមិនអាចមើលឃើញមុខរបស់ឃើញ នោះបុរសនោះមិនអាចមើលឃើញកំហុសរបស់ខ្លួនដែរ បើទោះជាគាត់ដឹងពីកំហុសរបស់ខ្លួនក៏គាត់មិនដឹងថាវាជាការដ៏អាក្រក់ដែរ។ ដោយសារគាត់មិនដឹងវា គាត់មិនអាចលន់តួបាបបាន បើទោះជាវាជាកំហុសដដែលក៏ដោយ គាត់ស្អប់ដដែលនោះដែលនៅនឹងអ្នកផ្សេងទៀត តែគាត់មិនបានស្អប់បាបដែលនៅនឹងគាត់ទេ។ ដូច្នេះ គាត់មិនធ្វើការលន់តួបាបទេ។ ប្រសិនបើអ្នកណាស្អប់កំហុសរបស់ខ្លួន នោះគេនឹងធ្វើការលន់តួប្រែចិត្ត។ វាការសេចក្តីល្ងីល្ងើដែលគាត់មិនមានចិត្តស្អប់ តែមានចិត្តស្អប់ដល់កំហុសរបស់អ្នកផ្សេងទៅវិញ។ លោកប៊ីស្សប Whately បានមានប្រសាសន៍ថា “បើទោះជាសេចក្តីកំហុសរាប់ម៉ឺននៅក្នុងអ្នកដទៃដែលអាចបំផ្លាញខ្ញុំក៏ដោយ តែវាមិនធំជាងកំហុសដ៏តូច

របស់ខ្ញុំទេដែលអាចនឹងនាំទុក្ខដល់ខ្ញុំបាន។” អ្នកដែលរស់នៅក្នុងជីវិតដែលស្អប់កំហុសរបស់ខ្លួន នោះគាត់មិនមានកន្លែងនឹងសង្កេតមើលកំហុសរបស់អ្នកដទៃឡើយ។

2) គាត់ព្យាយាមបង្ហាញទៅកាន់អ្នកដទៃ។ អ្នកដែលប្រែចិត្តមិនចង់បានការសរសើររបស់មនុស្សឡើយ។ គាត់សារភាពពីអំពើបាបដែលស្មោគគ្រោកនិងអាក្រក់របស់គាត់។ គាត់ចង់ទទួលការសរសើរពីព្រះ ជាជាងការសរសើររបស់អ្នកដទៃ ហើយគាត់គោរពដល់ភាពល្វីងជូរចត់របស់អ្នកផ្សេងទៀត។ ពីព្រោះគាត់មិនចង់ទទួលការគោរព ឬការសរសើរចេញពីមនុស្សឡើយ គាត់ទទួលស្គាល់ថាសេចក្តីអាម៉ាស់និងទុក្ខលំបាកចេញមកពីការសារភាពដូចជាពណ៌ការពារនៃជីវិត នោះពួកគេទទួលការទាំងនោះជាអំណរ។ ពីព្រោះប្រសិនបើគាត់ទទួលការគោរពនិងការសរសើររបស់មនុស្សវាជាបញ្ហាអាក្រក់ដល់គាត់នៅក្នុងស្ថានសួគ៌។ លោក Augustine បានមានប្រសាសន៍ថា “អ្នកដែលអួតពីអាកប្បកិរិយាល្អរបស់ខ្លួនប្រៀបដូចជាមេមាន់ដែលពងមក ហើយស្រែកខ្ពតអីចឹង”។ កាលណាដែលមេមាន់ខ្ពតដោយបង្ហាញពីសម្លេងខ្លួន នោះមនុស្សក៏មករកវាហើយក៏យកស៊ុតរបស់វាទៅ។ “រំពេលណាដែលមនុស្សអួតពីទង្វើល្អរបស់មនុស្ស នោះតម្លៃនៃកិច្ចការល្អនោះនឹងត្រូវសាបសូន្យទៅ។ ភាពក្រអឺតក្រទមនិងការអួតអាងបំផ្លាញទង្វើល្អ និងធ្វើឱ្យការអាក្រក់ហូរហៀរវិញ។ អ្នកដែលប្រែចិត្តពីអំពើបាបរបស់ខ្លួនមាន

បំណងទៅរកស្ថានសួគ៌ ហើយរស់នៅជីវិតដែលអាចំកំបាំងជាមួយនឹងចិត្តដែលស្កប់ស្កល់ ដែលនោះជាការប្រកបគ្នា ការកែតម្រូវ កំហុសនិងការផ្លាស់ប្តូរទៅជាសេចក្តីសប្បុរស។ គាត់មើលងាយអ្វីដែលមនុស្សទទួលស្គាល់។ គាត់រីករាយនឹងជីវិតដែលលាក់កំបាំងដោយស្ងៀមស្ងាត់។

(2) ល្បិចកិចកល្ប

“គ្រប់គ្នាពោលតែសេចក្តីភូតភរ ដល់អ្នកជិតខាងខ្លួន គេពោលដោយបបូរមាត់បញ្ចើចហើយដោយមានចិត្ត2” (ទំនុកដំកើង 12:2)។ “សូមកុំទាញទូលបង្គំទៅជាមួយនឹងមនុស្សអាក្រក់ ឬជាមួយនឹងមនុស្សដែលប្រព្រឹត្តការទុច្ចរិត ជាអ្នកដែលពោលពាក្យដោយមេត្រីនឹងអ្នកជិតខាង តែមានគំនិតកាចអាក្រក់នៅក្នុងចិត្តវិញ នោះឡើយ” (ទំនុកដំកើង 28:3)។ “គេបានលូកដៃទៅទាស់នឹងមិត្រ ដែលជាមេត្រីនឹងគេ គេបានក្បត់ចំពោះសញ្ញារបស់ខ្លួនហើយ មាត់គេរឹតលជាងខ្លាញ់ តែចិត្តគេមានពេញដោយការចំបាំងវិញ វាចាគេទន់ល្វន់ជាងប្រេង ប៉ុន្តែពាក្យទាំងនោះសុទ្ធតែជាដាវហូតស្រាប់” (ទំនុកដំកើង 55:20, 21) “អើ ទាំងមិត្រសំឡាញ់ស្និទ្ធស្នាលរបស់ទូលបង្គំ ជាអ្នកដែលទូលបង្គំបានទុកចិត្ត ហើយក៏បានបរិភោគបាយរបស់ទូលបង្គំផង នោះបានលើកកែងជើងចង់ជាន់ឈ្លីទូលបង្គំដែរ” (ទំនុកដំកើង 41:9)។ ចូរមើលនៅទំនុកដំកើង 55:12, 13, 20។ វាពិបាកណាស់ដែលការមិនកំរើកធ្វើការលន់តួបែបនោះ។ មនុស្សបែបនេះមិនស្តាប់តាមសេចក្តីពិតច្បាស់ណាស់។ មនុស្សមានល្បិចមិនទទួល

យកដំបូន្មានទេ ហើយមានអាកប្បកិរិយាដែលជ្រុលដែលអាចនឹងបាំងវា ហើយលាក់ពីកិច្ចការខុសឆ្គងរបស់គេផង។

(3) ទម្លាប់ដែលក្តៅអ៊ុនៗ

វាចង្អុលទៅកាន់ការប្រព្រឹត្តដែលជាទម្លាប់ដោយគ្មានការតាំងចិត្ត និងភាពស្ថិតស្ថេរ ពីព្រោះអ្នកខ្លះមានការតាំងចិត្តខ្ពស់ ជាបណ្តោះអាសន្នគាត់មានការសម្រេចចិត្តថ្មី។ តែដោយសារការតាំងចិត្តគាត់បានត្រឡប់ទៅកានទម្លាប់អាក្រក់ចាស់របស់គាត់ដដែល។ ដូច្នេះ ការតាំងចិត្តដែលគ្មានភាពស្ថេរភាពជាបែបដែលធ្វើឱ្យខ្ទល់ខ្ទាយ តែមិនមែនជាតាំងចិត្តដែលមានតម្លៃឡើយ។ 1ពង្សាវតារក្សត្រ 18:21 និយាយថា “រួចអេលីយ៉ាក៏ចូលទៅជិតពួកជនសួរថា តើអ្នករាល់គ្នានៅតែស្ទាក់ស្ទើរនាកណ្តាលផ្លូវទាំង2នេះ ដល់កាលណាទៀត បើព្រះយេហូវ៉ាទ្រង់ជាព្រះ នោះចូរដើរតាមទ្រង់ទៅ តែបើព្រះបាលជាព្រះវិញ នោះចូរប្រតិបត្តិតាមចុះ តែពួកបណ្តាជនមិនបានឆ្លើយ សូម្បី1ម៉ាត់ឡើយ”។ សុភាសិត 17:24 និយាយថា “ឯប្រាជ្ញា រមែងនៅចំពោះមុខមនុស្សដែលមានដំរិះ តែភ្នែកមនុស្សល្ងីល្ងើមើលទៅឯចុងផែនដីបំផុតវិញ”។ យ៉ាកុប 1:6-8 មានបន្ទូលថា “តែត្រូវឱ្យអ្នកនោះសូមដោយចិត្តជឿ ឥតសង្ស័យអ្វីសោះ ដ្បិតអ្នកណាដែលសង្ស័យ នោះប្រៀបដូចជារលកសមុទ្រដែលត្រូវផាត់ដោយខ្យល់ ទាំងរំពើកចុះឡើង កុំឱ្យមនុស្សយ៉ាងនោះនឹកស្មានថា ខ្លួននឹងបានអ្វីពីព្រះអម្ចាស់ឡើយ។ ដ្បិតអ្នកនោះជាមនុស្សមានចិត្ត2 ចេះតែសាវាក្នុងគ្រប់ទាំងផ្លូវ”។ យើងទទួលបានសេចក្តីសង្គ្រោះ

ដោយព្រះគុណ តែអ្វីដែលយើងដឹងជាសេចក្តីពិតថា អ្នកដែលទទួលព្រះគុណជាអ្នកដែលនឹងធ្វើការល្អ។

(4) ភាពក្រអឺក្រទម

ទំនុកដំកើង 17:10 មានបន្ទូលថា “គេបិទភ្ជិតជុំវិញ ដោយខ្លាញ់របស់គេ ហើយមាត់គេពោលតែពាក្យព្រហើន”។ (សូមពិនិត្យមើលនៅទំនុកដំកើង119:70)។ ទំនុកដំកើង 10:2 មានបន្ទូលថា “មនុស្សអាក្រក់ គេបៀតបៀនដល់មនុស្សក្រីក្រដោយសេចក្តីឆ្មើងឆ្មៃ សូមឱ្យគេជាប់នៅក្នុងឧបាយ ដែលគេបង្កើតនោះ”។ ដូចជាអ្នកដែលឆ្មើងឆ្មៃនេះ អួតអាងថាគំនិតនិងបំណងរបស់គេនោះល្អហើយ។ ដូច្នេះ គេមិនធ្វើការលន់តួប្រែចិត្តទេ។ បើទោះជាគេចង់ក្លាយជាស្តេចនៅក្នុងស្ថាននរកក៏ដោយ គេក៏គ្មានចិត្តនឹងធ្វើជាអ្នកបម្រើនៅស្ថានសួគ៌ទេ។ ពីព្រោះគេអួតពីបំណងទុច្ចរិតរបស់ខ្លួននៅក្នុងចិត្តគេ តើឱ្យគេធ្វើការលន់តួបាបម្តេចទៅ? ពីព្រោះមនុស្សឆ្មើងឆ្មៃធ្វើខ្លួនដូចជាស្តេច ហើយទុកខ្លួនជាមនុស្សខ្ពស់បំផុត ហើយសាងសង់វិមានខ្លួនជុំវិញ តើគាត់អាចធ្វើការលន់តួបាបម្តេចបាន? ស្តេចហេរ៉ូឌអាគ្រីប៉ា បានស្តាប់ទៅកាន់ការអធិប្បាយរបស់ប៉ូល ហើយបាននិយាយថា “ស្តេចអ័គ្រីប៉ាក៏មានព្រះបន្ទូលទៅប៉ុលថា បន្តិចទៀត ឯងនឹងនាំឱ្យយើងត្រឡប់ទៅជាអ្នកគ្រីស្ទានដែរ” (កិច្ចការ 26:28)។ ពីព្រោះមនុស្សឆ្មើងឆ្មៃបែបហ្នឹងមានហ៊ុំព័ទ្ធដោយអត្តចរិតដែលតម្កើងខ្លួនឡើយ ព្រះបន្ទូលនៃសេចក្តីពិតមិនចូលទៅដល់គាត់ទេ។ ទំនុកដំកើង 73:6 “ហេតុនោះបានជាសេចក្តីអំនួតរបស់គេប្រៀបដូចជាខ្សែច្រវាក់ពាក់នៅក ហើយគេប្រដាប់ខ្លួន ដោយសេចក្តីច្រឡោត”។ ការនោះពិតណាស់។ មនុស្សដែលក្រអឺតក្រទមអួតអាងដោយអត្តចរិតដែលឆ្មើងឆ្មៃដូចជាការលំអរ។ ពួកគេឆ្មើងឆ្មៃដោយអំណួតរបស់ខ្លួន។ ដូច្នេះមនុស្សឆ្មើងឆ្មៃមិនចូលចិត្ត

ស្តាប់ដំបូន្មាននិងការកែតម្រូវទេ។ សុភាសិត 15:12 មានបន្ទូលថា “មនុស្សដែលចំអកមើលងាយ គេមិនចូលចិត្តឱ្យអ្នកណាបន្ទោសខ្លួនឡើយ ក៏មិនដែលរកអ្នកប្រាជ្ញដែរ។” តែព្រលឹងដែលកាត់ការផ្តល់ដំបូន្មានចេញនឹងត្រូវវិនាស។ សុភាសិត 15:32 មានបន្ទូលថា “អ្នកណាដែលមិនព្រមទទួលសេចក្តីប្រៀនប្រដៅនោះឈ្មោះថាស្អប់ខ្ពើមដល់ព្រលឹងខ្លួន តែអ្នកណាដែលស្តាប់តាមសេចក្តីបន្ទោស នោះបានយោបល់វិញ”។

(5) ការសារភាពទូទៅនៃការប្រែចិត្ត

នៃការសារភាពពីអំពើបាប សៀវភៅតូចនៃ Westminster Confession បាននិយាយដូចខាងក្រោម។ (គោលលទ្ធិនេះគឺជាបញ្ជីនៃសេចក្តីជំនឿដែលអ្នកវិទូដែលសិក្សាពីព្រះ 151 និងអ្នកជឿលើព្រះត្រូវបានប្រមូលផ្តុំគ្នាអស់រយៈពេល 5 ឆ្នាំកន្លះ ហើយបានតាំងនៅ។ “ការដែលមនុស្សគ្រប់គ្នាហាក់ដូចជាមានទំនោរទៅរកការសារភាពអំពើបាបដោយផ្ទាល់ខ្លួនទៅចំពោះព្រះ ការអធិស្ឋានសូមការអត់ទោសនៅលើនោះ និងការលះបង់ការលើកលែងទោស។ ក្នុងចំណោមពួកគេ គេនឹងឃើញសេចក្តីមេត្តាករុណា។ ដូច្នេះ អ្នកណាដែលបង្ខូចកេរ្តិ៍ឈ្មោះរបស់បងប្អូនខ្លួន ឬក្រុមជំនុំនៃព្រះគ្រីស្ទ គួរតែស្ម័គ្រចិត្តដោយការសារភាពជាឯកជន ឬជាសាធារណៈ និងការសោកសៅចំពោះអំពើបាបរបស់ខ្លួន ដើម្បីប្រកាសពីការប្រែចិត្តដល់អស់អ្នកដែលអាក់អន់ចិត្ត ដែលនឹងត្រូវផ្សះផ្សាជាមួយគាត់វិញ។ ហើយដោយសេចក្តីស្រឡាញ់ក្នុងការទទួលគាត់។ “– ការបកប្រែជំពូកទី 15 មាត្រា 6។ តាមលទ្ធិនេះ ការសារភាពជាសាធារណៈនូវបាបជាបញ្ហាក្នុងការតាំងឡើងនូវគុណធម៌ជាជាងបញ្ហានៃការលន់តួបាបផ្ទាល់ គឺប្រភេទនៃការសារភាពជាសាធារណៈគឺសមាមាត្រទៅនឹងប្រភេទនៃបាបកម្ម។ ប្រសិនបើ

មនុស្សខ្លះរងគ្រោះថ្នាក់ដោយអំពើបាប អ្នកវាយប្រហារត្រូវសារភាពចំពោះអ្នកនោះ ប៉ុន្តែប្រសិនបើគាត់ធ្វើបាបទៅកាន់ក្រុម អ្នកវាយប្រហារនឹងសារភាពនៅចំពោះមុខក្រុមនោះ។ យើងអាចយោងទៅលើគោលលទ្ធិ Oberg ម្តងទៀត។ គោលលទ្ធិនេះគឺជាការសារភាពដែល Melanchthon បានសរសេរដោយការអនុញ្ញាតពី Luther លោក Charles V បានអនុញ្ញាតការនោះ ដើម្បីរួបរួមជាមួយគ្នារវាងក្រុមជំនុំប្រូតេស្តង់និងក្រុមជំនុំរ៉ូម៉ាំង។ ប៉ុន្តែពួករ៉ូម៉ាំងមិនបានទទួលពាក្យនេះទេ។ គោលលទ្ធិនេះបាននិយាយថា “ក្នុងការសារភាពអំពើបាប ក្រុមជំនុំរបស់យើងមិនបង្រៀនថា ជនល្មើសរាប់រាល់អំពើបាបរបស់គាត់ ហើយសារភាពនៅចំពោះមុខមនុស្ស (មនុស្ស ឬក្រុម) ទេ ព្រោះប្រសិនបើយើងឃើញថាការរាប់អំពើបាបនៅចំពោះមុខមនុស្ស ហើយបង្ហាញបាបទាំងនោះ គឺជាខ្លឹមសារនៃការប្រែចិត្ត ការប្រែចិត្តបែបនេះគឺមិនអាចទៅរួចទេ។ ក្នុងភាពជាមនុស្សតើគេអាចដឹងគ្រប់អំពើបាបខ្លួនច្បាស់និងចាំទាំងអស់បានទេ? (ទំនុកដំកើង 19:12 កិច្ចការ 17:9) កាលពីដើម ពួកបិតានៃក្រុមជំនុំក៏មិនបានរាប់ភាពចាំបាច់នៃការរាប់នូវការប្រែចិត្តដែរ។ លោក Chrysostom មានប្រសាសន៍ថា “ខ្ញុំមិននិយាយថាអ្នកគួរតែសារភាពនៅចំពោះក្រុមជំនុំនៅក្នុងទីសាធារណៈនោះទេ។ តែអ្នកដូចជាពាក្យរបស់ហោរា អ្នកគួរតែធ្វើឱ្យគេស្គាល់ព្រះអម្ចាស់តាមរយៈការប្រព្រឹត្តរបស់អ្នក។ ដូច្នេះអ្នកនឹងសារភាពអំពើបាបខ្លួននៅចំពោះចៅក្រមជាព្រះដោយការអធិស្ឋានរបស់អ្នកមិនមែនចេញពីបបូរមាត់របស់អ្នកទេ តែចេញពីចិត្តរបស់អ្នកវិញ។” (មាត្រា 4) ម្តងទៀតយើងអាចសំដៅទៅកាន់គោលជំនឿទីពីររបស់ Helvetic។ គោលជំនឿទីពីររបស់ Helvetic ត្រូវបានសរសេរឡើងដោយលោក Henry Bullinger (1504-1575) ដែលជាសិស្សរបស់លោក Zwingli ហើយគោលជំនឿនោះនិយាយថា "សេចក្តីពិតដែលអ្នកធ្វើខុសសារភាពអំពើបាបខ្លួននៅចំពោះព្រះជាគោលការណ៍។

ការសារភាពនៅចំពោះព្រះត្រូវការហេតុផលតែមួយថា អ្នកធ្វើខុសត្រូវបានអត់ទោសដោយអ្នកដែលរងទុក្ខ ឬដែលគាត់ត្រូវបានទទួលដោយអ្នកនោះ" (សូមពិនិត្យមើលនៅ 13)។ ដូច្នេះ ការសារភាពអំពើបាបរបស់គាត់ត្រូវការភាពស្មោគ្រូចិត្តដើម្បីនឹងសង់គុណធម៌នៅចំពោះមនុស្ស។ ប្រសិនសូម្បីតែអ្នកធ្វើខុសបង្ហាញភស្តុតាងនៃការប្រែចិត្តហើយ នោះក្រុមជំនុំមិនអាចធ្វើអ្វីបានក្រៅពីទាមទារគេឱ្យសារភាពជាសារធារណៈ។ ក្រុមជំនុំរ៉ូម៉ាំងអះអាងថា ការសារភាពនៅចំពោះមនុស្សជាធាតុសំខាន់នៃការលន់តួបាប។ គោលលិទ្ធិសេចក្តីជំនឿ Trent បានយល់ច្រឡំថាពួកបិតាក្រុមជំនុំនិងអ្នកដែលមានតំណែងដឹកនាំជាតំណាងរបស់ព្រះគ្រីស្ទ ហើយរួចមកពួកគេប្រកាសនូវការអត់ទោសបាបបន្ទាប់ពីពួកគេបានទទួលការសារភាពអំពើបាបនៅចំពោះមនុស្ស។ នៅក្នុងទស្សនៈនៃការលន់តួបាប វាបង្ហាញថាក្រុមជំនុំរ៉ូម៉ាំងមានទស្សនៈដែលមិនតាមបទគម្ពីរ។ ពួកគេយល់ច្រឡំថាការសារភាពនៅចំពោះមនុស្សជារូបភាពនៃការលន់តួបាប។ យើងតាមគោលលិទ្ធិនៃពួកកំណែទម្រង់ គួរតែព្យាយាមសារភាពនៅតែចំពោះព្រះដោយគ្មានការស្នាក់ស្ទើរអ្វីឡើយ។ សុភាសិត 28:13 មានបន្ទូលថា “អ្នកណាដែលគ្រប់បាំងការរំលងរបស់ខ្លួន នោះនឹងមិនចំរើនឡើងទេ តែអ្នកណាដែលលន់តួហើយលះបង់អំពើនោះ នឹងប្រទះបានសេចក្តីមេត្តាករុណាវិញ។” អ្នកដែលសារភាពយ៉ាងស្មោះស្ម័គ្រនៅចំពោះព្រះ ពីព្រោះគេបានទទួលការលើកលែងទោសដោយសារសេចក្តីមេត្តារបស់ព្រះ នោះគេនឹងត្រូវបានរាប់ថាជា “មនុស្សដែលគ្មានស្នាមប្រឡាក់ឡើយ”។

ផ្នែកទីបី

ចៅក្រម និងអ្នកបើកសម្តែងនូវការជំនុំជំរះ 4:1-5:14

ផ្នែកនេះគឺជាបុព្វកថានៃពាក្យខាងក្រោមជំពូកទីប្រាំមួយ។ មុនពេលគាត់បង្ហាញពីស្ថានភាពនៃថ្ងៃចុងក្រោយនៃពិភពលោកនេះ ជាដំបូង តើអ្វីជាសិរីរុងរឿងនៃធាតុ ថាព្រះជាម្ចាស់ជានរណា ដែលទ្រង់ជាអ្នកបើកសម្តែងពីកិច្ចការរបស់ទ្រង់ នោះគឺជាព្រះគ្រីស្ទ។

ជំពូកទី 4

ការបកស្រាយ

*ស្ថានសួគ៌*នេះមិនមែនជាបែបសាសនា និងជាសភាពខាងវិញ្ញាណទេ តែជាកន្លែងដែលពេញដោយសិរីរុងរឿងនៃស្ថានសួគ៌។ នៅក្នុងបទគម្ពីរ ព្រះយេស៊ូវគ្រីស្ទត្រូវបានលើកឡើងទៅទីនោះ បន្ទាប់ពីទ្រង់បានមានព្រះជន្មរស់ឡើងវិញ (កិច្ចការ 1:9, អេភេសូរ 4:10, 2កូរិនថូស 12:1-4) មានព្រះវរបិតា (លោកុប្បត្តិ 28:17 ទំនុកដំកើង 80:14, អេសាយ 66:1 ម៉ាថាយ 5:12-16 45, 48 23:9) មានទេវតា (ម៉ាថាយ 24:36, 28:2, ម៉ាកុស 13:32 លូកា 22:43) ដូច្នេះក៏មានពួកបរិសុទ្ធដែលត្រូវបានសង្គ្រោះផងដែរ (ម៉ាថាយ 5:12, 6:20, 18:10, អេភេសូរ 3:14, 1ពេត្រុស 1:4 វិវរណៈ 19:1, 4)។ ព្រះគ្រីស្ទទ្រង់នឹងយាងមកពីទីនោះមកលើផែនដីម្តងទៀត។ (យ៉ូហាន

3:13) នៅពេលអនាគត ទ្រង់នឹងយាងមកពីទីនោះមក (ម៉ាថាយ 24:30 1ថែស្សាឡូនិច 4:16 ភីលីព 3:20, 21)។ នោះយើងនឹងមានទំនាក់ទំនងជាមួយស្ថានសួគ៌ដូចតទៅនេះ (1) នៅក្នុងពេលបច្ចុប្បន្ននេះ គ្រីស្ទានដឹងថាមានជានរបស់ព្រះវិញ្ញាណបរិសុទ្ធ។ (2) ក្នុងកាលដែលអ្នកជឿចាកចេញទៅ ព្រលឹងរបស់ពួកគេនឹងចូលទៅកាន់ទីនោះមែន។ (3) កាលដែលព្រះគ្រីស្ទយាងមកម្តងទៀត រូបកាយរបស់អ្នកជឿនឹងបានរស់ឡើងវិញ នោះព្រលឹងនិងរូបកាយនឹងចូលទៅកាន់នគរស្ថានសួគ៌។

សម្លេងទីមួយ ដែលខ្ញុំបានស្តាប់ឮនិយាយមកកាន់ខ្ញុំដូចជាសូរត្រែ យោងតាមការបកស្រាយនៃ 1:10។

ខ្ញុំបានត្រឡប់នៅដោយវិញ្ញាណ យោងតាមការបកស្រាយនៃ 1:10

បល្ល័ង្ក នេះជាសញ្ញានៃការពិតដែលព្រះទ្រង់គ្រប់គ្រងលើសកលលោក។

ព្រះអង្គដែលគង់នៅលើបល្ល័ង្ក “គង់នៅ” នេះជាសញ្ញាដែលអំណាចអស្ចារ្យរបស់ទ្រង់មិនត្រូវរង្គើឡើយ។ ទ្រង់ជាព្រះជាម្ចាស់ដែលមានគ្រប់ព្រះចេស្តា ដោយទ្រង់អាកប្បកិរិយាដែលមិនទៀងទាត់ ឬមិនច្បាស់លាស់ឡើយ។ (ព្រហ្មជនានុស)

3 ឯព្រះអង្គដែលគង់នៅនោះ មើលទៅមានភាពដូចជាត្បូងមណីជោតិ និងត្បូងទទឹម នេះគឺ ហូ ខាសេមេនូស ហូម៉ូយីអស ហូរ៉ាសេ (ὁ καθήμενος ὅμοιος ὁράσει) ទីនេះ ជាភាសាកូរ៉ែត្រូវបានបកប្រែស្ទើតែជាការបកប្រែខុស។ កាលដែលយើងបកប្រែត្រង់ៗ ការដែលនិយាយបែបនេះគឺត្រូវថា “មួយអង្គដែលបានអង្គុយបង្ហាញមកដូចជា ...”។ ពាក្យថា “បានបើកសម្តែង” ត្រូវបានបកប្រែទៅជា “រូបរាង” អ្នកអាចងាយនឹងយល់ច្រឡំការនេះ។ “បើកសម្តែង” គឺ ហូរ៉ាសេ (ὁράσει) ចង្អុលទៅកាន់ការបើក

បង្ហាញជាចក្ខុវិស័យ (វិវរណៈ 9:17, កិច្ចការ 2:17)។ ព្រះទ្រង់មិនមានរូបកាយជារបស់ដែលមើលឃើញទេ មានតែសិរីរុងរឿងខាងវិញ្ញាណប៉ុណ្ណោះដែលបើកសម្តែងដល់យ៉ូហាន។ យើងអាចឃើញសិរីរុងរឿងទ្រង់បានដោយសារការបើកសម្តែងរបស់ទ្រង់តែមួយប៉ុណ្ណោះ ប៉ុន្តែយើងមិនអាចមើលឃើញធាតុស្នូលរបស់ទ្រង់បានទេ។ ត្បូងមណីជោតិ គឺថា យ៉ាស្ពីឌី (ἰάσπιδι) ជាភាសាក្រិក 21:11 បើកសម្តែងម្តងទៀតដែលត្រូវបានបកស្រាយថាជាសញ្ញានៃពន្លឺភ្លឺដូចជាកែវគ្រីស្តាល់។ ដូច្នេះនៅទីនេះ វាប្រាកដថា សិរីល្អនៃភាពបរិសុទ្ធរបស់ព្រះត្រូវបានតាងជាសញ្ញាសម្គាល់ដោយត្បូងមណីជោតិ។ ត្បូងទទឹម វាគឺ សារឌីស (σαρδίῳ) ជាភាសាក្រិក ពណ៌ក្រហមគឺត្រូវបានគិតថាជាសញ្ញាសម្គាល់នៃការជំនុំជំរះរបស់ព្រះ។

ក៏មានឥន្ទធនូនៅព័ទ្ធជុំវិញបល្ល័ង្ក ពាក្យនេះហាក់ដូចជាដកស្រង់ចេញពី អេសេគាល 1:28។ តើ “ឥន្ទធនូ” មានន័យដូចម្តេច? វាអាចជាសញ្ញាសម្គាល់នៃភាពស្មោះត្រង់របស់ព្រះ (ទៅកាន់ការតាំងសញ្ញារបស់ទ្រង់) (លោកុប្បត្តិ 9:13)។ ការតាំងសញ្ញាដែលទ្រង់បានបង្កើតត្រូវបានពន្យល់ដូចតទៅ។ កាលដែលព្រះទ្រង់ទាក់ទងនឹងមនុស្សតាំងពីដើមមក នោះទ្រង់នៅតែបន្តធ្វើវាដដែល។ ការតាំងសញ្ញាត្រូវបានបង្កើតឡើងតាមបែបបទទ្វេជាបួន ដូចលោក បណ្ឌិត ស្គីលឌើ (Dr. K. Schilder, was is de Hemel?) ។ (1) ការតាំងសញ្ញានៃការប្រព្រឹត្ត (លោកុប្បត្តិ 2:16, 17)។ ដែលជាការតាំងសញ្ញាដែលមនុស្សស្តាប់បង្គាប់តាមបញ្ញត្តិ (ក្រឹត្យវិន័យ) តែបើកាលណាគេមិនស្តាប់បង្គាប់ នោះគឺនឹងត្រូវទទួលបណ្តាសាវិញ។ (2) ការតាំងសញ្ញានៃព្រះគុណជាការតាំងសញ្ញាដែល ដោយសារព្រះគុណ និងសេចក្តីមេត្តា នោះមនុស្សណាដែលជឿដល់ព្រះគ្រីស្ទនឹងត្រូវបានអត់ទោសពីបាបដោយគ្មានលក្ខខណ្ឌ និងត្រូវទទួលបាន

ព្រះពរ។ (3) ការតាំងសញ្ញានៃធម្មជាតិ ដែលជាការតាំងសញ្ញាដែលបាតុភូតសកល ដែលបង្កើតឡើងដោយព្រះអម្ចាស់នឹងត្រូវបានរក្សាទុកដោយច្បាប់ដែលមិនអាចផ្លាស់ប្តូរបានរបស់ទ្រង់ (4) ការតាំងសញ្ញានៃសន្តិភាព ជាសេចក្តីសញ្ញាដែលមនុស្ស និងសកលលោកនឹងត្រូវបានស្តារឡើងវិញនូវភាពបរិសុទ្ធ និងសន្តិភាពដើមដោយព្រះ និងជាមួយព្រះ។ យើងមិនដឹងថាការតាំងសញ្ញានឹងត្រូវបានចាត់ថ្នាក់ជាបួនដូចជា លោក ស្គីឌើ ទេ។ ប៉ុន្តែអ្វីដែលយើងដឹងគឺថា វាជាការពិតថា ព្រះទាក់ទងនឹងមនុស្ស នៅក្នុងការតាំងសញ្ញាដែលពេញដោយសេចក្តីមេត្តាយ៉ាងស្មោះត្រង់។ ដោយសារព្រះទាក់ទងជាមួយនឹងមនុស្ស និងសកលលោក ចំណុចសំខាន់នៃទំនាក់ទំនងនៃការតាំងសញ្ញាគឺជាភាពស្មោះត្រង់របស់ព្រះ និងសេចក្តីមេត្តាករុណា និងគុណធម៌របស់ទ្រង់។ ទ្រង់មិនផ្លាស់ប្តូរអស់កល្បជានិច្ច ការរៀបចំទុកដាក់របស់ទ្រង់ដោយមេត្តាចំពោះមនុស្ស និងរបស់ដែលទ្រង់បានបង្កើតម្តងរួច ហើយនឹងនៅរហូត។ ទ្រង់បានតាងភាពស្មោះត្រង់ និងមេត្តាករុណារបស់ទ្រង់ជាឥន្ទធនូ។ (លោកុប្បត្តិ 9:12-17)។ ដោយសារពួករ៉ាប៊ីបានគិតថាឥន្ទធនូជានិមិត្តរូបនៃសិរីល្អរបស់ព្រះ នោះគេហាមមិនឱ្យសិក្សាពីវាទេ (Chagiga 16 a) វាហួសហេតុពេក។

អ្នកចាស់ទុំ24នាក់ តើពួកគេជានរណា? ពួកគេមិនមែនជាទេវតាទេ ដូច្នេះពួកគេត្រូវបានបែងចែកខុសៗគ្នា (7:11)។ ហានៈរបស់ពួកគេផងដែរជាលក្ខណៈនៃសកម្មភាពរបស់ពួកគេ គឺដូចគ្នាទៅនឹងអ្នកដែលត្រូវបានប្រោសលោះដែរ (7:14, 5:8)។ ពួកគេត្រូវតែជាអ្នកតំណាងនៃក្រុមជំនុំហើយ។ តើយើងអាចគិតថាអ្នកតំណាងក្រុមជំនុំជាមនុស្សពិតមួយចំនួននៅក្នុងសញ្ញាថ្មី និងសញ្ញាចាស់ដែរឬទេ? ឬតើវាជានិមិត្តសាមញ្ញទេ? លោក ប្រ្គេចដានុស ឃើញពាក្យនោះថាជាអត្ថន័យនៃពាក្យ "និមិត្ត

សញ្ញា" ដោយសារកណ្ដាគម្ពីរវិវរណៈមានបែបបទជានិមិត្តសញ្ញា គាត់បានយកវាជារូបភាពតំណាងវិញ។ ( ) យោងទៅលើការបកស្រាយនៃពាក្យ “Wij hebben nu niet aan beppaalde Qud-en Nieuwetestamentische personen te denken. We zouden dun ook in groote moeilijkheid komen. Doch ook met deze 24 ouderlingen spreekt de openbaring in bleed, 1:1 zoodat we slechts de zinnbeeldgige getachte te ggrijpen hebben van vertegenwoordiging der geheele gemeente des Heeren, alle eeuwen door, van het begin der wereld, tot harr einde – Openbaring P 122). យោងតាមការបកស្រាយ នៃ “ដែលព្រះបានប្រទានមកទ្រង់” នៅ 1:1។

ប៉ុន្តែ យើងមិនសង្កត់ធ្ងន់ថាអ្នកចាស់ទុំបែបនេះមិនរស់នៅស្ថានសួគ៌ទេ។ ពួកគេជានិមិត្តរបស់រូបកាយពិតនៅស្ថានសួគ៌។ បុគ្គលដែលប្រតិបត្តិនូវកិច្ចការរបស់ចាស់ទុំនៅស្ថានសួគ៌មានជីវិតគង់នៅ។ ពួកគេគឺជាពួកបរិសុទ្ធ។ លោក ម៉ាថាយ ហេនរី បាននិយាយថា នៅទីនេះ បល្ល័ង្កដែលជាកៅអីរបស់ពួកចាស់ទុំត្រូវបានហ៊ុំព័ទ្ធជុំវិញបល្ល័ង្ករបស់ព្រះ គឺជានិមិត្តសញ្ញានៃការពិតដែលថា ពួកគេរីករាយនឹងព្រះតែមួយអង្គគត់ ហើយបន្តចូលទៅជិតទ្រង់ផង។ លោក ម៉ូហ្វាត បាននិយាយថា នៅទីនេះ អ្នកចាស់ទុំទាំង 24 នាក់គឺពឹងផ្អែកលើទេវកថានៃផ្កាយទាំង24 ជាព្រះនៅបាប៊ីឡូន។ ប៉ុន្តែនេះជាពាក្យដែលមើលងាយអំណាចរបស់បទគម្ពីរ។ លេខ 24 មិនបានចេញមកពីរឿងព្រេងរបស់បាប៊ីឡូនតែមួយនោះទេ តែវាក៏ចេញមកពីគម្ពីរសញ្ញាចាស់ ហើយយ៉ូហានប្រាកដជាបានគំនិតពីលេខ24មកពីព្រះគម្ពីរសញ្ញាចាស់។ លេខ 24 នៃលំដាប់លំដោយរបស់សង្ឃនៅក្នុងសញ្ញាចាស់ (1របាក្សត្រ 1:1-19) ដូចគ្នានឹងលេខ 24

ត្រង់នេះ។ ឬ សាវកយ៉ូហានបានយកលេខ 12 ជាលេខនៃកុលសម្ព័ន្ធ និងជាតំណាងនៃសញ្ញាចាស់ និងលេខ 12 នៃសាវកទាំង12 របស់ពួកជំនុំនៃសញ្ញាថ្មី (21:12, 14) ។

ស្លៀកពាក់ស ការនេះចង្អុលថា ពួកគេត្រូវបានជ្រះស្អាតដោយសារឈាមនៃកូនចៀម ពួកគេទទួលបានអាកប្បកិរិយានៃការរាប់ជាសុចរិត និងបានចូលរួមនៅក្នុងសិរីល្អនៃពិភពស្ថានសួគ៌។ (វិវរណៈ 7:14)។

មកុដមាស នេះជានិមិត្តរូបនៃជ័យជំនះក៏ដូចជានិមិត្តរូបនៃសិរីរុងរឿងនៃភាពជាស្តេច។ សិរីល្អនេះគឺជាកម្មសិទ្ធិរបស់ព្រះយេស៊ូវគ្រីស្ទ ពួកគេត្រូវបានចូលរួមនៅទីនោះ ដោយសារគុណសម្បត្តិរបស់ព្រះអម្ចាស់។ (2ធីម៉ូថេ 2:12)។

មានផ្លេកបន្ទោរ សៀងសំឡេង និងផ្គរលាន់ យោងតាម និក្ខមនំ 19:16-19។ “ផ្លេកបន្ទោរ និងសៀងសំឡេង” ជានិមិត្តរូបនៃព្រះចេស្តាដ៏អស្ចារ្យរបស់ព្រះ អំណាចរបស់ទ្រង់ សេចក្តីក្រោធរបស់ទ្រង់ និងការជំនុំជំរះរបស់ទ្រង់ (ទំនុកដំកើង 29:3-11) ។ ប៉ុន្តែ “សូរសៀង” ដាក់ដូចជានិមិត្តរូបនៃព្រះបន្ទូលដែលបានផ្តល់ដល់អ្នកដែលទ្រង់ស្រឡាញ់វិញ។ នៅក្នុងបាតុភូតដ៏អស្ចារ្យរបស់ទ្រង់ (ផ្គរលាន់ និងផ្លេកបន្ទោរ) ដែលបានបង្ហាញនៅលើភ្នំស៊ីណាយ ព្រះជាម្ចាស់មានបន្ទូលទៅកាន់ម៉ូសេដែលជាអ្នកទីស្រឡាញ់របស់ទ្រង់ជាសំឡេងរបស់ទ្រង់។ (និក្ខមនំ 19:19)។ ទ្រង់មានព្រះចេស្តាលើអំពើបាប ប៉ុន្តែទ្រង់មានមេត្តាចំពោះមនុស្សដែលទ្រង់បានជ្រើសរើសជានិច្ច។

មានចង្កៀង៧ឆេះនៅពីខាងមុខ នេះគឺដូចជាចង្កៀងដែលបានបង្កើតឡើងនៅក្នុងរោងឧបោសថនៅក្នុងគម្ពីរសញ្ញាចាស់។ រោងឧបោសថមានទីសក្ការៈបំផុត (បល្ល័ង្ក)។ នៅមុខទីសក្ការៈបំផុត មានចង្កៀងប្រាំពីរ។ បន្ទាប់មក ចង្កៀងទាំងប្រាំពីរនេះគឺជានិមិត្ត

សញ្ញានៃព្រះវិញ្ញាណបរិសុទ្ធ ដូចឃ្លាខាងក្រោមបង្ហាញ។ យោងទៅលើការបកស្រាយ របស់ 1:4។

*6 សមុទ្រកែវ*វាគឺ ហូស សាឡាសា យូអាលីណេ ហូម៉ូយ៉ា គ្រីស្តាឡូ (ὡς θάλασσα ὑαλίνη ὁμοία κρυστάλλῳ) នៅក្នុងភាសាក្រិក ដែលត្រូវបានបកប្រែថា “ដូចជាគ្រីស្តាល់ ដូចជាសមុទ្រកែវ” ដែលវាមានន័យថា មានអ្វីមួយដូចជាគ្រីស្តាល់ និងសមុទ្រកែវ។ ការនេះមានគុណភាពនៃភាពច្បាស់ ដែលអាចមើលឃើញធ្លុះ ការដែលមិនសម្រាក (21:11)។ នេះក៏ជាមុខងាររបស់រោងឧបោសថ (យោងលើ 7:14)។

ក៏មានតួមានជីវិត4 ពួកគេមានភ្នែកនៅក្នុងពេញរាងកាយទាំងមូលរបស់ពួកគេ គឺជានិមិត្តសញ្ញាដែលសង្កេតមើលដោយមិនឈប់ ហើយភ្ញាក់ឡើង និងទទួលយកការយល់ដឹងដោយមិនឈប់។ លោក ប្រ្គេជដានុស បាននិយាយថា ពួកវាមានអត្ថន័យជានិមិត្តរូបសាមញ្ញ គ្រាន់តែជាតំណាងរបស់ភាវៈដែលត្រូវបានបង្កើតមកប៉ុណ្ណោះ មិនមែនជាសត្វពិតទេ។ (Het zijn wedrom symbolische gestatten)។ ប៉ុន្តែ អេសាយ 6:2 និងលោកុប្បត្តិ 3:24 បង្ហាញថាវត្តមានរស់នៅដូចជា សេរ៉ាភីម និង ចេរ៉ូប៊ីន មាននៅលើស្ថានសួគ៌។ ខ្ញុំគិតថា សត្វមានជីវិតដែលយ៉ូហានបានឃើញគឺជានិមិត្តរូបនៃភាវៈខាងវិញ្ញាណមួយចំនួន ឬជាតួខាងវិញ្ញាណផ្សេងទៀត។ ដូចដែលព្រះគ្រីស្ទទ្រង់មាននិមិត្តរូបជាកូនចៀម គឺជាអង្គដែលរស់នៅក្នុងពិភពនៃស្ថានសួគ៌។ អញ្ចឹងតើការងាររបស់ពួកគេជាអ្វី? (1) ពួកគេជាអ្នកបម្រើដែលត្រូវបម្រើព្រះយ៉ាងជិតស្និទ្ធ។ (11:5, 10:2)។ (2) ពួកគេជាអ្នកសរសើរព្រះដោយមិនឈប់ឈរ (ទំនុកដំកើង 94:11)។ តើអ្នកដែលនៅជិតស្និទ្ធនឹងព្រះអាចនឹងឈប់សរសើរទ្រង់បានយ៉ាងណាទៅ? (3) កាលលោកបើកត្រាទាំងប្រាំពីរ អ្នកជិះសេះចេញមក ហើយធ្វើការចាក់បង្ហូរ

គ្រោះចង្រៃនៃចានទាំងប្រាំពីរតាមទិសដៅរបស់ពួកគេ។ (6:1, 16:17)។ បន្ទាប់មក ពួកគេគឺជាបុគ្គលខាងវិញ្ញាណដ៏វិសុទ្ធបំផុត ដែលធ្វើការនៅចំពោះព្រះភ័ក្ត្រព្រះជាម្ចាស់ផ្ទាល់ ក្នុងការបើកសម្តែងការពីសេចក្តីក្រោធរបស់ព្រះជាម្ចាស់។ ប៉ុន្តែមនុស្សមួយចំនួនមិនឃើញវិញ្ញាណទាំងបួនថាជាតួជីវិតពិតដូចនោះទេ គឺគ្រាន់តែជានិមិត្តសញ្ញាទាំងបួននៃភស្តុតាង 4 ប្រភេទរបស់ព្រះជាម្ចាស់។

ហើយអ្នកផ្សេងទៀតគិតថាសត្វមានជីវិតទាំងនេះជានិមិត្តសញ្ញាតំណាងឱ្យរបស់ដែលត្រូវបានបង្កើតមក។

លោក ម៉ូហ្វាត បាននិយាយខុសគ្នាចំពោះសត្វមានជីវិតទាំងនេះថា វាគឺជានិមិត្តសញ្ញាអាថ៌កំបាំងដែលចង្អុលបង្ហាញពីភាពពេញលេញនៃជីវិត និងបញ្ញា។ ប៉ុន្តែវាជាទស្សនៈមួយដែលមើលងាយវត្តមាននៃវិញ្ញាណទាំងបួន។ សៀវភៅរបស់ហេណុកក៏បាននិយាយផងដែរថា ទេវតាទាំងបួនដែលក្រោកឈរនៅចំពោះព្រះនៅទីនោះ មានតែទេវតាដែលទៅមកប៉ុណ្ណោះ។ ប៉ុន្តែ វិវរណៈគីប្លែក ដោយសារពួកគេឡោមព័ទ្ធបល្ល័ង្ក ហើយស្នាក់នៅទីនោះផង។

សិង្ហគឺជាការច្រៀងនៃភាពក្លាហាននិងកម្លាំង គោជាសញ្ញានៃភាពស្មោះត្រង់និងការលះបង់ មនុស្សជាសញ្ញានៃប្រាជ្ញា ឥន្ទ្រីគឺជាសញ្ញានៃជីវិតខាងវិញ្ញាណ។ នៅទីនេះ រូបភាពចំនួនបួនគឺជានិមិត្តសញ្ញានៃការពិតដែលថាជា សត្វខាងវិញ្ញាណដែលបម្រើព្រះយ៉ាងជិតស្និទ្ធមានអំណាចបែបនេះ។ នៅក្នុងពិភពលោក អ្នកបម្រើដែលបម្រើព្រះគួរតែមានអំណាចបែបនេះ។

8 មានស្លាប់ប្រាំមួយ យោងលើ អេសាយ 6:2

ជាសិរីរុងរឿង និងកិត្តិយស។ នេះចង្អុលបង្ហាញពីភាពឆ្លាតវៃនៃគុណលក្ខណៈនៃព្រះដ៏ខ្ពង់ខ្ពស់បំផុត។ មនុស្សគ្មានជម្រើសអ្វីក្រៅពីបញ្ចេញមតិដូច្នេះទេ ព្រោះការបញ្ចេញមតិរបស់មនុស្សគឺខ្លី។ ពាក្យ “អរគុណ” កើតចេញពីកិច្ចការដែលព្រះបានធ្វើ នោះគឺជាកិច្ចការដ៏អស្ចារ្យនៃការបង្កបង្កើតរបស់ទ្រង់។ អត្ថបទនេះបង្ហាញថាសត្វមានជីវិតនិងអ្នកចាស់ទុំសរសើរការបង្កបង្កើតរបស់ព្រះជាមួយគ្នា។ (សូមមើល ខ 11)។

ពួកគេបានបោះមកុដរបស់ពួកគេនៅមុខបល្ល័ង្ក ដែលមានន័យថាជាកិត្តិយសនៃមកុដមាស ដែលពួកគេបានទទួល គឺសាកសមតែទៅចំពោះព្រះទេ តែពួកគេមិនអាចនឹងទទួលបានទេ។

11 សិរីល្អ កិត្តិនាម យោងតាមការបកស្រាយខ 9

អំណាច វាគឺជាអំណាចនៃការបង្កបង្កើតរបស់ព្រះ ហើយវាត្រូវបានបញ្ជាក់ដោយរបស់ដែលត្រូវបានបង្កើតមកជាសកលលោក។ រចនាសម្ព័ន្ធនៃប្រាជ្ញានៃរបស់ដែលត្រូវបានបង្កើតមកមិនមែនជាលក្ខណៈនៃធាតុធម្មជាតិផ្ទាល់របស់ពួកគេទេ ហើយជាការបង្ហាញនៃអំណាចរបស់ព្រះ។

ដ្បិតទ្រង់បានបង្កើតរបស់សព្វសារពើមក អត្ថបទភាសាក្រិកចាប់ផ្តើមជាមួយពាក្យថា ហូធី (ὅτι) ហើយបង្ហាញពីហេតុផលនៃពាក្យខាងលើ។

ហើយគឺដោយបំណងព្រះហឫទ័យទ្រង់ហើយ ដែលរបស់ទាំងនោះបានកើតមក។ នៅទីនេះពាក្យ "តាមបំណងព្រះហឫទ័យទ្រង់" គឺ ឌីអា ថូ ដេលេម៉ា ស៊ូ (διὰ τὸ θέλημά σου) ដែលវាមានន័យថា វាមានជីវិតសម្រាប់ (ឬសម្រាប់) បំណងព្រះហឫទ័យទ្រង់។ លោក ហ្គ្រេជដានុស បាននិយាយថា “នេះនិយាយថា វិធីសាស្ត្រក្នុង

ការបង្កើតរបស់ទាំងអស់ ក៏ដូចជាប្រភពដើមនៃវត្តមាននៃរបស់ទាំងអស់។ អាស្រ័យហេតុនោះ ក្នុងហេតុនៃរបស់ដែលត្រូវបានបង្កើតមកទាំងឡាយ ក្នុងការទ្រទ្រង់ និងក្នុងសភាពនោះ គឺមិនអាស្រ័យលើអំណាចគ្រប់គ្រងនៃភាពជាអម្ចាស់ទេ គឺវាត្រូវបានរៀបចំតាំងនៅដោយទ្រង់ ហើយត្រូវបានសម្រាកក្នុងទ្រង់ផង។“(Hiemede wordt die Wilniet maar als middleoorzaak, of instrument, voor het ontstaan aller dingen aangegeven, maar al shun bestaansground, zoodat zij in hun ontstaan, en bestaan, en voortbestaan, en wijze van bestaan, geheel, afhankrijk zijn van dien will, en door hem bepaald zijn, als op hem rusten – Openbaring. P 130)។ ពាក្យថា “កើតមក” មានន័យថា គ្រប់របស់ទាំងអស់មុនការបង្កបង្កើតបានមានវត្តមានដោយគម្រោងការទុកជាមុនរបស់ព្រះរួចហើយ។

ចំណុចសំខាន់

1. “ឥន្ធនូ” គឺជាបាតុភូតមួយដែលនាំមកដោយប្រតិបត្តិការនៃព្រះអាទិត្យចាំងពន្លឺដែលឆ្លុះបញ្ចាំងដោយការស្រោស្រពនៅពេលដែលស្នាដៃរបស់ខ្យល់និងភ្លៀងត្រូវបានដំណើរការ។ អ្នកប្រាជ្ញម្នាក់បានបកស្រាយថា នៅពេលយើងឃើញភ្លៀងធ្លាក់មក នោះវាជានិមិត្តរូបនៃសេចក្តីក្រោធរបស់ព្រះ ឥន្ធនូគឺជាការបញ្ចប់សេចក្តីក្រោធរបស់ព្រះ ជាបាតុភូតដែលសេចក្តីស្រឡាញ់របស់ព្រះត្រូវបានចាប់ផ្តើម។ (លោកុប្បត្តិ 9:13-16, 2ពេត្រុស 3:7)។ ការជំនុំជំរះរបស់ព្រះគឺបរិសុទ្ធដូចជាត្បូងមណីជោតិដែលមានថាមពលដ៏អាក្រក់ដូចជាការជក់បារីដូចជាត្បូងទទឹម។ ប៉ុន្តែសកម្មភាពនៃការសង្គ្រោះរបស់ព្រះគឺមានពេញដោយមេត្តា និងភាពស្មោះត្រង់ដូចជាឥន្ធនូ។ ពួក

អ្នកជឿមានការកោតខ្លាចព្រះអង្គនេះ ប៉ុន្តែពួកគេរីករាយនឹងទ្រង់វិញ។ ព្រះដែលមនុស្សមិនខ្លាច គឺជារូបព្រះ ព្រោះគេចាត់ទុកមនុស្សដូចជាអ្នកបម្រើ។ ឯព្រះដែលរីករាយនឹងមនុស្សវិញ តែជាព្រះដែលមិនវិនិច្ឆ័យមនុស្សនោះទេ គឺជាព្រះសិប្បនិមិត្តដែលត្រឹមតែជាបក្សពួករបស់មនុស្ស។

2. ការសរសើរនៃតួជីវិតទាំងបួនគឺទៅកាន់លក្ខណៈសម្បត្តិរបស់ព្រះ ហើយការសរសើរតម្កើងរបស់ពួកចាស់ទុំគឺទៅកាន់ការបង្កបង្កើតនៃរបស់ទាំងអស់របស់ព្រះ (ខ 11)។ ការសរសើរទាំងពីរនេះគឺនៅក្នុងលំដាប់លំដោយ។ លើសពីនោះទៀត វត្តមានរបស់ព្រះគឺជាការសំខាន់ណាស់ ហើយបន្ទាប់នោះគឺជាការបង្កបង្កើតនៃរបស់ទាំងអស់ (ខ 8)។

3. ជំពូក 4 នៅក្នុងកណ្ឌគម្ពីរនេះបង្ហាញពីការសំខាន់ៗនៃពិភពនៃស្ថានសួគ៌។ យើងជាយើងមានចំណេះដឹងប្រាកដពីពិភពនៃស្ថានសួគ៌ នោះយើងនឹងផ្តោតលើពិភពនៃស្ថានសួគ៌នៅលើផែនដីនេះ។ អ្នកណាដែលមិនមានការផ្តោតទៅលើពិភពនៃស្ថានសួគ៌ នោះចិត្តរបស់គេមិនអាចគេចផុតពីជីវិតជាទាសកនៅលើផែនដីបានឡើយ។
4. ការពិពណ៌នាអំពីការបើកសម្តែងពីពិភពនៃស្ថានសួគ៌គឺបែបប្រៀបធៀបដោយសាមញ្ញ។ ការពិពណ៌នាដ៏សាមញ្ញបែបនេះ គឺជាលក្ខណៈរបស់បទគម្ពីរ។ ព្រះគម្ពីរមិនបានចែងអំពីខ្លឹមសារដ៏ស្មុគស្មាញនៃពិភពរបស់ស្ថានសួគ៌ទេ ពីព្រោះដូចដែលយើងនិយាយវាដោយរញ៉ៃរញ៉ៃ នោះយើងមិនអាចនិយាយពីកិច្ចការនៃពិភពស្ថានសួគ៌បែបជាគោលគំនិតនៃផែនដីបានទេ។ បន្ទាប់មកលក្ខណៈនៃ

ស្ថានសួគ៌អាចខូច។ ដូច្នេះ ចរិតលក្ខណៈសាមញ្ញនៃការពិពណ៌នាអំពីពិភពលោកនៃស្ថានសួគ៌ចេញមកពីព្រះវិញ្ញាណបរិសុទ្ធដែលទ្រង់គួរឱ្យទុកចិត្ត។

ការអធិប្បាយ

ការអធិប្បាយទី 12 ស្ថានសួគ៌ (វិវរណៈ 4:1-11)

1. វត្តមាននៃស្ថានសួគ៌

(1) ការវែកញែកដែលសមហេតុផល

បុគ្គលមិនកាន់សាសនា ក៏ដឹងថា មនុស្សសុចរិតនឹងទៅកាន់ទីល្អក្រោយគេស្លាប់។ ប្រាកដណាស់ មានការគ្រប់គ្រងនៃបញ្ហាទំនុកចិត្តរបស់គាត់។ ប៉ុន្តែចំពោះរឿងពិតដ៏ល្អបំផុត គឺថាមានអ្នកជឿវាខ្សោយណាស់។ ដូច្នេះបញ្ហានៃភាពជឿជាក់ខ្លាំង និងខ្សោយមិនមែនជាបញ្ហាក្នុងការបង្កើតភាពប្រាកដប្រជានៃច្បាស់លាស់នោះទេ។ មានតែយើងទេដែលមិននិយាយពីការស្រមើស្រម៉ៃ ព្រោះអ្នកនោះមានការគិតជាសកលអំពីទំនុកចិត្តចំពោះអនាគត។ ក្នុងចំណោមមនុស្សលោកមានមនុស្សតែម្នាក់ឬពីនាក់ប៉ុណ្ណោះដែលមានគំនិតបែបនេះ យើងមិនអាចជឿលើការគិតបែបនោះទេ។ ប៉ុន្តែមនុស្សជាតិទាំងអស់មានគំនិតអំពីពិភពលោកនាពេលអនាគតដោយផ្ទាល់ ឬដោយប្រយោល យើងអាចជឿលើចរិតលក្ខណៈនៃសេចក្តីពិតរបស់វាបាន។

(2) ការវែកញែកចេញពីបទគម្ពីរ

ព្រះគម្ពីរមិនមែនជាគំនិតរបស់មនុស្សទេ ហើយវាជាព្រះបន្ទូលរបស់ព្រះ។ ក្នុង
ចំណោមការបង្រៀនពីទំនាយគួរតែសម្រេចពិតប្រាកដ គុណធម៌នឹងបានថ្លៃថ្នូពេញ
លេញ ព្រះបន្ទូលដែលធ្វើឱ្យយើងស្គាល់ព្រះថាទ្រង់ពិតប្រាកដមែន។ ដោយគ្មានបុរេ
វិនិច្ឆ័យ អ្នកដែលមិនអាចជឿថាព្រះគម្ពីរជាសេចក្តីពិតទេឬ? បើទោះជាវិទ្យាសាស្ត្រ
បច្ចុប្បន្នមានថ្ងៃដែលមិនមានទំនុកចិត្ត នោះបទគម្ពីរត្រូវបានបង្កើតឡើងដោយសេចក្តី
ពិតដែលនៅអស់កល្បវិញ។ ចិត្តដែលខ្លាចបទគម្ពីរជាចិត្តខុសឆ្គង។ (កិច្ចការ 17:9)
សេចក្តីពិតដែលងងឹតនឹងត្រូវបានបង្ហាញមកនៅថ្ងៃណាមួយ តែបទគម្ពីរជាសេចក្តីពិត
ដែលនៅអស់កល្បវិញ។ បើទោះជាពិភពលោកទាំងមូលបដិសេធបទគម្ពីរ ចុងក្រោយ
បទគម្ពីរនឹងបើកបង្ហាញការដែលត្រឹមត្រូវ ហើយខ្ញុំជឿលើបទគម្ពីរ។ យើងមិនអាចធ្វើអ្វី
បានឡើយ តែបទគម្ពីរនេះនិយាយច្រើនពីស្ថានសួគ៌។ ក្នុងចំណោមសេចក្តីពិតថាគម្ពីរ
សញ្ញាថ្មីក៏ដូចជាសញ្ញាចាស់ក៏និយាយច្រើនដូចគ្នា ទំនុកដំកើង 17:14, 15 មាន
បន្ទូលថា “ ឱរួចពីមនុស្សដោយព្រះហស្តទ្រង់ ឱព្រះយេហូវ៉ាអើយ គឺឱរួចពីមនុស្ស
នៅលោកីយ៍នេះ ដែលមានចំណែក របស់គេនៅតែក្នុងជីវិតនេះប៉ុណ្ណោះ ហើយដែល
ពោះគេបានឆ្អែត ដោយសារទ្រព្យរបស់ទ្រង់ គេបានស្កប់ចិត្តដោយមានកូនច្រើន
ហើយក៏ចែកសំណល់នៃសម្បត្តិគេដល់កូនង៉ែតរបស់ខ្លួន។ ឯទូលបង្គំវិញ ទូលបង្គំនឹង
រំពឹងមើលព្រះភក្ត្រទ្រង់ ដោយសេចក្តីសុចរិត កាលណាទូលបង្គំភ្ញាក់ឡើង នោះនឹង
បានស្កប់ចិត្តដោយឃើញរូបអង្គទ្រង់។” ព្រះបន្ទូលមានចំណាប់អារម្មណ៍ដល់យើង។
មិនត្រឹមតែនៅក្នុងលោកុប្បត្តិ 5:24 ការលើកឡើងរបស់អេណុកចង្អុលទៅកាន់វត្តមាន
នៃស្ថានសួគ៌។

2. លក្ខណៈនៃទីកន្លែងនៃស្ថានសួគ៌

ក្នុងចំណោមពួកយើង ទោះបីជាគេនិយាយពីស្ថានសួគ៌ ប៉ុន្តែមានមនុស្សជាច្រើនមិនស្គាល់វាច្បាស់ទេ។ ដ្បិតស្ថានសួគ៌ជាក្តីសង្ឃឹមតែមួយគត់របស់យើងដែលយើងគួរតែដឹងច្បាស់។ យើងគិតពីលក្ខណៈនៃស្ថានសួគ៌។ មានមនុស្សអះអាងថា ស្ថានសួគ៌មិនមែនជាកន្លែងមួយនោះទេ គឺមានតែស្ថានភាពនៃព្រលឹងប៉ុណ្ណោះ។ ប៉ុន្តែនៅពេលយើងសង្កេតមើលបទគម្ពីរ យើងឃើញថាវាជាកន្លែងនៃជីវិតដែលមានគោលដៅយ៉ាងច្បាស់។ ព្រះយេស៊ូវមានបន្ទូលទៅកាន់អ្នកទោសថា “ខ្ញុំប្រាប់អ្នកជាប្រាកដ ថ្ងៃនេះ អ្នកនឹងនៅជាមួយខ្ញុំក្នុងឋានសួគ៌” ឋានសួគ៌មិនមែនជាស្ថានភាពនៃព្រលឹងទេ តែជាកន្លែងមួយ។ អ្នកទោសដែលបានប្រែចិត្តគឺនៅជាមួយព្រះយេស៊ូវ មិនមែនមានន័យថាគាត់បានមកដល់ស្ថានភាពនៃសុភមង្គលនៅក្នុងព្រលឹងផ្ទាល់ខ្លួននោះទេ ប៉ុន្តែជាកន្លែងដែលអាចនឹងរស់នៅជាមួយគ្នា។ យ៉ូហាន 14:1-3 “កុំឱ្យចិត្តអ្នករាល់គ្នាថប់បារម្ភឡើយ អ្នករាល់គ្នាជឿដល់ព្រះហើយ ចូរជឿដល់ខ្ញុំដែរ។ នៅក្នុងដំណាក់នៃព្រះវរបិតាខ្ញុំ មានទីលំនៅជាច្រើន ពុំនោះ ខ្ញុំបានប្រាប់អ្នករាល់គ្នាហើយ ខ្ញុំទៅរៀបកន្លែងឱ្យអ្នករាល់គ្នា។ បើខ្ញុំទៅរៀបកន្លែងឱ្យអ្នករាល់គ្នា នោះខ្ញុំនឹងត្រឡប់មកវិញ នឹងទទួលអ្នករាល់គ្នាទៅឯខ្ញុំ ប្រយោជន៍ឱ្យអ្នករាល់គ្នាបាននៅកន្លែងដែលខ្ញុំនៅនោះដែរ”។ វាមិនមែនជាប្រស្នាទេ តែទ្រង់មានបន្ទូលដោយពាក្យច្បាស់លាស់ពិតមែន។ ពីព្រោះពាក្យដូចតទៅនេះ (ជំពូក 14) មិនដែលបង្ហាញពីប្រស្នាទេ។ នៅទីនេះពាក្យថា “ទៅ” ចង្អុលទៅកាន់ទិសដៅនៃកន្លែងស្ថានសួគ៌យ៉ាងច្បាស់។ (ចូរមើលទៅកាន់អេភេសូ 4:8, 9) មិនត្រឹមប៉ុណ្ណឹងទេ ពាក្យរបស់អ្នកមាននិងឡាសានៅក្នុងលូកា 16:19-30 ក៏ចង្អុលទៅកន្លែងស្ថានសួគ៌។ កាលដែលយើងឃើញពីការកត់ត្រាដែលប៉ូលបានទៅកាន់ស្ថានសួគ៌ទីបី (2កូរិនថូស 12:1-4) ជាន់ដែលគាត់បានទៅត្រូវតែជាកន្លែងមួយច្បាស់ណាស់។ តែវាមិនមែនជាសភាពខាងព្រលឹងនោះទេ។

3. ទិសនៃស្ថានសួគ៌មិនអាចនិយាយបានទេ

ក្នុងចំណោមមនុស្សនោះ មានមនុស្សជាច្រើនចង់ឃើញស្ថានសួគ៌។ ប៉ុន្តែស្ថានសួគ៌ជាកន្លែងដែលមនុស្សមិនអាចមើលឃើញក្នុងលោកនេះទេ។ ទោះបីជាស្ថានសួគ៌ត្រូវបានបង្កើតឡើងដោយព្រះក៏ដោយ ប៉ុន្តែនៅក្នុងពិភពលោកបច្ចុប្បន្ននេះ យើងមើលមិនឃើញទេ។ ក្នុងចំណោមរបស់ដែលបានបង្កើតមកទាំងនោះ យើងមិនអាចឃើញវាច្រើនទេ។ ចិត្ត និងព្រលឹងរបស់យើងជាប្រភេទរបស់វាដែរ ហើយទេវតា និងអារក្សក៏ជារបស់ខាងស្ថានសួគ៌ដែរ។ លោក K. Schilder បាននិយាយថា "យើងមិនដឹងទិសដៅនៃស្ថានសួគ៌ទេ"។ បន្ទាប់មកយើងមានបេះដូងងងឹតតូចចង្អៀតដែលទទួលស្គាល់តែអ្វីដែលអាចមើលឃើញ។ យើងគួរតែដឹងថាពិភពលោកដែលមើលមិនឃើញគឺធំជាង និងពិតជាងពិភពលោកដែលអាចមើលឃើញដែលជាពិភពនៃសម្ភារៈ។ យើងវិនិច្ឆ័យដោយល្ងង់ខ្លៅថា ភាពជា ឬមិនមែន និងតម្លៃនៃវត្តមាន។ ប៉ុន្តែបទគម្ពីរបានចែងថា ពិភពលោកដែលមើលមិនឃើញដោយមនុស្សមានបាប គឺជាស្តង់ដារ (ហេព្រើរ 11:3)។ បទគម្ពីរមិនបាននិយាយអំពីទិសដៅ និងធាតុនៃស្ថានសួគ៌យ៉ាងលម្អិតទេ។ យើងឮថាអ្នកជឿមួយចំនួនបានស្លាប់ ហើយបានទៅឋានសួគ៌ របាយការណ៍បានរួមបញ្ចូលមាតិកាលម្អិត និងទិដ្ឋភាពនៃពិភពលោកនាពេលខាងមុខនៅក្នុង Apocrypha (ឧទាហរណ៍នៅក្នុងសៀវភៅ ការបើកសម្តែងរបស់ពេត្រុស) ត្រូវបានបង្ហាញយ៉ាងលម្អិត។ ប៉ុន្តែយើងគួរដឹងថាខ្លឹមសារលម្អិតជាចំណុចខុស។ យើងគួរតែដឹងថាពិភពលោកខាងមុខពិបាកយល់ដល់យើងណាស់។ ក្នុងការកត់ត្រាពីស្ថានសួគ៌ និងពិភពលោកខាងមុខក្នុងបទគម្ពីរ វាបានចៀសវាងពាក្យលម្អិតជាជាងនិយាយវា

សាមញ្ញ ឬរចនាបទបែបប្រៀបធៀប។ ដោយសារតែពាក្យចំៗ និងលម្អិតរបស់វា បានធ្វើឱ្យវាបង្ហាញពីពណ៌នៃពិភពលោកនេះទៅវិញ។

4. តើព្រលឹងអាចបែងចែកគ្នានៅស្ថានសួគ៌ទេ?

ក្នុងការនិយាយពីបញ្ហានេះ វាអាចត្រូវបានដោះស្រាយដោយការបកស្រាយនៅ 1កូរិនថូស 13:8-13។ (1) "ចំពោះចំណេះដឹង វានឹងរលត់ទៅ។" (ចុងបញ្ចប់នៃខ 8) វាមិនមានន័យថាស្ថានសួគ៌មិនមានមុខងារគិតនោះទេ ប៉ុន្តែវាមានន័យថា វិធីសាស្ត្រប្រយោលនឹងត្រូវលុបចោល។ (2) "ដ្បិតឥឡូវនេះ យើងមើលឃើញបែបស្រអាប់ ដូចជាដោយសារកញ្ចក់ តែនៅវេលានោះ នឹងឃើញមុខទល់នឹងមុខ ឥឡូវនេះ ខ្ញុំស្គាល់មិនទាន់អស់ តែនៅវេលានោះ ខ្ញុំនឹងស្គាល់វិញ ដូចជាព្រះទ្រង់ស្គាល់ខ្ញុំដែរ" (ខ12)។ តើពាក្យនេះមានន័យត្រឹមតែបញ្ជាក់ពីការស្គាល់ព្រះមែនទេ? ខ្ញុំមិនគិតអញ្ចឹងទេ។ កូរិនថូសទី1 ជំពូកទី13 ក្នុងការជជែកវែកញែកអំពីសេចក្តីស្រឡាញ់ វាបាននិយាយថាសេចក្តីស្រឡាញ់ដ៏ឃ្លាតនៃសេចក្តីស្រឡាញ់ចំពោះមនុស្សនោះ។ ដើម្បីនឹងស្រឡាញ់ដល់មនុស្សត្រូវបានស្នើឱ្យស្គាល់មនុស្សនោះជាមុនសិន។ ដូច្នេះបញ្ហានេះទាក់ទងនឹងការស្គាល់មនុស្សនោះ។ នៅស្ថានសួគ៌ការស្គាល់មនុស្សចំពោះគ្នាទៅវិញទៅមកគឺពេញលេញហើយ។ បន្ទាប់មកការដឹងទាំងស្រុងក្លាយជាបុព្វហេតុនៃសេចក្តីស្រឡាញ់ពេញលេញ។ ព្រោះថាផ្នែកខាងក្នុងរបស់មនុស្សមិនមានអាក្រក់ទេ ពួកគេជាមនុស្សល្អ។ នៅលើផែនដីនេះមិនស្គាល់មនុស្សចំពោះគ្នាគឺជាការល្អ។ ដោយសារតែពួកគេស្គាល់គ្នា ពួកគេជ្រាបចូលគ្រប់រូបភាពដែលចង់បាននៅក្នុងពួកគេ។ ប៉ុន្តែពេលយើងចូលទៅក្នុងស្ថានសួគ៌វិញ ត្បិតមនុស្សមានចិត្តល្អក្នុងខ្លួន ព្រោះឃើញផ្នែកខាងក្នុង វា

ច្បាស់ជាមានសេចក្តីស្រឡាញ់យ៉ាងបរិបូណ៌។ ដូច្នេះ នៅស្ថានសួគ៌ ព្រលឹងឃើញសេចក្តីល្អ ស្គាល់ព្រះចេស្តានៃព្រះ ហើយស្រឡាញ់ព្រះ ហើយសរសើរតម្កើងដល់ទ្រង់។

(3) តើយើងអាចជួបមិត្តចាស់នៅផែនដីនៅឯស្ថានសួគ៌ដែរទេ? បញ្ហានេះក៏ត្រូវបានបង្រៀននៅ 1កូរិនថូស 13:8-13។ ពីព្រោះ “ចំណេះដឹងនឹងរលាយបាត់ទៅ” ពាក្យនេះមិនមានន័យថាលុបបំបាត់ខ្លឹមសារនៃចំណេះដឹងទេ តែជាវិធីសាស្ត្រនៃចំណេះដឹង ដែលជាវិទ្យាសាស្ត្រដែលនឹងត្រូវវិនាស កម្មវត្ថុនៃចំណេះដឹង ដែលយើងនឹងដឹងដោយផ្នែកនៅក្នុងលោកិយ វានឹងនៅនៅស្ថានសួគ៌ផង។ ដូច្នេះ មានការជួបជុំមិត្តចាស់នឹងត្រូវបានបំផ្លាញ ហើយនិងមានសភាពដែលនូវយូរអង្វែង។ នៅទីនោះ យើងអាចស្គាល់យ៉ាងច្បាស់វិញ។ លោក Schilder មានប្រសាសន៍ថា “នៅស្ថានសួគ៌ ខ្លឹមសាររបស់វានឹងមិនផ្លាស់ប្តូរឡើយ តែវិធីសាស្ត្រនៃចំណេះដឹងនឹងត្រូវបានផ្លាស់ប្តូរ។ 1កូរិនថូស 13:10 ចង្អុលទៅកាន់វា”។

(4) តើការប្រកបគ្នារវាងមនុស្សនិងមនុស្សវិញមានទេ? ទីកន្លែងដែលសេចក្តីស្រឡាញ់ពេញបរិបូរណ៌មានពេញដោយសេចក្តីអំណរ និងពិតណាស់ក៏មានការប្រកបគ្នាផង។ មិនមានគ្រួសារនិងមង្គលការទេដូចដែលព្រះយេស៊ូវបានប្រាប់មក (ម៉ាថាយ 22:30)។ ពេលដែលព្រះយេស៊ូវមានបន្ទូលជាពេលនៃការរស់ឡើងវិញពិតណាស់ ស្ថានសួគ៌ក៏ដូចគ្នា។ អ្នកដែលចូលទៅកាន់ស្ថានសួគ៌ជាកម្មសិទ្ធិរបស់ព្រះយ៉ាងពេញលេញ ហើយគេមានតែរីករាយនឹងទ្រង់តែមួយអង្គប៉ុណ្ណោះ។ តែលក្ខណៈបុគ្គលម្នាក់ៗនឹងនៅតែមាន ហើយក៏អាចទំនាក់ទំនងនឹងគ្នាបានផងដែរ។

ការអធិប្បាយទី 13 លំដាប់លំដោយនៃស្ថានសួគ៌ (វិវរណៈ4:1-11)

1. ព្រះទ្រង់ជាស្តេច

នៅក្នុងអត្ថបទពាក្យបល្ល័ង្កលេចមក14ដង។ មានការគ្រប់គ្រងរបស់ព្រះ ដែលទ្រង់មានពេញដោយភាពបរិសុទ្ធនិងសេចក្តីមេត្តា។ ប្រវត្តិសាស្ត្ររបស់មនុស្សជាតិជាប្រវត្តិសាស្ត្រនៃភាពមិនស្ថិតស្ថេរ ពីព្រោះមនុស្សគ្រប់គ្រងលើមនុស្ស។ លោក Beza ត្រូវបានរំដោះ 600ដងចេញពីស្ថានភាពគ្រោះថ្នាក់អស់រយៈពេល22ខែ។ ស្ថានភាពនោះបង្ហាញថាព្រះទ្រង់ជាស្តេចរបស់អ្នកបរិសុទ្ធ។ តែសម្រាប់អ្នកខ្លះទ្រង់មិនត្រូវបានបង្ហាញមកដូច្នោះទេដោយសារទ្រង់មិនបានការពារ។តែវាក៏ស្ថិតនៅក្នុងភាពជាស្តេចរបស់ទ្រង់ផងដែរ។

2. មានក្រុមជំនុំនៅចំកណ្តាលនៃព្រះ

ចំណុចកណ្តាលរបស់ព្រះមានន័យថាជាក្រុមជំនុំនៅក្នុងមជ្ឈមណ្ឌលនៃក្រុមជំនុំ។ ប៉ូលនិយាយថា "ដ្បិតតើខ្ញុំរកនឹងបញ្ចុះបញ្ចូលអ្នកណា តើជាមនុស្សឬព្រះ ឬចង់ចង់បំពេញចិត្តមនុស្សឬអី បើសិនជាខ្ញុំចង់បំពេញចិត្តមនុស្ស នោះខ្ញុំមិនមែនជាបាវបម្រើរបស់ព្រះគ្រីស្ទទេ។" (កាឡាទី 1:10)

3. រន្ទះ សម្លេងនិងផ្លែកបន្ទោរចេញពីបល្ល័ង្ក

ការនេះមិនចង្អុលតែទៅកានព្រះចេស្តារបស់ព្រះទេ តែក៏ចង្អុលថាទ្រង់នឹងយាងមកបំផ្លាញអំពើបាបនិងការអាក្រក់។ កាលដែលព្រះធ្វើការនៅភ្នំស៊ីណៃ "រន្ទះនិងផ្លែកបន្ទោរ" បានមកលើភ្នំផងដែរ។ (និក្ខមនំ 19:16)។ ទ្រង់មានបន្ទូលជាសម្លេងជាមួយនឹងម៉ូសេ (និក្ខមនំ 19:19)។ យ៉ាងណាក៏ដោយ ព្រះបន្ទូលនេះជាអំណាចចេស្តារបស់ព្រះ ដែលមនុស្សមានបាបមិនអាចនឹងខិតចូលជិតទ្រង់បាន។ ស្ថានសួគ៌គួរតែមានអំណាចចេស្តាដូច្នោះមែន។ ក្រុមជំនុំនៅលើផែនដីជាប្រភេទនៃក្រុមជំនុំនៅស្ថានសួគ៌ដែរ។ ក្រុមជំនុំពិតមានអំណាចចេស្តា។ ព្រះវរបិតាដែលបានត្រាស់ហៅលោក Nightingale ដែលបានប្រើយ៉ាងខុសឆ្គងនៅលើអាសនា គាត់បានធ្លាក់ចុះ ហើយករបស់គាត់បានបាក់និងក៏ស្លាប់ទៅ។

4. មានភ្លើងដែលឆេះសន្ធៅនៅខាងមុខបល្ល័ង្ក

នេះមានន័យថាវាជាព្រះបន្ទូលសម្រាប់ជាបំភ្លឺនិងជាកំដៅនៃព្រះវិញ្ញាណបរិសុទ្ធ។ តាមការប្រកាសព្រះបន្ទូលរបស់ព្រះយ៉ាងពិត នោះចិត្តដែលស្តាប់ក៏បានទៅដូចជាកម្តៅ។

5. សមុទ្រនៃកែវដូចជាគ្រីស្តាល់នៅខាងមុខបល្ល័ង្ក

សមុទ្រនៃកែវជាការប្រៀបប្រដូចនៃសេចក្តីសុចរិតរបស់ព្រះគ្រីស្ទ។ ក្រុមជំនុំពិតមិនមាននូវសេចក្តីសុចរិតរបស់មនុស្សទេ តែមានដោយសេចក្តីសុចរិតរបស់ព្រះគ្រីស្ទវិញ។

6. សត្វទាំងបួន (សត្វដែលមានជីវិត) ដើម្បីនឹងបម្រើព្រះ
7. ក្រុមជំនុំនៅផែនដីក៏គួរមានអ្នកដែលបម្រើដែរ

ការអធិប្បាយទី 14 ចូរសរសើរដល់សេចក្តីបរិសុទ្ធរបស់ព្រះ (វិវរណៈ 4:8)

តើអ្វីទៅជា "ការបន្សុទ្ធ"? ពាក្យថា បរិសុទ្ធ ថា ខាដូស (קָדַשׁ) នៅក្នុងភាសាហេព្រើរ។ អត្ថន័យនៃពាក្យដើមគឺការញែកចេញ។ ដូច្នេះពាក្យនេះមានន័យថា ព្រះទ្រង់ជាតួអង្គ នៃការញែកចេញពីរបស់ដែលត្រូវបានបង្កើតមក ដែលទ្រង់ជាអង្គដែលខ្ពង់ខ្ពស់បំផុត ដែលគ្មាននរណាម្នាក់អាចទៅដល់ ហើយទ្រង់ជាអង្គដែលល្អឥតខ្ចោះ។ ដូច្នេះវាមិន មានទំនាក់ទំនងទៅនឹងលក្ខណៈរបស់អ្វីៗដែលត្រូវបានបង្កើតមកទេ។ ទីពីរ វាមិន មានទំនាក់ទំនងនឹងអំពើបាបទេ។ ដូច្នេះ អត្តចរិតនៃការថ្វាយបង្គំភាពបរិសុទ្ធរបស់ ព្រះគួរតែដូចតទៅនេះ។

1. ជីវិតដែលចងចាំថាខ្លួនខ្ញុំជារបស់ដែលព្រះបានបង្កើតមក

(1) និយាយម្យ៉ាងទៀត វាមានន័យថាការដឹងពីជីវិត "ខ្ញុំមិនមែនជាព្រះអាទិករ ទេ" ហើយខ្ញុំមិនចេញមកជាព្រះអម្ចាស់ដល់អ្នកណាឬអ្វីមួយនោះទេ តែខ្ញុំជាអ្នកបម្រើ ចាត់ចែង ជាម្នាក់ដែលទាក់ទងនឹងរបស់ទាំងអស់ដែលបានបង្កើតដោយតាមការ ចង្អុលបង្ហាញរបស់ព្រះ។ ខ្ញុំមិនមែនជាម្ចាស់លើខ្លួនខ្ញុំឡើយ។ នៅពេលខ្ញុំមានភាពជា អ្នកបម្រើ ហើយបានក្លាយជាម្ចាស់មានន័យថាបានធ្វើបាបដោយការប្រមាថដែលថា ខ្ញុំក្លាយជាព្រះហើយ។ អ្នកបម្រើរបស់ព្រះមិនឆ្មើងឆ្មៃទេ តែកោតខ្លាចដល់ព្រះ ការ ទទួលស្គាល់ពីភាពជារបស់ព្រះបានបង្កើតរបស់ខ្ញុំបង្ហាញឱ្យឃើញដោយការកោត ខ្លាចរបស់ខ្ញុំដល់ព្រះតែមួយប៉ុណ្ណោះ។ នៅក្នុងអេសាយជំពូក 6 សេចក្តីពិតដែលពួក សេរ៉ាភីមបានបាំងមុខរបស់ពួកគេ នោះជាការកោតខ្លាចនៃរបស់ដែលព្រះបានបង្កើត ទៅដល់ព្រះអាទិករ។ ការកោតខ្លាចក្នុងនាមជារបស់ដែលព្រះបង្កើតមកទៅកាន់ព្រះ អាទិករជាឥរិយាបថនៃការស្តាប់បង្គាប់ដោយគ្មានលក្ខខណ្ឌទៅកាន់ព្រះបន្ទូលទ្រង់ ដោយដឹងថាអំណាចចេស្តានៃភាពជាអម្ចាស់ជារបស់ព្រះតែមួយគត់។ ការស្តាប់

បង្គាប់នេះដែលរូបកាយរបស់យើងបានជាយញ្ញបូជារស់ (រ៉ូម 12:1)។ យញ្ញបូជាគួរតែស្លាប់ ដង្វាយដែលរស់មានន័យថាការស្តាប់បង្គាប់ដូចជាមនុស្សម្នាក់ស្លាប់ហើយតែមានជីវិតដែរ។ ជីវិតនៃការទទួលខុសត្រូវដែល ខ្ញុំមិនអាចរស់ក្នុងជីវិតខ្ញុំបានដោយបំណងរបស់ខ្ញុំ ដែលជាការកោតខ្លាចដល់ព្រះនិងជីវិតដែលស្គាល់សេចក្តីបរិសុទ្ធរបស់ព្រះ។

(2) យើងគួរតែបែងចែកឱ្យដាច់ពីលក្ខណៈនៃរបស់ដែលព្រះបង្កើតនៅក្នុងចំណេះដឹង យើងមានបំណងអាក្រក់ដែលចង់ដឹងពីព្រះខ្លាំងពេក ហើយវាខុស។ យើងគួរតែដឹងអ្វីដែលយើងអាចដឹងបាននៅក្នុងផ្នែកនៃចំនេះដឹង តែអ្វីដែលយើងមិនដឹងបានទុកវាមួយផ្នែក។ សម្រាប់ផ្នែកណាដែលជាចំណេះដឹងមិនអាចដឹងបាន យើងមិនគួរដឹងវាទេ តែគួររក្សានូវសេចក្តីកោតខ្លាចដល់ទ្រង់វិញ។ បើទោះជាមនុស្សមានឥរិយាបថដែលអាក្រក់ដែលចង់ដឹងគ្រប់យ៉ាងពីព្រះ វាមិនមែនជាឥរិយាបថត្រឹមត្រូវក្នុងការបម្រើដល់ព្រះទេ។ វាជាការក្រអឺតក្រទមដែលអង្គុយនៅលើបល្ល័ង្កទ្រង់ ជាការប្រមាថវិញ។

2. ខ្ញុំគួរដឹងថាខ្ញុំជាមនុស្សមានបាប ហាយត្រូវមានអារម្មណ៍អាម៉ាស់ និងមិនគួរបង្ហាញពីខ្ញុំទេ

យើងព្យាយាមបង្ហាញពីខ្ញុំជំនួសឱ្យព្រះវិញ ហើយបង្ហាញពីគំនិតរបស់ខ្ញុំជំនួសឱ្យព្រះបន្ទូលរបស់ព្រះ ហើយវាជាអាកប្បកិរិយាមួយដែលមានបាប។ ពេលនោះ ខ្ញុំមិនលាក់ឡើយ តែបង្ហាញពីខ្ញុំ នោះខ្ញុំបានធ្វើបាបហើយ។ នៅពេលយើងបានទទួលព្រះគុណច្រើន យើងមានការដឹងខ្លួនពិតថា "ខ្ញុំជាមនុស្សមានបាប"។ យើងគួរតែដឹងពីខ្ញុំថាដាច់ចេញពីព្រះ។ ការដឹងខ្លួនពីការញែកចេញគ្នានេះជាចិត្តដែលមានការខ្មាស់ទៅកាន់អំពើបាបខ្លួន។ តែយើងមានការអាម៉ាស់។ យើងមិនដឹងពីការកខ្វក់របស់យើង

ច្រើនទេ។ យើងជាញឹកញាប់ឃើញមនុស្សអាក្រាតនៅពេលថ្ងៃ។ បន្ទាប់មកមនុស្ស មិនដឹងពីសេចក្តីអាម៉ាស់និងការប្រព្រឹត្តរបស់ខ្លួនទេ។ ហេតុអ្វីបានជាគេដឹងពីការ អាម៉ាស់របស់ខ្លួនទៅ? ពីព្រោះគេជាមនុស្សឆ្កួត។ ដូច្នោះដែលកាលណាដែលចិត្ត របស់យើងមានពេញដោយអំពើបាប យើងរាប់អំពើបាបយ៉ាងអាក្រក់។ ចាប់ពីពេល នេះទៅ យើងគួររស់នៅដើម្បីនឹងពិចារណានូវសេចក្តីខ្មាស់របស់ខ្ញុំ ដែលជាកែប្រែខ្លួន និងមានចិត្តដែលផ្លាស់ប្រែដើម្បីត្រូវខ្មាស់នឹងពិធីលៀងដែលនៅស្ថានសួគ៌ (ម៉ាថាយ 22:8-14)។ ព្រះយេស៊ូវមានបន្ទូលថា "មានពរហើយអស់អ្នកដែលទួញសោក ដ្បិតគេ នឹងបានសើចវិញ"។ "ត្រូវបណ្តាសាហើយអ្នកដែលសើចពេលនេះ ដ្បិតអ្នកនឹងទួញ សោកនិងយំផង" (លូកា 6:21, 25)

ការអធិប្បាយទី 15 ការសរសើរដល់សត្វដែលមានជីវិតរស់ទាំងបួន (វិវរណៈ 4:8-11)

1. ការសរសើរដែលមិនឈប់ឈរនៅពេលថ្ងៃនិងពេលយប់

នេះគឺជាការសរសើរដោយគ្មានអារម្មណ៍នឿយហត់។ ការសរសើរនេះជាមិនពិបាកទេ តែមានអំណរនិងអំណាចវិញ ពីព្រោះវាចេញមកពីខាងក្នុង។ ដូច្នេះ វាចេញមកដោយ គ្មានបង្អាក់ទេ។ ហេតុផលដែលការសរសើរចេញមកពីការទាំងនោះជាការពិតដែល ពួកគេជាភាវៈមានជីវិត (នៅក្នុងភាសាក្រិកថា ស្សូអា ζῴα)។ ហេតុផលដែលឈ្មោះ របស់ពួកត្រូវបានហៅថាជាសត្វដែលមានជីវិតគឺដោយសារសេចក្តីពិតដែលពួកគេ មានពេញដោយជីវិត។ អ្នកជឿដល់ព្រះគ្រីស្ទក៏មានសេចក្តីសន្យាដែលមានពេញ ដោយជីវិតរបស់ព្រះផងដែរ។ យ៉ូហាន 10:10 មានបន្ទូលថា ព្រះគ្រីស្ទបានមកនៅ

ក្នុងលោកិយ ""ចោរវាមកតែនឹងលួច សម្លាប់និងបំផ្លាញ។ ខ្ញុំបានមកដើម្បីឱ្យពួកគេបានជីវិត ហើយជាជីវិតដែលពេញបរិបូរណ៍ផង។" រ៉ូម 5:17 មានបន្ទូលថា "ដ្បិតបើសិនជាសេចក្តីស្លាប់បានសោយរាជ្យ ដោយសារមនុស្សតែម្នាក់ ដោយព្រោះម្នាក់នោះឯង បានប្រព្រឹត្តសេចក្តីរំលង ដូច្នេះប្រាកដជាពួកអ្នកដែលទទួលព្រះគុណដ៏បរិបូរ និងអំណោយទានជាសេចក្តីសុចរិត នោះនឹងបានសោយរាជ្យក្នុងជីវិតលើសទៅទៀត ដោយសារតែម្នាក់ដែរ គឺជាព្រះយេស៊ូវគ្រីស្ទ។"

2. ការសរសើរសេចក្តីបរិសុទ្ធរបស់ព្រះ

នេះជាការសរសើរព្រះដោយទន្ទឹងចង់ឃើញភាពបរិសុទ្ធនិងការគោរពភាពមានតម្លៃតែមួយរបស់វា។ យើងត្រូវបរាជ័យដែលបានបំភ្លេចភាពបរិសុទ្ធដោយពិចារណាពីសេចក្តីជំនឿ។ ប្រសិនបើយើងផ្ទាល់មិនបរិសុទ្ធ យើងមិនអាចមើលឃើញភាពបរិសុទ្ធរបស់ព្រះបានទេ។ ពេលយើងឃើញភាពបរិសុទ្ធរបស់ទ្រង់ តើយើងអាចសរសើរដល់ភាពបរិសុទ្ធរបស់ទ្រង់បានយ៉ាងដូចម្តេច? ហេព្រើរ 12:4 មានបន្ទូលថា "ដ្បិតអ្នករាល់គ្នាមិនទាន់តយុទ្ធនឹងអំពើបាប ដល់ទៅហូរឈាមនៅឡើយទេ"។ យើងគួរតែស្វែងរកភាពបរិសុទ្ធជាសុភមង្គលថែមទៀត។ ព្រះយេស៊ូវមានបន្ទូលថា "យើងគួរស្រេកឃ្លាននឹងស្វែងរកសេចក្តីសុចរិត" (ម៉ាថាយ 5:6)។ ហេតុផលដែលយើងគួរតែចង់បានសេចក្តីបរិសុទ្ធ និងគោរពដល់ការដែលមានតម្លៃ ជាការពិតដែលថា ព្រះអម្ចាស់ទ្រង់នៅក្នុងភាពបរិសុទ្ធ។ ដោយសារបទគម្ពីរមានបន្ទូលថា "ចូរទទួលថ្លែងប្រាប់ពីសិរីល្អនៃព្រះយេហូវ៉ា ឱ្យសំណំនឹងព្រះនាមទ្រង់ ចូរនាំយកដង្វាយ1មកនៅចំពោះព្រះយេហូវ៉ាចុះ ហើយថ្វាយបង្គំដល់ទ្រង់ដោយសិរីលំអនៃសេចក្តីបរិសុទ្ធ" (របាក្សត្រទី1 16:29, របាក្សត្រទី2 20:21, ទំនុកដំកើង 29:2) សម្រស់បែបនេះគួរតែរារនៅក្នុងចិត្តរបស់ខ្ញុំយ៉ាងខ្លាំង។ ហេព្រើរ 12:14 មានបន្ទូលថា "ចូរដេញតាមសេចក្តីមេត្រី ចំពោះមនុស្ស

ទាំងអស់ចុះ ហើយឱ្យបានញែកជាបរិសុទ្ធដែរ បើអ្នកណាគ្មានសេចក្តីបរិសុទ្ធ នោះមិនដែលឃើញព្រះអម្ចាស់ឡើយ”។

ដូច្នេះ យើងគួរវាយប្រឆាំងនឹងអំពើបាបដើម្បីឱ្យបានឃើញព្រះអម្ចាស់។ បើទោះជាយើងមិនអាចមានភាពមួយដែលគ្មានបាបសោះក៏ដោយ តែការរក្សានូវការតយុទ្ធនឹងអំពើបាបនោះព្រះទ្រង់បានឈរនៅខាងយើងហើយ។ តើការតយុទ្ធអនុវត្តនូវការតយុទ្ធនឹងបាបយ៉ាងដូចម្តេច? (1) ដំបូងបង្អស់ គេគួរតែស្គាល់នូវសភាពដែលស្មោកគ្រោករបស់គេ។ (2) គេគួរតែស្អប់អំពើបាបរបស់គេក៏ដូចជាការស្អប់ដល់អំពើបាបរបស់អ្នកផ្សេងផងដែរ 3) យើងគួរផ្តោតលើការកាត់អំពើបាបចេញដែលវាបាំងនូវជីវិតដែលមានជំនឿស្មោះត្រង់របស់យើង។

3. ការសរសើរព្រះវត្តមានរបស់ព្រះ

សត្វដែលមានជីវិតទាំងបួនមិនសរសើរ ពីព្រោះព្រះផ្តល់អ្វីមួយដល់ពួកគេ តែពួកគេសរសើរថាព្រះទ្រង់គង់នៅ។ ពីព្រោះ (1) ព្រះទ្រង់គ្មានបរាជ័យឬសេចក្តីកំសោយឡើយ។ (2) ដោយសារទ្រង់ជាព្រះអម្ចាស់ ទ្រង់ជាព្រះដែលមានគ្រប់ទាំងអំណាចចេស្តាលើគ្រប់របស់ទាំងអស់។ (3) ដោយសារទ្រង់ជាព្រះ ទ្រង់ជាអង្គជាវិញ្ញាណដែលគ្រប់គ្រងលើពិភពខាងវិញ្ញាណផង និងខាងសាច់ឈាមផង។ (4) ដោយសារទ្រង់មានគ្រប់អំណាចចេស្តា ទ្រង់អាចធ្វើគ្រប់ការទាំងអស់។ ដូច្នេះ វាជាសេចក្តីជំនឿដែលនឹងគ្រប់គ្រាន់សម្រាប់ព្រះអង្គ។

ព្រះអង្គនេះបានផ្តល់ភស្តុតាងនៃជំនឿរបស់យើង ពីព្រោះទ្រង់មានវត្តមានពីមុនមកផង។ ទំនុកដំកើង 74:12 ថា “ប៉ុន្តែព្រះទ្រង់ជាមហាក្សត្រនៃទូលបង្គំតាំងតែពីបុរាណមក ទ្រង់ក៏ប្រោសប្រទានសេចក្តីសង្គ្រោះនៅកណ្តាលផែនដី។” (2) ដោយសារតែទ្រង់គង់នៅនៅពេលនេះ ទ្រង់មានទំនាក់ទំនងរវាងជីវិត និងស្ថានភាពបច្ចុប្បន្ន។

ប្រសិនបើទ្រង់មិនមានទំនាក់ទំនងបច្ចុប្បន្នជាមួយយើងទេ នោះទ្រង់មិនមានទំនាក់ទំនងជាមួយយើងទេ។ តែតាមពិតនោះទ្រង់គង់នៅក្នុងខ្ញុំ។ ទំនុកដំកើង 68:19 ថា “សូមឱ្យព្រះអម្ចាស់បានប្រកបដោយព្រះពរដែលទ្រង់ទទួលយកបន្ទុកយើងរាល់ៗថ្ងៃ គឺជាព្រះជាទីសង្គ្រោះដល់យើងខ្ញុំ”។ ព្រះភ្ជាប់ទៅនឹងស្ថានភាពបច្ចុប្បន្នរបស់យើង ពីព្រោះយើងមិនអាចយល់ពីគំនិតរបស់ទ្រង់បានទេ នោះយើងនឹងមិនទទួលបានព្រះគុណរបស់ទ្រង់ទេ។ ជីវិតដែលមិនចូលចិត្តនឹងពិភាក្សាជាមួយទ្រង់ពីសេចក្តីពុករលួយនេះទេ។ (3) ព្រះទ្រង់គង់នៅនៅក្នុងពេលអនាគត។ កាលដែលអ្នកជឿទាំងអស់មើលពីអតីតកាលដែលបានកន្លងផុតទៅ នោះបច្ចុប្បន្នដែលនឹងត្រូវជួបហើយ តែអនាគតវិញជាការដែលអាថ៌កំបាំង។ ទេ គ្រប់ការទាំងអស់សុទ្ធតែជាការនៃអនាគត។ តែតាមព្រះបន្ទូលរបស់ព្រះនៅក្នុងភាពជាអ្នកជឿ ព្រះពរដែលនឹងទទួលបានជាការដែលនៅអនាគត។ នៅពេលអនាគត ព្រះនឹងយាងមករកយើញ ហើយនឹងគង់នៅជាមួយយើង។

ការអធិប្បាយទី 16 អំពីការបង្កបង្កើត (1) (វិវរណៈ 4:11)

ក្នុងចំណោមបទគម្ពីររបស់សាសនាគ្រឹស្ត នៅចំកណ្តាលនៃលោកុប្បត្តិជំពូក 1 – 2, សរុបទាំងអស់មាន 75 ជំពូក និងខនៅក្នុងសញ្ញាថ្មី និងសញ្ញាចាស់និយាយពីការបង្កបង្កើតនៃភាវៈទាំងអស់ដោយសារព្រះ។ ត្រង់ចំណុចនេះជាពិសេស ខ្ញុំនឹងអធិប្បាយជាមួយនឹងវិវរណៈជំពូក 4។ វានិយាយថា “ព្រះអម្ចាស់និងជាព្រះទ្រង់គួរតម្លើង ទ្រង់មានគ្រប់សិរីល្អ ការគោរពនិងព្រះចេស្តា ដោយសារទ្រង់បានបង្កើតគ្រប់ការទាំងអស់មក ហើយដោយបំណងរបស់ទ្រង់ពួកគេបានមានឡើងនិងត្រូវបានបង្កើតមក។” កាលដែលយើងឃើញពាក្យថា ចាស់ទុំទាំង 24 នៅស្ថានសួគ៌ដែលបានសរសើរថា គ្រប់ទាំងភាវៈទាំងអស់ត្រូវបានបង្កើតមកតាមព្រះហឫទ័យរបស់ព្រះ ដូច្នោះដែរពួកគេក៏ជារបស់ផងព្រះដែរ យើងមានតែអរព្រះគុណដល់ព្រះ។ លិទ្ធិនៃការវិវត្តន៍និយមដែលគិតថាគ្រប់ភាវៈទាំងអស់ជាលទ្ធផលនៃការអភិវឌ្ឍនៃធម្មជាតិ វាបានធ្វើទុក្ខច្រើនដល់មនុស្សជាតិ យើងមិនអាចនិយាយអ្វីក្រៅពីនោះឡើយ។ លិទ្ធិនៃការវិវត្តន៍និយមជាជំនឿតែមួយគត់ ដោយសារវាមិនមែនជាសេចក្តីពិតឡើយ គំនិតដែលនាំមកនូវថ្នាំពុក

ដ៏អាក្រក់យ៉ាងខ្លាំង។ ពេលនេះ កាលដែលយើងពិនិត្យពីវា នេះជាសេចក្តីពិតដូចតទៅនេះ

1. អ្នកដែលជឿលើការវិវត្តន៍មិនអនុវត្តការបង្រៀនខុសឆ្គងទេ
ពេលពួកគេគិតថា សម្រាប់ធម្មជាតិជាមនុស្សនោះវាល្អ ដែលពួកគេនឹងអភិវឌ្ឍដោយសេរី នោះពួកគេនឹងបានល្អឡើង។ ការអប់រំនេះធ្វើឱ្យពួកគេចូលទៅក្នុងការវិវត្តន៍និយមរបស់រុស្សី រួចមកវាធ្វើឱ្យមនុស្សទៅជាពុករលួយ និងកាន់តែធ្វើតាមចិត្ត។

2. ទស្សនៈបែបប្រវត្តិសាស្ត្រនៃអ្នកដែលជឿលើការវិវត្តិន៍និយម ជាចុងក្រោយនាំយើងទៅកាន់ការដឹងនាំរបស់ភាវៈជនដើម្បីនឹងបំផ្លាញមនុស្សជាតិ
កាលដែលការវិវត្តនៃភាវៈរស់ត្រូវបានអភិវឌ្ឍដោយគោលការណ៍នៃអាហារសាច់ដែលខ្សោយ តែអ្នកដែលទទួលវាទុកជាការយល់ឃើញរបស់ខ្លួនពីប្រវត្តិសាស្ត្រ ចុងក្រោយនឹងក្លាយជាភាវៈជន។ លោក អ៊ីស្តែបង្កើតនូវភាវៈជនណាស៊ីទៅតាមការវិវត្តន៍និយមរបស់លោកដាវីន ដែលគាត់ជាភាវៈជននៃជំនឿកុំម៉ុយន្ទីសដែលចេញមកពីជំនឿនៃការវិវត្តនិយម។ លោក កាល់ ម៉ាកស៍ អះអាងថាប្រវត្តិនៃមនុស្សជាតិមិនអាចជួយអ្វីឡើយ ក្រៅពីផ្លាស់ប្តូរវាតាមធម្មជាតិ។ ប្រៀបដូចជាមនុស្សមើលងាយការពិតដែលថាមនុស្សគួរប្រែចិត្តពីអំពើបាបខ្លួននៅចំពោះព្រះ តែអ្នកទស្សនៈវិទូពីប្រវត្តិសាស្ត្រដែលទទួលយកការប្រយុទ្ធនាំភាពអញនិយមដោយសុទិដ្ឋិនិយម ចុងក្រោយនឹងត្រូវចូលទៅក្នុងបក្សពួករបស់ភាវៈជនដែលនឹងបង្កើតមនុស្សជាច្រើនជាទាសកររបស់ពួកគេ។

3. ការវិវត្តន៍មើលងាយព្រះនិងគិតថាមនុស្សជាលទ្ធផលនៃការអភិវឌ្ឍនៃភាពចៃដន្យនិងធម្មជាតិ

ដូច្នេះ គំនិតនេះធ្វើឱ្យមនុស្ស (1) ពីព្រោះមិនមានចៅក្រម វាធ្វើឱ្យគេប្រព្រឹត្តបាបដោយឥតលក្ខខណ្ឌ។ (2) គេមើលងាយនូវភាពត្រឹមត្រូវរបស់មនុស្សដែលព្រះបានបង្កើតនៅក្នុងរូបឆ្លុះរបស់ព្រះ ដូច្នេះ វាធ្វើឱ្យមនុស្សពុករលួយ ដែលគេជាមនុស្សដែលគ្មានសេចក្តីស្រឡាញ់ដែលអាចនឹងលះបង់ពិតប្រាកដសម្រាប់អ្នកជិតខាងខ្លួន។ (3) ដោយសារគេមិនទទួលស្គាល់ថា គ្រប់ទាំងភាវៈជាកម្មសិទ្ធិរបស់ព្រះ ហើយអះអាងថាគេអាចធ្វើអ្វីតាមតែចិត្ត គេមិនមានទំនុកចិត្តយ៉ាងពេញលេញនៅក្នុងការប្រើការទាំងនោះឡើយ (4) ពួកគេជឿតែអ្វីនៅក្នុងលោកិយបច្ចុប្បន្ននេះ តែមិនជឿលើពិភពលោកដែលនឹងត្រូវមកដល់ឡើយ។

(5) ពួកគេអះអាងថា គ្រប់ការទាំងអស់នឹងត្រូវផ្លាស់ប្តូរ ហើយធ្វើឱ្យយើងឈប់ប្រកាន់ខ្ជាប់ទៅនឹងសេចក្តីពិតទូទៅពីដើមមក ហើយគុណសម្បត្តិខាងសីលធម៌ផង។ ដូច្នេះ គំនិតរបស់ពួកគេនៅក្នុងគុណតម្លៃខាងសីលធម៌ ដំណើររបស់ពួកគេ នោះពួកគេរស់តាមដែលគេចង់បាន។ តាមដែលយើងពិនិត្យការខាងលើនេះ ការវិវត្តន៍និយមជាគំនិតដែលបំផ្លាញមនុស្សជាតិ។

ការអធិប្បាយទី 17 អំពីការបង្កបង្កើត (2) (វិវរណៈ 4:11)

1. ភស្តុតាងដែលព្រះបានបង្កើតដែលអាចរកឃើញដោយមនុស្សគ្រប់រូបដែលពិចារណាបានជ្រាលជ្រៅពិត

លោក AC Morrison ដែលជាប្រធានសមាគមវិទ្យាសាស្ត្រញ្ញូវយ៉កបានចង្អុលបង្ហាញការពិតនៅក្នុង "ហេតុផលប្រាំពីរដើម្បីជឿលើព្រះក្នុងនាមជាអ្នកវិទ្យាសាស្ត្រ"។ នោះគឺប្រសិនបើពិភពលោករបស់យើងប្រែជាល្បឿន 1/10 លឿងជាងល្បឿនបច្ចុប្បន្ន នោះយប់និងថ្ងៃនឹងវែងជាងបច្ចុប្បន្ន 10 ដង។ បើដូច្នេះមែន ព្រោះនៅពេលថ្ងៃ បន្លែទាំងអស់ត្រូវបានបំភ្លឺជាប់ វាត្រូវបានសួត ប៉ុន្តែនៅពេលយប់សម្រាប់សីតុណ្ហភាពកម្រិតទាប បន្លែនឹងកកហើយស្លាប់។ មិនត្រឹមតែប៉ុណ្ណោះ ចម្ងាយរវាងផែនដី និងព្រះអាទិត្យគឺនៅឆ្ងាយជាងពេលបច្ចុប្បន្នបន្តិច នោះយើងនឹងកកហើយស្លាប់ ឬបើវានៅជិតជាងនេះបន្តិច យើងនឹងត្រូវឆេះខ្លោចស្លាប់។ ហើយមួយខែយើងនឹងនៅខាងក្រៅ 24 0000 ម៉ាយពីពិភពលោករបស់យើង ប្រសិនបើនៅខាងក្រៅ 50000 ម៉ាយ នោះជំនោរនឹងលិចផែនដីទាំងមូល។ លើកលែងតែពួកគេនៅក្រោមអំណាចបែបនេះ ដែលស្ថិតនៅក្រោមផែនការគណិតវិទ្យារបស់ព្រះវិញ ការពិតដែលថាសត្វមានជីវិតត្រូវបានទ្រទ្រង់អាចត្រូវបានពន្យល់ឧទាហរណ៍បន្ថែមទៀត។ ការដូច្នេះដែលកិច្ចការដែលជីវិតមនុស្សត្រូវបានរក្សាមិនអាចនិយាយបានថាវាជាការចៃដន្យទេ។

លោក ចេមស៍ ចេនស៍ ជាអ្នកវិទ្យាសាស្ត្រដ៏ពូកែរបស់អង់គ្លេសបានមានប្រសាសន៍ថា ក្នុងន័យថាគ្រប់ទាំងច្បាស់ធម្មជាតិទាំងអស់ជាគណិតវិទ្យា សកលលោកមិនមែនជាលទ្ធផលនៃឧប្បត្តិហេតុនោះទេ ប៉ុន្តែជាផលិតផលរបស់អ្នកវិទ្យាសាស្ត្រគណិតវិទ្យាដ៏អស្ចារ្យ ហើយបានសារភាពសេចក្តីជំនឿរបស់គាត់ថាជឿលើព្រះ។ ជាពិសេស ដោយសារតែការបង្កើតរបស់ទាំងអស់ គឺជាការងារមុនពេលដែលរបស់អ្វីទាំងអស់មានឡើង វាពិបាកគ្រប់គ្រងលើការនេះដោយប្រាជ្ញារបស់មនុស្សណាស់។ ការពិតដែលថាមនុស្សដឹងច្បាស់ជាងខ្លួនគាត់អំពីកំណើតរបស់គាត់ នោះរឪពុកម្តាយរបស់គាត់ដែលបានដឹងច្បាស់ជាងគាត់។ ដូចនោះដែរ អំពីការបង្កើតនៃរបស់ទាំងអស់ ព្រះ

ទ្រង់ជ្រាបច្រើនជាងយើងទៅទៀត។ ព្រះបន្ទូលរបស់ទ្រង់ធ្វើឱ្យយើងស្គាល់ការពិតកាន់តែច្បាស់។ បទគម្ពីរ 75 ជំពូក និងខគម្ពីរចែងអំពីការពិតនៃការបង្កើតរបស់ព្រះដល់របស់ទាំងអស់។ យើងគួរតែទទួលយកការពិតនេះ។ អ្វីដែលយើងទទួលយកពាក្យនេះមិនគួរអាស្រ័យលើការសិក្សាដោយបញ្ញាទេ ប៉ុន្តែដោយជំនឿវិញ។ តើជំនឿជាអ្វី? ការដឹងពីសេចក្តីពិតដ៏ខ្ពង់ខ្ពស់ គឺដំណើរការដោយវិធីសាស្ត្រខាងវិញ្ញាណ និងវិធីសាស្ត្រសីលធម៌។

2. អ្នកវិវត្តន៍និយមនិយាយថាមនុស្សដូចជាសត្វដែលត្រូវបានកើតចេញពីប្រភពដើមទូទៅច្បាស់លាស់មួយ។

ដើម្បីបង្កើតទ្រឹស្តីនេះ ពួកគេបានអះអាងពីចំណុចផ្សេងគ្នាជាមួយនឹងមនុស្សសម័យនេះ ដោយសារតែមនុស្សសម័យទំនើបត្រូវបានវិវឌ្ឍច្រើនជាងមនុស្សបុរាណចេញពីហ្វូស៊ីលនៃឆ្អឹងដែលពួកគេសន្មត់ថាមាននៅរាប់ម៉ឺនឆ្នាំមុន។ ប៉ុន្តែ (1) សូម្បីតែអ្នកវិទ្យាសាស្ត្រនៃការវិវត្តន៍ក៏មិនបញ្ជាក់បានដែរ។ ដោយសារតែហ្វូស៊ីលបែបនេះមានមិនច្រើនទេ ឆ្អឹងក៏គ្រាន់តែជាបំណែកប៉ុណ្ណោះ។ (2) បម្រាប់បរិស្ថានវិញ (បរិស្ថានសត្វអាចរស់នៅដូចជារូងភ្នំ) ដែលហ្វូស៊ីលត្រូវបានរកឃើញ។ បន្ទាប់មកមនុស្សលោកត្រូវបានសន្មត់ថាដូចជាសត្វធម្មតាវិញ។ ទោះជាយ៉ាងណាក៏ដោយ ដោយសារតែបរិយាកាសនៃជីវិតនៅក្នុងការពិតត្រូវបានអភិវឌ្ឍ និងត្រូវបានផ្លាស់ប្តូរ យើងមិនអាចដោះស្រាយតម្លៃរបស់មនុស្សជាសំខាន់បានទេ។ ដោយសារឆ្អឹងសត្វប្រៀបដូចជាឆ្អឹងមនុស្ស យើងមិនអាចកំណត់លក្ខណៈវិនិច្ឆ័យនៃការវិវត្តន៍បានឡើយ។ ថ្វីត្បិតតែយើងជាបុរសសម័យថ្មី ប្រសិនបើពួកគេជួបបរិស្ថានមិនរស់នៅដោយអាវុធអាតូម ពួកគេអាចនឹងធ្វើឱ្យបរិស្ថានដែលពួកគេគួរតែរស់នៅក្នុងរណ្តៅដូចសត្វជាបំណែកនៃប្រវត្តិ

សាស្ត្រ។ (3) មិនត្រឹមតែប៉ុណ្ណោះ សព្វថ្ងៃនេះ យើងមិនដែលឃើញការពិតថា ចន្លោះមួយត្រូវបានផ្លាស់ប្តូរទៅជាលំហផ្សេងទៀតនៅកន្លែងណានោះទេ។ តើមនុស្សបានឃើញសត្វណាមួយបានប្រែក្លាយទៅជាមនុស្សទេ? មិនដែលមានរឿងបែបនេះទេ។

(6) (1) មិនត្រឹមតែប៉ុណ្ណោះ អ្នកប្រាជ្ញខាងការវិវត្តន៍គិតថា មនុស្ស និងស្វាកើតចេញពីប្រភពតែមួយ។ តើពិតទេ? យើងមិនគួរដោះស្រាយអ្វីមួយដោយរូបរាងខាងក្រៅទេ។ ថ្វីត្បិតតែវត្ថុទាំងពីរមិនមានចំណែកដូចគ្នាក្នុងចំណុចច្រើនក៏ដោយ ជាពិសេសបេះដូងគឺខុសគ្នាទាំងស្រុង ដូចជារាងស្ពានសួត៍ និងផែនដីដែរ។ ស្វាមិនអាចរៀនដូចឆ្កែបានទេ គេមិនអាចរៀនដូចមនុស្សជាតិបានសិក្សារហូតនោះទេ។ លោក Paul Zimmerman បានបោះពុម្ពចំណុចផ្សេងគ្នា 50 ប្រភេទរវាងស្វានិងបុរស។

លើសពីនោះទៀត យើងគួររក្សានៅក្នុងចិត្តរបស់យើង។ អ្នកប្រាជ្ញខាងការវិវត្តន៍និយមខ្លួនគេផ្ទាល់ក៏មិនអាចបញ្ជាក់ពីទ្រឹស្តីរបស់ពួកគេបានដែរ។ លោក ដាវីនផ្ទាល់ជាអ្នកប្រាជ្ញខាងការវិវត្តន៍និយមបានផ្ញើសំបុត្រមួយទៅកាន់លោកហ្គ្រេហើយនិយាយថា "នៅពេលដែលខ្ញុំឃើញសកលលោកដ៏អស្ចារ្យជាពិសេសចិត្តរបស់មនុស្ស នោះខ្ញុំមិនស្កប់ចិត្តទេ ពីព្រោះវាជាលទ្ធផលនៃចេស្តាដែលគ្មានគោលបំណង។" ហើយគាត់ក៏បាននិយាយថា “ខ្ញុំមិនអាចគិតថាលោកិយនេះជាលទ្ធផលដែលចេញមកពីការចៃដន្យឡើយ”។ សម្តីរបស់លោកដាវីននេះជាការសម្លាប់ដល់ជំនឿខាងការវិវត្តន៍និយម។ ហេតុអ្វីបានជាមនុស្សបង្រៀនពីទ្រឹស្តីដែលប្រឆាំងគ្នាទៅមនុស្សដូចជាវាជាសេចក្តីពិតដូច្នេះ? យើងគួរតែត្រឡប់ទៅកាន់បទគម្ពីរដែលមានបន្ទូលពីសេចក្តីពិតតែមួយគត់មកកាន់យើង។ លោកុប្បត្តិ 1:1 ថា “” ទំនុកដំកើង 33:6 ថា “ផ្ទៃមេឃបានកើតមក

ដោយសារព្រះបន្ទូលព្រះយេហូវ៉ា ហើយពួកពលបរិវារដែលនៅលើនោះ បានកើត ដោយសារខ្យល់ពីព្រះឱស្ឋទ្រង់”។ ទំនុកដំកើង 121:2 មានបន្ទូលថា “សេចក្តីជំនួយរបស់ខ្ញុំមកតែពីព្រះយេហូវ៉ាទេ គឺជាព្រះដែលបង្កើតផ្ទៃមេឃនិងផែនដី”។

ការអធិប្បាយទី 18 ការសរសើរពីរប្រភេទ (វិវរណៈ 4:8-11)

អត្ថបទមានការសរសើរពីរ។ មួយជាការសរសើរនៃភាវៈខាងវិញ្ញាណ និងមួយទៀតជាការសរសើររបស់ពួកចាស់ទុំទាំង24។ ភាវៈខាងវិញ្ញាណទាំងបួនដែលសរសើរដល់ភាពបរិសុទ្ធនិងភាពអស់កល្បរបស់ព្រះទាំងថ្ងៃនិងយប់។ (8,9) ចាស់ទុំទាំង 24 បានបោះមកុដនិងសរសើរចេស្តានៃការបង្កបង្កើតរបស់ព្រះ។ (ខ 11)

1. ការសរសើរដោយមិនបង្អង់ទាំងថ្ងៃនិងយប់.

យើងរៀនអ្វីមួយពីការសរសើរសត្វមានជីវិតទាំងបួន។ វាគឺជាការពិតដែលថាការសរសើររបស់ពួកគេមិនមានការផ្អាកទេ (ខ 8)។ អ្នកដែលស្គាល់ភាពបរិសុទ្ធនិងភាពអស់កល្បរបស់ព្រះជាម្ចាស់ ច្បាស់ជាមិនអាចធ្វើអ្វីក្រៅពីសរសើរតម្កើងទាំងយប់ទាំងថ្ងៃនោះទេ។ 10 ពីព្រោះ (10 ព្រះជាម្ចាស់ទ្រង់គង់នៅក្នុងភាពបរិសុទ្ធជានិច្ច ហើយវិនិច្ឆ័យពិភពលោកនៃអំពើបាប ហើយទ្រង់មិនបំផ្លាញមរដករបស់ទ្រង់ និងរាស្ត្រដែល

ទ្រង់ប្រោសលោះអស់កល្បជានិច្ចឡើយ ហើយទ្រង់ធ្វើឱ្យពួកគេក្លាយជារបស់ទ្រង់អស់កល្បជានិច្ច។ ភាពអស់កល្បរបស់ព្រះជាម្ចាស់ និងភាពបរិសុទ្ធគឺប្រសើរជាងសុភមង្គល។ យើងមិនគួរតែចង់រស់នៅក្នុងភាពងាយស្រួលនោះទេ ប៉ុន្តែនៅក្នុងភាពបរិសុទ្ធ វាគឺជាការទាមទារដ៏អស្ចារ្យរបស់មនុស្សពិត ដែលបង្កើតឡើងដោយរូបអង្គនៃព្រះ។ ព្រះជាម្ចាស់ដែលបានបង្កើតស្ថានសួគ៌ និងផែនដីមានគឺពិតជារីករាយ ដោយមិនបង្ហាញដោយពាក្យរបស់យើងជាជាងការពិតដែលភាវៈទាំងអស់នៃស្ថានសួគ៌ និងផែនដីមាន។ ជាងការពិតដែលទ្រង់ប្រទានអ្វីមួយដល់យើង អ្នកដែលទទួលស្គាល់ការពិតថាព្រះជាម្ចាស់បរិសុទ្ធ និងគង់អស់កល្បជានិច្ច ច្បាស់ជាមិនអាចជួយបានក្រៅពីសរសើរទ្រង់ទាំងយប់ទាំងថ្ងៃ។

2. ការសរសើរនៅក្នុងការថ្វាយមកុដដាក់នៅចំពោះព្រះ

ចាស់ទុំទាំង 24 បានថ្វាយមកុដរបស់ពួកគេ ពួកគេបានបំពាក់នៅនឹងព្រះ ហើយបានសរសើរនូវការបង្កបង្កើតរបស់ទ្រង់ផង។ ការសរសើរជាការសារភាពមួយដ៏មានតម្លៃ ពីព្រោះគ្រប់ការទាំងអស់ត្រូវបានកើតឡើងដោយការបង្កើតរបស់ព្រះ គ្រប់ទាំងសិរីល្អនឹងត្រូវបានផ្តល់ដល់ទ្រង់តែមួយអង្គគត់។

កូរិនថូសទី1 4:7 ថា “ដ្បិតតើអ្នកណាដែលធ្វើឱ្យអ្នកផ្សេងពីគេ តើអ្នកមានអ្វីខ្លះដែលអ្នកមិនបានទទួល ចុះបើបានទទួលមែន ហេតុអ្វីបានជាអួតខ្លួនដូចជាមិនបានទទួលវិញ។” យើងគួរថ្វាយគ្រប់សិរីល្អទៅកាន់ព្រះ ពីព្រោះគ្រប់ទាំងសេចក្តីល្អត្រូវបានបង្កើតមកពីព្រះ ហើយទៅបានផ្តល់មកដោយសារទ្រង់មកដល់យើង។

មនុស្សគួរថ្វាយគ្រប់សិរីល្អដែលពួកគេបានទទួលទៅកាន់ព្រះ។ ពីព្រោះពួកគេត្រូវបានបង្កើតមកដោយព្រះ។ ដូច្នេះ អ្នកណាដែលថ្វាយសិរីល្អដល់ខ្លួន ជាអ្នកដែលមិនកោតខ្លាចដល់ព្រះទេនៅចំពោះព្រះ។ រ៉ូម 11:36 ថា “ដ្បិតរបស់សព្វសារពើបានកើតមកពី

ទ្រង់ ដោយសារទ្រង់ ហើយសម្រាប់ទ្រង់ សូមឱ្យទ្រង់បានសិរីល្អនៅអស់កល្បជានិច្ច អាម៉ែន។”

ជំពូកទី 5

ការបកស្រាយ

ឯនៅព្រះហស្តស្តាំនៃព្រះអង្គ ដែលគង់លើបល្ល័ង្ក នោះខ្ញុំឃើញមានក្រាំង។ នេះជាសញ្ញានៃគម្រោងការរបស់ព្រះសម្រាប់អនាគតនៃលោកិយនេះ ហើយគម្រោងមួយនៃភាពជាអម្ចាស់ដែលមានគ្រប់អំណាចរបស់ទ្រង់ផង។ មានតែព្រះទេទើបដឹងពីអនាគតរបស់លោកិយ ហើយទ្រង់ដែលគ្រប់គ្រងវាផង។ ដ្បិតដៃស្តាំមានអំណាច នោះវាជាសញ្ញានៃការថែរក្សាវា និងការដែលស្គាល់វាផង។ *ដែលសរសេរទាំងខាងក្នុង* នេះជាសញ្ញានៃការពិតដែលការរៀបគម្រោងសម្រាប់អនាគតរបស់ទ្រង់ត្រូវបានកំណត់យ៉ាងច្បាស់លាស់ ដែលគ្មាននរណានឹងបន្ថែម ឬដកចេញពីវាឡើយ។ ប៉ុន្តែលោក ហ្សាញ់ បកប្រែឃ្លាថា “នោះខ្ញុំឃើញមានក្រាំង ដែលសរសេរទាំងខាងក្នុង និងខាងក្រៅ” ទៅជា “ត្រូវបានសរសេរនៅខាងក្នុង និងនៅខាងក្រោយ ព្រមទាំងមានបិទត្រាប្រាំពីរផង”។ ប្រសិនបើការបកប្រែនេះត្រឹមត្រូវ គឺវាបានសង្កត់ធ្ងន់លើលក្ខណៈសម្ងាត់របស់វា តែការបកប្រែចាស់គឺត្រឹមត្រូវ ដោយសារ អេសេគាល 2:10 ក៏និយាយថាក្រាំង “ត្រូវបានសរសេរនៅខាងក្នុង” ហើយវេយ្យាករណ៍ក្រិកពាក្យដើម (γεγραμμένον ἔσωθεν καὶ ὄπισθεν) ដែលស្របទៅនឹងការបកប្រែចាស់។

ហេតុផលដែលព្រះទ្រង់បានបិទត្រានៅនឹងក្រាំងដោយដៃស្តាំគឺ ដើម្បីធ្វើឱ្យពួកជំនុំបានស្គាល់ពីអាថ៌កំបាំង។ ព្រះទ្រង់សព្វព្រះហឫទ័យនឹងប្រាប់ឱ្យរាស្ត្ររើសតាំងរបស់

ទ្រង់បានដឹង។ ហើយទ្រង់ក៏បំផ្លាញក្រុងសូដុម និងកូម៉ូរ៉ា ទ្រង់បានប្រាប់អ័ប្រាហាំថា “នោះព្រះយេហូវ៉ាទ្រង់មានព្រះបន្ទូលថា តើត្រូវលាក់នឹងអ័ប្រាហាំពីការដែលអញរៀបនឹងធ្វើឬទេ” (លោកុប្បត្តិ 18:17)។ *“ព្រមទាំងមានបិទត្រាប្រាំពីរផង”* “លេខប្រាំពីរ” មានន័យថាជាលេខពេញលេញ ត្រាប្រាំពីរជាសញ្ញានៃលក្ខណៈដែលលាក់បាំងដ៏មានមហិទ្ធិឫទ្ធិនៃអាថ៌កំបាំងប្រាំពីរនៃវិវរណៈ។ អាថ៌កំបាំងនៃត្រាទាំងប្រាំពីរត្រូវបានបើកបង្ហាញម្តងទៀតម្តងមួយៗនៅជំពូកទី 6។ យោងតាមទ្រឹស្តីមួយចំនួន សកម្មភាពនៃត្រាទាំងប្រាំពីរដែលត្រូវបានបិទចេញមកពីទំនៀមទម្លាប់របស់រ៉ូមគឺដើម្បីនឹងបញ្ជាក់ពីបំណងដោយត្រាប្រាំពីរ។ ប្រសិនបើវាពិតជាដូច្នោះ អត្ថន័យរបស់វានោះគឺការអះអាងពីទ្រព្យសម្បត្តិដែលព្រះទ្រង់បានប្រទានដល់កូនៗរបស់ទ្រង់។ ប៉ុន្តែវាពិបាកក្នុងការដែលយើងបានប្រាកដពីទ្រឹស្តីមួយនេះ។ ប៉ុន្តែបញ្ហានោះគឺពឹងលើថា តើអ្នកណាដែលអាចបកត្រាទាំងនោះបាន។

ទេវតាដ៏ខ្លាំងពូកែ។ ហេតុផលដែលទេវតាដ៏ខ្លាំងពូកែលេចមកគឺដើម្បីនឹងស្រែកដោយសម្លេចយ៉ាងឮៗខ្លាំង។ សម្លេងស្រែកហៅរបស់គាត់អាចនឹងទៅដល់ជុំវិញស្ថានសួគ៌ ផែនដី និងនៅក្រោមដីផង។ ពីព្រោះត្រាត្រូវបានបិតប្រាំពីរដងក៏ជាអាថ៌កំបាំងដល់ទេវតាដ៏ខ្លាំងពូកែផងដែរ គាត់បានស្រែកដោយសម្លេងខ្លាំងនោះ។ កិច្ចការដ៏អស្ចារ្យនៃការប្រោសលោះជាការដែលអស្ចារ្យដែលសូម្បីតែទេវតាក៏មើលឃើញថាគួរឱ្យភ្ញាក់ផ្អើលដែរ។ (I ពេត្រុស 1:12)។

“ដែលអាចនឹង”។ នេះគឺថា អាកស៊ីអស (ἄξιος) ក្នុងភាសាក្រិក នៅទីនេះវាមានន័យថា គុណសម្បត្តិដែលសុចរិតក្នុងការបើកត្រាទាំងប្រាំពីរនៃក្រាំង (ព្រះគ្រីស្ទជាមនុស្ស)។

3 នៅស្ថានសួគ៌។ វាជាកន្លែងដែលទេវតា និងពួកបរិសុទ្ធដែលបានស្លាប់ទៅរស់នៅ។ *នៅលើផែនដី* វាហាក់ដូចជាកន្លែងដែលមនុស្សទាំងអស់ និងភាវៈមានជីវិតទាំងអស់រស់នៅ។ *នៅក្រោមផែនដី* វាជាកន្លែងដែលហាក់ដូចជាព្រលឹងដែលមិនត្រូវបានឡើងទៅ និងភាវៈមានជីវិតរស់នៅ។ ការទាំងបីនេះរាប់បញ្ចូលគ្រប់ទីកន្លែងទាំងអស់នៃផែនដី និងក្រៅផែនដីផង។ មនុស្សមានបាបមិនអាចដឹងពីអាថ៌កំបាំងនៃគម្រោងផែនការរបស់ព្រះរហូតដល់ថ្ងៃចុងក្រោយនៃលោកិយនោះទេ (អេសាយ 11:25-)។ មិនត្រឹមតែប៉ុណ្ណោះ អ្នកដែលដឹងថាវាជាអ្វី អ្នកដែលមានគុណសម្បត្តិជាអង្គផ្សះផ្សាមិននៅក្នុងចំណោមពួកទេវតាទេ។ តើអ្នកណាដែលជាអ្នកដែលមានគុណសម្បត្តិគ្រប់គ្រាន់នោះ? ខ 5 ប្រាប់យ៉ាងច្បាស់។

4 នោះខ្ញុំយំ តើដោយហេតុផលអ្វីដែលយ៉ូហានយំយ៉ាងខ្លាំងម្ល៉េះ?

(1) ពីព្រោះគាត់គិតថាការបើកសម្តែង (ការបើកក្រាំង និងបង្ហាញវាមក) ដែលគាត់ស្រឡាញ់ និងទន្ទឹងរងចាំនឹងត្រូវបានបញ្ចប់។ កាលដែលយើងឃើញវា យើងទាយថាចិត្តរបស់គាត់ស្មោះត្រង់ប៉ុណ្ណានៅក្នុងការមើលឃើញពីកិច្ចការនៃនគររបស់ព្រះ។

(2) មូលហេតុមួយទៀតដែលគាត់យំគឺ ការដែលដឹងថាគ្មាននរណាម្នាក់អាចបើកក្រាំងនោះបានទេ ដោយសារតែអំពើបាបរបស់មនុស្ស។ ពីសំឡេងដែលទេវតាស្រែកនោះ ចក្រវាឡទាំងឡាយស្ងាត់គ្មានចម្លើយ ទើបចក្រវាឡលាតត្រដាងការពិតនៃសេចក្តីវិនាសដ៏អាក្រក់។ ហោរាដែលអាចមានអារម្មណ៍ដឹងពីវាមិនអាចជួយអ្វីបានក្រៅពីយំសោកនោះទេ។

(3) អ្នកប្រាជ្ញមួយរូបបាននិយាយថា ហេតុផលដែលយ៉ូហានស្រែកខ្លាំងៗគឺដោយគ្មានអ្នកណាអាចសម្រេចគម្រោងនៃសេចក្តីសង្គ្រោះបានទេ (ក្រាំងដែលបិទជិត

ជ្រាំពីរដង គឺអាចនិយាយបានថាជាគម្រោងការនៃគ្រាចុងក្រោយនៃសេចក្តីសង្គ្រោះរបស់ពួកបរិសុទ្ធ) ដែលគាត់បានរង់ចាំ។

ហេតុផលទាំងបីខាងលើគឺសមហេតុផល។ ពាក្យ "យំ" ជាភាសាក្រិក (ἔκλαιον) ជាទម្រង់អតីតកាលដែលមិនពេញលេញ ដែលវាត្រូវបានបកប្រែដោយត្រង់ថា “គាត់កំពុងយំ” យើងដឹងថាការយំរបស់គាត់គឺកំពុងកើតឡើង។

ចំពោះសំឡេងដ៏អស្ចារ្យដែលទេវតាបានហៅមក តែដោយគ្មាននរណាម្នាក់ឆ្លើយតបទៅកាន់សកលលោកទាំងមូល នោះគឺជាភាពស្ងៀមស្ងាត់ក្នុងពិភពលោកពេញដោយបាបដែលមិនអាចធ្វើអ្វីបានឡើយ។ ដូចជាមានអារម្មណ៍មួយនេះមិនអាចជួយបានក្រៅពីយំចេញមកនោះទេ។ ការយំនេះបានទទួលឥទ្ធិពលដ៏គួរឱ្យញាប់ញ័រនៅស្ថានសួគ៌ លើផែនដី និងក្រោមផែនដី។ សំឡេងយំដើម្បីប្រែចិត្តសម្រាប់ជាការថ្លូររបស់មនុស្សជាតិទាំងអស់និងអំពើបាបរបស់គេ! សំឡេងយំចង់បានការបើកសម្តែង និងសេចក្តីសង្គ្រោះ! សម្លេងទួញសោកនេះជាសម្លេងដែលមានតម្លៃដែលចូលមកដល់បល្ល័ង្ករបស់ព្រះ។ សម្លេងស្រែកហៅរបស់ទេវតាគឺអស្ចារ្យដូចជាសម្លេងទួញយំដែរ។

សត្វសិង្ហដែលកើតពីពូជអំបូរយូដា នេះជាពាក្យដែលគាត់បានសរសេរដោយរក្សាទុកនៅក្នុងចិត្តនូវ លោកុប្បត្តិ 49: 9, 10។ យ៉ាកុបបានថ្លែងទំនាយថា ព្រះមេស៊ីនឹងប្រសូត្រពីកុលសម្ព័ន្ធយូដា “យូដាជាកូនសិង្ហ”។

… វាបានក្រាបចុះ បានដេកដូចជាសិង្ហ នោះតើនរណាហ៊ានដាស់វា?” យោងតាមការសម្រេចបំពេញនូវទំនាយនេះ ព្រះយេស៊ូវពិតជាបានប្រសូត្រមកនៅក្នុងពូជសាសន៍យូដាមែន។ (ហេព្រើរ 7:14) “សិង្ហ” ជានិមិត្តសញ្ញានៃអ្នកដែលយកឈ្នះ ហើយអ្នកដែលមានជ័យជំនះជាតំណាងរបស់ព្រះមេស៊ី។ លោកុប្បត្តិ 3:15 បានទាយពីព្រះមេស៊ីថា “ពូជនាងនឹងកិនក្បាលឯង ហើយឯងនឹងចឹកកែងជើងគេ”។ “ការកិនក្បាលពស់” មានន័យថាការយកជ័យជំនះរបស់ព្រះមេស៊ី។ សាវកប៉ុលក៏និយាយនៅក្នុង

ន័យបញ្ជាក់ពីព្រះវិញ្ញាណបរិសុទ្ធ “ព្រះនៃសេចក្តីសុខសាន្ត នៅបន្តិចទៀតទ្រង់នឹងកិនអារក្សសាតាំង នៅក្រោមជើងអ្នករាល់គ្នាហើយ សូមឱ្យអ្នកបានប្រកបដោយនូវព្រះគុណនៃព្រះយេស៊ូវគ្រីស្ទ។” (រ៉ូម 16:20) ជាពាក្យដែលគាត់តែងតែនិយាយនៅក្នុងគំនិតរបស់គាត់។ បន្ទាប់ពីទំនាយនៃ លោកុប្បត្តិ 3:15 រាស្ត្រដែលត្រូវបានជ្រើសរើសនៅក្នុងគ្រាចាស់បានរងចាំនូវអង្គដែលមានជ័យជំនះដែលជាព្រះមេស៊ី។ ពួកហោរាបានប្រៀបធៀបព្រះមេស៊ីទៅនឹងសិង្ហ (លោកុប្បត្តិ 49:9, 10) ឬ ហៅទ្រង់ថាជាស្តេច (មីកា 5:2)។

ឫសកែវនៃហ្លួងដាវីឌ ត្រូវបានហៅថាជាឫស ដែលនឹងត្រូវកាត់ចេញនូវភាពជាស្តេចរបស់ដាវីឌ។ លំនាំនៃភាពជាស្តេចរបស់ដាវីឌត្រូវបានកាត់ចេញតាំងពីយូរលង់មកហើយ វាត្រូវបានបន្តដោយព្រះយេស៊ូវគ្រីស្ទវិញម្តងទៀត (ខាងវិញ្ញាណ) យោងតាម អេសាយ 11:1, 10, វិវរណៈ 22:16 រ៉ូម 12:12។

ទ្រង់បានឈ្នះ នេះជានិមិត្តរូបរបស់ព្រះមេស៊ី (លោកុប្បត្តិ 3:15) គឺថា ទ្រង់បានយកឈ្នះដោយការឆ្កាងនៅលើឈើឆ្កាង និងកិច្ចការនៃការប្រោសលោះដែលត្រូវបានសម្រេចដោយការឆ្កាងនោះផង។ (កូឡុស 2:14, 15)។ ជ័យជំនះនេះគឺជាការយកឈ្នះលើសាតាំង ជាអំណាចនៃអំពើបាប និងសេចក្តីស្លាប់ និងលោកិយនេះ។ យោងតាម លូកា 10:18, យ៉ូហាន 14:30, 12:31 វិវរណៈ 1:18។ គឺបែបដូច្នោះហើយដែលជាអ្នកដែលមានជ័យជំនះ ជាព្រះមេស៊ីដែលនឹងក្លាយជាអង្គផ្សះផ្សារវាងព្រះនិងមនុស្ស បង្ហាញពីអាថ៌កំបាំងរបស់ព្រះដល់រាស្ត្រដែលត្រូវបានជ្រើសរើសរបស់ទ្រង់ ហើយពីការបើកសម្តែងរបស់ទ្រង់វិញ ទ្រង់ធ្វើសម្រេចសេចក្តីសង្គ្រោះដូចអ្វីដែលព្រះគម្ពីរបង្រៀននោះ។ យោងតាម ហេព្រើរ 7:26-28។

គឺជាឫសកែវនៃហួងដាវីឌទ្រង់បានឈ្នះ ហើយអាចនឹងបកត្រាទាំងប្រាំពីរ បើក្រាំងនោះបាន។ ការពិតដែលព្រះគ្រីស្ទបានទទួលក្រាំង និងត្រាប្រាំពីរ និងបើកវាផងមានអត្ថន័យនៃការបើកសម្តែង ក៏ដូចជាមានន័យក្នុងការធ្វើតាមអត្ថន័យនៃការបើកសម្តែងនោះផង។ ដូច្នេះ ការនេះមានន័យថា ព្រះគ្រីស្ទទ្រង់បើកសម្តែង ទ្រង់សង្គ្រោះ និងជំនុំជំរះផង។ នោះមួយអង្គដែលអាចធ្វើការទាំងបីបានគឺមានតែព្រះគ្រីស្ទប៉ុណ្ណោះ។ ពីព្រោះព្រះគ្រីស្ទជាព្រះអង្គដែលផ្សះផ្សា។ ទ្រង់ដែលជាព្រះបានយាងមកតាមពូជរបស់ដាវីឌ (បានក្លាយជាមនុស្ស) បានទ្រាំទ្របន្ទុលរបស់យើង ហើយបានឈរមាំនៅចំពោះព្រះ ទ្រង់ជាមួយអង្គដែលមានទំនួលខុសត្រូវលើការបើកសម្តែង សេចក្តីសង្គ្រោះ និងការជំនុំជំរះ។

6 ដែលឈរនៅកណ្តាលបល្ល័ង្ក និងតួមានជីវិតទាំង4 ហើយនៅកណ្តាលពួកចាស់ទំទាំងប៉ុន្មាន។ យោងតាមការបកស្រាយនៃ វិវរណៈ 4:2, 4, 6។ ខ្ញុំបានឃើញកូនចៀមមួយឈរ ជារូបតំណាងថា កូនចៀមមិនឈរនៅខាងក្រៅពួកចាស់ទំទេ តែឈរនៅក្នុងចំណោម (μέσῳ) ពួកគេ បង្ហាញពីលក្ខណៈនៃអង្គផ្សះផ្សារបស់គាត់។ “កូនចៀម” ជាអាហារដែលពួកអ៊ីស្រាអែលបរិភោគនៅក្នុងពិធីបុណ្យរំលង ដែលវាជាដង្វាយប្រោសលោះ។ ដូច្នេះ ការនេះចង្អុលថាព្រះយេស៊ូវគ្រីស្ទ ជាអង្គដែលបានលោះថ្លៃបាប។ យោងតាម យ៉ូហាន 1:29, 36, អេសាយ 53:។ នៅទីនេះថា “កូនចៀម” ខុសពីវា (ἀμνὸς= amnos) នៅក្នុង យ៉ូហាន 1:29 ប៉ុន្តែ អារនៀន (ἀρνίον) វាជាពាក្យតូចមួយ។ គោលបំណងនៅទីនេះដែលប្រើពាក្យតូចនោះគឺ ដើម្បីនឹងសង្កត់ទៅភាពទន់ភ្លន់របស់ព្រះគ្រីស្ទ ភាពសុភាពរាបសារ សេចក្តីស្រឡាញ់ដ៏ពេញដោយការលះបង់របស់ទ្រង់។ (ហ្វ្រេដដានុស, de idee van het teedere, zachte, overgegevene, lidf devolle, te accentueeren)។ ការបើកសម្តែងដែលចង្អុលទៅកាន់ព្រះយេស៊ូវជាសិង្ហ នៅទីនេះ ភ្លាមនោះជាការបើកសម្តែងដើម្បីបង្ហាញកូន

ចៀមដែលមានន័យ។ ព្រះមេស៊ីជាអង្គដែលមានជ័យជំនះដូចជាសិង្ហ គោលការណ៍នៃសកម្មភាពរបស់ទ្រង់មិនមែនដូចជាសិង្ហទេ តែដូចជាកូនចៀមវិញ។ ទ្រង់បានថ្វាយអង្គទ្រង់ជាដង្វាយទៅកាន់ព្រះជាកូនចៀម ហើយទ្រង់បានទ្រាំទ្រឈើឆ្កាង ហើយបានក្លាយជាអ្នកមានជ័យជំនះដូចជាសិង្ហ។ ដោយសារពួកយូដាដែលមិនជឿបានដឹងថា គោលការណ៍នៃសកម្មភាពរបស់ព្រះមេស៊ីដូចជាតោ គឺនឹងដូចជាមួយអង្គដែលនឹងកាន់សិទ្ធិអំណាចរបស់លោកិយនេះ នោះពួកគេបានយល់ខុស តែយ៉ូហានបានស្វែងរកព្រះអង្គដែលជាអ្នកមានជ័យនេះ ចេញពីមួយអង្គដែលត្រូវបានថ្វាយជាដង្វាយប្រោសលោះដូចជាកូនចៀមមួយនេះ។ អ្នកជឿលើសាសនាគ្រីស្ទទាំងអស់ស្វែងរកព្រះមេស៊ីតាមពួកសាវក។ ព្រះមេស៊ី (ព្រះគ្រីស្ទ) ទ្រង់ពិតជាបានធ្វើសម្រេចសេចក្តីសង្គ្រោះដែលទ្រង់ដូចជាកូនចៀម។ ម៉ាថាយ 12:18-21 មានបន្ទូលពីព្រះមេស៊ីថា “ “Behold, my servant whom I have chosen, my beloved with whom my soul is well pleased. I will put my Spirit upon him, and he will proclaim justice to the Gentiles. He will not quarrel or cry aloud, nor will anyone hear his voice in the streets; a bruised reed he will not break, and a smoldering wick he will not quench, until he brings justice to victory; and in his name the Gentiles will hope.” កិច្ចការ 8:32-33 មានបន្ទូលពីព្រះមេស៊ីថា “said to the messiah, “Now the passage of the Scripture that he was reading was this: “Like a sheep he was led to the slaughter and like a lamb before its shearer is silent, so he opens not his mouth. In his humiliation justice was denied him. Who can describe his generation? For his life is taken away from the earth.”

យោងតាមទ្រឹស្តីនៅទីនេះការប្រើពាក្យតូចថា “កូនចៀម” (ἀρνίον) រាប់បញ្ចូលទាំងអត្ថន័យនៃភាពជិតស្និត។ (បេងហ្គាល) ដ្បិតព្រះគ្រីស្ទបានសុគតសម្រាប់យើង ពេលនេះទ្រង់គង់នៅស្ថានសួគ៌ និងមានទំនាក់ទំនងយ៉ាងជិតស្និតជាមួយយើង។

ដែលមើលទៅដូចជាបានសំឡាប់ហើយ ឃ្លានេះបញ្ជាក់ន័យពាក្យថា “ឈរ” នៅខាងលើ។ នោះគឺថា កាលដែលទ្រង់ឈរ តែធ្វើដូចជាបុគ្គលដែលបានស្លាប់។ គឺវាមានន័យថា ទ្រង់មានសញ្ញាថា ទ្រង់បានសុគតពីមុនមក។ (ឆាលស៍, ὡς ἐσφαγμένον, ឧទាហរណ៍ បើទោះជាត្រូវគេធ្វើឃាតនៅក្នុងការថ្វាយដង្វាយ ហើយតែនៅតែរក្សារូបរាងនៃសេចក្តីស្លាប់ របួសនៅលើរាងកាយ)។ នេះជាការបង្ហាញនិមិ្តតសញ្ញាដែលបង្កើតគុណសម្បត្តិនៃការជំនួសដោយហេតុការណ៍ដែលព្រះគ្រីស្ទបានសុគតនៅលើឈើឆ្កាងបង្ហាញពីប្រសិទ្ធិភាពនៅក្នុងស្ថានសួគ៌។ និយាយមួយបែបទៀតថា ព្រះគុណនៃការសុគតរបស់ទ្រង់ដោយការស្តាប់បង្គាប់ព្រះ និងបានទ្រាំទ្រឈើឆ្កាងនៃការប្រោស ហើយបានសុគតនៅក្នុងលោកិយដែលនឹងមកដល់អស់កល្បជានិច្ច។ ដូច្នេះ នេះជាសេចក្តីប្រោសលោះ សេចក្តីសុចរិត សេចក្តីបរិសុទ្ធ និងប្រាជ្ញាអស់កល្បជានិច្ចរបស់យើង។ (1កូរិនថូស 1:30)។

ស្នែងប្រាំពីរ នេះជានិមិ្តតសញ្ញានៃសិទ្ធិអំណាចបរិសុទ្ធពេញលេញ និងអំណាចដែលព្រះគ្រីស្ទបានសុគតនៅលើឈើឆ្កាង និងមានព្រះជន្មរស់ឡើងវិញ ហើយបានយាងឡើងទៅស្ថានសួគ៌។ យោងតាម 2:9-11, កិច្ចការ 2:36, ម៉ាថាយ 11:27, 28:18។

និងភ្នែកប្រាំពីរ យោងតាម សាការី *3:9, 4:10* នេះជាសញ្ញានៃព្រះវិញ្ញាណបរិសុទ្ធដូចដែលយើងឃើញនៅក្នុងឃ្លាខាងក្រោម ព្រះវិញ្ញាណបរិសុទ្ធដើរជាមួយព្រះបរិសុទ្ធ ហើយទ្រង់ការដើរជាមួយនឹងព្រះរាជបុត្រាផង (អេសាយ 11:2, 4:1)។ បន្ទាប់ពីព្រះ

រាជបុត្រាបានយាងឡើងទៅស្ថានសួគ៌ ទ្រង់បានចាត់ព្រះវិញ្ញាណបរិសុទ្ធមកកាន់យើងជាវិធីសាស្ត្រពិសេស (កិច្ចការ ជំពូក 2) ហើយបានធ្វើឱ្យព្រះវិញ្ញាណបរិសុទ្ធប្រកាសពីអង្គទ្រង់ ពាក្យនេះនៅក្នុងខនេះចង្អុលទៅកាន់ចំណុចនេះ។ (យ៉ូហាន 14:26, 15:26, 16:8, 13-15)។

ហើយបានយកក្រាំង ពាក្យនេះគឺ អេលេហ្វេន (ἐλεηφεν) នៅក្នុងភាសាក្រិក នៅក្នុងបច្ចុប្បន្នកាលកំពុងបន្ត ដែលមានន័យមានក្រាំងដែលទ្រង់បានយកមកនោះអស់កល្បជានិច្ច។ ព្រះគ្រីស្ទមិនបានយកការបើកសម្តែងរបស់ព្រះជាបណ្តោះអាសន្នទេ តែយកជាអចិន្ត្រៃយ៍វិញ។

ទាំងកាន់ស៊ុង និងពានមាសដែលពេញដោយគ្រឿងក្រអូបវៀងខ្លួន “ស៊ុង” ជាឧបករណ៍ដែលសម្រាប់ថ្វាយចំរៀងនៃការអរគុណ “ពានមាស” ផ្តោតលើគ្រឿងក្រអូបដែលនៅក្នុងនោះ “គ្រឿងក្រអូប” ជាសញ្ញាសម្គាល់នៃការអធិស្ឋានរបស់ពួកបរិសុទ្ធដែលអត្ថបទនិយាយ។ គ្រឿងក្រអូបនេះជាការអធិស្ឋានរបស់ពួកបរិសុទ្ធ វាបង្ហាញដែរថា ព្រះទ្រង់សព្វព្រះទ័យនឹងការអធិស្ឋានរបស់ពួកបរិសុទ្ធដូចជាក្លិនក្រអូបដែរ។ ការអធិស្ឋានមិនត្រឹមតែមានតម្លៃទៅចំពោះព្រះដូចជាគ្រឿងក្រអូបទេ វាក៏ដូចជាគ្នាទៅចំពោះពួកបរិសុទ្ធផ្ទាល់ដែរ។ អ្នកជឿពិតរីករាយនឹងពេលវេលាអធិស្ឋាន ហើយវាដូចជាក្លិនក្រអូប ហើយនៅពេលណាដែលគេស្តាប់ទៅកាន់ការអធិស្ឋានរបស់អ្នកដទៃក៏មានអារម្មណ៍ពីក្លិនក្រអូបដូចគ្នា។

ច្រៀងទំនុក1ថ្មីថា នេះជាការសរសើរដំកើងថ្មីដែលចេញមកពីបទពិសោធន៍ថ្មីនៃសេចក្តីសង្គ្រោះ។

ចេញពីគ្រប់ទាំងពូជមនុស្ស។ ពូជមនុស្សត្រូវបានរក្សានៅក្នុងគំនិត នូវលោហិតដើម ភាសាចង្អុលទៅកាន់មនុស្សនៃភាសាសាមញ្ញធម្មតាដូចគ្នាដោយមិនមានទាក់ទងទៅនឹងទស្សនៈនៃពូជ។ ហើយមនុស្សជាក្រុមដែលប្រមូលផ្តុំតាមនយោបាយនៃមនុស្ស ហើយជាតិសាសន៍ជាក្រុមដែលមានទម្លាប់ស្រដៀងគ្នានៃជីវិត (H. Cremer – J Kogel. Worterbuch de Neutest. Grazitat)។ វាពិបាកនឹងអះអាងថានិយមន័យខាងលើជាក់លាក់ណាស់។ យើងប្រាកដថាពាក្យទាំងបួនខាងលើគ្របដណ្តប់មនុស្សទាំងអស់។ កាលដែលព្រះទ្រង់សង្គ្រោះមនុស្ស ទ្រង់មិនបានធ្វើដោយមិនយុត្តិធម៌នោះទេ។ ប៉ុន្តែពាក្យខ្ញុំមិនមានន័យថាព្រះទ្រង់សង្គ្រោះមនុស្សទាំងអស់ដោយមិនខ្វល់អ្វីសោះនោះទេ។ ពាក្យខាងក្រោមវា ពីគ្រប់ជាតិសាសន៍ និងភាសា និងមនុស្ស និងជនជាតិ នៅក្នុងចំណោម (ἐκ) ចង្អុលទៅកាន់សេចក្តីសង្គ្រោះដែលបានរើសតាំង។ ព្រះទ្រង់មិនបែងចែករវាងជាតិសាសន៍ និងជនជាតិអ្វីនោះទេ តែការពិតដែលទ្រង់បានសង្គ្រោះពួកដែលទ្រង់បានរើសតាំងគឺ ជាអ្វីដែលគ្រប់ផ្នែកនៃបទគម្ពីរបានបង្រៀនយើងយ៉ាងទៀងទាត់។

ហើយទ្រង់បានលោះយើងរាល់គ្នាដោយព្រះលោហិតទ្រង់ថ្វាយដល់ព្រះ ពាក្យនេះជាខួរឆ្អឹងនៃដំណឹងល្អ។ អ្នកជឿពិតមិនស្វែងរកថាព្រះស្វែងរកដោយទទេរនោះទេ តែផ្តល់តម្លៃយ៉ាងខ្ពស់វិញ គឺដែលព្រះទ្រង់បានបង់ថ្លៃជាលោហិតរបស់ទ្រង់។

10 ជានគរ និងជាពួកសង្ឃ សំដៅទៅលើការបកប្រែនៃ 1:6

ហើយពួកគេនឹងសោយរាជ្យលើផែនដី។ នៅទីនេះ ពាក្យថា “នឹងសោយរាជ្យ” បាស៊ីលេអាន (βασιλείαν) ជាភាសាក្រិក ជាពាក្យនៅក្នុងកាលអនាគត ដែលជាការចម្លងនៃក្រាំងឯកសារយ៉ាងសំខាន់។ នៅក្នុងឯកសារខ្លះ (A, Q) ពាក្យត្រូវបានសរសេរជា

កាលបច្ចុប្បន្ន (βασιλείαν) ម៉ូហ្វាតបានជ្រើសរើសយកទីមួយ។ កាលដែលយើងគិតពីខ្លឹមសារនៃ 20:4 (បន្ទាប់ពីពួកបរិសុទ្ធបានរស់ឡើងវិញ នោះពួកគេបានក្លាយជាស្តេច) សាកសមជាងកាលបច្ចុប្បន្ន។ លោក R. H. Chales បាននិយាយថា កាលដែលវាជាកាលបច្ចុប្បន្ន វាអាចចង្អុលទៅកាន់អត្ថន័យនៃទស្សនៈការមកដល់នៃគ្រាចុងក្រោយនៃ 20:4។

11 ហើយក៏ឮសម្លេងទេវតាជាច្រើន នៅជុំវិញបល្ល័ង្ក ព្រមទាំងតួមានជីវិត និងពួកចាស់ទុំផង នៅទីនេះ ទីតាំងរបស់ពួកទេវតានៅជុំវិញពួកចាស់ទុំដែលជាតំណាងរបស់ពួកបរិសុទ្ធនៃស្ថានសួគ៌ និងធ្វើចលនាជុំវិញ។ វាបង្ហាញថា ពួកគេជាអ្នកបម្រើដល់ពួកបរិសុទ្ធ។ វត្តមាននៃពួកទេវតាត្រូវបានបង្ហាញជាច្រើននៅក្នុងព្រះគម្ពីរ។ យើងអាចនិយាយដូចតទៅ ម៉ាថាយ 22:30, 24:36, លូកា 1:13, 9:26, 15:10 ហេព្រើរ 1:6 1ពេត្រុស 1:12, យូដាស 1:6, 9 វិវរណៈ 12:7, 14:10, លោកុប្បត្តិ 19:1 2សាំយ៉ូអែល 14:20, សាការី 1:9 ជាដើម។ យោងតាមខគម្ពីរទាំងនេះ ពួកទេវតាមានហេតុផល សីលធម៌ ចំណេះដឹង និងទង្វើពេញដោយសេចក្តីថ្លៃថ្នូ និងសេចក្តីស្រឡាញ់ ផ្គាប់ចិត្ត ការប្រយុទ្ធ ថ្វាយបង្គំ និយាយ និងទៅវិញទៅមក។ លក្ខណៈរបស់ពួកទេវតាជារូបរាងដែលត្រូវបានបង្កើតរបស់ទ្រង់។ បញ្ហានៃពេលវេលាដែលទេវតាត្រូវបានបង្កើតគឺវាពិបាកនឹងនិយាយឱ្យជាក់លាក់ណាស់។ ប៉ុន្តែ យ៉ូប 38:7 បាននិយាយថា ពួកទេវតារួមមាននៅក្នុងការបង្កបង្កើតរបស់ព្រះ។ ប៉ុន្តែវាមិនមែនជាលក្ខណៈវិនិច្ឆ័យនៃគ្រប់របស់ដែលត្រូវបានបង្កើតមកទាំងអស់នោះទេ។ ពួកទេវតាហាក់បីដូចជាត្រូវបានបង្កើតមកនៅក្នុងការបង្កើតរបស់ទាំងអស់ក្នុងពេលតែមួយ (កូឡូស 1:16, នេហេមា 9:26, 20:36, 2កូរិនថូស 11:14, 1ធីម៉ូថេ 5:21, 2ពេត្រុស 2:4, យូដាស 1:6, វិវ

រណៈ 14:10)។ ហើយពួកគេមានការបែងចែកខាងសីលធម៌ និងមានឈ្មោះជាច្រើន តាមកិច្ចការរបស់ពួកគេ ទាំងនោះមាន សេរ៉ាផីម (លោកុប្បត្តិ 3:24, និក្ខមនំ 25:18, 2សាំយ៊ូអែល 22:11, ទំនុកដំកើង 18:10, 99:1 អេសាយ 37:16 ហេព្រើរ 9:5) , សេរ៉ាភីម (អេសាយ 6:2) ហ្គាព្រីអែល និងមីកែល (ដានីយ៉ែល 8:16, 9:21, 10:13, 21, លូកា 1:19, , 20 យូដាស 1:9 វិវរណៈ 12:7)។

ឯចំនួននៃទេវតានោះ មានទាំងម៉ឺនទាំងសែន ហើយទាំងពាន់រាប់ជាពាន់

(μυριάδες μυριάδων καὶ χιλιάδες χιλιάδων) វាមានន័យថាទាំងម៉ឺនៗ និង ទាំងពាន់ទាំងពាន់។ (យោងតាម ទំនុកដំកើង 68:17, ដានីយ៉ែល 7:10, ហេព្រើរ 12:22)

12 ចេស្តា អត្ថបទភាសាក្រិកបង្ហាញពាក្យ the (τὴν) នៅផ្នែកដំបូងនៃពាក្យ។ វាចង្អុលទៅកាន់ចំណងជើងទូទៅដែលបង្កើតជាក្រុមមានការសរសើរទាំងប្រាំពីរនៅក្នុងអត្ថបទ។ កាលដែលពាក្យ the នៅជាប់នឹងការសរសើរបីមានន័យថា ជាការសរសើរគុណតម្លៃដ៏ខ្ពស់របស់ព្រះអម្ចាស់។

13 កិត្តិនាម សិរីល្អ សំដៅទៅរកការបកប្រែនៃខ 4:9. “កិត្តិយស” ជាសេចក្តីថ្លៃថ្នូនៃលក្ខណៈរបស់ព្រះអម្ចាស់ “សិរីល្អ” ជារូបភាពនៃធាតុថ្លៃថ្នូដែលចែងចាំងមកក្រៅ និង “ការសរសើរ” គឺ យូឡូហ្គៀ (εὐλογία) នៅក្នុងភាសាក្រិក គឺជាការពិតដែលសិរីល្អខាងលើត្រូវបានកត់សម្គាល់ទៅជាទេវតា និងពួកបរិសុទ្ធ និងត្រូវបានសារភាពដោយពួកគេ។

13. ខនេះគឺជាការឆ្លើយតបទាំងបួនរបស់ទេវតាចំពោះការសរសើរដល់ការសរសើរទាំងប្រាំពីររបស់ទេវតា ព្រោះបានចាប់ផ្តើមដោយការសរសើរដោយការទទួលពាក្យ «សរសើរ» វាបង្ហាញពីចរិតនៃការឆ្លើយតប។ ហើយដែលយើងផ្តោតលើការពិតដែលថាភាគីទាំងពីរសរសើរការពិតដែលថាព្រះគ្រីស្ទបានសុគតហើយត្រូវបានលើកតម្កើង។ ទេវតាបាននិយាយថា "កូនចៀមបានស្លាប់" ហើយគ្រប់ទាំងរបស់ដែលត្រូវបានបង្កើតមកទាំងអស់សរសើរដល់កូនចៀម (អ្នកដែលត្រូវបានថ្វាយជាយញ្ញបូជា) ។

និងគ្រប់ទាំងអស់ដែលនៅស្ថានទាំងនោះនិយាយថា មិនមែនជាពាក្យដែលចេញពីគោលការណ៍នៃធាតុដូចគ្នានៃសម្ភារៈ និងខ្លួនទេ ដែលរបស់ដែលបានបង្កើតមកទាំងអស់ជាពិភពខាងវិញ្ញាណដែលអាចទំនាក់ទំនងជាមួយយើង។ បទគម្ពីរគិតយ៉ាងច្បាស់ពីការពិតដែលគ្មានៃរបស់ដែលត្រូវបានបង្កើតមកនិងព្រះ និងបានបែងចែកគ្រប់របស់ដែលត្រូវបានបង្កើតមកទាំងអស់និងមនុស្សយ៉ាងច្បាស់។ នៅក្នុងលោកុប្បត្តិជំពូក 3 ការពិតដែលសត្វពស់និយាយជាមួយមនុស្សគឺមិនត្រូវបានធ្វើឡើងដោយសត្វពស់ខ្លួនឯងឡើយ តែដោយការដឹកនាំរបស់អារក្ស។ ហើយអ្វីដែលសត្វលានិយាយនៅក្នុងជនគណនា គឺវាមិនបាននិយាយដោយខ្លួនវាឡើយ តែដោយចេស្តារបស់ព្រះតែមួយគត់។ នៅក្នុងសាច់រឿងបុរាណរបស់កូរ៉េ រឿងដែលបុរសចំណាស់ត្រូវប្រែទៅជាសត្វខ្លា ឬចចក ឬសត្វបែបនោះដែលទំនាក់ទំនង និងនិយាយជាមួយមនុស្ស គឺវាចេញមកពីទ្រឹស្តីនៃធាតុដូចគ្នានៃសម្ភារៈ និងរូបកាយ ដែលនោះជា ជំនឿលើព្រះច្រើនប្រភេទ។ នៅក្នុងការបើកសម្តែងរបស់បទគម្ពីរ ពាក្យដែលថាគ្រប់របស់ដែលត្រូវបានបង្កើតមកនិយាយគឺជា ការយកលក្ខណៈរបស់មនុស្សមករៀបរាប់ពីព្រះ (anthropomorphism)។

នេះគឺជាពាក្យដែលគ្រប់របស់ដែលត្រូវបានបង្កើតមកទាំងអស់ធ្វើចលនាដោយ
ឆ្លើយតបទៅនឹងការរីវត្តនៃសកលលោក។ (រ៉ូម 8:19)។

ចំណុចសំខាន់

1. ការយំសោកយ៉ាងខ្លាំងដែលយ៉ូហានមានត្រូវកើតឡើងដល់យើង យើងយំដោយសារការរងទុក្ខនៃរូបកាយរបស់យើង។ ហើយយើងក៏យំសោកចំពោះការបាត់បង់ទ្រព្យសម្បត្តិរបស់យើង ការស្លាប់របស់កូនយើង ជំងឺ និងទុក្ខលំបាករបស់យើង។ សុទ្ធតែជាការយំសោករបស់ក្មេងតូច។ យ៉ូហានបានស្រែកឡើង ដោយសារគាត់មិនអាចឃើញអ្នកណាម្នាក់ទទួលកណ្ឌគម្ពីរវិវរណៈ ហើយបើកវាបានឡើយ ។ វាជាការយំសោកចំពោះទុក្ខវេទនានៃមនុស្សជាតិទាំងអស់ដែលបានបាត់បង់ព្រះបន្ទូលដែលស្រែកហៅចេញពីស្ថានសួគ៌ ព្រោះវាដាច់ស្រយាលសម្រាប់អំពើបាប ហើយឯកោសម្រាប់វា។ វាពិតជាការយំដ៏អស្ចារ្យសម្រាប់សកលលោក និងពិភពលោកទាំងមូលនិងការយំដ៏បរិសុទ្ធសម្រាប់អំពើបាបរបស់មនុស្ស។(ខ 4)

2. ចំពោះកិច្ចការដែលកូនចៀម គឺព្រះយេស៊ូវគ្រីស្ទបានធ្វើ គ្មានរបស់ដែលត្រូវបានបង្កើតមកមួយណាមិនសរសើរទ្រង់បានឡើយ។ ដោយសារកិច្ចការរបស់ទ្រង់បានប្រោសមនុស្សទាំងអស់ដែលនៅស្ថានសួគ៌ និងផែនដី និងបានស្តារឡើងវិញ។ (កូឡុស 1:20)។ ដូច្នេះ ព្រះយេស៊ូវមានបន្ទូលថា “ខ្ញុំបានសូមអង្វរឱ្យពួកសិស្សលោកដេញចេញដែរ តែគេដេញមិនបានសោះ។” (លូកា 9:40)។ ការពិតដែលយើងគួររីករាយភាគច្រើនគឺការមានអ្នកសំដែងឡើងវិញ ដែលជាអ្នកប្រោសលោះនៅក្នុងយើង។ ប៉ុន្តែយើងបំភ្លេចព្រឹត្តិការណ៍ដ៏អស្ចារ្យនេះ ប៉ុន្តែរីករាយនឹងការធ្លាក់ចូលទៅក្នុងភាពរីករាយដ៏តូចមួយនៃលោកិយ។ ជំពូកនេះរួមបញ្ចូលទាំងការយំសោកយ៉ាងខ្លាំង

និងការត្រេកអរជាខ្លាំង ការយំសោកយ៉ាងខ្លាំងគឺសេចក្តីទួញសោករបស់លោកយ៉ូហាន ដែលជាការទួញសោកដើម្បីស្រែកដោយសារអំពើបាបរបស់លោកិយ។ ហើយសេចក្តីអំណរដ៏អស្ចារ្យគឺជាសេចក្តីអំណរនៃសកលលោកទាំងអស់ដែលការបើកសម្តែងពេញដោយព្រះគុណរបស់ព្រះគ្រីស្ទ និងការប្រោសលោះ (សកម្មភាពនៃការប្រោសលោះដោយការទទួលត្រាបិទជិតទាំងប្រាំពីរ គឺជាសកម្មភាពដើម្បីសង្គ្រោះពួកបរិសុទ្ធ)។ (7-14)

3. ដើម្បីឱ្យមានការអធិស្ឋានដូចជាក្លិនក្រអូប។ ក្លិនក្រអូបដែលបំបាត់ក្លិនស្អុយ ហើយធ្វើឱ្យចំណងមេត្រីភាពរវាងមនុស្ស និងមនុស្សមានក្លិនក្រអូប។ មូលហេតុដែលកូនក្រមុំយកក្លិនក្រអូបនោះ គឺដើម្បីរក្សាចំណងស្នេហ៍ជាមួយកូនកំលោះ ហើយធ្វើផ្ទះឱ្យក្រអូប។ ហើយម្យ៉ាងទៀត ពិភពធម្មជាតិ ហេតុផលដែលផ្កាមានសក់ក្រង គឺដើម្បីទាញមេអំបៅ និងឃ្មុំចូលទៅក្នុងផ្កា ដូចដែលយើងមានការអធិស្ឋានបែបនេះ ព្រះជាម្ចាស់ចង់បានការប្រកបជាមួយយើង ហើយមករកយើង និងរស់នៅជាមួយយើង ព្រះសព្វព្រះទ័យឱ្យពួកបរិសុទ្ធបានពេញដោយការអធិស្ឋាន ហើយគង់នៅជាមួយនឹងពួកបរិសុទ្ធដើម្បីឱ្យបានពេញដោយការអធិស្ឋាន។ យើងគួរប្រយ័ត្នចំណុចនេះ “ត្រូវតែបានពេញ” កាលណាយើងគ្មានការអធិស្ឋាន យើងក្លាយជាមនុស្សមានក្លិនមាត់។ ដើម្បីបំបាត់ក្លិនស្អុយនៅក្នុងខ្លួនយើង យើងមិនគួរអធិស្ឋានតិចតួចទេ មានតែយើងគួរតែយកការអធិស្ឋានពេញលេញតែមួយប៉ុណ្ណោះ។ ដូច្នេះ បទគម្ពីរសង្កត់ថា កណ្ឌគម្ពីរដំណឹងល្អ និងសំបុត្រទាំងអស់ផងបានបង្គាប់ថា “ចូរអធិស្ឋានឥតឈប់ឈរ”។ (8-10)

ការអធិប្បាយ

ការអធិប្បាយទី 19 មានតែព្រះគ្រីស្ទទេដែលជាអង្គដែលផ្សះផ្សា (វិវរណៈ 5:1-14)

1. ព័ន្ធកិច្ចរបស់អង្គដែលផ្សះផ្សា

ពាក្យថា “អ្នកផ្សះផ្សា” មិនត្រូវបានបង្ហាញនៅក្នុងអត្ថបទទេ ពីព្រោះកិច្ចការរបស់ព្រះយេស៊ូវគ្រីស្ទដែលបានធ្វើត្រូវបានកត់ទុកនៅទីនេះ វាជាកិច្ចការរបស់ព្រះដែលផ្សះផ្សា។ ដែលជា (1) កាលដែលគ្មានអ្នកណាអាចទទួលវា និងបើកក្រាំងដែលបិទដោយត្រាទាំងប្រាំពីរបាន នោះទ្រង់បានទទួលវានិងបើកវាផង។ នេះជាកម្មភាពនៃការបើកសម្តែងដែលបានបើកគម្រោងការនៃការសង្គ្រោះរបស់ព្រះ និងបើកបង្ហាញ និងអនុវត្តគម្រោងការនោះ។ (2) ខ 6 បាននិយាយថា ទ្រង់ក្រោកឈរឡើង (គឺថាទ្រង់បានក្រោកឈរឡើងនៅក្នុងឋានៈជាអ្នកជួយជាមួយនឹងពាក្យជំនួស) និងដូចនោះ។ នេះក៏ជាធាតុដែលសាកសមរបស់អង្គផ្សះផ្សា។ ព្រះយេស៊ូវគ្រីស្ទជាព្រះផ្សះផ្សាដែលព្រះទ្រង់ទុកចិត្ត និងបានតែងតាំង។ តើវាត្រឹមត្រូវទេដែលមនុស្សមិនទុកចិត្តទ្រង់នោះ?

2. ការទួញសោករបស់សាវកយ៉ូហាន

ខ4 បាននិយាយថា យ៉ូហានបានយំយ៉ាងខ្លាំង។ ហេតុផលដែលគាត់យំគឺជាការពិតដែលគ្មាននរណាម្នាក់បានបើកនូវក្រាំងដែលបិទដោយត្រាប្រាំពីរនោះបាន។ និយាយម៉្យាងទៀត អង្គដែលផ្សះផ្សានមិនបានបង្ហាញមកឱ្យគាត់ឃើញឡើយ។ គ្មានអង្គផ្សះផ្សា នោះយើងមិនអាចត្រូវបានរំដោះឱ្យរួចពីសេចក្តីស្លាប់បានឡើយ។ (ហេព្រើរ 2:5)។ មុនពេលយើងជួបនឹងព្រះផ្សះផ្សាតែមួយ យើងគួរតែត្រូវធ្លាក់ទៅក្នុងសភាពនៃការទួញសោក គឺយើងគួរតែស្រែកយំឡើង។ បន្ទាប់ពីយើងបានជឿដល់ព្រះយេស៊ូវ

កាលដែលទ្រង់បានចាកចេញពីយើង នោះយើងគួរតែស្រែកយំឡើង។ នេះជាការទួញសោកខាងវិញ្ញាណ។ កាលដែលយើងយំដោយទឹកភ្នែកខាងវិញ្ញាណ នោះយើងអាចទទួលបានជីវិតពិត។ លូកា 6:21 មានបន្ទូលថា “មានពរហើយ អ្នករាល់គ្នាដែលឃ្លានឥឡូវនេះ ដ្បិតអ្នករាល់គ្នានឹងបានឆ្អែត មានពរហើយ អ្នករាល់គ្នាដែលយំឥឡូវនេះ ដ្បិតអ្នករាល់គ្នានឹងបានសើចវិញ”។

3. អំណរដោយការបង្ហាញនូវព្រះអង្គដែលផ្សះផ្សា

កាលដែលអង្គផ្សះផ្សាបានបង្ហាញមក នោះពួកបរិសុទ្ធនិងរបស់ដែលបង្កើតមកទាំងអស់បានសរសើរដំកើងឡើង។ ពិតណាស់នេះជាសេចក្តីអំណរនៃសកលលោក។ (7-14) ព្រះយេស៊ូវគ្រីស្ទជាកម្មវត្ថុនៃសេចក្តីអំណរដ៏អស្ចារ្យនេះ។ (1) ហេតុផលដែលពួកបរិសុទ្ធត្រូវបានបង្ហាញមកជាតំណាងដោយចាស់ទុំ 24 នាក់ ដែលគួរតែរីករាយជាការពិតដែលពួកគេមានបទពិសោធន៍នូវសេចក្តីសង្គ្រោះ។ បទពិសោធន៍នៃសេចក្តីសង្គ្រោះផ្តល់សេចក្តីរីករាយដោយមិនចេះរលួយ។ ពួកគេច្រៀងចំរៀងថ្មី វាមានន័យថាពាក្យដែលថាការភ្លក្សភាពថ្មីជានិច្ច។ អ្នកដែលមានបទពិសោធន៍នូវសេចក្តីសង្គ្រោះរីករាយនឹងសេចក្តីរងទុក្ខវេទនា។ រ៉ូម 5:3 មានបន្ទូលថា “មិនតែប៉ុណ្ណោះសោត យើងនៅតែអួតក្នុងកាលដែលមានទុក្ខលំបាកដែរ ដោយដឹងថា សេចក្តីទុក្ខលំបាកបង្កើតឱ្យមានសេចក្តីទ្រាំទ្រ”។ (2) ហេតុផលដែលពួកទេវតាក៏រីករាយគឺជាការពិតដែលពួកគេបានមើលទៅកាន់សេចក្តីសង្គ្រោះដែលពួកបរិសុទ្ធបានទទួលដោយអស្ចារ្យខ្លាំងពេក។ 1ពេត្រុស 1:12 មានបន្ទូលថា “តែទ្រង់បានសំដែងឱ្យគេដឹងថា សេចក្តីទាំងនោះមិនមែនសំរាប់គេទេ គឺសំរាប់យើងរាល់គ្នាវិញ គឺជាសេចក្តីទាំងប៉ុន្មាន ដែលឥឡូវនេះ ពួកអ្នកផ្សាយដំណឹងល្អបានប្រាប់មកអ្នករាល់គ្នា ដោយព្រះវិញ្ញាណបរិសុទ្ធ ដែលទ្រង់បានចាត់ពីស្ថានសួគ៌មក ហើយពួកទេវតាក៏ចូលចិត្តចង់ពិនិត្យមើលសេចក្តីទាំងនោះ

ដែរ”។ (3) ហេតុផលដែលគ្រប់របស់ដែលបង្កើតមកទាំងអស់រីករាយគឺជាការពិត ដែលពួកគេទន្ទឹងរងចាំសេចក្តីសង្គ្រោះរបស់ពួកបរិសុទ្ធ ជាចុងក្រោយពួកគេបានឃើញរូបរាងដែលសិរីល្អនឹងត្រូវបានបង្ហាញមក។ រ៉ូម 8:18 មានបន្ទូលថា “ញុំរាប់អស់ទាំងសេចក្តីទុក្ខលំបាកនៅជាន់នេះ ថាជាសេចក្តីមិនគួរប្រៀបផ្ទឹមនឹងសិរីល្អ ដែលនឹងបើកសំដែងមកឱ្យយើងរាល់គ្នាឃើញនោះទេ”។

ការអធិប្បាយទី 20 កិច្ចការនៃឫសរបស់ដាវីឌ (វិវរណៈ 5:5,6) (ផ្ទៀងផ្ទាត់នឹង អេសាយ 53:2)

ឫសរបស់ដាវីឌជារូបតំណាងពីព្រះមេស៊ីជា “មែក ឬជាត្រួយ” ដែលចេញមកពីធាងដែលនៅសល់របស់ភាពជាស្តេចរបស់ដាវីឌដែលត្រូវបានកាត់ចេញ (Am 9:1)។ ពួកយូដា ជាអ្នកដែលមិនជឿក៏បានចង្អុលទៅកាន់ព្រះមេស៊ី ហើយនិយាយថា “កូនប្រុសនៃអ្នកដែលត្រូវបំផ្លាញ”។ វាសាកសមដែលថា ត្រួយដែលវេទនានិងខ្សោយជាតំណាងនូវការយាងមកជាលើកទីមួយរបស់ព្រះយេស៊ូវ។ បើទោះជាត្រួយខ្សោយ តែវាបានលូតលាស់ឡើងជានិច្ច។ ប្រៀបដូចជាកិច្ចការនៃការយាងមកលើកទីមួយរបស់ព្រះយេស៊ូវគ្រីស្ទមិនមែនជាវិធីសាស្ត្រសម្រាប់នឹងទទួលយកសិរីល្អនិងអំណាចទេ តែបង្ហាញពីស្ថានភាពដែលវេទនា ជាកិច្ចការនៃព្រះវិញ្ញាណបរិសុទ្ធដែលលាក់កំបាំងវិញ។

គោលការណ៍នេះត្រូវបានបើកសម្តែងនៅក្នុង អេសាយ 11:1, 2 “មានលំពង់1នឹងដុះចេញពីគល់របស់អ៊ីសាយហើយមែក1 ដែលចេញពីឫសគាត់ នឹងកើតមានផលផ្លែ។ ព្រះវិញ្ញាណនៃព្រះយេហូវ៉ា នឹងសណ្ឋិតនៅលើអ្នកនោះ គឺជាព្រះវិញ្ញាណនៃ

ប្រាជ្ញានឹងយោបល់ ជាព្រះវិញ្ញាណនៃគំនិតវាងវៃ និងឫទ្ធានុភាព ជាព្រះវិញ្ញាណនៃសេចក្តីចេះដឹង និងសេចក្តីកោតខ្លាចដល់ព្រះយេហូវ៉ា”។ បទគម្ពីរទាំងនេះបានបើកសម្តែងការបម្រើទាំងសងខាងនៃដំណឹងល្អរបស់ព្រះគ្រីស្ទ។ ទីមួយ វាគឺជាការរងទុក្ខដែលទ្រង់ត្រូវបានប្រព្រឹត្តមកលើដោយមនុស្សទន់ខ្សោយដូចជាពន្លកនៅក្នុងពិភពលោក។ ហើយទីពីរ កិច្ចការនៃព្រះវិញ្ញាណបរិសុទ្ធបានទៅជាមួយទ្រង់។ វិវរណៈ 5:5, 6 ចង្អុលទៅន័យដូចគ្នា។ ព្រះគ្រីស្ទត្រូវរងទុក្ខដូចជាឫសរបស់ដាវីឌ (ពន្លករបស់ដាវីឌ) ហើយ “បានសុគត” (វិវរណៈ 5:6)។ ប៉ុន្តែទ្រង់មានស្នែងប្រាំពីរ (អំណាចពេញលេញ) និង “ភ្នែកប្រាំពីរ” (កិច្ចការនៃព្រះវិញ្ញាណបរិសុទ្ធពេញលេញ)។

1. ការធ្វើចលនារបស់ដំណឹងល្អជាត្រួយមួយដែលហាក់ដូចជាខ្សោយ

ការធ្វើចលនានៃដំណឹងល្អរបស់ព្រះគ្រីស្ទធ្វើចលនាដូចជាត្រួយតូចទើបចាប់ផ្តើម។ តែការធ្វើចលនាជាការធ្វើចលនាដែលព្រះគ្រីស្ទបានក្លាយជាស្តេចនៅក្នុងដំណាក់របស់ដាវីឌអស់កល្បជានិច្ច។ ព្រះគម្ពីរមានបន្ទូលថា “បុត្រនោះនឹងបានជាធំឧត្តម ហើយគេនឹងហៅទ្រង់ ជាព្រះរាជបុត្រានៃព្រះដ៏ខ្ពស់បំផុត ព្រះអម្ចាស់ដ៏ជាព្រះ ទ្រង់នឹងប្រទានរាជ្យនៃហ្លួងដាវីឌ ជាឰយុកោទ្រង់ថ្វាយទ្រង់សោយ។ ទ្រង់នឹងសោយរាជ្យលើពួកវង្សរបស់យ៉ាកុប នៅអស់កល្បរៀងទៅ ហើយរាជ្យទ្រង់នឹងមិនផុតឡើយ” (លូកា 1:32-33)។ (មើលនៅ ដានីយ៉ែល 2:44, 7:14, 18, 27, ហេព្រើរ 1:8 វិវរណៈ 11:15) ការធ្វើចលនារបស់ទ្រង់ដូចជាគ្រាប់ពូជដែលខ្សោយ វាត្រូវបានមើលស្រាលនៅក្នុងលោកិយ។ “ទ្រង់មានព្រះបន្ទូល ជាពាក្យប្រៀបប្រដូច1ទៀតថា នគរស្ថានសួគ៌ប្រៀបដូចគ្រាប់ពូជម្យ៉ាង ដែលមនុស្សម្នាក់បានយកទៅព្រោះក្នុងចំការខ្លួន។ គ្រាប់នេះល្អិតជាងគ្រាប់ពូជទាំងអស់ពិតមែន តែកាលណាបានដុះឡើង នោះក៏ធំជាងតិណជាតិ

ទាំងអស់ ហើយក៏ត្រឡប់ជាដើមធំ ដល់ម្ល៉េះបានជាសត្វហើរលើអាកាស មកទំនៅលើមែកផង។” (ម៉ាថាយ 13:31, 32) “ដ្បិតដោយព្រោះព្រះទ្រង់បានសំរេចតាមប្រាជ្ញានៃទ្រង់ថា មនុស្សលោកនឹងរកស្គាល់ព្រះដោយអាងប្រាជ្ញាខ្លួនមិនបានទេ បានជាទ្រង់សព្វព្រះហឫទ័យនឹងជួយសង្គ្រោះអស់លោកអ្នកដែលជឿ ដោយសារសេចក្ដីល្ងីល្ងើវិញ គឺជាការប្រកាសដំណឹងល្អ” (កូរិនថូសទី1 1:21)។ “ព្រះទ្រង់បានរើសពួកល្ងង់ល្ងើនៅលោកីយ៍នេះ ដើម្បីនឹងធ្វើឱ្យអ្នកប្រាជ្ញមានសេចក្ដីខ្មាសវិញ ទ្រង់បានរើសពួកកំសោយនៅលោកីយ៍នេះ ដើម្បីនឹងធ្វើឱ្យពួកខ្លាំងពូកែមានសេចក្ដីខ្មាស។ ហើយទ្រង់បានរើសអ្នកទាបថោកនៅលោកីយ៍នេះ និងពួកអ្នកដែលគេមើលងាយ ព្រមទាំងរបស់ដែលគ្មានផង ដើម្បីនឹងលើកចោលរបស់ដែលមានចេញ” (កូរិនថូសទី1 1:27,28)។ “ដ្បិតសេចក្ដីល្ងង់ល្ងើរបស់ព្រះ នោះមានប្រាជ្ញាលើសជាងមនុស្ស ហើយសេចក្ដីកំសោយរបស់ព្រះ ក៏មានកំឡាំងលើសជាងមនុស្សដែរ។” (កូរិនថូសទី1 1:25)។

យើងគួរចងចាំក្នុងចិត្តថា អាណាចក្ររបស់ព្រះគ្រិស្តមិនមានភាពឈ្លាសវៃ និងរឹងមាំជាងនៅក្នុងពិភពលោកបច្ចុប្បន្ន ដូចដែលមនុស្សបានឃើញនោះទេ។ អាណាចក្ររបស់ព្រះគ្រីស្តមានប្រាជ្ញា និងរឹងមាំជាងក្នុងលោកិយបច្ចុប្បន្ន ដូចជាមានតែព្រះប៉ុណ្ណោះដែលឃើញ។ ក្នុងលោកនេះ អ្នកដែលមិនស្គាល់ព្រះជាម្ចាស់ត្រូវបានបង្ហាញឱ្យឃើញកាន់តែឈ្លាសវៃ និងខ្លាំងជាង ដោយសារការមិនអើពើនឹងព្រះជាម្ចាស់ គឺជាលក្ខណៈនៃពិភពលោកនេះ។ ក្នុងលោកនេះថា ការមិនអើពើនឹងព្រះជាលក្ខណៈនៃលោកីយ៍នេះ។ វាត្រូវបានប្រាប់ពិភពលោកនេះថា ការមិនអើពើអំពីព្រះជាប្រាជ្ញា និងជាជីវិតដ៏មានអំណាច។ ផ្ទុយពីការពិតនេះ ចលនានៃនគររបស់ព្រះ ជាការស្គាល់ព្រះ

និងការធ្វើឱ្យគេស្គាល់ថាព្រះជាប្រធានបទសំខាន់ ពិភពលោកនេះដែលលើកមនុស្ស
ឡើងមិនអាចយល់បានឡើយ។

លោក Geerhardus ជាអ្នកវិទូខាងការសិក្សាពីព្រះម្នាក់បានមានប្រសាសន៍ថា "នគរ
ជាទស្សនៈមួយដែលត្រូវជាចាំបាច់ដាក់មើលទៅលើងខ្លៅនិងមិនអាចទទួលបានទៅ
កាន់ទស្សនៈទាំងអស់របស់លោកិយ និងសាសនាដែលលើកដំកើងមនុស្សទៅដល់
ព្រះ" –នគររបស់ព្រះនិងក្រុមជំនុំ ទំព័រ 88)

ហេតុផលមួយទៀតដែលចលនានៃដំណឹងល្អត្រូវបានលាតត្រដាងថាមានភាពទន់
ខ្សោយ។ ព្រោះវាមិនមែនជារឿងនយោបាយទេ តែជាខាងវិញ្ញាណ។ ដំណឹងល្អគឺជា
កិច្ចការដើម្បីកាន់កាប់សាតាំង និងអំពើបាប។ នេះប្រៀបដូចជាប្រាជ្ញាក្នុងការកាត់ដើម
ឈើ គឺកាត់យកឫសល្អជាងកាត់មែក និងស្លឹក។ ប៉ុន្តែពិភពលោកនេះមិនដឹងថា
សាតាំង និងអំពើបាបគួរត្រូវបានចាត់ទុកជាបញ្ហាចម្បងនោះទេ។ ហេតុនេះហើយ
បានជាពិភពលោកមើលងាយដល់ចលនានៃនគររបស់ព្រះយេស៊ូវថាជាការលើងខ្លៅ
និងទន់ខ្សោយ។ លោក Vos បាននិយាយម្តងទៀតថា "កិច្ចការរបស់ព្រះយេស៊ូវ គឺជា
កិច្ចការដែលប្រទេសមួយប្រឆាំងនឹងប្រទេសមួយទៀត ពោលគឺ តាមរយៈប្រឆាំង
ទាស់ទៅនឹងអាណាចក្ររបស់សាតាំង នគរនៃព្រះនឹងសម្រេចបាន។ នគរនេះមាន
កម្រិតដែលនៅខ្ពស់ជាងអាណាចក្ររ៉ូមទៅទៀត។" បទគម្ពីរចែងយ៉ាងច្បាស់ថា ការ
ប្រយុទ្ធរបស់ព្រះយេស៊ូធ្វើជាប្រឆាំងទាស់នឹងអាណាចក្ររបស់សាតាំង ហើយបាន
កាន់កាប់លើវាផង។" "ប៉ុន្តែបើខ្ញុំដេញអារក្ស ដោយសារអង្គុលីព្រះហស្តនៃព្រះវិញ
នោះច្បាស់ជានគរព្រះបានមកដល់អ្នករាល់គ្នាហើយ" (លូកា 11:20)។ ប្រាជ្ញានិងចេ
ស្តារបស់ព្រះទ្រង់ទតមើលជាប្រាជ្ញានិងអំណាចស្តាពិត។ ហេតុអ្វីប្រាជ្ញានិងចេស្តា

កាលដែលព្រះទ្រង់ទតជាប្រាជ្ញានិងជាអំណាចពិតនោះ? ពីព្រោះវាមិនមែនជាប្រាជ្ញារបស់មនុស្សឬអំណាចរបស់មនុស្ស តែជាប្រាជ្ញារបស់ព្រះនិងអំណាចរបស់ព្រះ។ បើទោះជាលោកិយនេះចាត់ទុកវាទុកជាការល្ងីល្ងើនិងខ្សោយក៏ដោយ ប្រសិនបើវាជារបស់ព្រះ ដែលទ្រង់ជាព្រះដ៏មានគ្រប់អំណាចចេស្តាលើសទាំងអស់ នោះវាជាប្រជ្ញាដែលពិតនិងជាអំណាចដ៏ពិតផង។ ការស្គាល់ព្រះជាប្រាជ្ញា ហើយការរស់នៅក្នុងព្រះជាអំណាចពិតផង។ ដោយសារប្រាជ្ញានិងអំណាចត្រូវបានព្រះប្រទានមក វាមិនមែនការអស្ចារ្យបណ្តោះអាសន្នឡើយ តែជាការដែលនៅអស់កល្បក្នុងការបង្កើតនូវរបស់ថ្មីដែលនៅអស់កល្ប។ ដូច្នេះ ដោយសារម្នាក់ដែលស្គាល់ព្រះនិងរស់នៅដើម្បីនឹងថ្វាយសិរីល្អដល់ព្រះបានទទួលនូវព្រះគុណនៃការបង្កើតជាថ្មីរួចហើយ នោះគេក៏ទទួលបានប្រាជ្ញានិងអំណាចពិតដែរ។ ប្រាជ្ញានិងអំណាចនេះជាកិច្ចការដំបូង ដែលវាផ្ទាល់ជាអំណាចការបង្កើតនូវស្ថានសួគ៌និងផែនដីនៅពេលអនាគត។ (លោក Vos ថា កម្លាំងដែលនឹងផ្លាស់ប្រែស្ថានសួគ៌និងផែនដីកំពុងធ្វើការហើយ ទំព័រ 93)

2. បើទោះជាកិច្ចការរបស់ដំណឹងល្អខ្សោយខ្លាំងក៏ដោយ មានអំណាចរបស់ព្រះវិញ្ញាណបរិសុទ្ធដែលនឹងជាគូរកនទៅជាមួយផង

វិវរណៈ 5:6 មានបន្ទូលថា "កូនចៀម" មាន “ភ្នែកប្រាំពីរ” វាតំណាងឱ្យព្រះវិញ្ញាណបរិសុទ្ធដែលទ្រង់ផ្តល់ប្រាជ្ញាពិត (ប្រាជ្ញាដែលធ្វើឱ្យយើងស្គាល់ព្រះ) ដែលទ្រង់បានយាងមកនៅក្នុងថ្ងៃបុណ្យទីហាសិប អេសាយ 11:1, 2 ហើយក៏បាននិយាយដូចគ្នាពីព្រះវិញ្ញាណបរិសុទ្ធ។ ព្រះវិញ្ញាណបរិសុទ្ធដែលព្រះយេស៊ូវមុនពេលសុគតបានសន្យាថានឹងចាត់ទ្រង់មកនោះជាព្រះវិញ្ញាណនោះហើយ។ “កាលណាព្រះអង្គនោះ គឺជាព្រះវិញ្ញាណនៃសេចក្តីពិតបានមកដល់ នោះទ្រង់នឹងនាំអ្នករាល់គ្នាចូលក្នុងគ្រប់ទាំងសេចក្តីពិត ដ្បិតទ្រង់នឹងមានព្រះបន្ទូល មិនមែនដោយអាងព្រះអង្គទ្រង់

ទេ គឺនឹងមានព្រះបន្ទូល ចំពោះតែសេចក្តីណាដែលទ្រង់ឮ ហើយនិងសំដែង ឱ្យអ្នក
រាល់គ្នាដឹងការដែលត្រូវមក ទ្រង់នឹងដំកើងខ្ញុំ ដ្បិតទ្រង់នឹងយកសេចក្តីដែលតម្រូវពីខ្ញុំ
មកប្រាប់ដល់អ្នករាល់គ្នា” (យ៉ូហាន 16:13-14)។ ចលនារបស់ស្ថានសួគ៌របស់ព្រះ
យេស៊ូវជាចលនានៃព្រះវិញ្ញាណបរិសុទ្ធ។ ដូច ម៉ាថាយ 12:28 មានបន្ទូលថាជា
កន្លែងដែលព្រះវិញ្ញាណបរិសុទ្ធធ្វើការ ហើយក៏ជានគររបស់ព្រះ។ ព្រះយេស៊ូវបាន
ទទួលការចាក់ប្រេងតាំងដោយព្រះវិញ្ញាណបរិសុទ្ធ និងបានធ្វើការដោយអំណាច
ចេស្តាទាំងនោះ។ (លូកា 4:18) នៅពេលពួកផារីស៊ីប្រមាថព្រះយេស៊ូវកាលដែល
ទ្រង់ដេញអារក្ស ព្រះយេស៊ូវបានឃើញថាវាជាបាបដែលប្រមាថដល់ព្រះវិញ្ញាណ
បរិសុទ្ធ។ ហើយទ្រង់ដោយការប្តូរពិភពលោកខាងសំភារៈដោយកិច្ចការនៃព្រះវិញ្ញាណ
បរិសុទ្ធ (ការអស្ចារ្យ) ត្រូវបានបកប្រែមកដោយព្រះអម្ចាស់ទុកជាសញ្ញាតែមួយគត់នៃ
ការផ្លាស់ប្រែខាងវិញ្ញាណ (លូកា 11:20)។ ពួកសិស្សរបស់ព្រះយេស៊ូវបានក្លាយជា
មនុស្សរបស់ព្រះដោយសារព្រះវិញ្ញាណបរិសុទ្ធផងដែរ។ បើទោះជាពួកគេបានស្តាប់
ទៅកាន់ព្រះបន្ទូលរបស់ព្រះជាច្រើនក៏ដោយ ការជឿដល់អ្វីដែលពួកគេបានស្តាប់បាន
កើតមកបន្ទាប់ពីពួកគេបានទទួលព្រះវិញ្ញាណបរិសុទ្ធ។ ហើយមនុស្សដែលចូលទៅ
ក្នុងស្ថានសួគ៌ជាអស់អ្នកដែលបានទទួលព្រះវិញ្ញាណបរិសុទ្ធនិងបានកើតជាថ្មី
ប៉ុណ្ណោះ (យ៉ូហាន 3:3)។ បើមិនបានទទួលព្រះវិញ្ញាណបរិសុទ្ធ នោះគ្មាននរណាអាច
សារភាពថាព្រះគ្រីស្ទជាព្រះអម្ចាស់របស់ខ្លួនឡើយ (1កូរិនថូស 12:3)។ អ្នកណា
ដែលជឿដល់ព្រះយេស៊ូវ បើទោះជាយើងមិនអាចបង្ហាញវាក៏ដោយ គេបានទទួល
ប្រាជ្ញាផ្សេងទៀតមិនមែនគ្រាន់តែជាភាពឆ្លាតវៃធម្មតានិងជឿធម្មតាលើព្រះយេស៊ូវ
នោះទេ។ ការពិតដែលអ្នកជឿបានទទួលព្រះវិញ្ញាណបរិសុទ្ធខុសគ្នានៅក្នុងបរិមាណ
និងកម្រិត តែគុណភាពនោះដូចគ្នាទេ។ ខ្លះបង្ហាញមកនូវភស្តុតាងយ៉ាងច្បាស់ដែល
បានទទួលព្រះវិញ្ញាណបរិសុទ្ធដោយផ្ទាល់និងជាសារធារណៈ តែខ្លះទៀតបង្ហាញមក
តិចៗ។ បើទោះជាមនុស្សមានភាពកំសោយក្នុងការជឿដល់ព្រះគ្រីស្ទ តែគេទទួលបាន
ចិត្តថ្មីដើម្បីរស់នៅក្នុងជឿលើព្រះយេស៊ូវ។ បើទោះជាវាមិនសដូចជាព្រិល តែវាមាន

ពន្លឺសដែលយើងមិនអាចនិយាយថាជាពណ៌ខ្មៅ។ បើទោះជាវាមិនភ្លឺដូចជាព្រះអាទិត្យ តែវាមានពន្លឺដែលមិនអាចនិយាយថាជាសេចក្តីងងឹតបានឡើយ។ តែយើងគួរតែអធិស្ឋានយ៉ាងស្ម័គ្រស្មោះរហូតដល់យើងបានពេញដោយអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ។

ផ្នែកទី4

ការបើកក្រាំងដែលបិទដោយត្រាបួន 6:1-8:5

ផ្នែកនេះរាប់បញ្ចូលរូបភាពដែលថាកូនចៀម ព្រះយេស៊ូវគ្រីស្ទបានបើកនូវការបើក សម្តែងដែលមានត្រាប្រាំពីរត្រូវបានបង្ហាញមក។ នោះវាពិបាកនឹងបកប្រែនូវរូបភាព ដែលទ្រង់បានបកត្រាទាំងប្រាំពីរត្រូវបានបង្ហាញមក។ ដូច្នេះ ការបកប្រែមកដល់ទីនេះ គឺមានច្រើន។

1. ការបកប្រែរបស់លោក អែរលៀត

គាត់បាននិយាយថា ខ្លឹមសារនៃត្រាទាំងប្រាំពីរចង្អុលទៅគ្រប់ថ្ងៃទាំងអស់ ចាប់ពីការ សរសេរកណ្ឌគម្ពីរវិវរណៈទៅកាន់ចក្រភពរ៉ូមនៅគ.ស 395 ដែល ត្រាទី 1 ចង្អុលទៅ ពេលវេលានៃការបំផ្លាញពីអធិរាជ ណឺបារ ទៅអធិរាជ ខូម៉ុនដុស។ ត្រាទីពីរចង្អុល បង្ហាញពីថ្ងៃចុងក្រោយ។ នៃអធិរាជ ខូម៉ុនដុស ដល់ការតែងតាំងអធិរាជ ឌីអូក្លេសិន។ ត្រាទីបីគឺជាគ្រានៃការបង់ពន្ធយ៉ាងធ្ងន់ធ្ងររបស់អធិរាជ ខារ៉ាខាឡា។ ត្រាទី 4 ចង្អុល ទៅថ្ងៃដែលសង្គ្រាម គ្រោះកាច សត្វព្រៃជាដើមដែលមានភាពរុងរឿង (248- 268)។ ត្រាទីប្រាំចង្អុលទៅថ្ងៃដែលអធិរាជ ឌីអូក្លេសិន បៀតបៀនគ្រិស្តសាសនា។ ត្រាទី ប្រាំមួយចង្អុលទៅគ្រីស្ទសាសនាត្រូវបានដោះលែងដោយអធិរាជ ខនស្តែនធីនដ៏អស្ចា រ្យ ហើយអ្នកមិនជឿត្រូវបានសង្កត់សង្កិនវិញ។ ត្រាទីប្រាំពីររួមមានត្រែទាំងប្រាំពីរបាន ចាប់ផ្តើម ប្រវត្តិសាស្ត្ររ៉ូម៉ាំងរវាងឆ្នាំ 395 និង 1453 ចេញពីជំពូកទី 8 ។

2. ការបកប្រែរបស់លោក ម៉ូសេ ស្តូអាត

គាត់ចាត់ទុកគ្រប់ផ្នែកទាំងអស់នៃកណ្ឌគម្ពីរវិវរណៈជាការពន្យល់បែបនិមិត្តសញ្ញាទៅកាន់គោលការណ៍នៃការអភិវឌ្ឍនៃក្រុមជំនុំរហូតដល់ការដួលរលំនៃក្រុងយេរូសាឡិមនៅក្នុង គ.ស 70។ ដូច្នេះ គាត់និយាយថា ខ្លឹមសារនៃត្រាទាំងប្រាំពីរទីនេះបង្ហាញថាសត្រូវរបស់ក្រុមជំនុំនឹងត្រូវបំផ្លាញជាចម្បង។

3. ការបកប្រែរបស់លោក ផីតវីស

គាត់បានប្រើការបកស្រាយបែបនិមិត្តសញ្ញាដ៏ជ្រុលខ្លាំងបំផុត ដែលថាអ្នកជិះសេះសគឺជាព្រះគ្រីស្ទ។ អ្នកជិះដែលតាមទ្រង់គឺជាអំណាចដើម្បីបៀតបៀនក្រុមជំនុំ អ្នកជិះលើសេះខ្មៅគឺជាអំណាចនៃសាសនាខុសឆ្គងនិងអ្នកជិះលើសេះសម្បុរស្លាំងជា អំណាចនៃសម្តេចប៉ាប ឬអំណាចរ៉ូម៉ាំង។

4. អ្នកប្រាជ្ញមួយចំនួនពឹងផ្អែកលើម៉ាថាយ 24:5-8 នៅក្នុងការបកស្រាយត្រាទាំងប្រាំពីរ

យោងតាម ម៉ាថាយ 24:1-5 កាលដែលពួកសិស្សសួរអំពីទីសម្គាល់នៃគ្រាចុងក្រោយ ព្រះយេស៊ូវមានបន្ទូលថា នៅពេលអនាគតនឹងមានហោរាក្លែងក្លាយជាច្រើនមក ហើយមិនត្រូវចាញ់បញ្ឆោតគេឡើយ។ (ម៉ាថាយ 24:6) អ្នកប្រាជ្ញដែលថា ដោយសារការចាប់ផ្តើមនៃការបង្រៀនរបស់ព្រះយេស៊ូវពីពិភពលោកខាងមុខ ចង្អុលទៅមេរៀនរបស់ព្រះគ្រីស្ទក្លែងក្លាយ ការលេចចេញរបស់អ្នកជិះសេះសនៅត្រាទីមួយនៃវិវរណៈមានន័យថា ជានិមិត្តសញ្ញានៃហោរាក្លែងក្លាយ។ ប៉ុន្តែយើងមិនអាចទទួលយកទ្រឹស្តីនេះបានទេ។ មូលហេតុដែលព្រះយេស៊ូវដាក់មេរៀននៃព្រះគ្រីស្ទក្លែងក្លាយនៅក្នុងការបង្រៀនរបស់ទ្រង់នៅថ្ងៃចុងក្រោយនៅលើចាប់ផ្តើម មិនមែនមានន័យថាជាគំនិតដែលថាលំដាប់ទីមួយនៅក្នុងទីសំគាល់នៃថ្ងៃចុងក្រោយក្នុងពិភពលោកនោះទេ។ ជាដំបូង ចំពោះសំណួររបស់ពួកគេ ទ្រង់កត់សម្គាល់ដល់ពួកគេកុំឱ្យធ្វើតាមគ្រាចុង

ក្រោយដែលត្លែងក្លាយ។ ដូច្នេះ ទ្រង់បានរំឭកពួកសិស្សរបស់ទ្រង់ពីគ្រូត្លែងក្លាយ ដូច្នេះយើងមិនអាចទទួលស្គាល់ថា ព្រះបន្ទូលរបស់ព្រះយេស៊ូវជាមេរៀនសម្រាប់ទីសំគាល់នៅថ្ងៃចុងក្រោយបង្អស់ក្នុងលោកឡើយ។

5. ការបកប្រែរបស់លោក អាល់ហ្វត

គាត់និយាយដូចតទៅនេះ។ “រូបភាពដែលទ្រង់បានបកត្រាដែលត្រូវបានបង្ហាញមក គឺជាដំណើរការនៃព្រឹត្តិការណ៍នៃការកំណត់ដែលជំរុញដល់ការយាងមកជាលើកទីពីរ របស់ព្រះគ្រីស្ទ។ មួយអង្គដែលជិះសេះសជាសញ្ញានៃជ័យជំនះ នៅក្នុងដំណាក់កាលដែលសម្គាល់ពីជ័យជំនះរបស់អ្នកដែលជិះនោះ។ មួយអង្គដែលជិះនៅលើសេះក្រហម អង្គដែលជិះនៅលើសេះខ្មៅ និងអ្នកដែលជិះនៅលើសេះស្លាំងជាដើម។ ការសម្រេចបំពេញនៃជ័យជំនះរបស់ព្រះគ្រីស្ទត្រូវបានធំឡើងដែលធ្វើឱ្យមានចំណុចខ្ពស់បំផុតនៅក្នុងការយាងមកលើកទីពីរ ដំណាក់កាលត្រូវបានបង្ហាញមកជាការអភិវឌ្ឍនៃហេតុការណ៍តាមការកំណត់របស់ព្រះ។ ពាក្យថា “យាងមក” កាលដែលទ្រង់បើកឡើងត្រាបួនដំបូងមានន័យថា ការជំរុញដល់ការយាងមកលើកទីពីររបស់ព្រះគ្រីស្ទ។ ហើយក៏ការស្រែកឡើងរបស់អ្នកដែលត្រូវគេសម្លាប់ផងដែរ ដែលជាការសូមអង្វរដល់ការយាងមកលើកទីពីររបស់ព្រះអម្ចាស់ រូបភាពដែលត្រាទីប្រាំមួយត្រូវបានបើកឡើងមានន័យថា ការយាងមកលើកទីពីររបស់ទ្រង់នឹងមកដល់ឆាប់ៗ។” យើងមិនអាចធ្វើអ្វីក្រៅពីទទួលស្គាល់នូវការបកស្រាយរបស់លោកអាល់ហ្វតដ៏ពូកែនេះទេ។

6. ការបកស្រាយរបស់លោក ហ្គ្រេចដានុស

គាត់បាននិយាយពីខ្លឹមសារស្រដៀងគ្នាទៅនឹងការបកស្រាយរបស់លោក អាល់ហ្វត គាត់បន្ថែមលើការបកស្រាយរបស់គាត់ នៅក្នុងការបើកសម្តែងនៃត្រាប្រាំពីរថា នៅកណ្តាលនៃការបើកសម្តែងដែលបានលេចមក កាលដែលត្រាទីមួយត្រូវបានបើក

ឡើងដោយព្រះជាម្ចាស់។ នោះគឺ ត្រាទីមួយចង្អុលទៅកាន់ដំណឹងល្អ ទីមួយ ទីពីរ ទីបី ទីបួន ទីប្រាំ ជាដើម គឺសុទ្ធតែជាព្រឹត្តិការណ៍តាមការកំណត់របស់ព្រះដែលបានកើតឡើងក្នុងការសម្គាល់នូវជ័យជំនះរបស់ដំណឹងល្អ។ នេះហាក់ដូចជាការបកស្រាយដែលសមស្របបំផុង។

ជំពូកទី 6

ការបកស្រាយ

តួមានជីវិតមួយនៅក្នុងតួជីវិតទាំងបួនបញ្ចេញសំលេងដូចជាផ្គរលាន់ នេះជាសម្លេងតួជីវិតរស់ ដែលដូចជាសត្វសិង្ហ វាជាសម្លេងនៃអ្នកដែលមានជ័យជំនះ។ ការនេះ

បង្ហាញពីការពិតឱ្យបានកាន់តែច្បាស់ថា មួយអង្គដែលត្រូវបានបង្ហាញមកក្នុងកាលដែលត្រាទីមួយបើកឡើង (ជាមួយអង្គដែលជិះលើសេះស) ដែលនោះជាអ្នកដែលមានជ័យជំនះ ជាចលនានៃដំណឹងល្អ។ "ចូរមក" នេះជាការបង្គាប់របស់ព្រះដែលវិញ្ញាណដែលត្រូវគ្រប់គ្រងដែលជាចេស្តាគ្រប់គ្រងរបស់ព្រះត្រូវបានបង្ហាញមក។ ការនេះធ្វើឱ្យការមកដល់នៃចេស្តាគ្រប់គ្រងនៃដំណឹងល្អអាចទៅរួច។ ចលនានៃដំណឹងល្អរបស់ព្រះគ្រីស្ទ (អ្នកដែលជិះសេះស) ជាអ្នកដែលដើរនាំមុខ ហើយគ្រប់ព្រឹត្តិការណ៍ទាំងអស់មកតាមក្រោយ។ ដ្បិតដំណឹងល្អយកឈ្នះ គ្រោះទុរ្ភិក្សនឹងមកតាមវានៅក្នុងប្រវត្តិសាស្ត្រ។ ជាពិសេស លេខ 7 (លេខព្រះ) នៃត្រាប្រាំពីរប្រាប់ថា គ្រោះទុរ្ភិក្សត្រូវបានកើតឡើងតាមគម្រោងរបស់ព្រះ។ ដូច្នេះ គ្រោះទុរ្ភិក្សដូច្នោះត្រូវបានគ្រប់គ្រងដោយព្រះហស្តរបស់ព្រះ។ បើទោះជាវាជាកិច្ចការដ៏អាក្រក់ តែវាផ្តល់ប្រយោជន៍ដល់ពួកបរិសុទ្ធនៃស្ថានសួគ៌គ្រប់គ្រងការទាំងនោះ ពួកបរិសុទ្ធមើលឃើញការនោះ គួរតែងើបក្បាលរបស់ពួកគេឡើង។ ពាក្យថា "មក" ជាឈ្មោះដែលហៅដល់ការយាងមកនៃការគ្រប់គ្រងនៅក្នុងចំណុចកណ្តាលនៃដំណឹងល្អ។ ដល់ការសម្រេចបំពេញនៃសេចក្តីសង្គ្រោះសកល ហេតុការណ៍ដែលត្រូវបានរៀបចំទុក មិនថាវាល្ងីល្ងើឬផ្អែមនោះវានឹងមកយ៉ាងឆាប់។ យោងតាមទ្រឹស្តី វានិយាយថា ពាក្យថា "មក" ជាការអធិស្ឋានដែលជំរុញដល់ការយាងមកលើកទីពីររបស់ព្រះគ្រីស្ទ។ (រ៉ូម 8:19-21)។ តែវាមិនមែនមិនសមហេតុផលនោះទេ ពីព្រោះពាក្យថា "ដោយសម្លេងដូចផ្គរលាន់" មិនមានលក្ខណៈនៃការអធិស្ឋានទេ។

សេះស! និងអ្នកជិះដែលមានធ្នូ តើវាជាសញ្ញាតំណាងអ្វី? (1) អ្នកប្រាជ្ញមួយចំនួនបាននិយាយទីនេះថា "អ្នកដែលជិះសេះស" ជាសញ្ញានៃអ្នកដែលប្រឆាំងនឹងព្រះគ្រី

ស្ន។ តែពាក្យថា “យកជ័យជំនះ និងការយកឈ្នះ” មិនសាកសមនឹងអ្នកដែលប្រឆាំងនឹងព្រះគ្រីស្ទឡើយ។ (2) លោក រ៉ាំសេ បាននិយាយថា វាជាស្តេចរបស់ភើសៀ។ ត្រូវបានប្រាប់មកថាស្តេចភើសៀ និងកងទ័ពរបស់ទ្រង់គឺជិះសេះស និងប្រើធ្នូ។ តែលោក ហ្គ្រេចដានុស ជំទាស់នឹងទ្រឹស្តីត្រង់ៗនេះ ពីព្រោះវិវរណៈជាអក្សរសិល្បៈបែបជានិមិ្មតសញ្ញា ហើយមិនមែនជាប្រវត្តិសាស្ត្រត្រង់ៗនោះទេ។ (De Openbaring Spreekt met de beelden 1:1)។ (3) លោក អេលៀត បាននិយាយថា អ្នកដែលជិះសេះសជាពេលដែលចម្រុងចម្រើននៃក្រុងរ៉ូម ចាប់ពីអធិរាជ ដូមីសៀន រហូតដល់ការចាប់ផ្តើមរបស់អធិរាជ ខូម៉ូឌាស យើងមិនអាចទទួលយកទ្រឹស្តីនេះឡើយ ដោយទ្រឹស្តីបន្តនេះគឺជាទស្សនៈដែលត្រឹមត្រូវ។ (4) លោក ហ្គ្រេចដានុស ផ្ទាល់បាននិយាយថា វាជានិមិ្មតសញ្ញានៃដំណឹងល្អ។ រួចមកមានអ្នករិះគន់ថា “វាមិនសមទេពីព្រោះគ្រប់ទាំងត្រាទាំងអស់ត្រូវបានបើក គ្រោះដែលកាត់ទោសត្រូវបានចេញមក ហេតុអ្វីបានជាព្រះពរនៃដំណឹងល្អចេញមកនៅពេលត្រាទីមួយត្រូវបានបើកឡើង ដូច្នេះ? តែតាមពិតទៅដំណឹងល្អជាការកាត់ទោសដល់អ្នកដែលនឹងត្រូវវិនាសវិញ។ (យ៉ូហាន 3:16-21, 9:39-41) 2កូរិនថូស 2:16)។ ដូច្នេះ ការបកស្រាយរបស់លោក ហ្គ្រេចដានុស ហាក់ដូចជាត្រឹមត្រូវ។ លោក ញ្យូវែល និយាយយ៉ាងសាកសមទៅកាន់ចំណុចនេះ ដែលគាត់ហាក់ដូចជាគាំទ្រដល់ការបកស្រាយរបស់លោក ហ្គ្រេចដានុស។ នោះគឺ “អ្នកដែលជិះសេះសជាព្រះគ្រីស្ទ ជាអង្គដែលមកនៅក្នុងការប្រយុទ្ធនៅគ្រាចុងក្រោយមកកាន់ផែនដីពីទីចម្ងាយ ធ្នូជាអាវុធដែលបាញ់ចេញពីទីឆ្ងាយ ដែលនោះជាសញ្ញានៃព្រះបន្ទូលរបស់ព្រះ។ “យោងតាម ទំនុកដំកើង 45:5”។

តួមានជីវិតទីពីរនិយាយថា “ចូរមកមើលចុះ!” នោះមានសេះមួយទៀតចេញមកមានសម្បុរក្រហម។ កាលដែលយើងអាចពាក្យខាងក្រោម វាពិតណាស់ដែលសេះក្រហមជាសញ្ញានៃសង្គ្រាមយ៉ាងពិតប្រាកដ។ តែបញ្ហាគឺនៅពេលដែលសង្គ្រាមកើតឡើង។ លោក ហ្គ្រេចដានុស បានឃើញថា គ្រោះនៃកាលដែលបានបើកត្រាបីជាអត្ថន័យនៃការប្រកាសដំណឹងល្អ។ (គាត់ឃើញថាអ្នកជិះសេះសជាដំណឹងល្អ) (Rampen van hongerssnood enziektegrijpen de harten aan, enmaken ze ontvankelijk voor het aanhooren en aannemen van de Evangelie prediking)។ រួចមកតាមទស្សនៈរបស់គាត់ សង្គ្រាមទាំងនេះមិនទាក់ទងនឹងគម្ពីរសញ្ញាថ្មីទេ។ ឧទាហរណ៍នៅក្នុង គ.ស 100-138 មរតករបស់សាសន៍យូដាដែលត្រូវបានសម្លាប់តាមរយៈសង្គ្រាម។ ត្រូវបានប្រាប់ថាប្រហែលសាសន៍យូដា 580000 នាក់ត្រូវបានសម្លាប់។ (ស្តត)។

អ្នកជិះត្រូវបានអនុញ្ញាតដូចដែលយើងមើលឃើញ ជាសង្គ្រាមយ៉ាងអាក្រក់ដែលត្រូវបានបណ្តាលឱ្យកើតឡើងនៅក្នុងព្រះហស្តរបស់ព្រះ។ ដូច្នេះ មានតែកាលដែលវាត្រូវបានអនុញ្ញាតដោយព្រះ ទើបវាអាចត្រូវបាននៅជាប់។ ហើយវាត្រូវបានប្រើដើម្បីសម្រេចបំណងរបស់ព្រះ និងប្រើជាពិសេស។

ហើយគាត់ត្រូវបានផ្តល់ឱ្យនូវដាវយ៉ាងអស្ចារ្យ។ នេះជាដាវកងទ័ពដែលសម្រាប់ប្រើក្នុងសមរភូមិ។ លោក អេលៀត និង លោក បាណេស បាននិយាយថា វាជាសញ្ញានៃសង្គ្រាមខាងក្នុងនៅរ៉ូម។ (គ.ស 185-284) តែយើងមិនត្រូវការការនោះទេ វាត្រូវបានកំណត់ទៅនឹងសង្គ្រាមមួយ។ មានសង្គ្រាមជាច្រើនដែលទាក់ទងទៅនឹងការប្រកាសដំណឹងល្អ។ ចូរអានការអធិប្បាយនៅចុងបញ្ចប់នៃការបកស្រាយពន្យល់នៃជំពូក1។

5, 6 សេះខ្មៅ! ពណ៌ខ្មៅជាសញ្ញានៃទុក្ខសោក។ (បរិទេវ 5:10)។ អ្នកដែលជិះជាអ្នកដែលវាស់ដែង (ជាសញ្ញានៃគ្រោះទុរ្ភិក្ស អេសេគាល 4:10)។ ការបើកសម្តែងនេះទាក់ទងទៅនឹងគ្រោះទុរ្ភិក្ស និងគ្រោះរាំងស្ងួត។ ការបើកសម្តែងនេះមិនត្រូវបានបំបែកចេញពីដំណាក់កាលទាំងស្រុងនោះទេ។ នៅក្នុងគ្រាតែមួយដែលហេតុការណ៍នេះបានកើតឡើងជាមួយគ្នា។ គ្រានៃសង្គ្រាមជាញឹកញាប់តែងតែមានគ្រោះទុរ្ភិក្ស។ “ដ្បិតមួយ កាក់នេះគឺជាលុយរបស់រ៉ូមដែលជាប្រាក់ប្រចាំថ្ងៃរបស់កម្មករ ស្រូវសាលីមួយនាលិមានតម្លៃថ្លៃជាងនេះប្រាំបីជាងតម្លៃទូទៅ។ ដ្បិតស្រូវឱកថ្លៃជាងស្រូវសាលី បើប្រៀបធៀបទៅតម្លៃវាថោក។ លោក ស្តត បាននិយាយថា វាបានទស្សទាយពីគ្រោះទុរភិក្សនៅក្នុងអាណាចក្ររ៉ូមនៅកំឡុងគ.ស 138-192។ ប៉ុន្តែយើងមិនគិតថាវាមានដែនកំណត់ត្រឹមតែថ្ងៃនៃហេតុការណ៍នោះទេ។

តែកុំឱ្យបង្ខូចប្រេង និងស្រាទំពាំងបាយជូរឡើយ! នៅក្នុងប្រទេសប៉ាឡេស្ទីន និងអាស៊ីមីនើ ពួកគេមិនមានអាហារឡូយឆាយទេ តែគ្រាន់តែជាអាហារទូទៅ។ ការពិតដែលហាមមិនឱ្យបង្ខូចពួកគេនោះចេញមកពីសេចក្តីមេត្តារបស់ព្រះជាម្ចាស់។ លោក ឡូមេយើចង្អុលថា វាចាសញ្ញានៃការការពារនៅក្នុងជីវិតតាមសាសនារបស់អ្នកជឿ។

(Dann bedeutet die Schonung von oel und wein fur den sheher vielleicht shonung der Glubigen im Hinblick auf die Erfulung religioser Pffichten – Offenbarung ទំព័រ 61)។ ប្រេង និងស្រាទំពាំងបាយជូរជាសញ្ញាសម្គាល់ពីសាសនានៅក្នុងព្រះគម្ពីរ។ (យ៉ាកុប 5:14, លូកា 10:34, អេសាយ 55:1)

7, 8 សេះសម្បុរស្លាំងមួយ! សម្បុរស្លាំងជាពណ៌នៃការគួរឱ្យរន្ធត់ និងរូបកាយមនុស្សស្លាប់។ សេចក្តីវេទនានៃសហគមន៍នេះបានមកដល់ខ្ពស់បំផុត។ ដូច្នេះ សញ្ញានោះគឺ

ពណ៌ស្លាំង។ គ្រប់ទាំងគ្រោះនៃដាវ គ្រោះទុរភិក្ស និងជំងឺរោគា សត្វព្រៃនឹងចេញមកពីវា។ ដាវជានិមិត្តសញ្ញានៃការសម្លាប់នៅក្នុងសង្គ្រាម។ កាលដែលដំណឹងល្អត្រូវបានប្រកាសនៅគ្រប់ទីកន្លែងនៃសាសនាផ្សេងៗ។ ព្រឹត្តិការណ៍ជាច្រើនដែលសង្គ្រាម និងការបះបោរនឹងត្រូវកើតឡើងដែលមាននៅក្នុងប្រវត្តិសាស្ត្រ។ ក្រុងរ៉ូមពីបុរាណមានសង្គ្រាមនៅក្នុងប្រទេសយ៉ាងខ្លាំង មានការសម្លាប់យ៉ាងច្រើនដែលបានកើតឡើងជាបន្តបន្ទាប់ ដែលនោះគឺ លោកអធិរាជ កំម៉ុនដុស ត្រូវបានគេសម្លាប់ (គ.ស 193)ការរំខានត្រូវបានបន្ត នៅក្នុងអំឡុងពេលនោះ នៅក្នុងចំណោមព្រះចៅអធិរាជទាំង 32 ត្រូវបានដេញចេញ ព្រះអធិរាជ 22 នាក់ (Gibbon ទំព័រ 50-197) គឺដូចជាអ្នកផ្សេងដែរគឺមានការច្របូកច្របល់ និងគ្មានភាពស្ថិតស្ថេរទេ នោះមនុស្សបានត្រឡប់ទៅរកដំណឹងល្អ។ “គ្រោះទុរភិក្ស” បានដើរទៅជាមួយគ្នានឹងនយោបាយដែលច្របូកច្របល់ និងគ្រោះធម្មជាតិជាប់ជានិច្ចនៅក្នុងបទពិសោធន៍នៅក្នុងប្រវត្តិសាស្ត្រ។ “សេចក្តីស្លាប់” គឺពាក្យថា សាណាថូស (θάνατος) នៅក្នុងភាសាក្រិក LXX បានប្រើវា នៅក្នុងស្ថានភាពជាច្រើន ដូចជាអត្ថន័យនៃការក្តៅឧនៗ (នៅក្នុងភាសាហេព្រើរគឺ ដេបា דֶּבֶר) (30/50) ដូច្នេះ នៅក្នុងពាក្យក្រិកថា សាណាថូស ហា ជាអត្ថន័យនៃការក្តៅឧនៗ។ ដូច្នេះ នៅទីនេះ ពាក្យថា “ស្លាប់ (ថាណាថូស)” មានន័យថា កម្តៅឧនៗ។ ដូច្នេះ គ្រោះទុរភិក្សទាំងនេះដែលព្រះយេស៊ូវទ្រង់បានទស្សទាយគឺស្រដៀងទៅនឹងវាដែរ។ (លូកា 21:10, 11, គ្រោះទុរភិក្សក្តៅឧនៗ កម្តៅឧនៗ) ហើយអ្វីដែលអេសេគាលបានទាយទុកនោះស៊ីគ្នាយ៉ាងល្អ។ (អេសេគាល 14:21) ហេតុការណ៍ដែលមនុស្សត្រូវបានធ្វើទុក្ខដោយគ្រុនក្តៅត្រូវបានកើតឡើងជាច្រើននៅក្នុងប្រវត្តិសាស្ត្រ។ ដ្បិតនៅក្នុងក្រុងរ៉ូម មានមនុស្សប្រមាណ 100000 នាក់បានស្លាប់នៅក្នុងមួយថ្ងៃ

មានអ្នកប្រាជ្ញម្នាក់ដែលការបើកសម្តែងនេះបានចង្អុលទៅកាន់នៅក្នុងហេតុការណ៍នេះ។

លើផែនដីមួយភាគក្នុងបួន ដើម្បីនឹងសម្លាប់ ការនេះដាក់ដូចជាចំនួនតិចតួចជាងមួយភាគបី នៅក្នុង 8:7-12។ ប៉ុន្តែ វាពិបាកដឹងណាស់ពីការពិតដែល វាមានត្រឹមតែអត្ថន័យបែបជាសម្គាល់ ឬមានអត្ថន័យត្រង់ៗ។

ដោយសត្វព្រៃនៅផែនដីផង។ ក្រុងរ៉ូមពីបុរាណគឺការធ្វើបាបពីសត្វព្រៃបានកើតឡើងច្រើន។ នោះពួកមនុស្សនិយាយថា មានព្រឹត្តិការណ៍ជាច្រើនដែលគេត្រូវបានធ្វើបាបដោយសត្វព្រៃដែលចេញមកដោយកំហឹងនៃព្រះរបស់ពួកគេ ពីព្រោះដោយសារតែពួកគ្រីស្ទាន។ ដោយសារសម្តីបែបនេះ មានមនុស្សមួយចំនួនបានចំអកដល់ព្រះបន្ទូល គឺថាមុនគ្រីស្ទាននោះមាននៅក្នុងប្រទេសរបស់យើង តើគ្រោះនៃសត្វព្រៃនោះមិនបានកើតឡើងទេមែនទេ?(Non ante nos?) យោងតាមទ្រឹស្តីនេះ ត្រូវបានប្រាប់មកថា វាជាសញ្ញានៃសកម្មភាពនៃការបៀតបៀននៃពួកទាស់នឹងព្រះគ្រីស្ទ។

9,11 ***អស់ទាំងព្រលឹងរបស់មនុស្សដែលគេបានសម្លាប់*** នេះមិនមែនជាការបកប្រែត្រឹមត្រូវនៃអត្ថបទភាសាក្រិកទេ (τὰς ψυχὰς τῶν ἐσφαγμένων) ការបកប្រែត្រឹមត្រូវគឺ “ព្រលឹងនៃមនុស្សដែលត្រូវបានគេសម្លាប់”។ ការនេះហាក់ដូចជាចង្អុលទៅកាន់ព្រឹត្តិការណ៍នៃការសម្លាប់នៅក្នុងប្រវត្តិសាស្ត្រជាទូទៅ។ យោងតាមទ្រឹស្តីមួយ នេះជាទំនាយនៃការបៀតបៀនរបស់គ្រីស្ទានពីអធិរាជរ៉ូមឈ្មោះ ឌីអូឃ្លេសិន នៅគ.ស 270-304។ នៅក្នុងអាសនា ព្រះគម្ពីរមានបន្ទូលថា អាសនានៃទីបរិសុទ្ធដែលម៉ូសេបានបង្កើតជាប្រភេទនៃសម្ភារៈបែបស្ថានសួគ៌ (ហេព្រើរ 9:24)។ អ្នកដែលត្រូវគេសម្លាប់នៅក្រោមអាសនាដែលបរិសុទ្ធនេះបានយំឡើងទៅកាន់ស្ថានសួគ៌ដោយបន្ទាបខ្លួន

យ៉ាងស្មោះត្រង់។ ការទូលសូមគឺដូចតទៅនេះថា “ The martyrs under this holy altar cried out at the heaven humbly, sincerely. The requests are like following, ***“ឱព្រះដ៏ជាម្ចាស់ ជាព្រះបរិសុទ្ធ ហើយពិតប្រាកដអើយ តើទ្រង់ចាំដល់កាលណាទៀតបានជំនុំជំរះ ហើយសងសឹកដល់ពួកមនុស្សនៅលើផែនដី ដោយព្រោះឈាមយើងខ្ញុំរាល់គ្នា”*** មានអ្នកខ្លះនិយាយថា វាមិនមែននៅក្នុងសញ្ញាថ្មីទេ តែជាគំនិតនៃការសងសឹកនៅក្នុងសញ្ញាចាស់វិញ ដែលជាការអធិស្ឋានរបស់អ្នកដែលត្រូវគេសម្លាប់នៅក្នុងសញ្ញាចាស់។ តែអ្វីដែលយើងដឹងគឺជាការពិតដែលពួកបរិសុទ្ធនៅក្នុងសញ្ញាចាស់ក៏បានអធិស្ឋានចង់សងសឹកពួកសត្រូវដោយមិនប្រយ័ត្នដែរ។ កាលដែលយើងអាននៅក្នុងទំនុកដំកើង ពួកបរិសុទ្ធមិនត្រឹមតែបានដាក់បណ្តាសាតែទៅកាន់ “សត្រូវរបស់ព្រះ” តែទៅកាន់សត្រូវផ្ទាល់ខ្លួនរបស់គេផង។ នេះគឺដូចគ្នានៅក្នុងគ្រានៃសញ្ញាថ្មីដែរ។ អ្នកជឿនៅក្នុងសញ្ញាថ្មីមិនបានទូលសូមព្រះពរដល់សត្រូវរបស់ព្រះទេ តែស្វែងរកបណ្តាសាវិញ (កាឡាទី 1:8)។ ពីព្រោះវាពិបាកស្គាល់ណាថាគេជានរណា ពួកគេមិនគួរធ្វើដោយមិនប្រយ័ត្នឡើយ។ តែកាលដែលយើងចូលក្នុងពិភពនៃស្ថានសួគ៌ ដ្បិតយើងស្គាល់ពីសត្រូវយ៉ាងច្បាស់ ការទូលអង្វរបែបនេះនឹងត្រូវបានធ្វើដោយពួកគេ។ ដូច្នេះ ការអធិស្ឋាននេះអាចនឹងធ្វើឡើងដោយពួកដែលត្រូវគេសម្លាប់នៅក្នុងសញ្ញាថ្មី។ លោក មិហ្វាត បាននិយាយថា ពាក្យសម្តីនៃការអធិស្ឋានរបស់អ្នកដែលត្រូវគេសម្លាប់ជាគំនិតដែលត្រូវបានយកចេញមកពីអាផូគ្រីផា។ អាផូគ្រីផា របស់អេណុក បាននិយាយដូចតទៅនេះថា “ការអធិស្ឋានដែលស្រែកឡើងសូមការកាត់ទោសវា (ការវិនិច្ឆ័យទោស) នឹងមកជាប្រាកដ។ ការរងទុក្ខដែលអ្នកទទួលនឹងត្រឡប់ទៅរកមនុស្សដែលបានធ្វើបាបអ្នកជាប្រាកដ។ (អេណុក 104:3) តែពាក្យរបស់លោក មិហ្វាត ជាការយល់ច្រឡំ ហើយយើងមិនអាចទុកចិត្តលើវាបានទេ។ ផ្ទុយទៅវិញ

ពាក្យថា “បន្តស្រែកអំពាវនាវ” នៅក្នុង អេណុក អាផូគ្រីផា មិនមាននៅក្នុងវិវរណៈ
របស់លោកយ៉ូហានដែលនិយាយថា “ដែលបានប្រាប់ឱ្យសម្រាកយូរបន្តិចទៅ” នោះ
ទេ (11)? ការពិតដែលឈាមនៃអ្នកដែលត្រូវគេសម្លាប់ស្រែកឡើងទៅកាន់ព្រះ (លោ
កុប្បត្តិ 4:10) ហើយវាត្រូវបានបង់ថ្លៃរួចហើយ ហើយនេះជាអ្វីដែលព្រះអម្ចាស់របស់
យើងផ្ទាល់ទ្រង់បានបង្រៀនដល់យើង (ម៉ាថាយ 23:35), ឃ្លានេះត្រូវបានផ្អែកលើ
កណ្ឌគម្ពីរ ពីព្រោះជាសេចក្តីបរិសុទ្ធជាការដែលផ្ទុយពីអំពើបាប ហើយជាលក្ខណៈ
ដែលស្រែកឡើងសម្រាប់ពួកបរិសុទ្ធ “ព្រះអម្ចាស់ដែលមានគ្រប់ព្រះចេស្តាពិតមាន
ន័យថា ជាចេស្តាអស្ចារ្យដែលអាចទុកចិត្តបាន ដែលមានសិទ្ធិអំណាចក្នុងការដាក់
ទោស។ ព្រះអម្ចាស់ដែលមានចេស្តាគឺហៅថា ដេស្ពូថេស (δεσπότης) នៅក្នុងភាសា
ក្រិក ដែលមានន័យថា ភាពពេញលេញទាំងស្រុង (វាមិនមែនជាការគៀបសង្កត់ដែល
ទុច្ចរិតនោះទេ)។ ភាពពេញលេញនេះជាព្រះដែលមានគ្រប់ចេស្តានៃអត្ថន័យដែលថា
គ្មានអ្នកណាម្នាក់អាចបង្ខាំងនូវបំណងរបស់ទ្រង់ឡើយ។ កាលដែលគេទូលសូម
សម្រាប់ពួកបរិសុទ្ធ នោះគ្មានអ្នកណាអាចប្រឆាំងបានឡើយ។ “អស់អ្នកដែលនៅលើ
ផែនដី” ជាសត្រូវនៃនគររបស់ព្រះដែលនៅផែនដីនេះ (3:10, 8:13, 11:10) យោង
តាម យ៉ូហាន 8:23។ កាលដែលយើងឃើញពាក្យថា “តើទ្រង់ចាំដល់កាលណាទៀត
ទើបជំនុំជំរះ” យើងដឹងថាព្រះ ដែលទ្រង់តែងតែទ្រាំទ្រជានិច្ច ទ្រង់មិនដាក់ទោសមុន
ពេលអំពើបាបរបស់មនុស្សបានពេញនៅក្នុងខ្លួនរបស់ពួកគេនោះឡើយ ទ្រង់មិនដែល
ដាក់ទោសពួកគេទេ។ ដូច្នេះ ពួកបរិសុទ្ធសង្ឃឹម ហើយពួកគេត្រូវបានរងទុក្ខមួយរ
យៈ។

អាវសរីរាង នេះមិនមែនជារូបកាយខាងវិញ្ញាណដូចអ្វីដែលលោក ឆល និយាយនោះទេ តែចង្អុលទៅកាន់ការរាប់ជាសុចរិតដែលពេញលេញ និងសិរីល្អនៃសេចក្តីសង្គ្រោះដែលត្រូវបានលុបដោយសារព្រះលោហិតដ៏ថ្លៃថ្លារបស់ព្រះយេស៊ូវគ្រីស្ទ។ លោក ម៊ហ្វាត បានឃើញថា វាទាក់ទងទៅនឹងឃ្លារបស់អាផូគ្រីផា (អេសាយ 9:6) ឃ្លាដែលនិយាយថា "នៅក្នុងដំណាក់កាលទី7 អេបិល អេណុក និងពួកបរិសុទ្ធសាសន៍យូដាមួយទៀតត្រូវបានបំពាក់ដោយសំលៀកបំពាក់នៃពិភពលោកនៅខាងលើ ដែលត្រូវបានហៅថារូបកាយដែលត្រូវបានរស់ឡើងវិញ។" តែគំនិតរបស់អាផូគ្រីផាខុសពីវិវរណៈ។ អាវសរីរាងនៃវិវរណៈមិនបានចង្អុលទៅកាន់រូបកាយដែលរស់ឡើងវិញទេ។ (យោងតាម វិវរណៈ 6:11)។

សម្រាកបន្តិចសិន នេះជាការសម្រាកដ៏មានពរនៃពិភពនៃស្ថានសួគ៌ (14:13)

ទាល់តែបាវបំរើ ជាគូកន ហើយជាបងប្អូន ដែលត្រូវសំឡាប់បែបដូចគ្នា បានគ្រប់ចំនួន។ យោងតាម ហេព្រើរ 11:39, 40។

12-17 ការបើកសម្តែងនៃត្រាទីប្រាំមួយហាក់បីដូចជាចំណុចកំពូលនៃការបើកសម្តែងនៃការបើកសម្តែងដែលត្រាមុនៗទាំងអស់ដែលត្រូវបានបើកបង្ហាញមក។ កាលដែលយើងមើលទៅវិវរណៈ គ្រប់គ្រោះទាំងអស់នៅចុងបំផុតនៃផែនដីមិនបានមកក្នុងពេលមួយរំពេចនោះទេ កំពុងរងចាំការលន់តួបាបរបស់មនុស្សពីមួយជំហ៊ានទៅមួយជំហ៊ាន និងជាលំដាប់។ កាលដែលយើងឃើញការមួយនេះ យើងអាចដឹងពីសេចក្តីមេត្តាដ៏ធំរបស់ព្រះ យើងមិនគួរបកប្រែការបើកសម្តែងទាំងនេះដោយន័យត្រង់ៗឡើយ តែត្រូវបកស្រាយបែបជាសញ្ញាសម្គាល់វិញ។ នៅទីនេះ ពាក្យនេះប្រៀបដូចជាព្រះដែលប្រៀបធៀបដែលអេសាយបានប្រើដល់អេដុមដែរ។ ដូច្នេះ ការបើកសម្តែងដែល

ឃ្លាទាំងនេះបង្ហាញហាក់ដូចជាចង្អុលទៅកាន់ការដោះដូរបែបនយោបាយ។ អ្នកប្រាជ្ញមួយចំនួនបាននិយាយថា នេះជាទំនាយនៃការលុបបំបាត់អ្នកជឿព្រះក្លែងក្លាយ និងមន្ត្រីរបស់សាសនាដទៃដោយព្រះចៅអធិរាជរ៉ូមលោក ខនស្តែនធីន។ តែយើងមិនអាចធានាពីការនេះទេ។ យោងតាមទ្រឹស្តីមួយ វាចង្អុលទៅកាន់ការពិតដែលការវិនាសនៃលោកិយនេះសតវត្សត្រូវបានបិទ។ វាជាការបកប្រែដែលមានតម្លៃ។

ការកើតដីយ៉ាងខ្លាំង យោងតាម 8:5, 11:13, 16:18។ នេះអាចមានន័យថា ជាការរញ្ជួយដី ក្នុងន័យត្រង់ តែវាប្រៀបដូចជាការរំខានខ្លាំងនៃការវិនាសនៅក្នុងប្រទេសនានានៃផែនដីនេះ។ កាលដែលប្រទេស និងសង្គមមានការរំខានខ្លាំង នោះរញ្ជួយដីយ៉ាងខ្លាំងនឹងកើតឡើង។ នៅក្នុងពិភពលោកពីបុរាណ នៅក្នុងឆ្នាំមុនប្រទេសជប៉ុនត្រូវបានបំផ្លាញ (នៅរដូវរងានៃឆ្នាំ 1944) ការរញ្ជួយដីដ៏ខ្លាំងបានកើតឡើងនៅកូរ៉េ និងម៉ាន់ជូ។ លោក បានេស បាននិយាយថា ការរំខានដ៏ខ្លាំងនៃនយោបាយដោយការរបៀបរាប់របស់គាត់នៅក្នុងផ្នែកនេះ ចង្អុលទៅកាន់សេចក្តីវិនាសរបស់ក្រុងរ៉ូមដោយកុលសម្ព័ន្ធរបស់ហ្គស និងកុលសម្ព័ន្ធ វ៉ាន់ឌេល។ តែយើងមិននិយាយថា ពាក្យដែលចង្អុលទៅកាន់ភាពពេញលេញនៃជ័យជំនះនោះទេនៅក្នុងព្រឹត្តិការណ៍នៃសេចក្តីវិនាសរបស់ក្រុងរ៉ូម។

ការនេះនឹងត្រូវបានសម្រេចនៅពេលការយាងមកលើកទីពីររបស់ព្រះគ្រីស្ទ ដែលជាចំណុចការសម្រេចបំពេញខ្ពស់បំផុតកាលដែលការវិនាសរបស់ប្រទេសនានានៃលោកិយនេះ។ សំពត់រោមខ្មៅ នេះជាបាវក្បាញដែលមានពណ៌ខ្មៅ។

ថ្ងៃក៏ត្រឡប់ទៅជាខ្មៅដូចជាសំពត់រាមខ្មៅ ហើយខែក៏ត្រឡប់ពីប្រទៅដូចជាឈាម យោងតាម អេសេគាល 32:7 យ៉ូអែល 2:10, 13 អេសាយ 13:10 50:3 ម៉ាថាយ 24:29 យ៉ាកុប 13:24 លូកា 21:25។

13 ផ្កាយ the យោងតាម ដានីយ៉ែល 8:10

14 ផ្ទៃមេឃក៏បាត់ទៅ ដូចជាក្រាំងដែលគេមូរទៅវិញ យោងតាម អេសាយ 34:4។ ការផ្លាស់ប្រែរបស់ព្រះអាទិត្យ ព្រះច័ន្ទ និងផ្កាយ និងខ្យល់ចង្អុលទៅកាន់សញ្ញានៃការផ្លាស់ប្រែខាងនយោបាយយ៉ាងខ្លាំង។

15-17 កាលដែលខគម្ពីរទាំងនេះនិយាយ នោះមនុស្សដែលបានពួននៅក្នុងរូងភ្នំ និងនៅក្នុងថ្មនៅភ្នំ ហើយជាអ្នកដែលខ្លាចដល់ព្រះ និងសេចក្តីក្រោធរបស់កូនចៀម និងពួកដែលកំពុងតែញាប់ញ័រ (ខ15) ចង្អុលទៅកាន់គ្រប់លំដាប់ថ្នាក់របស់មនុស្ស។ មានមនុស្សជាច្រើនជាពិសេសអ្នកនិពន្ធ។ ហេតុផលដែលវាបានកើតឡើងគឺជាការប្រព្រឹត្តិបាបយ៉ាងច្រើន។

ចំណុចសំខាន់

1. មកុដត្រូវបានប្រគល់ដល់គេ (2) គាត់បានទទួលដាវយ៉ាងអស្ចារ្យ (4) កុំបង្ខូចប្រេង និងស្រាទំពាំងបាយជូរ!"(6) ពួកគេបានទទួលអំណាចនៅលើមួយភាគបួននៃផែនដី(8)។ កាលដែលយើងឃើញពាក្យ ផែនការរបស់ព្រះត្រូវបានកើតឡើងដោយព្រះអង្គជាបុគ្គលផ្ទាល់ គឺដោយការគ្រប់គ្រងរបស់ព្រះ តែមិនបានដំណើរការដោយឯកឯងដែលកើតដោយខ្លួនឯងនោះទេ។ កាលដែលយើងឃើញវា យើងអាចដឹងពីទស្សនៈនៃផែនការរបស់បទគម្ពីរ ដែលពិតជាពិតនិងត្រឹមត្រូវ។ អ្នកគោរពព្រះផ្សេងធ្វើចលនានៃផែនការដែលបានក្លាយទៅជាឯកឯង។ ទស្សនៈវិទ្យានៃប្រវត្តិសាស្ត្រ

នៅក្នុងព្រះពុទ្ធសាសនា និងសាសនាដែលជឿលើព្រះច្រើនដែលមើលទៅកាន់លោកិយនេះថាជាចលនានៃផែនការដែលមានដោយឯកឯង។ សកលលោកដែលសមហេតុផល ទ្រឹស្តីរបស់ខុងជឺក៏ដូច្នេះដែរ។ ទស្សនៈវិទ្យារបស់ប្រវត្តិសាស្ត្ររបស់ខុងជឺបង្ហាញនៅក្នុងសៀវភៅរបស់គាត់ ជុន ជូ ជិន។ ទស្សនៈរបស់គាត់ពីផែនការគ្រប់គ្រងនៅក្នុងជុន ជូ ជិន មិនមែនជាផែនការគ្រប់គ្រងពីខាងក្រៅទេ តែជាទ្រឹស្តីដើម្បីនឹងបង្រួបបង្រួមស្ថានសួគ៌ជាមួយនឹងមនុស្សវិញ។ នេះជាទ្រឹស្តីនៃសកលលោកដែលដំណើរការ ដែលគ្រប់ការទាំងអស់ឆ្លើយតបគ្នាទៅវិញទៅមក។ ពីព្រោះគោលជំនឿរបស់សាសនាគ្រឹស្តមិនបានបន្ទរបន្តុយជាមួយនឹងលោកិយដែលមានបាប ឡើយ អ្នកជឿបានទទួលការបៀតបៀននៅក្នុងលោកិយ។ កាលដែលយើងសង្កេតមើលនូវគោលជំនឿរបស់ពួកគេ នោះពួកគេមានគោលជំនឿតែមួយដែលត្រូវបានបៀតបៀនដោយលោកិយ។ តែបើទោះជាពួកគេត្រូវបានបៀតបៀនដោយអ្នកផ្សេងក៏ដោយ តែគេមិនធ្វើការបៀបបៀនដល់អ្នកផ្សេងដែរ។ (ខ 9)

2. ព្រលឹង (ខ 9) ត្រូវបានផ្តល់មកតែមកកាន់មនុស្សប៉ុណ្ណោះ ហើយវាត្រូវបានបង្កើតមកក្នុងរូបឆ្លុះរបស់ព្រះ។ មានភស្តុតាងជាច្រើនពីវត្តមានរបស់ព្រលឹងគឺដូចតទៅនេះ។

(1) បញ្ជាក់ដោយការប្រើនូវហេតុផល

(2) បញ្ជាក់ដោយសកម្មភាពដែលថ្លៃថ្នូនៃចិត្តដូចជា ការដឹងពីតួនាទី ដឹងកំហុស ការប្រែចិត្ត ជាដើម។

(3) បញ្ជាក់ដោយបទគម្ពីរ។ ខ្ញុំសរសេរទីនេះនៅក្នុងន័យនៃភស្តុតាងដែលព្រះគម្ពីរសំខាន់បំផុត។ សាស្តា 12:7 ដានីយ៉ែល 12:13 ម៉ាថាយ 10:28 លូកា 12:19, 20, 16:19, 31, 23:43-46 ភីលីព 1:22-24) លើកលែងពួកគេ មានខគម្ពីរជាច្រើននៃបទគម្ពីរបញ្ជាក់ពីវា និងប្រព័ន្ធនៃបទគម្ពីរផ្ទាល់បញ្ជាក់ពីវា។

4. ការយោងមកលើកទីពីររបស់ព្រះគ្រីស្ទជាការគួរឱ្យរន្ធត់គ្មានដែនកំណត់ទៅកាន់អ្នកដែលមានចិត្តចងភ្ជាប់ទៅនឹងលោកិយ (12-15)។

5. ដូចជាពេលវេលានៃគ្រានៃព្រះគុណរបស់ព្រះដែលមាន នោះពេលវេលានៃសេចក្តីក្រោធរបស់ទ្រង់ក៏មានដែរ។ គ្រប់ការទាំងអស់សុទ្ធតែមានពេលសាកសមរបស់វា (16, 17) (យោងតាម សាស្តា 3:1-8)។

ការអធិប្បាយទី 21 ការប្រកាសដំណឹងល្អនិងទុក្ខវេទនា (វិវរណៈ 6:1-11)

អត្ថបទបង្ហាញថា យើងជួបទុក្ខវេទនានៅក្នុងលោកិយ។ តែហេតុអ្វីបានជាទុក្ខលំបាកជាចំណែករបស់យើង? ដូចលោក Hendriksen បាននិយាយថា ទុកលំបាកមាននៅក្នុងឃ្លាំងរបស់កូនៗរបស់ព្រះ។ ហេតុផលដែលនាំឱ្យគិតបែបនេះគឺថា ទុក្ខវេទនាមកដល់ មនុស្សត្រូវបានកាត់ចេញពីបន្ទាត់របស់លោកិយ ហើយបានត្រឡប់មករកដំណឹងល្អ ដែលជាជំនឿរបស់ពួកគេត្រូវបានហ្វឹកហាត់។

“អ្នកដែលជិះលើសេះស” នៅក្នុងអត្ថបទ ខ្ញុំបកប្រែខាងក្រោម តែវាជាពាក្យប្រៀបប្រដូចនៃចលនារបស់ដំណឹងល្អ។ ការបើកសម្តែងនៃផ្នែកនេះទៅកាន់ទុក្ខលំបាកបានកើតជាបន្តជានិច្ច។ ដំបូងបង្អស់ បង្ហាញពីចលនានៃដំណឹងល្អរបស់ព្រះគ្រីស្ទ “ការយកជ័យជំនះ និងការវាយលុក” ដោយហេតុការណ៍វាធ្វើឱ្យអ្នកជឿមើលទៅកាន់ជ័យជំនះដែលពួកគេអាចយកឈ្នះគ្រប់ទុក្ខលំបាកទាំងអស់។

ជ័យជំនះរបស់ព្រះគ្រីស្ទជាជ័យជម្នះរបស់យើងរួចហើយ។ យ៉ូហាន 16:33 មានបន្ទូលថា “ខ្ញុំប្រាប់សេចក្តីទាំងនេះ ដើម្បីឱ្យអ្នករាល់គ្នាបានសេចក្តីសុខសាន្តដោយសារខ្ញុំនៅក្នុងលោកិយនេះ នោះអ្នករាល់គ្នាមានសេចក្តីវេទនាមែន ប៉ុន្តែត្រូវសង្ឃឹមឡើង ដ្បិតខ្ញុំបានឈ្នះលោកិយហើយ។” ព្រះបន្ទូលនេះមានន័យថា បើទោះជា

អ្នកជឿជួបនឹងទុក្ខវេទនា ពួកគេនឹងមិនបារម្ភពីវាឡើយ ពីព្រោះព្រលឹងរបស់ពួកគេនៅក្នុងពេលមានទុក្ខលំបាកនឹងមិនត្រូវវិនាសឡើយ (ព្រះយេស៊ូវគ្រីស្ទបានមានជ័យលើលោកិយសម្រាប់សេចក្តីសង្គ្រោះរបស់ពួកគេហើយ)។

នៅពេលដែលគាត់បើកត្រាទីពីរ អ្នកជិះសេះក្រហម វាមានន័យពីសញ្ញានៃការធ្វើសង្គ្រាម។ ម៉ាថាយ 24:7, 8 មានបន្ទូលថា “ពីព្រោះសាសន៍មួយនឹងលើកគ្នាទាស់នឹងសាសន៍មួយ នគរមួយនឹងនគរមួយ ហើយនឹងកើតមានអំណត់ ជំងឺអាសន្នរោគនឹងកក្រើកដីនៅកន្លែងផ្សេងៗ។ តែការទាំងនោះជាដើមចមនៃសេចក្តីទុក្ខទេ។” មនុស្សគិតថាលោកិយនេះនឹងមានសេចក្តីសុខសាន្តមកដល់ខុសពេល។ តែបទគម្ពីរនិយាយថា សង្គ្រាមនឹងនៅរហូតដល់ទីបញ្ចប់នៃលោកិយ។ ដូច្នេះយើងមិនគួរដាក់សង្ឃឹមលើលោកិយនេះឡើយ។

នៅពេលត្រាទីបីនឹងបើកឡើង ម្នាក់ដែលមកនឹងយកស្រកាពីរនៅក្នុងដៃ។ វាមានន័យថាជាសញ្ញានៃភេទស្រីដូចដែលបទគម្ពីរបានបកស្រាយ។ កាលដែលសង្គ្រាមកើតឡើង នោះគ្រោះអំណត់អត់ក៏មកតាមក្រោយ។ ម៉ាថាយ 24:8 និយាយថា “តែការទាំងនោះជាដើមចមនៃសេចក្តីទុក្ខទេ”។ ប្រសិនបើមនុស្សមានអាហារច្រើន នោះគេនឹងនៅឆ្ងាយពីព្រះ។ ហេតុផលដែលលោកិយនេះមានភាពអត់ឃ្លានច្រើន គឺវាធ្វើឱ្យមនុស្សចូលមកជិតព្រះកាន់តែជិត។ ទំនុកដំកើង 37:16 មានបន្ទូលថា “ឯរបស់បន្តិចបន្តួចនៃមនុស្សសុចរិត នោះវិសេសជាជាងរបស់បរិបូរនៃមនុស្សអាក្រក់ជាច្រើននាក់ទៅទៀត”។ ពីព្រោះមនុស្សសុចរិតសុខចិត្តមានសេចក្តីជំនឿរបស់គេដោយភាពក្រីក្រ។ បើទោះជាគ្រោះអត់ឃ្លាននោះវាធ្ងន់ធ្ងរក៏ដោយ ព្រះនឹងធ្វើឱ្យមនុស្សបាន

“ប្រេងអូលីវនិងទំពាំងបាយជូរ”។ ប្រេងអូលីវនិងទំពាំងបាយជូរជាសញ្ញានៃព្រះគុណខាងវិញ្ញាណ។

កាលដែលត្រាទីបួនត្រូវបានបើកឡើង អ្នកជិះសេះពណ៌ស្រអាប់បានចេញមក ឈ្មោះរបស់គាត់គឺសេចក្តីស្លាប់។ នេះមានន័យថាការសម្លាប់មនុស្សដោយវិធីដ៏អាក្រក់។ ការសម្លាប់មនុស្សនេះ “ជាមួយនឹងដាវនិងដោយការស្រេកឃ្លាន និងជាមួយនឹងគ្រោះនានា និងដោយសត្វព្រៃនៃផែនដី”។ មនុស្សបានទទួលការគំរាមនៃសេចក្តីស្លាប់មុនទីបញ្ចប់នៃលោកិយនេះជានិច្ច (គ្រាចុងក្រោយដ៏អស្ចារ្យ) មកដល់។ ហេព្រើរ 2:15 ចង្អុល “ហើយប្រគល់អស់អ្នកដែលដោយការភ័យខ្លាចសេចក្តីស្លាប់ទៅក្នុងភាពជាបាវបម្រើពេញមួយជីវិត។” កាលដែលគ្រាចុងក្រោយកាន់តែខិតមកជិតយើង មនុស្សក៏ជួបគ្រោះចង្រៃដែលមនុស្សមានអារម្មណ៍ដែលកាន់តែគ្រោះថ្នាក់នៃសេចក្តីស្លាប់។ កាលដែលទីបញ្ចប់នៃលោកិយនេះមកជិតមនុស្សកាន់តែចម្រើននៅក្នុងការរៀនសម្លាប់មនុស្សថែមទៀត។ ពួកគេបានរៀបចំវិធីសម្លាប់មនុស្សរាប់លាន ដែលជីវិតអស់កល្បជានិច្ចត្រូវបានផ្តល់ដល់មនុស្សដោយកម្លាំងយ៉ាងខ្លាំង។ ដំណឹងល្អជាចេស្តាក្នុងការធ្វើឱ្យមនុស្សរស់ឡើងវិញយ៉ាងគ្រប់គ្រាន់។

កាលដែលត្រាទីប្រាំត្រូវបានបើកឡើង ហេតុការណ៍ដែលអ្នកជឿត្រូវបានបៀតបៀននិងសម្លាប់ត្រូវបានកើតឡើង។ នេះជាទុក្ខវេទនាដែលអំណឹងល្អនឹងត្រូវបានប្រកាសយ៉ាងល្អ។ ផ្ទុយទៅវិញដំណឹងល្អនឹងត្រូវបានពង្រាយដោយទុក្ខលំបាកយ៉ាងល្អ។ តើអ្វីជាហេតុផលដែលអ្នកដែលត្រូវគេសម្លាប់ទទួលយកការស្លាប់ដោយផ្អែមល្ហែមបែបនេះ? វាជាព្រះបន្ទូលរបស់ព្រះនិងទីបន្ទាប់របស់ពួកគេ។ ពីព្រោះព្រះបន្ទូលរបស់ព្រះជាព្រះបន្ទូលនៃជីវិត វាជាប្រភពនៃជីវិតដែលដោះស្រាយបញ្ហានៃសេចក្តីស្លាប់។ ដូច្នេះ

វាផ្តល់នូវភាពក្លាហានដល់ការត្រូវគេសម្លាប់។ មិនត្រឹមប៉ុណ្ណឹងទេ "សាក្សីដែលពួកគេធ្វើ" មានន័យថាពួកគេប្រកាសពីព្រះគ្រីស្ទ។ ពាក្យថា “សាក្សី” (μαρτυρία) ជាពាក្យដែលមានទំនាក់ទំនងទៅនឹងពាក្យខាងច្បាប់ សាក្សីគួរតែមានទំនួលខុសត្រូវនៅក្នុងបញ្ហាទីបន្ទាល់។ បើទោះជាវាត្រូវបានដោះស្រាយដោយអ្នកផ្សេងទៀតក៏ដោយ គាត់មិនគួរនឹងបោះបង់ចោលព្រះគ្រីស្ទឡើយ។ នៅក្នុងសាក្សីនៃដំណឹងល្អគឺជាមនុស្សដែលស្លាប់រួចហើយដោយស្របច្បាប់។

អ្នកដែលត្រូវគេសម្លាប់ជាព្រឹត្តិការណ៍ពីមុន ដែលយើងគួរទទួលយកដោយស្មគ្រគិត្ត។ តែបញ្ហាចម្បងនោះគឺវាពិបាកនឹងទទួលយកការសម្លាប់ដោយការសម្រេចចិត្តរបស់យើងណាស់។

វាជាបញ្ហាចម្បងដែលចិត្តរបស់យើងចង់បានវា តែសាច់ឈាមរបស់យើងវាខ្សោយណាស់។ ដូច្នេះ អ្នកដែលត្រូវគេសម្លាប់គឺជាបច្ចុប្បន្ន។ ប្រសិនបើព្រះផ្តល់ឱ្យនរណាម្នាក់នូវអំណាច នោះគេនឹងអាចធ្វើបាប។ ដូច្នេះ អ្នកដែលអានដំណាក់កាលនៃការសម្លាប់នឹងមិនថ្វាយបង្គំអ្នកត្រូវគេសម្លាប់ឡើយ តែមើលទៅកាន់ព្រះចេស្តារបស់ព្រះវិញ។ រួចមកមានតែកិច្ចការរបស់អ្នកដែលត្រូវគេសម្លាប់ប៉ុណ្ណោះដែលនឹងបានពេញដោយព្រះគុណដល់យើង។ ពីព្រោះសម្រាប់ការសម្លាប់នេះយើងយល់ថាប្រភពនៃចេស្តារបស់ព្រះនោះអស្ចារ្យណាស់។

ដូចដែលយើងបាននិយាយខាងលើ អ្នកត្រូវគេសម្លាប់គឺបានកើតឡើងដោយសារព្រះគុណរបស់ព្រះ។ ដូចជាកិច្ចការដ៏អស្ចារ្យផ្សេងទៀតដែលបានកើតឡើងដោយអំណាចរបស់ព្រះវិញ្ញាណបរិសុទ្ធដូចជាការចាក់ប្រេងតាំង នោះអ្នកដែលត្រូវគេសម្លាប់ក៏ដូច

គ្នា។ ដូច្នេះ កូល៉ុស 1:10-12 មានបន្ទូលថា “ដើម្បីឱ្យបានដើរបែបគួរនឹងព្រះអម្ចាស់ ទាំងគាប់ចិត្តដល់មនុស្សទាំងអស់ ឱ្យបានបង្កើតផលក្នុងគ្រប់ការល្អ ហើយឱ្យស្គាល់ព្រះកាន់តែច្បាស់ឡើង។ ដោយគ្រប់ទាំងព្រះចេស្តាចំរើនកម្លាំងតាមឫទ្ធិបារមីដ៏ឧត្តមរបស់ទ្រង់ ដើម្បីឱ្យចេះទ្រាំទ្រ ហើយអត់ធន់គ្រប់យ៉ាងដោយអំណរ។ ព្រមទាំងអរព្រះគុណ ដល់ព្រះវរបិតាដែលទ្រង់បានប្រោស ឱ្យយើងបានគួរនឹងទទួលចំណែកកេរ្តិ៍អាករក្នុងពួកបរិសុទ្ធនៅទីភ្លឺផង។” នៅក្នុងបទគម្ពីរនេះ “ដែលត្រូវសម្លាប់” ន័យអសកម្ម “សំបុត្រមក7ដងចេញពីពួកគេ។ គ្រប់ទាំងការល្អ ធ្វើឱ្យអ្នកជឿបានសម្រេច” វាដោយសេចក្តីពិតថាព្រះបានផ្គត់ផ្គង់ព្រះគុណរបស់ទ្រង់។ បិតាគ្រូគង្វាល លោក Spurgeon បានអធិប្បាយ “ព្រះគុណ”។ ក្រោយមកគាត់និយាយថាព្រះគុណនៃការស្លាប់របស់គាត់។ រួចមកគាត់បាននិយាយទៅកាន់ក្រុមជំនុំថា “ព្រះគុណនៃសេចក្តីស្លាប់មិនអាចទទួលបានពេលនេះទេ តែនៅពេលយើងស្លាប់នោះយើងនឹងទទួលបានវា។”

ការអធិប្បាយទី 22 ព្រះបន្ទូលរបស់ព្រះនិងស្ថានសួគ៌ (វិវរណៈ 6:9)

នៅក្នុងអត្ថបទ “នោះនៅក្រោមអាសនា ខ្ញុំក៏ឃើញមានអស់ទាំងព្រលឹងរបស់មនុស្ស ដែលគេបានសម្លាប់ដោយព្រោះកាន់តាមព្រះបន្ទូល និងសេចក្តីបន្ទាល់” ចង្អុលថាពួកគេបានចូលទៅកាន់ស្ថានសួគ៌ (ខ 9)។ ពួកគេបានទូលប្រាប់ព្រះអម្ចាស់ដែលនៅស្ថានសួគ៌ថា “ឱព្រះអម្ចាស់ជាព្រះបរិសុទ្ធ ហើយពិតប្រាកដអើយ តើទ្រង់ចាំដល់កាលណាទៀតបានជំនុំជំរះ ហើយសងសឹកដល់ពួកមនុស្សនៅលើផែនដី ដោយព្រោះឈាមយើងខ្ញុំរាល់គ្នា”។ ពួកគេបានចូលទៅកាន់បល្ល័ង្កហើយពួកគេអាចនិយាយអ្វីដែលពួកគេចង់និយាយ។ ហេតុផលដែលពួកគេបានចូលទៅក្នុងស្ថានសួគ៌ជាព្រះបន្ទូលរបស់ព្រះនិងជាភស្តុតាងដែលពួកគេមាន។ ព្រះបន្ទូលរបស់ព្រះនិងសេច

ក្តីសង្គ្រោះព្រលឹងមិនអាចបំបែកចេញពីគ្នាទេ។ យ៉ាកុប 1:21 និយាយថា “បានជាចូលទទួលព្រះបន្ទូលដែលបានដាំក្នុងចិត្តអ្នករាល់គ្នា ដោយចិត្តសុភាពចុះ ទាំងលះចោលអស់ទាំងសេចក្តីស្មោកគ្រោកចេញ នឹងសេចក្តីគំរក់ដ៏មានច្រើនម្ល៉េះចេញផង ដ្បិតព្រះបន្ទូលនោះអាចនឹងជួយសង្គ្រោះព្រលឹងអ្នករាល់គ្នាបាន”។ ហេព្រើរ 4:1-3 និយាយថា មានតែព្រះបន្ទូលដែលរួបរួមគ្នាតែមួយគត់ដែលជាព្រះបន្ទូលរបស់ព្រះដែលអាចចូលក្នុងគ្រប់យ៉ាងដែលនៅសេសសល់។ 1ពេត្រុស 1:23-2:2 និយាយថា “ដ្បិតព្រះបានបង្កើតអ្នករាល់គ្នាជាថ្មី មិនមែនពីពូជដែលតែងតែពុករលួយនោះទេ គឺពីពូជដែលមិនចេះពុករលួយវិញ គឺជាព្រះបន្ទូលដ៏រស់ ហើយនៅជាប់លាប់។ ព្រោះគ្រប់ទាំងមនុស្សប្រៀបដូចជាស្មៅ ហើយសិរីល្អទាំងប៉ុន្មានរបស់មនុស្សក៏ដូចជាស្មៅ រីឯធម្មតាស្មៅ នោះតែងតែក្រៀមស្វិត ហើយផ្កាក៏រោយរុះទៅ។ តែឯព្រះបន្ទូលនៃព្រះអម្ចាស់ នោះនៅជាប់អស់កល្បជានិច្ចវិញ គឺជាព្រះបន្ទូលនេះ ដែលបានផ្សាយមកអ្នករាល់គ្នាហើយ។ ដូច្នេះ ដែលអ្នករាល់គ្នាបានលះបង់ចោលអស់ទាំងសេចក្តីគំរក់ និងកិច្ចកលទាំងប៉ុន្មាន ព្រមទាំងពុតមាយាចិត្តច្រណែន ហើយពាក្យនិយាយដើមគេទាំងអស់ចេញ នោះត្រូវឱ្យសង្វាតរកទឹកដោះសុទ្ធ ខាងព្រលឹងវិញ្ញាណវិញ ដូចជាទារកដែលទើបនឹងកើត ដើម្បីឱ្យអ្នករាល់គ្នាបានចំរើនធំឡើង ដរាបដល់បានសង្គ្រោះ។” មានតែម្នាក់ដែលទទួលព្រះបន្ទូលរបស់ព្រះនិងប្រកាសវាចេញទៅប៉ុណ្ណោះ ដែលអាចចូលទៅកាន់ស្ថានសួគ៌។ មិនថាមនុស្សល្អ ឬមនុស្សអាក្រក់ទេ បើមិនមានការកើតជាថ្មីដោយទឹកនិងព្រះវិញ្ញាណ នោះគេមិនអាចចូលទៅក្នុងស្ថានសួគ៌បានឡើយ។ យើងមិនគួរភ្លេចថា ព្រលឹងដែលចូលទៅក្នុងស្ថានសួគ៌គួរតែបានផ្លាស់ប្រែដោយព្រះបន្ទូលរបស់ព្រះ។ យើងគួរតែពិចារណានូវការបកស្រាយមួយទៀតនៅទីនេះថា ព្រលឹងនោះគួរតែត្រូវបានសម្លាប់ ដែលពាក្យនេះមានព្រុំដែលកំណត់ដល់តែពួកដែលគេសម្លាប់ប៉ុណ្ណោះ ប៉ុន្តែជាអ្នកជឿទូទៅដែលមានការផ្លាស់ប្រែ នោះជាអ្វីដែលលោក Ds A Ringnalda បាននិយាយថា "គ្រីស្ទានទូទៅក៏ជាម្នាក់ដែលចូលរួមនៅក្នុងទុក្ខលំបាក

និងសេចក្តីស្លាប់របស់ព្រះគ្រីស្ទ។" មើលទៅ ភីលីព 3:10, 17, 6:5 1កូរិនថូស 15:31 2កូរិនថូស 4:10, 11 Col 1:24។

ដូច្នេះ យ៉ូហានមិនគិតពីអ្នកដែលត្រូវគេសម្លាប់ទេ តែគិតពីគ្រប់អ្នកជឿទាំងអស់ដែលបានចូលរួមនៅក្នុងទុក្ខលំបាកនិងសេចក្តីស្លាប់វិញ។ (Het Koingschap Van Christus, 1939, Kampen . pp 131-132)

ការអធិប្បាយ 23 ការអង្វរការរបស់អ្នកត្រូវគេសម្លាប់និងការកំសាន្តរបស់ពួកគេ (វិវរណៈ 6:9-11)

1, ហេតុផលដែលពួកគេត្រូវបានសម្លាប់

ពាក្យថា "ដ្បិតព្រះបន្ទូលរបស់ព្រះនិងសេចក្តីបន្ទាល់" បានបង្ហាញពីហេតុផលនៃការសម្លាប់របស់ពួកគេ។ ពួកគេត្រូវស្លាប់ដោយសារការប្រកាសព្រះបន្ទូលរបស់ព្រះ។ អ្នកជឿគួរពិចារណាការស្លាប់បែបនេះទុកជាសិរីល្អរបស់គេ។ (ម៉ាថាយ 5:10, 11)។ មនុស្សដែលទទួលបានជីវិតអស់កល្បតាមរយៈព្រះគ្រីស្ទ ដែលព្រះបន្ទូលរបស់ព្រះបង្ហាញ និងដោយការកាន់តាមព្រះបន្ទូលរបស់ទ្រង់ នោះគេទទួលបានយ៉ាងបរិបូរណ៍នៃពិភពលោកដែលនឹងមកដល់។ ពីបុរាណអ្នកដែលត្រូវគេសម្លាប់បែបនេះបានប្រាប់ទៅកាន់អ្នកសម្លាប់ថា "អ្នកបានយកជីវិតមួយចេញពីខ្ញុំដែលខ្ញុំមិនអាចរក្សាវាបាន ហើយបានផ្តល់ជីវិតមួយដល់ខ្ញុំដែលខ្ញុំមិនអាចនឹងបាត់បង់បាន"។

3. ការទូលអង្វររបស់ពួកគេ

នៅពេលយើងគិតពីអ្នកដែលត្រូវគេសម្លាប់ យើងគួរតែនិយាយថា ពីព្រោះពួកគេមានអារម្មណ៍ពីភាពផ្អែមល្ហែមនៃការសុគតរបស់ទ្រង់ នោះពួកគេបានស្លាប់ទុកដូចជាសេចក្តីសប្បុរស។ ការដែលត្រូវបានបៀតបៀនជាព្រឹត្តិការណ៍ដែលត្រូវបានធ្វើទុក្ខ។ ការសម្លាប់ជាហេតុការណ៍ដ៏ឈឺចាប់បំផុត។ ទុក្ខលំបាកដែលពួកគេបានទទួលមិនមែន

ជាការកំសាន្តសម្រាប់ពួកគេទេ។ ជំហ៊ានរបស់ពួកគេរហូតដល់ពួកគេត្រូវសម្លាប់គឺជាមានការឈឺចាប់រហូតដល់ទីបំផុត។ ពួកគេមានការជាច្រើនត្រូវនិយាយ។ តែវាជាការពិតដែលថា បើទោះជាពួកគេត្រូវរងទុក្ខក៏ដោយ ជួនកាលពួកគេត្រូវបានលួងលោមពីព្រះអម្ចាស់។ អ្នកបរិសុទ្ធពិតនឹងស៊ូទ្រាំ និងរងចាំជានិច្ចនៅក្នុងទុក្ខលំបាកនិងការបៀតបៀន។ អេសាយនិយាយថា "រីឯខ្ញុំៗនឹងទន្ទឹងចាំព្រះយេហូវ៉ា ដែលទ្រង់លាក់ព្រះភក្ត្រនឹងពូជយ៉ាកុប ខ្ញុំនឹងចាំមើលតែទ្រង់។" (អេសាយ 8:17)។ ហើយគាត់បាននិយាយថា “ទោះបីជាយ៉ាងណា គង់តែព្រះយេហូវ៉ាទ្រង់រង់ចាំឱកាស នឹងផ្តល់ព្រះគុណដល់ឯងរាល់គ្នាដែរ ហើយនោះបើយ៉ាងនោះក៏ដោយ គង់តែទ្រង់នឹងចាំឯងលើកដំកើងទ្រង់ឡើង ដើម្បីឱ្យទ្រង់មានសេចក្តីអាណិតមេត្តាដល់ឯង ពីព្រោះព្រះយេហូវ៉ាទ្រង់ជាព្រះដ៏ប្រកបដោយយុត្តិធម៌។” (អេសាយ 30:18)។ លោក Spurgeon បាននិយាយដូចតទៅនេះ។ ហេតុផលដែលព្រះអនុញ្ញាតទុក្ខលំបាកដល់បុត្ររបស់ទ្រង់ឱ្យរងទុក្ខជាយូរគឺ ដើម្បីនឹងសាកល្បងថាពួកគេនឹងមើលងាយដល់ព្រះ និងចាកចេញពីទ្រង់ទេ។ លោក Samuel Rutherford និយាយថា “នៅគ្រាងងឹតដែលព្រះយេស៊ូវចាកចោលខ្ញុំ ហើយនៅឆ្ងាយពីខ្ញុំ ខ្ញុំនឹងគិតពីកំឡុងពេលងងឹតរបស់ខ្ញុំដោយចិត្តអរព្រះគុណ។ ផ្កាតែងតែត្រូវការពេលងងឹតនៅពេលយប់ជាពន្លឺព្រះអាទិត្យនៅពេលថ្ងៃ។ ដូចគ្នាដែរគ្រានៃភាពងងឹតនោះដែលព្រះយេស៊ូវចាកចេញពីខ្ញុំជាផលប្រយោជន៍ដល់ខ្ញុំ វាធ្វើឱ្យយើងចេះបន្ទាបខ្លួននិងជឿដល់ទ្រង់។” សេចក្តីជំនឿហាមនូវដំណើរលឿន។ ពីព្រោះព្រះកំពុងរង់ចាំជាយូរហើយដើម្បីនឹងផ្តល់ព្រះគុណដល់ពួកគេ។ មានស្ត្រីម្នាក់ដែលមានអារក្សចូលអស់រយៈពេល18ឆ្នាំ ត្រូវបានព្យាបាលដោយចេស្តារបស់ព្រះយេស៊ូវ (លូកា 13:11-13) អ្នកជំងឺអាយុ38ឆ្នាំនៅក្បែងស្រះបេតសេដា។ ដូច្នេះ យើងគួរតែទ្រាំទ្រនិងរង់ចាំកាលដែលយើងជួបនឹងការធ្វើទុក្ខនានា។

ការអធិប្បាយទី 24 ហេតុអ្វីពួកគេត្រូវបានសម្លាប់? (វិវរណៈ 6:9)

នៅក្នុងអត្ថបទពាក្យថា “ព្រលឹងរបស់មនុស្សដែលគេបានសម្លាប់” ដែលអានដូច្នេះថា ថាស់ ភូស្សខាស់ ថន អេស្ពីម៉ែណន (τὰς ψυχὰς τῶν ἐσφαγμένων)។ វាមានន័យថា “ព្រលឹងរបស់ពួកអ្នកដែលត្រូវគេសម្លាប់”។ ត្រង់ចំណុចនេះ តើហេតុអ្វីបានជាពួកគេត្រូវជួបបែបនេះ? ហេតុផលនៃការសម្លាប់របស់ពួកគេគឺដូចតទៅនេះ។

1. ពួកគេត្រូវសម្លាប់ដោយការពិតដែលថាព្រះបន្ទូលរបស់ព្រះគឺពិតប្រាកដមែន ។

ប្រវត្តិសាស្ត្ររបស់មនុស្សជាតិគឺត្រូវបានយល់ច្រឡំពីបទគម្ពីរ ព្រះបន្ទូលរបស់ព្រះមិនមានកំហុសអ្វីទាំងអស់។ ទ្រឹស្តីថ្មីបាននិយាយថា ទោះបីជាបទគម្ពីរមិនមានកំហុសក្នុងគោលការណ៍នៃការបង្រៀនក៏ដោយ ក៏វាមានកំហុសតិចតួចអាចកើតឡើងដែរ ឬទោះបីជាវាមានកំហុសខ្លះក៏ដោយ ក៏វាមិនមានបញ្ហាអ្វីដែរ។ មានន័យថា បើឆ្នាំងទឹកមានរន្ធធំ នោះវាពិតជាមានអ្វីខុសហើយ ប៉ុន្តែវាប្រៀបដូចជាគ្មានបញ្ហាទេ បើមានវារន្ធតូច។ បើធុងទឹកមានរន្ធតូច ទឹកនឹងចេញមកក្រៅ។ ព្រោះចិត្តរបស់មនុស្សខូច គេសង្ស័យសូម្បីតែរឿងដែលពិត។ ប្រសិនបើបទគម្ពីរមានរឿងខុសតិចតួច ដែលជាផ្នែកពិតនៃបទគម្ពីរនោះ យើងអាចសង្ស័យថា “វាអាចចេញមកពីកំហុស”។ ប៉ុន្តែដោយសារព្រះគឺជាសេចក្តីពិត នោះព្រះបន្ទូលរបស់ទ្រង់គ្មានអ្វីក្រៅពីសេចក្តីពិតទាំងស្រុងនោះទេ។ ការដែលបទគម្ពីរគ្មានកំហុស គឺជាការយល់ឃើញរបស់ព្រះអម្ចាស់របស់យើ

ង។ ព្រះយេស៊ូមានព្រះបន្ទូលថា “(ម៉ាថាយ 5:17, 18 ប្រៀបធៀបនឹង យ៉ូហាន 10:35។ ពួកសាវកក៏មានទស្សនៈដូចគ្នាពីបទគម្ពីររបស់ព្រះយេស៊ូវដែរ។ ពួកសាសនៈវិទូខាងកំណែទម្រង់ក៏ជឿដូចគ្នាដែរ។ លោក Herman Bavinck បាននិយាយថា "អ្នកសាសនៈវិទូខាងកំណែទម្រង់បានទទួលបទគម្ពីរនិងគោលលិទ្ធិសេចក្តីជំនឿនៃការបើកសម្តែងដែលក្រុមជំនុំបានប្រកាស។ នៅក្នុងទស្សនៈរបស់លោក Luther ពីបទគម្ពីរដែលគាត់មានគំនិតមិនពេញចិត្តនឹងការផ្លាស់ប្រែថ្មីទៅនឹងទស្សនៈនៃសេចក្តីសង្គ្រោះ គាត់បានធ្វើការវាយតម្លៃលើយ៉ាកុបជាដើមយ៉ាងទាប។ (ចំណាំថា លោក Luther ត្រូវបានប្រាប់មកថាបានទទួកស្គាល់សំបុត្ររបស់យ៉ាកុបទុកជាបទគម្ពីរ)។ ប៉ុន្តែនៅក្នុងអត្ថន័យរឹងតឹងគាត់ក៏មានន័យដូចនេះដែរថា គាត់ជឿលើទ្រឹស្តីនៃការបើកសម្តែងរបស់អក្សរសាស្ត្រ។ សាសនៈវិទ្យាបែបលោកលូធើជឿលើទ្រឹស្តីដូចគ្នាដែរ។ ប្រៀបដូចការនេះដែរនៅក្នុងទ្រឹស្តីនៃការបើកសម្តែងដែលមុតមាំ លោក កាល់វីនក៏ជឿទ្រឹស្តីនៃការបើកសម្តែងដែលគ្មានកំហុសសោះដែរ (សម្គាល់- លោក B Warfield ជាម្នាក់ក្នុងចំណោមសាសនៈវិទូកាល់វីនក៏ជឿលើទ្រឹស្តីនៃការបើកសម្តែងតាមរយៈអក្សរសាស្ត្រផងដែរ។ គាត់បាននិយាយដូចតទៅនេះថា “” បទគម្ពីរជាផលផ្លែដែលសកម្មភាពរបស់ព្រះនិងសកម្មភាពរបស់មនុស្សត្រូវបានរួបរួមជាមួយគ្នា។ តែនៅក្នុងធាតុនៃលក្ខណៈរបស់មនុស្សនោះវាគ្មានកំហុសទេ។ ពីព្រោះវាត្រូវបានដឹកនាំដោយការដឹកនាំរបស់ព្រះវិញ្ញាណបរិសុទ្ធនៅការបើកសម្តែងរបស់ទ្រង់។” (មានទាំងផ្នែករបស់មនុស្សនិងព្រះនៅក្នុងបទគម្ពីរ។ ដូច្នេះនៅក្នុងការបង្កើតជាបទគម្ពីរដោយការភ្ជាប់សកម្មភាពរបស់មនុស្សនិងធាតុរបស់ព្រះ ធាតុរបស់មនុស្សធ្វើសកម្មភាពតាមបែបមនុស្សហើយបានបន្សល់សញ្ញារបស់គេនៅក្នុងផលិតផលនោះដូចនោះ តែមិនអាចធ្លាក់ចូលក្នុងកំហុសដែលយើងនិយាយថាមនុស្សបានធ្លាក់នោះទេ ពីព្រោះការ

នោះមិនអាចកើតឡើងបានដោយដាច់ចេញពីផ្នែករបស់ព្រះឡើយ តែត្រូវបាននៅក្រោមការដឹកនាំដែលគ្មានកំហុសសោះវិញ– International Standard Bible Encyclopedia) លោក Charles Hodge ក៏ជឿការដូចគ្នានៃការបើកសម្តែងរខាងអក្សរសាស្ត្រដែរ។ ការបើកសម្តែងលាតសន្ធឹងស្មើគ្នាដល់គ្រប់ផ្នែកនៃបទគម្ពីរ ការបើកសម្តែងរបស់បទគម្ពីរលាតសន្ធឹងរហូតដល់ពាក្យទាំងអស់ គំនិតទាំងអស់នៅក្នុងពាក្យ ហើយព្រះគ្រីស្ទ និងពួកសាវកត្រូវបានជជែកវែកញែកចេញពីពាក្យនីមួយៗនៃបទគម្ពីរ– Systematic Theology Vol I p 163)។

2. ពួកគេត្រូវបានសម្លាប់ដោយសារព្រះបន្ទូលរបស់ព្រះដែលវាមានសិរីរុងរឿងនិងតម្លៃណាស់

បទគម្ពីរបានសន្យាព្រះរាប់មិនអស់ទៅកាន់អ្នកដែលជឿព្រះគ្រីស្ទ។ វាជាជីវិតអស់កល្បជានិច្ច ជាជីវិតអស់កល្បជានិច្ចដែលចង្អុលទៅកាន់ថាបានក្លាយជាបុត្ររបស់ព្រះនិងចូលទៅកាន់ការសន្យាថានឹងបានមរដកដែលនឹងទទួលបែបជាបុត្ររបស់ទ្រង់។ រ៉ូម 8:31 ហៅមួយនេះថា “គ្រប់ការទាំងអស់ (τὰ πάντα)” ព្រះពរនេះមិនត្រូវបានរាប់ទេ ដ្បិតវាជាសិរីរុងរឿង ដែលយើងមិនអាចនិយាយបាន។ (1 ពេត្រុស 1:8, 2 កូរិនថូស 9:15)។

3. ព្រះបន្ទូលរបស់ព្រះដែលជាបទគម្ពីរនោះជាបទបញ្ជាត្តិរបស់ព្រះ

ព្រះបន្ទូលនៃបទគម្ពីរមិនមែនត្រឹមតែជាគំនិតមួយនោះទេ។ គ្មានការស្តាប់បង្គាប់ គេនឹងត្រូវស្លាប់និងត្រូវរងគ្រោះ។ ប្រសិនបើគេស្តាប់តាមវា គេនឹងទទួលបានជីវិតអស់កល្បជានិច្ចដូចដែលព្រះអម្ចាស់បានបង្គាប់មក។ កាលដែលយើងមិនស្តាប់តាមព្រះបន្ទូលនៃសេចក្តីពិត នោះយើងនឹងត្រូវមានទោស។ អ្វីដែលយើងមើលឃើញចម្លែក

នៅក្នុងលោកិយនេះគឺ ជាការមើលឃើញជាទូទៅថា មនុស្សមានបាបនឹងមិនត្រូវដាក់ទោសទេ។ ហើយបើទោះជាមនុស្សមានបាបមិនព្រមផ្លាស់ប្រែចិត្តក៏ដោយ យើងឃើញថាពួកគេជួនកាលនៅតែរស់នៅយ៉ាងសុខសប្បាយ។ តែយើងគួរតែសង្កេតមើលពីហេតុផលឱ្យបានច្បាស់ល្អ។ នៅពេលយើងដឹងថាលោកិយនេះមិនមែនជាវាលនៃការជំនុំជំរះនៅឡើយទេ។ ព្រះទុកចោលមនុស្សមានបាបមួយចំនួនឱ្យនៅសភាពបច្ចុប្បន្នរបស់ពួកគេ។ ប៉ុន្តែទ្រង់ដាក់ទោសដល់មនុស្សមានបាបផ្សេងទៀត។ ហេតុផលដែលទ្រង់ដាល់ទោសដល់ពួកគេ គឺដើម្បីធ្វើឱ្យពួកគេយល់ថាព្រះទ្រង់ជាអ្នកកាត់ទោសទ្រង់គង់នៅហើយថាការជំនុំជំរះនៅតែមាន។ នៅក្នុងការដាក់ទោសមនុស្សមានបាបមួយចំនួន ទម្រង់នៃការដាក់ទោសត្រូវបានបើកបង្ហាញដោយលោក Ja sung Ja bag (វាត្រូវបានចងដោយអារម្មរបស់គេផ្ទាល់)។ តួអង្គដែលត្រូវបានដាក់ទោសត្រូវបានបង្ហាញយ៉ាងច្បាស់។ ស្តេច Henry III របស់ដែលមានគម្រោងសម្លាប់ពួកប្រឆាំងគាត់ត្រូវបានសម្លាប់ដោយវាយនឹងដាវ Maxi minus បានខ្វេះភ្នែករបស់អ្នកប្រឆាំងរាប់ពាក់នាក់ អំពើបាបរបស់គាត់នៅក្នុងចំណោមអាស្ត្ររបស់គាត់ នោះជម្ងឺភ្នែកត្រូវបានរាតត្បាត ហើយគាត់ផ្ទាល់ក៏ត្រូវបានស្លាប់ដោយជម្ងឺនោះដែរ។ ដូច្នេះព្រះបន្ទូលរបស់ព្រះគឺពិតជាគួរឱ្យខ្លាចណាស់។

សរុបសេចក្តី៖

អ្នកដែលត្រូវគេសម្លាប់ពិតបើទោះជាគេបានស្លាប់ដោយសារព្រះបន្ទូលរបស់ព្រះក៏ដោយ។ យើងមិនគួរត្រឡប់ទៅកាន់អ្នកដែលត្រូវគេសម្លាប់សម្រាប់សេចក្តីពិតនេះលើយតែយើងគួរដឹងថាត្រូវត្រឡប់ទៅរកព្រះបន្ទូលរបស់ព្រះវិញ។ មានមនុស្សជាច្រើនដែលថ្វាយបង្គំអ្នកដែលត្រូវគេសម្លាប់ តែនៅតែមើលងាយដល់ព្រះបន្ទូលរបស់ព្រះដដែល។

វាមិនមែនជាទង្វើដែលគួរឱ្យពេញចិត្តនោះទេ។ យើងដែលជាអ្នកត្រូវគេសម្លាប់បានស្មោះត្រង់ចំពោះព្រះរហូតដល់ស្លាប់ យើងគួរចងចាំថាព្រះបន្ទូលរបស់ព្រះពិតនិងល្អ ហើយបំបែកនូវការសង្ស័យនៅក្នុងយើង ហើយត្រឡប់ទៅរកព្រះបន្ទូលរបស់ព្រះម្តងទៀតហើយយើងនឹងទទួលបានអំណាច។

ការអធិប្បាយទី 25 ចលនានៃដំណឹងល្អនិងគ្រោះទូទៅ (វិវរណៈ 6:3-11)

ជំពូក6បង្ហាញពីដំណើរការនៃដំណឹងល្អនិងគ្រោះទូទៅ។ ពីព្រោះគ្រោះទូទៅបានបន្តមកដើម្បីធ្វើឱ្យពួកបរិសុទ្ធបានប្រែចិត្ត វិវរណៈជំពូក6និយាយពីសង្គ្រាម គ្រោះអំណត់អត់ ការបៀតបៀន និងគ្រោះផ្សេងៗទៀត។ ហើយគ្រោះចុងក្រោយសម្រាប់ការជំនុំជំរះ។ ការទាំងនេះត្រូវបានកត់ត្រានៅក្នុងជំពូច 16-20។

1. ដំណើរការនៃដំណឹងល្អនិងគ្រោះទូទៅ

ដំណើរការនៃដំណឹងល្អជាសញ្ញានៃការយាងមកលើកទីពីររបស់ព្រះអម្ចាស់។ ការសម្រេចនៃជំហានដែលលូតលាស់របស់គេដែលព្រមានថាការយាងមកលើកទីពីររបស់ព្រះអម្ចាស់ជិតមកដល់ហើយ។ ខ “អ្នកដែលជិះនៅលើសេះសហាក់ដូចជាចង្អុលទៅកាន់ដំណើរការនៃដំណឹងល្អ។ វាជាលំដាប់លំដោយធម្មជាតិដើម្បីឱ្យការយាងមកលើកទីពីររបស់ព្រះអម្ចាស់ ជាដំណើរការនៃដំណឹងល្អនឹងកើតឡើងជាដំបូង” ម៉ាថាយ 24:14 មានបន្ទូលថា “ដំណឹងល្អនេះ ដែលសំដែងពីនគរ នឹងត្រូវប្រកាសទូទៅគ្រប់ក្នុងលោកិយ ទុកជាទីបន្ទាល់ដល់អស់ទាំងសាសន៍ នោះទើបនឹងបានដល់ទីចុងបំផុត។” លូកា 21:24 និយាយថា “ពួកគេនឹងដួលនៅក្រោមមុខដាវ ហើយនឹងត្រូវដឹកនាំទៅជាឈ្លើយដល់អស់ទាំងនគរ ក្រុងយេរ៉ូសាឡិម និងត្រូវ

សាសន៍ដទៃជាន់ឈ្លី ដរាបដល់គ្រារបស់សាសន៍ដទៃបានសម្រេច។” ដូច្នេះតើដំណើរការនៃដំណឹងល្អនឹងកើតឡើងដោយអំណាចខ្លាំងប៉ុណ្ណាទៅ? នៅក្នុងវិវរណៈ 6:2 “ខ្ញុំក៏ក្រលេកទៅឃើញសេះស1 ឯអ្នកដែលជិះក៏កាន់ធ្នូ ហើយមានគេឱ្យមកុដដល់អ្នកនោះ រួចអ្នកចេញទៅយ៉ាងមានជ័យជំនះ ហើយឱ្យមានឈ្នះតទៅ។” មានន័យថាជាជ័យជំនះនៃដំណឹងល្អ ដែលវាត្រូវបានសម្រេចនៅក្នុងប្រវត្តិសាស្ត្រយ៉ាងច្បាស់លាស់។ សាសនាគ្រឹស្តបានក្លាយជាសាសនារបស់លោកិយ។ ពុទ្ធសាសនានិងកុងជឺមិនបានក្លាយជាសាសនារបស់លោកិយទាំងមូលឡើយ។ នៅគ.ស 2000 គ្រីស្ទានមួយចំនួនមាន 50 លាននាក់ 500 ឆ្នាំក្រោយមកវាកើនដល់100 លាននាក់។ 300 ឆ្នាំក្រោយមកវាបានកើនឡើងម្តងទៀតទ្វេរដងដែលបានដល់ 20 លាន។ 80 ឆ្នាំក្រោយមកវាបានកើនឡើងទ្វេរដង គឺកើនដល់ 40 លាន។ តែនៅពេលណាដែលដំណើរការនៃការផ្សាយដំណឹងល្អនេះបានកើតឡើងដោយស្មោះត្រង់បំផុតនោះ? គឺជាពេលដែលគ្រោះទូទៅបានកើតឡើង។

(1) សង្គ្រាម

នៅក្នុងខ 3-4 មានម្នាក់ដែលជិះសេះក្រហមដែលមានន័យថាជាការធ្វើសង្គ្រាម ហើយសេះខ្មៅនៅក្នុងខ 5, 6 មានន័យថាជាគ្រោះអំណត់អត់។ សង្គ្រាមនិងគ្រោះអំណត់អត់ដើរជាមួយគ្នា។ កាលដែលពេលនៃសង្គ្រាម នោះអាហារក៏ខ្វះខាតដែរ។ នៅក្នុងខ 7-8 វាបង្ហាញពីសេះខៀវ លឿង ដែលវាចង្អុលទៅ “លុះបកត្រាទីបួន នោះខ្ញុំឮតួជីវិតទីបួនថា ចូរមកមើលចុះ ខ្ញុំក៏ក្រឡេកមើលទៅឃើញសេះមួយសម្បុរស្លាំង ឯអ្នកដែលជិះមានឈ្មោះថា សេចក្ដីស្លាប់ ហើយស្ថានឃុំព្រលឹងមនុស្សស្លាប់ ក៏តាមអ្នកនោះទៅ គេឱ្យទាំងពីរនោះមានអំណាចលើផែនដីមួយភាគបួន ដើម្បីនឹងសំឡាប់

ដោយដាវ អំណាត់អត់ និងសេចក្តីវេទនា ហើយដោយសត្វព្រៃនៅផែនដីផង។" (វាមានន័យថាបញ្ហានៃសង្គ្រាមនិងបញ្ហានៅក្នុងការផ្សេងទៀត)។ ការបីយ៉ាងនៃចំណុចខាងលើចង្អុលពីទុក្ខវេទាននៅក្នុងកណ្តាលនៃសង្គ្រាម។ សង្គ្រាមមានទំនាក់ទំនងនឹងការផ្សាយដំណឹងល្អយ៉ាងជិតស្និតនៅក្នុងទស្សនៈនៃមេរៀនពីប្រវត្តិសាស្ត្រ ដូច្នេះទុក្ខវេទនាជាទុក្ខវេទាននៃការក្រឹត្យមកដើម្បីនឹងត្រាស់ហៅរាស្ត្រដែលបានជ្រើសរើសដែលជាការផ្សាយដំណឹងល្អនោះ។ ដោយការវាយប្រហាររបស់ទីតុស ជាមេទ័ពរបស់រ៉ូមដែលវាយទៅកាន់ពួកយូដា មានសាសន៍យូដាជាច្រើនត្រូវបានខ្ចាត់ខ្ចាយទៅក្រៅប្រទេស ហើយរួចមកដំណឹងល្អក៏បានរីកសាយឡើងទៅប្រទេសផ្សេងទៀត។ ដំណឹងល្អបានចូលទៅកាន់តំបន់នីមួយៗនៅក្នុងអាណាចក្ររ៉ូមរហូតដល់សតវត្សទី5។
ប្រទេសផ្សេងទៀតនៅអឺរ៉ុបមិនបានទទួលដំណឹងល្អទេ នៅក្នុងគ.ស 476 កាលដែលកុលសម្ព័ន្ធរបស់ Vandals បានវាយលុកចូលក្រុងរ៉ូម។ អ្នកទោសនៅរ៉ូមបានចូលទៅអឺរ៉ុបនិងប្រទេសផ្សេងទៀតនិងបានប្រកាសដំណឹងល្អ។ កុលសម្ព័ន្ធ Frank ក៏បានទទួលដំណឹងល្អ ពីព្រោះស្តេច Clovie បានជឿដំណឹងល្អនៅក្នុងសង្គ្រាម។ កុលសម្ព័ន្ធ Goths (អាល្លឺម៉ង់) ក៏បានវាយលុកចូលក្រុងរ៉ូម ហើយពួកគេបានរៀនដំណឹងល្អដោយអ្នកទោសដែលពួកគេចាប់បាន។ មិនត្រឹមតែប៉ុណ្ណោះទេ ប្រទេសអៀឡង់ក៏បានទទួលដំណឹងល្អដោយសារអ្នកទោសក្នុងសង្គ្រាមផងដែរ។ នៅក្នុងទីក្រុង Down នៅអៀឡង់អ្នកទោសម្នាក់បានស្នាក់នៅអស់រយៈពេល6ឆ្នាំ។ ឈ្មោះរបស់គាត់គឺ Patrick ដែលគាត់បានជឿដំណឹងល្អពេលគាត់អាយុ 16 ឆ្នាំ បានធ្វើការជាអ្នកមើលថែរចៀម ហើយគាត់បានខិតខំអធិស្ឋានតាមទម្លាប់កាលគាត់នៅក្មេង។ គាត់បានចូលទៅក្នុងភ្នំនៅពេលព្រឹកព្រលឹម ហើយអធិស្ឋាន ឬនៅលើព្រិល ឬនៅក្នុងពេលភ្លៀងដែលគាត់អធិស្ឋាន។ រួចមកគាត់បានថ្វាយខ្លួនគាត់ទៅព្រះដោយអស់ពីចិត្ត។ តាមរយៈសំបុត្រដែលគាត់ផ្តល់ត្រឡប់មកប្រទេសគាត់វិញ តែគាត់បានត្រឡប់អៀឡង់មកម្តងជាបេសកជន គាត់ចាប់ផ្តើមធ្វើការផ្សាយដំណឹងល្អនៅផ្ទះចៅហ្វាយមុនរបស់គាត់។ គាត់បានទទួលការអំណោយជាកន្លែងអោយចំណីជ្រូកទុកជាដី

សម្រាប់អាគារព្រះវិហារ ហើយគាត់បានសង់ក្រុមជំនុំយ៉ាងធំអស្ចារ្យនៅទីនោះ។ គាត់បានសង់ក្រុមជំនុំចំនួន 365 នៅជុំវិញប្រទេសអៀឡង់។ លោក Blackburn បាននិយាយថា "បើទោះជាប្រទេសអ៊ីតាលីនិងក្រុមជំនុំនៅហ្គាល(ប្រទេសបារាំង)ត្រូវបានគៀបសង្កត់ដោយអ្នកលុកលុយក៏ដោយ តែពួកគេបានផ្តល់ដំណឹងល្អដល់អ្នកដែលចូលលុកលុយនោះ។" កាលដែល Pepin ជាស្តេចរបស់ Frank បានលុកលុយចូលអាល្លឺម៉ង់ ហើយទ្វារនៃដំណឹងល្អបានបើកទៅកាន់អាល្លឺម៉ង់។ យើងអាចដឹងថាតាមរយៈហេតុការន៍ប្រវត្តិសាស្ត្ររឿងដែលជាបញ្ហាដូចជាសង្គ្រាមធ្វើឱ្យប៉ះពាល់ដល់ដំណើរការនៃការផ្សាយដំណឹងល្អ។ ទំនុកដំកើង 119:67 មានបន្ទូលថា “កាលមុនដែលទូលបង្គំកើតទុក្ខព្រួយ នោះទូលបង្គំបានវង្វេងទៅ តែឥឡូវនេះ ទូលបង្គំកាន់តាមព្រះបន្ទូលទ្រង់វិញ”។ ទំនុកដំកើង 119:69-72 មានបន្ទូលថា “ពួកមនុស្សឆ្មើងឆ្មៃបានបង្កើតសេចក្តីភូតភរទាស់នឹងទូលបង្គំ តែទូលបង្គំនឹងរក្សាទុកនូវបញ្ញត្តទ្រង់យ៉ាងអស់ពីចិត្ត ចិត្តគេស្ពឹកដូចជាមនុស្សមានខ្លាញ់ខន់ តែទូលបង្គំមានចិត្តអំណរចំពោះក្រឹត្យវិន័យទ្រង់វិញ ការដែលទូលបង្គំកើតមានទុក្ខព្រួយ នោះគឺជាប្រយោជន៍ដល់ទូលបង្គំហើយ ដើម្បីឱ្យទូលបង្គំបានរៀនយកបញ្ញត្តរបស់ទ្រង់ ក្រឹត្យវិន័យដែលចេញពីព្រះឱស្ឋទ្រង់មកនោះវិសេសដល់ទូលបង្គំ ជាជាងមាសប្រាក់ទាំងពាន់ផង។”

(2) ការបៀតបៀន

នៅពេលដែលត្រាទីប្រាំបានបើកឡើង រូបភាពរបស់អ្នកដែលត្រូវគេសម្លាប់ត្រូវបានបង្ហាញមក។ (9-11) ដំណឹងល្អរបស់គ្រីស្ទានមិនត្រូវបានលុបបំបាត់ដោយសារការបៀតបៀនឡើយ តែវាត្រូវមានជ័យជំនះវិញថែមទៀត។ នៅក្នុងក្រុមជំនុំដើមដោយសារតែការបៀតបៀនដែលស្ទើជានត្រូវបានសម្លាប់ ពួកសិស្សត្រូវបានខ្ចាត់ខ្ចាយទៅគ្រប់ទីកន្លែង ហើយបានប្រកាសដំណឹងល្អទៅ។ (កិច្ចការ 8:4) លោក Augustine និយាយថា "អស់រយៈពេល300នៅក្នុងក្រុមជំនុំដើម ក្រុមជំនុំបានលូត

លាស់ដោយសារការបៀតបៀន។ ចាប់ពីពេលដែលព្រះចៅអធិរាជខនស្តេនធីនបានបង្កើតសាសនាគ្រឹស្តជាសាសនារបស់ជាតិមក នោះក្រុមជំនុំត្រូវបានបំផ្លាញវិញ"។ មិនត្រឹមតែប៉ុណ្ណោះទេ ក្រុមជំនុំក៏ត្រូវបានទ្រទ្រង់ឱ្យស្ថិតស្ថេរដោយសារការបៀតបៀនផងដែរ។ ក្រុមអ្នកដឹកនាំក្រុមជំនុំត្រូវបានបង្ហាញឱ្យឃើញដោយសារតែលទ្ធផលនៃការបៀតបៀន។ ពន្លឺនៃដំណឹងល្អបានចែងចាំងឡើងដោយសារតែការបៀតបៀននោះ។

លោក Jerome ជាម្នាក់ដែលត្រូវគេសម្លាប់ដែលគាត់មកពី Bohemia គាត់ត្រូវបានគេចាប់ខ្លួនដោយសារមានជំនឿដែលត្រឹមត្រូវ ហើយត្រូវបានគេយកទៅដុត រួចមកគាត់បាននិយាយថា "ដូចដែលព្រះអម្ចាស់របស់ខ្ញុំត្រូវបានបំពាក់ដោយមកុដបន្លានោះខ្ញុំត្រូវគ្រងដោយមកុដនៃការចំអកឡកឡឺយដោយអំណរសម្រាប់ទ្រង់ដែរ"។ គាត់បានទៅកាន់ទីបញ្ចុះសពដោយការសរសើរដំកើង ហើយបើទោះជាគាត់ត្រូវគេដុតក្នុងភ្លើងនិងបាត់សម្លេងរបស់គាត់ក៏ដោយ គាត់បានកម្រើកបបូរមាត់យ៉ាងលឿងនិងអធិស្ឋានរយៈពេល 15 នាទី។ ព្រះយេស៊ូវបានរងទ្រាំឈើឆ្កាងសម្រាប់ខ្ញុំ តើហេតុអ្វីបានជាខ្ញុំត្រូវរក្សាសេចក្តីសុខទៅ? ទុក្ខវេទនាផ្តល់ឱ្យចិត្តរួចផុតពីអំពើបាប នៅពេលដែលពួកបរិសុទ្ធសម្រាក។ វាងាយទេដែលត្រូវបាត់ការប្រុងប្រយត្នហើយធ្លាក់ទៅធ្វើបាប។ តែកាលដែលគេត្រូវធ្វើទុក្ខ នោះគេអាចភ្ញាក់ឡើងហើយអធិស្ឋាន ហើយចែងចាំងពន្លឺរបស់គេ។ 1ពេត្រុស 4:1,2 មានបន្ទូលថា "ដូច្នេះ ដែលព្រះគ្រីស្ទទ្រង់បានរងទុក្ខក្នុងសាច់ឈាមជំនួសយើងរួចហើយ នោះត្រូវឱ្យអ្នករាល់គ្នាមានគំនិតដូច្នោះដែរទុកជាគ្រឿងការពារខ្លួន ដ្បិតអ្នកណាដែលបានរងទុក្ខក្នុងសាច់ឈាម នោះបានឈប់ខាងឯអំពើបាបហើយ ដើម្បីកុំឱ្យបង់ពេលដែលសល់ និងរស់នៅខាងសាច់ឈាមតាមតែសេចក្តីប៉ងប្រាថ្នារបស់មនុស្សទៀតឡើយ គឺតាមបំណងព្រះហឫទ័យនៃព្រះ

វិញ”។ តើវាមានន័យយ៉ាងណា? វាមានន័យថា យើងដែលជាអ្នកជឿគួរតែស្វែងរកសុវត្ថិភាព តែត្រូវមានការគ្រប់គ្រងខ្លួនតាមរយៈទុក្ខលំបាក។ លោក Rutherford បាននិយាយដូចតទៅនេះថា "ឈើឆ្កាងយើងគួរតែរងទ្រាំនោះវាធ្ងន់ តែវាមានរសជាតិផ្អែម។ សម្រាប់បក្សីស្លាបវាធ្ងន់ តែដោយសារស្លាបនោះទើបវាអាចហើរបាន។ ទូកមានក្តោងធ្ងន់ តែទូកអាចទៅមុខបានដោយសារក្តោង។ សម្រាប់អ្នកជឿឈើឆ្កាងគឺជាបន្ទុក តែវាធ្វើឱ្យគេបានទៅដល់ស្ថានសួគ៌ថែមទៀត។" លោក Moody បាននិយាយថា "កាលណាយប់មកដល់ នោះងងឹតកាន់តែខ្លាំង តែពន្លឺរបស់តារាកាន់តែភ្លឺខ្លាំងដែរ កម្រិតនៃកម្តៅរបស់ឡវ៉ាកាន់តែខ្ពស់យ៉ាងណា នោះមាសនឹងត្រូវបានផ្លាស់ប្រែទៅជាសុទ្ធកាន់តែខ្លាំងយ៉ាងនោះដែរ។" លោកគ្រូគង្វាល William បាននិយាយថា អត្ថន័យនៃ "ទុក្ខវេទនាគឺជាព្រះពរដែលក្លែងខ្លួន"។

ការអធិប្បាយទី 26 ជីវិតដែលរង់ចាំព្រះដែលទ្រង់មិនជំនុំជំរះភ្លាមៗទេ (វិវរណៈ 6:9-11)

អេសាយ 55:8 និយាយថា “ពីព្រោះព្រះយេហូវ៉ាទ្រង់មានព្រះបន្ទូលថា គំនិតអញ មិនមែនដូចជាគំនិតរបស់ឯងរាល់គ្នាទេ ឯផ្លូវរបស់ឯងរាល់គ្នាក៏មិនមែនជាផ្លូវរបស់ អញដែរ។” យើងប្រញាប់ប្រញាល់ តែព្រះនិងសេចក្តីពិតរបស់ទ្រង់មិនប្រញាប់នោះ ទេ។ សេចក្តីអត់ធ្មត់របស់ព្រះអស់ពេលជាយូរមិនត្រូវទៅជាអសារអត់ការឡើង។ វាជា គោលការណ៍នៃសកម្មភាពរបស់ព្រះដែលវាផ្ទុយទៅនឹងភាពល្ងង់ខ្លៅរបស់យើង ដែល ជាសកម្មភាពដែលប្រញាប់ប្រញាល់ វាមានពេញដោយប្រាជ្ញា មិនអាចប្រៀបស្មើរបា ន លម្អិត និងជាសកម្មភាពដែលល្អ។

1. អ្នកជឿមិនគួរប្រញាប់ទេដោយត្រូវតាមព្រះដែលទ្រង់ស្ងៀមស្ងាត់វិញ

បើមនុស្សមិនឈប់នៅនឹងសេចក្តីពិតដែលត្រូវស៊ូទ្រាំជាយូរទេ ហើយនិយាយបញ្ចេញ សម្លេងច្រើន ហើយធ្វើការដោយប្រញាប់ នោះគេងាយនឹងរអិលចុះណាស់។

ដូចគ្នានឹង yoksock budal ទោះបីជាវាជារឿងល្អប្រសិនបើគាត់ព្យាបាលវាដោយ ប្រញាប់ ផ្ទុយទៅវិញវាអាចនឹងនាំមកនូវលទ្ធផលខុស។ កសិករម្នាក់ដែលរស់នៅក្នុង ប្រទេស Cho ថ្ងៃមួយបានរើសដើមឈើហើយដាំនៅក្នុងចម្ការព្រោះវាលូតលាស់យឺ ត។ នៅថ្ងៃបន្ទាប់ពួកគេក៏ត្រូវបានស្លូតអស់។ សុភាសិត 19:2 មានបន្ទូលថា “មួយ ទៀត ការដែលចិត្តឥតមានចំណេះ នោះមិនគួរគប្បីទេ ហើយអ្នកណាដែលរហ័ស

ឈានទៅ នោះជ្រួសផ្លូវហើយ”។ សុភាសិត 28:22 មានបន្ទូលថា “អ្នកណាដែលមានភ្នែកអាក្រក់ នោះកំពុងតែរួសរាន់ដេញតាមទ្រព្យសម្បត្តិ ឥតដឹងឡើយថា សេចក្តីខ្វះខាតនឹងតាមខ្លួនទាន់”។ សុភាសិត 28:20 មានបន្ទូលថា “មនុស្សស្មោះត្រង់នឹងបានពរជាបរិបូរ តែអ្នកណាដែលប្រញាប់ប្រញាល់ឱ្យបានជាអ្នកមាន នោះនឹងមិនរួចចាកពីទោសឡើយ”។ សុភាសិត 20:21។ ដំណាំនៃចលនានៃសេចក្តីពិតនឹងមិនកើតឡើងយ៉ាងឆាប់រហ័សទេ។ សេចក្តីពិតមានអំណាចគ្រប់គ្រងលើសកលលោកនៅក្រោមជើងរបស់ខ្លួន ទោះបីជាវាត្រូវបានបៀតបៀនក៏ដោយ មុនពេលពេលវេលាដ៏ត្រឹមត្រូវនឹងមកដល់ ភាពជាស្តេចនឹងត្រូវបានបង្ហាញ។ សេចក្តីពិតធ្វើការដោយស្ងប់ស្ងាត់ ប៉ុន្តែទីបំផុតវាត្រូវបានលាតត្រដាងជាស្តេចចុងក្រោយ (អ្នកឈ្នះ)។

2. អ្នកជឿគួរតែដើរតាមទង្វើដែលសុភាពដែលព្រះទ្រង់អត់ធ្មត់

ព្រះទ្រង់ធ្វើការដោយសម្ងាត់។ ទ្រង់ហាក់ដូចជាមិនគង់នៅទេ តែទ្រង់គឺជាបុគ្គលដ៏ពិតបំផុត។ ទ្រង់ហាក់ដូចជាការដែលមិនអាចទៅរួច ប៉ុន្តែទ្រង់ជាព្រះដ៏មានឫទ្ធានុភាព។ ថ្វីត្បិតតែទ្រង់ពូកែមែន ប៉ុន្តែទ្រង់ធ្វើឱ្យសកលោកដំណើរការ ទ្រង់មិនបញ្ចេញសម្លេងអ្វីឡើយ។ ទ្រង់ហាក់ដូចជាមិននិយាយជានិច្ច តែទ្រង់មិនផ្អាកកិច្ចការនៃព្រះបន្ទូលនោះទេ។ ទំនុកដំកើង 19:1-4 មានបន្ទូលថា “ ផ្ទៃមេឃសំដែងពីសិរីល្អនៃព្រះ
ហើយលំហអាកាសក៏បង្ហាញការ ដែលព្រះហស្តទ្រង់ធ្វើ។ ថ្ងៃ1ពោលប្រាប់តដល់ថ្ងៃ1ទៀត ហើយយប់1ក៏សំដែងចំណេះដល់យប់1ទៀតដែរឯពាក្យសំដី ឬភាសា នោះគ្មានឮឡើយ គ្មានអ្នកណាដែលឮសំឡេងនៃរបស់ទាំងនោះទេ ប៉ុន្តែដំណឹងដែលរបស់ទាំងនោះផ្សាយមក ក៏បានចេញទៅគ្រប់លើផែនដីហើយសេចក្តីនោះបានឮទៅដល់ទីបំផុតលោកីយ៍នៅលើមេឃ ទ្រង់បានដំឡើងត្រសាលសំរាប់ព្រះអាទិត្យ។” នេះជាគោលការណ៍នៃសកម្មភាពរបស់ព្រះវរបិតា។ ម៉ាថាយ 12:18 មានបន្ទូលថា “មើល អ្នកបំរើដែលអញបានរើសតាំង ជាអ្នកស្ងួនភ្ងា ដែលជាទីពេញចិត្តអញ អញនឹងដាក់វិញ្ញាណ

អញ ឱ្យសណ្ដៅតនៅលើទ្រង់ ហើយទ្រង់នឹងថ្លែងប្រាប់ពីសេចក្ដីយុត្តិធម៌ ដល់សាសន៍ដទៃ”។ ចំណុចទាំងនេះចង្អុលទៅកាន់គោលការណ៍នៃសកម្មភាពរបស់ព្រះអម្ចាស់យេស៊ូវគ្រីស្ទរបស់យើង។

ជំពូកទី 7

យើងបានឃើញទុក្ខវេទនាដ៏អាក្រក់ដោយផ្ទាល់ មុនពេលនៃការយាងមកជាលើកទីពីររបស់ព្រះអម្ចាស់ នៅផ្នែកចុងក្រោយនៃជំពូកខាងលើ (ដូចដែលត្រាទីប្រាំមួយត្រូវបានបើក)។ គ្រាដែលសេចក្ដីទុក្ខវេទនាមកដល់ តែជារបស់ខាងអនាគតវិញ។ វាប្រាកដណាស់នៅពេលយើងឃើញចលនារបស់ទេវតាដែលពន្យារពេលទុក្ខព្រួយនៅផ្នែកដំបូងនៃជំពូក (1-3) ទីមួយគឺ មានបញ្ហាដែលត្រូវដោះស្រាយ។ ជាការពិតណាស់នេះគឺជាចលនានៃសេចក្ដីសង្គ្រោះ ដើម្បីផ្តល់ជីវិតអស់កល្បជានិច្ច ហើយត្រូវបានដោះស្រាយដោយមិនជួបគ្រោះថ្នាក់នៃទុក្ខវេទនានេះទេ។ ដូច្នេះ ជំពូកនេះគឺជាការបើកសម្តែងនៃការសម្រាលទុក្ខដែលធានាដល់សេចក្ដីសន្យានៅក្នុងគ្រាទុក្ខវេទនាជាខ្លាំងនាពេលអនាគត (វាត្រូវបានសរសេរពីជំពូកទី 8) អ្នកជឿត្រូវបានធ្វើទុក្ខខាងវិញ្ញាណ។ នៅទីនេះ សកម្មភាពនៃការផ្សាភ្ជាប់គឺការប្រទានមកនូវព្រះវិញ្ញាណដល់អ្នកដែលត្រូវបានរើសតាំងរបស់ទ្រង់តាមរយៈការប្រកាសដំណឹងល្អ និងបើកសម្តែងនៃនិមិត្តសញ្ញាដែលធានាការសង្គ្រោះខាងវិញ្ញាណចេញពីទុក្ខវេទនាជាខ្លាំងដែលបានចាប់ផ្តើមតាំងពី 8:7។

ការបកស្រាយ

1. ***ក្រោយនោះមក ខ្ញុំឃើញទេវតា4រូប ឈរនៅជ្រុងផែនដីទាំងបួន ទាំងទប់ខ្យល់នៅផែនដីទាំងបួនទិស។*** លេខ 4 ជារបស់ផែនដី។ “ទេវតាទាំងបួនឈរនៅជ្រុងទាំងបួននៃផែនដី ទប់ខ្យល់ទាំងបួននៃផែនដី” មានន័យថាការពន្យារពេលនៃទុក្ខវេទនាជាខ្លាំង (ខ្យល់ទាំងបួនគឺជានិមិត្តរូបនៃទុក្ខវេទនាជាខ្លាំងដែលនឹងមកនៅលើផែនដី) មុននឹងត្រានៃពួកបរិសុទ្ធ ដែលជានិមិត្តសញ្ញានៃការធានានៃសេចក្តីសង្គ្រោះនឹងត្រូវបានបញ្ចប់។ សូមយោងទៅលើការបកស្រាយនៃ ខទី 3 ថាតើត្រានៃពួកបរិសុទ្ធគឺជាអ្វី ។ "ខ្យល់" ចង្អុលបង្ហាញពីគ្រោះកាចនៃសង្គ្រាម។(យេរេមា 49:36-39, 51:1) អ្នកប្រាជ្ញម្នាក់និយាយថា គំនិតដែលថា ខ្យល់បក់មកលើផែនដី នោះចេញមកពីអាផូគ្រីផា (Sibyll 1.8.203 អេណុក 13:22) ប៉ុន្តែវាជាការបកស្រាយខុសដែលមិនអាចអានឃ្លានៅក្នុងវិវរណៈបាន។ អត្ថន័យនៃឃ្លានៅក្នុងវិវរណៈនេះជានិមិត្តសញ្ញា ហើយមិនមែនគ្រោះដោយខ្យល់តាមន័យត្រង់នោះទេ ពាក្យដែលថាមានគ្រោះដោយខ្យល់ជានិមិត្តសញ្ញាដែលចេញមកពីសញ្ញាចាស់។ (យេរេមា 49:36, 37, 51:1) វាមិនសមហេតុផលទេដែលយ៉ូហានបោះចោលក្រាំង តែបែជាទៅដកស្រង់ចេញពីអាផូគ្រីផាវិញនោះ។ “ផែនដី” ជាកន្លែងនៃសេចក្តីមិនជឿនៅក្នុងវិវរណៈ “សមុទ្រ” ជាប្រទេសនានានៅក្នុងពិភពលោក។ (ដានីយ៉ែល 7:2), “ដើមឈើ” ជានិមិត្តសញ្ញានៃមនុស្សដែលនៅលើពិភពលោកនេះ។ (អេសាយ 10:18, 19, អេសេគាល 31:3, 4, 5, 15, 17)។

2. ***ត្រាបស់ព្រះដ៏មានព្រះជន្មរស់*** ការពិតដែលព្រះទ្រង់ជាព្រះដ៏មានព្រះជន្មរស់គឺជាការពិតដែលរំលឹកពីការពិតថា នៅក្នុងសេចក្តីវេទនា នោះទ្រង់តែងតែថែ

រក្សាពួកបរិសុទ្ធ។ យោងតាម ម៉ាថាយ 16:16, 26:63, រ៉ូម 9:29, ហេព្រើរ 3:12, វិវរណៈ 4:9, 10, 15:7។ រួចមកនៅទីនេះ តើសកម្មភាពនៃការលាក់ត្រារបស់ព្រះមានន័យដូចម្តេច? អេសេគាល 9:4-6 ព្រះក៏ដាក់ត្រានៅលើថ្ងាស រួចមកក៏ធ្វើឱ្យពួកគេបានគេចផុតពីគ្រោះវេទនា ការដែលដាក់ត្រានៅទីនោះជាសញ្ញាសម្គាល់នៃពាក្យថា ថាវ ( ) នៅក្នុងអក្សរហេព្រើរ។ យោងតាមគំនិតនៃគម្ពីរសញ្ញាចាស់នេះ សកម្មភាពនៃការបោះត្រាជានិមិត្តសញ្ញានៃការផ្សាយដំណឹងល្អដើម្បីនឹងបញ្ជាក់ពីសេចក្តីសង្គ្រោះខាងវិញ្ញាណចេញពីទុក្ខវេទនានៃលោកិយនេះ។ (2ធីម៉ូថេ 2:19)

ទ្រឹស្តីមួយថា សកម្មភាពនៃការបោះត្រានៃជំពូកនេះដូចគ្នានឹងការប្រមូលផ្តុំពួកបរិសុទ្ធដែរ (ម៉ាថាយ 24:31) នៅគ្រានៃការយាងមកលើកទីពីររបស់ព្រះគ្រីស្ទ ពីព្រោះព្រឹត្តិការណ៍នេះនឹងកើតឡើងបន្ទាប់ពីការច្របូកច្របល់នៃព្រះអាទិត្យ ព្រះច័ន្ទ និងផ្កាយ (6:12-17) ហើយក៏ជាព្រឹត្តិការណ៍នៃការប្រមូលផ្តុំនៅក្នុងដំណឹងល្អរបស់ម៉ាថាយដូចគ្នា។ (ម៉ាថាយ 24:29) ហើយយោងតាមការបោះត្រានេះ វាជានិមិត្តសញ្ញានៃសកម្មភាពទៅកាន់ព្រះយេស៊ូវ ដែលនឹងត្រូវបានប្រែចិត្ត និងបានត្រឡប់មកកាន់ព្រះគ្រីស្ទនៅក្នុងគ្រានៃការយាងមកលើកទីពីររបស់ព្រះគ្រីស្ទ (រ៉ូម 11:12-13)។ សៀវភៅអាផូគ្រីផា ដូចគ្នាដែរ (ទំនុកដំកើងរបស់សាឡូម៉ូន 15:6) និយាយថា ពួកសុចរិតនឹងត្រូវបានដកចេញនូវសេចក្តីទុក្ខវេទនារបស់ពួកគេនៅគ្រាចុងក្រោយនៃផែនដីនេះ ដែលជាសញ្ញាសម្គាល់របស់ព្រះដែលនឹងត្រូវបានបោះត្រាដល់ពួកសុចរិតសម្រាប់សេចក្តីសង្គ្រោះពី គ្រោះទុរភិក្ស ដាវ និងសេចក្តីស្លាប់នឹងត្រូវចេញពីពួកគេទៅ” (ὁ’τι το’ σημειον τυό θεου επι δικαίους είς σωτηρίαν λιμός καί ρομφαια και θάνατος μακράν αποδικαίων) តែយើងមិនអាចគិតថា ឃ្លានេះពីសៀវភៅរបស់អាផូគ្រីផា មិនគួរត្រូវបានគិតថាជាមូលដ្ឋានគ្រឹះនៃវិវរណៈទេ។ មូលដ្ឋានគ្រឹះនៃការបើកសម្តែងរបស់យើងគឺតែងតែជាគម្ពីរសញ្ញាចាស់ដែលជាកណ្តាគម្ពីរវិញ។ សកម្មភាពនៃ

ការបោះត្រាគឺដើម្បីនឹងសម្គាល់នូវពួកបរិសុទ្ធដែលត្រូវបានបើកសម្តែងរួចមកនៅក្នុង និក្ខមនំ 12:13, វិវរណៈ 9:4-6 ជាដើម។

ចាប់ពីពេលថ្ងៃរះឡើង ការនេះចង្អុលទៅកាន់ទិសដៅទៅកាន់សេចក្តីមេត្តា (អេសេគាល 43:2 ម៉ាឡាគី 4:2)។

3. យោងតាមការបកស្រាយនៃខ2ខាងលើ។
4. គ្រប់ទាំងពូជអំបូរនៃជនជាតិអ៊ីស្រាអែល៖ នេះមិនចង្អុលទៅកាន់សាសន៍យូដាដោយន័យត្រង់ទេ តែទៅកាន់ពួកអ៊ីស្រាអែលខាងវិញ្ញាណវិញ ដែលវាហាក់ដូចជានិមិត្តសញ្ញារបស់ពួកគ្រីស្ទាន។ ហេតុផលដែលខ្ញុំមើលឃើញដូច្នេះគឺ (1) វិវរណៈមានទម្លាប់នៃការបង្ហាញការបង្រៀនខាងវិញ្ញាណនៃចលនានៃសេចក្តីសង្គ្រោះដោយពាក្យនៃប្រវត្តិសាស្ត្រនៃសេចក្តីសង្គ្រោះនៅក្នុងប្រវត្តិសាស្ត្រសេចក្តីសង្គ្រោះរបស់អ៊ីស្រាអែល។ ឧទាហរណ៍ដូចជា វិវរណៈ 7:4 និង 21:12 ជាដើម។ដែលមានបែបបទដូចគ្នា។ (2) ដោយសារលំដាប់លំដោយនៃពូជអំបូរនិងខ្លឹមសារដែលសរសេរនៅខាងក្រោមជាការខាងវិញ្ញាណ ពូជអំបូរយូដាមកជាដំបូងដែលព្រះគ្រីស្ទបានប្រសូត ពូជអំបូរដាន់ ដែលចាត់ទុកថាជាពូជអំបូរដែលទាស់ប្រឆាំងនឹងព្រះគ្រីស្ទហើយដែលត្រូវបានរំលងនោះ។ លោក អ៊ីរ៉ានៀសបានឃើញថាដាន់ជាអ្នកដែលប្រឆាំងនឹងព្រះគ្រីស្ទពិតមែន មុនពេលអ្នកប្រាជ្ញផ្សេងទៀតឃើញដូច្នោះ។ គោលការណ៍ដែលពួកគេឃើញពូជអំបូរនៅ លោកុប្បត្តិ 49:16-27, ចោទិយកថា 33:22, យេរេមា 8:16។ ដូចជាលោក អាន់ដ្រាសបកស្រាយវិវរណៈ 16:12 គាត់បាននិយាយថា ពួកដែលប្រឆាំងនឹងព្រះគ្រីស្ទនឹងចេញមកពីប្រទេស ផើសៀ ពីព្រោះគាត់គិតថា ផើសៀជាពូជពង្សរបស់ពូជអំបូរដាន់។

លេខ *144000 លោកឡូមេយើ បាននិយាយថា ចំណុចលេខនេះចង្អុលទៅកាន់លេខរបស់វិវរណៈ ដែលជាលេខពេញលេញខាងសាសនា ឬជាលេខពេញ។* (Die Zahl ist apokalyptisch d: h. ihr Sinn ist nur der religionsen Vollendung und vollstandigkeit – offenbarung, ទំព័រ 69)។ លោក ប្រ្គេចដានុស បកស្រាយលេខនេះដូចតទៅ។ វាជាពូជអំបូរ 12000 កាលដែលលេខ 12 គុណនឹង 10 បីដង។ រួចមកលេខ 12 ត្រូវបានគុណបីដង (ជាលេខរបស់ព្រះ) និង 4 (ជាលេខរបស់លោកិយនេះ) ហើយលេខ 10 ជាលេខនៃភាពពេញលេញ។ កាលដែលលេខ 12000 ត្រូវបានតាំងមកដូច្នេះ គឺត្រូវបានគុណនឹង 12 ដែលមានអត្ថន័យបែបសាសនា ដោយបានលេខ 144,000។

អត្ថន័យគឺមានដូចតទៅនេះ (1) ការរួបរួមរវាងលេខរបស់ព្រះ និងលេខរបស់មនុស្សគឺលេខរបស់អេម៉ាញ៉ូអែល (លេខនៃរាស្ត្រដែលត្រូវបានរើសតាំង) លេខ 12 ជាគ្រឹះ (2) វាត្រូវបានគុណដោយលេខពេញលេញគឺលេខ 10 ដែលជាគម្រូនៃលេខពេញលេញដោយសេចក្តីមេត្តាដ៏ធំរបស់ព្រះដែលថាទ្រង់អាចសង្គ្រោះមនុស្សជាច្រើន។

5-8 បទគម្ពីរនេះបង្ហាញពីឈ្មោះរបស់ពូជអំបូរនីមួយៗរបស់អ៊ីស្រាអែល។ លំដាប់លំដោយនៃឈ្មោះ និងខ្លឹមសាររបស់វាមានអត្ថន័យខាងវិញ្ញាណ។ ដូច្នេះ ពួកគេមិននិយាយពីអំបូរយូដាក្នុងន័យត្រង់ទេ។ លោក ឡូមេយើ បាននិយាយថា ការត្រាស់ហៅរបស់ “អ៊ីស្រាអែល” ជាឈ្មោះដ៏គួរឱ្យគោរព ដែលវិវរណៈមិនត្រឹមតែប៉ុណ្ណោះ (2:9, 9:9) តែគ្រីស្ទានពីមុនក៏បានគោរពដល់ដែរ។ (រ៉ូម 2:29, កាឡាទី 3:29, 6:16, ភីលីព 3:5 1ពេត្រុស 1:1 យ៉ាកុប 1:1) ហើយឈ្មោះនៃពូជអំបូរទាំង 12 ក៏បានដើរតាមបន្ទាត់ដូចគ្នា(vielmehr ist der Name Israel nicht nur in der Ape 2:9, 3:9 កាឡាទី 3:29 , 6:16 ភីលីព 3:3 1ពេត្រុស 1:1 យ៉ាកុប 1:1 (Auch die

nennung der Stammsnamen – dicsc Nam en sind langst eine ideal Grosse geworden – Offenbarung, ទំព័រ 69)។ ដូច្នេះ គ្រីស្ទានពីដើមចូលចិត្ត ដែលពួកគេមាននិមិត្តសញ្ញាជាក់ដោយឈ្មោះនេះ។ នៅទីនេះ វិធីសាស្ត្រក្នុងការសរសេរចុះពីពូជអំបូរគឺមានអត្ថន័យខាងវិញ្ញាណដូចតទៅ។

យូដា...រូបេន “ដ្បិតយូដាជាកុលសម្ព័ន្ធដែលព្រះគ្រីស្ទបានប្រសូតមក វាត្រូវបានគេដាក់នៅក្នុងកន្លែងសំខាន់ ប៉ុន្តែទោះបីជា “រូបេន” ជាកូនច្បងក៏ដោយ ក៏គេត្រូវគេទម្លាក់ចុះ។ នៅទីនេះ "អេប្រាអីម" ត្រូវបានដកចេញ ព្រោះជាពូជអំបូរដែលហាក់បីដូចជាក្រអឺតក្រទម។ (ចៅហ្វាយជំពូកទី 8 ជំពូកទី 12) “ដាន់” ក៏ត្រូវបានលុបចោលនៅទីនេះដែរ ពីព្រោះពូជអំបូរនេះហាក់ដូចជាត្រូវបានជូនដំណឹងថាជាពូជអំបូរដែលទាស់ប្រឆាំងនឹងព្រះគ្រីស្ទ។ សូមមើលការបកស្រាយនៃខគម្ពីរខាងលើ3។

9 អត្ថបទនេះបាននិយាយថា ហ្វូងមនុស្សដែលមិនអាចរាប់បាន ពួកគេមិនខុសគ្នាទេ ប៉ុន្តែវាចង្អុលទៅមនុស្សដូចគ្នាដែលតំណាងដោយលេខ 144000។ មានទ្រឹស្តីដែលចង្អុលទៅមនុស្សស្លាប់នៃអ្នកមិនជឿ ប៉ុន្តែវាមិនមែនតាមធម្មជាតិទេ។ ពីគ្រប់ប្រជាជាតិ គ្រប់កុលសម្ព័ន្ធ គ្រប់ជាតិសាសន៍ និងគ្រប់ភាសា ពាក្យនេះនិយាយពីដើមកំណើតនៃហ្វូងមនុស្សរាប់មិនអស់។ អំពីអត្ថន័យនៃអត្ថបទគម្ពីរនេះ សូមមើលការបកស្រាយនៃ 5:9 ។ **មានទាំងមឺនទាំងសែន ហើយទាំងពាន់រាប់ជាពាន់** លោក ប្រេ្គច ដានុស បាននិយាយថា វាមានន័យថា ក្រុមរបស់ពួកបរិសុទ្ធរាប់ទាំងមនុស្សនិងទេវតាដែលមិនអាចរាប់បាន ហើយត្រូវការការពិចារណា។ ដ្បិតចំនួនរបស់ពួកអ្នកដែលបានសង្គ្រោះមានច្រើនណាស់ អស់អ្នកដែលមិនអាចរាប់បាន នោះព្រះទ្រង់ដឹងពីពួកគេទាំងអស់ដោយផ្ទាល់ផង។ (យ៉ូហាន 6:37-39) “ដែលពាក់ដោយអាវសរែង” ចង្អុល

ទៅកាន់ការពិតដែលថា ពួកបរិសុទ្ធត្រូវបានអត់ទោសដោយសារព្រះលោហិតដ៏វិសេសរបស់ព្រះគ្រីស្ទ ហើយត្រូវបានចែងចាំងដោយសិរីល្អនៃការរាប់ជាសុចរិត។

ហើយកាន់ធាងចាកនៅដៃ យោងតាម យ៉ូហាន 12:13។ ធាងចាកមិនមែនជានិមិត្តសញ្ញានៃជ័យជំនះទេ តែជានិមិត្តសញ្ញានៃសេចក្តីអំណរវិញ។ កាលដែលប្រើវាគឺជាអត្ថន័យនៃជ័យជំនះដែលចេញមកពីសៀវភៅអាផូគ្រីជា (I Macc 13:51)។

10 "សេចក្តីសង្គ្រោះស្រែចនៅព្រះនៃយើងរាល់គ្នា ដែលគង់លើបល្ល័ង្ក ហើយស្រែចនឹងកូនចៀមផង" ពាក្យនេះជាការសារភាពនៃជំនឿនៃពួកបរិសុទ្ធនៅស្ថានសួគ៌។ ការពិតគោលជំនឿនៃផែនដីដែលភ្លឺដូចគ្នានឹងគោលជំនឿនៃផែនដីដែលងងឹតនេះដែរ។ ប្រៀបដូចជាយើងមានចង្កៀងនៅក្នុងយប់ងងឹតដែរ។ សេចក្តីសង្គ្រោះមិនមែនមានតម្លៃថោកដែលអាចទិញដោយបុណ្យរបស់មនុស្សនើទេ តែពិតជាមានតម្លៃណាស់ដែលត្រូវបានទិញដោយលោហិតនៃបុត្រាតែមួយរបស់ព្រះ។ ព្រះទ្រង់បានផ្តល់សេចក្តីសង្គ្រោះដល់អ្នកជឿដោយទទេរ។

12 និយាយថា "អាម៉ែន សូមថ្វាយព្រះពរ សិរីល្អ ប្រាជ្ញា ពាក្យអរព្រះគុណ កិត្តិនាម ព្រះចេស្តា និងឥទ្ធិឫទ្ធិ ដល់ព្រះនៃយើងរាល់គ្នានៅអស់កល្បជានិច្ចរៀងរាបតទៅ អាម៉ែន!" យោងតាមការបកស្រាយនៃ 5:12 នៃអត្ថន័យនៃឃ្លានេះ។ លេខ 7 នៅក្នុងឃ្លានេះមានន័យថា ជាភាពពេញលេញ។ កាលដែលយើងផ្តោតទៅលើពាក្យប្រាំពីរដែលសរសើរនោះ (1) (2) នៅក្នុងអត្ថបទភាសាក្រិក ពាក្យប្រាំពីរមានដាក់ ("the" ជាការសង្កត់ន័យ) , នៅទីនេះ "the" មានអត្ថន័យបន្ថែមលើពាក្យនោះ។ ឧទាហរណ៍ ពាក្យសរសើរមាន "ការសរសើរ" ហើយបន្ទាប់មកមានន័យថា "បើវាជាទំនុកតម្កើង មិនថាជាការសរសើរអ្វីក៏ដោយ"។(2) ហើយការសរសើរទាំងប្រាំពីរនេះបានចាប់ផ្តើម

ជាមួយនឹងអាម៉ែន ហើយឆ្លើយតបទៅនឹងការសរសើរនៃការសង្គ្រោះនៃពួកបរិសុទ្ធ ដែលពាក់សម្លៀកបំពាក់ពណ៌ស។ ការសរសើរគួរឆ្លើយតបជាចិត្តមាសនិងត្បូង។ ការសរសើរដោយគ្មានការឆ្លើយតបខាងវិញ្ញាណ គ្មានជីវិតទេ។ លោក ឡូមេយើ បាននិយាយថា ការសរសើរគឺសម្រាប់ការបង្កើតសកលលោក និងការទ្រទ្រង់ពួកគេ។ ប៉ុន្តែយើងមិនអាចជួយបានក្រៅពីនិយាយថា ការសរសើរនេះក៏និយាយអំពីការប្រោសលោះដែរ។

13 នោះពួកចាស់ទុំម្នាក់សួរមកខ្ញុំ ហេតុផលដែល “សួរមក” គឺជាការមានសំណួរនៅក្នុងភាពស្ងៀមស្ងាត់របស់សាវកយ៉ូហាន។ វាបញ្ជាក់ការពិតថា នៅក្នុងពិភពរបស់វិញ្ញាណ លំនាំនៃគំនិតដែលគ្មានការបង្ហាញពាក្យសម្តីនោះត្រូវបានបង្ហាញមក។

“តើអស់អ្នកដែលពាក់អាវសនេះជាពួកណា ហើយមកពីណា?” ពួកចាស់ទុំដែលព្យាយាមឆ្លើយនិយាយដូចជាវិធីសាស្ត្រនៃការឆ្លើយសំណួរ បង្រៀនវិធីសាស្ត្រដូច្នោះដែលមានឥទ្ធិពលដល់អ្នកដែលរៀនសូត្រ។

14 “អ្នកទាំងនោះជាពួកដែលបានចេញពីគ្រាវេទនាយ៉ាងធំមក” នៅទីនេះពាក្យថា “គ្រាវេទនាយ៉ាងធំ” គឺ ថេស ស្លីផ្សូស ថេស មេហ្គាលេស (τῆς θλίψεως τῆς μεγάλης) នៅក្នុងភាសាក្រិក ដែលលោក អាល់ហ្វដ បកប្រែថា “ការរងទុក្ខវេទនា ជាការដ៏ធំ” ដោយចង្អុលទៅកាន់ការប្រើប្រាស់ដែលសង្កត់ន័យនៃពាក្យថា “យ៉ាងធំ” នៅក្នុងឃ្លានោះ ដូច្នេះគាត់និយាយថា ការរងទុក្ខវេទនានេះជាគ្រាវេទនាជាពិសេសដែលបានកើតឡើងនៅគ្រាចុងក្រោយនៃលោកិយនេះ។ តែលោក ហ្គ្រេចដានុស បានហៅដោយ ឈ្មោះទូទៅនៃការរងវេទនានៃលោកិយ។ គាត់និយាយថា “បទគម្ពីរបាននិយាយថា ជីវិតរបស់យើងនៅក្នុងលោកិយ

និយាយមួយបែបទៀត ជាជីវិតរបស់អ្នកជឿដែលនោះជា របស់ក្រុមជំនុំ ដែលមានការទួញសោក ការបៀតបៀន ភាពក្រីក្រ និងគ្រោះថ្នាក់។" យោងតាម លោកុប្បត្តិ 5:29, 47:9, ទំនុកដំកើង 90:10 យ៉ូហាន 16:23។

អំពើបាប សេចក្តីពុករលួយ លក្ខណៈចាស់ (រ៉ូម 7:18, 24, ម៉ាថាយ 26:41) និងលោកិយ (យ៉ូហាន 15:19 1យ៉ូហាន 3:14, 5:19, កិច្ចការ 14:22) អាណាចក្ររបស់អារក្ស (អេភេសូរ 2:2, 6:10, 11 1ពេត្រុស 5:8 1យ៉ូហាន 1:31) ដែលធ្វើឱ្យក្រុមជំនុំធ្លាក់ចុះ និងត្រូវខូច។" (Openbaring ទំព័រ 175) ពួកបរិសុទ្ធនៃស្ថានសួគ៌ត្រូវបានសង្គ្រោះចេញពីទុក្ខវេទនានៃផែនដី ហើយជាពិសេសចេញពីគ្រាវេទនាយ៉ាងធំនៃគ្រាចុងក្រោយរបស់លោកិយនេះ (សរសេរនៅ 8:7) ហើយត្រូវបានឆ្លងផុតផង។

គេបានបោកអាវ រហើយធ្វើឱ្យឡើងសក្អុងឈាមរបស់កូនចៀម។ ដូចដែលយើងឃើញវា ការពិតដែលពួកបរិសុទ្ធត្រូវបានសង្គ្រោះនោះចេញមកពីការអត់ទោសបាបដ៏បរិសុទ្ធពិត តែមិនមែនដោយសារបុណ្យរបស់គេផ្ទាល់ឡើយ។ ការសម្អាតបាបដោយឈាមរបស់កូនចៀម នោះគឺមានន័យថាជាការអត់ទោសបានតែមួយគត់។ មនុស្សទទួលបានការសង្គ្រោះតាមរយៈទ្វារនៃការអត់ទោស ពីព្រោះមនុស្សតែងតែជាអ្នកមានបាប។ យើងត្រូវពិចារណាពីគោលលិទ្ធិនៃភាពធ្លាក់ចុះទាំងស្រុងរបស់មនុស្ស។

(1) ដូចលោក កាល់វីន និយាយថា "ការធ្លាក់ចុះទាំងស្រុងរបស់មនុស្ស" មិនមែនគ្រាន់តែជាការបង្រៀនរបស់សាវកប៉ុលតែម្នាក់នោះទេ (រ៉ូម 3:20) តែវាក៏ចេញមកពីការបង្រៀនរបស់ព្រះយេស៊ូវផងដែរ លោក ជី បី ស្វីន បានឃើញថា ទស្សនៈនៃ

ជីវិតរបស់ព្រះយេស៊ូវខុសពីទស្សនៈរបស់ប៉ុល និងកាល់វីន។ វាមានន័យថាវាបានយល់ច្រឡំនូវចិត្តដែលសំខាន់ហើយ។ លោកកាល់វីនទទួលបានទស្សនៈនៃជីវិតដែលគាត់បានមកពីប៉ុល ក៏ដូចជាព្រះយេស៊ូវ និងបានរបស់គាត់ផង។ ព្រះយេស៊ូវមានបន្ទូលនៅក្នុងពេលចាប់ផ្តើមនៅក្នុងព័ន្ធកិច្ចជាសាធារណៈថា មនុស្សគួរតែប្រែចិត្តដោយសារពួកគេបានធ្វើបាប។ ព្រះបន្ទូលនេះដូចគ្នានឹងព្រះបន្ទូលនៅយ៉ូហាន 3:3, “ប្រាកដមែន ខ្ញុំប្រាប់អ្នកជាប្រាកដថា បើមិនបានកើតជាថ្មី នោះគ្មានអ្នកណាអាចនឹងឃើញនគរព្រះបានទេ។” នៅទីនេះ ពាក្យថា “មនុស្ស” គឺថា ធីស (τις) នៅក្នុងភាសាក្រិក ដែលជាសព្វនាមច្បាស់ដែលសំដៅទៅលើអត្ថន័យនៃពាក្យ “អ្នកណាក៏ដោយ”។ នៅចំពោះមុខទ្វារនៃស្ថានសួគ៌ គ្រប់គ្នាសុទ្ធតែជាមនុស្សមានបាប។ ដូច្នេះការពិតដែលព្រះយេស៊ូវយាងមកនៅយកភាពជាមនុស្សមានបាប។ លោក ហឺម៉ាន់ បាវីង បាននិយាយថា “កាលដែលយើងឃើញថា នៅក្នុងព័ន្ធកិច្ចជាសាធារណៈដំបូងបំផុង ព្រះយេស៊ូវទ្រង់ប្រកាសទៅកាន់មនុស្សនៃលោកិយថា ឱ្យពួកគេប្រែចិត្តហើយជឿដល់ដំណឹងល្អ ព្រះយេស៊ូវរក្សាទុកនៅក្នុងចិត្តនូវភាពធ្លាក់ចុះមានបាបរបស់មនុស្ស”(Gereformeerde Dogma tiek, III ទំព័រ 63)។ ព្រះយេស៊ូវសង្កត់ធ្ងន់ថាមានតែព្រះប៉ុណ្ណោះដែលល្អ (ម៉ាថាយ 19:17)។

(2) លោក ស្វីរិន បាននិយាយថា វាច្បាស់ណាស់ថា ព្រះយេស៊ូវទទួលស្គាល់ពីលទ្ធភាពខ្លះចេញពីពួកមនុស្សនៅក្នុងទស្សនៈរបស់គាត់ ដូចដែលយើងឃើញនៅក្នុងម៉ាថាយ 9:37 “ចម្រូតធំណាស់”។ នេះជាការយល់ច្រឡំពីគោលបំណងដ៏សំខាន់របស់ព្រះយេស៊ូវ។ ព្រះយេស៊ូវមិនបានមានបន្ទូលដូច្នេះ ពីព្រោះដោយសារទ្រង់បានរកឃើញពីលទ្ធភាពខ្លះចេញពីមនុស្សនោះទេ។ ពីព្រោះទ្រង់បានឃើញនូវភាពអសមត្ថភាពដែលនោះគឺ ស្ថានភាពដែលអាក្រក់របស់ពួកគេដែលត្រូវបានខូចដោយសារអំពើបាបរបស់ពួកគេ នោះដែលទ្រង់បានប្រទាននូវសេចក្តីមេត្តា ហើយទ្រង់ចង់សង្គ្រោះពួកគេ។ លោក ស្វីរិន បានគិតពីព្រះបន្ទូលនៅក្នុង ម៉ាថាយ 18:3 ម្តងទៀត ដែលនិយាយថា “ខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា បើអ្នករាល់គ្នាមិនផ្លាស់គំនិត ហើយត្រ

ឡប់ដូចជាកូនតូចនេះ នោះនិងចូលទៅក្នុងនគរស្ថានសួគ៌ពុំបានឡើយ”។ ពីព្រោះទ្រង់បានមើលថា “កូនក្មេង” ទុកជាឧទាហរណ៍ពីមនុស្សដែលនៅស្ថានសួគ៌ ភាពធ្លាក់ចុះក្នុងអំពើបាបរបស់មនុស្សទាំងស្រុងគ្មានសល់អ្វីនៅក្នុងគំនិតរបស់ព្រះយេស៊ូវទេ។ ពិតទេ ដែលព្រះយេស៊ូវចាត់ទុកកូនក្មេងជាគំរូនៃអ្នកដែលនៅស្ថានសួគ៌? ពិតណាស់ គឺទ្រង់បានធ្វើដូច្នោះមែន។ ប៉ុន្តែអត្ថន័យនៃគំរូដែលទ្រង់ចង្អុលបង្ហាញនោះជាអ្វី? ពីព្រោះពួកគេមិនព្រមកែប្រែពីអំពើបាបដែលនៅក្នុងពួកគេមែនទេ? គឺមិនមែនទេ។ យើងអាចនិយាយថា កូនក្មេងមានអត្តចរិតដែលខូច ហើយពួកគេក៏មានការដែលត្រឹមត្រូវច្រើនដែរ ហើយពួកគេមានការត្រូវជាច្រើននៅក្នុងចំណេះដឹងរបស់ពួកគេ។ ពាក្យនេះជាការប្រៀបធៀបនូវនគររបស់ព្រះ ដែលវាបង្រៀនតែពីការពិត។

(3) ការពិតដែលថា ក្មេងៗមានចិត្តដែលបរិបូរណ៍ដោយទុកចិត្តលើឪពុកម្តាយរបស់ពួកគេ។ ចិត្តដែលទុកចិត្តមិនមែនជាលទ្ធផលនៃព្រះគុណពិសេសទេ តែជាលទ្ធផលនៃគុណទូទៅ។ វាមិនមែនជាលក្ខខណ្ឌដើម្បីទទួលបានសេចក្តីសង្គ្រោះនោះទេ។ លក្ខខណ្ឌដើម្បីទទួលបានសេចក្តីសង្គ្រោះមានទាក់ទងនឹងព្រះគុណពិសេស។ សេចក្តីសង្គ្រោះរបស់ក្មេងៗនោះក៏ចេញមកពីសេចក្តីមេត្តាតែមួយរបស់ព្រះយេស៊ូវដែរ។

16 គេនឹងមិនឃ្លាន ឬស្រេកទៀត ក៏មិនត្រូវថ្ងៃចាំងមកលើគេ ឬចំហាយណាទៀតឡើយ។ នេះជាព្រះបន្ទូលដែលរក្សានៅក្នុងគំនិតពីជីវិតនៅលើវាលរហោស្ថានដ៏គ្រោះថ្នាក់របស់អ៊ីស្រាអែល (យេរេមា 2:6) វារហោស្ថានត្រូវការអាហារ ហើយមានកម្តៅយ៉ាងខ្លាំងរបស់ព្រះអាទិត្យចែងចាំងមក។ តែអ៊ីស្រាអែលបានបរិភោគនំម៉ាណា និងសត្វលលក ហើយបានផឹកទឹកដែលចេញមកពីថ្មដារផង ហើយនៅពេលថ្ងៃពួកគេបានគេចផុតពីកម្តៅព្រះអាទិត្យដោយសារសេសរពពក។ ដូច្នេះវាលរហោស្ថានដូច្នោះជានិមិត្តសញ្ញានៃលោកិយនេះ។ ប៉ុន្តែមិនមានការរងទុក្ខដូចលោកិយដែលនៅក្នុង

លោកិយរបស់ស្ថានសួគ៌ឡើយ ពីព្រោះព្រះផ្ទាល់នឹងការពារលំនៅរបស់ពួកបរិសុទ្ធដូច ជាការគ្របបាំងនៃជំរុំផងដែរ។

17 កូនចៀមដែលនៅកណ្តាលបល្ល័ង្ក ពាក្យថា “នៅកណ្តាលបល្ល័ង្ក” ចង្អុលទៅកាន់ ចំណុចកណ្តាលរវាងបល្ល័ង្ករបស់ព្រះ និងពួកចាស់ទុំទាំង 24 នាក់។ បល្ល័ង្ករបស់ព្រះ គ្រីស្ទនេះជានិមិត្តសញ្ញានៃឋានៈរបស់ព្រះគ្រីស្ទដែលជាព្រះអង្គដែលផ្សះផ្សា។ គឺដូច្នេះ ព្រះគ្រីស្ទទ្រង់ធ្វើជាគង្វាលរបស់ពួកបរិសុទ្ធនៅស្ថានសួគ៌ នោះពួកគេនឹងមិនខ្វះអ្វី សោះឡើយ។ “ព្រះអម្ចាស់ទ្រង់ជាអ្នកគង្វាលនៃខ្ញុំ ខ្ញុំនឹងមិនខ្វះអ្វីសោះឡើយ”(ទំនុក ដំកើង 23:1)។

ព្រះទ្រង់នឹងជូតអស់ទាំងទឹកភ្នែកពីភ្នែកគេចេញ។ យោងតាម អេសាយ 25:8-10។ ខ 9-10 ខាងលើរៀបរាប់ពីជីវិតដែលមានពរដែលនៅស្ថានសួគ៌ (ជាកន្លែងដែលត្រូវចូល ទៅបន្ទាប់ពីស្លាប់) ដែលព្រលឹងដែលបានជឿនឹងចូលទៅមាន។ យោងតាមការ អធិប្បាយនៅជំពូកនេះ (ពីសេចក្តីសង្គ្រោះ)។

ចំណុចសំខាន់

1. រលកនៃសេចក្តីរងទុក្ខវេទនាមិនសម្រាកនៅលើផែនដីនោះទេ។ តែដំណឹងល្អ របស់ព្រះនោះខ្លាំងជាងរលកនោះ ហើយសង្គ្រោះព្រលឹងរបស់រាស្ត្រដែលបានរើសតាំង ចេញមកផង។ ដូច្នេះ យើងគួរប្រឆាំងនឹងរលកនៃការរងទុក្ខដោយគ្មានសម្រាក ហើយ យើងត្រូវតែប្រកាសដំណឹងល្អដោយឥតឈប់ឈរ។ ដំណឹងល្អនេះជាវិធីសាស្ត្រតែ មួយដែលធ្វើឱ្យរាស្ត្រដែលបានរើសតាំងបានដើរកាត់សេចក្តីរងទុក្ខវេទនា។ ម្នាក់ដែល គ្មានដំណឹងល្អហើយត្រូវជួបនូវទុក្ខវេទនានៅក្នុងលោកិយ នោះគេប្រៀបដូចជាម្នាក់ ដែលបានធ្លាក់ចុះក្នុងទឹកជ្រៅដោយគ្មានទូកដែរ (1-14)។

2. ខ 15-17 ធ្វើឱ្យយើងនឹកឃើញពីប្រវត្តិសាស្ត្រនៃទុក្ខលំបាករបស់អ៊ីស្រាអែលនៅក្នុងទីរហោស្ថាន។ លោកិយនេះប្រៀបដូចជាវាលរហោស្ថាន។ វាមិនបានផ្តល់ទឹករស់ដល់អ្នកដែលស្រេកខាងវិញ្ញាណនោះទេ។ ប៉ុន្តែមនុស្សដែលព្យាយាមវាយប្រហារហាក់ដូចជាដោះស្រាយភាពស្រេកខាងវិញ្ញាណជាមួយនឹងឧបករណ៍របស់លោកិយ។ វាប្រៀបដូចជាអ្នកដំណើរដែលស្រេកទឹកដែលបានមើលឃើញការបំភាន់ភ្នែកនៃជម្រកពីចម្ងាយ ហើយបានទៅជិតទីនោះ តែគេត្រូវទទួលការវាយប្រហារដោយកម្តៅយ៉ាងខ្លាំងវិញ។

ការអធិប្បាយ

ការអធិប្បាយទី 27 អ្វីដែលយើងអាចស្តាប់និងអាចឃើញ (វិវរណៈ 7:1-12)

1. ចលនានៃដំណឹងល្អត្រូវបានបង្កើតដោយការស្តាប់តែមួយគត់

នៅលើផែនដីយើងអាចដឹងបានដោយការស្តាប់សារដែលថា ម្នាក់ត្រូវបានសង្គ្រោះ ត្រូវបានជ្រើសរើស និងបានទទួលព្រះវិញ្ញាណបរិសុទ្ធ និងបានសេចក្តីសង្គ្រោះ។ ខ 4 និយាយថា “ខ្ញុំក៏ឮចំនួនពួកអ្នកដែលបានបោះត្រានោះ” ត្រូវហើយ។ នៅលើផែនដីយើងអាចស្តាប់ទៅវាបាន។ រ៉ូម 10:17 និយាយថា “ដូច្នេះ សេចក្តីជំនឿកើតឡើងដោយឮ ហើយដែលឮនោះ គឺដោយសារព្រះបន្ទូលនៃព្រះ”។ យើងនៅលើផែនដីនេះគួរដឹងថាការដែលស្តាប់នោះសំខាន់ណាស់។ តើអ្នកដែលនៅលើផែនដីនេះអាចមើលឃើញនគរព្រះបានយ៉ាងណាទៅ? ហេព្រើរ 2:1 និយាយថា “ដោយហេតុនោះ បានជាគួរឱ្យយើងរាល់គ្នាប្រុងប្រយ័ត្នលើសទៅទៀត ចំពោះសេចក្តីដែលយើងរាល់គ្នាបានឮ ក្រែងយើងរសាត់ចេញពីសេចក្តីទាំងនោះ”។

យើងអាចជឿវាក៏ដោយព្រោះតែការស្តាប់ទៅដំណឹងល្អតែមួយប៉ុណ្ណោះ។ ពីព្រោះ (1) ចលនានៃដំណឹងល្អជាចលនាដែល ព្រះបោះត្រានិងបង្ហាញនូវលក្ខណៈដ៏អស្ចារ្យរបស់ទ្រង់។ នៅពេលទ្រង់ចាត់ព្រះគ្រីស្ទឱ្យមក ទ្រង់បានបោះត្រានៅក្នុងទ្រង់ (យ៉ូហាន 6:27) ពេលទ្រង់ចាត់ព្រះវិញ្ញាណបរិសុទ្ធឱ្យមកយើងគឺដោយភ្ជាប់នឹងការបោះត្រាផង (2កូរិនថូស 1:22 អេភេសូរ 1:3 4:30) ក្នុងចំណោមមនុស្សម្នាក់ដែលត្រូវជឿព្រះគ្រីស្ទ ជាសកម្មភាពដែលបោះត្រានូវលក្ខណៈស្មោះត្រង់របស់ព្រះ។ (យ៉ូហាន 3:33)។ អ្នកដែលមិនព្រមជឿជាអ្នកដែលនិយាយថាព្រះទ្រង់ជាអ្នកកុហក (1 យ៉ូហាន 5:10) (2) ចលនានៃដំណឹងល្អជាចលនាដែលបោះត្រាមនុស្សចំនួន 144000 នាក់ ដែលវាជាចលនាបោះត្រាដល់រាស្ត្រដែលត្រូវបានជ្រើសរើស។ ម្នាក់ដែលបានចូលរួមនៅទីនេះ គេអាចទទួលវាយ៉ាងខ្លាំងក្លាដោយជឿពីសេចក្តីសង្គ្រោះរបស់ទ្រង់។ ដូច្នេះយើងមិនគួររំពឹងលើសពីអ្វីដែលព្រះបន្ទូលនិយាយឡើយ តែត្រូវមានឥរិយាបថដោយចេះស្តាប់ដោយត្រឹមត្រូវ។ បើអ្នកណាស្តាប់ហើយជឿនោះ គេនឹងបានសេចក្តីជំនឿពិត បើគ្មានការគិតថាវាជាការសំខាន់ទេ គេមិនអាចមកកាន់សេចក្តីជំនឿពិតឡើយ។ អ្វីដែលយើងគួរដឹងឱ្យច្បាស់គឺ យើងបានត្រឹមស្តាប់នៅលើលោកិយប៉ុណ្ណោះ។ នៅក្នុងជីវិតដែលជឿរបស់យើង យើងគួរបោះចោលសេចក្តីល្បួងដែលចង់ឃើញអ្វីមួយចេញ។ យើងគួរពិចារណាត្រឹមការស្តាប់នៅក្នុងទំនាក់ទំនងជាមួយព្រះ។

2. ពេលយើងចូលទៅក្នុងក្រុមជំនុំស្ថានសួគ៌នោះយើងអាចមើលឃើញ

សេចក្តីជំនឿមានសង្ឃឹមដែលរំពឹងថាពេលដែលអាចមើលឃើញនឹងមកដល់។ ខ 9 នៅក្នុងអត្ថបទនិយាយថា “បន្ទាប់ពីនេះខ្ញុំបានមើលទៅ”។ យើងអាចឃើញបន្ទាប់ពីឃើញបានចូលទៅក្នុងស្ថានសួគ៌។ (1) យើងឃើញ "ហ្វូងមនុស្សយ៉ាងធំដែលគ្មាន

នរណាម្នាក់អាចរាប់បាន”។ វាមានន័យថាគាត់បានឃើញហ្វូងមនុស្សធំ។ នៅក្នុងស្ថានសួគ៌មិនមានហ្វូងមនុស្សច្រើនហ្វូងទេ តែមានតែមួយក្រុមប៉ុណ្ណោះ។ ហ្វូងមនុស្សនោះតែមួយក្រុមប៉ុណ្ណោះដែលរួបរួមគ្នាដោយសេចក្តីស្រឡាញ់។ (2) “ហ្វូងមនុស្សដ៏ធំដែលគ្មាននរណាអាចរាប់បាន” បង្ហាញពីចំនួនជាច្រើននៃអ្នកដែលបានសង្គ្រោះ។ ពាក្យថា “គ្មាននរណាអាចរាប់បាន” ជាពាក្យដ៏មានអំណាចអស្ចារ្យ ដែលវាសង្កត់លើចំនួនមនុស្សច្រើន។ ពាក្យថា ចំនួនអ្នកដែលបានសង្គ្រោះវាតូចដែលមិនសមនឹងបទគម្ពីរទេ។ ដ្បិតសេចក្តីស្រឡាញ់របស់ព្រះនោះអស្ចារ្យ ព្រោះទ្រង់បានប្រទានព្រះរាជបុត្រាតែមួយរបស់ទ្រង់មក អំណាចចេស្តាទ្រង់នោះអស្ចារ្យ បំណងសង្គ្រោះមនុស្សជាតិរបស់ទ្រង់នោះខ្លាំងក្លា។ 1ធីម៉ូថេ 2:4 និយាយថា “ដែលទ្រង់សព្វព្រះហឫទ័យឱ្យមនុស្សទាំងអស់បានសង្គ្រោះ ហើយឱ្យបានស្គាល់សេចក្តីពិត”។ រួចមក កាលដែលអ្នកដែលបានសង្គ្រោះច្រើន ដូច្នេះតើយើងអាចរស់នៅក្នុងក្នុងជីវិតដែលខូចបង់ទេ? (1) ពីព្រោះគេគិតថាប្រសិនបើអ្នកដែលបានសង្គ្រោះមានតិច នោះមនុស្សដូចជា "ខ្ញុំ" មិនមានសង្ឃឹមឡើយ នោះគេនឹងខកចិត្ត នោះគេនឹងទៅជាខូចអាក្រក់ តែ “ខ្ញុំ” ដែលដឹងថាមនុស្សជាច្រើនបានសង្គ្រោះនឹងព្យាយាមចូលរួមទីនោះដោយសង្ឃឹមដ្បិតខ្ញុំមានភាគរយដែលអាចទៅរួច។ (2) អ្នកជឿមិនប្រគល់ខ្លួនទៅកាន់ភាពល្ងង់ខ្លៅមិនដឹងពីសេចក្តីសង្គ្រោះរបស់គេឡើយ គេដឹងពីសេចក្តីសង្គ្រោះរបស់គេ ហើយស្តាប់តាមដោយការអរគុណ។ អ្នកដែលដឹងថាហ្វូងមនុស្សយ៉ាងធំដែលបានសង្គ្រោះនៅស្ថានសួគ៌នឹងប្រាថ្នាចង់បានសេចក្តីស្រឡាញ់ដ៏ធំអស្ចារ្យដែលគ្មានដែនកំណត់របស់ព្រះ និងរស់នៅក្នុងជីវិតដោយសប្បុរស ដោយខ្លាំងក្លាយ។ គេនឹងមិនដួលចុះដូចជាកូនកំព្រា ដែលមិនបានទទួលដែលត្រូវដួលយ៉ាងងាយឡើយ។ (3) អ្នកជឿដែលដឹងថាមនុស្សជាច្រើននឹងបានសង្គ្រោះ ជឿវាយ៉ាងខ្លាំង ពីព្រោះវិធីនៃសេចក្តីសង្គ្រោះនៅក្នុង

ដំណឹងល្អនឹងនាំមកនូវប្រសិទ្ធិភាព។ ស្រាសនឹងត្រូវបានបង្កើតទុកជាជ័យជំនះរបស់ព្រះគ្រីស្ទ ជាជ័យជំនះដែលត្រូវបានបង្កើតដោយឈាមរបស់ទ្រង់។ ការសរសើររបស់ពួកគេ "សេចក្តីសង្គ្រោះជារបស់កូនចៀម!" (ខ 10) បង្ហាញពីសេចក្តីពិត។ អ្នកជឿជាគ្រីស្ទាន! ជាជ័យជំនះរបស់ព្រះគ្រីស្ទ!

ការអធិប្បាយទី 28 អំពីសេចក្តីសង្គ្រោះ (វិវរណៈ 7:1-17)

1. ត្រារបស់ព្រះបញ្ជាក់ពីគុណសម្បត្តិដែលអាចបានសង្គ្រោះ

ខ 1-8 អ្នកបម្រើរបស់ព្រះជាម្ចាស់ គឺថាកិច្ចការដែលត្រូវដាក់ត្រានៅនឹងថ្ងាសរបស់ពួកបរិសុទ្ធ មានន័យថាត្រានៅក្នុងចិត្តរបស់អ្នកជឿដោយព្រះវិញ្ញាណបរិសុទ្ធ។ ដូចការនេះដែរ ដែលវាត្រូវបានកត់ទុកនៅក្នុង 2កូរិនថូស 1:22 អេភេសូរ 1:13, 4:30, យ៉ូហាន 6:27។ ពាក្យថា "ហើយទ្រង់ដែលបានដាក់ត្រារបស់ទ្រង់លើយើង ហើយបានផ្តល់នូវវិញ្ញាណរបស់ទ្រង់នៅក្នុងចិត្តយើងទុកជាការធានាផង" អេភេសូរ 1:13 មានបន្ទូលថា "ឯអ្នករាល់គ្នា ក៏បានឮព្រះបន្ទូលនៃសេចក្តីពិត គឺជាដំណឹងល្អពីសេចក្តីសង្គ្រោះរបស់អ្នករាល់គ្នាដោយសារទ្រង់ដែរ ហើយកាលអ្នករាល់គ្នាបានជឿហើយ នោះទ្រង់ក៏ដៅចំណាំដោយព្រះវិញ្ញាណបរិសុទ្ធ ដែលបានសន្យា"។ អេភេសូរ 4:30 មានបន្ទូលថា "កុំធ្វើឱ្យព្រះវិញ្ញាណបរិសុទ្ធនៃព្រះបានព្រួយព្រះហឫទ័យ ដែលទ្រង់ដៅចំណាំអ្នករាល់គ្នា ទុកសំរាប់ដល់ថ្ងៃប្រោសលោះនោះឡើយ"។

នៅទីនេះ ដោយសារព្រះវិញ្ញាណបរិសុទ្ធជាត្រានៅក្នុងចិត្តរបស់អ្នកជឿ អត្ថន័យមួយនោះគឺជាការបញ្ជាក់ពីកម្មសិទ្ធិ ដែលថាជារបស់ផងព្រះ អត្ថន័យមួយទៀតគឺជាការសន្យាដែលធានាអះអាងនូវសេចក្តីសង្គ្រោះរបស់យើង។ ការពិតដែលអ្នកជឿជាកម្មសិទ្ធរបស់ព្រះបង្ហាញពីការបញ្ជាក់អះអាងពីសេចក្តីសង្គ្រោះរបស់យើង។ ព្រះទ្រង់មិនអាចបាត់ទ្រព្យសម្បត្តិរបស់ទ្រង់ទេ។ មិនត្រឹមតែប៉ុណ្ណោះ ទ្រង់បានប្រទានព្រះវិញ្ញាណបរិសុទ្ធទុកជាការធានាអះអាងដើម្បីនឹងបញ្ជាក់ប្រាប់ការពិតពីសេចក្តីសង្គ្រោះដល់យើង។ ពីព្រោះការទទួលព្រះវិញ្ញាណបរិសុទ្ធមានន័យថាទទួលបានភាពអស់កល្បជានិច្ច។ ដែលវាមានន័យជាស្រេចថាជាជីវិតអស់កល្បជានិច្ច។

ការពិតដែលយើងគិតពីការអះអាងពីសេចក្តីសង្គ្រោះ ជាមួយនឹងការពិតនៃការបោះត្រា ជាផ្នែកដែលឈ្មោះនៃកុលសម្ព័ន្ធទាំង12របស់យូដាត្រូវបានកត់ត្រា។ នៅទីនេះឈ្មោះចំនួន 212 កុសម្ព័ន្ធមិនមានន័យត្រង់ៗថាកុលសម្ព័ន្ធទាំង 12 នៃពួកយូដាទេ តែជានិមិត្តសញ្ញានៃរាស្ត្រដែលនៅក្នុងការតាំងសញ្ញាដែលនៅបន្តនៅក្នុងសញ្ញាថ្មី ហើយដែលបានសម្រេចខាងព្រលឹងវិញ្ញាណវិញ។ រាស្ត្រនៅសញ្ញាថ្មីត្រូវបានបង្កើតឡើងនៅលើគ្រឹះនៃកុលសម្ព័ន្ធទាំង12នៅក្នុងសញ្ញាចាស់ ជានិមិត្តរូបដែលរាស្ត្រដោយដំណឹងល្អត្រូវបានបង្កើតឡើងដូចជាប្រព័ន្ធខាងសញ្ញាចាស់។ ដូច្នេះ លោកបណ្ឌិត Dr. Van Der Meulen បាននិយាយដូចតទៅនេះដោយដកស្រង់ការបកស្រាយរបស់លោក Hadorn។ គឺថា "ថា(ការបោះត្រាកុលសម្ព័ន្ធទាំង12 នៅក្នុងជំពូក 7) ដូចជាផ្នាំងថ្មទាំង12 ដែលលោកអេលីយ៉ាបានយកមកសង់អាសនាដែរ។ (1 ពង្សាវតារក្សត្រ 18:31) គំនិតនៃការសាងសង់អ៊ីស្រាអែលឡើងវិញត្រូវបានបង្កើតដោយការស្តារឡើងវិញនូវកុលសម្ព័ន្ធទាំង12 ដែលជាសង្ឃឹមនៃក្រុមជំនុំពីបុរាណ ហើយវាជាការពិតដែលព្រះយេស៊ូវផ្ទាល់បានអះអាងយ៉ាងច្បាស់។ រួចមក វិវរណៈ 7:14 បង្ហាញថាអ្នកជឿចេញមកពីពួកសាសន៍ដទៃនឹងត្រូវបានបោះត្រាដោយព្រះយ៉ាងច្បាស់។ តែវាមិនមានន័យថាគ្រីស្ទានជាសាសន៍ផ្សេងអាចជំនួសឱ្យរាស្ត្ររបស់ព្រះនៅក្នុងសញ្ញាចាស់ឡើយ អ្នកជឿជាសាសន៍ដទៃបានចូលរួមជាមួយនឹងរាស្ត្រនៃការទាំងសញ្ញានៅក្នុងសញ្ញាចាស់និងត្រូវបានសម្រេចកុលសម្ព័ន្ធទាំង 12 ផង (រាស្ត្រអ៊ីស្រាអែលដែលជារាស្ត្រត្រូវបានជ្រើសរើស) (De Openbaring In Het Laatste Bijbelboek, p 215)។

កាលដែលយើងជឿដល់ព្រះគ្រីស្ទ វាមានន័យថាបានចូលរួមនៅក្នុងខ្សែស្រឡាយនៃការតាំងសញ្ញារបស់ព្រះ។ វាជាការដែលគួរឱ្យអបអរនៅក្នុងសកលោកនេះ។ ការពិត

ដែលព្រះហៅ “ខ្ញុំ” សម្រាប់ការសម្រេចការតាំងសញ្ញាដ៏អស់កល្បដូចនេះគឺ ជាការដែលគួរឱ្យអរគុណនៅក្នុងគំនិតរបស់យើង។ នៅលើផែនដីប្រសិនបើមនុស្សអបអរសាទរដោយទទួលបានចូលសញ្ជាតិនៃប្រទេសអស្ចារ្យ តើគេនឹងមានអំណរយ៉ាងណាទៅ ប្រសិនបើគេនឹងទទួលបានចូលសញ្ជាតិនៃនគររបស់ព្រះនោះ!

2. ការសម្រេចនៃសេចក្តីសង្គ្រោះដោយការរើសតាំង (9-17)

(1) ហ្វូងមនុស្សរាប់មិនអស់

ពីសេចក្តីសង្គ្រោះដោយការរើសតាំង មនុស្សយល់ច្រឡំជាមួយគំនិតដែលថា ប្រសិនបើមនុស្សព្យាយាមទទួលសេចក្តីសង្គ្រោះសម្រាប់ខ្លួន ភាពច្រើននឹងត្រូវបានសង្គ្រោះ តែប្រសិនបើត្រូវបានសង្គ្រោះដោយការរើសតាំងរបស់ព្រះ មនុស្សភាគតិចនឹងបានសង្គ្រោះ។ តែវាជាគំនិតដែលមិនត្រឹមត្រូវទេ។ ប្រសិនបើបញ្ហានៃការសង្គ្រោះពឹងផ្អែកលើអំណាចរបស់មនុស្ស ដែលពួកគេព្យាយាមសង្គ្រោះខ្លួនពួកគេ ជាចុងក្រោយពួកគេនឹងត្រូវវិនាសទាំងអស់។ ពីព្រោះមានតែព្រះប៉ុណ្ណោះដែលអះអាងនិងសម្រេចដោយការរើសតាំងនិងព្រះគុណនូវចំនួនមនុស្សដែលត្រូវបានសង្គ្រោះជាច្រើនរាប់មិនអស់។

ដោយសារព្រះបានកំណត់នឹងសង្គ្រោះមនុស្សជាតិដោយការរើសតាំង ការតាំងសញ្ញារបស់អ័ប្រាហាំនិយាយថា “ដ្បិតព្រះទ្រង់ស្រឡាញ់លោកិយនេះដល់ម្ល៉េះបានជាទ្រង់ប្រទានព្រះរាជ្យបុត្រាទ្រង់តែមួយ ដើម្បីឱ្យអ្នកណាដែលជឿដល់ទ្រង់នឹងមិនត្រូវវិនាសឡើយ តែមានជីវិតអស់កល្បជានិច្ចវិញ។” “(លោកុប្បត្តិ 3:16) ហើយ “នោះអញនឹងឱ្យពរដល់ឯង ហើយនឹងចំរើនពូជឯងឱ្យមានគ្នាសន្ធឹកដូចផ្កាយនៅលើមេឃ ហើយ

ដូចខ្សាច់នៅមាត់សមុទ្រ ពូជឯងនឹងបានគ្រប់គ្រងលើទ្វារក្រុងនៃពួកខ្មាំងសត្រូវ” (លោកុប្បត្តិ 22:17) ទំនុកដំកើង 40:5, 49:6, សាការី 9:10។

(2) ព្រះទ្រង់ដកពួកគេចេញពីការលំបាកវេទនាយ៉ាងខ្លាំង (ខ 14)

ដ្បិតពួកបរិសុទ្ធត្រូវបានបោះត្រាដោយព្រះវិញ្ញាណបរិសុទ្ធ (ខ 8) ពួកគេមិនបាត់បង់សេចក្តីជំនឿរបស់ពួកគេនៅក្នុងទុក្ខវេទនាទេ ហើយជាចុងក្រោយគេនឹងបានលូតលាស់នៅក្នុងទុក្ខវេទនានោះ។ លោក Greijdanus បានចង្អុលពីសេចក្តីពិតនៅទីនេះថា “កំពុងមក” ពាក្យនៅទីនេះជាបច្ចុប្បន្នកាល ដូច្នេះវាមានន័យថាកំពុងចេញមកពីទុក្ខវេទនាដូច្នេះជាការដែលកំពុងបន្ត។ (Nu wordt het participium van het praecense gebruik, en niet dat van verleden tijd, om anntegeven, dat dit komen uit de groote verdrukking nog steeds in gang is …. Openbaring , p 174)។ រួចមកតើ “ហ្វូងមនុស្សយ៉ាងធំ” មានន័យដូចម្តេច? លោក Van Der Meulen បាននិយាយអំពីចំណុច "តើសេចក្តីទុក្ខវេទនានេះចង្អុលទៅកាន់គ្រាចុងក្រោយដូចជាការបកស្រាយរបស់លោក Charles ទេ?”

ឬ ដូចជាការបកស្រាយរបស់លោក Greijdanus តើវាចង្អុលទៅកាន់ការរងទុក្ខទូទៅដែលគ្រប់គ្រីស្ទានទាំងអស់នៅគ្រប់ពេលចូលរួមមែនទេ? នេះជាចំណុចខ្ពស់បំផុតនៃទុក្ខលំបាកទាំងអស់ ដែលជាទុក្ខលំបាកមុនពេលនៃការយាងមកលើកទីពីរ ហើយក្នុងពេលតែមួយជាទុក្ខលំបាកបំផុតនៃសេចក្តីទុក្ខវេទនាទាំងអស់ផង (ទុក្ខលំបាកបានកើតឡើងគ្រប់ពេល)។ តែនៅក្នុងគោលការណ៍វាចង្អុលទៅកាន់ចំណុចរួមនៃទុក្ខលំបាកទូទៅដែលកើតឡើងគ្រប់ពេល។ (De Openbaring In Het Laatste bijbelbock, p 217).

(3) ពួកគេចំពោះបល្ល័ង្ក (ខ 15)

ដូចជាខគម្ពីរនេះបាននិយាយទីនេះ ពួកគេឈរនៅចំពោះបល្ល័ង្កព្រះ វាមានន័យថាពួកគេបានចូលទៅក្នុងស្ថានសួគ៌។ ដូច្នេះ ពួកគេជាព្រលឹងរបស់ពួកបរិសុទ្ធ ហើយមិនទាន់រស់ឡើងវិញនៅឡើយ។ លោក E. Smilde បង្ហាញយ៉ាងច្បាស់ត្រង់ចំណុចនេះ។ គាត់បាននិយាយថា "ទីនេះជាជីវិតរបស់ពួកបរិសុទ្ធ ត្រង់ចំណុចនេះមិនចង្អុលទៅកាន់កម្រិតនៃជីវិតអស់កល្បដែលយើងរីករាយនៅផែនដីនេះរួចហើយ។ ការនេះបង្ហាញពីជីវិតដែលមនុស្សបានប្រោសលោះបានចូលរួមនៅចំពោះបល្ល័ង្ក។ ហើយវាមិនចង្អុលទៅកាន់ជីវិតនៅគ្រាចុងក្រោយទេ (ជីវិតដែលរស់ឡើងវិញ) នៅក្នុងន័យម៉ឺងម៉ាត់។" (Leven In De Johanneische Geschriften, p 194)។ សេចក្តីពិតដែលពួកគេឈរនៅចំពោះបល្ល័ង្កព្រះ មានន័យថា ឈរនៅមុខព្រះដែលមានគ្រប់អំណាចចេស្តាដោយផ្ទាល់។ វាមិនមែនជាការងាយស្រួលទេ។ វាជាព្រះពរដែលមានតែអ្នកដែលបានប្រោសលោះដោយព្រះលោហិតរបស់កូនចៀមប៉ុណ្ណោះដែលអាចឈរបាន ។ ដូច្នេះ ខ 14, 15 បាននិយាយថា "ខ្ញុំក៏ឆ្លើយទៅថា លោកម្ចាស់អើយ លោកជ្រាបហើយ រួចអ្នកនោះនិយាយមកខ្ញុំថា អ្នកទាំងនោះជាពួកអ្នក ដែលបានចេញពីគ្រាវេទនាយ៉ាងធំមក គេបានបោកអាវ ហើយធ្វើឱ្យឡើងសក្អុងឈាមរបស់កូនចៀម។ ហេតុនោះបានជាគេស្ថិតនៅចំពោះបល្ល័ង្កព្រះ ព្រមទាំងបំរើទ្រង់ នៅក្នុងព្រះវិហារទាំងយប់ទាំងថ្ងៃ ហើយព្រះអង្គ ដែលគង់នៅលើបល្ល័ង្កនោះ ទ្រង់នឹងធ្វើជាត្រសាលបាំងឱ្យគេ" វាជាពាក្យប្រៀបប្រដូច។ គឺថា វាមានន័យថា ឈ្នួលនៃអំពើបាបត្រូវបានដកចេញដោយលោហិតដ៏ថ្លៃថ្លារបស់ព្រះយេស៊ូវ។ លោហិតរបស់ព្រះយេស៊ូវជាកំណប់ដ៏ពិសេសដែលអាចបង់ឈ្នួលអំពើបាបយើងបាន។ អ្នកដែលជឿដល់ឈាមនេះនឹងត្រូវបានលុបអំពើបាបចេញបើទោះជាខ្លាំងយ៉ាងណាក៏ដោយ។ ដូច្នេះ សេចក្តីជំនឿរបស់យើងគួរតែជាកម្មវត្ថុនៃលោហិតរបស់ព្រះយេស៊ូវ។ វាមិនមានន័យថា សេចក្តីជំនឿរបស់យើងពេលមួយ ជាដំណាក់កាលដែលជឿលើលោហិតរបស់ព្រះយេស៊ូវ

តែក្រោយមកមិនត្រូវការជឿលើព្រះលោហិតទៀតនោះឡើយ។ ដូចដែលយើងបានឃើញនៅក្នុងបទគម្ពីរថា “ដោយសារលោហិតរបស់ព្រះយេស៊ូវ ដែលព្រលឹងបានចូលទៅចំពោះបល្ល័ង្ករបស់ព្រះដ៏មានចេស្តា”។ ពួកគេនៅចំពោះបល្ល័ង្ករបស់ព្រះ ហើយបម្រើទ្រង់ទាំងថ្ងៃទាំងយប់នៅក្នុងព្រះវិហារ។ នៅទីនេះ "ព្រះវិហារ” គឺ (ναὸς) ជាភាសាក្រិក ដែលថា ទីបរិសុទ្ធបំផុត ដែលមានន័យថាជាការប្រកបយ៉ាងជិតស្និតជាមួយនឹងព្រះ។ មានតែជំនឿប៉ុណ្ណោះដែលអាចជឿលើលោហិតរបស់ព្រះយេស៊ូវ មិនមែនជំនឿដែលខ្ពស់បំផុតណាឡើយ។ ជួនកាលមនុស្សគិតពីជំនឿដែលខ្ពស់ជាងជំនឿនេះ តែវាជាសកម្មភាពដែលចម្លែកនៃអាថ៌កំបាំង។ នៅទីនេះការបម្រើទ្រង់ ពាក្យនោះគឺ latreuousin (λατρεύουσιν) វាមានន័យថា បម្រើដោយចិត្តស្មោះស្ម័គ្រ។ ពីព្រោះមនុស្សត្រូវបានបង្កើតមកឱ្យបម្រើព្រះ ជាកិច្ចការដែលព្រលឹងត្រូវបានសង្គ្រោះគួរធ្វើគឺការមួយនេះហើយ។ វាជាតួនាទីនិងជាសុភមង្គលរបស់គេផង។

(4) ការការពារនិងភាពគ្រប់គ្រាន់ដែលព្រះផ្តល់មក

អ្វីដែលបាននិយាយនៅទីនេះជាការប្រៀបប្រដូចទៅនឹងស្ថានភាពរបស់លោកិយ។ សរុបមក វាមានន័យថាពួកគេរីករាយនឹងព្រះជីវិតអស់កល្បជានិច្ចនិងគេស្គប់ស្គល់នឹងវាផង។ អ្វីដែលពួកគេបានធ្វើមិនបានចេញពីអំណាចរបស់ពួកគេទេ តែដោយកិច្ចការផ្សះផ្សារបស់ព្រះគ្រីស្ទវិញ។ ដូច្នេះ អត្ថបទរបស់យើងនិយាយថា "ដ្បិតកូនចៀមដែលនៅកណ្តាលបល្ល័ង្កនឹងជាគង្វាលរបស់ពួកគេ”។ ការពិតដែលកូនចៀមដែលជាព្រះយេស៊ូវគង់នៅកណ្តាលបល្ល័ង្ក ចង្អុលទៅមើលនៅកណ្តាលបល្ល័ង្ក។ ដែលវាមានន័យថា ទ្រង់ធ្វើកិច្ចការជាការផ្សះផ្សារវាងព្រះនិងពួកបរិសុទ្ធ។ មនុស្សមិនបានសង្គ្រោះដោយអំណាចខ្លួនគេទេ ហើយក៏មិនបានទទួលជីវិតអស់កល្បដែរ។ មានតែព្រះយេស៊ូវគ្រីស្ទជាព្រះរាជបុត្រារបស់ព្រះប៉ុណ្ណោះដែលប្រោសលោះយើង ជាអង្គដែលផ្សះផ្សាដែលយើងបានសង្គ្រោះ។

ការអធិប្បាយទី 29 ចំនួនមនុស្សដែលត្រូវបានបោះត្រា (វិវរណៈ 7:4)

1. សិទ្ធិអំណាចនៃត្រា

ត្រាត្រូវបានប្រើដើម្បីបង្ហាញពីសិទ្ធិអំណាចរបស់អ្នកដែលមានវា។ ត្រារបស់អ្នកមានគឺជាតំណាងនៃសិទ្ធិនៃទ្រព្យសម្បត្តិដែលខ្លួនមាន ហើយត្រារបស់ចៅក្រមជំនួសឱ្យអំណាចរបស់គាត់ដូចថាត្រានៃព្រះគឺបង្ហាញពីអំណាចនៃការកាន់កាប់របស់ព្រះ ដែលជានិមិត្តរូបនៃអំណាចអធិបតេយ្យភាពដ៏អស្ចារ្យ។ ព្រះមានឫទ្ធានុភាពដ៏អស្ចារ្យនេះ ហើយមើលទៅលើសកលលោក ហើយទ្រង់គ្រប់គ្រងលើវា។ ដូចដែលព្រះជាម្ចាស់ដាក់ត្រា ហើយបញ្ជាក់ថា គ្មាននរណាម្នាក់អាចផ្លាស់ប្តូរវាបានទេ។ ព្រះមានសិទ្ធិអំណាចដ៏អស្ចារ្យ ហើយក៏អនុវត្តវាដែរ។ យើងគួរចងចាំថាត្រាគឺជាត្រានៃព្រះដ៏មានព្រះជន្មរស់។ ទោះបីជាវាគឺជាត្រាដើម្បីជំនួសអំណាចដ៏អស្ចារ្យក៏ដោយ តែប្រសិនបើម្ចាស់មិនរស់នៅ គ្មានអ្វីអាចបង្ហាញពីប្រសិទ្ធភាពឡើយ។ ប៉ុន្តែព្រះស្ថិតនៅក្នុងភាពអស់កល្បជានិច្ចមានសិទ្ធិអំណាចទាំងអស់ ត្រារបស់ទ្រង់អាចបង្កើតប្រសិទ្ធភាពដែលជំនួសអធិបតេយ្យភាពដាច់ខាតដ៏អស្ចារ្យ។ ពួកបរិសុទ្ធដែលត្រូវបានជ្រើសរើសម្តងរួចហើយ ហើយបានទទួលត្រានៃព្រះវិញ្ញាណបរិសុទ្ធរួចហើយ នោះមិនត្រូវបានបំផ្លាញអស់កល្បជានិច្ចឡើយ ។

2. សេចក្តីសង្គ្រោះត្រូវបានអះអាងដោយត្រានេះ

សេចក្តីសង្គ្រោះត្រូវបានអះអាងដោយព្រះដ៏មានព្រះជន្មរស់ វាបង្ហាញការពីរយ៉ាងនៅក្នុងវិវរណៈជំពូក7នៅទីនេះ។

(1) ភាពយុត្តិធម៌របស់ព្រះ

នៅពេលយើងអានអត្ថបទនោះ ចំនួនអ្នកត្រូវបានបោះត្រាមាន 12000 នាក់ក្នុងកុលសម្ព័ន្ធនីមួយៗនៃ 12 កុលសម្ព័ន្ធ។ នេះមានន័យថាជាយុត្តិធម៌របស់ព្រះ។ ជាការពិតណាស់ចំនួននេះមិនគួរត្រូវបានគេមើលឃើញតាមអក្សរសាស្ត្រនោះទេ ប៉ុន្តែការពិតដ៏អស្ចារ្យមួយដែលយើងមើលគឺថា ព្រះជាម្ចាស់ទ្រង់យុត្តិធម៌។ កុលសម្ព័ន្ធខ្លះមានចំនួនភាគច្រើន ប៉ុន្តែកុលសម្ព័ន្ធផ្សេងទៀតមិនមានតិចតួចទេ ប៉ុន្តែកុលសម្ព័ន្ធទាំងអស់មានរហូតដល់ 12000។ ព្រះមិនអនុវត្តចំពោះមនុស្សទាំងអស់ទេ ប៉ុន្តែដើម្បីជ្រើសរើសមនុស្ស ប៉ុន្តែយើងមិនអាចសង្ឃឹមថាព្រះជាម្ចាស់ទ្រង់យុត្តិធម៌នោះឬអត់នោះទេ។ ទោះបីប្រទេសមួយមានឃាតក និងចោរជាដើមក៏ដោយ ការដែលប្រជាជនរស់នៅដោយសុខសាន្ត គឺកើតចេញពីការនឹកឃើញការពិតដើម្បីឱ្យមានរដ្ឋាភិបាលយុត្តិធម៌។ វិធីដើម្បីទទួលបានការលួងលោមក្នុងពិភពចម្រូងចម្រាស គឺត្រូវចងចាំការពិតថា មានតែព្រះនៃយុត្តិធម៌ប៉ុណ្ណោះ ដែលធ្វើអោយអ្វីៗទាំងអស់បានយុត្តិធម៌ពិត។

(2) ការអះអាងដែលឈានដល់ចំនួនធំបំផុត

នៅពេលយើងអានអត្ថបទដោយលម្អិត តួលេខដើម្បីសម្រេចបានសេចក្តីសង្គ្រោះគឺជាចំនួនអតិបរមា។ មនុស្ស 1200 នាក់ក្នុងចំណោមកុលសម្ព័ន្ធនីមួយៗត្រូវបានជ្រើសរើស ហើយត្រូវបានត្រា។ តើ 12000 ជានិយមន័យត្រង់ៗថាមានតែ 12000 មែនទេ? ទេ បើចំនួននៃវិវរណៈត្រូវបានចាត់ទុកតែលេខនិយមន័យត្រង់ៗ តើវិញ្ញាណទាំងប្រាំពីរ (ព្រះវិញ្ញាណបរិសុទ្ធ) មានក្នុងសៀវភៅវិវរណៈទេ? យើងមិនអាចគិតដូច្នេះទេ។ ព្រះ

វិញ្ញាណបរិសុទ្ធ គឺជាពាក្យមួយនៃវិញ្ញាណទាំងប្រាំពីរ ដែលជាការបង្ហាញជានិមិត្តរូប នោះគឺជាលក្ខណៈពេញលេញរបស់ទ្រង់ ដែលកិច្ចការនៃព្រះវិញ្ញាណបរិសុទ្ធអាចមានឥទ្ធិពលលើគ្រប់ការទាំងអស់។ (វិវរណៈ 5:6) 12000 ក៏ជាលេខនិមិត្តសញ្ញាដែរ។ តើវាបង្ហាញអ្វីខ្លះ? លេខ 12 គឺជាចំនួនប្រជាជនដែលព្រះជាម្ចាស់ជ្រើសរើស យើងអាចដឹងតាមរយៈកុលសម្ព័ន្ធ 12 និង សាវ័កទាំង12 ។ បន្ទាប់មក 1000 ដងនៃ 12 គឺ 12000 ។ លេខ "1000" មានន័យថាចំនួនអតិបរមានៅក្នុងគំនិតរបស់ហេព្រើរ (សូមមើល ទំនុកតម្កើង 90:4 2ពេត្រុស 3:8) បន្ទាប់មក 1000 ដងនៃចំនួន 12 ដែលជាចំនួនធំបំផុត នោះគឺវា ត្រូវបានពង្រីកដល់ 1000 ដង។ អត្ថន័យគឺការបង្កើនចំនួនដែលបានជ្រើសរើស (12) ទៅជាចំនួនធំបំផុត។ ម្យ៉ាងទៀត វាមានន័យថា កាលព្រះបានសង្គ្រោះមនុស្សនោះ ទ្រង់សង្គ្រោះចំនួនដ៏ច្រើនបំផុត។

ការអធិប្បាយទី 30 លោហិតរបស់កូនចៀម (វិវរណៈ 7:14-17)

ព្រះលោហិតនៃព្រះយេស៊ូវគ្រីស្ទ គឺជាឈាមនៃដង្វាយធួនបាបដែលព្រះអង្គទ្រង់បានធ្វើសម្រេចតាំងពីអស់កល្បជានិច្ច ។ បញ្ហាក្នុងជីវិតត្រូវដោះស្រាយដោយការដោះស្រាយបញ្ហាបាបនេះ។ ទោះបីបាបតិចបំផុតក៏ដោយ ក៏ធ្វើឱ្យមនុស្សធ្លាក់នរកដែរ (ម៉ា

ថាយ 5:22)។ ដូច្នេះយើងអាចដឹងថាវាគួរឱ្យរន្ធត់ប៉ុណ្ណា។ ប៉ុន្តែយើងមានអ្នកដែលអាចរំដោះយើងបាន គឺមានតែព្រះទេដែលទ្រង់ជាអ្នកកាត់ទោស។ ក្នុងន័យថា ព្រះទ្រង់ផ្ទាល់បានប្រោសលោះយើង ទ្រង់បានចាត់ទុកប្រាក់ឈ្នួលនៃអំពើបាបរបស់យើងប្តូរជាឈាមនៃព្រះរាជ្យបុត្រាតែមួយរបស់ទ្រង់។ កាលដែលព្រះជាម្ចាស់ផ្ទាល់គ្រប់គ្រងលើកិច្ចការនេះ ទ្រង់បានធ្វើដោយការលះបង់របស់ទ្រង់អស់រយៈពេលជាយូរ។ ការបង្កើតនេះត្រូវបានសម្រេចដោយពីរបីថ្ងៃ ប៉ុន្តែដង្វាយធួនត្រូវបានសម្រេចនៅទីបំផុតដោយឈាមរបស់ព្រះរាជ្យបុត្រាតែមួយរបស់ទ្រង់ តាមរយៈផែនការរបស់ទ្រង់នៅក្នុងភាពអស់កល្បជានិច្ច ដោយបានរើសទុកមុនមនុស្សរាប់ពាន់នាក់។ ឈាមនៃការដង្វាយធួននឹងបាបដែលបានសម្រេចដូចជាឈាមនៃសេចក្តីសញ្ញាដែលត្រូវបានបង្កើតឡើងតាំងពីអស់កល្បជានិច្ច។ ដ្បិតវាជាលោហិតនៃការតាំងសញ្ញា ដែលវាបានផ្តល់សេចក្តីជំនឿគ្នាមដែនកំណត់។ 1កូរិនថូស 1:20 មានបន្ទូលថា “តើអ្នកប្រាជ្ញនៅឯណា តើអាចារ្យនៅឯណា តើអ្នកដេញដោលនៃសម័យនេះនៅឯណា ព្រះទ្រង់បានធ្វើឱ្យប្រាជ្ញារបស់លោកីយ៍នេះ ទៅជាសេចក្តីល្ងង់ល្ងើវិញទេតើ”។ ព្រះលោហិតនៃសេចក្តីសញ្ញារបស់ព្រះយេស៊ូវគ្រីស្ទសន្យាលោកិយដែលនឹងមកដល់ដ៏អស់កល្ប និងអនាគតដ៏អស់កល្បជានិច្ច។ នោះគឺអ្នកដែលជឿលើទ្រង់នឹងមានជីវិតអស់កល្បជានិច្ច។ កិច្ចព្រមព្រៀងនេះត្រូវបានបង្ហាញនៅយ៉ូហាន 6:53-56។ នៅក្នុងខបួន ពាក្យដដែលលេចមកបួនដង។ មានបន្ទូលថា “នោះព្រះយេស៊ូវមានព្រះបន្ទូលទៅគេថា ប្រាកដមែនខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា បើអ្នករាល់គ្នាមិនពិសាសាច់ ហើយមិនផឹកឈាមរបស់កូនមនុស្ស នោះអ្នករាល់គ្នាគ្មានជីវិតនៅក្នុងខ្លួនទេ អ្នកណាដែលបរិភោគសាច់ នឹងឈាមរបស់ខ្ញុំ នោះមានជីវិតដ៏នៅអស់កល្បជានិច្ច ហើយខ្ញុំនឹងឱ្យអ្នកនោះរស់ឡើងវិញ នៅថ្ងៃចុងបំផុត ពីព្រោះសាច់ខ្ញុំជាអាហារពិត ហើយឈាមខ្ញុំក៏

ជាគ្រឿងផឹកពិតប្រាកដ អ្នកណាដែលបរិភោគសាច់ និងឈាមរបស់ខ្ញុំ នោះនៅក្នុងខ្ញុំ ហើយខ្ញុំក៏នៅក្នុងអ្នកនោះដែរ”

ក្នុងចំណោមពាក្យទាំងនេះ ហេតុផលដែលពាក្យដដែលៗលេចមក មានន័យថាមានការសង្កត់ន័យធ្ងន់លើវា។ ដោយសារសេចក្តីពិតដែលថាយើងត្រូវបានធួននឹងបាបដោយព្រះលោហិតរបស់ព្រះគ្រីស្ទគឺពិតណាស់ ហើយជាសេចក្តីពិតដែលមានរសជាតិឆ្ងាញ់ពេក នោះយើងគួរជឿលើវាដូចជាការបរិភោគ និងផឹក។ ជាពិសេសតាំងសញ្ញានេះត្រូវបានលាតត្រដាងពីភាពស្មោះត្រង់ ខណៈដែលអ្នកជឿត្រូវបានស្លាប់។ នៅពេលដែលអ្នកជឿជឿលើឈាមរបស់ទ្រង់ ហើយត្រូវបានចាកចេញ ភាពរីករាយក្នុងការចូលទៅក្នុងស្ថានសួគ៌ត្រូវតែមានបទពិសោធន៍ជាក់ស្តែង។ ដូច្នេះលោក ស្ពឺជិន និយាយថា “ដូចដែលយើងឃើញការចាកចេញរបស់ពួកបរិសុទ្ធ វាពិតជាគួរឱ្យចាប់អារម្មណ៍ណាស់។ យើងគួរតែកាន់ព្រះលោហិតរបស់ព្រះយេស៊ូវជាប់ជានិច្ចទុកជាការចម្រើនកម្លាំង។”

ជំពូកទី 8

ការបកស្រាយ

នោះនៅស្ថានសួគ៌បានស្ងាត់ជ្រៀប ប្រហែលជាកន្លះម៉ោង។ តើ “ភាពស្ងៀមស្ងាត់នៅស្ថានសួគ៌ប្រហែលកន្លះម៉ោង” មានន័យដូចម្តេច? នៅទីនេះមានទស្សនៈមួយចំនួន។ (1) លោក វីកធរីនុស បាននិយាយថា “សញ្ញានៃការសម្រាកអស់កល្បជានិច្ចដែលពួកបរិសុទ្ធនឹងបានរីករាយ”។ (Semi hora nitium quictis aeternae)។ (2) លោក ប្រ្គេចដានុស បាននិយាយថា “ការនេះប្រាប់ពីការភ័យខ្លាចនៃបណ្តាសា និងការដាក់ទោស” (En dat wijst op het verschrikklijke van hetgreen te wachten staat)។ (យោងតាម សេផានា 1:7) (3) លោក H. W. Swete បាននិយាយថា “ការនេះមានន័យថាជាការបើកសម្តែងរបស់ព្រះដែលត្រូវបានឈប់” (4) លោក ឆលស៍ បាននិយាយថា វាមានន័យថាជា ការស្ងាត់ពីការអធិស្ឋាន ដែលនៅពេលអនាគតនឹងចេញមក (3,4)។ គាត់បានផ្តល់នូវបទគម្ពីរដែលចេញមកពីឯកសាររបស់សាសនាយូដាដើម្បីនឹងសម្រេចបំពេញនូវទស្សនៈនេះ។ យោងតាមឯកសារនោះ ហ្វូងទេវតាដែលបម្រើនៅស្ថានសួគ៌ទីប្រាំបានសរសើរនៅពេលយប់ តែនៅពេលថ្ងៃបានលើកការសរសើររបស់អ៊ីស្រាអែលវិញ កាលដែលការសរសើររបស់ទេវតាដែលត្រូវឈប់ ហើយងនៅស្ងាត់នោះ។ (ICC Commentary, Revelation p 223-224) ការរក្សាស្ថានភាពស្ងៀមស្ងាត់នៅក្នុងការអធិស្ឋានត្រូវបានបង្រៀនដោយព្រះគម្ពីរសញ្ញាចាស់។ (2ក្រូនិចូស 29:29) (5) លោក រីកណាល់ដា បាននិយាយថា “ការនេះចង្អុលទៅកាន់សំពាធខ្លាំងមួយដែលនៅថ្ងៃចុងក្រោយរបស់លោកិយមិនអាចធ្វើអ្វីបានឡើយក្រៅពីត្រូវតែកើតឡើង។ គាត់និយាយថា “នេះជាការចាប់ផ្តើមនៃគ្រាចុងក្រោយ។ ពេលនេះថ្ងៃចុងក្រោយមកដល់ហើយ។ ព្រះគ្រីស្ទបានព្យាយាមចាប់ផ្តើមដោយបង្កើតភាពជាស្តេចនៅលើផែនដីទាំងមូល។ (Het Koningschap Van Christus, ទំព័រ 157) (6) យោងតាមទ្រឹស្តីមួយ ភាពស្ងៀមស្ងាត់នេះជានិមិត្តសញ្ញា

នៃសេចក្តីមេត្តាដែលពេញដោយព្រះគុណ ដែលព្រះទ្រង់ផ្តល់ដល់មនុស្សមានបាប។ ព្រះទ្រង់មិនសព្វព្រះទ័យដែលមនុស្សមានបាបត្រូវស្លាប់ឡើយ។ (អេសេគាល 33:11) ។ រួចមកមនុស្សមានបាបមិនបានប្រែចិត្តទេ នោះព្រះទ្រង់បានរក្សានូវភាពស្ងៀមស្ងាត់ដោយសម្ងាត់អស់ពេលជាយូរ។ នេះជាឱកាសល្អដែលអ្នកដែលបានប្រែចិត្តមាន តែជាអំឡុងពេលដែលគួរឱ្យរន្ធត់ដែលត្រូវដាក់នូវព្រះពិរោធរបស់ព្រះដែលមនុស្សមិនព្រមប្រែចិត្តនឹងត្រូវទទួល។

2 ទេវតាទាំងប្រាំពីរដែលឈរនៅចំពោះព្រះ។ ពាក្យថាទេវតា នោះចេញមកពី អេសាយ 35:9 ប៉ុន្តែលេខប្រាំពីររបស់ពួកគេបង្ហាញនៅទីនេះលើកដំបូង។ លោក ម៊ិហ្វាត និយាយថា វាចេញមកពី អាផូគ្រីផា (Tobid 15:12)។ ថូប៊ីត នៅក្នុងអាផូគ្រីផា និយាយថា “ខ្ញុំជារ៉ាហ្វាអែល ជាម្នាក់នៅក្នុងចំណោមទេវតាទាំងប្រាំពីរ ដែលនាំការអធិស្ឋានរបស់ពួកបរិសុទ្ធ និងចូលទៅក្នុងសិរីល្អនៃទីបរិសុទ្ធបំផុត។” ប៉ុន្តែវាជាការយល់ខុសក្នុងការអះអាងពីឃ្លាថាទេវតាប្រាំពីរនៅក្នុងវិវរណៈចេញមកតែ អាផូគ្រីផាទាំងស្រុងនោះ។ នៅទីនេះលេខប្រាំពីរនៃទេវតាត្រូវបានប្រើដោយទាក់ទងទៅនឹងត្រែប្រាំពីរនិងមានអត្ថន័យបែបជានិមិត្តសញ្ញា។ ប៉ុន្តែលេខប្រាំពីរនៃអក្សរសិល្ប៍របស់អាផូគ្រីផាមានអត្ថន័យបែបជាអក្សរសាស្ត្រ។

3 មានទេវតាមួយទៀតចេញមកឈរនៅចំពោះអាសនានៅមុខបល្ល័ង្ក ដោយសារទេវតានេះបានធ្វើការដូចជាសកម្មភាពរបស់អ្នកផ្សះផ្សា នោះមានមនុស្សម្នាក់បានសង្កេតឃើញថាទ្រង់ជាព្រះគ្រីស្ទ។ ប៉ុន្តែទេវតានេះមិនបានមកដល់អ្នកផ្សះផ្សាដែលធ្វើការដោយអំពើរបស់អង្គទ្រង់នោះទេ។ ទេវតានេះត្រូវបានផ្តល់នូវ**គ្រឿងក្រអូបជាច្រើន** (ἐδόθη) គ្រឿងក្រអូបមិនមែនជារបស់គេឡើយ។ “គ្រឿងក្រអូប”(ជាសេចក្តីប្រោស

លោះ) គឺមានតែព្រះគ្រីស្ទតែមួយអង្គគត់។ ដូច្នេះទេវតាជាអ្នកដែលបម្រើដល់ព្រះគ្រីស្ទ។ (វិវរណៈ 1:1) **ដើម្បីនឹងថ្វាយជាមួយនឹងសេចក្តីអធិស្ឋានរបស់ពួកបរិសុទ្ធ** លោកព្រ្តេចជានុសនិយាយថា "ការអធិស្ឋានផ្ទាល់គ្មានអំណាចដើម្បីលើកឡើងទៅចំពោះព្រះឡើយ។ ការអធិស្ឋានគួរតែទទួលបានដោយគុណសម្បត្តិរបស់ព្រះគ្រីស្ទដើម្បីធ្វើឱ្យការអធិស្ឋានបានថ្វាយដល់ព្រះ។ ដូច្នេះតើការអធិស្ឋានអ្វី? វាគឺដើម្បីស្វែងរកនគរនៃព្រះនិងសេចក្តីសុចរិតរបស់ទ្រង់ បែបជាអវិជ្ជមាន វាស្វែងរកការវិនិច្ឆ័យរបស់ព្រះដោយការប្រព្រឹត្តទៅចំពោះអំពើបាបនិងសត្រូវរួមនៃស្ថានបរមសួគ៌។ (យោងតាម ម៉ាថាយ 6:33, លូកា 18:7 វិវរណៈ 6:10)។ ពីដើមមក ការអធិស្ឋានរបស់ពួកបរិសុទ្ធត្រូវបានលើកឡើងទៅស្ថានសួគ៌ ហើយថ្វាយផង ហើយក៏ត្រូវបានឆ្លើយតបដោយគ្រោះកាចទាំង 7។ ប៉ុន្តែដូចដែលយើងឃើញពាក្យថា "ការអធិដ្ឋានច្រើន" (dimiamatpola = θυμιάματα πολλὰ) ការអធិស្ឋានច្រើនជាដំបូងគួរតែត្រូវបានលើកចេញពីពួកបរិសុទ្ធ។ ស្ថានសួគ៌រក្សាភាពស្ងប់ស្ងាត់រហូតដល់ការអធិស្ឋានដ៏ច្រើនរបស់ពួកបរិសុទ្ធត្រូវបានលើកឡើង (វិវរណៈ 8:1) បន្ទាប់ពីនោះព្រះពិរោធរបស់ព្រះធ្វើឱ្យពួកគេក្លាយទៅជាការច្របូកច្របល់យ៉ាងខ្លាំង នោះគឺគ្រោះកាចដ៏អាក្រក់ត្រូវបានទម្លាក់ចុះតាមសំឡេងត្រែប្រាំពីរ។

4 ពាក្យនេះនៅចំកណ្តាលគ្រឿងក្រអូបជាជាងការអធិស្ឋានដែលធ្វើឱ្យអធិដ្ឋានត្រូវបានលើកឡើងដល់លើបល្ល័ង្ក។ នៅក្នុង 5:8 ការអធិស្ឋានរបស់ពួកបរិសុទ្ធត្រូវបានហៅថាជាគ្រឿងក្រអូបដែលជាធាតុសម្រាប់បង្កើតការអធិស្ឋាននោះគួរតែជាគ្រឿងក្រអូប (កិច្ចការរបស់នៃព្រះគ្រីស្ទ) ។

5 រួចទេវតាក៏យកពាន ទៅដាក់ពេញដោយភ្លើងពីលើអាសនា បោះទៅលើផែនដី។

ភ្លើងនៅលើអាសនានេះមានន័យថាសេចក្តីក្រោធរបស់ព្រះ។ ដូច្នេះហើយ នៅទីនេះ “ហើយបានពេញដោយភ្លើងពីអាសនា ហើយបោះវាមកលើផែនដី” គឺជានិមិត្តរូបនៃការពិតថា កំហឹងរបស់ព្រះបំផ្លាញមនុស្សមានបាបដែលមិនព្រមប្រែចិត្ត ។ នៅចំណុចដែលយើងខ្ទល់ខ្វាយ ចង្កៀងមាសដែលពេញដោយគ្រឿងក្រអូបនៃការអធិស្ឋានត្រូវបានប្រើប្រាស់ដើម្បីពោពេញដោយភ្លើងនៃកំហឹង។

ឧបករណ៍នេះស្ថិតនៅម្ខាង ជាភាជន៍ទាញសេចក្តីមេត្តាដល់ពួកបរិសុទ្ធ ចំណែកម្ខាងទៀតជាភាជនៈនៃសេចក្តីក្រោធដល់សត្រូវរួមនៃស្ថានសួគ៌។ នេះគឺជាភាពផ្ទុយគ្នាដ៏ចម្លែក។ ជាក្លិនជីវិតដល់ពួកបរិសុទ្ធ ហើយក៏ក្លាយជាក្លិននៃសេចក្តីស្លាប់ចំពោះអ្នកដែលត្រូវបំផ្លាញ។(2កូរិនថូស 3:14-16)។

មានសម្លេងផ្គរលាន់ ផ្លេកបន្ទោរ និងការក្រើកដី។ នេះស្ទើរតែជានិមិត្តរូបនៃកំហឹងរបស់ព្រះ។ នៅទីនេះ “ការលាន់សម្លេង” ហាក់ដូចជាបង្ខំឱ្យមានការប្រែចិត្ត ដែលមនុស្សនោះអាចត្រូវបានគេស្គាល់ដោយបញ្ញាដោយការស្រែក។ វាហាក់ដូចជាគ្រាន់តែជាការបង្ហាញនៃសេចក្តីមេត្តាករុណាប៉ុណ្ណោះ។ ប៉ុន្តែយើងមិនអាចសម្រេចចិត្តច្បាស់នៅត្រង់ចំណុចនោះទេ ព្រោះ “ការថ្កោលទោស” ក៏អាចជាសំឡេងនៃការវិនិច្ឆ័យដែរ។ (ទំនុកដំកើង 29:) យោងតាមការបកស្រាយនៃ ទំនុកដំកើង 4:5។

ផ្នែកទី 5

គ្រោះនៃត្រែទាំងប្រាំពីរ

8:6-11:19

ត្រែទីមួយ - គ្រោះកាចនៃព្រឹលលាយជាមួយឈាមនិងភ្លើង (8: 7) ត្រែទីពីរ - ភ្នំដ៏ធំមួយដែលឆេះដោយភ្លើងត្រូវបានបោះចោលទៅក្នុងសមុទ្រ (8: 8,9) ត្រែទីបី - មួយភាគបីនៃព្រះអាទិត្យ ព្រះច័ន្ទ ផ្កាយបានក្លាយជាងងឹត។ (8:12) ត្រែទីប្រាំ គ្រោះកាចចេញពីជង្ហុកដែលគ្មានបាត (9:1-11)។ ត្រែទីប្រាំមួយ—[1] គ្រោះកាចនៃរទេះសេះ (9:13-23) [2] ការរៀបចំនៃវិវរណៈ (10:1-11:14) ត្រែប្រាំពីរជាសំឡេងដ៏អស្ចារ្យដែលចេញមកពីស្ថានសួគ៌ដើម្បីប្រាប់ពីសម្រេចបំពេញចុងក្រោយ (11:15-19)

តើការផ្លុំត្រែមានន័យដូចម្តេច? មានការបកស្រាយជាច្រើន។

1. ការបកស្រាយរបស់ ឡាញ

ត្រែជាឧបករណ៍ដែលប្រើនៅក្នុងសមរភូមិ ត្រូវប្រើសម្រាប់ព្រមានដល់ទាហានដើម្បីនិងប្រមូលយកទៅធ្វើសង្គ្រាម។ ដូច្នេះ ត្រែគឺជានិមិត្តសញ្ញានៃចង្អុលប្រាប់របស់ព្រះដែលព្រះដឹកនាំពួកគេចូលទៅក្នុងសង្គ្រាមខាងវិញ្ញាណ។ ហេតុផលដែលពួកជំនុំគួរធ្វើសង្គ្រាមខាងវិញ្ញាណ គឺដោយសារតែក្នុងលោកនេះ ពួកជំនុំគួរតែប្រឈមទ្វេទាស់ជាមួយនឹងការបង្រៀនខុសឆ្គង និងការបង្រៀនមិនពិត។ គ្រោះកាចនៃត្រែនៃវិវរណៈគឺទាក់ទងនឹងសាសនាខុសឆ្គង។ អ្វីដែលនឹងកើតឡើងដោយគ្រោះនៃត្រែដំបូងគឺព្រឹលលាយឈាមនិងភ្លើង។ "ព្រឹល" គឺជានិមិត្តសញ្ញានៃការមិនជឿដោយមិនយល់ពីសេចក្តីពិតរបស់ព្រះ។ "ភ្លើង" គឺជានិមិត្តសញ្ញានៃភាពជ្រុលនិយមដែលត្រូវបានដកចេញពីការពិត។ “ឈាម” គឺជានិមិត្តសញ្ញានៃការបៀតបៀនដោយការប៉ះទង្គិចខាងមនោគមវិជ្ជាដែលបានកើតឡើងនៅក្នុងសង្គមដែលយល់ខុសលើបន្ទាត់នៃការពិតត្រឹមត្រូវ។ ប៉ុន្តែយើងពិបាកទទួលយកទ្រឹស្តីនេះណាស់។ លោក ឡាញ បាននិយាយពីគ្រោះកាចនៃត្រែទីពីរដូចតទៅ៖ “នោះគឺគ្រោះកាចនៃត្រែទីពីរគឺដូចជាភ្នំដ៏អស្ចារ្យដែលឆេះដោយភ្លើ

ងត្រូវបានបោះចោលទៅក្នុងសមុទ្រ វាគឺជានិមិត្តសញ្ញានៃចលនាងប់ងល់នៃនិកាយសាសនាដែលបង្កគ្រោះថ្នាក់ដល់ប្រទេស។ ប៉ុន្តែយើងគិតថាទស្សនៈគាត់ជាការបកស្រាយខុស។ ហើយគាត់បាននិយាយថា "ផ្កាយដ៏អស្ចារ្យមួយបានធ្លាក់ពីលើមេឃឆេះដូចភ្លើង" ចង្អុលទៅសាសនវិទ្យាដែលខុសឆ្គងដែលថាជំនឿអ្នកបើត្រូវបានធ្លាក់ចុះមកជាភាពមនុស្សនិយមវិញ។ ហើយលោកបន្តថាដូចតទៅថា នោះគឺគ្រោះនៃត្រែទាំង 4 ជាសញ្ញានៃការពិតដែលថា សេចក្តីពិតមិនបញ្ចេញពន្លឺដោយការបកស្រាយខុសឆ្គងរបស់មនុស្សទេ ហើយគ្រោះត្រែទី5 ជាចលនានៃសេចក្តីទុច្ចរិតដើម្បីបិទបាំងនូវដំណឹងល្អ គ្រោះត្រែទី6 គឺចង្អុលប្រាប់ព្រឹត្តិការណ៍ដែលទេវតាអាក្រក់នឹងបក់បោកមកលើផែនដីដោយការបង្រៀនមិនពិតដូចជាអំណាចនៃក្រមរទេះចំបាំង។

2. លោក អេលៀត ពន្យល់ថា គ្រោះនៃត្រែគឺតទៅនេះ។ ត្រែទីមួយជានិមិត្តសញ្ញានៃពូជអំបូរហ្គស៊ែលបានវាយប្រហារក្រុងរ៉ូម (គ.ស 400-410) គ្រោះនៃត្រែទីពីរជានិមិត្តសញ្ញានៃការលុកលុយនៃពូជអំបូរហ្គស ពូជអំបូរ វ៉ាន់ដាល់ ពូជអំបូរហ៊ុនជាដើមមកកាន់ក្រុងរ៉ូម (គ.ស 429-477) គ្រោះនៃត្រែទីបីជានិមិត្តសញ្ញានៃការលុកលុយរបស់អាធីឡាមកកាន់ក្រុងរ៉ូម (គ.ស 450-453) គ្រោះនៃត្រែទីបួនជាការពិតដែលអាណាចក្ររ៉ូមត្រូវបានបំផ្លាញដោយ អូដូស៊ើ (476 ឬ 479) គ្រោះនៃត្រែទីប្រាំជាទំនាយដែល ទាហានរបស់មហាម៉ត (ដើម្បីចាប់ផ្តើមជាមួយនឹងសកម្មភាពរបស់គាត់នៅគ.ស 612) ដែលបានលុកលុយក្រុងរ៉ូមអស់រយៈពេល 150 ឆ្នាំ។ ហើយគ្រោះនៃត្រែទីប្រាំមួយជាទំនាយថា ប្រទេសតួគីនឹងលុកលុយទៅកាន់អាណាចក្ររ៉ូមខាងកើតនៅឆ្នាំ 1453 និងបំផ្លាញវាផង។ វាពិបាកដែលយើងទទួលនូវការបកស្រាយរបស់អេលៀត។

3. លោក ហ្គាស្តូ បានបកស្រាយដូចតទៅនេះ

គ្រោះនៃត្រែដំបូងចង្អុលទៅការពិតដែលថា 1/3 នៃជនជាតិយូដាត្រូវបានបំផ្លាញដោយរ៉ូម គ្រោះនៃត្រែទីពីរចង្អុលបង្ហាញការពិតដែលថាជនជាតិយូដាបានបះបោរក្រោមការដឹកនាំរបស់ បា ខកហាប ទៅកាន់ទីក្រុងរ៉ូម ហើយពួកគេត្រូវបានខ្ចាត់ខ្ចាយទៅក្នុងគ្រប់ជាតិសាសន៍។ គ្រោះនៃត្រែទីបី ចង្អុលទៅលើការកើតឡើងនៃសាសនាគ្រោះកាចទីបួន ចំណុចសាសនារបស់អារៀន។ គ្រោះនៃត្រែទីប្រាំ ចង្អុលទៅចលនាមិនជឿរបស់មហាម៉ាត។ គ្រោះនៃត្រែទីប្រាំមួយចង្អុលទៅទំនាយដែលសម្លាប់ពួកគ្រីស្ទានថា ព្រះវិហារ៉ូម៉ាំងកាតូលិក ចាប់ពីឆ្នាំ 112 នៃគ.ស រហូតដល់គ្រានៃចលនារបស់ពួកកំណែទម្រង់។ ប៉ុន្តែវាពិបាកណាស់ដែលយើងទទួលយកការបកស្រាយនេះយ៉ាងប្រាកដនោះ។

4. ការបកស្រាយខាងលើមានទំនោរទៅរកទំនោរដែលពិសេស

and fireការបកស្រាយខាងលើមានទំនោរនៃលក្ខណៈឯករាជ្យពេក។ យើងអាចមានទិដ្ឋភាពជាក់ស្តែងនៃគ្រោះនៃត្រែដូចខាងក្រោម។ (1) គ្រោះកាចនេះមិនបង្កគ្រោះថ្នាក់ដល់ពួកបរិសុទ្ធខាងវិញ្ញាណទេ (9:4) ប៉ុន្តែធ្វើបាបតែមនុស្សអាក្រក់ប៉ុណ្ណោះ។ ដូចគ្នានឹង គ្រោះកាចទាំងដប់ដែលបានបញ្ជូនទៅពួកអេហ្ស៊ីបបានបង្កគ្រោះថ្នាក់ដល់តែជនជាតិអេស៊ីបប៉ុណ្ណោះ។ ដូចដែលយើងប្រៀបធៀបគ្រោះកាចទាំងដប់នៃប្រទេសអេហ្ស៊ីប និងគ្រោះកាចនៃត្រែ វាមានចំណុចស្រដៀងគ្នា។ [1] ព្រឹលនិងភ្លើង (វិវរណៈ 8:7, និក្ខមនំ 9:24) [2] ទឹកត្រូវបានប្តូរទៅជាឈាម (វិវរណៈ 8:8 និក្ខមនំ 7:19) [3] សេចក្តីងងឹត (វិវរណៈ 8:12) និក្ខមនំ 10:21) [4] កណ្តូប (វិវរណៈ 9:3 និក្ខមនំ 10:12) ជាដើម។ (2) នៅក្នុងការបង្ហាញបែបជានិមិត្តរូបដោយគ្រោះនៃត្រែ [1] ឈាម (ជាគ្រោះនៃត្រែទីមួយ) មានន័យថាជាការសម្លាប់ ហើយវាជានិមិត្តសញ្ញានៃសង្គ្រាម [2] ភ្នំធំដែលកំពុងឆេះដោយភ្លើង (ជាគ្រោះនៃត្រែទីពីរដែលចង្អុលទៅកាន់

សេចក្តីវិនាសរបស់អ្នកប្រឆាំងនឹងនគររបស់គ្រីស្ទាននៅក្នុងទំនាយរបស់យេរេមា វាពិបាកដែលយើងនិយាយនៅទីនេះថាមិនមែនជានិមិត្តសញ្ញានៃគ្រីស្ទាននោះ។ [3] ការពិតដែលផ្កាយដ៏ធំត្រូវបានធ្លាក់ចុះនៅក្នុងទឹក ហើយធ្វើឱ្យវាក្លាយជាល្វីញដែលចង្អុលទៅកាន់និមិត្តសញ្ញានៃសេចក្តីពុករលួយនៃអ្នកដឹកនាំសាសនា។ ពីព្រោះកិច្ចការដែលធ្វើឱ្យទឹកទៅជាល្វីញនោះជារបស់ហោរក្លែងក្លាយ។ ការធ្វើឱ្យទឹកទៅជាល្វីញជានិមិត្តសញ្ញានៃចលនារបស់គ្រូខុសឆ្គងដែលបន្លំព្រះបន្ទូលរបស់ព្រះ។ [4] ការបាត់បង់ពន្លឺពីព្រះអាទិត្យ ព្រះច័ន្ទ និងផ្កាយ (គ្រោះចង្រៃទីបួន) គឺជានិមិត្តសញ្ញាដែលសាសនាត្រូវបានផ្លាស់ប្តូរទៅជាងងឹតដោយគ្រោះចង្រៃទី 3 ខាងលើ តាមគោលការណ៍វានឹងត្រូវបំភាន់ផងដែរ។ ព្រះអាទិត្យ ព្រះច័ន្ទ ផ្កាយ គឺជានិមិត្តរូបនៃអ្នកដឹកនាំសាសនា (ដានីយ៉ែល 12:3) ហើយអាចជានិមិត្តសញ្ញានៃអ្នកដឹកនាំនយោបាយ។ (អេសាយ 13:10, វិវរណៈ 6:13-15)។ គ្រោះនេះហាក់ដូចជាទាក់ទងនឹងស្ថានភាពនាសម័យទំនើប។ បន្ទាប់ពីសង្គ្រាមលោកលើកទី 2 យើងរំពឹងថានឹងមានការសម្អាតព្រះវិហារ និងការរស់ឡើងវិញរបស់នាង។ ប៉ុន្តែ ផ្ទុយទៅវិញ ដូចជា “ភ្នំដែលឆេះដោយភ្លើង” ប្រទេសដែលប្រឆាំងនឹងព្រះគ្រីស្ទត្រូវបានចាញ់ ហើយសង្គ្រាមត្រូវបានបញ្ចប់ក៏ដោយ ក៏ពួកជំនុំបច្ចុប្បន្នដើរក្នុងផ្លូវដែលខូចដដែល។ យោងទៅតាមភាពរុងរឿងនៃការបង្រៀនខុសឆ្គងដូចជា "" អ្នកដឹកនាំមានការភ័ន្តច្រឡំ។ ពួកគេមិនបានឃើញការពិត ហើយមិនគិតពីបញ្ហានៃការប្រែចិត្តធ្ងន់ធ្ងរនោះទេ ដោយការបន្ទូរបន្ថយទៅនឹងលំហូរនោះបន្ទាប់ពីសង្គ្រាម ពួកគេធ្វើតាមចលនានៃភាគច្រើន (ជំនឿស្តិតិ)។ ដោយសារមនុស្សជំនាន់នេះបង្ហាញនូវរូបរាងនៃចលនាបះបោរ មិនយូរប៉ុន្មានគ្រោះត្រៃទីប្រាំ នោះគឺ ផែនដីនឹងពោរពេញទៅដោយការក្បត់សាសនា។ ហើយស្របតាមគ្រោះទីប្រាំមួយនោះ សង្គ្រាមដ៏ធំនឹងកើតឡើង។ [5] ផ្កាយត្រូវបានទម្លាក់ចុះពីលើ

មេឃបានបើករណ្តៅដែលគ្មានបាត (គ្រោះនៃត្រែទីប្រាំ) គឺជានិមិត្តសញ្ញានៃអំពើពុករលួយខាងសាសនាឬការក្បត់សាសនា។ [6] សកម្មភាពសម្លាប់ក្រុមរទេះសេះ (គ្រោះនៃត្រែទីប្រាំមួយ) គឺជាសកម្មភាពសម្លាប់ ពោលគឺយើងមិនអាចជួយបានក្រៅពីនិយាយពីសង្គ្រាម។ គ្រោះកាចទាំងអស់នៅខាងលើ ទាក់ទងនឹងស្ថានភាពនៃថ្ងៃផ្សេងទៀត ជាពិសេសកិច្ចការដែលបានកើតឡើងនៅថ្ងៃចុងក្រោយនៃពិភពលោក។ ជាការត្រឹមត្រូវដែលទាំងនេះគួរតែត្រូវបានបកស្រាយថាជាអត្ថន័យនៃសង្គ្រាម សាសនាខុសឆ្គង ការក្បត់សាសនាម្តងហើយម្តងទៀត និងសេចក្តីវេទនាដ៏អាក្រក់។ អ្វីដែលឃើញនៅពេលអនាគតគឺសង្គ្រាមដ៏ធំ។ សង្គ្រាម សាសនាខុសឆ្គង ការក្បត់សាសនា និងសង្គ្រាមម្តងទៀត! ខ្ញុំគិតថាយើងស្ថិតក្នុងគ្រាដ៏អាក្រក់។

លោក ហ្គ្រេចដានុស ក៏ចង្អុលថា នៅក្នុងការប្រៀបធៀបជាមួយនឹងគ្រោះទូទៅនៅក្នុងជំពូកទី 6 គ្រោះនៃត្រែជាគ្រោះដែលប្លែក។ វាជារឿងដែលជំពូកទី6ត្រូវបានប្រើសម្រាប់បណ្តាញដ៏មានប្រយោជន៍ដើម្បីប្រកាសដំណឹងល្អ ប៉ុន្តែគ្រោះកាចដែលចាប់ផ្តើមពីជំពូកទី 8 គឺជាមធ្យោបាយដែលទ្រង់បញ្ជូនមកដាក់ទណ្ឌកម្មលើពិភពលោក។ (ឃ្លា)

(In hoofdstuk 6 komen die oorlogen, en rampen, en benauwingen, voor in hunne beteekenis voor den loop, en de zege der Evangelies, hoe zij n. m. 1. Dienen als middelen, om voor dat Evangeliie de wegen onder het menschdom te banen, en de harten ontvankelijk te maken. Met gebruik making daarvan wil de Heere het. Evangelie tot zjn volle zege doen komen, over het gansche rond der aarde. In hoofdstuckken 8-10 homen die bazoekingen en verschrikkingen, echter voor als werkingen van Gods torn, waarmede Hij de wereld aangrijpt, en atraft. Vanwege

hare goddeloosheid, in antwoord op het reopen der zijnen tot Hem over die Godverwerping. En gruwelijkheid der wereid. – Openbaring. P. 179)

ការបកស្រាយ

7 ទេវតាទីមួយក៏ផ្លុំត្រែឡើង ត្រែមានន័យថាស៊ីរ៉ែនៃការចាប់ផ្តើមនៃសង្គ្រាម។ នៅទីនេះ ត្រែរបស់ទេវតា ប្រកាសអំពីកំណល់កល់ជើងរបស់ព្រះពិរោធរបស់ព្រះជាម្ចាស់មកដល់ផែនដី (ពិភពធម្មជាតិប្រឆាំងនឹងក្រុមជំនុំ។ ទីក្រុងយេរីខូត្រូវបានបំផ្លាញដោយសំឡេងត្រែបែបនេះ។ នៅចុងបញ្ចប់នៃពិភពលោកនេះផងដែរ ការដាក់ទណ្ឌកម្មនៃស្ថានបរមសុខ។ ដើម្បីឱ្យមានអត្ថន័យបែបនេះនឹងកើតឡើង។ (យោងតាម យេរេមា 4:19)

ព្រិល និងភ្លើង លាយជាមួយឈាម ដូចដែលយើងឃើញនៅ និក្ខមនំ 9:18-26 ការដាក់ទោសដូច្នោះរបស់ស្ថានសួគ៌មកពីអេស៊ីប។ ប៉ុន្តែគ្មានព្រះបន្ទូលនៃសេចក្តីសុចរិតទេ។ “ឈាម” ប្រាប់ថា មនុស្សស្លាប់ និងមនុស្សដែលត្រូវបានធ្វើទុក្ខដោយព្រិលនឹងកើតមាន។ ពាក្យនេះគួរតែមិនត្រូវបានបកស្រាយដោយន័យត្រង់ទេ តែបែបជានិមិត្តសញ្ញានៃសេចក្តីក្រោធវិញ។ “ព្រិលនិងភ្លើង” ជានិមិត្តសញ្ញានៃសេចក្តីក្រោធរបស់ព្រះ។ យោងតាម អេសាយ 28:2-7, 30:30, ទំនុកដំកើង 18:13, អេសេគាល 13:13, 38:22។

ទីបី យោងតាម សាការី 13:8 , 9 អេសេគាល 5:2។ ដូចជាទ្រីស្តីមួយ លេខ 3 ជារបស់ព្រះ។ គ្រោះនេះត្រូវបានបញ្ជូនមកដោយព្រះផ្ទាល់ ជាលទ្ធផលនៃគ្រោះនេះដែឡត្រូវបានបង្ហាញដោយលេខនេះ។ អ្នកប្រាជ្ញផ្សេងទៀតបាននិយាយថា "ទីក្រុងរ៉ូមត្រូវបានបែងចែកទៅជាបីផ្នែកគឺ តំបន់ខាងកើត តំបន់កណ្តាល និងតំបន់ខាងលិច ដោយការលុកលុយរបស់កុលសម្ព័ន្ធហ្គស និងកុលសម្ព័ន្ធវ៉ាន់ដាល់ ពួកគេអះអាងថានៅក្នុងវិវរណៈនៅទីនេះ 1/3 ចង្អុលទៅផ្នែកមួយក្នុងចំណោមតំបន់ទាំងបីនេះ។ ទោះយ៉ាងណាក៏ដោយ លេខនេះត្រូវបានគេប្រើជាអត្ថន័យដើម្បីចង្អុលបង្ហាញថាព្រះដាក់ទណ្ឌកម្ម 1/3 នៃពិភពលោកនេះនៅទីនេះ។

នៃផែនដី ព្រមទាំងដើមឈើភាគក្នុងបីដែរ និងស្មៅទាំងអស់ផង។ តាមទ្រឹស្តីមួយគេនិយាយថា វាចង្អុលទៅលើការខូចខាតដោយសារគ្រោះកាចនៃព្រិលខាងលើ។ ប៉ុន្តែអ្នកប្រាជ្ញមួយបាននិយាយថា ការដែលទាំងនេះរួមបញ្ចូលទាំងនិមិត្តសញ្ញានៃមនុស្សដែលត្រូវបានចូលរួមក្នុងការដាក់ទណ្ឌកម្មពីស្ថានសួគ៌។ នោះគឺ “ទឹកដី” ជាទីអាស្រ័យនៅនៃមនុស្សមានបាប ដើមឈើជាអ្នកដែលមានសិទ្ធិអំណាច (យេរេមា 7:20, 17:8, អេសេគាល 31:3, ដានីយ៉ែល 4:20-22) “ស្មៅខ្ចី” ចង្អុលទៅកាន់មនុស្សទូទៅ (អេសាយ 40:7) យោងទៅតាមទ្រឹស្តីមួយ គ្រោះកាចនៃព្រិលនេះជានិមិត្តរូបនៃសង្គ្រាម ដែលជាការព្យាករណ៍អំពីការប្លន់របស់កុលសម្ព័ន្ធហ្គសនៅឆ្នាំ 395។ ប៉ុន្តែការបកស្រាយត្រឹមត្រូវនៃជំពូកនេះបានមក ចេញពីបុព្វបទនៃជំពូក។

8, 9 នោះមានដូចជាភ្នំយ៉ាងធំកំពុងតែឆេះជាភ្លើង បានបោះទំលាក់នៅក្នុងសមុទ្រ រួចសមុទ្រមួយភាគក្នុងបីក៏ត្រឡប់ទៅជាឈាម។ ក្នុងឃ្លានោះ យើងគួរតែប្រយ័ត្ននឹងពាក្យ “ដូចជាអ្វីមួយ”។ យើងមិនបដិសេធទេថារឿងនេះនឹងកើតឡើងពិត។ ប៉ុន្តែចំណុចសំខាន់នៃវិវរណៈនេះរួមបញ្ចូលឃ្លាបែបជានិមិត្តរូបនៃឃ្លានេះ ។ នៅឆ្នាំ 1570 នៅសមុទ្រ អាហ្គាន រួមមានកោះ ប៉ាត់ម៉ុស ដែលជាភ្នំភ្លើងដ៏អស្ចារ្យត្រូវបានផ្ទុះឡើង

ទឹកសមុទ្រត្រូវបានផ្លាស់ប្តូរពណ៌ដីទៅដូចជាឈាមប្រហែល 20 ម៉ាយ។ ហើយត្រូវបានប្រាប់មកថា គ.ស 1707 ថ្មនៅក្នុងសមុទ្រត្រូវបានលើកឡើង ដោយសារតែទឹកមានជាតិពុល ត្រីទាំងអស់នៅក្នុងឈូងសមុទ្រត្រូវបានស្លាប់។ (ម៊ិហ្វាត) យើងមិនជឿថា សម្លេងធម្មជាតិបែបនេះមិនមែនជាគោលបំណងនៃទំនាយនេះទេ។ "ភ្នំធំមួយឆេះ" មានន័យថា ផ្ទុយទៅវិញ វាចង្អុលទៅនគរដែលត្រូវបានដាក់ទោសមកពីស្ថានសួគ៌។ នៅសម័យបុរាណ វាគឺជាបាប៊ីឡូន។ (យេរេមា 51:25) "សមុទ្រ" ជានិមិត្តសញ្ញារបស់គ្រប់ជាតិសាសន៍។ (17:15)

ភ្លាយជាឈាម "ឈាម" ជានិមិត្តសញ្ញានៃសេចក្តីស្លាប់។ វាជាគ្រោះដែលព្រះទ្រង់ដាក់ទោសដល់ប្រទេសអេស៊ីប ជានគរដែលទាស់នឹងព្រះគ្រីស្ទ។ ដូច្នេះនេះ

ហើយអស់ទាំងសត្វនៅក្នុងសមុទ្រ ដែលមានជីវិតរស់ ក៏ស្លាប់អស់ 1ភាគក្នុង3 ហើយអស់ទាំងនាវា ក៏ត្រូវបំផ្លាញ។ នេះចង្អុលទៅកាន់ទ្រព្យសម្បត្តិនៅក្នុងគ្រប់ជាតិសាសន៍ទាំងអស់។ នៅពេលមនុស្សនៅក្នុងគ្រប់ជាតិសាសន៍ត្រូវបានទទួលការដាក់ទោសពីព្រះ ដូចនោះគ្រប់ភាវៈទាំងអស់ត្រូវបានទទួលវា។ យោងតាម សេផានា 1:3 យ៉ូហាន 4:11។

យោងតាមទ្រឹស្តី "ដូចជាភ្នំយ៉ាងធំ កំពុងតែឆេះជាភ្លើង" ចង្អុលទៅកាន់ក្រុងរ៉ូមដែលត្រូវបានធ្លាក់ចុះក្នុងសេចក្តីវិនាសដោយការវាយលុករបស់ពូជអំបូរហ៊ុន។ តែទំនាយនេះមិនត្រូវបានសម្រេចដោយហេតុការណ៍នៃសេចក្តីវិនាសរបស់ក្រុងរ៉ូមឡើយ។ ពីព្រោះនៅពេលថ្មីៗនិងសម័យថ្មីនេះ ប្រទេសនានានៃអ្នកប្រឆាំងនឹងព្រះគ្រីស្ទត្រូវបានបំផ្លាញ យើងគួររក្សាទុកក្នុងចិត្ត និងគិតពីវាផង។

មួយភាគក្នុងបី យោងតាមការបកស្រាយខ 7 ខាងលើ។

10 នោះមានផ្កាយមួយយ៉ាងធំធ្លាក់ចុះពីលើមេឃ ទាំងឆេះដូចជាចន្លុះ នេះគឺជានិមិត្តរូបនៃការប្រព្រឹត្តអំពើពុករលួយរបស់គ្រូគង្វាល ត្បិតគេបានលាយព្រះបន្ទូលរបស់ព្រះ (2 កូរិនថូស 5:17) ពួកគេបានសម្លាប់ព្រលឹងជាច្រើន។ សូមមើលបុព្វកថានៃការបកស្រាយជំពូកនេះ។ ឬអ្នកខ្លះបាននិយាយថានេះគឺជា អារៀស ជាគ្រូខុសឆ្គងឬ ផេឡាជៀស។ ប៉ុន្តែនេះចង្អុលទៅការខុសឆ្គងទាំងអស់ដែលបានកើតឡើងនៅក្នុងប្រវត្តិសាស្ត្រ ក្នុងពេលជាមួយគ្នានោះវាចង្អុលបង្ហាញពីសាសនាខុសឆ្គងបានកើតឡើងនៅថ្ងៃចុងក្រោយក្នុងពិភពលោក។ នៅគ្រានៃការយាងមកជាលើកទីពីររបស់ព្រះអម្ចាស់ដែលទ្រង់នឹងយាងមកជិតមកដល់ នោះមានការក្បត់សាសនាដ៏អស្ចារ្យនៅលើផែនដី។ (2ថែស្សាឡូនិក 2:3-7) ដ្បិតព្រឹត្តិការណ៍នេះ ជាដំបូងបង្អស់ ជាការបង្រៀនខុសឆ្គងដែលនឹងត្រូវកើនឡើង។

11 ផ្កាយនោះឈ្មោះថា "ស្លែង"។ "ឬសនៃភាពល្ងិញ" នៅក្នុង ហេព្រើរ 12:15 ចង្អុលទៅកាន់ហោរាក្លែងក្លាយ។ ដូច្នេះនៅទីនេះ "ស្លែង" បង្ហាញយ៉ាងច្បាស់ថា ផ្កាយដែលធ្លាក់ចុះនេះជានិមិត្តរូបនៃហោរាក្លែងក្លាយ។

ហើយទឹកមួយភាគក្នុងបីបានត្រឡប់ទៅជាពុល មានមនុស្សជាច្រើនស្លាប់ដោយសារទឹកនោះ ដ្បិតបានត្រឡប់ទៅជាល្ងិញអស់ហើយ។ ហោរាពិតប្រាកដ គឺម៉ូសេដែលបានប្តូរទឹកដែលល្ងិញទៅជាទឹកដែលផ្អែម ដែលផ្ទុយពីហោរាក្លែងក្លាយដែលបានប្តូរទឹកទៅជាល្ងិញ។ ទឹកជានិមិត្តសញ្ញានៃដំណឹងល្អដែលធ្វើឱ្យព្រលឹងរស់ឡើង (ចៅហ្វាយ 1:12 យ៉ូហាន 7:8, វិវរណៈ 22:17)។ ការដែលធ្វើឱ្យទៅជាល្ងិញមានន័យថាធ្វើបំភាន់ព្រះបន្ទូលរបស់ព្រះ។ ដូចដែលព្រះបន្ទូលរបស់ព្រះគួរតែត្រូវបានប្រកាស នោះអ្នកដែលទទួលនឹងទទួលបានជីវិតអស់កល្បជានិច្ច។ តែកាលដែលវាត្រូវបានប្តូរទៅជាអ្វីផ្សេងដោយលាយជាមួយនឹងពាក្យអ្វីផ្សេង នោះឥទ្ធិពលនឹងត្រូវបានបាត់បង់។

12 ការពិតដែលព្រះអាទិត្យ ព្រះច័ន្ទ និង 1/3 នៃផ្កាយនៅក្នុងខគ្រូវបាត់ពន្លឺនឹង មានពិតមែន (និក្ខមនំ 10:21, 22) ហើយវាក៏មានអត្ថន័យជានិមិត្តសញ្ញាផងដែរ។ អេសាយ 13:10 បានទាយពីព្រឹត្តិការណ៍នៃបាប៊ីឡូនដែលត្រូវបំផ្លាញដោយ សាសន៍មីដេ ជានិមិត្តសញ្ញាដែលព្រះអាទិត្យ ព្រះច័ន្ទ និងផ្កាយត្រូវបាត់ពន្លឺ។

13 ទៅតាមួយ នេះជានិមិត្តសញ្ញានៃការវិនិច្ឆ័យរបស់ព្រះ។ សូមពិនិត្យមើលនៅ ចោទិយកថា 28:49, ហូសេ 8:1 ហេព្រើរ 1:8 យេរេមា 48:40, អេសេគាល 17:3 ម៉ាថាយ 24:28។

ចំណុចសំខាន់

ពាក្យជំពូកទី 8 បង្ហាញថា គ្រោះកាចដែលនឹងកើតឡើងក្នុងមនុស្សលោកនឹងកើនច្រើននៅពេលអនាគតជាងបច្ចុប្បន្នយ៉ាង។ តើជាគ្រោះកាចសាហាវខ្លាំងប៉ុណ្ណាទៅដែលនឹងបំផ្លាញមនុស្សកាន់តែច្រើននោះ! ព្រះគម្ពីរបង្រៀនថា គ្រោះកាចនឹងកាន់តែខ្លាំងឡើង នៅពេលនៃគ្រាចុងក្រោយនៃពិភពលោកដែលខិតជិតមកដល់នេះ។ (8:13, 15:1) ដូច្នេះ យើងគួរតែយល់សប្តិពីអនាគត និងដាក់សេចក្តីសង្ឃឹមរបស់យើងនៅក្នុងស្ថានសួគ៌ និងគួរតែពង្រឹងសេចក្តីជំនឿរបស់យើងថែមទៀត។

ការអធិប្បាយ 31 ការអធិស្ឋានដែលអាចនឹងលើកឡើងទៅកាន់ព្រះ (ការអធិស្ឋានដែលព្រះទ្រង់ឆ្លើយតប) (វិវរណៈ 8:1-5)

ទោះជាពួកបរិសុទ្ធត្រូវគេបៀតបៀននៅលើផែនដី វិធីសាស្ត្រនៃការនោះគឺដើម្បីនឹងឱ្យពួកគេផ្តោតលើការអធិស្ឋាន។ ទំនុកដំកើង 109:4 មានបន្ទូលថា “ទូលបង្គំស្រឡាញ់ពួកគេ ប៉ុន្តែ ពួកគេបែរជាចោទប្រកាន់ទូលបង្គំទូលបង្គំបានអធិស្ឋានអោយពួកគេ”។

វិវរណៈ 8:4 មានបន្ទូលថា ការអធិស្ឋានរបស់ពួកបរិសុទ្ធត្រូវបានលើកឡើងដូចជាផ្សែងគ្រឿងក្រអូប។

(1) យ៉ាកុប 4:3 មានបន្ទូលថា “បងប្អូនទូលសូមដែរ តែឥតបានទទួល ព្រោះបងប្អូនទូលសូមដោយបំណងអាក្រក់ គឺបងប្អូនចង់បានសម្រាប់តែបំពេញចិត្តស្រើបស្រាលរបស់ខ្លួនប៉ុណ្ណោះ”។ មានតែការអធិស្ឋានដែលយើងបោះចោលនូវភាពអត្មានិយមរបស់យើង និងដើម្បីថ្វាយសិរីល្អដល់ព្រះទេដែលនឹងត្រូវបានលើកថ្វាយដល់ព្រះ។

(2) អេសាយ 59:1,2 មានបន្ទូលថា “កុំនឹកស្មានថា ព្រះអម្ចាស់មានបារមីទន់ខ្សោយ ពុំអាចសង្គ្រោះអ្នករាល់គ្នាបាននោះឡើយ ហើយកុំនឹកស្មានថា ព្រះអង្គមានព្រះការណ៍ធ្ងន់មិនឮនោះដែរ! តាមពិតគឺអំពើអាក្រក់របស់អ្នករាល់គ្នាទេតើដែលខណ្ឌអ្នករាល់គ្នាពីព្រះរបស់អ្នករាល់គ្នា អំពើបាបរបស់អ្នករាល់គ្នាធ្វើឱ្យព្រះអង្គលាក់ព្រះភក្ត្រមិនព្រមស្តាប់ឮពាក្យរបស់អ្នករាល់គ្នា”។ នៅពេលយើងអធិស្ឋានដោយការលន់តួបាបរបស់យើង ការអធិស្ឋាននឹងត្រូវបានលើកឡើង។ ថូរី បានអធិស្ឋានចង់បានថវិការដែលចាំបាច់នៅក្នុងបរិមាណមួយ តែគាត់មិនបានទទួលចម្លើយពីព្រះទេ។ តែគាត់បានចងចាំពីអេសាយ 59:1, 2 ហើយបានលន់តួបាបដោយការទួញសោកនិងបានទូលសូមដល់ព្រះ នោះគាត់ក៏ទទួលបានសេចក្តីសុខសាន្តយ៉ាងប្លែកនៅក្នុងចិត្តរបស់គាត់។ ថ្ងៃបន្ទាប់ សុខៗគាត់បានទទួលនូវការផ្សាយដំណឹងល្អមួយ។

(3) អេសេគាល 14:3 មានបន្ទូលថា “កូនមនុស្សអើយ អ្នកទាំងនោះជំពាក់ចិត្តនឹងព្រះក្លែងក្លាយ ហើយនឹងនាំគ្នាគោរពអ្វីៗដែលនាំឱ្យខ្លួនប្រព្រឹត្តអំពើបាប។ តើពួកគេនឹកស្មានថា យើងនឹងផ្តល់ចម្លើយអោយឬ?” កាលដែលយើងមានរូបព្រះក្លែងក្លាយនៅក្នុងចិត្តរបស់យើង នោះយើងមិនអាចទទួលបានការឆ្លើយតបដល់ការអធិស្ឋាន

របស់យើងទេ។ ប្រសិនបើយើងទុកការអ្វីផ្សេងនៅក្នុងចិត្តដែលយើងគួរតែមានតែព្រះទែមួយនោះ ហើយប្រសិនបើយើងស្រឡាញ់ការនោះជាងព្រះ នោះវាជារូបព្រះក្លែងក្លាយហើយ។ កាលដែលយើងបំផ្លាញរូបព្រះក្លែងក្លាយពីចិត្តយើង ហើយយើងអធិស្ឋានទៅកាន់ព្រះ នោះការអធិស្ឋាននឹងត្រូវបានលើកឡើងទៅកាន់ព្រះ។

(4) សុភាសិត 21:13 មានបន្ទូលថា "អ្នកណាធ្វើជាថ្លង់ មិនឮសម្រែករបស់មនុស្សទុរគ៌ត លុះពេលមានអាសន្នស្រែកហៅគេជួយនឹងគ្មាននរណាអើពើឡើយ។" ប្រសិនបើយើងទទួលបានការឆ្លើយតបនៃការអធិស្ឋាន យើងគួរផ្តល់សេចក្តីមេត្តាដល់អ្នកផ្សេង និងផ្តល់ការអាណិតអាសូរដល់ពួកគេផង។

(5) ម៉ាកុស 11:25 មានបន្ទូលថា "ម្យ៉ាងទៀតពេលឈរអធិស្ឋាន បើអ្នករាល់គ្នាមានទំនាស់អ្វីនឹងនរណាម្នាក់ ចូរអត់ទោសអោយគេទៅ ដើម្បីព្រះបិតារបស់អ្នករាល់គ្នា ដែលគង់នៅស្ថានបរមសុខអត់ទោសអោយអ្នករាល់គ្នា"។ កាលដែលយើងអត់ទោសអ្នកផ្សេង យើងអាចទទួលបានចម្លើយដល់ការអធិស្ឋានរបស់យើង។

(6) 1 ពេត្រុស 3:7 មានបន្ទូលថា "រីឯបងប្អូនដែលជាស្វាមីក៏ដូច្នោះដែរ ម្នាក់ៗត្រូវរួមរស់ជាមួយភរិយារបស់ខ្លួន ដោយយល់ថា ស្ត្រីៗជាមនុស្សទន់ខ្សោយជាងខ្លួន។ ត្រូវគោរពនាង ទុកដូចជាអ្នកត្រូវរួមទទួលជីវិត ដែលព្រះជាម្ចាស់ប្រោសប្រណីប្រទានមកបងប្អូនជាមត៌ក ដើម្បីកុំអោយមានអ្វីមកការាំងការអធិស្ឋានរបស់បងប្អូនឡើយ។" ដើម្បីទទួលចម្លើយនៃការអធិស្ឋាន យើងគួរតែអធិស្ឋានដោយឥតមានការសង្ស័យ។ លោក George Muller មុនពេលអធិស្ឋាន គាត់អានព្រះគម្ពីរ និងសម្អាតចិត្តរបស់គាត់ ហើយអធិស្ឋានដោយជំនឿ គាត់ក៏ទទួលបានចម្លើយយ៉ាងច្រើន។

ការអធិប្បាយទី **32** ការអធិស្ឋានដែលត្រូវបានថ្វាយទៅចំពោះព្រះ (វិវរណៈ **8:3-5)**

1. ការអធិស្ឋានដែលត្រូវបានលើកទៅចំពោះព្រះត្រូវបានរួមគ្នាជាមួយនឹងគ្រឿងក្រអូប។ ក្លិនក្រអូបជាក្លិននៃការស្គាល់ព្រះគ្រីស្ទ (2 កូរិនថូស 2:14-16)។ ការអធិស្ឋានត្រូវបានលើកឡើងនៅក្នុងព្រះនាមរបស់ព្រះគ្រីស្ទ។ នៅក្នុងព្រះនាមព្រះគ្រីស្ទ មានន័យថា ការអធិស្ឋានដែលទុកចិត្តដល់កិច្ចការរបស់ទ្រង់សម្រាប់បំណងព្រះហឫទ័យទ្រង់។ យ៉ូហាន 14:14 មានបន្ទូលថា “បើអ្នករាល់គ្នាសូមអ្វីក្នុងនាមខ្ញុំ ខ្ញុំនឹងធ្វើកិច្ចការនោះ”។ ការអធិស្ឋានដូចនេះត្រូវបានហាមដល់ការលោភលន់ផ្ទាល់ខ្លួន។ ការអធិស្ឋានដូចនេះគឺ “ការអធិស្ឋានរបស់ពួកបរិសុទ្ធ”។ ដែលវាមានន័យថា វាជាអ្វីដែលពួកបរិសុទ្ធអធិស្ឋានជាទូទៅ។ យើងមិនគួរអធិស្ឋានសម្រាប់សេចក្តីប៉ងប្រាថ្នាផ្ទាល់ខ្លួនរបស់យើងឡើយ។ បុរសនៃការអធិស្ឋានគួរតែអធិស្ឋានសម្រាប់មិនត្រឹមតែគ្រួសាររបស់គាត់តែសម្រាប់អាណាចក្ររបស់ព្រះ។ លោក George Muller បាននិយាយថា ការអធិស្ឋានដែលទទួលបានចម្លើយរាប់សិបពាន់គួរតែមានលក្ខណៈដូចតទៅនេះ៖ (1) គាត់គួរតែអធិស្ឋានដោយផ្អែកលើកិច្ចការរបស់ព្រះគ្រីស្ទបានធ្វើ (2)

ត្រូវចាកចេញពីអំពើបាបដែលបង្ហាញមក។ ទំនុកដំកើង 66:18 មានបន្ទូលថា “ប្រសិនបើខ្ញុំមានគំនិតទុច្ចរិត ព្រះអម្ចាស់មុខជាមិនស្តាប់ខ្ញុំឡើយ”។ (3) ត្រូវជឿលើសេចក្តីសន្យារបស់ព្រះ (ហេព្រើរ 6:13-20, 11:6) (4) ត្រូវស្វែងរកបំណងព្រះហឫទ័យរបស់ព្រះ (1 យ៉ូហាន 5:13 យ៉ាកុប 4:3) (5) ត្រូវខិតខំស្វែងរក (យ៉ាកុប 5:7 លូកា 18:1-10) ។ល។ អ្នកដែលអធិស្ឋានដោយពឹងផ្អែកលើកិច្ចការដែលព្រះគ្រីស្ទបានធ្វើ នោះគេបានរក្សានូវគោលការណ៍នៃបទគម្ពីរហើយ។ ការអធិស្ឋានដូច្នេះជាការអធិស្ឋានដោយមានក្លិនក្រអូប។

2. ការដែលយើងទទួលស្គាល់ថាការអធិស្ឋានវាសំខាន់ និងបានធ្វើការលះបង់សម្រាប់វា នោះការអធិស្ឋាននឹងត្រូវបានលើកទៅកាន់ព្រះ។ នៅពេលដែលទុក្ខវេទនាចុងក្រោយមកដល់យើង មុនពេលដែលការសង្គ្រោះរបស់យើងនឹងត្រូវបានបញ្ចប់ អ្វីដែលយើងគួរធ្វើគឺការអធិស្ឋាន។ មុនគ្រាទុក្ខវេទនាជាខ្លាំង អត្ថបទនិយាយតែពីការអធិស្ឋាន ដោយមិននិយាយអំពីអ្វីផ្សេងទៀតនោះទេ។ (3-5) ការអធិស្ឋានមានសារៈសំខាន់ដែលវាគួរតែត្រូវបានលើកឡើង។ មុនពេលមានទុក្ខវេទនាជាខ្លាំងសម្រាប់ការញែកជាបរិសុទ្ធរបស់យើង យើងគួរអធិស្ឋាន។ ក្លិនក្រអូបដែលបំបាត់ក្លិនមិនល្អ។ នៅពេលដែលយើងមិនអធិស្ឋានដោយក្លែងក្លាយ ហើយអធិស្ឋានពិតប្រាកដដោយព្រះនាមនៃព្រះគ្រីស្ទ ("គ្រឿងក្រអូប") អំពើអាក្រក់នៅក្នុងយើងក៏ត្រូវបានកាត់បន្ថយផងដែរ។ នៅពេលមនុស្សអធិស្ឋានច្រើនគាត់បានក្លាយជាបរិសុទ្ធ។ ព្រះយេស៊ូក៏បានលះបង់អង្គទ្រង់ដើម្បីអធិស្ឋាន។ (1) ទ្រង់បានចាត់ទុកការអធិស្ឋានសំខាន់ជាងមនុស្សច្រើន។ លូកា 6:12 មានបន្ទូលថា “នៅគ្រានោះ ព្រះយេស៊ូយាងឡើងទៅលើភ្នំដើម្បីអធិស្ឋាន។ ព្រះអង្គអធិស្ឋានពេញមួយយប់” (3) ទ្រង់មានបន្ទូលថា ការអធិស្ឋានអាចយកឈ្នះលើការអាក្រ

ក់។ ម៉ាថាយ 26:41 មានបន្ទូលថា “ចូរប្រុងស្មារតី ហើយអធិស្ឋាន*កុំអោយចាញ់ការល្បួងឡើយ។ វិញ្ញាណរបស់មនុស្សប្រុងប្រៀបជាស្រេចមែន តែគេនៅទន់ខ្សោយ ព្រោះនិស្ស័យលោកីយ៍” (4) ទ្រង់បានអធិស្ឋានយ៉ាងអស់ពីចិត្ត។ ម៉ាថាយ 26:39 មានបន្ទូលថា “ព្រះអង្គយាងទៅមុខបន្តិច ក្រាបព្រះភក្ត្រដល់ដីទូលអង្វរថា ៖ «ឱព្រះបិតាអើយ! ប្រសិនបើបាន សូមអោយពែងនៃទុក្ខលំបាកនេះ ចេញឆ្ងាយពីទូលបង្គំទៅ ប៉ុន្តែ សូមកុំធ្វើតាមបំណងទូលបង្គំឡើយ គឺសូមអោយបានសំរេចតាមព្រះហឫទ័យរបស់ព្រះអង្គវិញ”។ យ៉ូមបាននិយាយថា “ប្រសិនបើខ្ញុំមានទុក្ខដូចលោកវិញ ខ្ញុំនឹងស្រែកអង្វរព្រះជាម្ចាស់ ខ្ញុំលើកយករឿងហេតុរបស់ខ្ញុំមកទូលថ្វាយព្រះអង្គ” (យ៉ូប 5:8) ពីព្រោះការអធិស្ឋានគួរតែត្រូវបានលើកឡើងទៅកាន់ព្រះ អ្នកដែលអធិស្ឋានមិនគួរឈប់នោះឡើយ តែត្រូវបន្តវិញ។ បើទោះជាការអធិស្ឋានហាក់ដូចជាមិនទទួលបានចម្លើយក៏ដោយ តែវាប្រាកដណាស់ថានឹងទទួលបានចម្លើយ។ លោក Gorge Muller មិនមានការរអាក់រអួលនៅក្នុងចិត្តឡើយ បើទោះជាការអធិស្ឋានរបស់គាត់មិនត្រូវបានឆ្លើយតបក៏ដោយ។ គាត់បាននិយាយពីហេតុផលដើម្បីនឹងប្រាប់ពីចម្លើយនៃការអធិស្ឋានដូចតទៅនេះថា (1) វាមិនមែនជាពេលរបស់ព្រះ (2) ពីព្រោះការឆ្លើយតបយឺតនឹងធ្វើឱ្យពួកបរិសុទ្ធអធិស្ឋានថែមទៀត វាជាប្រយោជន៍ដល់ជំនឿរបស់គេឱ្យបានធំធាត់ឡើងថែមទៀត។ លោក Muller បានចុះចូលនឹងផ្នែកព័ន្ធកិច្ចដើម្បីក្លាយជាបេសកជនបរទេសបានប្រាំដង ការបង់ថ្លៃរបស់គាត់ប្រាំដងមិនត្រូវបានទទួល តែបន្ទាប់ពីគាត់បានធ្វើការព័ន្ធកិច្ចក្មេងកំព្រាអស់រយៈពេល 40ឆ្នាំ នោះគាត់បានទៅប្រទេសផ្សេងទៀតធ្វើជាបេសកជន ហើយវាជាការដែលកាត់បានធ្វើបន្ទាប់ពីគាត់មានអាយុ 70ឆ្នាំហើយ។

បើទោះជាការអធិស្ឋានរបស់គាត់យឺតក៏ដោយ តែចុងក្រោយវានៅតែបានសម្រេច។

ជំពូកទី 9

អត្ថបទជាព្រះបន្ទូលដែលកាលដែលត្រែត្រូវបានបន្លឺឡើង។ គ្រោះនោះបានធ្លាក់ចុះមក ហើយបន្តនៅជំពូកខាងលើ។

1. គ្រោះនៃត្រែជាការលេចមកនូវភ្នាក់ងារនៃអារក្ស ដែលធ្វើឱ្យពន្លឺនៅក្នុងលោកិយទៅជាងងឹត។ (1-11) រួចមកអ្នកជឿដែលមានពុត ដែលមិនត្រូវបានជ្រើសរើសនឹងក្បត់សាសនា ក្រៅពីវា នោះមនសិកា និងសីលធម៌នៃមនុស្សជាច្រើនដែលនឹងត្រូវខូចផង។ (2ថែស្សាឡូនិក 2:3-7)
2. គ្រោះនៃត្រែទីប្រាំមួយហាក់ដូចជាសញ្ញាសម្គាល់នៃសង្គ្រាមយ៉ាងធំ។ (12-21) បន្ទាប់ពីសង្គ្រាម គ្មានសេចក្តីសុខសាន្តនៅលើផែនដីឡើយ។ (20, 21) អ្នកដែលប្រឆាំងនឹងព្រះគ្រីស្ទចុងក្រោយបំផុតនឹងត្រូវបានបង្ហាញមក។ ជំពូក 9 ជំពូក 13) បន្ទាប់ពីអ្នកដែលប្រឆាំងនឹងព្រះគ្រីស្ទធ្វើឱ្យលោកិយច្របូកច្របល់ នោះការយាងមកជាលើកទីពីររបស់ព្រះគ្រីស្ទនឹងមកដល់ (វិវរណៈ 19:11-21)។

ការបកស្រាយ

1 ផ្កាយមកធ្លាក់ចុះពីលើមេឃមកលើផែនដី នេះជានិមិត្តសញ្ញានៃទេវតាដែលអាក្រក់ដែលជាអារក្ស ឬជានិមិត្តសញ្ញារបស់ទេវតារបស់អារក្ស (អ្នកដែលធ្វើការឱ្យអារក្សក្នុង

នាមជាមនុស្ស)។ (យោងតាម លូកា 10:18)។ កាលដែលយើងឃើញពាក្យថា “ត្រូវ បានធ្លាក់ពីស្ថានសួគ៌” គេជាវត្តមានដែលខូចបង់ពិតប្រាកដណាស់។ លោក ហ្គ្រេច ដានុស បាននិយាយថា “ នេះចង្អុលទៅកាន់សាតាំង និងការពិតនៃសេចក្តីពុករលួយ របស់គេ ហើយនឹងអំណាចរបស់គេនៅក្នុងពិភពងងឹត។” (daarom kan hier ook van Satan en jijn zondeval, gesproken worden, en van Zijne heerschappij in het rijk der duisternis, na dien val. – Openbaring. ទំព័រ 195)។ ការបកស្រាយរបស់លោក ហ្គ្រេចដានុស មិនចង្អុលទៅកាន់ការពុករលួយ របស់សាតាំងដែលនឹងកើតឡើងនៅមុនការយាងមកលើទីពីររបស់ព្រះគ្រីស្ទទេ តែ ចង្អុលទៅកាន់សេចក្តីពុករលួយដើមវិញ។ លោក ស្តត ចង្អុលទៅ មហាម័ត និង ចលនារបស់គាត់ដែលបានកើតឡើងនៅក្នុងគ្រាដើមនៃស.វ ទីប្រាំពីរនៃគ.ស។ ប៉ុន្តែ ចលនារបស់សាតាំងខនេះចង្អុលជាការពិត ដែលថាវានឹងកើតឡើងនៅគ្រាចុងក្រោយ នៃជីវិតរបស់មនុស្សនៅក្នុងលោកិយនេះ។ លោក អាប្រាហាំ ខាយភើ ក៏បាននិយាយ ពីវានៅក្នុងន័យដូចគ្នា (វិវរណៈរបស់យ៉ូហាន ទំព័រ 99)

មានគេឱ្យក្អូនសោទីជំរៅនៃជង្ហុកធំដល់ផ្កាយនោះ។ ព្រះទ្រង់ប្រើអារក្ស។ បើទោះជា អារក្សធ្វើការក៏ដោយ តែវាធ្វើការនៅក្រោមការអនុញ្ញាតរបស់ព្រះ ហើយការនោះនឹង បង្ហាញពីសិរីល្អរបស់ព្រះ វាគ្រាន់តែត្រូវបានប្រើជាឧបករណ៍ប៉ុណ្ណោះ។ ដូច្នេះ លោក ស្តត បាននិយាយថា “យើងមិនអាចធ្វើអ្វីបានក្រៅពីរីករាយដោយសារព្រះរបស់យើង ទ្រង់ដោតច្រមុះរបស់អារក្ស និងប្រមូល និងចាប់គ្រប់ទាំងសត្វដែលក្រអឺតក្រទម (អារក្ស)”។ (យើងអាចនឹងមានអំណរដែលព្រះអម្ចាស់មានសៀវភៅមួយនៅក្នុងច្រ មុ[illegible]ះ និងឃ្លុះបបូរមាត់នៃគ្រប់សត្វដែលអួតទាំងអស់)។

2 រួចមានផ្សែងហុយឡើងពីទីនោះ ដូចជាផ្សែងពីគុកភ្លើងយ៉ាងធំ។ នេះជាផ្សែងដែលធ្វើឱ្យពន្លឺព្រះអាទិត្យ និងខ្យល់ទៅជាងងឹត ហើយក៏ជាផ្សែងដែលហ្វូងកណ្តូបចាក់ចេញមកដែរ។ ការធ្វើឱ្យពន្លឺព្រះអាទិត្យនិងខ្យល់ទៅជាខ្មៅមានន័យថា ជាការពង្រាយគំនិតដែលទុច្ចរិតនៅក្នុងលោកិយ ហើយបំភាន់នូវសេចក្តីពិត។ ហ្វូងកណ្តូបជានិមិត្តរូបនៃក្រុមដែលមានគំនិតអាក្រក់ ហើយបំផ្លាញព្រលឹងនៃអស់អ្នកដែលមិនជឿ ហើយក៏ជានិមិត្តរូបនៃហ្វូងរបស់ហោរក្លែងក្លាយ។ លោក អាប្រាហាំ ខាយភើ បានសង្កត់ធ្ងន់ទីនេះថា វាដូចគ្នា ពីព្រោះ ហ្វូងកណ្តូបចង្អុលទៅកាន់និមិត្តសញ្ញានៃក្រុមដែលនៅក្នុងគម្ពីរសញ្ញាចាស់។ ពួកគេបានធ្វើបាបដល់មនុស្សដោយកន្ទុយរបស់ពួកគេ ជំពូក 9 ខ 10)។ ពួកគេធ្វើបាបមនុស្សដោយសេចក្តីមិនពិតដូចជាហោរក្លែងក្លាយ (អេសាយ 9:15)។

ហើយព្រះអាទិត្យ និងអាកាសក៏ងងឹតដោយព្រោះផ្សែងដែលហុយពីទីនោះមក។ លោក ហ្គ្រេចជានុស បាននិយាយថ “ព្រះអាទិត្យ និងខ្យល់” ជានិមិត្តរូបនៃដំណឹងល្អដែលព្រះទ្រង់បង្ហាញ ឬជាសេចក្តីពិត។ រួចមក កាលដែលគ្រាចុងក្រោយរបស់លោកិយជិតមកដល់ ចលនាក្នុងការពង្រាយគំនិតទុច្ចរិតក៏បានកើតឡើងជាមួយនឹងពួកទាហានយ៉ាងអាក្រក់ ហើយធ្វើឱ្យដំណឹងល្អនៃក្រុមជំនុំរបស់ព្រះបានទៅជាមិនច្បាស់។

3 បានទទួលអំណាច ដូចជាអំណាចខ្យាដំរីដែលនៅផែនដី។ “ខ្យាដំរីជានិមិត្តរូបនៃអំណាចទុច្ចរិត។ កាលដែលវាទិចមនុស្ស នោះវានឹងមិនត្រូវបានលេបទៅឡើយ តែប្រមាណ 3 ថ្ងៃវានឹងមានអារម្មណ៍ឈឺចាប់ក្តៅ។ វាជាសត្វដែលមានពិសដែលត្រូវបានប្រើសម្រាប់ជាការប្រៀនប្រដៅដល់មនុស្ស។ (1ពង្សាវតារក្សត្រ 12:11, 14, អេសេគាល 2:6 លូកា 10:19)។

4 ពួកគេត្រូវបានប្រាប់មកថាមិនឱ្យបង្ខូចដល់ស្មៅនៅផែនដី ឬរុក្ខជាតិបៃតង ឬដើមឈើណាឡើយ តែដល់តែមនុស្សទាំងនោះដែលមិនមែនត្រារបស់ព្រះនៅនឹងថ្ងាស

របស់ពួកគេប៉ុណ្ណោះ។ យោងតាមទ្រឹស្តីមួយ យ៉ាស្ពេត ដែលជាមនុស្សដែលជារបស់ទំពរបស់មហាម័ត គាត់បានបញ្ជាថា ពួកគេមិនគួរធ្វើប៉ះពាល់ដល់ដើមឈើ ស្មៅ និងរុក្ខជាតិនៅក្នុងអំឡុងពេលនៃការធ្វើធម្មយាត្រាឡើយ។ ហើយទីកន្លែងដែលពួកគេបានលុកលុយនោះកាលនោះជាកន្លែងដែលគ្រីស្ទានត្រូវបានទៅជាពុករលួយ។ (ជាអ្នកដែលមិនមានត្រានៅលើថ្ងាស) (ថូម៉ាស់ ស្កត) គ្រោះនៃត្រែទីប្រាំនេះចង្អុលទៅកាន់ការលុកលុយរបស់កងទំពរបស់មហាម័តដោយពឹងផ្អែកលើព្រះនេះ។ អាប្រាហាំ ខាយកើ

5 ដែលវាបានទទួលអំណាចនោះគឺឱ្យបានគ្រាន់តែធ្វើទុក្ខក្នុងរវាងប្រាំខែវិញប៉ុណ្ណោះ។

នៅទីនេះ ប្រាំខែគឺ 150 ថ្ងៃ អ្នកប្រាជ្ញថាចំនួនថ្ងៃនៃវិវរណៈត្រូវបានរាប់ជានិមិត្តសញ្ញានៃឆ្នាំ បាននិយាយថាជាអំឡុងពេល 150 ឆ្នាំវិញ។ លោក ស្កត បាននិយាយថាចំនួននៃឆ្នាំនេះដែលមហាម័តបានធ្វើការលុកលុយ។ មហាម័តបានកើតនៅក្នុងឆ្នាំ 612 ចលនានោះបានមកដល់នៅក្នុងកម្រិតចុងក្រោយបន្ទាប់ពី 150 ឆ្នាំ ហើយបានចាប់ផ្តើមធ្លាក់ចុះនៅក្នុងកម្រិតទាប។ ប៉ុន្តែវាពិបាកដែលគិតថាការរាប់ឆ្នាំឱ្យបានជាក់លាក់នោះ។ តើចលនារបស់មហាម័យបានចម្រុងចម្រើនត្រឹមតែ 150 ឆ្នាំមែនទេ? ឬបើទោះ មួយចំនួននៃចលនានេះត្រូវបានសម្រេចនៅក្នុងចលនានៃការលុកលុយរបស់មហាម័ត។ វាជាការសម្រេចនៃផ្នែកខ្លះដែលមិនទាន់បញ្ចប់នៅឡើយ។ ការសម្រេចចុងក្រោយនៃចលនានេះនឹងបានជាចលនានៃការក្បត់សាសនា។

នៅទីនេះ ពាក្យថា “រយៈពេលប្រាំខែ” ត្រូវបាននិយាយនៅក្នុងការរក្សាក្នុងគំនិតពីអំឡុងពេលដែលកណ្តូបបានរស់នៅ តែជាងពាក្យនេះ ដូចជា ម៉ាធាស រីស៊ី បាននិយាយ នៅក្នុងជំពូក 8 កន្លែងនៃគ្រោះជាផ្នែក(វានិយាយ 1/3) ទីនេះ ពេលដែលត្រូវ

ទទួលគ្រោះត្រឹមតែមួយផ្នែកប៉ុណ្ណោះ។ (dazu ist eine sachliche Parallele zu beachten. Mit diesem Ausdruck soll openschtliche etwas Aehniliches ausgesagt warden wie mit dem, im Zusammenhang der selben Plagenreihe esscheinenden “ Drittel” (vgl. 8, 7-13, 9, 18): Der, Driitel” bezeichnet eine raumliche Gegrenzung der Plagen, die funf Monate bezeichnen eine zeitliche. Zeit und Geschchte in der Offenbarung des Johannes, p 32).

6 មនុស្សនឹងរកចង់បានសេចក្តីស្លាប់ តែសេចក្តីស្លាប់នឹងរត់ចេញពីគេទៅ។ កាលដែលយើងឃើញពាក្យ គ្រោះដែលចេញមកពីជង្គុកដែលគ្មានបាត គឺប្រៀបដូចទៅនឹងប្រភេទនៃការដាក់ទោសរបស់ស្តាននរក។ ការដាក់ទោសនៃស្តាននរកគឺគួរឱ្យភ័យខ្លាចជាងសេចក្តីស្លាប់។ វាជាពិសដែលគ្រោះថ្នាក់បំផុត ដែលអ្នកមិនព្រមប្រែចិត្តនឹងទទួលនៅគ្រាចុងក្រោយនៃផែនដី។ នោះគឺសេចក្តីរងទុក្ខវេទនាយ៉ាងខ្លាំងដោយគ្មានការនិយាយអ្វីទាំងអស់ នោះព្រលឹងនឹងត្រូវបានធ្លាក់ចុះទៅក្នុងរណ្តៅយ៉ាងជ្រៅ។ ព្រះទ្រង់ធ្វើឱ្យអ្នកដើរតាមអារក្សត្រូវទទួលនូវទុក្ខវេទនាដោយសារអារក្សនោះ។ (1) ដូច្នេះនៅទីនេះជាមេរៀន ដែលថាអ្នកណាដែលនៅខាងអារក្សនោះគេនឹងមិនទទួលបានព្រះពរចេញពីអារក្សទេ តែជាបណ្តាសាវិញ។ (2) “ពួកគេនឹងចង់ស្លាប់” ពួកគេត្រូវបានធ្លាក់ចុះនៅក្នុងស្ថានភាពនៃការខកចិត្ត និងបាក់ទឹកចិត្ត។ រាស្ត្រដែលត្រូវបានរើសតាំងដែលជឿដល់ការបើកសម្តែងរបស់ព្រះនឹងបានរីករាយនូវសេចក្តីសុខសាន្តរបស់ព្រះនៅក្នុងព្រះគ្រីស្ទ តែអ្នកដែលមិនត្រូវបានរើសតាំងហើយជាអ្នកដែលរស់នៅក្នុង

សេចក្តីងងឹតជាមួយនឹងអារក្ស (ខ2) ស្ថិតនៅក្នុងការបាក់ទឹកចិត្ត ហើយគ្មានសង្ឃឹម និងអំណារនៃអនាគតឡើយ។ (ប្រែ្តចដានុស)

7-11 នៅក្នុងការលេចមកនូវសត្វកណ្តូប នោះប្រៀបដូចជាសេះដែលត្រូវបានរៀបចំសម្រាប់សង្គ្រាម៖ ការពិតដែលរូបភាពនៃសត្វកណ្តូបដូចជាសេះសង្គ្រាមនោះត្រូវបាននិយាយនៅក្នុង ហោរាយ៉ូអែលនៅគ្រាដើម។ (យ៉ូអែល 2:4) សេះសង្គ្រាមជាតំណាងដែលរត់ដោយមានអំណាច និងយ៉ាងរហ័ស។ ដូច្នេះ វាជានិមិត្តរូបនៃចលនានៃការក្បត់សាសនាដែលពង្រាយយ៉ាងរហ័សយ៉ាងធំធេង។

នៅលើក្បាលវាមានដូចជាមកុដដែលស្រដៀងនឹងមាស។ ការនេះមានន័យថាជាអំណាចដែលជាចលនានៃសេចក្តីមិនពិត (ការបង្រៀនខុសឆ្គង) ដែលទទួលបានជ័យជំនះដោយបែបបញ្ឆោរបណ្តោះអាសន្ន។ វាប្រៀបដូចជាមាស តែមិនមែនជាមាសពិតនោះទេ ដូច្នេះវាមិនមានលក្ខណៈដែលគង់វង្សនោះទេ។

ហើយមានមុខដូចជាមុខមនុស្ស មុខមនុស្សជាសញ្ញានៃចំណេះដឹងពីអំណាចរបស់អារក្សដែលនឹងមកដោយហិង្សា តែបើទោះជាយ៉ាងណាវាមកតែពីខាងក្រៅ ហើយវាមានកលល្បិចមួយចំនួន។

ខ សក់វានោះដូចជាសក់របស់ស្រីៗ អ្នកប្រាជ្ញម្នាក់អះអាងថា ដោយសារទាហានរបស់មហាម័តមានសក់វែង នោះពួកគេជាកម្មវត្ថុនៃទំនាយដូច្នេះ។ តែនៅទីនេះ ការពិតដែលមនុស្សប្រុសមានសក់វែងគឺចង្អុលទៅកាន់និមិត្តសញ្ញាឱ្យចាកចេញពីតំណែងរបស់គេ។ (1កូរិនថូស 11:14) ការរៀបរាប់បែបនិមិត្តសញ្ញានេះទៅកាន់ភ្នាក់ងាររបស់សាតាំងដែលបះបោរនឹងព្រះនោះគឺសាកសមណាស់។

ហើយធ្មេញវាដូចជាធ្មេញរបស់សត្វសិង្ហ ការនេះចង្អុលទៅកាន់លក្ខណៈដែលសាហាវ ការដែលសម្លាប់ព្រលឹងមនុស្ស ដោយហ្វូងមនុស្សចាប់យកអំណាចនៃកងទ័ពដែលអាក្រក់ និងការបង្រៀនខុសឆ្គង។

9 វាពាក់អាវសឹកដូចជាអាវសឹកដែក ហើយសូរស្តាហា ឮដូចជារទេះចំបាំង។ ការនេះប្រាប់ពីអំណាចបណ្តោះអាសន្នរបស់ពួកគេដែលយកជ័យជំនះ។

10 មានកន្ទុយ ជាសញ្ញានៃហោរាក្លែងក្លាយ (អេសាយ 9:15) ហើយក៏ជានិមិត្តសញ្ញាដែលធ្វើបាបដល់ព្រលឹងមនុស្សជាមួយនឹងពាក្យរបស់អារក្ស (ព្រួញរបស់អារក្ស អេភេសូរ 6:16)។ ទាហាននេះមិនធ្វើបាបដល់រូបកាយរបស់មនុស្សទេ តែធ្វើបាបដល់ព្រលឹងរបស់មនុស្សដំបូងគេ។ និយាយមួយបែបទៀត ពួកគេចាក់ទៅក្នុងព្រលឹងមនុស្សនូវគំនិតទុច្ចរិត ហើយធ្វើឱ្យពួកគេឈឺ។

ទេវតានៃជង្ហុកធំ ដែលតាមភាសាហេព្រើរមានឈ្មោះហៅថា "អាបាដូន" តែតាមភាសាក្រិកហៅថា "អាប៉ូលីយ៉ូន" វិញ។ ឈ្មោះទាំងពីរនេះជាអត្ថន័យរបស់មេបំផ្លាញ។

12 សេចក្តីវេទនាទីមួយ ការនេះចង្អុលទៅសេចក្តីវេទនាមួយនៅក្នុងចំណោមបីដែលនៅសល់ ដែល 8:13 បាននិយាយ។ នៅទីនេះ ប្រាប់ពីសេចក្តីវេទនាដែលនឹងមកដល់ជាការធ្វើឱ្យមនុស្សបានប្រែចិត្ត។

13 នោះខ្ញុំឮសម្លេងមួយចេញពីស្នែងទាំង៤របស់អាសនាមាសដែលនៅចំពោះព្រះ។ នេះជានិមិត្តសញ្ញានៃចម្លើយដែលពួកបរិសុទ្ធថ្វាយជាការអធិស្ឋាន សង្ឃលាបឈាមនៃយញ្ញបូជានៅលើស្នែងរបស់អាសនា វាមានន័យថាជានិមិត្តសញ្ញាដែលផ្នែកនេះមានអំណាចនៃសេចក្តីសង្គ្រោះនៃការប្រោសលោះ (លេវីវិន័យ 4:25)។ ដូច្នេះ នៅទីនេះសម្លេងដែលចេញមកមានន័យថា ការឆ្លើយនូវការអធិស្ឋានដែលបានថ្វាយដោយយល់ដល់ព្រះលោហិតដ៏វិសេសរបស់ព្រះយេស៊ូវគ្រីស្ទដែលចេញមកនោះ។

14, 15 "ចូរស្រាយទេវតាទាំងបួន ដែលចងទុកនៅទន្លេអ៊ើប្រាតដ៏ជាធំទៅ" "ទេវតា" មានសិទ្ធិអំណាចក្នុងការចាត់ចែងគ្រប់ភាវៈទាំងអស់នៅចំពោះព្រះ (វិវរណៈ 16:5)។ តើ "ទេវតាបួនដែលត្រូវបានចងនៅទន្លេអ៊ើប្រាត" មានន័យដូចម្តេច? វាមានន័យថា ជាស្ថានភាពដែលពួកគេឈរ ដែលពួកគេមានប្រទេសមួយចំនួនដែលនៅតំបន់នោះ ហើយដែលមានសិទ្ធិនឹងសម្លាប់មនុស្ស 1/3 តែមុននឹងពេលវេលារបស់ព្រះកំណត់ទុកមកដល់ នោះពួកគេមិនអាចធ្វើការទាំងនោះបានឡើយ។ អ្នកប្រាជ្ញម្នាក់បានបកស្រាយវាថា ទេវតាបួននេះជាទេវតាដែលអាក្រក់ វាចង្អុលទៅកាន់ទេវតាបួនដែលបង្កើតប្រទេសបួននៅតំបន់ទន្លេអ៊ើប្រាត ហើយនឹងសម្លាប់មនុស្សជាច្រើនដោយប្រើហិង្សា។

15 ពេលកំណត់ ថ្ងៃ ខែ និងឆ្នាំ នោះជាប្រទេសបួនដែលជាប្រទេសរបស់ស៊ីលធិន ដែលប្រទេសតួគីបានបង្កើតនៅស.វ ទី11 ហើយរួចមកពួកគេបានចាប់ផ្តើមលួចនៅតំបន់រ៉ូម ហើយធ្វើវារហូតដល់ឆ្នាំ 1672។ រយៈពេលសរុបគឺ 391 ឆ្នៃ ដែលត្រូវបានបង្ហាញដោយខ 15 ពេលកំណត់ ថ្ងៃ ខែ និងឆ្នាំ។ ដែល "ឆ្នាំ" គឺ 360 ថ្ងៃ "ខែ" មាន 30 ថ្ងៃ "ថ្ងៃ" ជាមួយថ្ងៃគឺមាន 31ថ្ងៃ ប្រសិនបើមើលទៅថ្ងៃដូចជាឆ្នាំនៅក្នុងវិធីសាស្ត្ររបស់វិវរណៈ នេះគឺ 391 ឆ្នាំ។ តែការរាប់ឆ្នាំនេះជាយោងតាមហេតុផល តែដោយសារវាបានដកឆ្នាំចេញពីឆ្នាំ ខែ និងថ្ងៃ។ វាពិបាកក្នុងការទុកចិត្តលើវា។ មិនត្រឹមតែប៉ុណ្ណោះទេ ឃ្លាថា ឆ្នាំ ខែ និងថ្ងៃ (τὴν ὥραν καὶ ἡμέραν καὶ μῆνα καὶ ἐνιαυτόν) មិនមែនជារយៈពេលនៃពេលនៅក្នុងវេយ្យាករណ៍ទេ តែជាទីតាំងនៃឆ្នាំននិងថ្ងៃ។ លោក អាល់ហ្វត បានប្រុងប្រយ័ត្នពីពាក្យថា "the" (τὴν)" គឺដូចតទៅនេះ ពាក្យថា "the" ទាក់ទងទៅនឹងខែ ថ្ងៃ តែមិនទាក់ទងនឹងឆ្នាំទេ ជាទូទៅការនេះសង្កត់ធ្ងន់ថាគម្រោងការរបស់ព្រះសម្រាប់ថ្ងៃដែលប្រទេសនានាចាប់ផ្តើមធ្វើការវាយលុក។

16 ឯចំនួនពលសេះ នោះមានម្ភៃកោដិ ពាក្យថា “ពលសេះ” មិនគួរត្រូវបានអាន ដោយពាក្យន័យត្រង់ៗនោះទេ។ នៅខាងក្រោមនេះ កាលដែលយើងឃើញខ 17 ជា អារុធពិសេសដ៏អាក្រក់។ ហើយមានម្ភៃកោដិជាចំនួនដ៏ច្រើនមហិមា។ រហូតមកថ្ងៃនេះ មិនមានសង្គ្រាមដែលមានមនុស្សម្ភៃកោដិត្រូវបានប្រមូលផ្តុំទេ។ កាលដែលយើង ឃើញការសម្រេចបំពេញនៃទំនាយនេះហាក់ដូចជាស្ថិតនៅក្នុងអនាគត។

17 18, ក្នុងការជាក់ស្តែងនេះ ពាក្យនេះជាពាក្យថា អែន ថិ ហូរ៉ាសេ (ἐν τῇ ὁράσει) នៅក្នុងភាសាក្រិក ដែលមានន័យថា “នៅក្នុងនិមិត្ត”។ ដូច្នេះ ពាក្យខាងក្រោមវា យើងមិនគួរអានតាមន័យត្រង់ៗឡើយ តែមើលវាក្នុងន័យជានិមិត្តសញ្ញាវិញ។ (Dusterdick)

សម្បុរភ្លើង ស្វាយខ្ចី និងស្ពាន់ធ័រ លោក ស្កត ចង្អុលទៅកាន់ការពិតដែលអ្នកលុក លុយរបស់តួគី (សូមមើលទៅកាន់ខ 14 ខាងលើ) ស្លៀកពាក់ក្នុងពណ៌ដូចគ្នា។ តែ ទំនាយនេះមិនបានសម្រេចបំពេញទាំងស្រុងដោយវានោះទេ។ ពណ៌ស្វាយជានិមិត្ត សញ្ញានៃការវិនិច្ឆ័យទោស និងការសម្លាប់ “ស្ពាន់ធ័រ” ជាឧបករណ៍ដែលចាំបាច់ (សម្រាប់ធ្វើគ្រាប់បែក) នៃសង្គ្រាម (ជាពិសេសនៅសម័យទំនើប)។ ដូច្នេះ ឃ្លានេះ ហាក់ដូចជានិមិត្តសញ្ញានៃសង្គ្រាម។

ឯក្បាលសេះនោះដូចជាក្បាលសិង្ហ “សេះ” នៅក្នុងបទគម្ពីរត្រូវបានប្រើជានិមិត្តសញ្ញា នៃ “កម្លាំង” ឬ “ចលនា” មានឃ្លាដែលមិនមានន័យជាពាក្យត្រង់ៗទេ។ (ទំនុកដំកើង 20:7) “សិង្ហ” មានន័យជានិមិត្តសញ្ញានៃអំណាចគ្រប់គ្រងដែលពេញហិង្សា។

មានភ្លើង ផ្សែង ហើយស្ពាន់ធ័រចេញពីមាត់វាមក។ ហេតុផលដែលឃ្លានេះមិនគួរអាន ដោយន័យត្រង់នោះទេ តែជានិមិត្តសញ្ញាវិញនោះគឺ ជាការបង្ហាញពីការទាមទារនូវ បែបបទន័យត្រង់ៗ។ កាលដែលយើងអានវាបែបជាអក្សរសិល្ប៍ វាប្រឆាំងនឹងហេតុផ

ល។ តើកងទ័ពនៅទីណាដែលបំបែកចេញជាភ្លើងចេញពីមាត់នោះ? ដូច្នេះ នេះជា និមិត្តសញ្ញានៃវិធីសាស្ត្រនៃការវាយប្រហារដោយយន្តហោះ ការវាយប្រហារដោយ អាវុធ អគ្គិសនី ការវាយប្រហារ ការបាញ់ ជាដើម ដែលត្រូវបានបង្កើតមក។

19 ពីព្រោះអំណាចរបស់សេះនោះ គឺមាននៅក្នុងមាត់ និងកន្ទុយរបស់វា។ អំណាច របស់សង្គ្រាម និងទិចនិកតាមរយៈមាត់របស់សេះខាងលើ។ ហើយអំណាចនៃស ង្គ្រាម និងទិកនិកដោយកន្ទុយជាការបង្រៀននៃហោរាក្លែងក្លាយដូចជា អេសាយ 9:15 ។ នៅក្នុងពេលមួយ អាថ៌កំបាំងដែលកងទ័ពរបស់អារក្សដែលយកឈ្នះគឺ ជាការ ប្រកាសការបង្រៀនខុសឆ្គងរបស់គាត់ និងគំនិតទុច្ចរិតរបស់គាត់ទៅក្នុងវិញ្ញាណរបស់ មនុស្ស និងល្បួងពួកគេ។ ពីព្រោះព្រះធ្វើឱ្យកើតឡើង និងដាក់ទោសដល់ផែនដី វាទ ទួលបានអំណាចជាមួយនឹងកំលាំងនិងគំនិតមួយរយៈ។

20 21 រីឯសំណល់មនុស្សដែលមិនបានស្លាប់ដោយសារសេចក្តីឥទនាទាំងនោះ។ លោក ស្កត និយាយថា វាចង្អុលទៅកាន់ពួកវ៉ូមុាំងដែលសេសសល់ពីការវាយលុក តែ តាមរយៈការនេះ ទំនាយមិនត្រូវបានសម្រេចទាំងស្រុងទេ។ ការសម្រេចដោយវិជ្ជមាន នៃការនោះនឹងស្ថិតនៅពេលអនាគត។ ក៏មិនបោះបង់ចោលការថ្វាយបង្គំអារក្ស ឬរូប ព្រះក្លែងក្លាយនៃមាសនិងប្រាក់ និងស្ពាន់ និងថ្ម និងឈើ ដែលមិនអាចមើលឃើញឬ ស្តាប់ឮ ឬដើរបានឡើយ។ 21 ក៏ពួកគេមិនប្រែចិត្តពីសម្លាប់របស់ពួកគេ ឬពីមន្តអាគម ឬពីការកំផិត ឬពីការលួចប្លន់របស់ពួកគេឡើយ។ នៅទីនេះ បញ្ជីនៃអំពើបាបចង្អុល ទៅកាន់ការធ្វើទាស់នឹងក្រឹត្យវិន័យរបស់ម៉ូសេនៅខ 20 សម្គាល់ពីអំពើបាបនៃការ ថ្វាយបង្គំរូបព្រះ ដែលជាតំណាងនៃការធ្វើបាបទាស់នឹងព្រះ (ក្រឹត្យវិន័យពី 1-4)។ ដូច្នេះ ខ 21 (មន្តអាគម ការកំផិត ការលួចប្លន់) សម្គាល់ពីអំពើបាបដែលធ្វើទៅកាន់ មនុស្ស (ក្រិត្យវិន័យពី 5-10)។ នៅទីនេះ អំពើបាបដែលធ្វើទាស់នឹងបញ្ញាត្តិទីប្រាំ

ហាក់ដូចជាត្រូវបានមើលរំលង តែវាត្រូវបានរាប់បញ្ចូលនៅក្នុងអំពើបាបនៃការសម្លាប់។ អំពើបាបនៃការធ្វើបន្ទាល់ក្លែងក្លាយរាប់បញ្ចូលនៅក្នុងមន្តអាគម។ ការលោភត្រូវបានរាប់បញ្ចូលនៅក្នុងអំពើបាបនៃការលួចប្លន់។

ចំណុចសំខាន់

1. "ត្រូវធ្វើទុក្ខដល់មនុស្សណាដែលគ្មានត្រារបស់ព្រះនៅថ្ងាសវិញប៉ុណ្ណោះ"(ខ 4)។ អ្នកជឿពិតនោះត្រូវបានបោះត្រាដោយព្រះ និងបានទទួលការអះអាងពីព្រះ។ ដូច្នេះ ពួកគេបានមកដល់សេចក្តីសប្បុរសតាមរយៈគ្រប់ការដែលធ្វើការជាមួយគ្នា។ (រ៉ូម 8:28) ហើយមិនត្រូវបានគេធ្វើទុក្ខឡើយ។

2. សត្វកណ្តូបនៅក្នុងខ 7-11 ត្រូវបានលេចមកជាមួយនឹងរូបរាងបែបហិង្សាជាធម្មតា។ វាមានកងទ័ពដែលសាហាវ ហើយចង្អុលទៅកាន់និមិត្តសញ្ញានៃការបង្រៀនក្លែងក្លាយដែលមិនត្រឹមត្រូវ និងចម្លែក។ ចលនានៃការបង្រៀនចម្លែកបំផ្លាញដល់ព្រលឹងរបស់មនុស្ស។ បទគម្ពីរបង្រៀនពីការពិតនិងមេរៀនដែលអស្ចារ្យ។ តែព្រះបន្ទូលគ្មានលក្ខណៈចម្លែកនោះទេ។ កណ្តូបបង្ហាញនៅក្នុងខ 7, 8 មានមុខដូចជាមនុស្ស (ប្រុស) ហើយសក់ដូចជាសក់របស់មនុស្សស្រី វាជារូបរាងដែលចម្លែក។

3. ខ 15 បង្ហាញថាកិច្ចការដែលព្រះទ្រង់ធ្វើគឺត្រូវបានកំណត់ទុកតាមលំដាប់លំដោយយ៉ាងលម្អិត។ អ្នកជឿពិតប្រាកដ (1) គួរថ្វាយគ្រប់ការទាំងអស់ដល់ព្រះ ហើយគេមិនគួរខ្វល់ខ្វាយអ្វីឡើយ។ (2) គេមិនគួរបាត់បង់ឱកាសជាមួយនឹងភាពស្មោះត្រង់ និងការលះបង់ឡើយ។

4. អ្វីដែលយើងគួរប្រយ័ត្ននោះគឺ ការធ្វើសកម្មភាពដដែលៗបន្ទាប់ពីយើងបានឃើញថា អ្នកខ្លះទទួលបាននូវការដាក់ទោសពីស្ថានសួគ៌ដោយសារអំពើបាប

ណាមួយ។ (21) “អ្នកណាដែលត្រូវបន្ទោសជាញយៗ តែតាំងចិត្តរឹងវិញ នោះត្រូវ វិនាសក្នុងមួយរំពេច ទាល់បើជួយផងៗ” (សុភាសិត 29:1)។ និក្ខមនំ 32:9, 10 បាននិយាយថា “ព្រះយេហូវ៉ាទ្រង់ក៏មានបន្ទូលនឹងម៉ូសេថា អញឃើញបណ្តាជន នេះ ថាជាពួកមនុស្សមានក្បាលរឹង ដូច្នេះទុកឱ្យអញឥលូវចុះ ឱ្យសេចក្តីក្រោធ របស់អញបានឆេះក្តៅឡើងទាស់នឹងគេ អញនឹងបំផ្លាញគេឱ្យសូន្យទៅ ហើយនឹង បង្កើតនគរ1យ៉ាងធំពីឯងវិញ។” “ឯងនឹងឡើងទៅឯស្រុកមួយដែលមានទឹកដោះ ហើយនឹងទឹកឃ្មុំហូរហៀរ តែអញមិនឡើងទៅកណ្តាលពួកឯងទេ ក្រែងអញធ្វើឱ្យ ឯងវិនាសតាមផ្លូវ ដ្បិតឯងរាល់គ្នាជាមនុស្សមានក្បាលរឹងៗ” (និក្ខមនំ 33:3)។ “ព្រះយេហូវ៉ាទ្រង់បង្គាប់ម៉ូសេ ឱ្យប្រាប់ដល់ពួកកូនចៅអ៊ីស្រាអែលថា ឯងរាល់គ្នា ជាមនុស្សមានក្បាលរឹង បើអញឡើងទៅកណ្តាលឯងរាល់គ្នាតែមួយភ្លែត នោះ នឹងធ្វើឱ្យវិនាសអស់ហើយ ដូច្នេះ ចូរឯងរាល់គ្នាដោះគ្រឿងលំអពីខ្លួនចេញឥលូវ ដើម្បីឱ្យអញនឹងដឹងជាត្រូវធ្វើដល់ឯងរាល់គ្នាជាយ៉ាងណាៗ” (និក្ខមនំ 33:5)។ “សប្បាយហើយអ្នកណាដែលមានចិត្តកោតខ្លាចជានិច្ច តែអ្នកណាដែលតាំងចិត្ត រឹងទទឹង នោះនឹងធ្លាក់ទៅក្នុងសេចក្តីអន្តរាយវិញៗ” (សុភាសិត 28:14)

5. វាពិបាកថា ចិត្តរបស់មនុស្សត្រូវបានគ្រប់គ្រងដោយការដាក់ទោស (ជំពូក 9 ខ 20,21)។ តែវាជាវិធីសាស្ត្រមួយដើម្បីនឹងគ្រប់គ្រងចិត្តយ៉ាងពិតប្រាកដ។ ដូច្នេះ មុនពេលគេត្រូវបានគ្រប់គ្រងដោយការដាក់ទោស ឱកាសក្នុងការគ្រប់គ្រងដោយ ព្រះគុណនោះមានតម្លៃណាស់។ តើផារ៉ោនបានទទួលការដាក់ទោសបានយ៉ាង ដូចម្តេច? តែគាត់មិនបានប្រែចិត្តទេ។ ចិត្តរបស់គាត់បានរឹងរុសម្តងទៀត។ បើ ទោះជាគាត់ត្រូវបានបង្ហាញមកថាមានការភ័យខ្លាចកាលដែលគាត់ទទួលបាន

គ្រោះនានាជាបណ្តោះអាសន្ន ហើយគាត់ហាក់ដូចជាមានការជជែកវែកញែកថ្មីៗ ផង តែបន្ទាប់ពីគ្រោះចង្រៃបានផុតទៅ គាត់បានធ្វើចិត្តរឹងរុសម្តងទៀត។

ការអធិប្បាយទី **33** ទុក្ខលំបាកនៃការដែលមិនត្រូវបានជ្រើសរើស

1. ការឈឺចាប់នៃសេចក្តីងងឹត

យើងមិនដឹងថាភាពងងឹតនោះមានការឈឺចាប់ប៉ុណ្ណាទេ។ នៅពេលដែលអ្នកជីករ៉ែធ្យូងថ្មមួយចំនួននៅស្កុតឡែនបានចូលទៅក្នុងរូងក្រោមដីដោយមានចង្កៀង វាត្រូវបានរលត់នៅក្នុងនោះ វាងងឹតច្របូកច្របល់នៅទីនោះ។ បន្ទាប់មក ពួកគេមិនអាចចេញពីវាបានទេ។ តើពួកគេនឹងត្រូវរងទុក្ខប៉ុណ្ណា! ដោយសារពួកគេមិនអាចចេញពីទីនោះបាន ពួកគេមិនអាចធ្វើអ្វីបានទេ ប៉ុន្តែត្រូវនៅទីនោះ។ (1) គ្មានសេចក្តីសង្ឃឹមក្នុងភាពងងឹតទេ។ ហេតុនេះហើយបានជាមានបទគម្ពីរចែងថា៖ “ដូច្នេះ ស្តេចមានបន្ទូលទៅពួកអ្នកបម្រើថា “ចូរចងដៃចងជើងអ្នកនេះ សែងយកទៅចោលនៅទីងងឹតខាងក្រៅ ជាកន្លែងយំសោកខឹងសង្កៀតធ្មេញនោះទៅ!” (ម៉ាថាយ 22:13) ទៅកាន់ម្នាក់ដែលត្រូវបានសង្គ្រោះ។ (2) នៅក្នុងទីងងឹត យើងមិនអាចធ្វើអ្វីបានទាំងអស់។ ព្រះយេស៊ូវមានបន្ទូលថា “យើងត្រូវធ្វើកិច្ចការរបស់ព្រះអង្គដែលបានចាត់ខ្ញុំអោយមកទាន់នៅភ្លឺនៅឡើយ ដ្បិតដល់ពេលយប់ គ្មាននរណាអាចធ្វើការបានឡើយ។” (យ៉ូហាន 9:4)។ ប្រសិនបើមនុស្សមិនអាចនឹងធ្វើអ្វីបាន គេនឹងត្រូវស្លាប់។ កាលដែលមនុស្សត្រូវបានធ្វើឱ្យងងឹតដោយសារអារក្ស នោះគាត់នឹងត្រូវបានធ្វើទុក្ខ។ ដែលគេនឹង

គ្មានសង្ឃឹម ពីព្រោះគេស្នាក់នៅក្នុងសេចក្តីងងឹត ដោយមិនស្គាល់ព្រះ ហើយគេគ្មានការប្រព្រឹត្តពិតប្រាកដនោះទេ។

2. ការឈឺចាប់នៃអំពើបាប

ការឈឺចាប់នៃអំពើបាបជាការឈឺចាប់មួយ ដែលមនុស្សមិនអាចមានអារម្មណ៍ទេជួនកាល។ ពិតណាស់ វាជាការឈឺចាប់ដូចជាខ្សាដំរីទិច (ខ 5) 1កូរិនថូស 15:56 មានបន្ទូលថា “ទ្រនិចនៃសេចក្តីស្លាប់នោះ មកពីអំពើបាប រីឯអំណាចនៃអំពើបាបមកពីក្រឹត្យវិន័យ”។ ពីព្រោះអំពើបាបតែងតែមិនសប្បាយទេ ហើយតែងតែមានស្នាមនៅក្នុងចិត្ត។ ទំនុកដំកើង 51:3, “ទូលបង្គំទទួលសារភាពថា ទូលបង្គំបានធ្វើខុសហើយ អំពើបាបរបស់ទូលបង្គំជិតជាប់ នៅក្នុងអារម្មណ៍ទូលបង្គំជានិច្ច”។ ដ្បិតខ្ញុំដឹងពីការបះបោររបស់ខ្ញុំ ហើយអំពើបាបរបស់ខ្ញុំដែលនៅចំពោះខ្ញុំជានិច្ច។ វាមានន័យថា កាលណាដែលមនុស្សឈរនៅចំពោះព្រះ អំពើបាបដែលបានធ្វើនឹងទិចដល់មនសិការ ហើយធ្វើឱ្យគេបានឈរឡើង។ ទំនុកដំកើង 130:3, “ឱព្រះអម្ចាស់អើយ ប្រសិនបើព្រះអង្គចងចាំកំហុសរបស់យើងខ្ញុំទុកនោះគ្មាននរណាម្នាក់អាចរួចខ្លួនបានឡើយ” ចង្អុលមកកាន់ការមួយនេះ។

3. ការឈឺចាប់ដែលមិនចេះស្លាប់

បើទោះជាព្រលឹងត្រូវរងទុក្ខការឈឺចាប់នៃស្ថាននរក ហើយចង់ស្លាប់ក៏ដោយ គេមិនអាចធ្វើបានឡើយ តែគេត្រូវរងទុក្ខវេទនានៃស្ថាននរក។ នៅក្នុងលោកិយនេះ មានការទួញសោកដែលអាក្រក់ជាសេចក្តីស្លាប់ទៀត។ វាជាការឈឺចាប់នៃអំពើបាប។ ដូច្នេះពួកបរិសុទ្ធគួរព្យាយាមគេចពីការទួញសោករបស់គេ បើទោះជាគេត្រូវរងសេចក្តីស្លាប់ក៏ដោយ។ នោះគឺ (1) ពួកគេផ្ទុយនឹងអំពើបាបរហូតដល់ហូរឈាម (ហេព្រើរ 12:4) (2) ប្រៀបដូចជាយ៉ូប បើទោះជាព្រះសម្លាប់ខ្ញុំ “ព្រះអង្គមុខជាប្រហារខ្ញុំខ្ញុំលែងមាន

សង្ឃឹមអ្វីទៀតហើយប៉ុន្តែ ខ្ញុំនឹងការពារខ្លួននៅចំពោះព្រះភក្ត្រព្រះអង្គ” (យ៉ូប 13:15), (3) ពួកគេមិនគួរខ្លាចអ្នកដែលអាចសម្លាប់បានតែរូបកាយ តែមិនអាចសម្លាប់ព្រលឹងឡើយ។

ជំពូកទី 10

ជំពូកនេះជាវគ្គនៃការបើកសម្តែង និងគ្រោះចង្រៃដែលនឹងមកនៅក្នុងឥទ្ធិពលនាពេលអនាគតនៅក្នុងផ្នែកខ្លះនៃផែនដី តែមិនមែននៅក្នុងពិភពលោកទាំងមូលទេ។

ការបកស្រាយ

ទេវតាដ៏ខ្លាំងពូកែមួយទៀត វាត្រូវបានបកប្រែថា ទេវតានេះជាព្រះគ្រីស្ទផ្ទាល់ តែលោកប្រ្តេចដានុស គិតថា ជាទេវតាដែលមានកម្រិតខ្ពស់វិញ។ (In elk geval is het een zeer hooge engel, zoo al suit geheel zijne verschijning, en uit zijn doen blijkt – Openbaring p 214)។

មានពពកហ៊ឺ “ពពក” ទាក់ទងទៅនឹងព្រះជាម្ចាស់ (ទំនុកដំកើង 104:3, ដានីយ៉ែល 7:13 វិវរណៈ 1:7, 14:14) ដែលជានិមិត្តសញ្ញាបែបស្ថានសួគ៌ យ៉ាងមានចេស្តា និងវាងវៃ។ ដ្បិតទេវតានេះនាំមកនូវកិច្ចការយ៉ាងសំខាន់ ទ្រង់បង្ហាញពីចេស្តាស្ថានសួគ៌។

ហើយមានឥន្ទធនូនៅលើក្បាល ដ្បិតនៅទីនេះ “ឥន្ទធនូ” មានពាក្យ “the” ដូចដែលយើងបានបកប្រែយ៉ាងត្រឹមត្រូវថា វាជា “ឥន្ទធនូ”។ ហេតុអ្វីបានជានិយាយពី “ឥន្ទធនូ”? វាពិបាកនឹងមួយទៀតនៅក្នុង 4:3 ដែលជាឥន្ទធនូនៅក្នុងលោកិយទូទៅ

ដែលជាឥន្ទធនូដែលយើងស្គាល់យ៉ាងច្បាស់។ (ព្រូចដានុស) ដ្បិត “ឥន្ទធនូ” នៅក្នុង 4:3 មិនមានពាក្យ “the” ទេ វាជាឥន្ទធនូដែលពិសេសដែលទាក់ទងនឹងព្រះ។ ឥន្ទធនូបង្ហាញដល់ទេវតានេះដែលត្រូវបានចាំងផ្លាតពីពពករបស់ទ្រង់ ហើយក៏ត្រូវបានបង្ហាញមកដោយភាពប្រាជ្ញារបស់ទ្រង់។ នេះក៏ជានិមិត្តសញ្ញានៃភាពស្មោះត្រង់នៅក្នុងការតាំងសញ្ញានៃសេចក្តីសង្គ្រោះដែរ។ សូមអានការបកស្រាយនៃ 4:3។ ហើយព្រះភ័ក្ត្ររបស់ទ្រង់ដូចជាព្រះអាទិត្យ សូមអាននៅ ម៉ាថាយ 13:43។ វត្តមាននៅក្នុងលោកិយនៃស្ថានសួគ៌ដែលពិតជាសុចរិត បរិសុទ្ធ និងផ្ទៃមុខដែលភ្លឺ។

ហើយជើងដូចជាបង្គោលភ្លើង។ សូមអាននៅ និក្ខមនំ 14:19, 24។ នេះជានិមិត្តសញ្ញាដែលបង្ហាញពីចេស្តានៃការកាត់ទោសរបស់ព្រះនៅក្នុងការជំនួសវា។ លោកព្រូចដានុស បាននិយាយថា “ឃ្លានេះចង្អុលទៅកាន់ចេស្តាយ៉ាងខ្លាំងរបស់ទេវតា និងក្នុងពេលតែមួយ វាជានិមិត្តសញ្ញានៃភាពអស្ចារ្យនៅក្នុងឋានៈរបស់ទ្រង់ និងកិច្ចការរបស់ទ្រង់។” (Alles spreekt in divers van des engels grootheid en schitering, en wijat daarmede tevens op de grootheid en beteekenis van zijne positive, en van zijn werk).

2 មានកាន់ក្រាំងមួយតូចបើកនៅដៃ យោងតាមទ្រឹស្តីមួយ នេះមិនមែនជាសៀវភៅខុសគ្នាទេ ប៉ុន្តែជាសៀវភៅតូចមួយដែលជាសៀវភៅជំនុំជំរះនៅក្នុងព្រះហស្តរបស់ព្រះ (5:1) ត្រូវបានបង្ហាញម្តងទៀតនៅក្នុងការនិមិត្តនេះ។ នេះចង្អុលទៅទំនាយនៅជំពូកទី 11ខាងក្រោម។ ហេតុផលដែលទេវតាមកលើសាវ័កជាមួយនឹងសៀវភៅនៅក្នុងនិមិត្តគឺដើម្បីទទួលស្គាល់បេសកកម្មក្នុងការទាយទំនាយ (សូមមើល ខ 11) ។

នៅលើសមុទ្រ ហើយជើងឆ្វេងនៅលើដីគោក។ នេះជាការបង្ហាញដែលចង្អុលទៅកាន់គ្រប់ការទាំងអស់នៅក្នុងសកលលោក។ (និក្ខមនំ 20:4, 11, ទំនុកដំកើង 69:35, 98:4, 7) ពាក្យដែលទេវតាប្រកាស (ឬទំនាយខាងក្រោមនៅជំពូក 11 ដែលសាវកយ៉ូហានបានទទួល និងបានផ្ទេរមក)ដែលទាក់ទងនឹងលោកិយទាំងមូល។

3, 4 រួចបន្លឺឡើង ដោយសម្លេងយ៉ាងខ្លាំង ដូចជាសម្លេងនៃសត្វសិង្ហដែលគ្រហឹម។ នៅទីនេះ ពាក្យ "បន្លឺឡើង" ម៉ូខាដាយ (μυκᾶται) ជាភាសាក្រិច ដែលជាពាក្យដែលជាទូទៅមិនត្រូវប្រើសម្រាប់ការយំរបស់សត្វតោទេ។ (1ពេត្រុស 5:8) លោក H. B. Swete បាននិយាយថា “ពាក្យនេះមានន័យថាបរិមាណនៃសំឡេងគឺអស្ចារ្យណាស់ ហើយកម្រិតនៃពាក្យគឺស្មោះត្រង់ ហើយធ្វើឱ្យអ្នកស្តាប់ផ្តោតលើការប្រុងប្រយ័ត្ន និងការភ័យខ្លាច។

សម្លេងផ្គរលាន់7។ “នេះគឺជាការបកប្រែដែលមិនបង្ហាញពីអត្ថន័យពេញលេញ The gzreek text elaral lesan haiheptai brontaites heauton ponas (ἐλάλησαν αἱ ἑπτὰ βρονταί, καὶ μὴ αὐτὰ) ដែលត្រូវបានបកប្រែយ៉ាងត្រឹមត្រូវ “រាល់ផ្គរលាន់ប្រាំពីរនិយាយដោយសំឡេងនីមួយៗ” នោះគឺជាការនិយាយថា ផ្គរលាន់ប្រាំពីរនិមួយៗនិយាយដោយសំឡេងពិសេសនីមួយៗ។ ទំនុកតម្កើង 29 ត្រូវបានគេប្រើ “សំលេងនៃព្រះយេហូវ៉ា” ក្នុងរយៈពេលប្រាំពីរដង ឃ្លានៃវិវរណៈនេះហាក់ដូចជាទាក់ទងនឹងពាក្យនៃការបើកសម្តែង។ បន្ទាប់មក គំរូនៃការបើកសម្តែងរបស់ព្រះដែលត្រូវស្តាប់ឮដូចជាសំឡេងផ្គរលាន់ចេញពី យ៉ូហាន 12:28, 29 ដូច្នេះហើយ នេះមិនមែនជាសំឡេងផ្គរលាន់ទេ ប៉ុន្តែជាសំឡេងដ៏អស្ចារ្យ ពោលគឺវាមានព្រះបន្ទូលរបស់ព្រះដែលមានលក្ខណៈនៃការវិនិច្ឆ័យជាខ្លឹមសាររបស់វា។ (8:5) បន្ទាប់មកខ្លឹមសារនៃផ្គរលាន់

ទាំងប្រាំពីរត្រូវបានគេយល់សម្រាប់តែយ៉ូហាន ព្រោះបើវាមិនត្រូវបានកត់ត្រាទេយើងក៏មិនអាចដឹងបានដែរ។ អ្វីដែលយើងគួរគិតអំពីចំណុចនោះគឺអត្ថន័យនៃបើកសម្តែងនៃផ្គរលាន់ប្រាំពីរដែលមិនត្រូវបានសរសេរ ត្រូវមានដល់សាវកយ៉ូហាន។ ហាក់ដូចជាត្រូវបានគិតដូចតទៅ ដោយសារតែមានតែគាត់ទេដែលដឹងពីការបើកសម្តែងនៃផ្គរលាន់ប្រាំពីរ ចិត្តរបស់គាត់ត្រូវបានរីកឡើងដោយភាពប្រាកដប្រជា ហើយកំដៅខាងវិញ្ញាណរបស់គាត់នឹងក្តៅឡើង។ អ្នកផ្សាយដំណឹងល្អគ្រប់រូបគួរតែមានព្រះគុណខាងវិញ្ញាណរក្សាទុកនៅក្នុងចិត្ត ដែលមិនបញ្ចេញនិងមិនបាត់បង់កំដៅ។ សូមអាន 2កូរិនថូស 12:4។

5, 6 រួចទេវតាដែលខ្ញុំឃើញឈរលើសមុទ្រ ហើយលើដីគោក ក៏លើកដៃស្តាំទៅលើមេឃ ទាំងស្បថនឹងព្រះដ៏មានព្រះជន្មរស់អស់កល្បជានិច្ចរៀងរាបតទៅ ជាព្រះដែលបង្កើតមេឃ ដី សមុទ្រ និងរបស់ទាំងប៉ុន្មានដែលនៅស្ថានទាំងនោះ។ នៅក្នុង "ទេវតា" និយាយទំនាយពីការវិនិច្ឆ័យដ៏អស្ចារ្យនាពេលអនាគត ជាដំបូងគាត់ចង្អុលបង្ហាញថាព្រះជានរណា។ ព្រះដ៏មានចេស្តាដ៏ចំរើនយ៉ាងនេះ ព្រះអង្គទ្រង់ធ្វើការវិនិច្ឆ័យដ៏ប្រសើរ ហើយគួរធ្វើតាមពិត ព្រះអង្គនឹងធ្វើក្នុងពេលឆាប់ៗនេះ ព្រះបន្ទូលសំដែងនូវគំនិត។ លោក ប្រ្គេចដានុស បាននិយាយថា "ហេតុផលដែលទេវតាចង្អុលទៅកិច្ចការនៃការបង្កបង្កើតរបស់សត្វទាំងអស់គឺដើម្បីបង្ហាញពីការពិតទាំងស្រុងដែលការវិនិច្ឆ័យដ៏អស្ចារ្យរបស់ទ្រង់នឹងមានឥទ្ធិពលលើភាវៈទាំងឡាយដែលត្រូវបានបង្កើតមករបស់ទ្រង់ដោយផ្ទាល់។ ( )

គ្មានពេលបង្អង់ទៀតឡើយ។ នេះគឺជា ក្រូណូស អ៊ីខេធី អេសថាយ (χρόνος οὐκέτι ἔσται) ជាភាសាក្រិច។ ការបកប្រែអក្សរសិល្ប៍ហាក់បីដូចជាលេខយោងនៅក្នុងការបកប្រែជាភាសាកូរ៉េ។ "ពេលវេលាមិនមានទៀតទេ" អត្ថន័យនៃឃ្លានេះគឺចំពោះការពិតដែលថាការវិនិច្ឆ័យនៅគ្រាចុងក្រោយ ដែលនឹងទូទាត់ឈាមរបស់ពួកបរិសុទ្ធមក

យ៉ាងជិតស្និទ្ធដែលទាក់ទងនឹងព្រះបន្ទូល 6:11 ។ លោក ឡ្យូមេយើ បាននិយាយ ផ្ទុយពីពាក្យរបស់ ដានីយ៉ែល 12:7 ថា “នៅទីនោះ (12:7) ដូចជាការនិយាយអំពី នគរនៃអ្នកប្រឆាំងនឹងព្រះគ្រីស្ទ នៅទីនេះ ដូចជាត្រែទីប្រាំពីរត្រូវបានផ្លុំ ពេលវេលា ដែលនគរមកដល់ត្រូវបានលើកឡើង។ ” (ការបកប្រែសង្ខេប) (χρόνος οὐκέτι ἔσται Wird Wohl durch die bestonte Beziehung auf ដានីយ៉ែល 12:7 sicher Gestelt’; Wie es sich dort um las Reich des Antichrist handelt, so wird auch hier gesagt dass die stunde dieses Reiches mit der 7 Posaune beginnt. – Offenbarung ទំព័រ 85)។ ការលេចមកនូវនគរនៃពួកប្រឆាំង នឹងព្រះគ្រីស្ទគឺត្រូវបានលុបចោលដោយសារនគរដែលត្រូវបានឃើញច្បាស់ពេញ លេញរបស់ព្រះ មុនការទូលអង្វរដោយសារឈាមរបស់ពួកបរិសុទ្ធ (សេចក្តីសង្គ្រោះ ដែលពេញលេញ) បានមកដល់។ ទីមួយ នគរនៃពួកប្រឆាំងនឹងព្រះគ្រីស្ទនឹងមកដ ល់។

7 នោះសេចក្តីអាថ៌កំបាំងនៃព្រះនឹងបានសម្រេច។ នៅទីនេះ “សេចក្តីអាថ៌កំបាំងរបស់ ព្រះ” (τὸ μυστήριον τοῦ θεοῦ) ចង្អុលទៅកាន់ដំណឹងល្អរបស់ព្រះ។ ហេតុអ្វីបាន ជាដំណឹងល្អត្រូវបានហៅថាជាសេចក្តីអាថ៌កំបាំងរបស់ព្រះបែបនេះ? ពីព្រោះអ្នកដែល មិនបានទទួលព្រះវិញ្ញាណបរិសុទ្ធមិនយល់ពីដំណឹងល្អទេ ហើយក៏មិនព្រមជឿដែរ ដែលវាមានឈ្មោះជាអាថ៌កំបាំង។ មិនត្រឹមតែប៉ុណ្ណោះទេ មុនពេលខ្លឹមសារនៃដំណឹង ល្អត្រូវសម្រេចបំពេញយ៉ាងពេញលេញ វាហាក់ដូចជាសេចក្តីអាថ៌កំបាំងដល់មនុស្ស គ្រប់រូប។

8-10, “ក្រាំងនេះនឹងធ្វើឱ្យពោះឯងល្វីង តែនៅក្នុងមាត់នឹងបានផ្អែមដូចទឹកឃ្មុំ” សូម អាន អេសេគាល 2:8, 3:1-3 កិច្ចការ 15:16។ ការបកស្រាយព្រះបន្ទូលគឺដូចតទៅ នេះ។ ពីព្រោះសៀវភៅតូចជាព្រះបន្ទូលរបស់ព្រះ នោះអ្នកដែលបានទទួលវានឹង

រីករាយនឹងរសជាតិយ៉ាងជ្រៅរបស់ដំណឹងល្អ។ (ប្រេចដានុស) វាជាបទពិសោធន៍នៃអំណរយ៉ាងផ្អែមល្ហែម។ តើវាមានន័យយ៉ាងណាដែរដែលវាល្វីងនៅក្នុងពោះនោះ? (1) វាមានន័យថា បន្ទាប់ពីហោរាបានទទួលវា ដូចដែលគាត់បានទស្សទាយដោយផ្ទាល់គាត់ជួបនូវបញ្ហាមួយចំនួន។ (2) ពីព្រោះ ខ្លឹមសារនៃទំនាយរាប់បញ្ចូលនូវគ្រោះចង្រៃនៃពួកដែលទាស់ប្រឆាំងនឹងព្រះគ្រីស្ទ (ជំពូក 13) នឹងមានទុក្ខលំបាករបស់ពួកបរិសុទ្ធ។ ដូច្នេះ ពីព្រោះការខ្វល់ខ្វាយរបស់យ៉ូហាននោះខ្លាំង នោះវានឹងបានក្លាយជារឿងបញ្ហាវិញ។

11 “ឯត្រូវទាយម្តងទៀត” “ទាយ” មានន័យថាការនិយាយតំណាងឱ្យព្រះ។ ដូច្នេះរឿងនេះមិនអាចត្រូវបានគេអនុវត្តដោយមិនទទួលបានការបើកសម្តែងគំនិតដោយគ្មានកំហុសទេ។ កិច្ចការនៃការបើកសម្តែងនូវសិទ្ធិអំណាចរបស់ព្រះផ្ទាល់មិនអាចត្រូវបានបង្កើតឡើងដោយគ្មានការធ្វើតាមលក្ខណៈនៃភាពពេញលេញរបស់ព្រះឡើយ។ ពាក្យដែលត្រូវទាយម្តងទៀតចង្អុលទៅលើព្រឹត្តិការណ៍ដែលនឹងត្រូវបើកសម្តែងនៅពេលអនាគត (ខ7) ពោលគឺគួរនិយាយថាទំនាយថ្មីដែលបានបើកសម្តែងចេញពី ខ 15 15 (ឆលស៍) ប៉ុន្តែអ្នកប្រាជ្ញមួយចំនួនបាននិយាយថា ទំនាយថ្មីនេះចង្អុលទៅលើការពិតដែលគាត់គួរតែប្រកាសពាក្យទាំងអស់ខាងក្រោម 11:1។ អ្នកដែលទទួលបេសកកម្មនៃការថ្លែងទំនាយនោះ ក្រោកឈរឡើងលើស្ថានភាពនោះថា គាត់មិនអាចប្រតិបត្តិវាបានឡើយ។ គាត់គឺជាអ្នកទោសរបស់ព្រះ។

ចំណុចសំខាន់

1. “អ្នកណាដែលជឿលើព្រះបន្ទូលរបស់ព្រះ នោះមានបទពិសោធក្នុងការទទួលព្រះបន្ទូលរបស់ព្រះដោយផ្អែមល្ហែមនិងបន្តរក្សាទុកទៀត។ ហើយគាត់គួរតែក្លាយជាអ្នក

ការពារព្រះបន្ទូលនៃព្រះដែលគាត់បានទទួលនោះ។ ហោរាអេសាយបាននិយាយទៅកាន់អ្នកយាមដែលគ្មានទំនួលខុសត្រូវថា “ពួកយាមល្បាតរបស់គេសុទ្ធតែខ្វាក់ភ្នែក គេគ្មានដំរិះគ្រប់គ្នា គេសុទ្ធតែជាឆ្កែគ ព្រុសមិនកើត គេតែងតែស្រម៉ើឃើញ គេចេះតែដេក ហើយចូលចិត្តតែលក់ទៅ” (អេសាយ 56:10)។

2. អ្នកដែលទទួលបានព្រះបន្ទូលរបស់ព្រះមានទំនួលខុសត្រូវនឹងថែរក្សាជីវិត និងសេចក្តីស្លាប់របស់ព្រលឹងរបស់អ្នកផ្សេង។ ដូច្នេះ កាលដែលគេមានកំហុស នោះគេគួរតែទទួលការដាក់ទោសពិត។ ដូច្នេះ កិច្ចការរបស់គេមានរសជាតិល្វីង។ (10, 11) តែនៅក្នុងពិភពរបស់ក្រុមជំនុំ មានគ្រូគង្វាលជាច្រើនដែលប្រព្រឹត្តដោយគ្មានទំនួលខុសត្រូវដោយការរើសតាំងដោយគ្មានទំនួលខុសត្រូវ ដោយគេគិតថាព័ន្ធកិច្ចរបស់គ្រូគង្វាលជាវិធីនៃការជោគជ័យ។ គ្រូគង្វាលដូច្នោះជាមនុស្សដែលមិនមានទំនួលខុសត្រូវ និងជាមនុស្សដែលធ្វើតាមចិត្តខ្លួនឯង។ ព្រះគម្ពីរមានបន្ទូលថា “បងប្អូនអើយ កុំឱ្យធ្វើជាគ្រូច្រើនគ្នាពេកឡើយ ពីព្រោះដឹងហើយថា យើងនឹងត្រូវទោសធ្ងន់ជាងគេ។” (យ៉ាកុប 3:1) ហើយ “ឯអ្នកណាដែលមិនបានស្គាល់ តែបានប្រព្រឹត្តគួរនឹងត្រូវរំពាត់នោះនឹងត្រូវវាយតិចវិញ ឯអស់អ្នកណាដែលគេប្រគល់ទុកជាច្រើនឱ្យ នោះគេនឹងទារជាច្រើនពីអ្នកនោះវិញ គេនឹងសូមលើសទៅទៀត ពីអ្នកនាដែលគេបានផ្ញើទុកជាច្រើនផង។” (លូកា 12:48) “ហេតុនោះត្រូវឱ្យយើងរាល់គ្នាចេញទៅឯទ្រង់ នៅខាងក្រៅទីដំឡើងត្រសាលដែរ ទាំងផ្ទុកសេចក្តីដំនៀលរបស់ទ្រង់ចុះ” ហើយ “ចូរស្តាប់តាម ហើយចុះចូលនឹងពួកអ្នក ដែលនាំមុខអ្នករាល់គ្នាចុះ ដើម្បីឱ្យអ្នកទាំងនោះបានថែរក្សាព្រលឹងអ្នករាល់គ្នាដោយអំណរ មិនមែនដោយស្រែកថ្ងូរទេ ដ្បិតបើត្រូវស្រែកថ្ងូរ នោះបង់ប្រយោជន៍ដល់អ្នករាល់គ្នាហើយ ពីព្រោះអ្នកទាំងនោះ ថែរក្សាហាក់ដូចជានឹងត្រូវ

រៀបរាប់ទូលដល់ទ្រង់វិញ។" (ហេព្រើរ 13:17)។ សូមអាន រ៉ូម 1:14, 1កូរិនថូស 9:16 ។ ពីព្រោះគ្រូគង្វាលជាមនុស្សដែលត្រូវមានទំនួសខុសត្រូវដូច្នោះ គ្រូគង្វាលចាស់ព្យាយាមមិនទទួលឋានៈទេ តែព្យាយាមគេពីវាវិញ។ លោក អូហ្គាស្ទីន ត្រូវបានជ្រើសរើសជាបីស្សបដែលគាត់មិនចង់បានទេ នៅ គ.ស 392 លោក អាំប្រូស បានក្លាយជាបីស្សបដែលគាត់មិនចង់បានទេ ហើយលោក កាល់វីន បានស្នាក់នៅ ក្រុងស៊ើនែវ និងបានទទួលតំណែងបរិសុទ្ធដោយការបង្ខំរបស់លោកហ្វារែល។

ការអធិប្បាយទី **34** ភាពផ្អែមនៃព្រះបន្ទូលរបស់ព្រះ (វិវរណៈ **10:9, 10)**

ក៏ដើរទៅរកទេវតានោះ ទាំងសុំអោយលោកប្រគល់ក្រាំងតូចមកខ្ញុំ។ លោកពោលមកកាន់ខ្ញុំថា៖ «ចូរយកក្រាំងនេះ ហើយបរិភោគវាទៅ។ ក្រាំងនេះនឹងធ្វើអោយអ្នកឈឺពោះ តែកាលនៅក្នុងមាត់ វាផ្អែមដូចទឹកឃ្មុំ»។ ខ្ញុំក៏ទទួលយកក្រាំងតូចពីដៃទេវតាមកបរិភោគ នៅក្នុងមាត់ខ្ញុំ វាផ្អែមដូចទឹកឃ្មុំ លុះបរិភោគរួចហើយ ខ្ញុំក៏ឈឺពោះ។" (វិវរណៈ 10:9, 10) "ការគោរពកោតខ្លាចព្រះអម្ចាស់ជាអំពើមួយល្អបរិសុទ្ធណាស់ ហើយស្ថិតស្ថេររហូតតទៅ។ វិន័យរបស់ព្រះអម្ចាស់ សុទ្ធតែត្រឹមត្រូវ និងសុចរិតទាំងអស់ គួរអោយប្រាថ្នាជាងមាសសុទ្ធដ៏ច្រើន ព្រមទាំងផ្អែមជាងទឹកឃ្មុំដែលហូរចេញពីសំបុកទៅទៀត។" (ទំនុកដំកើង 19:9, 10)។ យើងរៀនថាព្រះបន្ទូលរបស់ព្រះផ្អែមដល់យើង។ ដាវីឌបានសារភាពថា ព្រះបន្ទូលរបស់ព្រះផ្អែមជាងទឹកឃ្មុំ។ ហេតុអ្វីបានជាគាត់និយាយថាព្រះបន្ទូលរបស់ព្រះផ្អែម? យើងអាចបំបែកភាពផ្អែមជាពីរផ្នែក។

1. ភាពឯករាជ្យដ៏អស្ចារ្យរបស់ព្រះគម្ពីរ (αυτοπιστια)

វាមានន័យថា បទគម្ពីរផ្ទាល់លាតត្រដាងសេចក្តីពិតដោយមិនពឹងផ្អែកលើទីបន្ទាល់របស់មនុស្សទេ ព្រោះបទគម្ពីរខ្លួនឯងជាសេចក្តីពិត។ ប្រយោគនៃពាក្យដែលមនុស្ស

ចាស់យល់ច្រឡំថាជាកំហុស ត្រូវបានបង្ហាញឱ្យឃើញនៅពេលនេះ។ ដូចនឹងបទគម្ពីរមួយនេះដែលលោកបានបញ្ជាក់ដោយខ្លួនឯង នោះទីបំផុតទស្សនៈបែបនេះត្រូវបានយកឈ្នះបានដោយបទគម្ពីរ។

2. ទីបន្ទាល់នៃព្រះវិញ្ញាណបរិសុទ្ធ

អ្នកដែលអានបទគម្ពីរ ហើយបានទទួលទីបន្ទាល់ពីព្រះវិញ្ញាណបរិសុទ្ធ មានចិត្តក្តៅគគុក និងរីករាយក្នុងចិត្ត ដូចជាគាត់ត្រូវបានដោះស្រាយរាល់បញ្ហាលំបាកៗនៅក្នុងចក្រវាឡ ពីព្រោះព្រះបានបង្កើតមនុស្ស និងសកលលោក សង្ឃឹមថាគេនឹងស្គាល់បទគម្ពីរ សៀវភៅតែមួយគត់ដែលធ្វើឱ្យយើងបានស្គាល់វាយ៉ាងត្រឹមត្រូវតាមរយៈព្រះវិញ្ញាណបរិសុទ្ធ ដែលជាសេចក្តីសង្ឃឹមនឹងភ្លឺ។ យោងតាមលូកា 24:32 ការពិតដែលថាសិស្សពីរនាក់ដែលដើរទៅផ្លូវឆ្ពោះទៅអេម៉ោសបានធ្វើឱ្យបេះដូងក្តៅបានមកពីការទទួលបានព្រះគម្ពីរដោយព្រះយេស៊ូវ។ ពាក្យដែលថាក្តៅគឺ ខៃអូមេនេ (καιομένη) ជាភាសាក្រិក ដែលមានន័យថា "ដែលត្រូវឆេះ" ដែលយើងរំឭកនូវប្រវត្តិសាស្ត្រនៃមនុស្ស វាប្រៀបដូចជាកិច្ចការនៃសេចក្តីស្លាប់ ជាប្រវត្តិសាស្ត្រនៃគ្រោងឆ្អឹង។ នៅទីនេះយើងមិនអាចហាមឃាត់នូវភាពឯកាឡើយ។ ប្រៀបដូចជាពួកសាវ័កនៅអេម៉ុស យើងយល់ថាបទគម្ពីរនិងចិត្តរបស់យើងតែងផ្លាស់ប្តូរ យើងអាចយកឈ្នះភាពឯការបាន ហើយអាចឃើញលោកិយនៃសិរីល្អនិងព្រះពរបាន។

(1) ចាស្ទីន ជាអ្នកទស្សនៈវិទូ គាត់ជាសាសន៍សាម៉ារី ហើយបានកើតនៅដើមគ .សទី2 ហើយបានសិក្សាគ្រប់ទាំងទស្សនៈវិទ្យា និងគម្រូនៃសេចក្តីពិត។ គាត់បានកត់ចំណាំទស្សនៈវិទូរបស់ស្តូអីក ហើយក៏បានសម្គាល់គ្រប់ទស្សនៈវិទូទាំងនោះដូចជា ទស្សនៈវិទូរបស់លោកអារីស្តូត របស់លោកភីតាហ្គោរ៉ាស របស់ផ្លាតូ ជាដើម។ តែគាត់មិនអាចរកឃើញសេចក្តីពិតចេញពីនោះឡើយ ហើយគាត់មានអារម្មណ៍ឯកា ហើយ

បានដើរនៅលើឆ្នេរសមុទ្រ ហើយបានជួបបុរសចំណាស់ម្នាក់។ បុរសចំណាស់នោះបានសួរថា “តើអ្នកស្គាល់ខ្ញុំទេ? ហេតុអ្វីបានជាអ្នកសម្លឹងមើលមកខ្ញុំ?” រួចមកចាស្ទីនឆ្លើយថា “ខ្ញុំកំពុងស្វែងរកសេចក្តីពិត។” បុរសចំណាស់នោះបាននាំចាស្ទីនទៅកាន់ព្រះគម្ពីរសញ្ញាចាស់។ ចាប់ពីពេលនោះមកចាស្ទីនបានអានសញ្ញាចាស់ ហើយបានយល់សេចក្តីពិតយ៉ាងច្រើន ហើយបានកត់ត្រាវាជាឯកសារដែលមានការវែកញែក និងបានប្រកាសវាទៅកាន់អ្នកផ្សេងទៀត។ គាត់បានផ្ញើការសរសេរនោះទៅកាន់អធិរាជថា “អ្នកអាចសម្លាប់ខ្ញុំ តែមិនអាចធ្វើឱ្យយើងមានគ្រោះថ្នាក់ទេ”។ បន្ទាប់ពីនោះមក គាត់ក៏ត្រូវបានគេសម្លាប់។

(2) អហ្គាស្ទីនបានកើតនៅ គ.ស ឆ្នាំ 354 ហើយត្រូវបានពុករលួយតាំងពីនៅវ័យជំទង់របស់គាត់ ហើយបានវង្វេងនៅគ្រប់កន្លែង។ នៅគ.សឆ្នាំ 386 គាត់ត្រូវបានធ្លាក់ចុះទៅក្នុងការលទ្ធិដែលសង្ស័យ។ តែនៅក្នុងតំបន់ អ៊ីមរ៉ាន កាលដែលគាត់បានស្តាប់ទៅកានពាក្យរបស់ក្មេងប្រុសម្នាក់ថា "លើកមកអានមក"។ បន្តិចមកគាត់បានបើកគម្ពីរ ហើយអានរ៉ូម 13:11-14 ហើយចិត្តរបស់គាត់ត្រូវបានបញ្ឆេះ ហើយបានថ្វាយខ្លួនគាត់ទៅកាន់ព្រះអម្ចាស់។ គាត់និយាយថា “ព្រះអម្ចាស់អើយ ទ្រង់បានបង្កើតយើងសម្រាប់អង្គទ្រង់ ចិត្តរបស់យើងគ្មានសេចក្តីសុខសាន្តទេ ដោយសារយើងសម្រាកនៅក្នុងទ្រង់។”

(3) លូធើត្រូវបានតែងតាំងធ្វើជាសង្ឃនៅខែ ឧសភា ទី2 1507 តែកាត់មិនបានស្គាល់ពីសេចក្តីពិតទេ។ ក្រោយមក គាត់បានដឹងថា ក្រុងរ៉ូមជាប្រាសាទមួយដែលបរិសុទ្ធ ដូចជាទីបរិសុទ្ធបំផុត ហើយពីព្រោះ គាត់គិតថាការទៅលេងក្រុងរ៉ូមជាសកម្មភាពមួយដើម្បីទទួលបានព្រះពរនៅ ឆ្នាំ 1952 (?)គាត់បានឆ្លងកាត់ភ្នំ Alps ឆ្លងកាត់វាល Ribald ហើយឆ្ពោះទៅទីក្រុងរ៉ូម។ ក្នុងអំឡុងពេលដែលគាត់ស្នាក់នៅ

Bologna នៅតាមផ្លូវគាត់បានឈឺហើយបានជាសះស្បើយ។ ហើយបានឮសំឡេងនៃបទគម្ពីរថា “មនុស្សសុចរិតនឹងបានរស់នៅដោយសេចក្តីជំនឿ” ខ្លាំង។ គាត់បានទទួលអារម្មណ៍ខ្លាំងចំពោះបទគម្ពីរដូចគ្នានឹងគាត់បានបង្រៀនជនជាតិរ៉ូម ហើយបន្ទាប់មក នេះជាបទពិសោធន៍ទីពីរ។ បន្ទាប់ពីជំងឺរបស់គាត់បានជាសះស្បើយ គាត់បានក្រោកឡើង ហើយចេញដំណើរទៅទីក្រុងរ៉ូម ហើយបានមកដល់កន្លែងដែលមានគោលបំណងតាមឆ្លងកាត់ភ្លូរិន។ គាត់បានឡើងលើជណ្តើរ (Acela Sancta = ជណ្តើរបរិសុទ្ធ) ព្រោះប្រសិនបើមនុស្សនោះឡើងម្តងដោយ លត់ជង្គង់ នោះអំពើបាបប្រមាណ15 ឆ្នាំត្រូវបានសម្អាត។ បន្ទាប់មកក្នុងការឡើងទៅទីនោះ លូធើបានទទួលអារម្មណ៍នូវពាក្យថា “មនុស្សសុចរិតរស់នៅដោយសេចក្តីជំនឿ” យ៉ាងខ្លាំងម្តងទៀត។ គាត់បានយល់ថាគាត់បានដឹងថាគាត់គួរតែជឿតាមបទគម្ពីរបានត្រឹមត្រូវ។ គាត់បានបោះបង់ចោលប្រពៃណីរបស់រ៉ូម៉ាំងចេញ។

(4) Calvin បានដើរតាមផ្លូវ ហើយមើលរូបភាពរបស់លោកឪពុកទាហាន និងពលរដ្ឋត្រូវបានប្រមូលផ្តុំ ហើយដុតបុរសបាតុករម្នាក់។ គាត់បានឃើញរូបដ៏រីករាយដោយសន្តិវិធី ដែលពួកបរិសុទ្ធមានក្នុងសេចក្តីស្លាប់។ ពេលនោះគាត់គិតតែម្នាក់ឯងក្នុងចិត្តថា “តើធ្វើម្តេចឱ្យពួកបរិសុទ្ធដែលស្លាប់ក្នុងសភាពឆេះក្នុងភ្លើងនោះបានសប្បាយយ៉ាងនេះ? ខ្ញុំគ្មានការមួយនេះទេ? គាត់ត្រូវបានដុតដោយភាពក្លាហាន។ ហេតុអ្វីបានជាគាត់ទទួលបានភាពក្លាហានបែបនេះក្នុងស្ថានភាពដ៏អាក្រក់បែបនេះ? ត្រឹមត្រូវហើយ។ សូមសិក្សាបទគម្ពីរតាមការណែនាំរបស់សាច់ញាតិរបស់ខ្ញុំ អូលីវេតាន់! ចូរស្វែងរកវិធីថ្មី!»។ គាត់បានបើកបទគម្ពីរ។ ក្នុងចំណោមនោះ គាត់បានអានបទគម្ពីរ គាត់មានអារម្មណ៍ថាស្ថានភាពដ៏អាក្រក់។ គាត់មិនអាចទ្រាំទ្រនឹងអារម្មណ៍នៃកំហុសនៅក្នុងចិត្តបានទេ។ (D' Aubigne, Reform in Europe

សៀវភៅទី 2. ជំពូក 7.) គាត់ហាក់ដូចជាបើករន្ធដ៏ជ្រៅដែលមិនអាចវាស់វែងបាន។ ដោយសារគាត់រន្ធត់ខ្លាំងណាស់ គាត់បានឈប់អានបទគម្ពីរ ហើយអានវាជាបន្ត បន្ទាប់ គាត់បានយល់ពីរូបភាពដែលព្រះគ្រីស្ទត្រូវរងទុក្ខ ច្បាស់ណាស់ គាត់បានទទួលសន្តិភាពក្នុងចិត្តគាត់។ បន្ទាប់ពីគាត់បានយល់ពីដំណឹងល្អនៅក្នុងបទគម្ពីរ គាត់មានការចង់បារម្ភខ្លះនៅក្នុងចិត្តចំពោះបញ្ហាពិបាកក្នុងការចាកចេញពីក្រុមជំនុំរ៉ូម។ ការចាកចេញពីព្រះវិហារគឺជាបញ្ហាដ៏អាក្រក់ដូចជាការបំបែកឈ្មោះរបស់គាត់ចេញពីសៀវភៅ។ គាត់ពិបាកនៅក្នុងចិត្ត" "តើខ្ញុំអាចដើរទៅកាន់មនុស្សដែលត្រូវបានបោះចេញពីក្រុមជំនុំដ៏ធំយ៉ាងដូចម្តេច?" តែចុងក្រោយគាត់បានដោះស្រាយបញ្ហានេះតាមរយៈបទគម្ពីរ។ គាត់គិតថា "ដោយគ្មានសេចក្តីពិត ក្រុមជំនុំរ៉ូមមានការរុករកឃើញដែលល្ងីល្ងើ ខុសឆ្គង និងពិធីដែលគោរពព្រះក្លែងក្លាយ តែហាសគមន៍ដែលនឹងត្រូវរកឃើញដោយពួកគេមិនត្រូវបានហៅថាជាក្រុមជំនុំទេ។" ជាចុងក្រោយ គាត់បានក្រោកឈរឡើងនៅខាងមុនការកែទម្រង់។ គាត់ស្មោះត្រង់ទៅកាន់ព្រះជាម្ចាស់ដូចជាសាសនៈវិទូ ដែលចាត់ទុកបទគម្ពីរជាស្តង់ដាតែមួយនៃជំនឿនៅពេញមួយជីវិត។ មុនពេលគាត់ចាកចេញពីលោកិយ គាត់បានអធិស្ឋានអស់រយៈ8ថ្ងៃជាបន្ត ហើយភ្នែករបស់គាត់អ៊ីវ៉ង់ហូតដល់ទីបញ្ចប់ ហើយបង្ហាញពីសង្ឃឹមរបស់គាត់ទៅកាន់ពិភពលោកនាពេលអនាគត។ មុនពេលគាត់ស្លាប់គាត់ទន្ទិញដដែលថា "ខ្ញុំរាប់អស់ទាំងសេចក្តីទុក្ខលំបាកនៅជាន់នេះ ថាជាសេចក្តីមិនគួរប្រៀបផ្ទឹមនឹងសិរីល្អ ដែលនឹងបើកសំដែងមកឱ្យយើងរាល់គ្នាឃើញនោះទេ" (រ៉ូម 8:18) នៅក្នុងពេលចុងក្រោយរបស់គាត់ គាត់មិនបានបញ្ចប់វាទេ ហើយពេលនោះគាត់ក៏ដាច់ដង្ហើមទៅ។

ដូចដែលយើងក៏បានទទួលទីបន្ទាល់នៃព្រះវិញ្ញាណបរិសុទ្ធ ទស្សនៈនៃព្រះ ទស្សនៈនៃលោកិយ ទស្សនៈនៃជីវិត និងទស្សនៈនៃសេចក្តីសង្គ្រោះត្រូវបានដោះស្រាយ ហើយបន្ទាប់មកមានទំនុកចិត្តចំពោះការពិត។ នេះគឺជារសជាតិផ្អែមនៃព្រះបន្ទូលរបស់ព្រះ។

ជំពូកទី 11

វាពិបាកក្នុងការដឹងពីអត្ថន័យនៃជំពូកនេះ តែប្រសិនបើយើងដឹងពីអត្ថន័យនៃ “42 ខែ” នៅក្នុងខ 2 បានត្រឹមត្រូវ នោះយើងអាចយល់ផ្នែកមួយចំនួន។ វានិយាយពីការបកស្រាយមួយចំនួននៃពាក្យ “42 ខែ” នៅទីនេះ។

1. គំនិតរបស់អ្នកប្រាជ្ញនៅក្នុងកម្មវិធីពីអតីតកាល

ពួកគេបាននិយាយថាវិវរណៈត្រូវបានសរសេរមុនពេលការបំផ្លិចបំផ្លាញនៃក្រុងយេរូសាឡឹម “42 ខែ” ចង្អុលទៅរយៈពេល (ពីនិទាឃរដូវ គ.ស 67 ដល់រដូវស្លឹកឈើជ្រុះ គ.ស 70) ដែលរ៉ូមត្រូវបានលុកលុយដែលបានកាន់កាប់ក្រុងយេរូសាឡឹមនៅ គ.ស 70។ ប៉ុន្តែនេះគឺជាការបកស្រាយដែលយល់ច្រឡំពីកាលបរិច្ឆេទនៃការសរសេរកណ្ឌគម្ពីរវិវរណៈទេ។ ការពិតដែលថាវិវរណៈត្រូវបានសរសេរបន្ទាប់ពីការបំផ្លាញក្រុងយេរូសាឡិមគឺជាគំនិតត្រឹមត្រូវរបស់អ្នកប្រាជ្ញទូទៅ។

2. ក្រុមអ្នកប្រាជ្ញរបស់ប្រវត្តិសាស្ត្រក្រុមជំនុំនិយាយថា “42 ខែដូចគ្នានឹង 1260 ថ្ងៃដែរ (និមិត្តសញ្ញានៃ 1260 ឆ្នាំ)។ អ្នកប្រាជ្ញម្នាក់នៅក្នុងក្រុមនោះនិយាយថា វាជា

កាលបរិច្ឆេទដែលត្រូវបានរាប់ពីការចាប់ផ្តើមនៃចលនានៃសេចក្តីពីតរបស់ ក្រុមរបស់ វ៉ាល់ដូ (គ.ស 1170) ឬ វាជាកាលបរិច្ឆេទដែលត្រូវបានរាប់ពីសម័យកំណែទម្រង់ របស់លូធើ។ (1517 ឆ្នាំ)

3. គំនិតរបស់ពួកអ្នកប្រាជ្ញនៃក្រុមដែលបញ្ចប់ចុងក្រោយ។ បុរសម្នាក់នៅក្នុង ចំណោមពួកគបាននិយាយថា នេះគឺបន្ទាប់ពីសាសន៍យូដាបានទទួលឯករាជ្យ មិន យូរប៉ុន្មានទេ ម្តងទៀត អំឡុងពេលដែលពួកគេនឹងបានចូលទៅកាន់កាប់លើអ្នកមិន ជឿ។

4. លោក ហ្គ្រេចដានុស មើលឃើញព្រះវិហារថាជាការប្រៀបធៀបទៅនឹងក្រុមជំនុំ 42 ខែជារយៈពេលទាំងមូលនៃព្រះគម្ពីរសញ្ញាថ្មី គាត់គិតថាអាសនានិងអ្នកថ្វាយបង្គំ នៅក្នុងនោះជាអ្នកជឿពិតប្រាកដ ហើយក្នុងពេលតែមួយ គាត់គិតថា ដីដែលនៅខាង ក្រៅព្រះវិហារជាមនុស្សដែលមានពុត។ ហើយសាក្សីពីរជានិមិត្តសញ្ញានៃអ្នកផ្សាយ ដំណឹងល្អនៅគ្រប់សម័យទាំងអស់។

ការបកស្រាយ

1 ដើមបបុសទុកជាខ្នាត សូមអាន អេសេគាល 40:3, 42:2។ ***"ចូរក្រោកឡើងទៅ វាស់ព្រះវិហារនៃព្រះ និងអាសនា ហើយនឹងពួកអ្នកដែលថ្វាយបង្គំក្នុងព្រះវិហារ ផង"*** ពាក្យថា "ព្រះវិហារ" គឺ ណាអូស (ναός) ក្នុងភាសាក្រិក ដែលមានន័យថា បរិសុទ្ធបំផុត។ រួចមកទីកន្លែងដែលបរិសុទ្ធបំផុត និងអាសនា និងអស់អ្នកដែល ថ្វាយបង្គំទីនោះ" ជាពាក្យប្រៀបធៀបដែលចង្អុលទៅកាន់ព្រះវិហារខាងវិញ្ញាណ ដែល ជាក្រុមជំនុំគ្រីស្ទាន។ (ឆលស៍ ស្វីត) តើ "ខ្នាត" មានន័យដូចម្តេច? នេះជាអត្ថន័យ និមិត្តសញ្ញានៃការស្តារឡើងវិញនូវទ្រព្យសម្បត្តិ ឬការគ្រប់គ្រងទ្រព្យសម្បត្តិ។ (អេរសេ

គាល 40:2 43:12)។ វាជាការប្រៀបប្រដូចមួយតាមរយៈការតាំងឡើងនូវព្រះគម្ពីរ សញ្ញាថ្មីនៃក្រុមជំនុំរបស់ព្រះ ដែលប្រមូលរាស្ត្រដែលបានរើសតាំងរបស់ព្រះ ចលនានៃដំណឹងល្អ ជាដើម។ នៅក្នុងគំនិតមួយ វាជាការប្រៀបធៀបដែលពួកយូដាខ្លះត្រឡប់ទៅរកដំណឹងល្អនៅក្នុងគ្រាចុងក្រោយនៃលោកិយនេះ។

2 តែទីលានដែលនៅខាងក្រៅនោះត្រូវចាលចេញកុំឱ្យវាស់វាឡើយ។ នេះមានន័យថា ត្រូវបដិសេធមនុស្សដែលថ្វាយបង្គំព្រះដោយរូបខាងក្រៅ ឬដោយមិនមានគោលបំណង ឬជាពិសេសនៅក្នុងសម័យនៃព្រះយេស៊ូវ និងពួកសាវក មនុស្សដែលអះអាងថាជាសាសន៍យូដាប៉ុន្តែមិនទទួលយកដំណឹងល្អចេញពីចលនាថ្មីរបស់អ៊ីស្រាអែល (ចលនានៃដំណឹងល្អ)។ (ស្វីត)។ ការក្លាយជាសាសន៍យូដាខាងក្រៅគឺមិនមែនជាគុណសម្បត្តិរបស់ជនជាតិអ៊ីស្រាអែលនោះទេ ប៉ុន្តែមានតែការជឿលើព្រះអម្ចាស់ដោយការរើសតាំងពីព្រះប៉ុណ្ណោះ ទើបជាគុណសម្បត្តិរបស់កូនចៅអ៊ីស្រាអែល។(រ៉ូម 9:6,7)

ដ្បិតបានឱ្យទីនោះដល់សាសន៍ដទៃហើយ ការនេះចង្អុលថា ពួកយូដាបានបាត់បង់ប្រទេស តែត្រូវពង្រាយនៅគ្រប់ទីកន្លែង ពួកសាសន៍ដទៃនឹងគ្រប់គ្រងផែនដី ដែលនោះជាការដែលព្រះយេស៊ូវទាយទុក (លូកា 21:24)។ ដ្បិតអំពើបាបដែលពួកគេបដិសេធដំណឹងល្អ ដែលពួកគេបានធ្វើដូច្នោះ។

អស់រាំង 42ខែ នេះហាក់ដូចជារយៈពេលដែលអាចបកប្រែពាក្យ ដានីយ៉ែល 9:24-27។ 42 ខែនៅក្នុងសៀវភៅរបស់ដានីយ៉ែលជាផ្នែកដំបូងនៅក្នុងគ្រាចុងក្រោយបង្អោះរបស់លោកិយ។ ផ្នែកចុងក្រោយនឹងពោរពេញដោយទុក្ខវេទនាយ៉ាងធ្ងន់ធ្ងរ វាដូចជាអ្វីដែលជំពូកទី 13 នៅក្នុងវិវរណៈបានសរសេរ ប៉ុន្តែផ្នែកទីមួយនៅខាងលើមិនមែនជា

ឆ្នាំតាមន័យទ្រង់ទេ ប៉ុន្តែជាឆ្នាំបែបនិមិត្តសញ្ញា ប៉ុន្តែចង្អុលទៅរឿងទាំងមូលនៃថ្ងៃ ទាំងមូលនៃគម្ពីរសញ្ញាថ្មី មុនពេលសកម្មភាពនៃអស់អ្នកដែលប្រឆាំងនឹងព្រះគ្រីស្ទ។ បន្ទាប់មកវាចង្អុលទៅពេលវេលានៃអ្នកមិនជឿនៅក្នុងកណ្ឌគម្ពីរនៃដំណឹងល្អ ។ (លូកា 21:24)

បន្ទាល់អញ្ជើទាំងពីរនាក់ ការបកស្រាយពាក្យនេះមានការយល់ឃើញពីរយ៉ាង។ (1) លោក ឆលស៍ បាននិយាយថា ចំណុចនេះដែលម៉ូសេ ជាអ្នកតំណាងនៃក្រិត្យវិន័យ និងអេលីយ៉ា ដែលជាតំណាងនៃទំនាយនឹងត្រូវបានបង្ហាញនៅថ្ងៃចុងក្រោយនៃពិភពលោកនេះ។ (2) នៅក្នុងឃ្លាបន្ទាប់ “ដើមអូលីវពីរដើម និងជើងចង្កៀងពីរដែលឈរនៅចំពោះព្រះអម្ចាស់នៃផែនដី” ពាក្យដែលទាក់ទងនឹងសាការី 4:14 នៅទីនេះ “សាក្សីពីរនាក់” ចង្អុលទៅកាន់ព្រះវិហារ។ សាការី ជំពូក 3, 4 បានចាត់ទុកថា យ៉ូស្វេ ជាសង្ឃជាន់ខ្ពស់ និងស៊ូរូបាបិល ជាអ្នកសង់ព្រះវិហារបរិសុទ្ធក្រុងយេរូសាឡិមត្រូវបានចាត់ទុកជាតំណាងនៃព្រះវិហារនៅសម័យនោះ។(នេហេមា 7:5-7)។ ដូច្នេះ ពួកគេត្រូវបានជាតំណាងឱ្យព្រះវិហារនៅសម័យនោះ។ ដូច្នេះ “សាក្សីពីរនាក់” នៃជំពូក និងខគម្ពីរទាំងនេះនៅក្នុងវិវរណៈ ក៏ជានិមិត្តសញ្ញានៃក្រុមជំនុំនៃព្រះគម្ពីរសញ្ញាថ្មីដែរ ។ ប៉ុន្តែ លោក ព្រ្គេចដានុស មានន័យថាវាចង្អុលប្រាប់សាក្សីពីរនាក់នោះថាជា “សាក្សីរបស់ព្រះអម្ចាស់” (zij worden in ons vers getuigen van den Heere genoemd) ដែលមានន័យថាសាក្សីពិតនៅក្នុងក្រុមជំនុំ។ ការបកស្រាយនេះក៏លាតត្រដាងថា សាក្សីទាំងពីរនាក់មានន័យគឺចង្អុលទៅក្រុមជំនុំ ពីព្រោះសាក្សីពីរនាក់នៅក្នុងជំពូកទាំងនេះ និងខគម្ពីរនៃវិវរណៈចង្អុលទៅសាក្សីពិតដែលប្រកាសដំណឹងល្អ។ ចំនួនពីរនៃសាក្សីត្រូវការវា ដើម្បីបង្កើតភាពស្មោះត្រង់នៅក្នុងទីបន្ទាល់។ (ចោទិយក

ថា 19:15) ពេលព្រះយេស៊ូចាត់សិស្សរបស់ទ្រង់ឱ្យទៅផ្សាយដំណឹងល្អ គឺបញ្ជូនមនុស្សពីរនាក់ដោយចេញពីមូលហេតុនេះ។ ហើយបទគម្ពីរក៏បានចែងថា មនុស្សពីរនាក់ជាអត្ថន័យនៃកិច្ចសហប្រតិបត្តិការ។(សាស្តា 4:9, 12)

ទាំងស្លៀកពាក់សំពត់ធ្មៃផង នេះជានិមិត្តសញ្ញានៃការប្រែចិត្តនៃការទួញសោក (សូមអាន 1ពង្សាវតារក្សត្រ 21:27, ម៉ាថាយ 11:21)។ សេចក្តីសោកសង្រេងនៃការប្រែចិត្តរបស់ពួកគេបានកើតឡើងមិនមែនដោយសារបាបរបស់ពួកគេទេ តែគឺដោយសារអំពើបាបរបស់មនុស្សនៅក្នុងលោកិយ។ ហោរា និងអ្នកផ្សាយដំណឹងល្អមានទំនួលខុសត្រូវទាក់ទងនឹងអំពើបាបរបស់អ្នកផ្សេង (ហេព្រើរ 11:17) ហើយប្រគល់ឱ្យនូវសេចក្តីសង្គ្រោះនៃព្រលឹងរបស់ពួកគេផង (អេសេគាល 3:16-21)។

1,260 ថ្ងៃ វាជាអត្ថន័យតែមួយនឹងពាក្យ 42 ខែនៅខាងលើ ដែលចង្អុលទៅកាន់ថ្ងៃនៃគ្រាគម្ពីរសញ្ញាថ្មី។ គ្រានៃក្រុមជំនុំសញ្ញាថ្មីដែលជានិមិត្តសញ្ញានៃការប្រកាសដំណឹងល្អ។

ដើមអូលីវទាំងពីរ ហើយជាចង្កៀងទាំងពីរ ពាក្យនេះគឺមានន័យដូចគ្នានឹងពាក្យសាក្សីពីរនាក់នៅក្នុងខ 3។ យោងទៅតាមសាការីជំពូក 4 ពីព្រោះ "ដើមអូលីវពីរ" គឺជាប្រភពសម្រាប់ផ្តល់ប្រេងដល់ជើងចង្កៀងពីរ វាគឺជានិមិត្តសញ្ញានៃសរីរាង្គដែលត្រូវមានកិច្ចការវិញ្ញាណបរិសុទ្ធ។ ក្រុមជំនុំពិតគឺជាកិច្ចការរបស់អ្នកធ្វើបន្ទាល់ដែលប្រកាសដំណឹងល្អ ទោះបីជាយើងនិយាយថា វាចង្អុលទៅសាក្សីនៃដំណឹងល្អក៏ដោយ វាមិនខុសពីការបកស្រាយដែឡចង្អុលទៅក្រុមជំនុំនោះទេ។

5, 6 ដ្បិតខទាំងនេះជាការបង្ហាញពីប្រភេទនៃនិមិត្តសញ្ញា យើងមិនត្រូវការមើលទៅកាន់វាដោយន័យត្រង់នោះទេ។ កាលដែលយើងបានឃើញវាក្នុងន័យត្រង់ នោះវា

ពិបាកក្នុងការបកស្រាយឃ្លានោះណាស់ “ភ្លើងចាក់ទៅក្នុងមាត់របស់ពួកគេ”។ ឃ្លានេះជាពាក្យ ដែលទ្រង់មានបន្ទូលវាដោយរក្សានៅក្នុងគំនិតនូវសកម្មភាពរបស់ម៉ូសេ (និក្ខមនំ 7:20) និងអេលីយ៉ា (1ពង្សាវតារក្សត្រ 7:1, 2ពង្សាវតារក្សត្រ 1:9-12)។ វាហាក់ដូចជាមានន័យថា ក្រុមជំនុំមានអំណាចខាងវិញ្ញាណដូចជាអេលីយ៉ា។ ព្រះយេស៊ូវមានបន្ទូលពីកិច្ចការអស្ចារ្យដែលអ្នកធ្វើការក្នុងក្រុមជំនុំនៅក្នុងគ្រានៃសញ្ញាថ្មីគួរធ្វើ។ (ម៉ាថាយ 21:21, ម៉ាកុស 16:17, 18 យ៉ូហាន 14:12-14)។

7 កាលណាពីរនាក់នោះបានធ្វើបន្ទាល់ពួចត្រួចហើយ អ្នកធ្វើបន្ទាល់ពិតនៃដំណឹងល្អដែលព្រះទ្រង់បានតាំងឡើងមិនស្លាប់មុនកិច្ចការនោះបានសម្រេចទេ។ លោក វីល្លីហ្វ ដែលជាអ្នកប្រកាសពីការកំណែទម្រង់ប្រហែល 100 ឆ្នាំយូរជាងលោកលូធើ គាត់ជាអ្នកសរសេរដែលជោគជ័យដោយការតវ៉ានឹងអំណាចរបស់រ៉ូម៉ាំងកាតូលិក។ នៅពេលដែលគាត់ប្រឆាំងដូច្នោះ មនុស្សខាងលោកិយបានគិតថាគាត់នឹងមិនរស់ទេ នោះគាត់នឹងស្លាប់ តែជាចុងក្រោយ គាត់ស្លាប់នៅពេលគាត់ចាស់ហើយគឺតាមគម្រោងផែនការរបស់ព្រះ។

សត្វសាហាវដែលឡើងមកពីជង្ហុកធំ ការនេះមិនមែនមានន័យថា ទីបំផុតសត្វនោះចេញមកក្រៅជង្ហុកធំទេ ប៉ុន្តែវាបានបង្ហាញពីទីតាំងរបស់វាយ៉ាងច្បាស់។ នោះគឺដោយសារសត្វជារបស់ដែលនៅក្នុងជង្ហុកធំ នោះវាមានអត្ថន័យពីអំពើដ៏ឃោរឃៅដូចសត្វដែលបានបង្ហាញក្នុងឃ្លានោះ។ សត្វនេះមានន័យថាជាអ្នកដែលប្រឆាំងនឹងព្រះគ្រីស្ទ វាបានកើតឡើងជាច្រើនដងពីសម័យដើម ហើយត្រូវបានគេប្រើដើម្បីបំផ្លាញ។ (ចូលទៅក្នុងជង្ហុកធំ) ឧទាហរណ៍ ពួកវាជាប្រទេសអេស៊ីប បាប៊ីឡូន ក្រិក។ល។

បន្ទាប់មក សត្វដែលខគម្ពីរចែង គឺជាពេលវេលាដែលនគរដែលទាស់ប្រឆាំងនឹងព្រះគ្រីស្ទនឹងត្រូវបានបង្ហាញជាផ្នែកចុងក្រោយនៃ 7 ឆ្នាំ។ សូមអាន ដានីយ៉ែល 9:27។

និងច្បាំងនឹងគេ ការនេះបង្ហាញពីការពិតខ្លះនៃជំពូក 13 រួចហើយ (13:5-7)។

8 ខ្មោចគេទាំងពីរនាក់ "ខ្មោច" គឺ ផ្តូម៉ា (πτῶμα) ក្នុងភាសាក្រិក ដែលសាមញ្ញដែលចង្អុលទៅកាន់ប្រព័ន្ធប្រមូលផ្តុំ។ ដូចដែលយើងឃើញថា អ្នកធ្វើបន្ទាល់ពីរនាក់ខាងលើមិនមែនជាមនុស្សពីរនាក់ទេ តែជាប្រព័ន្ធដែលប្រមូលផ្តុំដែលហាក់ដូចជាកម្មករជាច្រើននៅក្នុងក្រុមជំនុំ។ ពាក្យនេះគឺសាមញ្ញ តែមានន័យនៃនាមដែលប្រមូលផ្តុំ។

នឹងដេកនៅផ្លូវទីក្រុងធំ មនុស្សខាងលោកិយប្រឆាំងនឹងក្រុមជំនុំតែងតែមើលងាយដល់អ្នកដែលត្រូវគេសម្លាប់ ហើយដើរជាន់សពរបស់ពួកគេ ហើយប្រមៀលពួកគេនៅលើផែនដី។

ដែលខាងព្រលឹងវិញ្ញាណហៅថាក្រុងសូដុំម ហើយស្រុកអេស៊ីព្ទ ដ្បិត "ក្រុងសូដុំម" ជាអ្នកដែលមិនកោតខ្លាចព្រះ ហើយសីលធម៌ត្រូវបានធ្លាក់ចុះ (2 ពេត្រុស 2:6,7)។ ព្រះទ្រង់បានដាក់ទោសពួកគេ "ស្រុកអេស៊ីព្ទ" គឺសាហាវ ពួកគេបានបៀតបៀនរាស្ត្ររបស់ព្រះយ៉ាងខ្លាំង។ ពួកគេគ្មានសេចក្តីកោតខ្លាចដល់ព្រះ ខូចខាងសីលធម៌ ការបៀតបៀនគ្រីស្ទានជាលក្ខណៈរបស់លោកិយ ជានគរនៃអ្នកដែលប្រឆាំងនឹងព្រះគ្រីស្ទយ៉ាងខ្លាំង។ ដូច្នេះ អ្នកជឿត្រូវរងទុក្ខ ហើយត្រូវគេមើលងាយនៅក្នុងនគររបស់អ្នកដែលប្រឆាំងនឹងព្រះគ្រីស្ទដូចជាសូដុំម និងអេស៊ីព្ទ។

នៅក្រុងនោះឯងដែលមនុស្សបានឆ្កាងព្រះអម្ចាស់នៃអ្នកទាំងពីរនោះ។ កន្លែងដែលព្រះអម្ចាស់ត្រូវគេឆ្កាងជាពាក្យដែលប្រើបែបខាងវិញ្ញាណដែលចង្អុលទៅកាន់ "កុលកូថា"

ដែលជាលោកិយដែលអាក្រក់បំផុត។ លោកិយនេះជាកន្លែងដែលបានចាប់ព្រះគ្រីស្ទ ហើយងបានសម្លាប់ទ្រង់។ តែពេលខ្លះ លោកិយអាចបង្ហាញពីអ្នកជឿដែរ។ តែនេះគ្រាន់តែជារូបរាងក្លែងក្លាយប៉ុណ្ណោះ។ អ្នកណាដែលជឿដល់លោកិយនឹងត្រូវវិនាស។

9 នោះនឹងមានមនុស្សពីគ្រប់ទាំងគ្រួសារ ពូជមនុស្ស ភាសា និងសាសន៍ទាំងប៉ុន្មាន សូមអានការបកស្រាយនៃ 5:9។

បានឃើញខ្មោចគេ នៅអស់ទាំងថ្ងៃកន្លះ មិនព្រមឱ្យអ្នកណាកប់ឡើយ។ ការនេះប្រាប់ពីរយៈពេលនៃនគររបស់អ្នកដែលទាស់នឹងព្រះគ្រីស្ទ (3ឆ្នាំកន្លះ) ជាកិច្ចការនៃការបៀតបៀនដល់ពួកបរិសុទ្ធដែលមិនព្រមឈប់។ ហេតុផលដែលព្រះអនុញ្ញាតឱ្យខ្មោចរបស់អ្នកធ្វើបន្ទាល់ត្រូវគេមើលងាយគឺដើម្បីនឹងគ្របបាំងពួកគេដោយសិរីល្អខ្លាំងថែមទៀតនៅក្នុងលោកិយដែលនឹងមកដល់។

10 ហើយមនុស្សនៅផែនដីទាំងប៉ុន្មាន គេនឹងមានសេចក្ដីអំណរ ហើយរលេងសប្បាយពីដំណើរអ្នកទាំងពីរបានស្លាប់ហើយ។ ការនេះជាសញ្ញានៃហោរាពិតប្រាកដ។ ហោរាក្លែងក្លាយបញ្ឆោរមនុស្ស (យេរេមា 6:14, 8:11) មិននិយាយអំពើបាបរបស់ពួកគេត្រឹមត្រូវទេ ហើយមិនព្យាបាលពួកគេផង។ តែហោរាពិត (អេសេគាល 2:7, 2ធីម៉ូថេ 4:2) ស្តីបន្ទោសដល់អំពើបាបរបស់ពួកគេ មិនថាមនុស្សព្រមស្តាប់ដល់គាត់ ឬអត់នោះទេ។ ដូច្នេះ ពួកគេទទួលបានការស្អប់ពីមនុស្សខាងលោកិយ។ យ៉ូហាន 15:18-21

11 ក្រោយបីថ្ងៃកន្លះនោះមក ព្រះវិញ្ញាណនៃជីវិតដែលមកពីព្រះក៏ចូលក្នុងខ្មោចទាំងពីរ រួចគេក្រោកឈរឡើង នេះជាទំនាយដែល បន្ទាប់ពីអ្នកដែលប្រឆាំងនឹងព្រះគ្រីស្ទកន្លងផុតទៅ (ដ្បិតព្រះគ្រីស្ទនឹងមកម្តងទៀត) អ្នកជឿដែលស្លាប់ដ្បិតព្រះអម្ចាស់នឹងប្រោស

គេឱ្យរស់ឡើងវិញ ហើយហាក់ដូចជាឆាប់និយាយមុន 20:5 ដែលចង្អុលទៅកាន់។ កាលដែលព្រះទ្រង់បង្កើតមនុស្ស ទ្រង់បានផ្តុំខ្យល់ដង្ហើមនៃអំណាចរស់នៅក្នុងច្រមុះរបស់ពួកគេ ហើយធ្វើឱ្យពួកគេមានជីវិតរបស់។

“អំណាចរស់” មិនមានន័យថាអំណាចខ្យល់ (ដង្ហើម) ទេ តែជាអំណាចដែលបង្កើតនូវអំណាចនៃជីវិតរស់នៅនៅក្នុងការរួបរួមរបស់ព្រះនិងមនុស្ស។ វាចង្អុលទៅថា មានតែព្រះមួយអង្គប៉ុណ្ណោះដែលមានចេស្តានៃការបង្កបង្កើត។ អំណាចនេះត្រូវបានបង្ហាញមកជាចម្បងកាលដែលទ្រង់បង្កើតមនុស្ស ហើយធ្វើឱ្យគេរស់ឡើង។ កាលដែលរូបកាយដែលស្លាប់នៃអ្នកធ្វើបន្ទាល់ទាំងពីរបានទទួលអំណាចរស់នេះ នោះពួកគេត្រូវបានស្តារឱ្យរស់ឡើងវិញ ហើយក៏ក្រោកឈរឡើយ “ហើយពួកអ្នកដែលឃើញក៏មានសេចក្តីភ័យខ្លាចជាខ្លាំង” ដ្បិតពួកគេបានឃើញអំណាចដែលមិនអាចរារាំងបានរបស់ព្រះ។ អ្នកដែលបៀតបៀនពិតជាមានពេលមួយដែលនឹងត្រូវភ័យខ្លាចដល់ពួកបរិសុទ្ធ។ វាជាពេលដែលព្រះទ្រង់ដាក់ទោសដល់ពួកគេពិតប្រាកដ។

13 ទីក្រុងនោះមួយភាគក្នុងដប់ក៏រលំអស់ទៅ ហើយមានមនុស្ស7ពាន់នាក់ស្លាប់ក្នុងខណៈដែលការក្រើកដីនោះ។ ពីព្រោះនៅទីនេះ 1/10 និង 7000 នាក់ ជាលេខនិមិត្តសញ្ញា វាពិបាកនឹងដឹងពីពួកគេដោយលេខទូទៅរបស់មនុស្សណាស់។ ការនេះធ្វើឱ្យពួកយើងដឹងថា កាលដែលព្រះទ្រង់ប្រទាននូវជ័យជំនះខាងវិញ្ញាណដល់ពួកបរិសុទ្ធ ហេតុការណ៍ដែលទ្រង់ដាក់ទោសដល់សត្រូវប្រាកដជាកើតឡើង។ ដូចដែលយើងបានមើលទៅកាន់ប្រវត្តិសាស្ត្រ ព្រះទ្រង់បានផ្តល់ការដាក់ទោសទៅកាន់ប្រទេសដែលបៀតបៀនដល់ក្រុមជំនុំ។ “រញ្ជួយដី” អាចជាការច្របូកច្របល់ខាងនយោបាយ។ “មួយភាគក្នុងដប់” ចង្អុលទៅកាន់ផ្នែកនៃលោកិយនេះ ហើយ “មនុស្ស7ពាន់នាក់”

ជាមនុស្សដែលនៅសេសសល់នៃនគររបស់ព្រះគ្រីស្ទ។ សេចក្តីវិនាសរបស់ពួកគេជាការសម្អាតទាំងស្រុងនូវអ្នកដែលទាស់នឹងព្រះគ្រីស្ទ ដែលទ្រង់បានមានបន្ទូលពីការដែលនៅគ្រាចុងក្រោយនៅជំពូក 19។

រួចមក ឯពួកមនុស្សដែលនៅសល់ គេមានចិត្តភ័យខ្លាច ក៏សរសើរដំកើងដល់ព្រះនៃស្ថានសួគ៌។ វាហាក់ដូចជាចង្អុលទៅការពិតដែលថាមនុស្សនៅក្នុងគ្រាចុងក្រោយនៃពិភពលោកនឹងត្រូវបានប្រែចិត្ត។ ព្រះដែលមានចិត្តមេត្តាមិនឈប់សម្រាកពីកិច្ចការប្រោសលោះរបស់ទ្រង់រហូតដល់ពេលចុងក្រោយបង្អស់។ ដូចដែលយើងឃើញឃ្លាថា រួចមកចំនួនដែលត្រូវសង្គ្រោះតាមរយៈការប្រែចិត្តនឹងមានច្រើនជាងចំនួនមនុស្សដែលនឹងត្រូវបំផ្លាញ។

*14 "**សេចក្តីវេទនាទីពីរ**"* ជាគ្រោះនៃត្រែទីប្រាំមួយ "សេចក្តីវេទនាទីបី" ជាគ្រោះនៃត្រែទីប្រាំពីរ។ សូមអាន 9:12។

15-18 នៅទីនេះ ព្រះគ្រីស្ទនឹងមកនៅលើផែនដីជាស្តេច និងមានបន្ទូលថា ទ្រង់នឹងកាត់ទោស និងសង្គ្រោះពួកបរិសុទ្ធ។ *"**នគរទាំងប៉ុន្មាននៅលើលោកិយ បានក្រឡប់ជានគររបស់ព្រះអម្ចាស់នៃយើងរាល់គ្នា និងជារបស់ព្រះគ្រីស្ទនៃទ្រង់ ហើយទ្រង់នឹងសោយរាជ្យ**"*(15) រហូតដល់ពេលដែលពិភពលោកត្រូវបានគ្រប់គ្រងដោយអ្នកកាន់អំណាចនៅលើអាកាស នោះគឺសាតាំង។ (ទោះបីជាការផ្តល់ជំនួយរបស់ព្រះគ្រប់គ្រងលើក៏ដោយ) ប៉ុន្តែចាប់ពីពេលនេះ ព្រះទ្រង់គ្រប់គ្រងលើវាទាំងស្រុង។ នេះជាទំនាយថា នៅពេលដែលព្រះគ្រីស្ទយាងមកម្តងទៀត ហើយបង្វែរពិភពលោកមកក្នុងព្រះវិញ នោះវានឹងត្រូវបានបង្ហាញដូចពេលបច្ចុប្បន្ន។ ខ 17 បាននិយាយថា "ទ្រង់ដែលបាន

គង់នៅពីដើម ហើយទ្រង់គង់នៅ" ហើយពាក្យថា "ហើយទ្រង់នឹងយាងមកនៅពេលអនាគត" មិនបង្ហាញឱ្យឃើញឡើយ។

ខែដលត្រូវជំនុំជំរះពួកមនុស្សស្លាប់ (ខ18) ព្រះទ្រង់ជាព្រះដែលមានគ្រប់អំណាចចេស្តាក្នុងការគ្រប់គ្រងលើរបស់ដែលបង្កើតមកទាំងអស់ មនុស្សស្លាប់ តែមិនត្រូវបានស្វែងរក ហើយត្រូវបានចាប់ឱ្យទទួលតាមកិច្ចការដែលគេបានធ្វើ។ ពាក្យថា "មនុស្សស្លាប់នឹងត្រូវជំនុំជំរះ" មានន័យថា ពួកគេនឹងត្រូវរស់ឡើងវិញ ហើយនឹងត្រូវកាត់ទោសនៅចំពោះព្រះភ័ក្ត្ររបស់ព្រះ។

នោះមានគេបើកព្រះវិហារនៃព្រះ នៅស្ថានសួគ៌ ហើយឃើញមានហឹបនៃសេចក្តីសញ្ញារបស់ទ្រង់នៅក្នុងព្រះវិហារនោះ។ "ហឹបនៃសេចក្តីសញ្ញា" ជានិមិត្តរូបនៃការតាំងសញ្ញាដែលព្រះទ្រង់បានតាំងឡើង ដែលថ្មនៃការតាំងសញ្ញាត្រូវបានគេបង្ហូច។ (ហេព្រើរ 9:4 និក្ខមនំ 25:22) ។ ការពិតដែលព្រះទ្រង់បង្ហាញវា មានន័យថាព្រះទ្រង់នឹងចងចាំពាក្យនៃការតាំងសញ្ញាដែលបានតាំងនឹងរាស្ត្ររើសតាំងរបស់ទ្រង់។

រួចមកវិធីសាស្ត្រដែលសម្គាល់ពួកគេត្រូវបានបង្ហាញមកជា **ផ្លេកបន្ទោរ សៀងសំឡេងផ្គរលាន់ កក្រើកដី និងព្រិលយ៉ាងធំៗ** ដែលនោះជានិមិត្តសញ្ញានៃការកាត់ទោសដ៏អស្ចារ្យ។

ចំណុចសំខាន់

1. យើងគួរតែវាស់ចិត្តរបស់យើងជានិច្ចដោយព្រះបន្ទូលរបស់ព្រះ ហើយគួរតែឆ្លុះបញ្ចាំងថា ខ្លួនយើងជាកម្មសិទ្ធនៃទីបរិសុទ្ធខាងក្នុង។ កាលដែលយើងបរាជ័យក្នុងការវាស់នេះ យើងគួរតែដឹងថា វាជាគ្រោះថ្នាក់ ហើយយើងគួរតែលន់តួបាបភ្លាម។

2. ខ 10, 11 បង្ហាញថា (1) ការរងទុក្ខនៃពួកបរិសុទ្ធនឹងមិនយូរ នឹងត្រូវបានរីកឡើងដោយសិរីល្អនៃសេចក្តីរស់ឡើងវិញ។ តែការសប្បាយដ៏អាក្រក់ដែលរីករាយនឹងការស្លាប់របស់ពួកបរិសុទ្ធនឹងត្រូវបានប្តូរទៅជាការភ័យខ្លាចយ៉ាងខ្លាំងវិញមួយរយៈខ្លីក្រោយមក។ (2) បើទោះជាមនុស្សបៀតបៀនដល់ពួកបរិសុទ្ធមានអំណាចខ្លាំងក៏ដោយ ពួកគេនឹងមានការពីរដែលពួកគេអាចហាមបាន នោះគឺ 1) មុនគ្រាកំណត់របស់ព្រះមកដល់ ពួកគេមិនអាចឈប់ប្រកាសដំណឹងល្អដោយពួកបរិសុទ្ធបានទេ (2) កាលដែលពួកបរិសុទ្ធដែលរងទុក្ខទទួលសិរីល្អដែលព្រះទ្រង់ផ្តល់មក នោះពួកគេ (សត្រូវរបស់ពួកបរិសុទ្ធ) មិនអាចបញ្ឈប់វាបានទេ។

ការអធិប្បាយទី **35** សាក្សីពីរ **(11:3)**

ពាក្យ "សាក្សី" គឺជាពាក្យធម្មតានៃពាក្យច្បាប់។ សាក្សីនៃដំណឹងល្អគឺជាអ្នកដែលដឹងពីការពិតជាប្រវត្តិសាស្ត្រនៃការផ្សាយដំណឹងល្អ (ការពិតដែលថាព្រះគ្រីស្ទបានសុគតហើយបានរស់ឡើងវិញពីការសុគតរបស់ទ្រង់។) ក្នុងករណីសាក្សីនៅតុលាការមិនពិតគាត់ទទួលការផ្តន្ទាទោស។ សាក្សីនៃដំណឹងល្អបានទទួលយកតំណែងដាច់គឺដើម្បីប្រកាសហេតុការណ៍របស់ព្រះគ្រីស្ទដែលបទគម្ពីរបានប្រាប់យើងដោយស្មោះត្រង់។ ហេតុដូច្នេះហើយ សាក្សីនៃដំណឹងល្អមិនប្រកាសពីគំនិតរបស់គាត់ ឬជាបទពិសោធន៍របស់គាត់អំពីសេចក្តីជំនឿ ដោយសារគំនិតរបស់គាត់មិនមែនជាព្រះគ្រីស្ទផ្ទាល់ ហើយបទពិសោធន៍របស់គាត់ក៏មិនមែនជាព្រះគ្រីស្ទដែរ។ សាក្សីនៃដំណឹងល្អ

គួរតែប្រកាសអំពីព្រឹត្តិការណ៍នៃព្រះគ្រីស្ទ។ ព្រឹត្តិការណ៍នេះគឺជាវត្ថុបំណងដែលគាត់គួរតែលះបង់ជីវិតរបស់គាត់។

“សាក្សីពីរនាក់” តើលេខពីជាសញ្ញាសម្គាល់អ្វី? គឺវាមានអត្ថន័យនៃការសហការណ៍គ្នា។ សាស្តា 4:9 មានបន្ទូលថា “មានគ្នាពីរនាក់ប្រសើរជាងម្នាក់ឯង ដ្បិតពួកគេមានរង្វាន់ដែលល្អសម្រាប់ការខំប្រឹងរបស់ពួកគេ” (សាស្តា 4:12 មានបន្ទូលថា “ហើយបើមានខ្មាំងណាមក ដែលមានកំឡាំងជាង នោះ2នាក់នឹងអាចទប់ទល់បាន ឯពួរ3ផ្លុងមិនងាយដាច់ទេ”។ ព្រះយេស៊ូវក៏បានបញ្ជូនសិស្សពីរនាក់ទៅប្រកាសដំណឹងល្អ។ (លូកា 10:1) ការសហការណ៍នៃទីបន្ទាល់បានទាញយកនូវអ្វីដែលពិតមក។ (យ៉ូហាន 8:17) យើងដឹងសេចក្តីពិតថា ពេលដែលយើងសហការណ៍គ្នា នោះយើងមានអំណាច។ ដូចជាក្មេងៗបង្ហោះខ្លែង មានអ្នកសួរថា “ធ្វើយ៉ាងម៉េចទោះធ្វើឱ្យខ្លែងហោះបាន?” ពួកគេបានឆ្លើយថា គឺដោយសារខ្យល់។ តែក្មេងផ្សេងទៀតថា គឺដោយសារតែខ្សែរបស់ខ្លែង។ បន្ទាប់មកពិតណាស់ ខ្លែងអាចហោះបានដោយសារមានការសហការណ៍ពីគ្រប់ការទាំងអស់។ ដូចគ្នានឹងការប្រកាសដំណឹងល្អក៏វាត្រូវបានបង្កើតឡើងដោយការសហការរបស់សាក្សី។ ដោយសារពួកគេគ្មានកិច្ចសហការនោះ វាច្បាស់ជាគ្មានអំណាច។ ទោះបីជាការពិតក៏ដោយ អ្នកជឿគ្រិស្តសាសនាមិនសហការក្នុងកិច្ចការច្រើនទេ។ ដើម្បីចូលទៅក្នុងសភាពនោះ វាគឺជាប្រភេទឆ្កួត។ នៅមន្ទីរពេទ្យឆ្កួតមានអ្នកជំងឺផ្លូវចិត្តរាប់រយនាក់។ អ្នកត្រួតពិនិត្យមានតែម្នាក់ប៉ុណ្ណោះ។ អ្នកខ្លះមករកគាត់ ហើយសួរទៅអ្នកគ្រប់គ្រងថា "តើអ្នកមិនខ្លាចមនុស្សឆ្កួតរាប់រយនាក់ទេ?" ប្រសិនបើពួកគេសហការគ្នា ហើយវាយប្រហារអ្នក តើអ្នកអាចដោះស្រាយពួកគេ

ដោយរបៀបណា? បន្ទាប់មក អ្នកគ្រប់គ្រងឆ្លើយថា “ពួកគេមានមុខងារមិនសហការគ្នា”

ការអធិប្បាយទី **36** អំពីការផ្សាយដំណឹងល្អដែលគួរឱ្យភ័យខ្លាចនិងអាក្រក់ (**វិវរណៈ 11:3-11)**

នៅក្នុងខ10, ហោរាពីរនាក់មិនបានទទួលដំណឹងល្អទេ ហើយបានភ្លក្សនូវភាពល្ងិញតែដំណឹងល្អត្រូវបានប្រកាសទៅកាន់ពួកគេដែលព្រះបានប្រគល់ដល់ហោរាអេសាយថា “ត្រូវធ្វើឱ្យចិត្តនៃជនជាតិនេះទៅជាស្ពឹក ហើយឱ្យត្រចៀកគេធ្ងន់ ចូរបាំងភ្នែកគេ ក្រែងគេមើលឃើញ ដោយភ្នែក ស្តាប់ឮដោយត្រចៀក ហើយយល់ ដោយចិត្ត រួចប្រែចិត្ត ដើម្បីឱ្យបានប្រោសឱ្យជា” (អេសាយ 6:10)។ នេះមិនមែនជាការផ្សាយសេចក្តីមេត្តារបស់ព្រះទេ តែជាម្នាក់ដែលប្រកាសសេចក្តីក្រោធរបស់ព្រះ។ នៅក្នុងបទគម្ពីរមានការផ្សាយដំណឹងល្អដើម្បីបង្ហាញពីសេចក្តីក្រោធរបស់ព្រះ។ ការប្រកាសរបស់ម៉ូសេទៅកាន់ផារ៉ោន បានធ្វើឱ្យចិត្តរបស់ផារ៉ោនរឹងឡើង នោះជាការប្រកាសនៃសេចក្តីក្រោធ។ រ៉ូម 9:15-18 មានបន្ទូលថា “ដ្បិតទ្រង់មានបន្ទូលទៅលោកម៉ូសេថា «អញនឹងផ្សាយសេចក្តីមេត្តាករុណា ដល់អ្នកណាដែលអញមេត្តាករុណា ក៏នឹងមានសេចក្តីក្តួលអាណិត ដល់អ្នកណាដែលអញក្តួលអាណិត» ដូច្នេះ មិនសំរេចនឹងអ្នកណាដែលចង់បាន ឬនឹងអ្នកណាដែលខំរត់តាមនោះទេ គឺស្រេចនឹងព្រះ ដែលមានសេចក្តីមេត្តាករុណាវិញ ដ្បិតមានបទគម្ពីរសំដែងដល់ផារ៉ោនថា «អញបានតាំងឯងឡើងសំរាប់ការនេះឯង គឺដើម្បីសំដែងឫទ្ធិបារមីអញក្នុងខ្លួនឯង ប្រយោជន៍ឱ្យគេប្រកាសប្រាប់ពីឈ្មោះអញទូទៅពេញលើផែនដី» ដូច្នេះ ទ្រង់តែងផ្សាយមេត្តាករុណា ដល់អ្នកណាតាមព្រះហឫទ័យ ហើយទ្រង់ធ្វើឱ្យអ្នកណារឹងទទឹងក៏តាមតែព្រះហឫទ័យដែរ។” ដូច

ជាយើងបានមើលនៅក្នុងបទគម្ពីរហើយ ព្រះធ្វើឱ្យអ្នកផ្សេងរឹងទទឹង។ វាមានន័យថា ព្រះទ្រង់ធ្វើឱ្យចិត្តដែលមិនរឹងទៅជារឹង តែបានទុកចិត្តដែលរឹងទុកឱ្យនៅក្នុងសភាពដដែល។ ខ10 នៅក្នុងបទគម្ពីរ "ហើយអស់អ្នកដែលរស់នៅលើផែនដីនឹងរីករាយដោយសារការនោះ ហើយនឹងរីករាយនឹងប្តូរអំណោយគ្នា ពីព្រោះហោរាពីរនេះត្រូវបានជាទុក្ខបុកម្នេញដល់អ្នកដែលនៅលើផែនដី។" នៅពេលពួកគេប្រកាសដំណឹងល្អ ពួកគេមិនបានប្រកាសដំណឹងល្អដល់អ្នកដែលបានរើសតាំងទេ តែទៅកាន់អ្នកដែលស្តាប់វា ឬមិនស្តាប់វាប៉ុណ្ណោះ។ តើអ្វីទៅជាហេតុផលដែលត្រូវប្រកាសដំណឹងល្អទៅកាន់អ្នកដែលស្តាប់ ឬក៏មិនស្តាប់នោះ?

មានន័យថាដូចជាការពិត បន្ទាប់ពីបានប្រាប់ទុកជាមុន នឹងត្រូវបានសម្រេចយ៉ាងពិតប្រាកដ ដែលសិរីល្អនៃព្រះនឹងត្រូវបានបើកសម្តែង។ នៅពេលដែលសេចក្តីពិតបានសម្រេច ការរស់នៅរបស់ព្រះ និងភាពស្មោះត្រង់របស់ទ្រង់នឹងត្រូវបានបង្ហាញ។ ប្រសិនបើយើងដឹងតែថាការផ្សាយដំណឹងល្អត្រូវការសម្រាប់ការសង្គ្រោះរបស់បុរសនោះ វាជាការខុស។ ការផ្សាយដំណឹងល្អគ្រាន់តែសម្រាប់ការលើកតម្កើងព្រះ។ នៅពេលដែលមនុស្សនោះស្តាប់តាមព្រះបន្ទូលរបស់ព្រះជាម្ចាស់បានសង្គ្រោះ នោះសេចក្តីសង្គ្រោះ សិរីរុងរឿងរបស់ព្រះជាម្ចាស់នឹងត្រូវបានបង្ហាញ ប៉ុន្តែដូចដែលយើងនឹងត្រូវបានបៀតបៀន យើងមិនគួរភ្លេចថាការផ្សាយដំណឹងល្អមិនមែនជាទីបញ្ចប់ឡើយ។ (1) ការប្រកាសអំពីណូអេអស់120ឆ្នាំមិនមានប្រសិទ្ធភាពទេ។ ការផ្សាយដំណឹងល្អក៏មានគោលបំណងបង្ហាញពីសេចក្តីក្រោធដ៏អាក្រក់របស់ព្រះផងដែរ។ វាជាប្រភេទនៃការប្រកាសថ្កោលទោស។ (ហេព្រើរ 11:7)។ ដូច្នេះ អ្នកផ្សាយដំណឹងល្អត្រូវឈរនៅដោយឥរិយាបថដូច្នេះ មិនថាមិនស្តាប់ឬមិនស្តាប់នូវសាររបស់គាត់។ (2) អេណុ

កដែលជាកូនចៅជំនាន់ទី7របស់អ័ដាមបានព្រមានដល់មនុស្សបះបោរនៅក្នុងគ្រានោះ ។ (យូដាស 1:14, 15)។ បើទោះជាមានមនុស្សដែលនឹងត្រូវបរាជ័យ ឬជោគជ័យ គ្រប់ការទាំងអស់នៃការផ្សាយដំណឹងល្អនៅទីរហោស្ថានបង្ហាញពីសេចក្តីសុចរិត និងសេចក្តីស្រឡាញ់របស់ព្រះអម្ចាស់។ គោលបំណងនៃការផ្សាយដំណឹងល្អគឺ “ការលន់តួប្រែចិត្តរបស់មនុស្ស” ក៏ដូចជាដើម្បីនឹងបង្ហាញពីសិរីល្អរបស់ព្រះ។ (4) ព្រះគ្រីស្តប្រកាសព្រះបន្ទូលរបស់ព្រះនៅស្រុកយូដា តែមានមនុស្សជាច្រើនមិនស្តាប់តាមព្រះបន្ទូលរបស់ទ្រង់ តែតើយើងអាចនិយាយថានេះជាបរាជ័យនៃការប្រកាសរបស់ទ្រង់ទេ? វាមិនមែនជាបរាជ័យទេ។ ការប្រកាសបង្ហាញពីសិរីល្អរបស់ព្រះ។ "ពីព្រោះដែលភ្លៀងនឹងហិមៈធ្លាក់ចុះមកពីលើមេឃឥតវិលត្រឡប់ទៅលើវិញ គឺមកស្រោចដីធ្វើឱ្យកើតចេញជាពន្លកឡើង ហើយក៏ឱ្យពូជពង្រោះដល់អ្នកដែលព្រោះ នឹងអាហារដល់អ្នកដែលបរិភោគជាយ៉ាងណា ពាក្យអញ ដែលចេញពីមាត់អញទៅ ក៏មិនដែលវិលមកឯអញវិញ ដោយឥតកើតផលយ៉ាងដូច្នោះដែរ គឺនឹងធ្វើសំរេចតាមសេចក្តីប៉ងប្រាថ្នានៅក្នុងចិត្តអញ ហើយនឹងចំរើនកើនឡើង ក្នុងការអ្វី ដែលអញចាត់ទៅធ្វើនោះ" (អេសាយ 55:10, 11)។

ការអធិប្បាយទី 37 ចូរចងចាំថាលោកិយជារបស់ព្រះជាម្ចាស់ (វិវរណៈ 11:15)

នៅក្នុងពិភពលោក របស់ដែលត្រឹមត្រូវគឺមិនអាចជោគជ័យទាំងស្រុងនោះទេ។ ផ្ទុយទៅវិញ នៅពេលនោះ អ្វីដែលត្រូវត្រូវបានគេមើលងាយវិញ។ តើនយោបាយនៃការពិតត្រូវបានបង្ហាញនៅលើផែនដីនៅពេលណា? មុនអ័ប្រាហាំគឺមិនមាននយោបាយបែបនេះទេ។ តើអេបិល ហេណុក ណូអេ ជាដើម មិនមែនជាមនុស្សចម្លែកទេឬ? អេសាយ និងយ៉ាកុប ក៏ជាអ្នកចម្លែកដែរ។ ទោះជាម៉ូសេជាអ្នកតំណាងនៃលទ្ធិប្រជាធិបតេយ្យក៏ដោយ តើគាត់ស្ថិតនៅក្រោមការភ្ជួញភ្ជែររបស់ប្រជាជនអ៊ីស្រាអែលជាច្រើនឬទេ? ចុះនៅគ្រារបស់ពួកចៅហ្វាយវិញ? គ្រានោះជាពេលនៃការមិនស្តាប់បង្គាប់ ដូចជាថ្ងៃនៃភាពងងឹតដូចជា៖ “ប្រជាជនអ៊ីស្រាអែលបានប្រព្រឹត្តអំពើអាក្រក់នៅចំពោះព្រះភ័ក្ត្រព្រះអម្ចាស់ ហើយព្រះអម្ចាស់បានប្រគល់ពួកគេទៅក្នុងកណ្តាប់ដៃរបស់លោកមេឌានប្រាំពីរឆ្នាំ។ (ចៅហ្វាយ 6:1)។ តើថ្ងៃនៃរាជវង្សស្តេចយ៉ាងម៉េចដែរ? បន្ទាប់មក ស្តេចភាគច្រើនអាក្រក់។ ប្រវត្តិជាប្រវត្តិនៃអំពើបាប តើនៅសម័យនោះតើហោរារស់នៅឯកោប៉ុណ្ណា? តើគ្រានៃព្រះគម្ពីរសញ្ញាថ្មីយ៉ាងណាដែរ? ព្រះគ្រីស្ទត្រូវបានឆ្កាងនៅលើឈើឆ្កាង ហើយសាវ័កទាំងអស់ក៏ត្រូវរងទុក្ខដែរ។ នៅគ្រាក្រោយមកទៀត- ពួកសាវកគឺជាពេលវេលានៃការបៀតបៀន មានការបៀតបៀនដ៏អស្ចារ្យនៅគ.ស 202-311 អស់រយៈពេល 100 ឆ្នាំ។ បន្ទាប់ពីអធិរាជ ខនស្តិនធីន បានដោះលែងគ្រីស្ទាន តែដោយសារ

ហេតុការណ៍នេះ គ្រីស្ទានបានចាកចេញពីសេចក្តីពិតយ៉ាងច្រើន ក្រុមជំនុំនៅសម័យកណ្តាលបានចាកចេញពីសេចក្តីពិត រហូតដល់គ្រានៃការកែទម្រង់ ក្រុមជំនុំបានក្លាយសុទ្ធតែជាក្រុមជំនុំរ៉ូម ជាសេចក្តីគួរខ្ពើមយ៉ាងខ្លាំងដែលនៅក្នុងសេចក្តីងងឹត។

1. ហេតុផលដែលសេចក្តីពិត (ដំណឹងល្អ) មិនអាចក្លាយទៅជាស្តេច

ព្រោះសេចក្តីពិតឥឡូវនេះត្រូវបានប្រកាសក្នុងលោក វាមិនបានក្លាយជាស្តេចទេ ប៉ុន្តែវាមិនដូច្នោះ ដោយសារភាពមិនអាចទៅរួចរបស់វា។ ទោះបីជាមនុស្សតែងតាំងសេចក្តីពិតដោយបង្ខំក៏ពិតមិនចង់បាន។ នៅថ្ងៃនៃព្រះយេស៊ូបានតែងតាំងទ្រង់ជាស្តេចដោយបង្ខំ។ ប៉ុន្តែនៅក្នុងលោកនេះ ការពិតមិនមានសម្រាប់គ្រប់គ្រងទេ ប៉ុន្តែការប្រកាស។ ការពិតមិនកើតក្នុងលោកនេះទេ។ បើការពិតកើតក្នុងលោកនេះ ពិភពលោកនេះអាចក្លាយជាមិត្តរបស់ពិភពលោក។ អាស្រ័យហេតុនេះ ការពិតមានឱកាសគ្រប់គ្រងពិភពលោក។ សេចក្តីពិតបានកើតចេញពីការខាងលើ គឺមុនពេលវេលា (អវសាននៃពិភពលោកនេះ) មកដល់ ហើយគ្មានគំនិតគ្រប់គ្រងពិភពលោកឡើយ។ បើមានគំនិតបែបនេះ វាអាចធ្វើបាន។ ប៉ុន្តែការពិតមិនបានគិតបែបនេះទេ។ កិច្ចការដែលសេចក្តីពិតធ្វើក្នុងពិភពលោកគឺដើម្បីបន្ទោសពិភពលោកធ្វើឱ្យវាប្រែចិត្ត ឬធ្វើឱ្យវាជួយសង្គ្រោះ។ ហេតុនេះ សេចក្តីពិតខ្លាំងជាងលោកីយ៍នេះ ហើយត្រូវគេបៀតបៀនក្នុងលោកទៅទៀត។ ប៉ុន្តែដោយសារការពិតត្រូវបានបៀតបៀនដោយពិភពលោក យើងមិនអាចនិយាយថាការពិតគឺខ្សោយនោះទេ។ មូលហេតុដែលសេចក្តីពិតព្រមានឱ្យប្រែចិត្តគឺសម្រាប់ពិភពលោកខាងមុខ។ ដូច្នេះ ថ្ងៃនៃតួនាទីរបស់ហោរា និងសង្ឃនឹងត្រូវបញ្ចប់។

ប៉ុន្តែពេលដែលចាប់ផ្តើមជាមួយនឹងតួនាទីស្តេចនឹងមកដល់។ ព្រះយេស៊ូវជាស្តេច ហើយទ្រង់ត្រូវបានបៀតបៀននៅក្នុងលោកិយដោយទ្រង់បានប្រកាសសេចក្តីពិត។ (យ៉ូហាន 18:36, 37)។

2. នៅក្នុងចំណុចខ្ពស់បំផុងនៃចលនានៃសេចក្តីពិត (ចលនានៃដំណឹងល្អ) ភាពជាស្តេចនៃសេចក្តីពិតត្រូវបានប្រតិបត្តិ

សេចក្តីពិតកំណត់ថ្ងៃបញ្ចប់នៃពិភពលោកនេះ បានធ្វើការ ហើយរង់ចាំវា។ មកដល់ថ្ងៃដែលស្តេចនៃសេចក្តីពិតត្រូវធ្វើការ។ សេចក្តីពិតមានថ្ងៃឡើងគ្រងរាជ្យ។ វាត្រូវបានហោរាអេសាយថា៖ “នៅជាន់ក្រោយបង្អស់ នោះភ្នំ ជាទីស្អាងព្រះវិហារនៃព្រះយេហូវ៉ា នឹងបានតាំងឡើងខ្ពស់លើសអស់ទាំងភ្នំធំៗ ហើយនឹងបានដំកើងឡើងជាប្រសើរជាងអស់ទាំងភ្នំតូចៗដែរ អស់ទាំងសាសន៍នឹងចូលហូរហៀទៅក្នុងទីនោះ” (អេសាយ 2:2)។ នេះជាទំនាយថា ថ្ងៃដែលពិភពនៃសេចក្តីពិត និងពិភពនៃសេចក្តីសុចរិតនឹងមកគ្រប់គ្រងលើពិភពលោក។ ពោលគឺមានន័យថាថ្ងៃដែលជីវិតធ្វើការជាស្តេចនឹងចុះមក។ ដោយសារការគ្រប់គ្រងនៃសេចក្តីពិតនឹងត្រូវបានសម្រេចនៅលើភ្នំទាំងអស់ក្នុងទំនាយ វាបង្ហាញពីលក្ខណៈរីកចម្រើននៃចលនានៃសេចក្តីពិត។ ក្នុងប្រវត្តិសាស្ត្រពិភពលោក ការពិតលាតត្រដាងពីចរិតនៃភាពស្មោះត្រង់ជាច្រើនដង ហើយពង្រីកសកម្មភាពរបស់វាបន្តិចម្តងៗ ទីបំផុតវានឹងត្រូវបានបង្ហាញជាសមិទ្ធិផលដ៏អស្ចារ្យ។ ពេលវេលាដែលដំណឹងល្អដែលមិនឱ្យធ្វើផ្លូវនៅអាស៊ី ប៉ុន្តែផ្លូវនៃទ្វីបអឺរ៉ុបត្រូវបានត្រឡប់មកវិញនៅពេលមួយនៅជុំវិញពិភពលោកត្រូវបានហោះហើរជាយូរ។ ពិភពលោកទាំងមូលត្រូវបានអភិវឌ្ឍ និងផ្លាស់ប្តូរទៅជាដូចជាផ្ទះមួយ។ កំពូលភ្នំមិនត្រូវបានបង្កើតឡើងភ្លាមៗទេ ប៉ុន្តែបានក្លាយជាវាដោយការលើកឡើងពីកន្លែងទាបបន្តិចម្ត

ងៗ។ ដូចដែលពិភពសម័យនោះត្រូវបានលាតត្រដាងដូចកំពូលភ្នំដូចជាយើងបានសង្កេតមើលពួកគេយ៉ាងខ្លាំង។ ឥឡូវនេះផ្នែកខ្លះមានចរន្តនៃថាមពលរសើបចំពោះរឿងទាំងមូល។ ពីមុនប្រទេសទាំងអស់ក្នុងលោកមិនស្គាល់គ្នាទេ តែឥឡូវប្រទេសក្នុងលោកទាក់ទងគ្នាដូចផ្ទះ។ ពិភពលោករបស់អ្នកបានក្លាយជាពិភពកំពូល។ អនាគតកាលដែលយើងគួរក្រឡេកមើល គួរតែជាភ្នំនៃទីបរិសុទ្ធ ដែលចុះពីខាងលើ (ការចុះមកនៃសេចក្តីពិត) នៅលើកំពូលភ្នំ។

ផ្នែកទី 6
ការរងទុក្ខរបស់ក្រុមជំនុំ 12:1-13:18

ផ្នែកនេះបង្ហាញពីរូបភាព ដែលក្រុមជំនុំរបស់ព្រះគ្រីស្តត្រូវរងទុក្ខនៅក្នុងលោកិយ។ ព្រះគ្រីស្តផ្ទាល់បានរងទុក្ខ។ (12:4) ក្រុមជំនុំបានទទួលគ្រប់ការរងទុក្ខវេទនា (12:13, 15) អ្នកដែលជឿដល់ព្រះគ្រីស្តដោយស្មោះត្រង់បានទទួលការរងទុក្ខពិសេសដោយផ្ទាល់។ (12:17) ហើយនៅថ្ងៃចុងក្រោយនៃផែនដីនេះ ពួកបរិសុទ្ធនឹងទទួលនូវការបៀតបៀនចុងក្រោយដោយពួកអ្នកដែលប្រឆាំងនឹងព្រះគ្រីស្ត។ (13:1-18)

ជំពូក 12

យោងទៅតាមការបកស្រាយរបស់អ្នកប្រាជ្ញដ៏ធំម្នាក់នៅក្នុងជំនឿរបស់កាល់វីន ជំពូកនេះពិនិត្យមើលឡើងវិញជាមួយនឹងវិធីសាស្ត្រសំខាន់នៃការប៉ាន់ស្មានដល់ខ្លឹមសារ

ដូចគ្នានៃជំពូកទី 11 ម្តងទៀត។ នោះគឺជាជំពូកដែលបានសរសេរស្តានភាពដែលថា ក្រុមជំនុំត្រូវបានរងទុក្ខចាប់ពីការប្រសូតរបស់ព្រះគ្រីស្ទ ពីខាងក្នុងមូលហេតុនៃការរងទុក្ខគឺសាតាំង។ លោក ប្រ្តេចដានុស មានប្រសាសន៍ថា “ជំពូកខាងលើបាននិយាយពីស្តានភាពដែលក្រុមជំនុំរបស់ព្រះអម្ចាស់ប្រឈុទ្ធនឹងសកម្មភាពជាប្រភេទក្រុម និងពិភពលោក នេះជាចង្អុលបង្ហាញពីសាវតារ (សាតាំង) នៃអំណាចនៃមនុស្សដែលប្រឆាំងជាមួយនឹងក្រុមជំនុំនៃព្រះអម្ចាស់។”(In het vorige hoofdstuk teekende jij’s Heeren gerneente in hare institutairewerkzaamheid, en in hare bestrijding dor de wereld, .. . dien strijd der wereld tegen’s Heeren gemeete; ontsluierd. – Openbring, p 2480) Bousset said that the materials of the chapter comes out of the myth of the sun. (ein alter Sonnenny thus scheint aller wahrscheinlichkeit nach in Apok. 12 verarbeitet zu sein. – a. w. S. 411)។ ប៉ុន្តែវាជាការទាយខុស។ លោក ប៊ូសេត ផ្ទាល់បាននិយាយថា នៅក្នុងសេចក្តីសរុបនៃការឈ្លោះនៃខ្លួនឯង “វាពិបាកនិយាយពីកន្លែងដែលអ្នកនិពន្ធបានយកសំភារៈនេះមក។ (Woher nun der Verfasser von Arok, 12 sein Material entjehnt, das wird sich kaum mehr mit Sicherheit sagen lassen, a. w. S. 411)។

ការបកស្រាយ

រូចមានទីសំគាល់មួយយ៉ាងធំនៅលើមេឃ: “ទីសំគាល់” គឺ ស៊ីម៉ែអន (σημεῖον) ក្នុងភាសាក្រិក ដែលមានន័យថាជាសញ្ញា និងវាស្រដៀងដែលចង្អុលទៅកាន់ពាក្យ “និមិត្តសញ្ញា”។ **“ស្ត្រី”** ជានិមិត្តសញ្ញារបស់ក្រុមជំនុំ ដែលចង្អុលទៅកាន់ក្រុមជំនុំនៅ

សញ្ញាថ្មីនៅក្នុងរង្វាស់នៃសញ្ញាចាស់។ ការពិតដែលក្រុមជំនុំសញ្ញាថ្មីចេញមកពីរង្វាស់នៃសញ្ញាចាស់គឺត្រូវបានបញ្ជាក់ដោយទីបន្ទាល់ដូចតទៅ។ (1) **មកុដធ្វើពីផ្កាយ12។** វាធ្វើឱ្យយើងរលឹកពីផ្កាយទាំង12។ (លោកុប្បត្តិ 37:9) (2) ពាក្យថា "នាងមានគភ៌ ក៏ស្រែកដោយរៀបនឹងសំរាលចេញ"។ ហាក់ដូចជាបង្ហាញអ្វីមួយអំពីប្រវត្តិរបស់យូដា។ បទគម្ពីរនិយាយថា ប្រវត្តិសាស្ត្ររបស់យូដាមានគោលបំណងឆ្ពោះទៅការយាងមកររបស់ព្រះមេស៊ី និងប្រវត្តិនៃការឈឺចាប់នៃការប្រសូត្រកូន (មីកា 5:2 អេសាយ 66:7, 8) (3) កិច្ចការដែលទេវតា មីកែល បានវាយជាមួយនឹងសាតាំងនៅក្នុងលោកិយដែលចេញមកពីស្ថានសួគ៌ និងបានយកឈ្នះវាទាក់ទងនឹងប្រវត្តិនៃសាសន៍យូដាក្នុងផ្នែកខ្លះ។ កណ្ឌគម្ពីរដានីយ៉ែលនិយាយថា មីកែល ជាទេវតាដែលការពារសាសន៍អ៊ីស្រាអែល។ (10:13, 21)

ក្រុមជំនុំសញ្ញាថ្មីដែលចេញមកពីរូបកាយដំបូងនៃសញ្ញាចាស់ជានិមិត្តសញ្ញាជាមនុស្សស្រីនៅក្នុងអត្ថបទ។ ខគម្ពីរដែលស្ត្រីជានិមិត្តសញ្ញាក្រុមជំនុំគឺដូចតទៅនេះ។ វិវរណៈ 19:7, 21:9, ហូសេ 2:1, យ៉ូហាន 3:29, អេភេសូរ 5:31, 32 ។ល។

លោក ហ្វ្រូស (Henry W. Frost) អះអាងថា នៅទីនេះ មនុស្សស្រីគឺសំដៅទៅកាន់ម៉ារី ដ្បិតនាងម៉ារីជាគ្រីស្ទានសាសន៍យូដា នាងជានិមិត្តសញ្ញានៃក្រុមជំនុំគ្រីស្ទានសាសន៍យូដា ដែលនឹងកើតឡើងនៅថ្ងៃចុងក្រោយនៃលោកិយនេះ។ (ម៉ាថាយ 24 និងវិវរណៈ) តែទ្រឹស្តីនេះមិនធម្មតាទេ។

ជាស្ត្រីម្នាក់ប្រដាប់ខ្លួនដោយព្រះអាទិត្យ មានព្រះចន្ទនៅក្រោមជើង ក៏មានមកុដធ្វើពីផ្កាយ12នៅលើក្បាលដែរ។ "ការប្រដាប់ខ្លួនដោយព្រះអាទិត្យជាសិរីល្អយ៉ាងភ្លឺចែងចាំង ដែលបំពាក់ដោយសេចក្តីសុចរិតរបស់ព្រះគ្រីស្ទ (វិវរណៈ 7:8)។ ការដាក់ព្រះចន្ទ

នៅក្រោមជើងជាសញ្ញានៃជ័យជំនះ (លោកុប្បត្តិ 37:9, 10 2:10, 4:4, 6:2)។ “មកុដធ្វើពីផ្កាយ12”។ នៅទីនេះ លេខ12ជានិមិត្តសញ្ញានៃក្រុមជំនុំរបស់ព្រះ។ ក្រុមជំនុំសញ្ញាចាស់ត្រូវបានតាំងលេខ 12 ដែលកុលសម្ព័ន្ធទាំង12ធ្វើជាគ្រឹះ ហើយក្រុមជំនុំសញ្ញាថ្មីបានតាំងសាវកទាំង12ជាគ្រឹះផង។ ហើយ “ផ្កាយ” ជាសញ្ញានៃអ្នកជឿដែលប្រកាសពីសេចក្តីពិត។ (លោកុប្បត្តិ 15:5 ដានីយ៉ែល 12:3, លូកា 16:8, 1ថែស្សាឡូនិក 5:5) សូមអាន ទំនុកដំកើង 84:12, អេសាយ 60:20, ម៉ាឡាគី 4:2។ ដូច្នេះ មកុដដែលធ្វើពីផ្កាយ12ជាសញ្ញានៃជ័យជំនះរបស់ក្រុមជំនុំ។

លោក ព្រ្តេចដានុស បាននិយាយថា “ការតុបតែបែបនេះរបស់ស្ត្រីនេះជានិមិត្តសញ្ញាដែលក្រុមជំនុំចេញមកពីប្រភពនៃស្ថានសួគ៌ ដែលចូលទៅក្នុងព្រះគុណរបស់ព្រះជាម្ចាស់ និងការប្រកបរបស់ទ្រង់ ហើយនិងភាពជាអម្ចាស់ដ៏មានគ្រប់ចេស្តារបស់ទ្រង់នៅលើផែនដីទាំងមូល។ (En Zij wordt gekenschetst naar hare hemelsche arkomst, en voorgesteld, zooals zij mag deelen in de volle gemeenschap, engust, des Heeren, en bezitten de heerschappij over de geheele wereld. – Openbaring. P. 250)។

2 នាងមានគភ៌ ក៏ព្រែកដោយឈឺចាប់នឹងសម្រាលចេញ ទាំងឈឺចាប់នឹងបង្កើតកូនមក។

នៅត្រង់នេះ “កូន” ចង្អុលទៅកាន់ព្រះយេស៊ូវគ្រីស្ទច្បាស់ណាស់។ ពីព្រោះកិរិយាសព្ទ “មានគភ៌” នៅក្នុងអតីតកាលរបស់ពាក្យ ថេខេន (τεκεῖν)។ ទម្រង់អតីតកាលរបស់ភាសាក្រិក (Aorist) ចង្អុលទៅកាន់សកម្មភាពនៅក្នុងមួយរយៈពេល។ នៅទីនេះវេយ្យាករណ៍នេះមានន័យថា ជាកំណើតរបស់ព្រះយេស៊ូវ ដែលជាព្រឹត្តិការណ៍កើតឡើងម្តងរួចមក។ (ព្រ្តេចដានុស)

3 ឃើញមានទីសំគាល់មួយទៀត សូមអានការបកស្រាយនៃពាក្យដូចគ្នា។

នាគដ៏ធំមានសម្បុរក្រហម នៅទីនេះ “នាគ” ជានិមិត្តសញ្ញារបស់សាតាំង (វិវរណៈ 12:9, លោកុប្បត្តិ 3:1)។ “ពណ៌ក្រហម” របស់វាជាពណ៌នៃឈាម ហើយជាសញ្ញានៃការសម្លាប់ ការគំរាមដែលនឹងធ្វើទុក្ខដល់ក្រុមជំនុំ។ (វិវរណៈ 6:4)

ដែលមានក្បាល7 និងស្នែង 10 “កូនចៀម” (ព្រះយេស៊ូវ) មានភ្នែក7 និងស្នែង7 (5:6) តែនាគក្រហម (សាតាំង) មានក្បាល7 និងស្នែង7របស់នាគក្រហម (សាតាំង)។ “ស្នែង7 និងភ្នែក7” របស់កូនចៀមចង្អុលទៅកាន់ព្រះដែលបរិសុទ្ធគ្រប់លក្ខណ៍ និងព្រះវិញ្ញាណបរិសុទ្ធ (5:6) “ក្បាល7 និងស្នែង10របស់នាគក្រហមចង្អុលទៅកាន់និមិត្តសញ្ញានៃប្រទេសចំនួន7នៃអ្នកដែលប្រឆាំងនឹងព្រះគ្រីស្ទនៅក្នុងលោកិយនេះ ហើយស្តេច10។ (វិវរណៈ 17:9-12) សាតាំងព្យាយាមធ្វើទុក្ខដល់ក្រុមជំនុំតាមរយៈភាពជាស្តេចរបស់ផែនដី ព្រះគ្រីស្ទបានបំផ្លាញកិច្ចការរបស់សាតាំងជាមួយនឹងអំណាចចេស្តារបស់លោកិយនៃស្ថានសួគ៌ និងអំណាចខាងវិញ្ញាណ។ សូមអាន 2ថែស្សាឡូនិក 2:8។ លេខ 7 ជារបស់ព្រះជាម្ចាស់តែមួយអង្គគត់ដែលសាតាំងបានលួចវា ហើយវាក៏មានឥរិយាបថដែលក្រអឺតក្រទមធ្វើខ្លួនដូចព្រះ។ លេខ 10 ជារបស់លោកិយដែលអាចជាសញ្ញានៃការបះបោរយ៉ាងខ្លាំងបំផុតរបស់ប្រទេសនៃលោកិយនេះទៅកាន់ព្រះ។ សូមអាន 13:1, 17:9-12។

ឯនៅក្បាលវាមានមកុដ7។ សត្វតិរច្ឆាន ដែលជាភ្នាក់ងាររបស់សាតាំង មានមកុដដប់។ មកុដទាំងប្រាំពីរនេះ គឺជាការក្លែងបន្លំនៃសិរីល្អរបស់ព្រះ ហើយវាគឺជានិមិត្តសញ្ញានៃការប្រមាថដែលអះអាងថាខ្លួនជាស្តេច ហើយវាក៏អះអាងថាជាព្រះផងដែរ។

4, 5 “កន្ទុយ” ជានិមិត្តសញ្ញានៃការកុហក។ (អេសាយ 9:15), “តារា” ជាសញ្ញានៃទេវតា។ (យ៉ូប 38:7) សាតាំងជាទេវតាម្នាក់ តែបន្ទាប់ពីគេបានធ្វើបាប នោះគេត្រូវបានផ្លាស់ប្តូរទៅជាអារក្ស (2ពេត្រុស 2:4 យូដាស 6)។ ហើយគេបានធ្វើការល្បួងទេវតាជាច្រើនថែមទៀត ហើយបានធ្វើឱ្យពួកគេខូចដែរ។ “គ្រវាត់ចោលទៅផែនដីទៅ” មានន័យថា ធ្វើឱ្យពួកគេត្រូវបានធ្លាក់ខ្លួនទៅ។ ហើយនាគបានឈរនៅចំពោះស្ត្រីដែលរៀបនឹងប្រសូត្រកូន មុនពេលសាតាំងធ្វើបាប “ស្ត្រី” ដំបូង គេព្យាយាមធ្វើបាបដល់ក្មេងប្រុសនោះ (ព្រះយេស៊ូវគ្រីស្ទ) ដែលច្បាស់ណាស់នៅក្នុងប្រវត្តិរបស់ដំណឹងល្អ។ ព្រះជន្មរបស់ព្រះយេស៊ូវបានចាប់ផ្តើមជាមួយនឹងជីវិតដែលដើរគ្រប់ទីកន្លែងកាលនៅវ័យកុមារ ហើយត្រូវបានគេបៀតបៀនជាច្រើន បន្ទាប់ពីទ្រង់ត្រូវបានគេឆ្កាងនៅលើឈើឆ្កាង។ នាងបានបង្កើតបុត្ររបស់នាង។ ការនេះមានន័យថាការចាប់កំណើតរបស់ព្រះយេស៊ូវគ្រីស្ទ។ លោក សេស បាននិយាយថា ការនេះចង្អុលទៅថា ពួកបរិសុទ្ធបានរស់ឡើងវិញ ហើយត្រូវបានលើកឡើងទៅលើអាកាស (1ថែស្សាឡូនិក 4:16-17) តែវាមិនតាមធម្មជាតិទេ លោក អេលៀត បាននិយាយថា វាជាការប្រៀបធៀបនៃព្រឹត្តិការណ៍ដែលអធិរាជ ខនស្តែនធីន បានក្លាយជាអធិរាជដ៏ខ្លាំង តែវាជាការយល់ច្រឡំទេ។

តែព្រះទ្រង់លើកកូននាងទៅឯទ្រង់ និងដល់បល្ល័ង្កទ្រង់វិញ។ សាតាំងមិនបានបំផ្លាញព្រះយេស៊ូវគ្រីស្ទទេ គឺព្រះយេស៊ូវទ្រង់មានព្រះជន្មរស់ឡើងវិញ និងបានឡើងទៅលើ។

6 រួចស្ត្រីនោះក៏រត់ទៅទីរហោស្ថាន ការនេះជាការនិយាយប្រៀបធៀបជីវិតរបស់លោកិយនៃជីវិតនៅទីរហោស្ថាន។ (1) រាស្ត្រអ៊ីស្រាអែលបានចាកចេញពីប្រទេសអេស៊ីប ហើយត្រូវបានបង្វឹកនៅក្នុងសេចក្តីជំនឿនៅលើវាលរហោស្ថាន។ វាពិតជាត្រូវមុនពេលដែលគេចូលទៅក្នុងទឹកដីកាណាន។ ប្រៀបដូចទៅនឹងក្រុមជំនុំដែលត្រូវបានបង្វឹកនៅក្នុងលោកិយដោយសេចក្តីជំនឿដែរ។ (2) នៅក្នុងចំណុចនេះ យើងត្រូវគិតពីមួយចំណុចទៀត។ ដែលនោះជា “ស្ត្រីដែលបានរត់ទៅទីរហោស្ថាន” ចលនារបស់

ក្រុមជំនុំនៅក្នុងសញ្ញាថ្មីដែលមានចលនារបស់ក្រុមជំនុំជានិច្ចនៅក្នុងសញ្ញាចាស់ ដែលត្រូវបានបដិសេធដោយពួកយូដា ហើយរួចមកវាបានលូតលាស់នៅក្នុងទឹកដីរបស់អ្នកមិនជឿ (វាលរហោស្ថានជានិមិត្តសញ្ញានៃលោកិយ)។ យោងតាម លោក Henry W. Frost "ព្រឹត្តិការណ៍ដែលស្ត្រីរត់គេចមានអត្ថន័យដូចតទៅ។ នោះគឺ វាជានិមិត្តសញ្ញាដែលគ្រាចុងក្រោយរបស់ក្រុមជំនុំសញ្ញាថ្មីរបស់ក្រុមជំនុំគ្រីស្ទានជាសាសន៍យូដាដែលនឹងត្រូវគេបៀតបៀនដោយអ្នកប្រឆាំងនឹងព្រះគ្រីស្ទ ហើយពួកគេនឹងត្រូវខ្ចាត់ខ្ចាយទៅតំបន់របស់អ្នកមិនជឿចេញពីផាលេស្ទីន។ ( ) តែការបកស្រាយនេះមិនតាមបែបធម្មតាទេ។

នៅទីនោះព្រះបានរៀបចំកន្លែងឱ្យនាង ដើម្បីនឹងចិញ្ចឹមនាងនៅទីនោះ។ លោកិយនេះប្រៀបដូចជាទីរហោស្ថាន។ កន្លែងដែលព្រះទ្រង់រៀបចំដើម្បីនឹងចិញ្ចឹមក្រុមជំនុំនោះជាលោកិយ។

1,260 ថ្ងៃ។ នេះជារយៈពេលដែលទាក់ទងនឹង "ពេលមួយខួប ពីរខួប ហើយកន្លះខួប។" លោក ប្រ្គេចដានុស ដែលជាអ្នកសរសេរការពន្យល់របស់ជំនឿកាល់វីនបាននិយាយថា ការនោះចង្អុលទៅកាន់ថ្ងៃនៃសញ្ញាថ្មី។ (Openbaring ទំព័រ 255)

7-9 សាតាំងត្រូវបានដេញចេញ

7 នោះមានចំបាំងនៅលើមេឃ ការនេះចង្អុលទៅកាន់ការពិតដែលតាមការយាងឡើងរបស់ព្រះគ្រីស្ទ នោះអារក្សត្រូវបានដាច់ចេញពីពិភពនៃស្ថានសួគ៌ (លូកា 10:18)។ គេតែងតែធ្វើការចោទប្រកាន់ដល់ពួកបរិសុទ្ធនៅចំពោះព្រះ។ (យូដាស 1:1-11 2:4, 5) ។ ឥឡូវនេះ ព្រះយេស៊ូវគ្រីស្ទត្រូវបានឆ្កាងនៅលើឈើឆ្កាង ហើយបានសុគត ហើយបានរស់ឡើងវិញ ហើយត្រូវបានយាងឡើង គេនោះត្រូវបានបំបែកចេញពីពិភពនៃស្ថានសួគ៌ ហើយត្រូវបានបណ្តេញចេញពីផែនដី។ (សូមមើល លូកា 10:3818, យ៉ូ

ហាន 12:30) ព្រះគ្រីស្ទបានសុគត ហើយបានរស់ឡើងវិញ ហើយបានឡើងទៅស្ថានសួគ៌ សាតាំងត្រូវបានទម្លាក់ចុះ ចុះហេតុអ្វីបានជាសាវ័កប៉ុលនិយាយថា សាតាំងធ្វើការនៅស្ថានសួគ៌ក្នុងគម្ពីរសញ្ញាថ្មី? អេភេសូរ 6:12 បាននិយាយថា “ដ្បិតយើងរាល់គ្នាមិនមែនតយុទ្ធនឹងសាច់ឈាមទេ គឺនឹងពួកគ្រប់គ្រង ពួកមានអំណាច និងពួកម្ចាស់នៃសេចក្ដីងងឹតនៅលោកិយនេះវិញ ហើយទាស់នឹងអំណាចអាក្រក់ខាងវិញ្ញាណនៅស្ថានដ៏ខ្ពស់ដែរ។” យើងមិនគិតថាពាក្យរបស់ប៉ុលមិនមែនជារឿងចម្រូងចម្រាសនោះទេ។ នេះគឺជាហេតុផល។ នោះគឺ សាតាំងត្រូវបានបណ្តេញចេញពីកន្លែងចោទប្រកាន់ ដោយសារព្រះយេស៊ូវគ្រីស្ទបានសុគត ហើយបានរស់ឡើងវិញ ហើយបានឡើងទៅស្ថានសួគ៌ ប៉ុន្តែវានៅក្នុងកន្លែងល្បួង (នេះក៏ជាស្ថានសួគ៌ នោះគឺជាអាកាស)។ បន្ទាប់ពីនោះ នៅថ្ងៃ ចុងក្រោយនៃគម្ពីរសញ្ញាថ្មី គេនឹងត្រូវបណ្តេញចេញពីផែនដីទាំងស្រុង។ កាលដែលព្រះគម្ពីរមានបន្ទូលថា កិច្ចការជាក់ស្តែងដែលព្រះនឹងសម្រេច ទ្រង់មានបន្ទូលថាបានសម្រេច ទោះជាមិនបានសម្រេចក្តី ក៏ហោរានៃគម្ពីរសញ្ញាចាស់ក៏ប្រើជាពាក្យដដែល។

បន្ទាប់មក "សង្គ្រាមនៃស្ថានសួគ៌" ដែលត្រូវបានលើកមកដោយព្រឹត្តិការណ៍បានកើតឡើងរវាងទេវតាមីកែលនិងនាគ។ តើយើងនឹងមានលក្ខណៈវិនិច្ឆ័យអ្វីខ្លះទៅនឹងព្រឹត្តិការណ៍ដែលព្រះគ្រីស្ទបានសុគត ហើយបានរស់ឡើងវិញ? តើមីកែល និងភ្នាក់ងាររបស់គាត់មិនបានកត់សម្គាល់អ្វីទេ ប៉ុន្តែមានតែមីកែល និងទេវតារបស់គាត់ប៉ុណ្ណោះដែលប្រយុទ្ធជាមួយនាគឬ? ប៉ុន្តែវាមិនមែនជាបញ្ហាទេ។ ពីព្រោះ (1) កិច្ចការដែលព្រះគ្រីស្ទបានធ្វើ នឹងត្រូវបានសម្រេចដោយមនុស្សក្នុងលោកីយ៍របស់មនុស្ស។ ឧទាហរណ៍ វាដូចជាកិច្ចការនៃការផ្សាយដំណឹងល្អ។ នៅក្នុងរូបភាពខាងក្រៅ ការផ្សាយដំណឹងល្អត្រូវបានដំណើរការដោយមនុស្ស ហើយនៅផ្នែកផ្សេងទៀត ព្រះគ្រីស្ទទ្រង់ជាអ្នកធ្វើសម្រេច។ ដូចនោះដែរ “សង្គ្រាមនៃស្ថានសួគ៌” ត្រូវបានអនុវត្តដោយការសុគតរបស់ព្រះគ្រីស្ទ និងការរស់ឡើងវិញរបស់ទ្រង់ (យ៉ូប 38:7) ក្នុងទិដ្ឋភាពមួយ

ហើយនៅក្នុងលក្ខណៈខាងក្រៅដែរ ដែលមីកែលនិងពួកទេវតារបស់គាត់បានដឹង។ (2) ជាពិសេស យើងគួរតែបកស្រាយ “សង្គ្រាមនៃស្ថានសួគ៌” ជាសំឡេងនៃស្ថានសួគ៌ ដែលបានបញ្ជាក់នៅក្នុងខ 10-12។ (RCH. Lenski, The Interpretation of St. John’s revelation, ទំព័រ 372)។ ដោយសារតែសំឡេងនៃស្ថានសួគ៌បាននិយាយអំពីខ្លឹមសារនៃសង្គ្រាម។ នោះគឺពាក្យដែលអ្នកចោទប្រកាន់ពួកបរិសុទ្ធត្រូវបានបណ្តេញចេញ (ខ 10) មានន័យថា នៅក្នុងថ្ងៃនៃគម្ពីរសញ្ញាចាស់ អារក្សបានចោទប្រកាន់ពួកបរិសុទ្ធតាមរយៈដង្វាយធួនរបស់ព្រះគ្រីស្ទ អំពើនៃការចោទប្រកាន់របស់គេត្រូវបានបញ្ចប់។ នេះមានន័យថាជាជ័យជំនះរបស់ពួកបរិសុទ្ធ។ ក្នុងន័យដូចនេះ ខ 11 បានមាននិយាយថា “ហើយពួកគេបានយកឈ្នះគេដោយឈាមនៃកូនចៀម និងដោយព្រះបន្ទូលនៃទីបន្ទាល់របស់ពួកគេ ត្បិតពួកគេមិនស្រឡាញ់ជីវិតរបស់ពួកគេរហូតដល់ស្លាប់ឡើយ”។ ដូច្នេះហើយ សង្គ្រាមនៃស្ថានសួគ៌ ចង្អុលទៅការពិតដែលថា ព្រះគ្រីស្ទបានសុគតនៅលើឈើឆ្កាង ហើយបានរស់ឡើងវិញ ហើយបានទទួលជ័យជំនះ។

មីកែល ការនេះជាការបកប្រែសៀងនៃពាក្យដើមរបស់ភាសាហេព្រើរ (מִיכָאֵל) ដែលមានន័យថា “តើអ្នកណាដូចជាព្រះជាម្ចាស់ទៅ?” ដូចដែលយើងមើលឃើញការមួយនេះ ទេវតាជាអ្នកដែលប្រយុទ្ធសម្រាប់ព្រះ។ នៅក្នុងសង្គ្រាមខាងវិញ្ញាណ ព្រះគ្រីស្ទទ្រង់បានសុគតដោយត្រូវឆ្កាងនៅលើឈើឆ្កាង ហើយទ្រង់មានព្រះជន្មរស់ឡើងវិញ ហើយបានយាងឡើងទៅស្ថានសួគ៌ ហើយជ័យជំនះត្រូវបានតាំងនៅរួចហើយ។

នឹងពួកទេវតារបស់លោកច្បាំងនឹងនាគ និងទេវតាវាក៏ច្បាំងនឹងលោកដែរ។ សម្រាប់ពាក្យនេះ សូមអាននៅជំពូកមួយទៀត (យកឈ្នះលើអារក្ស)

10-12 ខគម្ពីរទាំងនេះចង្អុលទៅកាន់ការពិតដែលកិច្ចការនៃការប្រោសលោះត្រូវបានសម្រេចយ៉ាងអស្ចារ្យដោយការរស់ឡើងវិញរបស់ព្រះគ្រីស្ទ និងការយាងឡើងរបស់ទ្រង់។

10 សេចក្តីសង្គ្រោះ ព្រះចេស្តា និងរាជ្យរបស់ព្រះនៃយើងរាល់គ្នា សេចក្តីសង្គ្រោះហាក់ដូចជាការបង់ថ្លៃលោះដែលព្រះយេស៊ូវគ្រីស្ទបានសម្រេចបំពេញ (វិវរណៈ 7:10) “ព្រះចេស្តា” មានន័យថាជាអំណាចខាងវិញ្ញាណរបស់ព្រះវិញ្ញាណបរិសុទ្ធ ដែលទ្រង់បានយាងមកដោយការយាងឡើងរបស់ព្រះយេស៊ូវគ្រីស្ទ។ (វិវរណៈ 4:11, 5:12)។ “រាជ្យ” ជាស្ថានសួគ៌ “អំណាច” របស់ព្រះគ្រីស្ទចង្អុលទៅកាន់អំណាចដែលព្រះជាម្ចាស់ដែលទ្រង់បានយាងឡើងទៅស្ថានសួគ៌ បានក្លាយជាព្រះដែលមានគ្រប់ចេស្តានៅស្ថានសួគ៌និងនៅផែនដី។ (ម៉ាថាយ 28:18) ឃ្លានេះជាពាក្យនៃលទ្ធផលដែលបានយកឈ្នះសាតាំងទាំងស្រុងតាមរយៈព្រឹត្តិការណ៍ដែលព្រះគ្រីស្ទបានរស់ឡើងវិញ និងបានយាងឡើងទៅស្ថានសួគ៌។

អានោះដែលចោទប្រកាន់នឹងពួកបងប្អូនយើងរាល់គ្នា អ្វីដែលជាបញ្ហានៃចំណុចនេះគឺជាបញ្ហា នៅទីនេះ អ្នកណានិយាយការមួយនេះ។ (1) លោក ស្វីត បាននិយាយថាគេគឺជាអ្នកចាស់ទុំម្នាក់ប៉ុន្តែវាមិនសមហេតុផលទេ (2) លោក ប្រ្គេចដានុស និយាយថាជាទេវតា (3) លោក ឡូមេយើ បាននិយាយថា "អ្នកដែលត្រូវគេសម្លាប់" ឬ (4) មនុស្សម្នាក់និយាយថាវាគឺជាពួកបរិសុទ្ធនៃគម្ពីរសញ្ញាចាស់។ “អ្នកចោទប្រកាន់” ដែលចង្អុលទៅកាន់សាតាំង គេនោះប្រព្រឹត្តចំពោះមនុស្សដែលត្រូវបាន រើសតាំងនៅថ្ងៃនៃគម្ពីរសញ្ញាចាស់ ហើយចោទប្រកាន់នៅចំពោះព្រះ។ (សូមអាននៅ យ៉ូប 1:-2:) ប៉ុន្តែការពិតដែលថាព្រះយេស៊ូវបានសុគតលើឈើឆ្កាង ហើយទ្រង់បានរស់ឡើងវិញ ហើយបានឡើងទៅដែលបានរាប់ជាសុចរិតដល់រាស្ត្ររបស់ព្រះឥឡូវនេះ នោះកិច្ចការចោទប្រកាន់របស់សាតាំងត្រូវបានបញ្ចប់ហើយ។

*11 គេបានឈ្នះវាដោយសារឈាមនៃកូនចៀម ហើយដោយសារសេចក្តីបន្ទាល់របស់គេ។*នៅទីនេះ ពាក្យថា "បានឈ្នះ" ត្រូវបានតាំងយ៉ាងពិតប្រាកដដោយខខាងលើ ដោយការបញ្ចប់ការចោទប្រកាន់របស់សាតាំង។ ដូច្នេះ ខគម្ពីរនេះទាក់ទងនឹងខគម្ពីរខាងលើ។ នៅទីនេះ ពាក្យ "ដោយ" គឺជា ឌីអា (διά) ជាភាសាក្រិច ដែលគួរបកប្រែជា "ព្រោះ" ។ ព្រោះពាក្យនេះតាំងពីមុខនាមកម្មបទ មិនមែនមានន័យថា ជាមធ្យោបាយនៃជ័យជំនះទេ តែជាហេតុនៃកុសលដ៏ពេញដោយព្រះគុណដែលត្រូវទទួលថាជាអ្នកឈ្នះ។ ម្យ៉ាងវិញទៀត ជ័យជម្នះរបស់ពួកគេមិនបានមកពីការងាររបស់គេទេ ប៉ុន្តែដោយសារព្រះលោហិតដ៏វិសេសរបស់ព្រះគ្រីស្ទដែលបានប្រទានដល់ពួកគេជាព្រះគុណ ហើយពាក្យបន្ទាល់ដែលធ្វើឱ្យពួកគេចូលរួមក្នុងការទទួលជ័យជម្នះ។ យោងទៅសេចក្តីអធិប្បាយ (យកឈ្នះអារក្ស) នៅផ្នែកខាងក្រោយ។

ក៏មិនបានស្តាយជីវិតខ្លួនដរាបដល់ស្លាប់ អ្នកជឿដែលជាគ្រីស្ទានៅក្នុងវិវរណៈនៅក្នុងន័យដែលជាប់លាប់គឺជាអ្នកដែលត្រូវបានគេសម្លាប់។ ចុះតើការដែលត្រូវគេសម្លាប់ជាលក្ខខណ្ឌដែលសាកសមនឹងទទួលបានសេចក្តីសង្គ្រោះមែនទេ? គឺវាមិនមែនោះទេ។ នៅក្នុងវិវរណៈ អ្នកជឿត្រូវបានដាច់ចេញពីកូនចៀម។ (ព្រះយេស៊ូវទ្រង់បានសុគត)។ (វិវរណៈ 14:1, 17:14, 19:11, 14) ដូច្នេះអ្នកជឿក៏រីករាយនឹងគុណសម្បត្តិនៃអ្នកមានជ័យជំនះដោយសារកិច្ចការរបស់ព្រះគ្រីស្ទ បើទោះជាអ្នកជឿនៅក្នុងលោកិយមិនត្រូវបានគេសម្លាប់ក៏ដោយ។ និយាយម្យ៉ាងទៀត គេជាសត្រូវរបស់លោកិយ ជាអ្នកដែលត្រូវរងទុក្ខនៅក្នុងលោកិយ ហើយជាអ្នកដែលយកឈ្នះលោកិយនេះផង។

ដូច្នេះសម្រាប់ពួកគេទទួលបានជីវិតដ៏នៅអស់កល្បជានិច្ចដោយការជឿលើដំណឹងល្អនៃព្រះគុណ នោះពួកគេមិនចាំបាច់សង្គ្រោះទេ (ខ 11) ជីវិតខាងសាច់ឈាមរបស់ពួកគេត្រូវស្លាប់ (រ៉ូម 8:10)។ ព្រះគ្រីស្ទបានប្រទានជីវិតអស់កល្បដល់ពួកគេ ហើយទ្រង់ការពារពួកគេ។ គឺថាជីវិតរបស់យើងមិនបានសង្គ្រោះខ្លួនយើងទេ ប៉ុន្តែយើងចុះចូល

(πεπίστευκα) វាចំពោះព្រះគ្រីស្ទ គឺជាចំណុចសំខាន់នៃជីវិតនៃសេចក្តីជំនឿរបស់យើង។ អ្នកជឿគួរលះបង់កាត់ចិត្តដែលពឹងលើខ្លួនឯង។ យើងមិនអាចទទួលបានសេចក្តីសង្គ្រោះតាមវិធីដែលដៃម្ខាងកាន់ខ្លួនឯង ប៉ុន្តែដៃម្ខាងទៀតកាន់ព្រះអម្ចាស់ទេ។ យើងគួរតែជារបស់ព្រះគ្រីស្ទ ដោយការចុះចូលខ្លួនយើងទៅកាន់ព្រះជាម្ចាស់ដោយផ្ទាល់។ យើងមិនគួរពឹងផ្អែកលើអ្នកដទៃទេ។ យើងមិនគួរពឹងផ្អែកលើពេត្រុសទេ។ ពេត្រុសក៏បានសង្គ្រោះដោយពឹងលើព្រះអម្ចាស់ ដែលខ្ញុំពឹងផ្អែកដែរ។ លោក លូធើ បាននិយាយថា៖ “ទុកឱ្យទ្រង់ដែលបានស្លាប់ដើម្បីព្រលឹងខ្ញុំ ចូរមើលទៅការសង្គ្រោះរបស់ចុះ។” ដូចដែលខ្ញុំបាននិយាយរួចហើយ អ្នកជឿមិនខ្លាចបាត់បង់សេចក្តីសង្គ្រោះរបស់គាត់ទេ ពីព្រោះអ្នកជឿបានលះបង់ជីវិតរបស់គាត់ទៅលើព្រះគ្រីស្ទរួចហើយ។

12 ដោយហេតុនោះ ឱស្ថានសួគ៌ និងពួកអ្នកដែលនៅស្ថាននោះអើយ ចូរអរសប្បាយឡើង! ទាំងនេះជាមនុស្សដែលជឿដល់ព្រះអម្ចាស់ ហើយត្រូវបានចាកចេញ ហើយបានចូលទៅក្នុងស្ថានសួគ៌។ **ផែនដី និងសមុទ្រ** ជាការត្រាស់ហៅជាសរុបទៅកាន់អ្នកដែលនៅរស់នៅលើផែនដី។ **ដោយវាដឹងថា ពេលវេលាខ្លីណាស់ហើយ**! ពេលដែលព្រះគ្រីស្ទយាងមកម្តងទៀតនៅពេលអនាគត នោះអារក្សនឹងត្រូវគ្រវាត់ទៅក្នុងបឹងភ្លើង។ ពីព្រោះវាបានដឹងវាសនាដ៏អាក្រក់របស់វា ក្នុងកាលដែលវាត្រូវបានបោះចេញមកលើផែនដីមក វានឹងទទួលរងយ៉ាងអាក្រក់។

13,14 ខគម្ពីរនេះពន្យល់នៅខ 6 ខាងលើម្តងទៀត។ សូមអានការពន្យល់បកស្រាយនោះ។

នោះមានស្លាបពីរដូចជាស្លាបនៃសត្វឥន្ទ្រី ហ្គ្រេចដានុស បាននិយាយនៅទីនេះថា “ស្លាបពីរ” ជាសេចក្តីជំនឿ និងក្រឹត្យវិន័យ ជាអំណាចរបស់អ្នកជឿ និងក្រុមជំនុំដែលចេញមកពីការដែលមានរបស់ទាំងពីរនេះ។ (De sterkte van geloovige en gemeente ligt in deze twee.) តែការបកស្រាយនេះមិនមែនជាការប៉ាន់ស្មានតែ

មួយនោះទេ។ “ស្លាបពីររបស់សត្វឥន្ទ្រី” ជានិមិត្តសញ្ញាដែលព្រះទ្រង់ចិញ្ចឹមរាស្ត្រ ដែលទ្រង់បានរើសតាំងជាមួយនឹងវិធីសាស្ត្រនៃការរងទុក្ខ។ (ចោទិយកថា 32:11-12, ទំនុកដំកើង 103:5, អេសាយ 40:31)។ នៅពេលសត្វឥន្ទ្រីបង្វឹកកូនៗរបស់វា វាទម្លាក់ពួកគេពីលើមកដើម្បីនឹងបង្រៀនឱ្យពួកគេហើរ កាលដែលពួកគេជួបនូវគ្រោះនៅពេលកំពុងធ្លាក់មកដី នោះម្តាយក៏មកទទួលពួកគេដោយស្លាប់របស់នាង នោះព្រះទ្រង់ក៏ប្រើវិធីសាស្ត្រដូចគ្នានោះដើម្បីនឹងបង្វឹកដល់រាស្ត្រដែលទ្រង់បានរើសតាំង (និក្ខមនំ 19:4)។

ទីរហោស្ថាន នេះជាពាក្យប្រៀបធៀបនៃលោកិយ (1) ដូចជាទីរហោស្ថានដែលឯកោពិភពលោកក៏ឯកោដែរ។ (សុភាសិត 21:19) (2) ដូចជាបញ្ហោសម្លៀកបំពាក់ អាហារ និងផ្ទះនៅទីរហោស្ថាន ពិភពលោកក៏ដូចគ្នាដែរ។ (ទំនុកតម្កើង 78:19) (3) លើកលែងការទាំងនោះ ស្ថានភាពទាំងអស់នៃពិភពលោកផ្តល់ឱ្យយើងនូវទុក្ខវេទនាថែមទៀត។ ការរងទុក្ខហាក់ដូចជាផ្តល់ទុក្ខដល់យើង វាពិតជាធ្វើឱ្យយើងចូលទៅជិតព្រះយ៉ាងត្រឹមត្រូវណាស់។ ក្មេងប្រុសម្នាក់បានបណ្តែតកប៉ាល់ក្មេងលេងនៅលើទឹកហើយលេង។ មួយសន្ទុះក្រោយមក កប៉ាល់មួយបានចូលកណ្តាលទន្លេ គាត់ខ្លាចបាត់បង់សំពៅ។ ពេលនោះ បុរសនោះបានបោះដុំថ្មយ៉ាងធំទៅខាងលើកប៉ាល់ ក្មេងប្រុសនោះស្រែកឡើងព្រោះគាត់ស្មានថាសំពៅនឹងខូច។ ប៉ុន្តែកប៉ាល់បានចេញពីទឹកដោយសាររលកដែលថ្មដែលធ្វើឱ្យវាចេញមកក្បែរដី ហើយក្មេងប្រុសក៏ចាប់បាន។ ដូចដែលយើងរងទុក្ខនៅក្នុងពិភពលោកដែល គឺវាធ្វើឱ្យយើងចូលទៅជិតព្រះយេហូវ៉ាកាន់តែជិតស្និទ្ធ។

មួយពេល ពីរពេល និងកន្លះពេល។ នេះគឺជាផ្នែកពាក់កណ្តាលនៃរយៈពេលមួយភាគចិតសិបសប្តាហ៍ចុងក្រោយ ពោលគឺរយៈពេលបីឆ្នាំកន្លះនៅក្នុងដានីយ៉ែល 9:24។ ចុះហេតុអ្វីបានជារយៈពេលបីឆ្នាំកន្លះនិយាយថាពេលមួយពេល ពីរពេល និងកន្លះពេលដូច្នេះ? វិធីសាស្ត្រនៃការបញ្ចេញមតិប្រភេទបែបនេះ រួមបញ្ចូលអត្ថន័យជានិមិត្តរូ

ប។ យោងទៅតាមលោកបណ្ឌិត យ៉ាំង (EJ Young) ថាវាចង្អុលបង្ហាញបីដំណាក់កាលនៃសកម្មភាពរបស់អ្នកធ្វើទុក្ខបៀតបៀន ពោលគឺវាបង្ហាញថាសកម្មភាពបៀតបៀនកាន់តែខ្លាំង ហើយនឹងត្រូវកាត់បន្ថយ។ “ពេលមួយ” គឺជារយៈពេលដែលត្រូវបញ្ចប់នៅក្នុងផែនការសម្ងាត់របស់ព្រះ “ពីរពេល” មានន័យថាការបន្តនៃពេលវេលា (“ពេលមួយ”)។ (Calvin) ដូចដែលអ្នកបៀតបៀនទទួលបានអំណាចមួយពេល ហើយក្នុងន័យថាវាត្រូវបានពង្រឹងបន្តិចម្តងៗ គេបាននិយាយថាជា “ពីរដង”។ ហើយ "ពាក់កណ្តាលពេល" គឺជានិមិត្តសញ្ញាដែលសកម្មភាពនៃការបៀតបៀននឹងត្រូវកាត់ផ្តាច់។ ព្រះបន្ទូលនៃព្រះយេហូវ៉ានៅក្នុងគ្រាទុក្ខវេទនាបង្ហាញការបកស្រាយបែបនេះ។ ព្រះយេស៊ូវបានមានបន្ទូលថា “” (ម៉ាថាយ 24:6-8) ហើយបន្ទាប់ទៀតទ្រង់មានបន្ទូលថា “តែដោយយល់ដល់ពួកអ្នកដែលត្រូវបានរើសតាំង នោះថ្ងៃនោះនឹងត្រូវបានកាត់នៅខ្លី” (ម៉ាថាយ 24:22) សូមអាន ម៉ាថាយ 24:6 ម៉ាកុស 13:7, លូកា 21:9។ ដូចជាព្រះយេស៊ូវទ្រង់មានបន្ទូលថា “ថ្ងៃនោះនឹងត្រូវកាត់ខ្លី” មានន័យថាទ្រង់កាត់បន្ថយថ្ងៃនៃទុក្ខវេទនា។ បន្ទាប់មកយើងមិនអាចនិយាយបានថានៅទីនេះពាក្យ "មួយពេល ពីរពេល និងកន្លះពេល" មិននិយាយរយៈពេលខ្លះទេ។ (1) យោងទៅតាមអ្នកប្រាជ្ញនៃគោលជំនឿរបស់កាល់វីនពេលវេលាគឺជាថ្ងៃនៃគម្ពីរសញ្ញាថ្មី មានន័យថា "42 ខែ" ឬរយៈពេល 1260 ថ្ងៃ" (11: 3) (2) យោងទៅតាមការបកស្រាយរបស់លោក ហ្វ្រូសថ៍ (Henry W. Frost) រយៈពេលបីឆ្នាំកន្លះចុងក្រោយនេះ ដែលក្រុមជំនុំគ្រីស្ទានសាសន៍យូដាត្រូវបានគេបៀតបៀន។ Matthew Twenty Four and the Revelation pp 219-224) ប៉ុន្តែ វាពិបាកក្នុងការទទួលយកការបកស្រាយនេះ។

15 រួចពស់វាព្រួសទឹកចេញពីមាត់វាដូចជាទន្លេ ទឹកទន្លេងហាក់បីដូចជានិមិត្តសញ្ញានៃសេចក្តីរងទុក្ខវេទនាជាច្រើន (អេសាយ 43:2)។ តែលោក ហ្គ្រេចដានុស បាននិយាយថា វាជាជីវិតខាងសាច់ឈាមដែលធ្វើឱ្យយើងចាកចេញពីព្រះគ្រីស្ទ ដែលនោះជា ការខ្វល់ខ្វាយ ការលោភលន់ ការផ្សេងទៀត ជីវិតខាងរូបសាច់មួយចំនួន (ម៉ាថាយ

13:22) (Openbaring p 263)។ ហើយការព្រួសនេះចង្អុលទៅកាន់កងទ័ពដែលធ្វើការឈ្លានពានមក។

16 ប៉ុន្តែផែនដីបានមកជួយស្ត្រី ហើយផែនដីក៏បើកមាត់លេបទឹកទន្លេដែលនាគបានចាក់ចេញពីមាត់របស់វាទៅ។ ចំណុចនេះដែលថា កលល្បិចអាក្រក់ទាំងអស់របស់សាតាំងនឹងត្រូវបរាជ័យ ដោយសារសកម្មភាពផ្តល់ជំនួយរបស់ព្រះ។ ជាឧទាហរណ៍ នៅពេលដែលសូលលះបង់ចិត្តតាមចាប់ដាវីឌ នោះដោយការលុកលុយរបស់យោធាប៉ាឡេស្ទីន ដាវីឌបានឱកាសរត់គេចទៅ។

